# ស្រី

# ហិតោបទេស

ភាគទី ១

## ការគប់មិត្ត

ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ
អ្នកប្រែចេញពីភាសាសំស្ក្រឹត

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស. ២៤៩៧

នារាយណបណ្ឌិត

# ស្រី

# ហិតោបទេស

ភាគទី ១

## ការគប់មិត្ត

ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ
ជា
អ្នកបកប្រែចេញពីភាសាសំស្ក្រឹត

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៤៩៧ គ.ស ១៩៥៤

ចារឹកឡើងវិញ៖ ណុល ដារ៉ា
២០០៩

# បញ្ជីរឿង


| | | |
|---|---|---|
| កថាមុខអ្នកប្រែ | | ក |
| អារម្ភកថា | | ៧ |
| ការគប់មិត្ត | (រឿងក្អែក អណ្តើក កណ្តុរ និងប្រើស) | ១៣ |
| ផ្តើមរឿង | (រឿងព្រាបចិត្រគ្រីព) | ១៤ |
| កថាទី ១ | រឿងអ្នកដំណើរ និងខ្លាចាស់ | ១៤ |
| កថាទី ២ | រឿងប្រើស ចចក និងក្អែក | ២៤ |
| កថាទី ៣ | រឿងត្មាត ឆ្មា និងបក្សី | ២៥ |
| កថាទី ៤ | រឿងកណ្តុរ**ហិរណ្យកៈ** | ៣៦ |
| កថាទី ៥ | រឿងពាណិជចាស់ជរា និងភរិយាក្រមុំ | ៣៧ |
| កថាទី ៦ | រឿងព្រាន ប្រើស ជ្រូក ពស់ និងចចក | ៤៦ |
| កថាទី ៧ | រឿងព្រះរាជា បុត្រពាណិជ និងភរិយា | ៥២ |
| កថាទី ៨ | រឿងចចក និងដំរីស្គ | ៥៤ |

# កថាមុខ

កាលខ្ញុំអានគតិលោករបស់លោកអ្នកឧកញ៉ាសុតន្តប្រីជា ឥន្ទ មុនដំបូង, ខ្ញុំឃើញមាននិទាន និងសុភាសិតជាកាព្យ មានរសជាតិផ្អែមល្ហែមចាប់ចិត្តចាប់ថ្លើម នាំឲ្យនឹកស្ងើចស្នាដៃលោក និងទឹកចិត្តលោកពេញដោយមេត្តាករុណាដ៏ធ្ងន់ជ្រាលជ្រៅ ។ ខ្ញុំយល់ថា លោកមិនមែនត្រឹមតែជាអ្នកកវីឯកប៉ុណ្ណោះទេ លោកជាអ្នកប្រាជ្ញ សីលធម៌ និងទស្សនវិជ្ជាផង ។ តមកមិនយូរប៉ុន្មាន ខ្ញុំបានអានហិតោបទេសបណ្ឌិតនារាយណៈទៀត ខ្ញុំឃើញសីលធម៌ និងអរិយធម៌ខ្ពង់ខ្ពស់វិសេសក្រៃលែងទៅទៀត ខ្ញុំគិតថា ធ្វើដូចម្ដេចហ្ន៎ នឹងមានលោកណាប្រែជាភាសាខ្មែរ ទុកជាសម្បត្តិទិព្វវិសេសសម្រាប់ជនជាតិខ្មែរ? តាំងពីកាលនោះច្រើនឆ្នាំ បញ្ចតន្ត្រៈជាប្រភពហិតោបទេស និងរឿងរ៉ាវទាំងឡាយក្នុងពិភពលោក ធ្លាក់មកលើដៃខ្ញុំទៀតដូចជាទេពតាប្រទាន ខ្ញុំអានហើយអានទៀត ជាប់ចិត្តស្អិតចំពោះអរិយធម៌នេះ មានបីតិបាមោជ្ជផ្អែតកាយ ផ្អែតចិត្ត ហាក់ដូចជាបានក្រេបផឹកទឹកអម្រឹត, ហើយសរសើរភ័ព្វសំណាងខ្ញុំដែលកើតមកក្នុងសម័យវិបត្តិអក្សរសាស្ត្រខ្មែរ បានជួបប្រទះកិច្ចការជាស្នាដៃសំខាន់បែបនេះ, ខ្ញុំនឹកដល់លោក ឃើត្លកវីជាតិអាល្លឺម៉ង់ដ៍ ដែលបានក្រេបរសជាតិកាព្យសកុន្តលា ជាបទល្ខោនកវីកលិទាសៈជាតិឥណ្ឌា មុនដំបូងលោកលុតជង្គង់ចុះដល់ដី លើកដៃសំពះប្រណម្យទៅលើ អរគុណចំពោះទេពតា ដែលបានទុកអាយុឲ្យលោករហូតដល់បានអានរឿងវិសេសនេះ ។ មិនតែប៉ុណ្ណោះទេ អក្សរសាស្ត្រសំស្ក្រឹតផ្នែកពុទ្ធសាសនាក្ដី ផ្នែកសាសនាព្រាហ្មណ៍ក្ដី ឬផ្នែកឯទៀតក្ដី សុទ្ធសឹងប្រកបដោយលម្អគួរស្ងើចជាទីបំផុត ។ រឿងនេះជាដើមហេតុនាំឲ្យខ្ញុំតាំងចិត្តមាំថា៖ “ដរាបណាខ្ញុំមិនទាន់អស់ជីវិតទេ ដរាបនោះ ខ្ញុំនឹងប្រែហិតោបទេស និងបញ្ចតន្ត្រៈភាសាសំស្ក្រឹតនេះមកជាភាសាខ្មែរ ទុកជាប្រយោជន៍ដល់ជនានុជនទាំងឡាយ តាមកម្លាំងដែលខ្ញុំអាចធ្វើបាន” ។

ការប្រែគម្ពីរដីកាក្បួនខ្នាតជាអរិយធម៌ឥណ្ឌាមកជាភាសាខ្មែរ ទុកថាជាការប្លែកក៏ពុំមែន ឬទុកថាជាការមិនប្លែក ក៏ពុំមែនដែរ ។ ព្រះបាទកៅណ្ឌិណ្យៈជាក្សត្រសម័យក្រុងភ្នំ (Fou-nan) ជាជាតិឥណ្ឌាបាននាំអរិយធម៌មកកាន់ប្រទេសកម្ពុជាមុនដំបូង រវាងខាងចុងសតវត្សរ៍ទី ២ នៃគ្រឹស្តសករាជ ។ ចាប់ពីសម័យនោះមក អរិយធម៌ឥណ្ឌា ហូរចូលមកកាន់ប្រទេសកម្ពុជាឥតអាក់ រហូតដល់បច្ចុប្បន្នកាលនេះ មានគោលគឺ សាសនាព្រាហ្មណ៍ មានគម្ពីរត្រៃវេទ គម្ពីឧបនិស័ទ គម្ពីរហិរវង្ស គម្ពីរបុរាណរឿងរាមកេរ្តិ៍ រឿងមហាភារតៈ និងពុទ្ធសាសនា មានគម្ពីរព្រះត្រៃបិដកជាដើម តែគម្ពីរដីកា និងទំនៀមទម្លាប់សាសនាព្រាហ្មណ៍អស់នោះ កប់បាត់នៅក្រោមប្រាសាទបុរាណទាំងឡាយស្ទើរតែអស់ហើយ នៅសល់តែពុទ្ធសាសនាដែលហូរចូលមកក្រោយគេ ។ អរិយធម៌អស់នេះ មិនមែនជាអាថ៌កំបាំងអ្វីសោះ

កាលបើយើងបើកភ្នែកក្រឡេកមើលទៅលើទំព័រប្រវត្តិសាស្ត្រសាកល ដែលអ្នកប្រាជ្ញទាំងឡាយបាន ចារឹកទុកមក ។ ដើម្បីបញ្ជាក់សេចក្តីពិតនេះ លោក ស៊ីល្វាំងឡេវី សរសេរថា៖(១) ប្រទេសឥណ្ឌាជាដើម មេគំនិតប្រាជ្ញា មេដើមរឿងនិទានផ្សេងៗ មេជំនឿសាសនា មេទស្សនវិជ្ជា មេច្បាប់ និងមេការរចនា ទ្វីបអាស៊ីអស់ភាគ ៣ ក្នុង៤" ។ លោក សឺដែស សរសេរថា៖(២) "អ្នកប្រាជ្ញប្រទេសឥណ្ឌាភ្លេចសូន្យ ឈឹង មិនដឹងជាវប្បធម៌ខ្លួនផ្សាយទៅកាន់ប្រទេសអាស៊ីភាគខាងកើត និងភាគអាគ្នេយ៍ រហូតមកដល់ កាលឥឡូវនេះអ្នកប្រាជ្ញឥណ្ឌាខ្លះចេះបារាំង និងចេះហុល្លង់ដ៏ ទៅស្វះស្វែងរកប្រភពប្រវត្តិអស់នេះចេញ ពីមហាវិទ្យាល័យក្រុងបារីស (Paris) និងឡីដ៍ (Leyde) ហើយពោលថា "មហាប្រទេសឥណ្ឌា" (Greater India) ។

ហិតោបទេសនេះប្រែថា ការប្រៀនប្រដៅប្រយោជន៍ ការពន្យល់ប្រយោជន៍, ការប្រាប់ ប្រយោជន៍ ឬការដឹកនាំជនានុជនឲ្យបានប្រយោជន៍នៅនាលោកិយនេះ ពុំនោះថា ពាក្យប្រៀនប្រដៅ សីលធម៌ដល់ជនានុជនទាំងឡាយ ពុំនោះសោតនឹងហៅថា ធម៌បំពេញមនុស្សភាពក៏សឹងបាន ជាគម្ពីរ ចាស់បុរាណ មានអាយុរាប់ពាន់ឆ្នាំ គេនិយមប្រែស្ទើរគ្រប់ភាសាក្នុងសាកលលោក ទោះជាអាស៊ី ឬអឺរ៉ុប គេទុកជាលោកនីតិ ឬគតិលោកមួយដ៏សំខាន់ ។ ហិតោបទេស ជាភាសាសំស្រ្កឹតនេះមានលម្អ៤ប្រការគឺ ១- សេចក្តីជ្រាលជ្រៅទន់ផ្អែម, ២- ប្រើពាក្យពេចន៍លែបខាយល្អស្រស់, ៣- ជើងកាព្យណែងណង, ៤- រឿងរ៉ាវទាក់ទងគ្នាដឹកដូចរឿង១០០១យប់ ។ បើនរណាបានអានហើយ នរជននោះ ជាប់ចិត្តនឹកស្ញើច ជញ្ជក់មាត់ចង់មើលចង់អាន និងនឹកទៅដល់អ្នកនិពន្ធដើម ស្ញើចសរសើរស្នាដៃ និងចិត្តប្រកបដោយមេត្តា ក្រាលទៅគ្របដណ្តប់សព្វសត្វទាំងឡាយ ។

លោក ល័ល្វ ល័ល្វ បណ្ឌិតឥណ្ឌាជាតិព្រាហ្មណ៍ សរសេរទុកថា "ហិតោបទេសនេះលោក នារាយណៈមហាបណ្ឌិតឥណ្ឌារៀបរៀងឡើងដកស្រង់ពីគម្ពីរដើមឈ្មោះបញ្ចតន្ត្រៈ និងគម្ពីរផ្សេងៗទៀត ដូចសេចក្តីដែលបណ្ឌិតនារាយណៈបានពោលទុកក្នុងអារម្ភបទលោកស្រាប់ ។ ផ្ទៃសេចក្តីហិតោបទេស នេះ បើតាមការសង្កេតមើល ឃើញមានទំនងស្របទៅខាងពុទ្ធសាសនា ដោយច្រើន ដូចសេចក្តីយល់ នៃលោក បេន-ហ្វៃ បណ្ឌិតអង់គ្លេសថា៖ "ហិតោបទេសនេះ គង់អាស្រ័យគោលពុទ្ធសាសនាផ្សំផង ដែរ" ។ តាមសេចក្តីគ្នេរគ្នាន់អ្នកប្រាជ្ញពង្សាវតារលោកសរសេរថា ហិតោបទេសភាសាសំស្រ្កឹត កើត ឡើងក្នុងរវាងសតវត្សរ៍ទី ១០ នៃពុទ្ធសករាជ (សតវត្សរ៍ទី ៥ គ.ស.) ហើយចម្លងតគ្នាទៅស្ទើរតែគ្រប់

---

[១] L'Inde civilisatrice: Page 136.

[២] Historire ancienne des Etats hindouiee d'Extreme Orienl, Introduction Page III.

ភាសាប្រទេសឥណ្ឌា មានភាសាបង្គ័ល មហរ័ត ជាដើម តែដែលសំខាន់ជាងគេនោះ គឺរបស់បណ្ឌិត ល័ល្លូល័ល្ល ជាភាសា ក្រ័ជកាខា ឈ្មោះរាជនីតិ ។ តពីប្រទេសឥណ្ឌាទៅទៀត គេប្រែជាភាសាបេហ្លី រវាងសតវត្សរ៍ទី ១០ នៃពុទ្ធសករាជ (សតវត្សរ៍ទី ៦ គ.ស), ពីភាសាបេហ្លី ជាភាសាអារ៉ាប់ រវាងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (សតវត្សរ៍ទី ៨ គ.ស), ប្រែពីអារ៉ាប់ទៅជាភាសាហិបរូ (ជ្វិហ្វ), ប្រែពីភាសាហិបរូទៅជាភាសាក្រិក ទៅជាភាសាធំៗក្នុងទ្វីបអឺរ៉ុបមានភាសាអាល្លឺម៉ង់ អង់គ្លេស និង បារាំង ជាដើម ។ ខ្ញុំសូមអភ័យទោសដោយខ្ញុំមិនបានលើកយកឈ្មោះអ្នកប្រែទាំងអស់មកចារឹកទុកក្នុង ទីនេះទេ យកតែគោលខ្លះ ល្មមឲ្យដឹងដំណើរសេចក្ដីដូចតទៅនេះ៖

ក្នុងសតវត្សរ៍ទី ២៣ នៃពុទ្ធសករាជ (សតវត្សរ៍ទី ១៧ គ.ស) បណ្ឌិតលទ្ធិឥស្លាមជាតិបារសី (បៀរស៍) ឈ្មោះតាជ ឯទខិន ភាសាបៀរស៍ឲ្យឈ្មោះថា មហ្វោរីហ៍ អល កូលូព ប្រែថា “គម្ពីរបញ្ជើត ចិត្តឲ្យរីករាយ” តែជាធម្មតាអ្នកកាន់សាសនាឥស្លាម កាលប្រែនោះគេបំប្លែងសេចក្ដីដើមជាលទ្ធិសាសន៍ ព្រាហ្មណ៍ ឲ្យមានទំនងទៅជាលទ្ធិឥស្លាមទាំងអស់ ។ ឯសេចក្ដីប្រែរបស់បណ្ឌិត តាជ ឯទខិត នេះត្រូវ បណ្ឌិតឥណ្ឌាឈ្មោះ មើរ ពហា ឌួរ-អាលី ហូសៃនី ប្រែត្រឡប់ជាភាសាឥណ្ឌូស្ថានីវិញ កាល ព.ស. ២៣៤៥ (គ.ស ១៨០២) បោះពុម្ពនៅក្រុងកល្កកត្តា ឲ្យឈ្មោះជាអក្លាត ឥ.ហិណ្ឌិ ប្រែថា សីលធម៌ ឥណ្ឌា ។ ឯសេចក្ដីប្រែជាភាសាទ្វីបអឺរ៉ុបមុនដំបូង ច្រើនមានសេចក្ដីឃ្លៀងឃ្លាតពីសៀវភៅដើមដោយ ច្រើន ព្រោះកាលនោះ ការចេះដឹងភាសាសំស្ក្រឹតនៅទ្វីបអឺរ៉ុបពុំទាន់មានបរិបូណ៌ ក្នុង ព.ស ២៣៥៧ (គ.ស ១៨៤៤) ទើបលោក ម៉ាក់ មុល្លើបណ្ឌិតអាល្លឺម៉ង់ដ៍ ប្រែបានត្រឹមត្រូវតាមសៀវភៅដើម ។ កាល ព.ស ២៣៩១ (គ.ស ១៨៤៩) លោក ហ្វ្រង្ស៊ីស ជនសុង បណ្ឌិតអង់គ្លេស ប្រែជាភាសាអង់គ្លេស ក្នុង ព.ស ២៣៩៤ (គ.ស ១៨៥១) លោក ដេម៉េត្រីយ៉ូស គាឡាណូស៍ ជាតិក្រិក នៅក្រុងអាថែន ប្រែជា ភាសាក្រិក, លោកនេះបានចូលទៅនៅប្រទេសឥណ្ឌាទាំងពីកាល ព.ស ២៣២៩ (គ.ស ១៧៨៦) ដល់ ព.ស ២៣៧៦ (គ.ស ១៨៣៣) ។ ក្នុងព.ស ២៣៩៨ (គ.ស ១៨៥៥) លោកអេឌូអារដ៍ ឡង់ស៊ឺរូ ប្រែជាភាសាបារាំងក្នុងបណ្ណាល័យ ឯលសេវិរីយែន ដឺ បស៊ានេត៍ (Bibliathequeelzevirienne de P.jannet) ។ ក្នុង ព.ស ២៥៦២ (គ.ស ១៩២១) លោកនាគប្រទីប បណ្ឌិត សៀម ប្រែជាភាសា សៀម ។ ដើម្បីឲ្យស្រួលទៅតាមទំនងភាសាខ្លួន ហិតោបទេសជាសំស្ក្រឹត បោះពុម្ពផ្សេងគ្នាក្ដី សេចក្ដី ប្រែគ្រប់ជាតិភាសាក្នុងសាកលលោកក្ដី តែងមានសេចក្ដីខ្វះខាតលើសលស់គ្នាខ្លះដោយអន្លើ ដោយការ បន្ថែមបន្ថយទៅតាមអត្តនោម័តិ ពុំនោះក្លាយទៅជាសុភាសិត ឬរឿងនិទានជាតិភាសានោះៗសុទ្ធសាធ ដូចកាព្យលោក ឡាហ្វុងតែន បណ្ឌិតបារាំងជាឧទាហរណ៍ សេចក្ដីពិត ហិតោបទេសនេះគឺបញ្ចតន្ត្រ:ត្រង់

តែម្តង ដោយគ្រាន់តែបំពេញមកនៅត្រឹមតែ ៤ ភាគគឺៈ មិត្តលាភ (ការគប់មិត្ត)១, សុហ្ឫទ្ភេទ (ការបំបែកមិត្ត)១, វិគ្រហៈ (សង្គ្រាម)១ និងសន្ធិ (សន្តិភាព១) ។ អែបញ្ចតន្ត្រៈមាន ៥ភាគ (បញ្ច = ប្រាំ, +តន្ត្រៈ = ច្បាប់) ច្បាប់ប្រាំប្រការ ។ ខ្ញុំប្រែជាភាសាខ្មែរនេះ ក្នុងមួយភាគបោះពុម្ពជាមួយសៀវភៅ រហូតដល់គ្រប់ទាំង ៤ភាគ ។

ហិតោបទេសដែលខ្ញុំប្រែនេះ ខ្ញុំប្រែត្រង់តាមច្បាប់ភាសាសំស្ក្រឹតនារាយណបណ្ឌិត ដែលលោក កាសីនាថ បាណ្ឌុរង្គ បរ័ព បោះពុម្ពលើកទី ១០ កែតម្រូវដោយលោក វាសុទេវ- លក្ស្មណៈសាស្ត្រី បាង្សិកការបោះពុម្ពផ្សាយដោយលោក បាណ្ឌុរង្គ ជាវជី ម្ចាស់រោងពុម្ព “និយមសាគ័រ” នៅក្រុងបុំបៃ គ.ស ១៩២១ ។ កាលប្រែ ខ្ញុំរកកលនឹងប្រែផ្ទិត មិនបានបន្ថែមសេចក្តីឲ្យឃ្លាតឆ្ងាយពីច្បាប់ដើមពេកទេ គ្រាន់តែសម្រួលទៅតាមទំនងភាសាខ្មែរប៉ុណ្ណោះ ព្រោះចង់រក្សារសជាតិលំនាំភាសាសំស្ក្រឹតឲ្យគង់នៅ តែទោះជាខំប្រិតប្រៀនយ៉ាងណា ខ្ញុំនៅតែមានភ័យក្នុងរឿងនេះមិនអស់មិនហើយ ព្រោះការប្រែភាសាមួយទៅភាសាមួយ តែងមានការឃ្លៀងឃ្លាតលម្អៀងសេចក្តីគ្នាជាធម្មតា ដែលជាទោសគេចពុំរួច ណាមួយវិជ្ជាអក្សរសាស្ត្រខ្មែររបស់ខ្ញុំនៅទន់ខ្សីពេក មិនអាចឈោងចាប់សំនួនវោហារពាក្យមួយមាត់ៗ នៃអក្សរសាស្ត្រសំស្ក្រឹត យកមកប្រែជាពាក្យខ្មែរឲ្យច្បាស់លាស់ដូចសេចក្តីដើមបាន ហើយជាការលំបាកលើសសមត្ថភាពរបស់ខ្ញុំផង ។ ដើម្បីជាគ្រឿងណែនាំឲ្យទូលាយគំនិត ខ្ញុំបានយក ហិតោបទេស ច្បាប់ប្រែជាភាសាសៀមរបស់លោក នាគប្រទីប រោងពុម្ព ហាងសមុទថៃ ខែតុលា ព.ស២៤៩៤ និងហិតោបទេស ច្បាប់ប្រែភាសាបារាំងរបស់លោក អេឌួអារដ៍ ឡង់សឺរ៉ូ រោងពុម្ពមេស៊ននីវ គ.ស ១៨៨២ ។ ខ្ញុំបានធ្វើន័យលក្ខណៈខ្លះប្រាប់សេចក្តីប្លែកគ្នាចំពោះសុភាសិតដែលមានប្រយោជន៍គួរឲ្យដឹង ហើយបំពេញនាមលោក អេឌួអារដ៍ ឡង់សឺរ៉ូ ថា “ឡង់សឺរ៉ូ” នាមលោកសេដ្ឋីរយកោសេស នាគប្រទីប ថា “នាគប្រទីប” សូម្បីខ្ញុំខំប្រឹងប្រែងកុំឲ្យមានការភ្លាំងភ្លាត់ ការប្រែនេះនៅតែមានការខុសឆ្គាំឆ្គងតក់សេចក្តី ឬទោសអ្វីមួយ ដែលហួសកម្លាំងសតិបញ្ញាសេចក្តីព្យាយាមខ្ញុំ ថាបើមានធម្មតាគង់អភ័យទោសឲ្យបច្ឆាជនជាអ្នកប្រាជ្ញភាសាសំស្ក្រឹតអនាគត និងជាភាជនៈ ទទួលត្រង់រងនូវកេរ្តិ៍មត៌ក គឺការភ្លាំងភ្លាត់ខុសរបស់ខ្ញុំក្នុងការប្រែច្បាប់នេះ ហើយនឹងកែសម្រួលឲ្យបានត្រឹមត្រូវល្អឡើង ទុកជាហិតានុហិតដល់បងប្អូនរួមជាតិតទៅ ។ សេចក្តីប្រែនេះ ខ្ញុំទុកជាទីរឮកការនៅចាំវស្សាអស់ត្រៃមាសក្នុងឆ្នាំឆ្លូវឯកស័ក ព.ស ២៤៩២ ។

ខ្ញុំមានអំណរយ៉ាងក្រៃលែង ចំពោះលោកគ្រូព្រះទេពសត្ថា សូរ ហាយ ក្រុមជំនុំព្រះត្រៃបិដក និងព្រះគ្រូមុនីសោភ័ណ សេខ នាង សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ដែលជួយឲ្យន័យក្នុងការប្រែ ។ ខ្ញុំសូមអរគុណលោកព្រះបាឡាត់ពោធិរាម ជា ឆាយ សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ដែលពេញចិត្ត

នឹងភាសាសំស្ក្រឹតដូចខ្ញុំដែរ ព្រមទាំងសហការីទាំងឡាយ ដែលបានយកព្រះទ័យទុកដាក់ជួយសរសេរ ជួយកែតម្រង់ជំនួសខ្លួនខ្ញុំ ។ សូមអរគុណលោក ជុំ ទូត ទីប្រឹក្សាព្រះរាជាណាចក្រ ដែលស្រឡាញ់ការនេះ ហើយបានអារាធនាសូមឲ្យប្រែបហិតោបទេសនេះយកទៅបោះពុម្ពផ្សាយដល់សាធារណជន ។

ខ្ញុំសូមឲ្យប្រជាជនខ្មែរបានប្រកបដោយសេចក្តីសុខចម្រើនគ្រប់ប្រការ!

វត្តឧណ្ណាលោម ថ្ងៃពុធ ៦ រោច ខែភទ្របទ ឆ្នាំឆ្លូវ ឯកសក ព.ស ២៤៩២

ត្រូវនឹងថ្ងៃទី ២៧ ខែកញ្ញា គ.ស ១៩៤៩

ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

# អារម្ភកថាលើកទី ២

ហិតោបទេសភាគទី ១ ឡើងកាន់ពុម្ពលើកដំបូងនៅក្នុងឆ្នាំឆ្លូវ ឯកសក ព.ស ២៤៩២ បណ្ណាគារឃីន ឆែ ជាអ្នកបោះពុម្ពផ្សាយ មកដល់ឥឡូវនេះ សៀវភៅនេះបាត់មុខពីបណ្ណាគារអស់ទៅហើយ ។ មានអ្នកត្រូវការមកសួររឿយៗ សម្តែងឲ្យឃើញថា មានអ្នកអានច្រើននាក់ត្រូវការណាស់ ។ ខ្ញុំឃើញដូច្នោះ មានសេចក្តីរីករាយសប្បាយចិត្តណាស់ដោយគិតឃើញថា ការព្យាយាមរបស់ខ្ញុំដែលខំប្រឹងប្រែងនោះ មិនឥតប្រយោជន៍ទេ បានផលសមតាមបំណងខ្ញុំហើយ ។ ឥឡូវនេះគួរចាត់ការបោះពុម្ពលើកទី ២ តទៅទៀត ដើម្បីបំពេញសេចក្តីត្រូវការអ្នកអានទាំងឡាយ ដែលមានសេចក្តីស្រេកឃ្លានចង់ចេះដឹង ទើបខ្ញុំប្រគល់ហិតោបទេសនេះទៅបណ្ណាគារគីម គី ឲ្យចាត់ការបោះពុម្ពលើកទី២នេះ តទៅ ។ ខ្ញុំបានកែតម្រឹមតម្រូវសេចក្តីខ្លះ ដែលភ្លាត់ផ្តាំផ្គងឲ្យបានល្អ ហើយបានអនុញ្ញាតឲ្យចាត់ការបោះពុម្ព ។

វត្តឧណ្ណាលោម ថ្ងៃសៅរ៍ទី ៥ រោច ខែពិសាខ ឆ្នាំមមី ឆស័ក ព.ស ២៥៩៧

ត្រូវនឹងថ្ងៃទី ២២ ខែឧសភា គ.ស ១៩៥៤

វីរិយបណ្ឌិតោ ប. ខាត់

# *ស្រី*

# *ហិតោបទេស*

## អារម្ភបទ

១- សូមសេចក្ដីប្រាថ្នារបស់ សាធុជនទាំងឡាយបានសម្រេចផល ដោយកិរិយាប្រសិទ្ធីនៃព្រះឥសូរ ដែលរស្មីភាគ១ ក្នុង ១៦ ស្ថិតនៅឰដ៏ព្រះនលាដ ដូចជាលេខា ([១]) នៃពពុះទឹកទន្លេគង្គា ។

២- ហិតោបទេសនេះ នរជនបានត្រងត្រាប់ស្ដាប់ហើយ នឹងប្រគល់ឲ្យនូវសេចក្ដីជំនាញក្នុងភាសាសំស្រ្កឹត នូវសេចក្ដីផ្ទៀវផ្ទាសក្នុងសម្ដីថ្មីមាត់ និងក្នុងនីតិវិជ្ជាទាំងឡាយដ៏វិចិត្រផ្សេងៗ ក្នុងទីទាំងពួង ។

៣- អ្នកប្រាជ្ញ កាលបើស្វែងរកវិជ្ជា និងទ្រព្យ គប្បីគិតថាដូចជាខ្លួនមិនចាស់ មិនស្លាប់, កាលបើស្វែងរកធម៌ គប្បីគិតថាខ្លួនត្រូវម្រឹត្យុចាប់ក្របួចសក់បោកសម្លាប់ឥឡូវនេះហើយ ។

៤- បណ្ដាទ្រព្យទាំងពួង, វិជ្ជា លោកពោលថាជាទ្រព្យដ៏ឧត្ដម ព្រោះវិជ្ជាចោរលួចយកមិនបានផង កាត់ថ្លៃមិនបានផង មិនចេះរេចរឹលទៅផង សព្វៗកាល ។

៥- វិជ្ជាយិតយោងជនដែលនៅថោកទាប ឲ្យបានចូលទៅជិតព្រះនរបតីដែលគេនៅជិតបានដោយកម្រ ឬអ្នកមានបុណ្យដ៏ក្រៃលែងជាងព្រះនរបតីទៅទៀត ដូចស្ទឹងដែលនៅក្នុងទីទាបតែងប្រមូលយកទឹកចូលទៅកាន់សមុទ្រ ។

៦- វិជ្ជា នាំឲ្យមានវិន័យ, វិន័យ នាំឲ្យបានសេចក្ដីថ្លៃថ្នូរ, សេចក្ដីថ្លៃថ្នូរ នាំឲ្យបានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិ នាំឲ្យបានធម៌ ធម៌ ដឹកនាំឲ្យបានសេចក្ដីសុខ ។

៧- សស្ត្រវិជ្ជា([២]) និងសាស្ត្រវិជ្ជា ([៣]) ទាំងពីរនេះ គួរប្រតិបត្តិសិក្សារៀនឲ្យចេះដឹងទាំងអស់ វិជ្ជាទី១ ខាងដើម (សស្ត្រវិជ្ជា) កើតចម្រើនឡើង ដើម្បីសើចលេងជាត្លុកកំប្លែង, វិជ្ជាទី២ ខាងចុង (សាស្ត្រវិជ្ជា) បុគ្គលគួរគោរពក្នុងកាលទាំងពួង ។

៨- រូបគំនូរដែលគេគូរទុកឰដ៏ភាជនៈថ្មី មិនឃ្លាតក្លាយទៅជាប្រការដទៃយ៉ាងណា នីតិវិជ្ជា

---

[១] - បន្ទាត់ គំនូស ឬត្រា គឺរស្មីភ្លឺផ្ទេកដូចបន្ទាត់ ឬត្រាផ្សាយចេញពីពពុះទឹក ។

[២] - វិជ្ជា កសាង ឬប្រើជាអាវុធសម្រាប់ប្រហារគ្នាទៅវិញទៅមក ។

[៣] - វិជ្ជា ការចេះដឹងក្បួនខ្នាត គម្ពីរ ដីកា ច្បាប់ សម្រាប់ប្រតិបត្តិឲ្យកើតសេចក្ដីសុខក្សេមក្សាន្ត ឬសេចក្ដីចម្រើនលាភ ។

ដែលគេបង្ហិកបង្ហាត់ដល់កូនក្មេងទាំងឡាយដោយថា ជាគ្រឿងប្រៀបផ្ទៀប ក៏ជាប់នៅយ៉ាងនោះ លោកពោលទុកក្នុងទីនេះគឺ៖

៩- ១. មិត្តភាព (ការគប់មិត្ត) ២. សុហ្ឫទ្ភេទ (ការបំបែកមិត្ត) ៣. វិគ្រហៈ (សង្គ្រាម) ៤. សន្ធិ (សន្តិភាព) ដែលដកស្រង់យកមកពីគម្ពីរបញ្ចតន្ត្រៈ និងគម្ពីរដទៃទៀតនោះ ខ្ញុំពោលទុកក្នុងទីនេះដូចសេចក្ដីតទៅ ។

ក្នុងអតីតកាល, មាននគរមួយឈ្មោះបាដលីបុត្រ ស្ថិតនៅក្បែរស្ទឹងគង្គា ។ ព្រះបាទសុទសិនៈ ទ្រង់ប្រកបដោយស្វាមីគុណគ្រប់ប្រការ ស្ដេចគ្រប់គ្រងនគរនោះ ។ សម័យមួយ, ទ្រង់បានធ្វើព្រះសណ្ដាប់ស្លោកពីរបទដែលអ្នកប្រាជ្ញបានពោលទុក មានសេចក្ដីដូចតទៅនេះ៖

១០- សាស្ត្រវិជ្ជា ជាគ្រឿងកាត់បង់នូវសេចក្ដីសង្ស័យជាអនេក ជាគ្រឿងបើកបង្ហាញនូវអាថ៌កំបាំង និងជាភ្នែកសម្រាប់មើលសព្វសារពើការណ៍ទាំងឡាយ, អ្នកណាមិនមានសាស្ត្រវិជ្ជា អ្នកនោះទុកដូចជាមនុស្សខ្វាក់ ។

១១- ភាពជាយុវជន១ ភាពជាអ្នកមានទ្រព្យច្រើន១ ភាពជាអ្នកមានអធិបតេយ្យ១ និងភាពជាអ្នកមិនបែកបាក់គ្នា១ បើមានតែមួយៗ ក៏នាំឲ្យខូចប្រយោជន៍, ធ្វើដូចម្ដេចហ្ន៎ឲ្យបានគ្រប់ទាំង៤ ប្រការក្នុងខ្លួនមនុស្ស?

កាលព្រះរាជាអង្គនោះទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ក៏ទ្រង់ព្រួយតានតឹងព្រះរាជហឫទ័យចំពោះព្រះរាជបុត្ររបស់ព្រះអង្គ ដែលមិនទាន់បានសិក្សាសាស្ត្រវិជ្ជាទាំងឡាយ ព្រមទាំងប្រព្រឹត្តក្នុងផ្លូវខុសគន្លងធម៌ដោយសេចក្ដីប្រមាថ ទើបទ្រង់ព្រះតម្រិះក្នុងព្រះរាជហឫទ័យដូច្នេះថា៖

១២- មានប្រយោជន៍អ្វី ចំពោះកូនដែលកើតហើយល្ងង់ផង មិនប្រកបដោយធម៌ផង? ដូចភ្នែកឈឺ មានប្រយោជន៍អ្វី? បានគ្រាន់តែឈឺចាក់ដោតនាំឲ្យរំខានប៉ុណ្ណោះ ។

១៣- បណ្ដាកូន៣ ពួក គឺកូនមិនទាន់កើត១ ពួក កូនកើតហើយស្លាប់ទៅវិញ១ ពួក និងកូនល្ងង់១ ពួក កូនពីរពួកខាងដើមជាកូនគាប់ប្រសើរ, ពួកកូនទីបី មិនប្រសើរឡើយ ព្រោះថា កូនពីរពួកខាងដើមធ្វើទុក្ខព្រួយតែម្ដងក៏អស់ហើយទៅ ឯពួកកូនទីបីធ្វើទុក្ខមាតាបិតាឲ្យលំបាកគ្រប់ជំហានជើង ។

១៤- អ្នកណាកើតហើយដឹកនាំត្រកូលឲ្យចម្រើនខ្ពង់ខ្ពស់ឡើង អ្នកនោះទើបឈ្មោះថា "កើត" មែនទែន ឬពេញជាកើតត្រឹមត្រូវ ព្រោះក្នុងសំសារវដ្ដដែលប្រព្រឹត្តទៅនេះ អ្នកណាមួយដែលស្លាប់ទៅហើយមិនត្រឡប់កើតវិញទៀត?

១៥- ក្នុងពេលប្រារព្ធនឹងរើសរកឈ្មោះ នៃពួកអ្នកមានគុណ ចុះក្នុងបញ្ជី ឬផែនថ្ម ឈ្មោះអ្នក

ណាឥតគុណ មិនញុំាងចិត្តគេឲ្យរំភើបព្រឺព្រួចទេ គេមិនចារឹកឈ្មោះអ្នកនោះឡើយ បើដូច្នោះ តើគួរនឹងហៅម្ដាយដែលបង្កើតកូននោះ ថាជាស្ដ្រីអា ឬស្ដ្រីអ្វីហ្ន៎?

១៦- អ្នកណាមិនតម្កល់ខ្លួនក្នុងការឲ្យទាន, ក្នុងតបធម៌ គឺសុច្ចរិត, ក្នុងសេចក្ដីអង់អាចក្លាហាន, ក្នុងវិទ្យាសាស្ដ្រ និងការស្វែងរកទ្រព្យ អ្នកនោះលោកទុកជាឧច្ចារៈនៃមាតា ។

១៧- កូនមានគុណគាប់តែម្នាក់ជាកូនប្រសើរ កូនល្ងង់រាប់រយមិនប្រសើរទេ ដូចព្រះចន្ទ្រតែមួយដួង អាចកម្ចាត់ងងឹតអន្ធការបាន កងតារាទាំងឡាយកម្ចាត់ងងឹតមិនបានទេ ។

១៨- តបៈ គឺការបំពេញកុសល ដែលបុគ្គលណាមួយធ្វើក្នុងទីស័ក្ដិសិទ្ធិ ពុំនោះបំពេញទុក្ករកម្ម ដ៏ក្រៃលែងឯណាមួយ ព្រោះប្រាថ្នាកូន កូននៃអ្នកនោះ គួរជាកូនប្រដៅងាយ សមប្ញទ្ធិ សម្រេចប្រយោជន៍ ប្រកបដោយធម៌ និងមានប្រាជ្ញាបរិបូណ៌ ។

១៩- កិរិយាបានទ្រព្យ១ ភាពជាបុគ្គលមិនមានរោគជានិច្ច១ ភរិយាជាទីស្រឡាញ់១ ភរិយាពោលពាក្យពីរោះ១ កូនប្រដៅងាយ១ និងមានវិជ្ជាធ្វើប្រយោជន៍ដល់សាធារណជន១, បពិត្រព្រះរាជា! ធម៌៦ ប្រការនេះ ជាបរមសុខក្នុងជីវលោកនេះ ។

២០- គួរនឹងរាប់អ្នកមានកូនច្រើនថា គាប់ប្រសើរឬទេ? បើកូនទាំងឡាយនោះទុកដូចជានាឡិទទេក្នុងជង្រុក, កូនតែម្នាក់ជាទីពឹងផ្អែកទំនុកបម្រុងត្រកូលល្អជាជាង កេរ្ដិ៍ឈ្មោះបិតាក៏ល្បីល្បាញឮខ្ចរខ្ចាយទៅគ្រប់ទិសានុទិស ។

២១- បិតាធ្វើបំណុលទុកឲ្យកូនជាសត្រូវ, មាតាប្រព្រឹត្តទុច្ចរិតខុសគន្លងប្រពៃណីជាសត្រូវ, ភរិយាមានរូបល្អ ជាសត្រូវ, កូនល្ងង់ក៏ជាសត្រូវ ។

២២- វិជ្ជា បើមិនយកទៅប្រើប្រាស់ ជាពិសពុល, ភោជន ដែលបរិភោគទៅហើយមិនរលួយជាពិសពុល សភា(១) ជាពិសពុលសម្រាប់អ្នកក្រីក្រ, ស្ដ្រីក្រមុំជាពិសពុល សម្រាប់មនុស្សចាស់ជរា ។

២៣- នរជន សូម្បីកើតចេញពីត្រកូលណាក៏ដោយ តែមានគុណគាប់ប្រសើរហើយ លោកក៏គួរគោរពបូជា, ធ្នូសូម្បីបរិសុទ្ធដោយវង្ស (២) តែមិនប្រសិទ្ធី នឹងធ្វើអ្វីកើត?

២៤- ឱកូនតូចកម្សត់អើយ! អ្នកមិនទាន់បានរៀនសូត្រសោះ រាត្រីទាំងឡាយចេះតែប្រព្រឹត្តកន្លងទៅៗ បើដូច្នោះ ខ្លួនអ្នកនឹងកប់បាត់នៅកណ្ដាលហ្វូងអ្នកប្រាជ្ញទាំងឡាយ ដូចគោលង់ទ្រនេសជាប់ក្នុង

---

១ ទីប្រជុំ រោងមហោស្រព ឬទីថានឥស្សរជន ។

២ វំស ប្រែថា ឫស្សី រន្ទូត រត ខ្លុយ ឆ្អឹងខ្នង ខ្សែស្រឡាយវង្សជាតិ ។ ទីនេះមានសេចក្ដីផ្សេងគ្នា គឺធ្នូឫស្សីនេះ គេមិនប្រសិទ្ធីក៏មិនពូកែ, ធ្នូមានវង្ស ដូចជាធ្នូព្រះឥសូរ ព្រះរាមជាដើម បើមិនបានប្រសិទ្ធីក៏មិនពូកែ ។

កណ្តាលបឹងភក់ ។

កាលបើដូច្នេះ ធ្វើដូចម្តេចឲ្យកូនអាត្មាអញត្រឡប់បានជាបុគ្គលមានគុណគាប់ប្រសើរឡើង ក្នុងកាលឥឡូវនេះ?

២៥- បរិភោគអាហារ១ ការដេក១ ភ័យ១ និងសេពមេថុន១ ធម៌ទាំង៤ប្រការនេះ មនុស្ស និងសត្វមានស្មើគ្នា, មានតែព្រះធម៌ប៉ុណ្ណោះទេ ទើបអាចធ្វើមនុស្ស និងសត្វឲ្យវិសេសប្លែកពីគ្នា នរណាប្រាសចាកធម៌ អ្នកនោះទុកស្មើសត្វ ។

២៦- ធម៌ (ព្រះវេទ), អាថ៌ធម៌ (សេចក្តីអធិប្បាយព្រះវេទ) កាម (សេចក្តីប្រាថ្នាធម៌ និងអាថ៌ធម៌) និងមោក្ស:ធម៌ ទាំង៤ប្រការនេះ អ្នកណាមិនមានក្នុងខ្លួន សូម្បីតែមួយប្រការ ជីវិតអ្នកនោះឥតប្រយោជន៍សោះសូន្យទទេ ដូចបូកពពែ[១] រកប្រយោជន៍គ្មាន ។

២៧- អាយុ១ កម្ម១ ទ្រព្យ១ វិជ្ជា១ និងសេចក្តីស្លាប់១ ធម៌៥ប្រការនេះកើតសម្រេចមកជាមួយរាងកាយមនុស្សតាំងពីស្ថិតនៅក្នុងគភ៌ម្ល៉េះ ។

២៨- ភារធម៌ នៃបុគ្គលមានភារធម៌ តែងកើតមានដល់ភារ: នៃបុគ្គលជាធំដោយពិត, ភារ: អាក្រាត តែងមានដល់ព្រះឥសូរ កិរិយាដេកលើពស់ធំ[២] តែងមានដល់ព្រះហរិ[៣] ។

២៩- របស់ណាមិនមានបច្ច័យ របស់នោះក៏តែងមិនមាន, ថាបើរបស់ណាមានបច្ច័យ របស់នោះក៏មិនមែនជាមិនមាន, ថ្នាំនេះរម្ងាប់នូវពិសពុល គឺសេចក្តីគិតបាន ហេតុដូចម្តេចក៏គេមិនផឹកថ្នាំនេះហ្ន៎? ។

តែភាសិតនេះប្រើជាសម្តីមនុស្សខ្ជិលពួកខ្លះ ក្នុងចំណោមមនុស្សមិនចេះអត់ធន់ដល់ការងារទាំងឡាយ ។

៣០- បុគ្គល សូម្បីគិតឃើញព្រេងវាសនា ក៏មិនគួរលះបង់សេចក្តីព្យាយាមខ្លួនចោលឡើយ, បើបុគ្គលមិនព្យាយាមចម្រាញ់ល្ង មិនបានប្រេងល្ងទេ ។

៣១- ជោគលាភ តែងចូលទៅរកបុរសសីហ: ដែលជាអ្នកមានព្យាយាមក្លៀវក្លា, មានតែបុរសគម្រក់ទេ តែងពោលថា "ស្រេចតែព្រេងសំណាង!" បុគ្គលចូរផ្ចាញ់វាសនា ហើយធ្វើនូវព្យាយាមឲ្យពេញជាកូនប្រុស តាមកម្លាំងខ្លួនដែលអាចធ្វើបាន ថាបើតាំងព្យាយាមប្រឹងប្រែងធ្វើហើយ នៅតែមិនសម្រេចទៀត តើវានឹងកើតទោសអ្វី? ។

---

[១] នៅប្រទេសឥណ្ឌាខាងបេង្កាល់មានពពែមួយពួកគេហៅថា គលស្តនី ប្រែថា ពពែមានដោះនៅក ។

[២] យានព្រះនារាយណ៍ ឈ្មោះមហាអហិ ។

[៣] នាមព្រះនារាយណ៍ ។

៣២- រថមិនគប្បីទៅបានដោយកង់តែមួយយ៉ាងណា, ព្រេងវាសនាបើវៀរចាកព្យាយាមនៃបុរស ហើយ ក៏មិនសម្រេចយ៉ាងនោះដែរ ។

៣៣- កម្ម ដែលបុគ្គលធ្វើអំពីបុព្វជាតិ លោកហៅថា "ព្រេងវាសនា" ព្រោះហេតុនោះ បុគ្គល មិនខ្ជិលច្រអូស គប្បីធ្វើសេចក្តីប្រឹងប្រែងដោយព្យាយាមពេញជាបុរស ។

៣៤- ជាងប៉ាន់ ប៉ាន់ដុំដីជារូបផ្សេងៗ តាមចិត្តខ្លួនប៉ាន់ យ៉ាងណាកម្មដែលបុគ្គលសាងទុកខ្លួនឯង ក៏ប៉ាន់មនុស្សមានភាវៈផ្សេងៗ តាមលក្ខណៈនៃកម្មរបស់ខ្លួនយ៉ាងនោះដែរ ។

៣៥- បុគ្គល សូម្បីឃើញកំណប់ទ្រព្យនៅក្នុងទីចំពោះមុខ ដូចរឿងក្អែក ដោយមិនទឹកនាថា នឹង កើតមានបាន ហើយចាំព្រេងវាសនាគាស់កកាយយកមកឲ្យឯងៗ មិនរវល់ធ្វើសេចក្តីព្យាយាមពេញជា ប្រុស មិនបានកំណប់នោះទេ ។

៣៦- ការទាំងឡាយ តែងសម្រេចដោយសេចក្តីព្យាយាមប្រឹងប្រែងដោយពិត មិនមែនដោយ មនោរថទេ ដូចម្រឹគទាំងឡាយមិនដែលបោលចូលមាត់សីហៈដេកលក់ឡើយ ។

៣៧- កូនក្មេង ដែលមាតាបិតាបានហ្វឹកហ្វឺនហើយ ទៅជាកូនមានគុណគាប់ប្រសើរបាន មិន ដែលមានកូនក្មេងណាបានទៅជាបណ្ឌិត ដោយគ្រាន់តែច្បុតចេញពីគភ៌មាតាទេ ។

៣៨- កូនក្មេង ដែលមាតាបិតាណាមិនបានឲ្យរៀនសូត្រ មាតានោះត្រឡប់ជាសត្រូវ បិតានោះ ត្រឡប់ជាបុគ្គលមានពៀរ ព្រោះកូនមិនបានរុងរឿងក្នុងទីប្រជុំជន ដូចកុកកណ្តាលហ្វូងហង្ស ។

៣៩- ក្មេងបរិបូណ៌ដោយរូប និងវ័យ ក្មេងសម្ភពក្នុងត្រកូលដ៏វិសេសឥតចេះដឹងវិជ្ជាអ្វី មិនមាន រាសីរុងរឿងទេ ដូចផ្កាចារឥតមានក្លិនក្រអូប ។

៤០- មនុស្សល្ងង់ ប្រដាប់កាយដោយគ្រឿងអម្ពរ តែងមានរាសីរុងរឿងក្នុងទីប្រជុំជន បើមនុស្ស ល្ងង់នោះ មិនទាន់ហារមាត់ចេញនិយាយដរាបណា ក៏នៅតែមានរាសីរុងរឿងដរាបនោះ ។

កាលព្រះរាជាទ្រង់រំពឹងដូច្នោះ ទ្រង់ត្រាស់បង្គាប់ឲ្យប្រជុំអ្នកប្រាជ្ញទាំងឡាយ ទើបទ្រង់ ត្រាស់ថា៖ "នៃលោកបណ្ឌិតទាំងឡាយ សូមលោកស្តាប់ខ្ញុំ បណ្តាលោកបណ្ឌិតទាំងឡាយនេះ មានលោក ណាខ្លះ ជាអ្នកប្រាជ្ញអាចបង្រៀននីតិសាស្ត្រដល់កូនខ្ញុំ ដែលល្ងង់ខ្លៅ ប្រព្រឹត្តខុសគន្លងធម៌ជានិច្ច ឲ្យមាន កំណើតថ្មី ឲ្យត្រឡប់បានល្អឡើង ក្នុងកាលឥឡូវនេះបានឬទេ?", ព្រោះថា៖

៤១- កញ្ចក់នៅរួមជាមួយនឹងមាស អាចចោលស្រមោលក្លាយទៅជាកែវមរកតយ៉ាងណា, មនុស្សល្ងង់ នៅរួមជាមួយនឹងលោកសប្បុរស ក៏អាចត្រឡប់ទៅជាសប្បុរសឆ្លៀវឆ្លាតបានយ៉ាងនោះ ដែរ ។

៤២- កូនអើយ! មតិថោកទាប ព្រោះសមាគមមួយអន្លើដោយបុគ្គលថោកទាប សមាគមមួយអន្លើដោយបុគ្គលស្មើគ្នា មតិក៏ស្មើគ្នា, សមាគមមួយអន្លើដោយបុគ្គលប្រសើរ មតិក៏រឹងរឹតតែប្រសើរឡើង ។

សម័យនោះ, មហាបណ្ឌិតម្នាក់ឈ្មោះ **វិស្ណុស័ម័ន** មានការចេះដឹងសាកលនីតិសាស្ត្រពិតប្រាកដដូចជាព្រះព្រឹហស្បតិ៍ ក្រាបទូលថា៖ “បពិត្រព្រះសម្មតិទេវាវង្ស! ព្រះរាជបុត្រទាំងឡាយនេះ ទ្រង់សម្ភពក្នុងមហាត្រកូល ទូលព្រះបង្គំអាចបង្រៀននីតិសាស្ត្រទាំងឡាយ តាមព្រះរាជបំណងបាន, ព្រោះថា៖

៤៣- កិច្ចការអ្វីមួយដែលប្រកបដោយអំពើឥតប្រយោជន៍ ក៏រមែងមិនបានផលសមតាមប្រាថ្នាទេ ដូចជាប្រើពេលវេលាព្យាយាមបង្រៀនសត្វកុកឲ្យចេះនិយាយដូចសត្វសេក សូម្បីច្រើនរយដង នឹងបានផលក៏ឥតអង្គឹមានឡើយ ។

៤៤- តែក្នុងមហាត្រកូលបែបនេះ អ្នកគ្មានបុណ្យមិនមកកើតទេ ប្រៀបដូចអណ្តូងរ៉ែកើតត្បូងទទឹម ធ្វើដូចម្តេចនឹងកើតមានកញ្ចក់? ។

ហេតុនេះ, ខ្ញុំព្រះអង្គសូមទទួលយកព្រះរាជទានអាសាបង្រៀនព្រះរាជកុមារទាំងឡាយនេះ ត្រឹមតែឆមាសប៉ុណ្ណោះ ឲ្យមានការចេះដឹងនីតិសាស្ត្រស្ទាត់ជំនាញ” ។

ព្រះរាជា ទើបទ្រង់ត្រាស់តបដោយសុភាពថា៖

៤៥- ដង្កូវឡើងទៅទំនៅលើក្បាលសាធុជនទាំងឡាយ ព្រោះនៅលាយឡំជាមួយកម្រងផ្កា, ដុំថ្មដែលអ្នកធំលើកតម្កើងហើយ ក៏ក្លាយទៅជាភាពទេវតាពូកែស័ក្តិសិទ្ធិ ។

៤៦- របស់ទ្រព្យដែលនៅលើកំពូលភ្នំខាងឧទយាទិត្យ តែងបានទទួលពន្លឺស្វាងរុងរឿង ព្រោះនៅជិតព្រះអាទិត្យយ៉ាងណា, ជនហីនជាតិវណ្ណៈថោក តែងបានទទួលការចេះដឹងជាពន្លឺ ព្រោះនៅជិតលោកអ្នកសប្បុរសយ៉ាងនោះដែរ ។

៤៧- អ្នកមានគុណគាប់ តែងដឹងល្អ និងអាក្រក់, អ្នកមានគុណគាប់នោះ បើទៅសេពគប់មនុស្សអាក្រក់ ក៏ត្រឡប់ទៅជាអាក្រក់វិញ ដូចស្ទឹងមានទឹកដ៏ហើយដោយរសជាតិល្អ លុះហូរចូលដល់សមុទ្រហើយក៏ក្លាយទៅជាមានរសប្រៃផឹកមិនបាន ។

ព្រោះហេតុនោះ, ខ្ញុំសូមប្រគល់អំណាចដល់លោកជាអ្នកបង្រៀននីតិសាស្ត្រដល់កូនខ្ញុំ, ទ្រង់ត្រាស់ហើយ ទើបប្រគល់ព្រះរាជឱរសដល់បណ្ឌិត**វិស្ណុស័ម័ន** ដោយសេចក្តីគោរពក្រៃលែង ។

អារម្ភបទ ចប់ប៉ុណ្ណោះ

# ១- ការគប់មិត្ត

កាលនោះ, មហាបណ្ឌិត**វិស្ណុស័ម៌ន**ក្រាបបង្គំទូលព្រះរាជបុត្រទាំងឡាយ ដែលប្រថាប់នៅក្នុងទីចំពោះមុខ ដោយសេចក្ដីសុខសម្រាន្តលើផ្ទៃនៃប្រាសាទ ដោយស្លោកដូច្នេះថា៖

១- អ្នកប្រាជ្ញតែងប្រើកាលវេលាឲ្យប្រព្រឹត្តទៅ ដោយការកំសាន្តកាព្យសាស្ត្រ, មនុស្សល្ងង់តែងប្រើកាលវេលាឲ្យប្រព្រឹត្តទៅ ដោយការប្រព្រឹត្តសេចក្ដីវិនាស ដោយការដេក និងដោយការឈ្លោះទាស់ទែង ។

ព្រោះហេតុនោះ ទូលព្រះបង្គំនឹងពោលកថាដ៏វិចិត្រមានរឿងក្អែក និងអណ្ដើកជាដើមចម ទុកជាព្រះសណ្ដាប់ ដើម្បីកំសាន្តព្រះហឫទ័យនៃទ្រង់ទាំងឡាយ ។ ព្រះរាជបុត្រទាំងឡាយត្រាស់បតថា៖ “បពិត្រលោកអាយ៌ះ! សូមលោកមេត្តារាយរឿងនោះៗ ឲ្យទានស្ដាប់” ។ បណ្ឌិត**វិស្ណុស័ម៌ន** ពោលពាក្យដាស់តឿនថា៖ “បើដូច្នោះ, សូមទ្រង់តាំងព្រះទ័យស្ដាប់ចុះ ការគប់មិត្តនេះនឹងផ្ដើមពោលឥឡូវនេះ ដូចមានស្លោកទុកជាខាងដើមថា៖

២- អ្នកប្រាជ្ញមានចិត្តល្អ សូម្បីខ្សត់ទ្រព្យហើយឥតកម្លាំង ក៏អាចជួយកែខៃឲ្យសម្រេចប្រយោជន៍បានដោយរួសរាន់ ដូចរឿងក្អែក អណ្ដើក និងកណ្ដុរ ។

ព្រះរាជបុត្រទាំងឡាយត្រាស់សួរថា៖ “រឿងនោះតើដូចម្ដេច?” ។ បណ្ឌិត**វិស្ណុស័ម៌ន**ក្រាបបង្គំទូលថា៖

## រឿងក្អែក អណ្ដើក និងកណ្ដុរ

- នៅលើត្រើយស្ទឹងគោទាវរី មានជ្រៃមួយដើមធំត្រសុំសាខាមែកត្រឈឹងត្រឈៃ ពួកហ្វូងបក្សីផ្សេងៗ លុះដល់វេលាទន់ទាបព្រះសុរិយាល្ងាចថ្ងៃហើយ តែងបបួលគ្នាហើរមកពីទិសានុទិស ច្រៀវច្រៃចូលមកជ្រកអាស្រ័យព្ឋដ៏ដើមជ្រៃនោះ ។ សម័យមួយ, វេលាព្រឹកព្រាងស្វាងឡើង ជិតអស់ខែនៃរាត្រីកាលហើយ ព្រះចន្ទ្រជាទីគោរពជានាយកនៃកងកោមុទជាតិ លិចបាត់វង់រស្មី កំពូលភ្នំអស្ដង្គត, មានក្អែកមួយឈ្មោះ ***លឃុបតនក:*** ភ្ញាក់ឡើងពីពន់ព្រលឹមក្រឡេកមើលទៅឃើញព្រានម្នាក់មកដល់ ប្រៀបដូចជាឃើញព្រះយមរាជទី២ លុះឃើញហើយក៏រំពឹងគិតថា “ថ្ងៃនេះ, ឃើញឧបទ្រព្យចង្រៃកើតឡើងតាំងពីព្រលឹមតែម្ដង អាត្មាអញមិនគប្បីដឹងបានថា ឧបទ្រព្យចង្រៃនេះ នឹងកើតប្រាកដឡើងបែបណា! រំពឹងគិតហើយ រន្ធត់តក់ស្លុតក្នុងចិត្តឥតឧបមា ក៏ហើរឆ្ពោះទៅតាមមើលស្នាមព្រាននោះចរទៅ, ព្រោះថា៖

៣- មនុស្សល្ងង់ តែងជួបប្រទះ ប៉ះទង្គិច ហេតុដែលនាំឲ្យកើតសេចក្ដីសោកមួយពាន់ដង ឬ

ហេតុដែលនាំឲ្យកើតភ័យមួយរយដង ក្នុងមួយថ្ងៃៗ តែអ្នកប្រាជ្ញជួបប្រទះប៉ះទង្គិចហេតុដូច្នេះឥតអង្គឹមានឡើយ ។ នរជននៅក្នុងលោកនេះ គួរធ្វើមនសិការៈ ក្នុងចិត្តដូច្នេះរាល់ថ្ងៃកុំខាន ។

៤- ការភ្ញាក់ក្រោកឡើងពីព្រលឹម នរជន គប្បីដាស់សតិ រឭករាល់ថ្ងៃថា "មហាភ័យទាំងឡាយជិតមកដល់ហើយ បណ្ដាមហាភ័យទាំងឡាយនោះ ការឈឺចាប់ សេចក្ដីស្លាប់ និងសេចក្ដីទុក្ខសោករោគភ័យ ឬអន្តរាយអ្វីមួយ មុខជាធ្លាក់មកដល់អាត្មាអញក្នុងថ្ងៃនេះ" ។

កាលនោះ, ព្រានបក្សីនោះខ្មីឃ្មាត ព្រោះគ្រាប់ស្រូវ ហើយត្រដាងលប់ លុះចាត់ចែងរួចសព្វគ្រប់ហើយ ក៏ពួនសំងំអាត្មាក្នុងទីមួយ ។ ក្នុងកាលនោះឯង, ស្ដេចព្រាប**ចិត្រគ្រីព** ហើរចរមកពីចម្ងាយ ព្រមមួយអន្លើដោយព្រាបជាបរិវារ ឈរាលើអាកាសវេហាស៍ ឃើញគ្រាប់ស្រូវរាត់រាយខ្ចាត់ខ្ចាយដូច្នោះ ក៏ពោលរំឭកព្រាបជាបរិវារដែលល្មោភចង់ចុះទៅស៊ីគ្រាប់ស្រូវនោះថា៖ "ហេតុអ្វីក៏មានគ្រាប់ស្រូវនៅក្នុងដងព្រៃជ្រៅ នីរជនលន្លង់លន្លោចឆ្ងាយពីទីឋានមនុស្សដូច្នេះហ្ន៎? ដំណើរនេះគួរពិចារណាមើលសិន យើងឃើញរបស់នេះ នឹងទុកជាលាភចម្រើន ក៏ឥតអង្គឹមាន, ព្រោះការល្មោភស៊ីគ្រាប់ស្រូវនេះ នឹងត្រឡប់ឲ្យវិនាសអន្តរាយ ក្ដៅក្រហាយ ស្ដាយក្រោយដល់យើងគ្រប់គ្នាក៏សឹងថាបាន ។

៥- ព្រោះលោភចង់បានកងមាស, អ្នកដំណើរម្នាក់ធ្លាក់ផុងជាប់ក្នុងបឹងភក់ជ្រៅឡើងមិនរួច ត្រូវខ្លាចាស់សង្គ្រប់ចាប់ហែកស៊ីស្លាប់ទៅ" ។

ព្រាបជាបរិវារសួរឡើងថា៖ "រឿងនោះតើដូចម្ដេច?" ។ ស្ដេចព្រាបឈ្មោះ**ចិត្រគ្រីព**និយាយរឿងប្រាប់ថា៖

# កថាទី១

## រឿងអ្នកដំណើរ និងខ្លាចាស់

ថ្ងៃមួយ, កាលខ្ញុំហិចហើរកាត់ឆ្លងទក្សិណារណ្យ ខ្ញុំបានឃើញរឿងនេះ, មានខ្លាចាស់មួយ ធ្វើពិធីមុជទឹកលាងបាប([១]) ហើយឡើងមក ដៃកាន់ស្បូវភ្លាំង ឈរទៀបមាត់ស្រះ ស្រែកហៅអ្នកដំណើរម្នាក់ថា៖ "នែអ្នកដើរ! អ្នកចូលមកយកកងមាសឯនេះ" ។ លំដាប់នោះ, អ្នកដំណើរបានឮហើយ ក៏មានចិត្តចង់បានកងមាសដោយសេចក្ដីលោភ ទើបគិតថា៖ អាត្មាអញមានបុណ្យវាសនាធំណាស់ ត្រូវបានកង

---

[១] ទំនៀមទម្លាប់សាសនាព្រាហ្មណ៍ ត្រូវមុជទឹកលាងបាប គេប្រកាន់ថាជាការបរិសុទ្ធ ។ នៅទន្លេគង្គាប្រទេសឥណ្ឌាមានព្រាហ្មណ៍រាប់ពាន់នាក់ចុះទៅមុជទឹកលាងបាបរាល់ថ្ងៃ ។ នៅប្រទេសខ្មែរយើងគេយកទឹកដូងជំនួសទឹកគង្គា លាងធាតុប្រកាន់ថាបរិសុទ្ធជ្រះឧបទ្រព្យចង្រៃ ។

មាស តែក្នុងទីនេះប្រកបដោយសេចក្តីរង្កៀស ក្រែងមានសេចក្តីអន្តរាយដល់អាត្មា មិនគួរពានពារខ្លួនទេ, ព្រោះថា៖

៦- ការស្វែងលាភក្នុងវត្ថុដែលពេញចិត្តអំពីមនុស្សអាក្រក់ មិនមែនជាគតិល្អទេ ព្រោះថា ទឹកអម្រឹតលាយដោយពិសពុល មានក្នុងទីណា គេអាចស្លាប់បានក្នុងទីនោះ ។

ការស្វែងរកទ្រព្យក្នុងទីទាំងពួង នឹងថាមិនត្រូវពានពារឧបស័គ្គក៏មិនមែន, ព្រោះថា៖

៧- នរជនមិនឡើងកាន់សេចក្តីសង្ស័យ (មិនចេះសង្ស័យ) មើលមិនឃើញសេចក្តីចម្រើនទេ ថាបើឡើងកាន់សេចក្តីសង្ស័យម្តងហើយ ម្តងទៀត ចិត្តនៅសាញ សាំញ៉ាំ ចេះតែសង្ស័យ ស្ទាក់ស្ទើរ កាលបើឃើញសេចក្តីចម្រើនហើយ ក៏ឈ្មោះថាមិនឃើញដែរ ។

បើដូច្នោះ អាត្មាអញគួរសួរដេញដោលឲ្យអស់ជើងសិន ។ អ្នកដំណើរនោះប្រកាសសួរទៅថា “នៅឯណាកងឯងនុ៎ះ?” ។ ពេលនោះ, ខ្លាក៏លើកជើងមុខបង្ហាញឲ្យមើល ។ អ្នកដើរផ្លូវពោលថា៖ “ធ្វើម្តេចឲ្យទុកចិត្តស្និទ្ធស្នាលនឹងឯង ពីព្រោះឯងនេះជាសត្វខ្លា ចូលចិត្តស៊ីសាច់ប្រចាំចក សម្លាប់គេដូច្នេះ?” ។ ខ្លាឆ្លើយតបថា៖ “នែអ្នកអើយ! ចូរអ្នកស្តាប់ខ្ញុំ កាលខ្ញុំនៅពីបឋមវ័យនៅឡើយ ខ្ញុំប្រព្រឹត្តអាក្រក់មែន ខ្ញុំខាំសម្លាប់គោ មនុស្សច្រើនអនេក, ដល់អំពើអាក្រក់នោះឲ្យផល កូនប្រពន្ធខ្ញុំស្លាប់ចោលអស់ ខ្ញុំផុតពូជអស់ហើយ ខ្ញុំនៅកំព្រាតែម្នាក់ឯង ។ លំដាប់មក, មានតាបសឥសីចិត្តសប្បុរសម្នាក់ទូន្មានប្រដៅខ្ញុំឲ្យកាន់ធម៌ថា៖ “នែអ្នក! អ្នកចូរប្រព្រឹត្តធម៌ ឲ្យទាន កុំប្រព្រឹត្តអាក្រក់ទៀត” ។ តាំងពីនោះមកខ្ញុំធ្វើតាមពាក្យប្រៀនប្រដៅរបស់តាបសឥសីនោះដរាប មិនដែលហ៊ានប្រព្រឹត្តិធ្វើអាក្រក់ទេ ប្រព្រឹត្តមុជទឹកលាងបាបជានិច្ច រក្សាសីលដាក់ទានជាប្រក្រតី មានមេត្តាករុណា, ពេលនេះ ខ្ញុំក៏កាន់តែចាស់ជរាគ្រាំគ្រាទុព៌ល ធ្មេញ ក្រចកក៏រេចរឹលអស់រលីងហើយ ដូចម្តេចក៏អ្នកនៅតែមិនជឿខ្ញុំទៀត មិនអាចយកខ្ញុំជាវិស្សាសភូមិបាន, ព្រោះថា៖

៨- ការបូជាយញ្ញ១ ការសិក្សាព្រះវេទ១ ទាន១ តបៈ១ សច្ចៈ១ សន្តោស១ សេចក្តីអត់ធន់១ និងការមិនលោភ១ ទាំង៨ប្រការនេះ ជាបដិបទានៃព្រះវេទ បុគ្គលគប្បីចាំទុកចុះ ។

៩- បណ្តាធម៌៨ ប្រការនេះ ធម៌៤ ប្រការខាងដើម គេប្រតិបត្តិដើម្បីបង្អួត ឬឆបោកក៏បាន, ធម៌៣ ប្រការខាងចុង ស្ថិតនៅបានចំពោះតែបុគ្គលមានមហាត្ម័ន (មានចិត្តប្រសើរ) ។

ឥឡូវនេះ, ខ្ញុំអស់សេចក្តីលោភរលីងហើយរហូតដល់ចង់ឲ្យកងមាសដែលនៅក្នុងដៃខ្ញុំនេះ ជាទានដល់អ្នកថែមទៀត តែបើទុកជាខ្ញុំប្រព្រឹត្តល្អដូច្នេះ ក៏នៅតែពិបាកនឹងគេច ឬឃាត់ហាមលោក

ប្រវាទ(១) ពាក្យញុះញង់ ស៊កសៀតមនុស្សលោកថា "ខ្លាស៊ីមនុស្ស" ព្រោះថា៖

១០- មនុស្សលោក តែងផ្អៀងទៅតាមដំណើរហេតុដែលកន្លងទៅហើយ មិនជឿទុកចិត្តស្ត្រីផ្កាមាស ដែលគេបានឲ្យឧបទេស (គេបានទូន្មានល្អ) ហើយមិនគិតយកព្រះធម៌ជាប្រមាណ ដូចគេមិនជឿទុកចិត្តព្រាហ្មណ៍ដែលធ្លាប់កាប់សម្លាប់គោ ។

មួយទៀត គម្ពីរធម៌សាស្ត្រ ខ្ញុំក៏បានរៀនសូត្រអស់ជើងហើយ សូមអញ្ជើញអ្នកត្រងត្រាប់ស្តាប់ដូចតទៅនេះ៖

១១- បពិត្រព្រះបាទបាណ្ឌនន្ទនៈ! (១) ភ្លៀងដែលបង្អុរចុះលើផែនពសុធាដែលរីងហែងរំហួតយ៉ាងណា ការឲ្យភោជនាហារដល់ជនស្រេកឃ្លានអត់បាយក្រហាយទឹកក៏យ៉ាងនោះដែរ ។ ការឲ្យទានដែលបានផលានិសង្សច្រើន គឺការឲ្យទានដល់មនុស្សអ្នកទីទ័លក្រីក្រលំបាកតោកយ៉ាក ។

១២- ជីវិតរបស់ខ្លួនជាទីស្រឡាញ់ពេញចិត្តយ៉ាងណា ជីវិតរបស់ជនដទៃក៏យ៉ាងនោះដែរ ។ លោកសប្បុរសទាំងឡាយតែងធ្វើសេចក្តីមេត្តាករុណា ព្រោះលោកយកខ្លួនរបស់លោកជាគ្រឿងឧបមា ។

មួយទៀតលោកពោលទុកថា៖

១៣- កំណាញ់ និងការឲ្យទាន, សេចក្តីសុខ និងសេចក្តីទុក្ខ, ស្រឡាញ់ និងស្អប់ បុគ្គលអាចយកប្រមាណសេចក្តីបាន ដោយយកខ្លួនអាត្មាជាគ្រឿងឧបមា ។

១៤- នរជនណាឃើញភរិយាអ្នកដទៃ ទុកស្មើដោយមាតារបស់ខ្លួន, ឃើញទ្រព្យអ្នកដទៃ ទុកស្មើដោយដុំថ្ម, ឃើញសព្វសត្វទាំងឡាយទុកស្មើដោយរូបខ្លួន នរជននោះ លោកហៅថា "បណ្ឌិត" ។

ខ្លួនអ្នកជាបុគ្គលទុគ៌តកម្សត់ក្រីក្រក្រៃលែង ព្រោះហេតុនោះទើបខ្ញុំខំប្រឹងប្រែងជាបំផុត នឹងឲ្យទានដល់អ្នកព្រោះថា៖

១៥- បពិត្រព្រះបាទបាណ្ឌុព សូមទ្រង់មេត្តាករុណាចិញ្ចឹមអ្នកក្រីក្រកម្សត់ទុគ៌ត កុំប្រទានទ្រព្យដល់ឥស្សរជនដែលមានទ្រព្យច្រើនឡើយ ដូចជាឱសថជាប្រយោជន៍ដល់អ្នកជំងឺឈឺចាប់ទុរន់ទុរា ជនឥតរោគាព្យាធិត្រូវការអ្វីដោយឱសថ?

១៦- ទានជារបស់គួរគប្បីឲ្យ តែឲ្យដល់អ្នកមិនមានឧបការគុណ មិនសូវមានប្រយោជន៍ទេ,

---

[១] ពាក្យមនុស្សលោកពោលបង្ខូច ។

[១] នាមព្រះបាទបាណ្ឌពក្សត្រីយ៍មានបងប្អូន ៥ ព្រះអង្គ ក្នុងរឿងមហាភារៈ, ជាឱរសព្រះនាងកុន្តី បានជានាមខ្លះថា កោរន្តដា ។

ការឲ្យទានដែលអ្នកប្រាជ្ញពោលថាប្រកបដោយផលប្រយោជន៍នោះ គឺឲ្យទានត្រឹមត្រូវតាមកាលៈទេសៈ និងឲ្យដល់បុគ្គលមានគុណគួរឲ្យ ។

ដូច្នេះ អ្នកចូរទៅមុជទឹកលាងបាបក្នុងត្រពាំងនេះឲ្យស្អាតបាតសិន ហើយសឹមឡើងមកយកកងមាសពីខ្ញុំចុះ ។ លំដាប់នោះអ្នកដំណើរបានស្ដាប់ពាក្យខ្លាចាស់ពោលលលួងឲ្យវង្វេងស្មុងគំនិតហើយ ដើរចុះទៅមុជទឹកលាងបាបក្នុងត្រពាំងនោះ ដោយចិត្តលោភលន់ពន់ប្រមាណ ក៏ផុងប្រាណលង់ទ្រនេសជាប់ក្នុងបឹងជ្រៅ នឹងគេចវេះរត់លូនទៅពួនក្នុងទីឯណាក៏ពុំបាន រីឯខ្លាចាស់ កាលឃើញអ្នកដំណើរផុងលង់ទ្រនេសស៊ប់ជាប់ក្នុងភក់រើខ្លួនមិនរួចសមបំណងហើយ ទើបក្លែងធ្វើជាស្រែកជួយភ័យថា៖ “ហ៎ា! ហ៎ា! យីអ្នកផុងលង់ក្នុងភក់ហើយតើ! មិនអីទេ ចាំខ្ញុំចុះទៅជួយស្រង់ អ្នកកុំភ័យ!” ថាហើយក៏ដើរចុះសន្សឹមបន្តិចៗ ស្ទាបស្ទង់មើល ធ្វើជាខ្លាចផុងខ្លួនឯង ចូលទៅចាប់អ្នកដំណើរនោះ ។ ឯអ្នកដំណើរ កាលបើខ្លាចូលទៅសង្គ្រប់ជាប់ក្នុងដៃហើយ ក៏នឹកអាណិតខ្លួន ទើបពោលបន្ទោសខ្លួនឯងថា៖

១៧- បុគ្គលចិត្តអាក្រក់សាមាន្យ នឹងសម្គាល់បានដោយអាងហេតុថា “ចេះពោលធម្មសាស្ត្រ” ក៏មិនមែន ឬថា “ចេះស្វាធ្យាយគម្ពីរព្រះវេទ” ក៏មិនមែនដែរ ។ មធុរសនៃទឹកដោះគោរមែងផ្អែមល្ហែមទៅតាមប្រក្រតីរបស់ទឹកដោះយ៉ាងណា, សភាពសត្វលោកក្នុងសំសារវដ្តនេះលោកពោលថា ដូចគ្នាយ៉ាងនោះឯង ។

១៨- ការធ្វើអ្វីទាំងពួង នៃបុគ្គលអ្នកមានឥន្ទ្រិយ និងចិត្តមិនលុះនៅក្នុងអំណាចខ្លួន ក៏មិនជាផលដូចជាការលាងជម្រះដំរី[១] ពុំនោះការចេះដឹង បើប្រាសចាកការធ្វើឲ្យជាប្រយោជន៍ហើយ ក៏ធ្ងន់ខួរក្បាលឥតអំពើ ដូចជាការបំពាក់គ្រឿងអលង្ការ បំប៉នឲ្យភរិយាចង្រៃ បានតែធ្ងន់ខ្លួនឥតប្រយោជន៍ ។

អាត្មាអញ ធ្វើសេចក្ដីស្និទ្ធស្នាលទុកចិត្តមនុស្សអាក្រក់សាមាន្យ ចូលចិត្តសម្លាប់គេ ដោយហេតុឯណា ហេតុនោះអាត្មាអញឈ្មោះថាមិនធ្វើសេចក្ដីចម្រើនទេ, ព្រោះថា៖

១៩- បុគ្គលមិនគួរគប្បីធ្វើសេចក្ដីស្និទ្ធស្នាលទុកចិត្តទឹកទន្លេ, បុគ្គលមានសាស្ត្រាវុធក្នុងដៃ, សត្វមានក្រចកមុត, សត្វមានស្នែង និងស្ត្រីក្នុងរាជត្រកូលទាំងឡាយ ។

២០- សភាព (លក្ខណៈ) នៃបុគ្គលទាំងអស់ក្នុងលោកនេះ គេមើលឃើញច្បាស់ប្រាកដ តែគុណធម៌ទាំងឡាយនៃបុគ្គល គេមើលមិនឃើញងាយទេ, សភាពនៃបុគ្គលនីមួយៗ កម្ចាត់បង់នូវគុណធម៌ទាំងពួង ហើយចូលទៅទំនៅលើក្បាលបាន ។

---

[១] ការលាងដំរី ឥតអំពើ ព្រោះស្បែកដំរីគ្រើមៗ ហើយដំរីចូលចិត្តបាចដីដាក់លើខ្លួន ។

២១- មែនពិត ព្រះចន្ទ្រទ្រទ្រង់នូវសហស្សរង្សី ត្រាច់ចររុងរឿងពួដ៏នភាល័យប្រទេស កម្ចាត់បង់នូវងងឹតអន្ធការអ័ព្វសូន្យសុងកណ្ដាលដួងតារាព្រោងព្រាត សូម្បីមានឫទ្ធិដល់ម្ល៉ោះ ដល់គ្រោះជោគគ្រោះជាក៏ត្រូវរាហូចាប់លេបបាន នរណាហ្ន៎! អាចវេះគេចឲ្យរួចពីលិខិតដែលព្រះជាម្ចាស់ត្រាទុកពួដ៏ថ្វាសបាន? ។

វីអ្នកដំណើរនោះ, កាលកំពុងត្រិះរិះពិចារណាដូច្នេះ ត្រូវខ្លាចាស់ខាំជញ្ចែងហែកស៊ី ស្លាប់វិនាសអន្តរធានពួដ៏កាលនោះហោង ។ ហេតុនេះបានជាខ្ញុំ (ស្ដេចព្រាប) ពោលជាស្លោកមានអាទិ៍ថា៖ "ព្រោះលោភចង់បានកងមាសដូច្នេះជាដើម"(៥) ។ ព្រោះហេតុនោះ ការងារផងទាំងពួង ដែលមិនបានពិចារណាឲ្យជុំវិញខ្លួនសព្វគ្រប់ មិនគួរគប្បីធ្វើឡើយ, ព្រោះថា៖

២២- អាហារដែលរលួយល្អ, កូនមានប្រាជ្ញាឆ្លៀវឆ្លាត, ភរិយាស្ដាប់បង្គាប់ឱវាទ, ព្រះនរបតីមានប្រជារាស្ត្រស្វាមីភ័ក្តិ, គិតគូរឲ្យល្អិតល្អ ហើយទើបនិយាយ, ពិចារណាឲ្យជុំវិញខ្លួនហើយទើបធ្វើទាំងអស់នេះលោកពោលថា សូម្បីស្ថិតនៅអស់កាលយូរអង្វែងក៏ដោយ ក៏មិនឃ្លាតក្លាយទៅជាអ្វីឡើយ ។

កាលនោះ មានព្រាបជាបរិវារមួយ បានឮស្ដេចព្រាបពោលថាដូច្នេះហើយ ក៏ទាស់ចិត្តនិយាយដោយអាការទ្រនង់យង់ឃ្នងថា៖ អ៊ំា! ដូចម្ដេចក៏លោកមានប្រសាសន៍ដូច្នេះ?

២៣- បើមានការអន្តរាយមកដល់ជិត បុគ្គលគប្បីកាន់តាមពាក្យចាស់ព្រឹទ្ធាចារ្យ តែបើការពិចារណាឲ្យសព្វគ្រប់ យ៉ាងនោះហើយ សូម្បីស្វែងរកអាហារភោជន ក៏មិនត្រូវស្វែងរកដែរ ។

២៤- បុគ្គលដែលស្វែងរកបាយទឹកនំចំណីលើផែនពសុធានេះ សុទ្ធសឹងប៉ះទង្គិច ដោយសេចក្ដីរង្កៀសភយន្តរាយទាំងឡាយ នឹងប្រព្រឹត្តស្វែងរកក្នុងកាលណា? ធ្វើម្ដេចហ្ន៎ គេនឹងអាចចិញ្ចឹមជីវិតឲ្យប្រព្រឹត្តទៅបាន?

២៥-បុគ្គលមានឥច្ឆាឈ្នានីស បុគ្គលពោលពាក្យនិន្ទារិះគន់, បុគ្គលមិនសន្ដោស, បុគ្គលក្រោធច្រើន, បុគ្គលមានសេចក្ដីរង្កៀសជានិច្ច និងបុគ្គលពឹងផ្អែកស៊ីតែដោយសារបុគ្គលដទៃ បុគ្គលទាំង៦ បែបនេះត្រូវទទួលចំណែកនៃសេចក្ដីទុក្ខ ។

ព្រាបជាបរិវារទាំងឡាយ លុះបានស្ដាប់ពាក្យព្រាបអ្នកនិយាយនោះហើយ ក៏បបួលគ្នាហើរត្រសងទៅចុះក្នុងស្រែនោះ, ព្រោះថា៖

២៦- បុគ្គលជាពហុស្សូត ចេះដឹងនូវសាស្ត្រាវិជ្ជាទាំងឡាយច្រើនមហិមា អាចកាត់នូវសេចក្ដីសន្ទិះសង្ស័យគ្រប់ប្រការបាន កាលបើសេចក្ដីលោភចង់បានមកបំបាំងគំនិតឲ្យងងឹតសូន្យសុងហើយ ក៏

តែងទទួលសេចក្តីទុក្ខលំបាកតោកយ៉ាក ។

២៧- សេចក្តីក្រោធមានដើមកំណើតមកពីលោភៈ, កាមរាគកើតមកពីលោភៈ មោហៈ និង សេចក្តីវិនាស ក៏កើតមកពីលោភៈដែរ ព្រោះហេតុនោះ លោភៈជាប្រភពនៃសេចក្តីអាក្រក់គ្រប់ប្រការ ។

២៨- ដោយពិត ប្រើសមាសមិនដែលកើតមានទេ បើទុកជាដូច្នេះ ព្រះរាមក៏ទ្រង់នៅតែជាប់ ព្រះទ័យចង់បានប្រើសមាស រីសេចក្តីអន្តរាយក្នុងកាលវិបត្តិមកដល់ សូម្បីប្រាជ្ញានៃបុរសជាតិ ក៏ត្រឡប់ ជា ងងឹតងងល់គិតមិនយល់បានដែរ ។

លំដាប់នោះ ព្រាបទាំងឡាយត្រូវលប់ជាប់ក្រញង់ទាំងអស់គ្នា ។ ពួកព្រាបទាំងឡាយដែលជឿ ស្តាប់ពាក្យព្រាបជាអ្នកនិយាយនោះ ក៏ជេរប្រទេចផ្តាសា រអ៊ូរទាំដោយប្រការផ្សេងៗ, ព្រោះថា៖

២៩- ([១])បុគ្គលមិនគប្បីចេញមុខជាមេគណៈ ធ្វើការងារណាដែលសម្រេចប្រយោជន៍ទៅហើយ ត្រូវបានផលស្មើគ្នាទេ ព្រោះថា បើការងារនោះអន្តរាយវិញ អ្នកចេញមុខនោះត្រូវស្លាប់ក្នុងទីនោះមុន គេ ។

កាលដែលព្រាបទាំងឡាយកំពុងរអ៊ូរទាំពោលទោសព្រាបអ្នកនិយាយនោះ ស្តេចព្រាបប្រកាស ឲ្យដឹងច្បាស់ថា៖ “ទោសនេះមិនមែន ទោសព្រាបជាអ្នកនាំនោះទេ” ព្រោះថា៖

៣០- សូម្បីមិត្ត ជាអ្នកធ្វើប្រយោជន៍ឲ្យពិតៗ ក៏អាចក្លាយទៅជាដើមហេតុនាំបណ្តាលឲ្យកើត អន្តរាយធ្លាក់មកបាន ដូចស្នងមេគោអាចទៅជាស្នឹងចងកូនគោ ។

៣១- អ្នកណាមួយ អាចជួយអ្នកមានគ្រោះឲ្យរួចពីក្តីអន្តរាយដែលមកដល់ អ្នកនោះលោកទុកជា ផៅពង្ស, ឯបណ្ឌិតតែមាត់ បានតែពោលបន្ទោសទម្លាក់ខុសទៅគេ អួតថាខ្លួនជួយស្រោចស្រង់ឲ្យរួចពី ក្តីភិតភ័យ នឹងទុកថាជាផៅពង្សពុំបានឡើយ ។

ក្នុងគ្រាក្រ ការថយកម្លាំងទឹកចិត្តជាលក្ខណៈបុរសគម្រក់ ។ ក្នុងរឿងនេះ ត្រូវសម្តែងសេចក្តីម៉ឺង ម៉ាតអង់អាច ហើយត្រិះរិះរកឧបាយរើខ្លួនតទៅ ព្រោះថា៖

៣២- ([២])ចិត្តម៉ឺងម៉ាត់ក្នុងគ្រាក្រទុក្ខព្រួយ, ចិត្តនឹងធឹងក្នុងគ្រាសុខចម្រើន, សេចក្តីអង់អាចក្នុងទី ប្រជុំដោយសម្តីថ្វីមាត់, ចិត្តក្លៀវក្លាក្នុងរណរង្គ([៣]), ចិត្តត្រេកអរក្នុងយស និងចិត្តស្រវាស្រទេញក្នុងការ សិក្សាទាំងអស់នេះ ជាលក្ខណៈសម្បត្តិមានជាប្រក្រតី ចំពោះតែបុគ្គលមានមហាត្មន (មានចិត្តដ៏

---

[១] ហិតោបទេសសេចក្តីប្រែជាភាសាបារាំងរបស់លោកស៊ីរ៉ូ និងសេចក្តីប្រែជាភាសាសៀម របស់លោកនាគប្រទីប មានគាថា លើសដូច្នេះគឺ ការមិនបានទូន្មានឥន្ទ្រិយ លោកពោលថា ជាផ្លូវនាំឲ្យកើតអន្តរាយ, ការទូន្មានឥន្ទ្រិយឈ្នះហើយ ជាផ្លូវនាំ ឲ្យកើតសេចក្តីចម្រើន, នរជន ដើរផ្លូវណាក៏ដើរចុះតាមចិត្តប្រាថ្នា ។

ប្រសើរ) ។

៣៣- អ្នកណាមិនរីករាយហួសហេតុ ក្នុងគ្រាបានសេចក្ដីសុខចម្រើន, មិនខ្វះចកម្លាំងទឹកចិត្ត ក្នុងគ្រាក្រទុក្ខព្រួយ, មានសេចក្ដីក្លាហានក្នុងរណរង្គ, មាតាបង្កើតកូនដែលមានតិលក:([១]) ដូច្នេះក្នុងលោកទាំងបីនេះកម្រមានណាស់ ។

៣៤- ក្នុងលោកនេះ ទោស៦ប្រការ បុគ្គលប្រាថ្នាសេចក្ដីសុខចម្រើនគួរគប្បីលះបង់ចោល គឺដេកទ្រមក់១ ខ្ជិលច្រអូស១ ភ័យ១ ក្រោធ១ ទន់មួរមុខ និងឡេឡាយឺតយូរក្រោយគេ១ ។

ឥឡូវនេះ គួរយើងទាំងអស់គ្នាធ្វើយ៉ាងនេះ ត្រូវអ្នកទាំងអស់ស្រុះចិត្តគ្នាតែមួយ ហើយស្ទុះហើរតែមួយឯកប្បហារឲ្យព្រមៗគ្នា ទើបរបើកលប់រួចខ្លួនបាន, ព្រោះថា៖

៣៥- ការវេញចងបាច់វត្ថុអ្វីមួយ សូម្បីតូចឆ្មារឲ្យរួបរួមគ្នា ក៏អាចញុំាងការងារឲ្យសម្រេចប្រយោជន៍បាន ដូចគេប្រមូលស្មៅវេញជាទន្លីងយកទៅផ្គឹងដំរីចុះប្រេងឲ្យជាប់បោលទៅណាមិនរួច ។

៣៦- ការចងបាច់វង្សត្រកូលរបស់ខ្លួនសូម្បីពីរបីនាក់ ឲ្យរួបរួមមូលត្រកូលគ្នា ក៏ជាការគាប់ប្រសើរល្អណាស់ ដូចគ្រាប់ស្រូវដែលបកសំបកចេញហើយ យកទៅសាបព្រោះមិនដុះលូតលាស់ឡើងបានទេ ។

លុះព្រាបទាំងឡាយបានស្ដាប់ពាក្យណែនាំស្ដេចព្រាបឈ្មោះ**ចិត្រគ្រីព**ហើយ ព្រមព្រៀងបបួលគ្នាស្ទុះហើរជាឯកប្បហារ របើកលប់បាន រួចពីក្ដីវិនាសអន្តរាយនោះទៅហោង ។ រីឯព្រានបក្សីពួនលបចាំមើល ឃើញហ្វូងបក្សីស្រុះគ្នាទទះស្លាបហើររបើកលប់រត់រួចទៅបានដូច្នោះ ក៏នឹកស្ដាយណាស់ រត់ទៅតាមបណ្ដើរគិតបណ្ដើរថា៖

៣៧- ហ្វូងបក្សីនេះ ស្រុះចិត្តចងគ្នាជាបាច់ ស្ទុះហើររបើកលប់រត់រួចទៅអស់រលីង តែបើវាចុះដីដរាបណា វានឹងនៅក្នុងកណ្ដាប់ដៃអាត្មាអញដរាបនោះមិនខានឡើយ ។

បក្សីទាំងឡាយ ខំប្រឹងហើរទៅឆ្ងាយសន្ធឹម ក្រឡេកមើលមកក្រោយ ឃើញព្រានអស់សង្ឃឹមត្រឡប់វិលវិញហើយ ក៏សួរទៅកាន់ស្ដេចព្រាប**ចិត្រគ្រីព**ថា៖ “បពិត្រលោកជាស្ដេចបក្សី ឥឡូវនេះតើគួរ

---

[២] ហិតោបទេស សេចក្ដីប្រែជាភាសាបារាំងរបស់លោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះ នរជនណា អាចជួយស្រោចស្រង់យើងឲ្យរួចពីក្ដីអន្តរាយ និងចេះរកឧបាយជួយឲ្យរួចភ្លាមៗ មិនបង្អង់, នរជននោះ លោកហៅថា មិត្តពិត ។

[៣] សមរភូមិទីចម្បាំងជាញជ័យ ។

[១] បុរសលក្ខណៈនៃបុគ្គលដ៏ប្រសើរក្នុងត្រៃភព ជាតិឥណ្ឌូចូលចិត្ត តិលក: នេះយកទៅគូសនៅថ្ងាស ទុកជាគ្រឿងសម្រាប់សម្គាល់និកាយខ្លួន ។

នឹងធ្វើដូចម្តេចតទៅទៀត?", ស្តេចព្រាបឈ្មោះ**ចិត្រគ្រីព**ឆ្លើយតបថា៖

៣៨- មាតា, មិត្ត និងបិតា ត្រៃអង្គនេះជាអ្នកធ្វើហិតានុហិតតាមសភាពខ្លួន ឯអ្នកដទៃទៀតធ្វើហិតានុហិតបែបនេះដែរ ព្រោះគេយកនាទីមាតា, មិត្ត, បិតា មកទុកជាហេតុដើម ។

កាលបើដូច្នេះ យើងមានមិត្តមួយឈ្មោះ **ហិរណ្យកៈ** ជាស្តេចកណ្តុរ ចិញ្ចឹមជីវិតអាស្រ័យនៅតាមអរញ្ញប្រទេសឈ្មោះចិត្រវ័ន ទៀបឆ្នេរស្ទឹងគណ្ឌកី យើងនឹងទៅសូមឲ្យជួយកកេរកាត់លប់ ដោះឲ្យរួចពីគ្រោះកាចចង្រៃនេះដោយធ្មេញគេ ។ លុះពិចារណាឃើញដូច្នោះហើយ ព្រាបទាំងនោះក៏បបួលគ្នាហើរត្រសងទៅជិតព្រង់(១) ជាទីលំនៅនៃស្តេចកណ្តុរឈ្មោះ**ហិរណ្យកៈ**នោះ ។

ឯស្តេចកណ្តុរជាសត្វមានសេចក្តីប្រយ័ត្នខ្លួន ដោយក្តីរង្កៀសពីភយន្តរាយ បានកាយព្រង់មួយមានមាត់មួយរយកន្លែង ហើយអាស្រ័យនៅក្នុងទីនោះ ។ លំដាប់នោះស្តេចកណ្តុរឈ្មោះ **ហិរណ្យកៈ** ឮសូរសន្ធឹកព្រាបហើរមកចុះជិតលំនៅខ្លួន ក៏តក់ស្លុតរន្ធត់ក្នុងចិត្ត ខំសម្លឹងមើលដោយសេចក្តីព្រួយបារម្ភពួនសំងំនៅស្ងៀមឈឹងមិនមាត់ឡើយ ។

ស្តេចព្រាបឈ្មោះ **ចិត្រគ្រីព** ស្រែកសួរថា៖ "អឺសម្លាញ់**ហិរណ្យកៈ**! ហេតុអ្វីក៏សម្លាញ់នៅស្ងៀមទ្រមឹងទ្រមើយ មិននាំពាមាត់កចេញមកទទួលយើងសោះ?" ខណៈនោះ ស្តេចកណ្តុរស្តាប់សម្តីស្តេចព្រាបបាន ក៏ស្ទុះរត់ចេញមកក្រៅដោយប្រញាប់ប្រញាល់ ហើយឆ្លើយឆ្លងទៅវិញថា៖ "អ៊ំាសម្លាញ់! ខ្ញុំមានភ័ព្វណាស់ **ចិត្រគ្រីព** សម្លាញ់ជាមិត្តស្មើចិត្តស្មើថ្លើមគ្នា ឥឡូវមកដល់ហើយតើ!" ។

៣៩- ក្នុងលោកនេះ មិនមាននរណាមានបុណ្យវាសនា ជាងអ្នកដែលបានជួបប្រទះសន្ទនារីករាយជាមួយនឹងមិត្ត អ្នកដែលស្ថិតនៅរួមមួយអន្លើដោយមិត្ត និងអ្នកដែលប្រស្រ័យប្រាប់សុខទុក្ខទៅវិញទៅមកមួយអន្លើដោយមិត្តដូច្នេះទេ ។

កាលស្តេចកណ្តុរឃើញព្រាបទាំងឡាយជាប់ចំណងលប់ដូច្នោះ ក៏ភ្ញាក់ព្រើត ទ្រឹងមួយស្របក់ទើបសួរហេតុនោះថា៖ "នែសម្លាញ់! ចុះហេតុនេះដូចម្តេច?" ។ ស្តេចព្រាបឆ្លើយប្រាប់ថា៖ "អំពើនេះជាផលនៃកម្មរបស់យើងគ្រប់គ្នាពីបុរាណកាលណ៎ាសម្លាញ់! ព្រោះថា៖

៤០- សេចក្តីល្អ និង សេចក្តីអាក្រក់ ជាកម្មរបស់ខ្លួនឯណា ព្រោះហេតុឯណា, ដោយប្រការណា, ក្នុងកាលណា, ដរាបណា, ក្នុងទីណា អំពើនោះ សម្រេចផលតាមអំណាចនៃព្រះព្រហ្មបង្កើតលោក ព្រោះហេតុនោះ ដោយប្រការនោះ ក្នុងកាលនោះ ដរាបនោះ ក្នុងទីនោះ ។

---

(១) - រន្ធ, ប្រហោង

៤១- រោគាព្យាធិ, សោកសង្រេងសង្រៃ, សេចក្តីក្តៅក្រហាយការជាប់អន្ទាក់ចំណាង និង សេចក្តីវិនាសអន្តរាយទាំងឡាយនេះ ជាផលដែលមកពីព្រឹក្សាជាតិ គឺទោសកំហុសរបស់ខ្លួននៃមនុស្សទាំងឡាយ ។

ស្តេចកណ្តុរបានស្តាប់ពាក្យនោះហើយ ក៏ស្ទុះចូលទៅជិតសម្លាញ់ ដើម្បីកាត់ចំណាងលប់ដោយប្រញាប់ប្រញាល់ ។ ស្តេចព្រាបឃាត់ថា៖ “សម្លាញ់! កុំអាល ឈប់សិន! ចូរអ្នកកាត់ចំណាងព្រាបទាំងឡាយដែលជាបរិវារមុនសិន ហើយសឹមកាត់ចំណាងឲ្យខ្ញុំក្រោយគេ ។ **ហិរណ្យកៈ** តបឡើងថា៖ “កម្លាំងខ្ញុំខ្សោយណាស់ ធ្មេញក៏មិនសូវមាំមួន ហេតុនេះធ្វើម្តេចនឹងអាចកាត់អន្ទាក់ឲ្យបរិវារអ្នកគ្រប់គ្នាច្រើនដល់ម្ល៉េះបាន? បើដូច្នោះ ខ្ញុំនឹងកកេរកាត់ចំណាងឲ្យសម្លាញ់មុនសិន បើធ្មេញខ្ញុំមិនទាន់រេចរឹលទេ ខ្ញុំនឹងកកេរកាត់ឲ្យបរិវារសម្លាញ់ទាំងឡាយតទៅទៀតជាលំដាប់ តាមកម្លាំងដែលអាចនឹងកកេរកាត់បាន” ។ **ចិត្រគ្រីព** ប្រកែកខ្លាំងៗថា៖ “ទេ! ទេ! សម្លាញ់កុំធ្វើដូច្នោះ ទោះបីយ៉ាងណាក៏ដោយសូមសម្លាញ់អាណិតមេត្តាកាត់ចំណាងឲ្យបរិវារមុនសិន សឹមកាត់ឲ្យខ្ញុំក្រោយគេ” ។ ស្តេចកណ្តុរថ្លែងសុភាសិតថា៖ “កិរិយាការពារថែរក្សានូវបរិវារខ្លួន ដោយការបរិច្ចាកខ្លួនជាពលិកម្មនោះ អ្នកប្រាជ្ញឆ្លៀវឆ្លាតក្នុងនីតិសាស្ត្រលោកមិនសរសើរទេ, ព្រោះថា៖

៤២- បុគ្គលគប្បីថែរក្សាទ្រព្យទុក ដើម្បីការពារគ្រាក្រ គប្បីរក្សាភរិយាដោយទ្រព្យ តែគប្បីរក្សាខ្លួនរឿយៗដោយភរិយាផង ដោយទ្រព្យផង ។

៤៣- ប្រាណគឺជីវិត មានការតាំងនៅមាំជាហេតុដើម្បីប្រព្រឹត្តធម៌ ស្វែងរកទ្រព្យសម្បត្តិ សេពកាម និងរកមោក្ខធម៌ បើប្រាណគឺជីវិតវិនាសហើយ អ្វីមួយដែលឈ្មោះថាមិនវិនាសទៅនុ៎ះ? ការរក្សាប្រាណ គឺជីវិតឲ្យគង់វង់នៅ អ្វីមួយដែលឈ្មោះថា មិនរក្សាផងដែរ?

ស្តេចព្រាបពោលឡើងថា៖ “សម្លាញ់អើយ! សម្តីសម្លាញ់និយាយមកអម្បាញ់មិញនេះ ជាគោលនៃនីតិសាស្ត្រពិតហើយ តែថារូបខ្ញុំនៅតែមិនអស់ចិត្ត មិនអាចឈរមើលបរិវារដែលអាស្រ័យនៅជាមួយរងទុក្ខវេទនាដូចនេះចំពោះភ្នែកសោះ បានជាខំអង្វរករសម្លាញ់ដូច្នេះឯង, ព្រោះថា៖

៤៤- អ្នកប្រាជ្ញគប្បីលះបង់ទ្រព្យផង ជីវិតផង ជាពលិកម្ម ដើម្បីការពារជនដទៃ ការបរិច្ចាកជីវិតក្នុងអំពើល្អបែបនេះ ជាកិត្តិយសប្រសើរណាស់ បើសេចក្តីស្លាប់ជាធម៌ទៀង ។

សម្លាញ់! មានសុភាសិតដែលគួរនឹងទាញយកមកជានិទស្សន៍ទៀតដូច្នេះថា៖

៤៥- បណ្តាគុណធម៌ទាំងឡាយគឺជាតិ ទ្រព្យ និងគុណសម្បត្តិ គុណធម៌៣ប្រការនេះ បរិវារមានស្មើនឹងម្ចាស់, សម្លាញ់! ចូរអ្នកនិយាយឲ្យឃើញច្បាស់មកមើល ដូចម្តេចដែលហៅថា ភាពនៃខ្លួនជាធំ

វិសេសជាងគេ? ដល់កាលណាទៅ ត្រូវសម្តែងភាពជាធំ?

៤៦- បរិវារទាំងឡាយនេះ មិនមានគ្រឿងអាហារចិញ្ចឹមជីវិត និងមិនលះបង់ការសំណាក់ពឹងពាក់ចោលខ្ញុំទេ ព្រោះហេតុនោះ សូមសម្លាញ់ជួយស្រោចស្រង់ជីវិតបរិវារទាំងឡាយនេះមុនសិន សូម្បីតែត្រូវក្តីវិនាសអន្តរាយជីវិត ខ្ញុំក៏មិនថាដែរ ។

៤៧- នែសម្លាញ់ ចូរលះបង់ព្រួយក្នុងកឡេវរៈ រាងកាយដែលនិមិត្តដោយសាច់ទឹកមូត្រ, អាចម៍ និង ឆ្អឹងឆ្អែងជារបស់ពុកផុយរលួយនេះចោលឲ្យស្រឡះទៅ សូមជួយអភិបាលលើកតម្កើងយសកេរ្តិ៍ឈ្មោះខ្ញុំវិញ ។

៤៨- ថាបើបុគ្គលគប្បីបាននូវកិត្តិយស ដែលទៀងទាត់មិនមានមន្ទិល ដោយការបរិច្ចាកកាយដែលផ្ទុកដោយគ្រឿងមន្ទិលសៅហ្មងស្មោកគ្រោក មិនទៀងទាត់នេះបាន បើដូច្នោះតើបុគ្គលនឹងមិនគប្បីកាន់យកនូវគុណធម៌គឺកិត្តិយសនោះឬអ្វី?

៤៩- សរីរៈ និង កិត្តិគុណ មានចន្លោះតាំងនៅឆ្ងាយពីគ្នាលន្លង់លន្លោចណាស់ ។ សរីរៈនេះរលត់រលាយទៅក្នុងមួយខណៈ ឯកិត្តិគុណស្ថិតនៅរហូតកល្បាវសាន ។

កាលស្តេចកណ្តុរបានស្តាប់ពាក្យពោលដូច្នេះហើយ ក៏មានចិត្តរីករាយក្រៃលែង ព្រឺរោមព្រឺស្បែកនិយាយតបថា៖ “សាធុ! សម្លាញ់ សាធុ! សម្លាញ់ឯងមានចិត្តមេត្តាករុណាទន់ភ្លន់ ចំពោះបរិវារដូច្នេះល្អណាស់ សមគួរនឹងជាធំក្នុងត្រៃលោកនេះ ។ ស្តេចកណ្តុរនិយាយហើយកកេរកាត់ចំណង ដែលចងព្រាបទាំងឡាយនោះ ឲ្យរួចស្រឡះក្នុងកាលនោះឯងហោង ។ លំដាប់នោះ ស្តេចកណ្តុរសម្តែងសេចក្តីសាទរចំពោះព្រាបទាំងឡាយ ហើយបែរទៅនិយាយលួងលោមស្តេចព្រាបថា៖ “ហៃសម្លាញ់**ចិត្រគ្រីព**! ក្នុងលោកនេះ ការជាប់លប់ជាប់អន្ទាក់ជាធម្មតាទេ ត្រូវខ្លាចទោសពៃរ៍អន្តរាយទាំងអស់នេះ តែកុំអាក់អន់ចិត្តព្រួយបារម្ភចំពោះភ័ព្វវាសនាដូច្នេះឡើយ, ព្រោះថា៖

៥០- ក្នុងលោកនេះ សត្វបក្សីមើលឃើញអាហារចំណីដែលស្ថិតនៅឆ្ងាយជាងមួយរយយោជន៍ តែសត្វបក្សីនោះ កាលបើគ្រោះជោគគ្រោះជាំមកដល់ហើយ មើលចំណងមិនឃើញទេ ។

៥១- កាលខ្ញុំបានឃើញព្រះចន្ទ្រ និងព្រះអាទិត្យ ត្រូវរាហូចាប់បៀតបៀន, ឃើញដំរី និងនាគជាប់ចំណង, ឃើញអ្នកប្រាជ្ញឆ្លៀវឆ្លាតត្រូវក្តីក្រីក្រលំបាកតោកយ៉ាក ខ្ញុំមានមតិដូច្នេះថា៖ “ឱហ្ន៎ វិធីកម្មនេះមានឫទ្ធិតេជៈកម្លាំងខ្លាំងណាស់តើ!” ។

៥២- វិហគជាតិ (បក្សី) ទាំងឡាយ ហិចហើរខ្ពស់ត្រដួចចរទៅឰដ៏អាកាសព្យោមា, សមបើដែរ! ធ្លាក់ដល់ក្តីវិនាសអន្តរាយបាន, មច្ឆជាតិទាំងឡាយអាស្រ័យនៅក្នុងសមុទ្រសាគរ មានទឹកដ៏ជ្រាលជ្រៅ

រាប់ប្រមាណមិនបាន សមបើដែរ! ត្រូវព្រានប្រមង់ចាប់យកបានដោយការប៉ិនប្រសប់, បើដូច្នោះមែន ក្នុងលោកនេះចាំបាច់មានទុច្ចរិតធ្វើអ្វី? សេចក្តីពិត, ព្រះកាល(១) ជាអ្នកមានដៃក្រាលលាតត្រដាងនូវសេចក្តីអន្តរាយទូទៅ ហើយចាប់សម្លាប់សត្វទាំងឡាយ សូម្បីស្ថិតនៅក្នុងទីឆ្ងាយស្រឡោចក៏ដោយ ។

ស្តេចកណ្តុរនិយាយដាស់តឿនក្រើនរំឭកដោយពាក្យសុភាសិត ធ្វើបដិសណ្ឋារៈទទួលរាក់ទាក់ ចាប់ឱបជប់ព្រាប**ចិត្រគ្រីព**នោះហើយ ទើបបញ្ជូនឲ្យហើរទៅកាន់ស្រុកទេស តាមសេចក្តីប្រាថ្នាព្រមទាំងបរិវារទៅហោង ។ ឯស្តេចកណ្តុរក៏ចូលទៅក្នុងព្រង់ជាលំនៅរបស់ខ្លួនវិញក្នុងពេលនោះឯង ។

៥៣- បុគ្គលគប្បីស្វែងរកសេពគប់មិត្ត ឲ្យបានច្រើនចំនួនរាប់រយ ។ ចូរមើល! សត្វព្រាបទាំងឡាយរួចពីចំណងចងសម្លាប់ខ្លួនបាន ព្រោះអាស្រ័យស្តេចកណ្តុរជាមិត្ត ។

កាលនោះ ក្អែកឈ្មោះ **លឃុបតនកៈ** បានឃើញជាក់ច្បាស់នូវព្រឹត្តិការណ៍តាំងពីដើមដល់ចុង ក៏នឹកស្ងើចក្នុងចិត្តឥតឧបមា ទើបបន្លឺវាចាសរសើរថា៖ “ហៃសម្លាញ់**ហិរណ្យកៈ** បងឯងមានគុណគាប់ប្រសើរណាស់ ឥឡូវនេះខ្ញុំមកសូមយកអ្នកធ្វើជាមិត្ត! អែបងក៏គួរគិតសង្គ្រោះលើកយករូបខ្ញុំធ្វើជាមិត្តវិញដែរ” ។ កណ្តុរបានឮពាក្យសរសើររបស់ក្អែកឈ្មោះ **លឃុបតនកៈ**ហើយ ស្រែកសួរពីក្នុងព្រង់មកថា៖ “ចុះបងឈ្មោះអ្វី?” ។ ក្អែកឆ្លើយប្រាប់ថា៖ “ឈ្មោះ**លឃុបតនកៈ**ណ៎ាបង!” ។ ស្តេចកណ្តុរឮហើយអស់សំណើច សើចបណ្តើរនិយាយបណ្តើរថា៖ “យកបងជាក្អែកមកផ្អែកជាមិត្តម្តេចកើត? ព្រោះថា៖

៥៤- ក្នុងលោកនេះ អ្នកមានប្រាជ្ញាតែងធ្វើសមាគមចំពោះតែអ្នកដែលមានសភាពដូចគ្នាគួរចងជាមិត្តបាន ចុះបើខ្លួនខ្ញុំត្រូវជាចំណីអាហារ ឯខ្លួនបងជាអ្នកស៊ី ដូច្នេះតើគួរចងគ្នាធ្វើជាមិត្តម្តេចបាន?

៥៥- ការចងគ្នាជាមិត្ត រវាងអ្នកស៊ី និងអ្នកត្រូវគេស៊ី លោកពោលថា ហេតុនាំឲ្យវិបត្តិមិត្តភាពដូចជារឿងប្រើសជាប់អន្ទាក់ ព្រោះចចក បានក្អែកជួយស្រោចស្រង់ ។

ក្អែកសួរឡើងថា៖ “ចុះរឿងនោះ តើដូចម្តេច?” កណ្តុរ**ហិរណ្យកៈ**ចាប់ផ្តើមរៀបរាប់រឿងនោះដូចតទៅនេះ...

# កថាទី២

## រឿងប្រើស ចចក និង ក្អែក

ក្នុងប្រទេសមគធៈ មានព្រៃធំមួយឈ្មោះចម្បាកវតី ជាទីអាស្រ័យនៅនៃប្រើស និង ក្អែក សត្វ

---

[១] សេចក្តីស្លាប់ អ្នកកាន់សាសនាព្រាហ្មណ៍ ទុកជាទេវតាមួយអង្គ កាន់នាទីខាងការបំផ្លាញជីវិតសត្វ ។

ទាំងពីរនេះចងគ្នាជាមិត្តស្និទ្ធស្នេហា ស្រឡាញ់គ្នាយូរយារណាស់មកហើយ ។ ប្រើសតែងត្រេកត្រអាលចរទៅស្វែងរកស្មៅជាចំណីអាហារដោយទំនើងចិត្តតាមធម្មតា ជាវិស័យសត្វឥតមានខ្លាចក្រែងរអែងរអាអ្វីឡើយ រហូតដល់មានកាយធាត់ធំមាំមួនឡើងត្រឡុចឡុច ។ សម័យមួយ មិនដឹងជាទេសកាលអ្វីបណ្ដាលឲ្យឆ្កែចចកគំនិតភ្លាត់ខ្លួនឲ្យចចកឃើញ ។ ឯចចក លុះឃើញប្រើសហើយ ក៏ត្រេកអររកខិបកខុបនឹកត្រិះរិះគិតរកឧបាយថា៖ “ធ្វើដូចម្ដេចអេះ អាត្មាអញនឹងបានស៊ីសាច់ប្រើសមុខគួរឲ្យឆ្ងាញ់ណាស់នេះហ្ន៎? គង់បានកណ្ដាប់ដៃអញទេ ។ អាត្មាអញនឹងបញ្ឆោតបោកវៃអែបឲ្យស្និទ្ធ ទាល់តែស្គាប់ចិត្តជាមុនសិន” ។ ចចកគិតរកឧបាយឃើញហើយ ក៏ដើរចូលទៅសុំជួបនឹងប្រើស ស្រែកសួរពីចម្ងាយថា៖ “អីសម្លាញ់អើយ! អ្នកបានប្រកបដោយសេចក្ដីសុខសប្បាយឬទេ?” ។ ប្រើសបានឮហើយដណ្ដឹងសួរថា៖ “បងឈ្មោះអ្វី?” ចចកឆ្លើយប្រាប់ថា៖ “ឈ្មោះ**ក្សុទ្រពុទ្ធ**អាស្រ័យនៅនាព្រៃនេះ ឥតមានញាតិសន្ដានពឹងពាក់ទេ នៅត្រមង់ត្រមោចឯកោអនាថោតែម្នាក់ឯង ដូចជាមនុស្សស្លាប់ទៅហើយ, ពេលនេះ មានភ័ព្វសំណាងបានសាងមកជួបនឹងបង នាំឲ្យកើតសេចក្ដីស្រឡាញ់ពេញចិត្ត ហាក់ដូចជាបានចាប់កំណើតកើតក្នុងលោកនេះជាថ្មីម្ដងទៀត ហើយបានជួបជុំញាតិសន្ដានព្រៀងលានវិញ, តទៅរូបខ្ញុំសូមធ្វើជាមិត្តស្និទ្ធស្នាលជាមួយនឹងបង គ្រាន់បានជាទីពឹងពាក់បណ្ដើរគ្នាទៅមករកស៊ីតាំងពីពេលនេះតទៅ” ។ ប្រើសស្លុងចិត្តជឿ ហើយឆ្លើយថា៖ “មិនអីទេ! តាមចិត្តបងស្ម័គ្រចុះ” ។

ក្សិណនោះព្រះទិនករដ៏ជាទីគោរព មានរស្មីរុងរឿងត្រចះពណ្ណរាយ ទ្រង់បររថប្រទក្សិណភ្នំព្រះសុមេរុ រសៀលជ្រៀងជ្រេរទេរទន់ទាបរៀបនឹងអស្ដង្គតរលត់ចូលទៅកាន់សន្ធិយារាត្រី នៅនាភ្នំខាងបស្ចិមទិស សត្វទាំងពីរក៏លីលាបណ្ដើរគ្នាត្រសងទៅកាន់ទីលំនៅនៃប្រើស ។ កាលនោះ ក្អែកឈ្មោះ**សុពុទ្ធិ** ដែលជាមិត្តស្និទ្ធស្នេហានិងសត្វប្រើសមកអស់កាលយូរអង្វែងហើយ កំពុងទំអាស្រ័យនៅលើមែកចំបក់នោះ លុះឃើញសត្វទាំងពីរបណ្ដើរគ្នាមកដល់ ក៏សួរទៅថា៖ “ហៃសម្លាញ់**ចិត្រាង្គៈ**! អ្នកទីពីរនោះហ្ន៎! ត្រូវជាអ្វីនឹងបងឯង?” ។ ប្រើសឆ្លើយប្រាប់ថា៖ “ជាសត្វចចក ចូលមកសូមចងស្ពានមេត្រីរាប់អានយើង” ។ ក្អែកក៏ពោលឡើងថា៖ “នែសម្លាញ់! ការទុកចិត្តចងមេត្រីរាប់អានជាមួយអាគន្តុកៈមិនស្គាល់មុខដូច្នេះមិនល្អទេ ព្រោះថា៖

៥៦- អ្នកណានីមួយ មិនគួរគប្បីឲ្យទីអាស្រ័យនៅរួមគ្នាដល់មនុស្សមិនស្គាល់មុខ មានត្រកូលផ្សេងគ្នាឡើយ ដូចត្មាតឈ្មោះ**ជរទ្គវៈ**ត្រូវគេសម្លាប់បង់ ព្រោះទោសមកពីឆ្មា” ។

ប្រើស និងចចកសួរឡើងថា “រឿងនោះតើដូចម្ដេច?” ។ ក្អែកថ្លាថ្លែងរឿងនោះថា៖

# កថាទី៣

## រឿងត្មាត ឆ្មា និង បក្សី

នៅក្បែរត្រើយទន្លេគង្គា លើភ្នំគិជ្ឈកូដ មានជ្រៃមួយដើមធំត្រសុំសាខាដ៏ហើយដោយព្រង់ជាទីអាស្រ័យនៅនៃបក្សី និងត្មាតឈ្មោះ**ជរទ្គវៈ** ។ ដោយកម្មអាក្រក់តាមឲ្យផល ត្មាតនោះក៏ទៅជាខ្វាក់ងងឹតងងល់ក្រចករេចរឹលក្សិលអស់រលីង ។ ហ្វូងបក្សីជាតិទាំងឡាយដែលអាស្រ័យនៅនាដើមជ្រៃនោះ មានចិត្តអាណិតអាសូរ តែងរំលែកចែកអាហារខ្លួនបន្តិចៗម្នាក់ឲ្យដល់ត្មាតនោះ ជួយចិញ្ចឹមឲ្យមានជីវិតរស់នៅតទៅ ។ គ្រានោះ, មានឆ្មាមួយឈ្មោះ **ទីឃ៌កណ៌ៈ** ចូលមករកចាប់កូនបក្សីស៊ីជាចំណីអាហារនៅក្នុងព្រង់ឈើនោះ ។ កូនបក្សីទាំងឡាយកាលឃើញឆ្មាកំពុងដើរចូលមក ក៏ភិតភ័យរន្ធត់រត់ឆ្អែឆ្អាកោលាហលពេញទាំងព្រង់ ។ ត្មាតឈ្មោះ **ជរទ្គវៈ** បានឮសំឡេងអឺងកងខ្ទៀវខ្វាដូច្នោះ ក៏ស្រែកសួរទៅថា៖ “អាណាមកធ្វើអ្វីឲ្យជ្រួលច្របល់រចល់ដូច្នេះ?” ។ ឆ្មាសម្លឹងមើលទៅឃើញត្មាត ក៏តក់ស្លុតញាប់ញ័រត្រិះរិះគិតថា៖ “ឱអាត្មាអញ ដល់គ្រោះស្លាប់ហើយតើ” ព្រោះថា៖

៥៧- ដរាបណា ក្ដីភយន្តរាយមិនទាន់មកដល់ទេ ដរាបនោះបុគ្គលគប្បីប្រុងប្រយ័ត្នដល់ភ័យនោះ បើក្ដីភយន្តរាយមកដល់ហើយ បុគ្គលគប្បីក្លាហានតស៊ូនឹងភ័យនោះ តាមគំនិតខ្លួនដែលបានគិតទុកស្រេចហើយ ។

ឥឡូវនេះ អាត្មាអញចូលមកខកខ្លួនដល់ជិតក្ដីស្លាប់ហើយ នឹងដកខ្លួនថយរត់ទៅក្រោយវិញក៏មិនបាន ណ្ហើយចុះ បើមានការណ៍យ៉ាងណាកើតឡើងក៏តាមការណ៍ចុះ អាត្មាអញនឹងចូលទៅឲ្យដល់ត្មាតវៃអែបឲ្យស្និទ្ធជាមុនសិន ។ ឆ្មាគិតរកឧបាយឃើញដូច្នេះហើយ ក៏លោតចូលទៅជិតត្មាត ពោលពាក្យសំពះសួរថា៖ បពិត្រលោកអាយ៌ៈ! ខ្ញុំបាទសូមសំពះជម្រាបសួរលោក” ។ ត្មាតសួរថា៖ “ឯងជាអ្វី?” ឆ្មាឆ្លើយតបទៅវិញថា “ខ្ញុំបាទជាសត្វឆ្មា” ។ ត្មាតនិយាយកំហែងថា៖ “នែអាសត្វចង្រៃ! ចូរថយចេញឲ្យឆ្ងាយទៅ បើមិនថយចេញទេ អាឯងត្រូវគ្រោះស្លាប់ឥឡូវមិនខាន” ។ ឆ្មានិយាយអង្វរកថា “សូមលោកស្ដាប់ពាក្យខ្ញុំបាទសិន កាលបើលោកស្ដាប់ពាក្យខ្ញុំបាទហើយ ឃើញថាគួរសម្លាប់កាលណា ខ្ញុំបាទក៏សុខចិត្តស្លាប់ឥតប្រកែកកាលនោះ, ព្រោះថា៖

៥៨- ហេតុអ្វីក៏ស្រាប់តែត្រូវគេកាប់សម្លាប់ ឬ ត្រូវគេបូជាដល់អ្នកណានីមួយ តាមតែជាជាតិអ្វីក៏ដោយតែម្ដង គួរតែពិចារណាឲ្យជុំវិញខ្លួន មើលឲ្យឃើញច្បាស់សេចក្ដីប្រព្រឹត្តរបស់គេសិន សឹមយល់ជាគួរសម្លាប់ ឬពុំនោះ គួរបូជា ។

ត្អាតស្តាប់ហើយនិយាយថា៖ “មើល៍! និយាយមកមើលអាឯងចូលមកនេះត្រូវការរកអ្វី?” ។ ឆ្មាឆ្លើយប្រាប់ថា៖ “ខ្ញុំបាទនៅក្បែរត្រើយទន្លេគង្គានេះឯង ប្រព្រឹត្តមុជទឹកលាងបាបជានិច្ច ប្រព្រឹត្តព្រហ្មចរិយធម៌ជាប្រក្រតី មិនប៉ានស៊ីសាច់ឈាមទេ សមាទានតែចន្ទ្រាយណព្រត([1]) ខ្ញុំបាទបានឮហ្វូងបក្សីជាតិ សរសើរកិត្តិគុណលោក ចំពោះមុខខ្ញុំបាទជារឿយៗថា លោកជាអ្នកចេះដឹងច្រើន ចិត្តធ្ងន់ក្នុងធម៌ល្អមទុកចិត្តស្និទ្ធស្នេហាយកជាវិស្សាសភូមិ, ហេតុនេះ បានជាខ្ញុំបាទមានចិត្តត្រេកអរ ចង់ចូលមកត្រងត្រាប់ស្តាប់ធម៌រៀនវិជ្ជា ច្បាប់គតិលោក គតិធម៌អំពីសំណាក់លោក ដែលជាបុគ្គលចាស់ព្រឹទ្ធាចារ្យ មានការចេះដឹងស្ទាត់ជំនាញ ប្រសប់ប៉ុនប៉ាវក្នុងវិជ្ជាផ្សេងៗ ហេតុអ្វីក៏លោកដែលជាអ្នកចេះធម៌អាថ៌ជ្រាលជ្រៅប្រាកដយ៉ាងនេះ បែរទៅជារករឿងកាប់សម្លាប់ខ្ញុំបាទដែលជាភ្ញៀវទៅវិញ ព្រោះធម៌ជានាទីអ្នកគ្រប់គ្រងផ្ទះនេះលោកពោលថាដូច្នេះ៖

៥៩- បុគ្គលគប្បីព្រមធ្វើបដិសណ្ឋារៈ ទទួលភ្ញៀវដែលមកដល់ផ្ទះហើយ ទោះបីភ្ញៀវជាសត្រូវក៏ដោយ ដូចព្រឹក្សាជាតិ តែងឲ្យម្លប់ជាទីសំចតមិនរើសមុខ សូម្បីអ្នកកាប់ឈើក៏ដោយ ។

បើទុកជាខ្សត់ខ្សោយទ្រព្យ មិនមានចំណីអាហារទទួលភ្ញៀវដែលមកដល់ ដោយហោចទៅ ក៏គួររាប់អានរាក់ទាក់ទទួលភ្ញៀវ ដោយសម្តីពីរោះជាទីត្រេកអរដែរ, ព្រោះថា៖

៦០- ស្មៅ (ឬចំបើងសម្រាប់អុជបំភ្លឺ) ភូមិទីលំនៅ ទឹក និងសម្តីពីរោះផ្អែមល្ហែម ធម៌៤ប្រការនេះ ក្នុងកាលណាក៏ដោយមិនដែលខ្វះខាតរលីបរលាប ក្នុងផ្ទះលោកអ្នកសប្បុរសទាំងឡាយទេ ។

៦១- ([2])លោកសប្បុរសទាំងឡាយតែងសម្តែងមេត្តាករុណាចំពោះសត្វទាំងឡាយមិនរើសមុខ សូម្បីបុគ្គលថោកទាបក៏ដោយ ដូចជាព្រះចន្ទ្រនឹងថាកំណាញ់ពន្លឺមិនឲ្យដល់លំនៅជនចណ្ឌាល ក៏ឥតអង្គីមានឡើយ ។

៦២- ភ្ញៀវវិលត្រឡប់ចេញពីផ្ទះអ្នកណា ដោយក្តីក្តៅក្រហាយចិត្ត ភ្ញៀវនោះឈ្មោះថាប្រគល់ឲ្យ

---

[1] ការប្រតិបត្តិវត្តតាមដំណើរព្រះចន្ទ្រតាមទំនៀមប្រទេសឥណ្ឌា ។ ព្រតនេះមានច្រើនបែប, ព្រតដែលគេប្រតិបត្តិដោយច្រើននោះគឺការប្រព្រឹត្តបរិភោគបាយ ១៥ពំនូតនៅថ្ងៃ ១៥កើត ហើយ បន្ថយ១ថ្ងៃ ១ពំនូតទៅខាងរនោចគឺថ្ងៃទី២ បរិភោគ១៤ពំនូត ធ្វើដូច្នេះរៀងរាល់ថ្ងៃដល់ទី ១៥ គេអត់អាហារ ។ ដល់ខាងខ្នើតថ្ងៃ ១កើត គេបរិភោគបង្កើត១ពំនូតវិញ គឺថ្ងៃទី ១ បរិភោគ ១ពំនូត ថ្ងៃទី២ បរិភោគ ២ពំនូត ធ្វើដូច្នេះរៀងទៅដល់ថ្ងៃទី ១៥កើត គេបរិភោគ ១៥ពំនូត ។

[2] ហិតោបទេស សេចក្តីប្រែជាភាសាបារាំង របស់លោកឡង់ស៊ីរ៉ូ និងសេចក្តីប្រែជាភាសាសៀមរបស់លោកនាគប្រទីប មានគាថាលើសដូច្នេះគឺ ទោះបីក្មេងកំលោះ ក្រមុំ ឬចាស់ព្រឹទ្ធាចារ្យ ដែលមកដល់ផ្ទះហើយ បុគ្គលត្រូវតែជ្រះថ្លាទទួលរាក់ទាក់ដោយការរាប់អានយ៉ាងខ្ពង់ខ្ពស់ ព្រោះក្នុងលោកនេះ គេទុកភ្ញៀវជាបុគ្គលខ្ពង់ខ្ពស់ជាងជនទាំងពួង ។

នូវបាប អពមង្គល ដល់អ្នកម្ចាស់ផ្ទះនោះ ហើយកាន់យកនូវបុណ្យសិរីសួស្តីត្រឡប់ទៅវិញ ។

៦៣- បុគ្គលមានគោត្រកូលឧត្តមខ្ពង់ខ្ពស់ ហើយមានភ្ញៀវត្រកូលថោកទាបមកដល់ផ្ទះហើយ ក៏គួរតែគោរពបូជា តាមគួរដែលអាចទទួលបាន ព្រោះភ្ញៀវទាំងអស់សុទ្ធតែទេវតា ។

ត្មាតនិយាយកាត់ថា៖ "ឱ្យឈ្មោះតែឆ្មាហើយ សុទ្ធតែជាសត្វចូលចិត្តស៊ីសាច់ជាអាហារទាំងអស់ នៅក្នុងព្រង់ដើមឈើនេះ មានសុទ្ធតែកូនបក្សីអាស្រ័យនៅ ហេតុនេះកូវ បានជាអញនិយាយហាមឃាត់យ៉ាងនេះ" ។ ឆ្មាស្តាប់ពាក្យត្មាតហើយ ក៏ស្រពោនខិនដាក់មុខយកជើងមុខស្ទាបត្រចៀកទាំងសងខាង ក្រាបសំពះនិយាយបញ្ជាក់ថា៖ "ខ្ញុំបាទបានសិក្សាគម្ពីរធម្មសាស្ត្រចប់អស់ជើងហើយ បានប្រព្រឹត្តធម៌ លះបង់រាគៈ ទោសៈ មោហៈ សមាទានចន្ទ្រាយណព្រត ជាទុក្ករកម្មដ៏ក្រៃលែង សូម្បីគម្ពីរធម្មសាស្ត្រទាំងឡាយ ដែលមានសេចក្តីខ្លះប្លែក គេតែងជជែកវែកញែកគ្នាទៅវិញទៅមក ក៏គង់រួមគោលសេចក្តីធំដើមមកនៅត្រឹមតែមួយម៉ាត់គឺ៖ "អហឹសា ការមិនបៀតបៀន" ថាជាធម៌ដ៏ប្រសើរ ក្រៃលែង, ព្រោះថា៖

៦៤- នរជនណា មិនបៀតបៀនសព្វសត្វទាំងឡាយឱ្យក្តៅក្រហាយ មានព្យាយាមអត់ធន់ចំពោះការងារទាំងពួង និងជាទីពឹងពំនាក់អាស្រ័យនៃសព្វសត្វ នរជននោះឈ្មោះថា កសាងស្ពានទៅកាន់ស្ថានសួគ៌ ។

៦៥- មានតែធម៌មួយទេ លោកហៅថា "មិត្តធម៌" ដែលជាប់ជិតតាមជាមួយខ្លួនទៅក្នុងពេលស្លាប់ ឯអវៈអយៈ ដទៃទៀត សុទ្ធតែដល់នូវក្តីវិនាសអន្តរាយជាមួយនឹងសរីរាងកាយទាំងអស់ ។

៦៦- កាលបើអ្នកនឹងស៊ីសាច់គេ គួរពិចារណាមើល អ្នកស៊ីសាច់គេ និងសាច់គេដែលអ្នកត្រូវស៊ី ឱ្យឃើញប្លែកគ្នាទាំងសងខាងសិនថា អ្នកម្ខាងបានឆ្អែត មានបីតិរីករាយតែក្នុងមួយខណៈប៉ុណ្ណោះ ឯអ្នកម្ខាងទៀតនោះត្រូវបាត់បង់ជីវិត ។

៦៧- នរជន តែងមានសេចក្តីទុក្ខព្រួយ ដោយគិតឃើញថា "ខ្លួនត្រូវគេសម្លាប់" កាលបើគិតឃើញដូច្នេះគ្រប់គ្នាហើយ និយាយថ្វីដល់ទៅមិត្ត សូម្បីសត្រូវក៏អាចជួយការពារជីវិតបាន ។

៦៨- បុគ្គលគប្បីបំពេញផ្ទៃខ្លួនឯង ដោយបន្លែជារុក្ខាលតាជាតិ ដែលដុះក្នុងព្រៃតាមទំនើងវាបាន ហេតុអ្វីចាំបាច់កាប់សម្លាប់គេដ៏អាក្រក់ក្រៃលែង ដើម្បីបំពេញផ្ទៃខ្លួនដែលគ្រាន់តែស្រេកឃ្លានប៉ុណ្ណោះ?

កាលឆ្មា វិឡារជាតិ និយាយបន្ទន់ចិត្តត្មាតឱ្យជឿទុកចិត្តហើយ ក៏សរសៀចូលទៅក្នុងព្រង់ជ្រៃនោះបាន ។ លំដាប់មក ឆ្មាចាប់កូនបក្សីក្នុងព្រង់យកមកហែកជញ្ជែងស៊ីជាចំណីអាហាររាល់ៗថ្ងៃ ឯមេបក្សីទាំងឡាយលុះឆ្មាស៊ីកូនអស់ហើយ ក៏សោកសង្រេងសង្រែងយំខ្សៀវខ្សា រត់ឆ្កេឆ្កាទៅខាងនេះទៅខាងនោះ ប្រជុំគ្នាស៊ើបសួររកដំណើរដើមទងនៃការបាត់បង់កូន ។ ឯឆ្មា លុះបានដឹងរឿងនោះហើយ ក៏បោល

ចេញពីព្រង់រត់ទៅខាងក្រៅបាត់ភ្លាម ។ ក្រោយដែលឆ្មារត់បាត់ទៅបក្សីទាំងឡាយបបួលគ្នាគយគន់មើលខាងនេះខាងនោះ ប្រទះឃើញតែឆ្អឹងកូននៅក្នុងព្រង់ដើមជ្រៃនោះ ក៏ចោទប្រកាន់ត្មាតចាស់នោះថា "ត្មាតខ្វាក់កញ្ចាស់នេះឯង ដែលស៊ីកូនរបស់យើង" ទើបបក្សីទាំងអស់នោះមូលមតិគ្នា សម្លាប់ត្មាតចាស់ចោលបង់សៀតពួដកាលនោះទៅ ។ ហេតុនោះបានខ្ញុំ (ក្អែកឈ្មោះ**សុពុទ្ធិ**) ពោលថា៖ "អ្នកណានីមួយ មិនគួរគប្បីឲ្យទីអាស្រ័យនៅរួមគ្នា ដូច្នេះជាដើម(៥៦) ។

កាលនោះ ចចកបានស្តាប់ក្អែកនិយាយមកត្រូវគំនិតខ្លួនហើយ ក៏ក្រេវក្រោធច្រឡោតខឹង និយាយស៊កតបទៅវិញថា៖ "កាលបងឯង និងប្រើសបានមកជួបប្រទះគ្នាជាបឋមនោះ រូបរាងក៏មិនបានស្គាល់វង្សត្រកូល និងចិត្តថ្លើមបងក្អែកដែរ ហើតុអ្វីក៏បងឯងចេះស្នេហាស្រឡាញ់គ្នាស្និទ្ធស្នាលរហូតមកកើត?

៦៩- ទីឋានណា មិនមានអ្នកប្រាជ្ញរាជបណ្ឌិត ទីឋាននោះសូម្បីមានតែអ្នកចេះដឹងបន្តិចបន្តួច ក៏គួរលើកតម្កើងសរសើរ ដូចជាប្រទេសណានីមួយ ដែលឥតមានព្រឹក្សាជាតិ បើមានតែដើមល្ហុង ក៏លោកសន្មត់ថាជាដើមឈើបានដែរ ។

៧០- អ្នកនេះជាពួកយើង អ្នកនោះជាពួកគេ នេះជាសម្តីអ្នកមានចិត្តគំនិតស្រាលទេ ឯអ្នកដែលមានការសិក្សាច្រើនមានចិត្តគំនិតល្អតែងនិយាយថា អ្នកនៅលើផែនពសុធា សុទ្ធតែជាផៅពង្សនឹងគ្នាទាំងអស់" ។

ប្រើសនេះជាផៅពង្សរូបខ្ញុំយ៉ាងណា បងឯងក៏យ៉ាងនោះដែរ ។ ប្រើសឆ្លើយ៖ "និយាយជជែកតវ៉ាគ្នាតទៅទៀត បានប្រយោជន៍អ្វី? ចូរយើងទាំង៣នាក់ នៅជាសុខសប្បាយក្នុងទីនេះជាមួយគ្នា ជាមិត្តស្និទ្ធស្នាលតទៅ, ព្រោះថា៖

៧១- នឹងថាអ្នកណាជាមិត្តអ្នកណាក៏ពុំទាន់បាន នឹងថាអ្នកណាជាសត្រូវនឹងអ្នកណាក៏ពុំទាន់បាន ដោយអំពើដែលគេប្រព្រឹត្ត ទើបគេស្គាល់គ្នា "អ្នកនេះជាមិត្ត អ្នកនោះជាសត្រូវ" ។

ក្អែកនិយាយចាក់បណ្តោយតាមថា៖ "យ៉ាងនេះក៏បាន" ។ លុះព្រឹកព្រាងស្វាងឡើង សត្វទាំងបីបបួលគ្នាទៅស្វែងរកចំណីអាហារតាមទីឋានដែលខ្លួនគាប់ចិត្ត ។ ថ្ងៃមួយ ចចកនិយាយនឹងប្រើសដោយសម្ងាត់ថា៖ "សម្លាញ់អើយ! នៅក្នុងព្រៃមួយនោះមានស្រែមួយពេញដោយសន្ទូងលាស់ខៀវខ្ចី រូបខ្ញុំនឹងនាំសម្លាញ់ភក្តិទៅបង្ហាញសន្ទូងក្នុងស្រែនោះ" លុះចចកបង្ហាញស្រែនោះហើយ ប្រើសទៅរកស៊ីសន្ទូងក្នុងស្រែនោះតែរាល់ថ្ងៃ ។ កាលនោះអ្នកស្រែបានឃើញប្រើស ចេះតែចូលទៅស៊ីសន្ទូងក្នុងស្រែខ្លួន ក៏គ្នាន់ក្នាញ់មួម៉ៅក្នុងចិត្តណាស់ ទើបធ្វើអន្ទាក់ដាក់ប្រើសនោះ ។ តមកមិនយូរប៉ុន្មាន ប្រើសមកស៊ីសន្ទូងក្នុងស្រែនោះទៀតត្រូវអន្ទាក់ជាប់រើខ្លួនមិនរួច ទើបត្រិះរិះគិតថា៖ "ក្រៅពីមិត្ត, នរណាហ្ន៎ អាចជួយដោះទុក្ខ

អាត្មាអញចេញពីអន្ទាក់ព្រាន ដែលទុកដូចជាអន្ទាក់នៃព្រះកាលនេះបាន? កាលប្រើសកំពុងរិតក្កដូច្នេះ ចចកដើរមកដល់ជិត នឹកសប្បាយក្នុងចិត្តថា៖ "ឧបាយកលរបស់អាត្មាអញបានសម្រេចផលតាមបំណង ហើយតើ! កាលបើអ្នកស្រែពន្លះប្រើសនេះអាត្មាអញត្រូវបានឆ្អឹង ដែលជាប់ដោយសាច់ និងឈាមដោយពិតឥតសង្ស័យឡើង អាត្មាអញនឹងបានភោជនាហារឆ្ងាញ់ពិសាយ៉ាងច្រើនបរិភោគមិនខាន" ។ ឯប្រើស លុះឃើញចចកមកដល់ហើយក្រោកឈរឡើងសប្បាយចិត្តឥតឧបមា ស្រែកប្រាប់ថា៖ "អើសម្លាញ់អើយ! ចូរសម្លាញ់អាណិតកាត់អន្ទាក់នេះឆាប់ៗ ដើម្បីឲ្យខ្ញុំបានរួចខ្លួន, ព្រោះថា៖

៧២- គេដឹងចិត្តមិត្តក្នុងគ្រាក្រ, ដឹងចិត្តទាហានក្លៀវក្លាក្នុងសង្គ្រាម ដឹងចិត្តស្មោះត្រង់ក្នុងការសងបំណុលគេ, ដឹងចិត្តភរិយា ក្នុងពេលខ្សត់ទ្រព្យ និងដឹងចិត្តផៅពង្សក្នុងគ្រាវិនាសអន្តរាយ ។

៧៣- អ្នកណាមិនលះបង់មិត្តក្នុងគ្រាមានទុក្ខ ក្នុងគ្រាអន្តរាយ ក្នុងគ្រាទុរភិក្ស ក្នុងគ្រារាស្ត្រចលាចល ក្នុងទ្វារព្រះរាជា និងក្នុងអង្គព្រៃស្មសាន, អ្នកនោះលោកហៅថាផៅពង្ស" ។

ចចកសម្លឹងមើលអន្ទាក់ មើលហើយមើលទៀតច្រើនដងឃើញថាអន្ទាក់នេះជាប់មាំមួនណាស់ ទើបនិយាយថា៖ "សម្លាញ់អើយ! អន្ទាក់នេះធ្វើពីសរសៃសត្វ ថ្ងៃនេះជាភដ្ដារកវារ([1]) ខ្ញុំយកធ្មេញទៅឲ្យប៉ះពាល់អន្ទាក់សរសៃសត្វដូចម្ដេចកើត? ណ្ហើយសម្លាញ់! ខំអត់ទ្រាំបន្តិចទៅសិនចុះ ថាបើចិត្តបងមិនមានគិតអ្វីដទៃផ្សេងទេ ចាំព្រឹកព្រាងស្អែកឡើង, ពេលនោះ បើបងប្រាប់ឲ្យធ្វើយ៉ាងណា ខ្ញុំនឹងធ្វើតាមចិត្តបងមិនខាន" ។ ចចកថាដូច្នោះហើយ ចូលទៅលាក់ខ្លួនពួនអាត្មាសំងំក្នុងព្រៃស៊ុបទ្រុបជិតខាងនោះទៅ ។ ផ្លែងពីក្អែក លុះវេលារសៀលជ្រៀងជ្រេរទេរទន់ទាបព្រះទិនករ ក្រឃើញប្រើសវិលត្រឡប់មកលំនៅវិញ ក៏ហើរឆ្វេឆ្វាតាមរកខាងនេះខាងនោះ រកទៅៗបានឃើញប្រើសមានគ្រោះជាប់អន្ទាក់ទើបសួរទៅថា៖ "ហៃសម្លាញ់! ហេតុអ្វីក៏ជាប់អន្ទាក់ធ្លាក់កដូច្នេះ?" ប្រើសបានស្ដាប់ពាក្យក្អែកហើយ ឆ្លើយប្រាប់ថា៖ "អំពើនេះ ជាផលនៃការមើលងាយពាក្យសម្ដីមិត្តនេះឯង ព្រោះថា៖

៧៤- នរជនណា មិនជឿស្ដាប់ភាសិតមិត្តសម្លាញ់ដែលប្រាថ្នាធ្វើប្រយោជន៍ឲ្យ ក្ដីភយន្តរាយស្ថិតនៅជិតអ្នកនោះ នរជននោះឈ្មោះថា ធ្វើសេចក្ដីត្រេកអរដល់សត្រូវ ។

ក្អែកសួរប្រើសថា៖ "ចុះអាចចកចង្រៃបោកប្រាស់គេនោះ វាទៅនៅឯណាហើយ?" ។ ប្រើសប្រាប់ថា៖ "វាទៅពួនសំងំនៅក្នុងព្រៃស៊ុបទ្រុបនោះឯង ដើម្បីចាំស៊ីសាច់ខ្ញុំ" ។ ក្អែកនិយាយសើរើរឿងដើមមកពោលថា៖ "អើ! ដូចខ្ញុំបានដាស់តឿនបងតាំងពីដើមមកហើយ" ។

---

[1] ថ្ងៃព្រះជាម្ចាស់សួគ៌ គឺថ្ងៃអាទិត្យគេកាន់សីលតមមិនធ្វើបាប មិនពាល់សាច់ ។

៧៥- បើមានអ្នកណានីមួយនិយាយថា៖ "ខ្ញុំមិនមានចិត្តអាក្រក់ព្យាបាទទេ ដូច្នេះក៏ដោយ បុគ្គលមិនគួរជឿពាក្យនេះ យកជាហេតុមេត្រីស្និទ្ធស្នាលឡើយ សេចក្តីពិត អ្នកដែលមានគុណ គឺការចេះដឹងច្រើន ក៏តែងមានភ័យកើតមកពីមនុស្សទុច្ចរិតទាំងឡាយដែរ ។

៧៦- មនុស្សស្លាប់ មិនធុំក្លិនផ្សែងចង្កៀងដែលគេលត់ ស្តាប់មិនឮពាក្យដាស់តឿនមិត្តសម្លាញ់ មើលឃើញផ្កាយអរុន្ធតី([២]) ។

៧៧- បុគ្គលគប្បីវៀរមិត្ត ដែលប៉ងបំផ្លាញការងារក្នុងទីកំបាំងមុខ ហើយនិយាយពាក្យពីរោះផ្អែមល្ហែមក្នុងទីចំពោះមុខ មិត្តបែបនេះប្រៀបដូចឆ្នាំងដ៏ពេញដោយពិសពុល មានមាត់ប្រឡាក់ដោយទឹកដោះផ្អែម" ។

ខណៈនោះ ក្អែកតានតឹងចិត្តស្ទើរប្រេះទ្រូង ដកដង្ហើមវែងឃ្យូរៗនិយាយថា៖ "ឱអាចង្រៃបោកប្រាស់នេះ! ម្តេចក៏អាឯងហ៊ានធ្វើកម្មអាក្រក់អ្វីម៉្លេះ? ព្រោះថា៖

៧៨- ក្នុងលោកនេះ បើគេនិយាយឲ្យស្តាប់ចិត្ត ដោយប្រើពាក្យផ្អែមល្ហែមដូចទឹកឃ្មុំ បើគេធ្វើឲ្យលុះក្នុងអំណាច ដោយឧបាយមច្ឆាចារ គេមិនបញ្ឆោតបោកបាន? ឱគួរសង្វេគណាស់! ។

៧៩- ឱព្រះម្ចាស់ផែនពសុធាដ៏មានបុណ្យអើយ! ហេតុអ្វីក៏លោកព្រមទទួលមនុស្សបោកគេ ចិត្តបាបអាក្រក់ក្រៃលែងមិនដឹងឧបការគុណគេ ដែលគេប្រគល់ជំនឿ គឺគេជឿទុកចិត្តអស់ពីពោះពុង នឹងដែលគេមានចិត្តបរិសុទ្ធ ឲ្យនៅលើផ្ទៃផែនដីនេះដូច្នេះ?

៨០- បុគ្គលកុំគប្បីចងមិត្តសម្លាញ់ ឬ ចងស្ពានមេត្រីមួយអន្លើដោយមនុស្សទុជ៌នឲ្យសោះ ដូចជាធ្យូង បើនៅក្តៅរលាកដៃ បើរលត់ហើយ វាប្រឡាក់ដៃ ។

ពាក្យទាំងនេះ ជាលក្ខណៈនៃមនុស្សទុជ៌ន ។

៨១- នៅមុខអ្នក វាសំពះលុតក្រាបជិតបាតជើង នៅក្រោយអ្នកវាបេះសាច់ឆ្អឹងជំនីរស៊ី វានិយាយសម្តីទន់ផ្អែមល្ហុកល្ហិន មានលែបខាយដ៏វិចិត្រ ល្ហឹមៗ ជិតត្រចៀកអ្នក បើមានចម្លោះ លូកចូលទៅបេះយកថ្លើមប្រមាត់មួយរំពេច ឥតកោតញញើតឡើយ, សត្វរុយវាចេះធ្វើត្រាប់លក្ខណៈមនុស្សចិត្តអាក្រក់សាមាន្យបានទាំងអស់ ។

៨២- មនុស្សទុជ៌ន និយាយពាក្យពីរោះគួរជាទីពេញចិត្ត តែមិនត្រូវយកជាហេតុមកធ្វើសេចក្តីស្និទ្ធស្នាល ព្រោះតែសម្តីពីរោះនោះទេ ប្រៀបដូចទឹកឃ្មុំជាប់នៅចុងអណ្តាត ក្នុងចិត្តពេញដោយពិសពុល

---

[២] ផ្កាយព្រឹក ។

ដ៏ក្ដៅក្រហាយរោលរាល ។

លុះព្រឹកព្រាងស្វាងឡើង ក្អែក**សុពុទ្ធិ**នោះ ឃើញអ្នកស្រែកាន់ដំបងងងាសដើរមកដល់ ទើបស្រែកទៅប្រើសថា៖ “អើបងប្រើសសម្លាញ់អើយ! អ្នកស្រែមកដល់ហើយ ចូរបងដេកពុតក្លែងជាស្លាប់ទៅ ធ្វើភ្នែកស្ទឹង បំប៉ោងពោះឲ្យធំ ជើងឲ្យរឹងស្លក ហើយនៅឲ្យស្ងៀមនឹងថ្កល់ ។ ដរាបណាខ្ញុំស្រែកប្រាប់ឲ្យសញ្ញា ដរាបនោះចូរបងក្រោកភ្លាមយ៉ាងរហ័ស ហើយស្ទុះរត់បោលឲ្យអស់ទំហឹង ។ ឯប្រើសលុះបានស្ដាប់ពាក្យក្អែកហើយ ក៏ពុតក្លែងធ្វើជាស្លាប់ដូចសម្ដីក្អែកប្រាប់ នៅនឹងថ្កល់ ។ ថ្លែងឯអ្នកស្រែដើរមកដល់ យល់ប្រើសជាប់អន្ទាក់ស្លាប់ក្រញូង់ដូច្នោះ បើកភ្នែកក្រឡោតធំៗ រីករាយសប្បាយចិត្តណាស់ លាន់មាត់ថា៖ “អេះប៉ៃអាតាយហោង អាឯងស្លាប់ខ្លួនឯងហើយតើ!... ពោលដូច្នេះហើយក៏ស្រាយអន្ទាក់ចេញពីប្រើស ដោះរួចស្រេច ភ្លេចខ្លួនអាល័យតែរៀបចំអន្ទាក់ ស្រាប់តែក្អែកស្រែកឲ្យសញ្ញាក្វកៗ ប្រើសក៏ក្រោកឡើងស្ទុះបោលផ្ដោះប្រិចដូចគេបោះព្ធយលឿនស្ទៅសំដៅព្រៃប្រោក ឯអ្នកស្រែស្រឡាំងកាំង ក៏ស្ទុះរលះរលាំងទៅចាប់បានដំបងគ្រវែងចោលប្រួសសំដៅទៅប្រើសនោះភ្លាម ហេតុតែកម្មតាមទាន់ ពានទៅត្រូវចចកម៉ោក ដួលស្លាប់ហីនហោចទៅហោង ។ បានជាលោកពោលទុកថា៖

៨៣- បុណ្យបាបដែលបុគ្គលធ្វើទុកក្នុងលោកនេះ មានកម្លាំងប្លែកចម្លែកអស្ចារ្យណាស់ តែងឲ្យផលតបស្នងវិញយ៉ាងយូរ៣ឆ្នាំ ឬក៏៣ខែ ពុំនោះ ៣កប្ប បើពុំនោះត្រឹម ៣ថ្ងៃ ។

ព្រោះហេតុនោះបានជាខ្ញុំ (កណ្ដុរ**ហិរញ្ញកៈ**) និយាជាភាសិតទុកខាងដើមថា៖ “ការចងគ្នាជាមិត្តរវាងអ្នកស៊ី និងអ្នកត្រូវគេស៊ី” ដូច្នេះជាដើម (៥៥) ។

ក្អែកឈ្មោះ**លឃុបតនកៈ**ឆ្លើយឡើងថា៖

៨៤- ឱសម្លាញ់ជាអ្នកនិរទុក្ខដូចស្ដេចព្រាប**ចិត្រគ្រីព** បើខ្ញុំស៊ីបងជាអាហារ ខ្លួនបងតូចម្ល៉េះមិនស្កប់ផ្ទៃខ្ញុំទេ កាលបើបងរស់នៅ ខ្ញុំក៏ឈ្មោះថារស់នៅដែរ ។

៨៥- ទោះបីសត្វតិរច្ឆាន ដែលប្រព្រឹត្តល្អតែម្យ៉ាង វិស្សាសនៈស្និទ្ធស្នាល អាចធ្វើឲ្យគេឃើញជាក់ស្ដែងបាន ដូចសភាពលោកសប្បុរសទាំងឡាយ នឹងថាវិលត្រឡប់ទៅផ្សេង ក៏ឥតអង្គឹមាន ព្រោះលោកមានសភាពជាសប្បុរសជាប្រក្រតី ។

៨៦- សន្ដានចិត្តលោកសប្បុរសទាំងឡាយ សូម្បីមានសេចក្ដីក្រេវក្រោធកើតឡើង ក៏មិនប្រែប្រួលអាកប្បកិរិយា ដូចជាគេមិនអាចយកគុបស្មៅមួយគុប ទៅដុតកំដៅទឹកសមុទ្រសាគរឲ្យក្ដៅពុះពោរបានឡើយ ។

កណ្ដុរឈ្មោះ**ហិរញ្ញកៈ**បានស្ដាប់ហើយ ក៏និយាយទៅវិញថា៖ “បងឯងនេះជាសត្វចិត្តរបិល

រប៉ូចខិលខូចណាស់ បុគ្គលមិនគប្បីចងជាមិត្តស្និទ្ធស្នេហាជាមួយនឹងសត្វរបិលរប៉ូចដូច្នេះទេ ព្រោះថា៖

៨៧- ឆ្មា១ ក្របី១ ចៀម១ ក្អែក១ និងមនុស្សចិត្តអាក្រក់១ ទាំង៥ពួកនេះ បានសេចក្តីចម្រើនរុងរឿង ព្រោះអាងស្មៀតរើរអែបធ្វើវិស្សាសៈស្និទ្ធស្នាល ព្រោះហេតុនោះ បុគ្គលមិនគួរគប្បីប្រគល់ឲ្យនូវវិស្សាសៈស្និទ្ធស្នាលចំពោះបុគ្គលទាំង៥ ពួកនោះឡើយ ។

៨៨- បើជាសត្រូវហើយ បុគ្គលកុំគប្បីចងមេត្រីជឿទុកចិត្តយ៉ាងជិតស្និទ្ធឲ្យសោះ ដូចជាទឹក ទុកជាពុះខ្លាំងគគ្រឹកៗក៏អាចរំលត់ភ្លើងបាន ។

៨៩- រីមនុស្សទុជ៌ន សូម្បីប្រដាប់ខ្លួនដោយគ្រឿងអម្ពរគឺចំណេះវិជ្ជា ក៏បុគ្គលគប្បីចៀសវាងចេញឲ្យផុត ដូចសត្វអាសិរពិស សូម្បីប្រដាប់ដោយកែវមណី វានឹងមិនធ្វើឲ្យយើងមានភ័យឬអ្វី?

៩០- របស់ណាមិនអាច របស់នោះនៅតែមិនអាចពិតប្រាកដ របស់ណាអាច របស់នោះនៅតែអាចពិតប្រាកដ ដូចជារទេះបរទៅលើទឹកមិនបានទេ ឯទូក អុំលើគោក ក៏ទៅមិនបានដូច្នេះដែរ ។

៩១- នរជនណាទៅចងចិត្តស្និទ្ធស្នាលនឹងសត្រូវ ឬនឹងភរិយា ដែលមិនមានចិត្តប្រតិព័ទ្ធខ្លួនដោយអាងថាមានទ្រព្យសម្បត្តិច្រើន ជីវិតនរជននោះ ឈ្មោះថាចូលទៅដល់ទីបំផុតខេត្តត្រឹមនោះហើយ ។

ក្អែកពោលតបទៅវិញថា៖ "ខ្ញុំបានស្តាប់សម្តីបងនិយាយសព្វគ្រប់អស់ប៉ុណ្ណឹងហើយ ក៏ដូចជាឃើញថាបងមិនព្រមព្រៀងសោះ តែទោះជាយ៉ាងណា ក៏ខ្ញុំបានតាំងចិត្តទុកជាមុនរួចហើយ ថានឹងយកបងធ្វើជាមិត្តស្និទ្ធស្នេហាពិតប្រាកដឥតសង្ស័យឡើយ ថាបើមិនដូច្នោះទេ រូបខ្ញុំនឹងអត់អាហារ បោកខ្លួនសម្លាប់នៅមាត់ព្រង់បងឲ្យស្លាប់ចោលបង់សៀតទៅល្អជាង, ព្រោះថា៖

៩២- មនុស្សទុជ៌នចិត្តអាក្រក់សាមាន្យ ប្រៀបដូចឆ្នាំងដីបែកបាក់ប្រេះឆាក៏ឆាប់រហ័សណាស់ ដល់តវិញមិនជាប់ទេ ឯលោកសាធុជនចិត្តសប្បុរស ប្រៀបដូចឆ្នាំងមាស មិនងាយបាក់បែកប្រេះឆាទេ ដល់ផ្សារភ្ជាប់វិញក៏ងាយជាប់ ។

៩៣- ជាតិលោហធាតុទាំងអស់ រលាយចូលគ្នាបាន ព្រោះដែកមានការរលាយជាលក្ខណៈ ម្រឹគបក្សីទាំងឡាយ រួបរួមចូលជាហ្វូងបាន ព្រោះមានរូបរាងសណ្ឋានជាលក្ខណៈ មនុស្សល្ងង់ រួបរួមគ្នាបាន ព្រោះមានភ័យ និងលោភជាលក្ខណៈ, ឯសាធុជនមានមហាគុ្ណ រួបរួមចូលគ្នាបាន ដោយទស្សនាញាណ (ស្គាល់ហេតុ ស្គាល់ផល) ។

៩៤- មែនពិត សាធុជនចិត្តល្អ គេមើលទៅឃើញមានអាការដូចផ្លែដូង ឯអ្នកដទៃទៀត គេមើល

ទៅឃើញដូចផ្លែពុទ្រា មានសំបកក្រៀរលោងស្រិលគួរជាទីពេញចិត្ត ។

៩៥- ខ្សែមេត្រីចិត្តនៃលោកសប្បុរសទាំងឡាយ សូម្បីមានឧបសគ្គអ្វីមកផ្តាច់ពីក្តីស្នេហាគ្នា គុណប្រសើរមិនផ្លាស់ប្តូរប្រែប្រួលទេ ដូចដើមឈូក សូម្បីបាក់ពាក់កណ្តាល ក៏នៅតែមានជាប់សរសៃអន្លាយដែរ ។

៩៦- ភាពជាបុគ្គលមានចិត្តបរិសុទ្ធ ភាពជាបុគ្គលមានចិត្តស្មើក្នុងគ្រាសុខទុក្ខ ភាពជាបុគ្គលមានចិត្តមេត្តាករុណា ភាពជាបុគ្គលមានចិត្តស្រឡាញ់រាប់អាន ភាពជាបុគ្គលមានចិត្តទៀងត្រង់ ទាំងអស់នេះជាគុណសម្បត្តិនៃមិត្ត ។

ខ្ញុំនឹងទៅរកមិត្តសម្លាញ់ឲ្យប្រកបដោយគុណសម្បត្តិដូច្នេះ ក្រៅពីរូបបងឯណាបាន?” ។ កណ្តុរ **ហិរញ្ញកៈ** លុះបានឮពាក្យក្អែក**លឃុបតនកៈ**ពោលដូច្នេះហើយ ក៏ចេញពីព្រង់មកខាងក្រៅ និយាយតបថា៖ “ខ្ញុំមានចិត្តត្រេកអរចំពោះសម្តីបងណាស់ ដូចជាបានក្រេបផឹកទឹកអម្រឹត, ព្រោះថា៖

៩៧- កិរិយាមុជទឹកថ្លាត្រជាក់ត្រជុំក្តី, កិរិយាប្រកបដោយខ្សែកដ៏ហើយដោយកែវមុក្តាក្តី កិរិយាប្រោះព្រំរីតរួតសព៌ាង្គកាយ ដោយខ្លឹមចន្ទន៍ក្តី នឹងថាមិនធ្វើបុគ្គលដែលក្តៅស្អុះស្អាប់ដោយកំដៅឲ្យត្រជាក់ស្រួលក៏មិនមែន តែមិនប្រសើរជាងសុភាសិតនៃលោកសប្បុរសទាំងឡាយ ដែលអាចចូលទៅប៉ះពាល់ដល់ចិត្តត្រជាក់មុនដោយបីតិជ្រះថ្លាដ៏ក្រៃលែង ព្រោះលោកទុកភាសិតជាត្រីមុខ ទុកដូចជាមន្តសម្រាប់ស្រួបចិត្តលោកសប្បុរសទាំងឡាយ ។

៩៨- កិរិយាទម្លាយអាថ៌កំបាំងក្តី ល្មោភសូមក្តី ភាពជាបុគ្គលមានចិត្តរឹងរូសក្តី ភាពជាបុគ្គលមានចិត្តរបិលរប៉ូចក្តី សេចក្តីក្រោធច្រើនក្តី ភាពជាបុគ្គលមិនមានសច្ចៈក្តី ស្រវឹងល្បក់ក្នុងល្បែងក្តី ទាំងអស់នេះជាគ្រឿងប្រទូសនៃមិត្ត ។

តាមពាក្យសម្តីដែលបងបាននិយាយមកទាំងអស់នេះ រូបខ្ញុំមិនឃើញមានទោសជាគ្រឿងប្រទូសអ្វី សូម្បីតែមួយក៏ឥតអង្គីមាន, ព្រោះថា៖

៩៩- បុគ្គលគប្បីសង្កេតដឹង នូវភាពនៃបុគ្គលមានចិត្តអាក្រក់ និងភាពនៃបុគ្គលពោលពាក្យសច្ចៈដោយទឹកប្រយោគសម្តី, បុគ្គលគប្បីមើលឃើញនូវភាពនៃបុគ្គលមានចិត្តមិននឹងធឹង និងភាពនៃបុគ្គលមានចិត្តមិនរបិលរប៉ូច ដោយឃើញប្រត្យក្សនឹងភ្នែក ។

១០០- មែនពិត, មេត្រីចិត្តនៃបុគ្គលមានចិត្តបរិសុទ្ធ មានសភាពម្យ៉ាង ឯសម្តីនៃបុគ្គលមានចិត្តអាក្រក់ខិលខូច មានសភាពម្យ៉ាងទៀត ។

១០១- មនុស្សចិត្តអាក្រក់ ចិត្តគិតផ្សេង, សម្ដីនិយាយផ្សេងទៀត, កិរិយាប្រព្រឹត្តធ្វើផ្សេងទៅទៀត ឯបុគ្គលមានមហាគុណ ចិត្តគិត សម្ដីនិយាយប្រព្រឹត្តធ្វើតែមួយ ។

ប្រពៃហើយ! ប្រពៃហើយ! សូមឲ្យបងបានសម្រេចតាមប្រាថ្នាកុំបីឃ្លាត, លុះនិយាយដូច្នោះហើយ កណ្ដុរ**ហិរណ្យកៈ**ព្រមព្រៀងចងស្ពានមេត្រីរាប់អានជាមួយនឹងក្អែក**លឃុបតនៈ** រៀបចំភោជនាហារដ៏ពិសេសឲ្យក្អែកបរិភោគស្កប់ស្កល់ ហើយក៏លាចូលទៅកាន់ព្រង់របស់ខ្លួនដូចប្រក្រតីដើមវិញ ឯក្អែកក៏លាត្រឡប់ទៅកាន់លំនៅខ្លួនវិញហោង ។ ចាប់ដើមតាំងពីថ្ងៃនោះរៀងមក ក្អែក**លឃុបតនៈ**តែងហើរទៅជួបសន្ទនាជាទីរីករាយសប្បាយជាមួយកណ្ដុរ**ហិរណ្យកៈ** ចែកអាហារគ្នាបរិភោគតាមមានតាមបានសួរសុខទុក្ខទៅវិញទៅមកធ្វើធម្មតាសាកច្ឆាសាកសួរគ្នាពីគតិលោក គតិធម៌រឿយៗ ដោយសេចក្ដីស្និទ្ធស្នាលដ៏ក្រៃលែងអស់កាលយូរអង្វែង ។

ថ្ងៃមួយ ក្អែក**លឃុបតនកៈ**និយាយប្រឹក្សាជាមួយកណ្ដុរ**ហិរណ្យកៈ**ថា៖ "ហៃសម្លាញ់! ទីនេះសត្វក្អែកពិបាករកចំណីអាហារចិញ្ចឹមជីវិតណាស់ ខ្ញុំគិតថាលះបង់ទីឋាននេះ ហើយនឹងហើរទៅស្វែងរកទីឋានឯទៀត ដែលងាយរកចំណីអាហារបរិភោគចិញ្ចឹមជីវិតជាងទីនេះ" ។

កណ្ដុរ**ហិរណ្យកៈ**ស្ដាប់ពាក្យក្អែកហើយ មានចិត្តបារម្ភ ទើបសួរទៅថា៖ "នែសម្លាញ់! សម្លាញ់គិតទៅនៅទីឋានឯណាវិញ? ព្រោះថា៖

១០២- ([១]) អ្នកមានប្រាជ្ញា កាលដែលលើកជើងក្រោយ លុះត្រាតែជើងមុខជាន់ស៊ុបហើយគឺថារកទីឋានឯទៀតបានហើយ ទើបលះបង់ទីឋានចាស់ចោលបាន" ។

ក្អែកប្រាប់ថា ទីឋានដែលខ្ញុំបានពិនិត្យមើលឃើញថាល្អនោះ មានមួយកន្លែង ។ កណ្ដុរ**ហិរណ្យកៈ**សួរទៅវិញថា៖ "ចុះទីឋាននោះនៅឯណា?" ។ ក្អែកប្រាប់ថា៖ "មានស្រះមួយទឹកថ្លាយល់ដីឈ្មោះកប៉ូរគោរៈ([២]) ស្ថិតនៅក្នុងព្រៃទណ្ឌក, មានអណ្ដើកមួយឈ្មោះ**មន្ថរៈ**ជាមិត្តសម្លាញ់ខ្ញុំចិត្តថ្លើមល្អណាស់ អាស្រ័យនៅក្នុងស្រះនោះ ព្រោះថា៖

១០៣- ការគ្រាន់តែប្រដៅនរជនទាំងឡាយដទៃឲ្យគេបានជាបណ្ឌិត នរណាក៏ធ្វើបានងាយ តែការទូន្មានខ្លួនឯងឲ្យប្រព្រឹត្តទៅតាមគន្លងធម៌ជាការក្រ ធ្វើបានចំពោះតែបុគ្គលមានមហាគុណ ។

---

[១] ហិតោបទេសប្រែជាភាសាបារាំងរបស់លោកឡង់សឺរ៉ូមានគាថាផ្សេងមួយទៀតគឺ៖ ធ្មេញ, សក់, ក្រចក និងមនុស្សបើផ្លាស់ទីកន្លែងថ្មី ក្រៅពីកន្លែងដើម មិនល្អទេ អ្នកមានប្រាជ្ញារិះគិតឲ្យជ្រាលជ្រៅហើយ មិនគួរលះបង់ចោលទីឋានឡើយ ។

[២] មានពណ៌ដូចកប្បូរ ។

អណ្ដើក**មន្ថរៈ**ជាសម្លាញ់ខ្ញុំ មុខជាធ្វើបដិសណ្ឋារៈទទួលដោយគ្រឿងភោជនាហារដ៏ឆ្ងាញ់ពិសាក្រៃលែង" ។ កណ្ដុរ**ហិរញ្ញកៈ**ឆ្លើយតបទៅវិញថា៖ "បើដូច្នោះមែន រូបខ្ញុំនឹងក្រាញនៅក្នុងទីនេះ តែម្នាក់ឯងធ្វើអ្វី ព្រោះថា៖

១០៤- ប្រទេសឯណា មិនមានគេរាប់អាន មិនមានផ្លូវរកស៊ីចិញ្ចឹមជីវិត មិនមានញាតិសន្ដានផៅពង្ស ឬក៏មិនមានវិទ្យាគមចម្រើនចំណេះវិជ្ជា បុគ្គលគប្បីលះបង់ប្រទេសនោះចេញ ។

១០៥- លោកយាត្រា (ការលក់ដូរ) ១ សេចក្ដីភ័យ១ អាម៉ាស់មុខ១ មេត្តាករុណា១ ការបរិច្ចាកទាន១ ទីឋានណាមិនមានធម៌៤ប្រការនេះទេ បុគ្គលមិនគប្បីតាំងទីឋានអាស្រ័យនៅ នៅក្នុងទីនោះឡើយ ។

១០៦- មនុស្សសងបំណុលគេ១ គ្រូពេទ្យ១ សមណព្រាហ្មណ៍ចេះដឹងវេទ១ ទន្លេមានទឹកថ្លាបរិសុទ្ធ១ នែសម្លាញ់! ទីឋានណាមិនមានវត្ថុ៤ប្រការនេះទេ បុគ្គលមិនគប្បីតាំងលំនៅ ក្នុងទីឋាននោះឡើយ ។

កណ្ដុរ**ហិរញ្ញកៈ**បន្តនិយាយថា៖ "សម្លាញ់អើយ! បងចូរនាំគ្នាទៅជាមួយផង" ។ ក្អែកនាំកណ្ដុរ**ហិរញ្ញកៈ**ទៅ កាលបណ្ដើរគ្នាទៅនិយាយសន្ទនាគ្នាជាទីរីករាយ សប្បាយក្សេមក្សាន្តតាមដំណើរផ្លូវរៀងទៅត្រាតែដល់ស្រះនោះ ។ ឯអណ្ដើក**មន្ថរៈ** កាលឃើញសត្វទាំងពីរបណ្ដើរគ្នាត្រសងតាំងពីចម្ងាយមក រីករាយសប្បាយចិត្តណាស់ ធ្វើបដិសណ្ឋារដ៏ខ្ពង់ខ្ពស់ តាមដែលបានគិតទុកមុន ទទួលក្អែកព្រមទាំងកណ្ដុរ**ហិរញ្ញកៈ**ជាភ្ញៀវថ្មីដោយសក្ការៈរាប់អានដ៏ក្រៃលែង, ព្រោះថា៖

១០៧- ទោះក្មេងតូច ឬកម្លោះក្រមុំ ពុំនោះចាស់ព្រឹទ្ធាចារ្យក៏ដោយ ដែលជាភ្ញៀវមកដល់ផ្ទះហើយ បុគ្គលគប្បីរៀបចំគ្រឿងសក្ការរាប់អានដល់ជននោះៗ ព្រោះអ្នកទាំងនោះមកដល់ផ្ទះហើយ លោកទុកជាគ្រូទាំងអស់ ។

១០៨-ព្រះអគ្និជាគ្រូនៃព្រាហ្មណ៍ទាំងឡាយ ព្រាហ្មណ៍ជាគ្រូនៃជនវណ្ណៈឯទៀត ប្ដីជាគ្រូនៃភរិយាទាំងឡាយ ឯភ្ញៀវដែលមកដល់ផ្ទះជាគ្រូជនទាំងអស់ ។

ខណៈនោះ ក្អែក**លឃុបតនកៈ**និយាយឡើងថា៖ "ហៃបងសម្លាញ់**មន្ថរៈ** សូមសម្លាញ់រៀបទទួលភ្ញៀវថ្មីនេះឲ្យជាពិសេស ព្រោះថាភ្ញៀវថ្មីនេះ ជាស្ដេចកណ្ដុរឈ្មោះ**ហិរញ្ញកៈ** ជាកំពូលនៃអ្នកប្រព្រឹត្តធ្វើបុណ្យទានទាំងឡាយ ជាកែវមុត្តានៃមនុស្សមានមេត្តាករុណាទាំងឡាយ បើទុកជាស្ដេចនាគមានជីវ្ហារ ២០០០ ខ្ញុំជឿថាមិនអាចនឹងពោលសរសើរពីកិត្តិគុណស្ដេចកណ្ដុរនេះឲ្យអស់បានឡើយ" ។ លុះក្អែកនិយាយដូច្នោះហើយ ក៏ពណ៌នារឿងស្ដេចព្រាបចិត្ត**គ្រីព**មកថ្លាថ្លែងប្រាប់ទៀត ។ អណ្ដើក**មន្ថរៈ**បាន

ស្តាប់ពាក្យក្អែកហើយ ក៏មានចិត្តសាទរឥតឧបមា ទើបគោរពបូជាកណ្តុរ**ហិរញ្ញកៈ**ដ៏ក្រៃលែង ហើយពោលពាក្យប្រស្រ័យថា៖ “នែសម្លាញ់ដ៏ចម្រើនអើយ! សូមបងមេត្តាប្រាប់ហេតុដែលនាំឲ្យមកកាន់ទីឋាននិរជនស្ងាត់ដូច្នេះឲ្យខ្ញុំបានដឹងផង!” ។ កណ្តុរ**ហិរញ្ញកៈ**និយាយប្រាប់ថា៖ “សូមចាំស្តាប់ ខ្ញុំនឹងពណ៌នាពីប្រព្រឹត្តហេតុឲ្យស្តាប់ដូចតទៅនេះ” ។

# កថាទី៤

## រឿងកណ្តុរហិរញ្ញកៈ

នៅក្នុងនគរចម្បកៈមានពួកបរិព្វាជកអាស្រ័យនៅច្រើន ។ បណ្តាបរិព្វាជកទាំងឡាយនោះ មានបរិព្វាជកម្នាក់ឈ្មោះ **ចូឌាកណ៌ៈ** តាំងទីឋានអាស្រ័យនៅក្នុងទីមួយ ។ គាត់តែងដាក់ភោជនាហារសេសសល់អំពីកិរិយាបរិភោគក្នុងបាត្រមួយ ហើយយកទៅព្យួរទុកព្ធដ៏ដៃកែវជាប្រក្រតី រួចសំងំដេកលក់ទៅ ។ ខ្ញុំ (**ហិរញ្ញកៈ**) លោតទៅលួចយកអាហារភោជននោះមកបរិភោគជានិច្ចរាល់ៗថ្ងៃ ។ ពេលមួយនោះបរិព្វាជកម្នាក់ទៀតឈ្មោះ**វិណាកណ៌ៈ** ជាមិត្តសម្លាញ់ធ្លាប់រាប់អានគ្នាចូលមករក ជួបបរិព្វាជក**ចូឌាកណ៌ៈ**នោះ ។ បរិព្វាជកទាំងពីរនិយាយជជែកគ្នាលេងកំសាន្តសប្បាយដោយរឿងផ្សេងៗ កំពុងតែនិយាយបរិព្វាជក**ចូឌាកណ៌ៈ** យកបន្ទះឫស្សីកំបាក់គោះដីប៉ូកៗ ធ្វើយ៉ាងនេះញឹកញយណាស់ ដើម្បីបំភ័យបន្លាចខ្ញុំឲ្យបោលរត់ទៅ ។ អែបរិព្វាជក**វិណាកណ៌ៈ** កាលឃើញអាការកិរិយាសម្លាញ់ខ្លួននៅមិនស្ងៀម ក៏សួរទៅថា៖ “សម្លាញ់! សម្លាញ់មានរឿងអ្វី? បានជាមិននាំពាស្តាប់ពាក្យខ្ញុំនិយាយសោះ! ដូចជាមានរឿងកង្វល់ខ្វល់អ្វីដទៃប្លែកនាំមិនឲ្យសុខស្រួល!” ។ បរិព្វាជក**ចូឌាកណ៌ៈ**តបថា៖ “នែសម្លាញ់! ខ្ញុំមិនមែនព្រងើយកន្តើយទេ ប៉ុន្តែសម្លាញ់មិនមើល អាសត្វកណ្តុរចង្រៃនេះ វាចេះតែមករំខានខ្ញុំ វាលបលោតមកលួចយកភោជនាហារដែលនៅក្នុងបាត្រនេះ យកទៅស៊ីរាល់វេលា” ។ បរិព្វាជក**វិណាកណ៌ៈ**ដើរទៅលបមើលដៃកែវនោះ ហើយងឿងឆ្ងល់ខ្វល់ក្នុងចិត្តក៏សួរថា៖ “ម៉េចក៏អាសត្វកណ្តុរនេះវាលោតទៅតោងបាត្រនៅឆ្ងាយបាន បើខ្លួនវាតូច កម្លាំងតិចដូច្នេះហ្ន៎? ព្រោះថា៖

១០៩- ប្រពន្ធក្រមុំស្រាប់តែធ្វើមារយាទាញសក់ប្តីចាស់ជរាជប់ថើប ហើយចាប់ឱបញក់ញីឥតប្រណី ខុសទំនងនុ៎ះមុខជាមានហេតុអ្វីក្តងមិនខាន ។

បរិព្វាជក**ចូឌាកណ៌ៈ**សួររឿងនោះថា៖ “តើរឿងនោះដូចម្តេច?” ។ បរិព្វាជក**វិណាកណ៌ៈ**ពណ៌នារឿងនោះដូច្នេះថា៖

# កថាទី៥

## រឿងពាណិជចាស់ជរា និងភរិយាក្រមុំ

នៅប្រទេសគៅឌី([១]) មានក្រុងមួយឈ្មោះកោសម្ពី ។ មានពាណិជម្នាក់ឈ្មោះ ចន្ទ្រ**ទាសះ** ជាអ្នកមានទ្រព្យសម្បត្តិច្រើន អាស្រ័យនៅក្នុងក្រុងនោះ ។ លុះដល់បច្ឆិមវ័យចាស់ជរាហើយ ពាណិជនោះទៅដណ្ដឹងស្ត្រីក្រមុំម្នាក់ឈ្មោះនាង**លីលវតី** ជាធីតាសេដ្ឋីម្នាក់យកមកធ្វើជាភរិយា ព្រោះសេចក្ដីស្រវឹងល្អក់ក្នុងកាមរាគ និងឡើងចាងព្រោះអាងមានទ្រព្យសម្បត្តិច្រើន ។ ឯនាងភរិយានោះ នៅក្មេងកំពុងពេញពាលក្រមុំខ្ចីល្អក់ ជាស្រីបញ្ចពិធកល្យាណី គួរជាទីប្រិមប្រិយនៃជនទាំងឡាយ ប្រៀបដូចជាទង់សុវណ្ណជ្វាលាដ៏មានជ័យនៃកាមទេព([២]) ។ ឯតាពាណិជជាប្ដីចាស់ជរាមិនអាចញ៉ាំងភរិយាក្មេងនោះ ឲ្យរីករាយស្កប់ស្កល់ដោយកាមបានឡើយ, ព្រោះថា៖

១១០-ពន្លឺត្រជាក់នៃព្រះចន្ទ្រ មិនជាទីពេញចិត្តនៃមនុស្សរងា, ពន្លឺក្ដៅនៃព្រះអាទិត្យ មិនជាទីពេញចិត្តនៃមនុស្សក្ដៅក្រហល់ក្រហាយ ប្ដីចាស់ជរាគ្រាំគ្រាតគ្រេតតគ្រត ក៏មិនជាទីពេញចិត្តនៃភរិយាក្មេងដែរ ។

១១១- បើប្ដីចាស់មើលទៅឃើញសក់ស្កូវសព្រោងហើយ ឲ្យភរិយាក្មេងប្រាថ្នាកាមរាគដូចម្ដេចកើត? ភរិយាណា មានចិត្តប្រគល់ឲ្យទៅប្រុសដទៃទៀតហើយ ភរិយានោះ ទុកប្ដីដូចជាថ្នាំកែរោគ ។

ឯតាចាស់ជាប្ដីមានក្ដីប្រតិព័ទ្ធស្នេហាចំពោះភរិយាខ្លាំងណាស់ នឹងពណ៌នាដូចម្ដេចក៏ពុំបានឡើយព្រោះថា៖

១១២- សេចក្ដីប្រាថ្នាចង់បានទ្រព្យសម្បត្តិ សេចក្ដីប្រាថ្នាចង់ឲ្យមានអាយុយឺនយូរ ជាធម៌តែងមាននៅក្នុងចិត្តនៃសព្វសត្វទាំងឡាយ ឯភរិយាក្មេងរូបរាងកាយស្រស់ឥតខ្ចោះត្រង់ណា ជាធម៌ធ្ងន់កណ្ដុកជាប់ក្នុងចិត្តដ៏ក្រៃលែងនៃប្ដីចាស់ជរាជាងជីវិតទៅទៀត ។

១១៣- មនុស្សចាស់ជរាលុះក្នុងវិស័យនៃកាម នឹងបរិភោគកាមក៏មិនកើត ឬនឹងលះបង់ចោលកាមក៏មិនកើតទៀត ដូចសត្វសុនខដែលបាក់ចង្កូមហើយ គ្រាន់តែបានអង្កៀមយកអណ្ដាតលិឍឆ្អឹងតែប៉ុណ្ណោះ ។

លំដាប់មកមិនយូរប៉ុន្មាន, នាង**លីលវតី**ស្រីចិត្តចើកទៅស្រឡាញ់កម្លោះម្នាក់ជាកូនពាណិជ បាន

---

[១] ប្រទេសវង្គ (ឥណ្ឌា)

[២] រូបទេពនៃកាមរោគ ។

រួមខ្នើយផ្តេកផ្តិតស្នេហាកន្លងប្រពៃណីត្រកូល លះបង់ចោលតាជរាឥតអាល័យ ដោយសេចក្តីស្រវឹងអាងវ័យក្មេង, ព្រោះថា៖

១១៤- កិរិយាប្រព្រឹត្តតាមទំនើងចិត្ត, កិរិយានៅក្នុងផ្ទះនៃបិតា, កិរិយាចូលចិត្តមើលមហោស្រព, កិរិយាចូលចិត្តសេពគប់និយាយច្រើននឹងញាតិ, កិរិយាចូលចិត្តអង្គុយជិតបុរស, កិរិយានៅបរទេស, សមាគមញយៗដោយស្ត្រីផ្កាមាស, វិនាសទ្រព្យសម្បត្តិព្រោះចាយវាយឥតសណ្តាប់ធ្នាប់, ស្វាមីចាស់ជរាប្រចណ្ឌប្ញស្យា និងស្វាមីធ្វើដំណើរទៅប្រទេសក្រៅ អស់ទាំងនេះ ជាហេតុនាំឲ្យភរិយាក្បត់ចិត្តប្តី ។

១១៥- កិរិយាផឹកទឹកស្រវឹង១ កិរិយានៅច្រឡំបល់ដោយមនុស្សអាក្រក់១ កិរិយានៅស្ងាត់ពីស្វាមី១ កិរិយាដើរលេង១ កិរិយាដេកក្នុងផ្ទះអ្នកដទៃ១ កិរិយានៅឆ្ងាយពីស្វាមី១ ទោសទាំង៦ ប្រការនេះជាគ្រឿងប្រទូសនៃស្ត្រីទាំងឡាយ ។

១១៦- បពិត្រព្រះតាបសនារទ! ស្ត្រីដែលឈ្មោះថាមានសេចក្តីស្មោះត្រង់ (សេចក្តីបរិសុទ្ធ) នោះដោយសារតែមិនមានកន្លែងស្ងាត់ មិនមានឱកាសមួយស្របក់ និងមិនមានបុរសប្រាថ្នាខ្លួនប៉ុណ្ណោះទេ ។

១១៧- នឹងថាបុរសណាស្ត្រីមិនស្រឡាញ់ក៏មិនមែន នឹងថាបុរសណាស្ត្រីស្រឡាញ់ក៏មិនមែនទៀត ដោយពិត, ស្ត្រីភាព ដូចគោដើរស្វែងរកស្មៅជាអាហារក្នុងព្រៃ តែងប្រាថ្នានូវស្មៅថ្មីជានិច្ចរហូតទៅ ។

១១៨- នារីបីដូចជាឆ្នាំងខ្លាញ់ បុរសបីដូចជាភ្លើង ហេតុនោះបានជាអ្នកប្រាជ្ញលោកមិនតម្កល់ទុកឆ្នាំងខ្លាញ់នឹងភ្លើងក្នុងទីជិតគ្នាទេ ។

១១៩- ([១])ធម្មជាតិជាស្ត្រី, នឹងថាអៀនខ្មាស ក៏មិនមែន នឹងថាមានខ្លួនទូន្មានហើយ ក៏មិនមែន នឹងថាមានចិត្តស្មោះត្រង់ចំពោះប្តី ក៏មិនមែន ពុំនោះ នឹងថាមានសេចក្តីភ័យខ្លាច ក៏មិនមែនដែរ, សេចក្តីពិត គឺមិនមែនបុរសចង់ នេះជាហេតុនៃសេចក្តីស្មោះត្រង់ (បរិសុទ្ធ) នៃស្ត្រីទាំងឡាយ ។

---

[១] ហិតោបទេស សេចក្តីប្រែជាភាសាបារាំងរបស់លោកឡង់សឺរ៉ូ មានគាថាផ្សេងដូច្នេះគឺ កាលឃើញបុរសស្លៀកពាក់ហ៊ឺហាទោះបងប្អូន ឬកូនចៅ ស្ត្រីភាពតែងសម្តែងសេចក្តីប្រាថ្នាឲ្យដឹងខុសខ្នាតមាត្រា ឱ! តាបសនារទ: នេះជាសេចក្តីពិតឥតតវ៉ាឡើយ ។ សេចក្តីប្រែជាភាសាសៀមរបស់លោកនាគប្រទីប មានគាថាផ្សេងដូច្នេះ ក- សេចក្តីពិត ស្ត្រីភាពមានចិត្តប្រែប្រួលជានិច្ច សូម្បីក្នុងប្រជុំទេវតាក៏មានល្បីឈ្មោះ បុរសណាអាចប្រលោមនាងបាន បុរសនោះទុកជាមានវាសនាល្អ ។ ខ- បុរសមិនគួរអង្គុយក្នុងទីស្ងាត់ជាមួយមាតា បងស្រី ឬប្អូនក្រមុំខ្លួន, កាមនេះ បើនៅរួមគ្នាក្នុងទីស្ងាត់ មានកម្លាំងក្លៀវក្លាណាស់ សូម្បីអ្នកប្រាជ្ញក៏ឆក់ឈ្លក់ងងឹតមុខទប់មិនបានដែរ ។

១២០- បិតារក្សាក្នុងកាលនៅក្មេង, បងប្រុសគ្រប់គ្រងកាលនៅក្រមុំ, កូនប្រុសរក្សាកាលដល់វ័យចាស់ជរា ស្ត្រីភាពនៅឯករាជ្យមិនគួរឡើយ ។

តមក ថ្ងៃមួយនាង**លីលវតី**ស្រីចិត្តចើក កំពុងត្រេកត្រអាលជាមួយគូស្នេហាជាកូនពាណិជលើទែនសយនា ដែលរចនារំលេចពណ៌ដ៏វិចិត្រភ្លឺផ្លេកច្រាលឆ្អិនឆ្អៅ ផ្ទះឆ្អៀលច្រវាត់ដោយកែវមណី និយាយសាសងឆ្លើយឆ្លងល្អកល្អិនដោយក្តីរីករាយ ស្រាប់តែឃើញតាចាស់ជាប្តីដើររលេះរលាំងមកដល់ជិតមិនដឹងខ្លួន នាងក៏ស្ទុះប្រញាប់ប្រញាល់លោតទៅឱបតោងកស្វាមីចាស់ ចាប់ទាញសក់ប្រកៀកប្រឱបជប់ថើបធ្វើបែបស្និទ្ធស្នាលណាស់ ឯកូនពាណិជជាសហាយបានឱកាសក៏លបលាក់ខ្លួនគេចរត់ចេញទៅបាត់ភ្លាម, ព្រោះថា៖

១២១- តាបសខសនា[២] និងព្រះព្រឹហស្បតិ៍ លោកចេះដឹងកលមាយាសាស្ត្រឯណា កលមាយាសាស្ត្រនោះ ប្រតិស្ឋានស្រេចហើយក្នុងប្រាជ្ញានៃស្ត្រីភាព តាមសភាពតាំងតែពីកំណើតមកស្រាប់ ។

ក្សិណនោះ, មានស្ត្រីផ្កាមាសម្នាក់ឈរនៅក្នុងទីជិតនោះ បានឃើញអាការកលមាយានាង**លីលវតី**ដូច្នោះ ក៏នឹកឆ្ងល់ខ្វល់ក្នុងចិត្តឥតឧបមា មិនចេញវាចានិយាយថាអ្វីសោះចេះតែគិតមមៃក្នុងចិត្តថា៖ “មានបើហើយ! បើមិនមានរឿងអ្វីប្លែក នាងនេះមុខជាមិនចេញស្នៀតចាប់ឱបជប់ថើបប្តីចាស់ដូច្នេះទេ” ។ តមក, មិនយូរប៉ុន្មាន ស្ត្រីផ្កាមាសដឹងរឿងរ៉ាវនោះអស់ជើង ក៏ត្រូវនាង**លីលវតី**សូកប៉ាន់មាសប្រាក់យ៉ាងច្រើន ជាតម្លៃជួយលាក់បំបិទបំបាំងរឿងអាម៉ាស់មុខខ្លួនតទៅ ។ ព្រោះហេតុនេះបានជាខ្ញុំ (បរិព្វាជកវិណាកណ៌ៈ) ពោលគាថាមានអាទិ៍ថា៖ “ប្រពន្ធក្រមុំ ស្រាប់តែទាញសក់ប្តីចាស់ជរា” ដូច្នេះជាដើម (១០៩) ។

បរិព្វាជក**វិណាកណ៌ៈ**ត្រិះរិះគិតថា៖ “ប្រហែលជាមានហេតុអ្វីមួយសំខាន់នៅក្នុងទីនោះ បានជាកណ្តុរនេះមានកម្លាំងខ្លាំងម៉េះ?” ពិចារណាមួយស្របក់ ទើបពោលថា៖ “គង់មានទ្រព្យច្រើន ជាប្រភពនៃរឿងនេះមិនខាន ព្រោះថា៖

១២២- សព្វកិច្ចការ គ្រប់ទីឋាន គ្រប់កាលវេលា ក្នុងលោកនេះបុគ្គលមានទ្រព្យច្រើន ឈ្មោះថាមានកម្លាំង, សេចក្តីពិត, ព្រះរាជាមានភាពជាមហាអំណាច ព្រោះមានទ្រព្យជាមូលហេតុ” ។

លំដាប់នោះ, បរិព្វាជក**វិណាកណ៌ៈ** យកជំនីកទៅជីកព្រង់ដែលខ្ញុំ (**ហិរណ្យកៈ**) អាស្រ័យនៅដណ្តើមយកទ្រព្យសម្បត្តិខ្ញុំ ដែលខំសន្សំទុកមកយូរហើយអស់រលីងធេង ។ តាំងពីពេលនោះមក ខ្ញុំទៅ

---

[២] តាបសជាគ្រូពួកអសុរ ។

ជាខ្សត់ទ្រព្យអស់ឫទ្ធិអំណាច ខ្សោយព្យាយាម មិនអាចស្វះស្វែងរកចំណីអាហារចិញ្ចឹមជីវិតបានឡើយ ចេះតែដើរក្រវេចក្រវៀនទៅមកសន្សឹមៗតិចៗ ដោយសេចក្ដីភិតភ័យ អែបរិព្វាជក លុះឃើញខ្ញុំធ្លាក់ក្នុងឋានៈដូច្នេះហើយ ក៏ពោលថា៖

១២៣- ក្នុងលោកនេះ បុគ្គលមានទ្រព្យ ឈ្មោះថាមានកម្លាំង ឈ្មោះថាបណ្ឌិត, អ្នកចូរមើល! អាសត្វកណ្ដុរចង្រៃនេះ វាធ្លាក់ខ្លួនទៅតាមសភាពដើមវាវិញហើយ ។

១២៤- បុគ្គលមានការចេះដឹងតិច កាលបើហីនហោចរលំរលាយទ្រព្យអស់ហើយ, កិច្ចការទាំងឡាយឯទៀត ក៏ឈ្មោះថាវិនាសអន្តរធានទៅដែរ ដូចជាស្ទឹងមានទឹកតិចដល់គិម្ហរដូវក៏រីងស្ងួតហួតហែងអស់រលីង ។

១២៥- អ្នកមានទ្រព្យ ឈ្មោះថាមានមិត្ត, អ្នកមានទ្រព្យ ឈ្មោះថាមានផៅពង្ស, អ្នកមានទ្រព្យ ឈ្មោះថាជាបុរស, អ្នកមានទ្រព្យ ឈ្មោះថាជាបណ្ឌិត ។

១២៦- ផ្ទះអ្នកមិនមានកូន ជាផ្ទះសោះសូន្យ, នរជនមិនមានមិត្តចិត្តល្អ ជាបុគ្គលសោះសូន្យ, ទិសមនុស្សល្ងង់ខ្លៅ ក៏ជាទិសសោះសូន្យ ឯភាពមនុស្សក្រីក្រ ឈ្មោះថាជាភាពសោះសូន្យ ជាងអ្វីទាំងអស់ ។

១២៧- ([១]) បើឥន្ទ្រិយទាំងឡាយមិនវិកលហើយ គេក្តីឈ្មោះក៏នៅដដែល, បើប្រាជ្ញាមិនវិបត្តិចរិតហើយ វាចាក៏គង់នៅដដែលមិនប្លែក បើបុរសប្រាសចាកកម្លាំងទ្រព្យសម្បត្តិអស់រលីងហើយ អ្វីដទៃទៀតដែលមិនឈ្មោះថារលំរលាយនៅក្នុងមួយខណៈនោះដែរឬ? ឱធម្មជាតិអស់នេះគួរឲ្យស្ងើចអស្ចារ្យណាស់ហ្ន៎! លុះខ្ញុំ (**ហិរណ្យកៈ**) បានស្ដាប់ពាក្យនេះរួចស្រេចហើយ ក៏រំពឹងគិតថា៖ “ឥឡូវនេះ អាត្មាអញមិនគួរនឹងអាស្រ័យនៅក្នុងទីនេះតទៅទៀតទេ ឬនឹងនិយាយរឿងនេះឲ្យគេឯងដឹងឮទៀតក៏ពុំគួរដែរ, ព្រោះថា៖

១២៨- អ្នកមានប្រាជ្ញាមិនគួរគប្បីប្រកាស ការវិនាសទ្រព្យសម្បត្តិ ការក្តៅក្រហាយចិត្ត ទុច្ចរិតឧបទ្រពចង្រៃក្នុងផ្ទះ ការត្រូវគេប្រវ័ញ្ចន៍ និងការគេមើលងាយ ឲ្យគេដឹងឮឡើយ ។

១២៩- អាយុជីវិត, ទ្រព្យសម្បត្តិ, ទោសជាចន្លោះក្នុងផ្ទះ, មន្ត្រី (រឿងសម្ងាត់) មេថុន, ភេសជ្ជៈ (ថ្នាំកែរោគ), តបធម៌, ការឲ្យទាន និងការគេមើលងាយ លក្ខណៈ៨ ប្រការនេះ បុគ្គលគប្បីគ្រប់គ្រង

---

[១] ហិតោបទេសប្រែជាភាសាសៀមរបស់លោកនាគប្រទីបមានគាថាលើសដូច្នេះ “បណ្ដាសេចក្តីក្រីក្រ និង សេចក្តីស្លាប់ពីរប្រការនេះ គេចូលចិត្តសេចក្តីក្រីក្រជាងសេចក្តីស្លាប់ តែដោយពិតសេចក្តីស្លាប់នាំឲ្យកើតក្តីទុក្ខស្រាលទេ ហើយតែម្តងក៏អស់ទៅ ឯសេចក្តីក្រីក្រធ្វើឲ្យកើតក្តីព្រួយខ្លាំងបំផុតស្ទើរតែអត់ទ្រាំមិនបាន ។

រក្សាទុកដោយប្រយ័ត្នប្រយែងមែនទែន ។

១៣០- អ្នកមានប្រាជ្ញា តែខ្សត់ទ្រព្យ បើព្រេងវាសនាមិនជួយព្យាយាមរបស់បុរសក៏ឥតប្រយោជន៍ តើនឹងស្វែងរកសេចក្តីសុខដទៃឯណាក្រៅពីការចូលទៅក្នុងព្រៃ?

១៣១- អ្នកមានប្រាជ្ញា បើទុកជាត្រូវស្លាប់ក៏មិនប្រកែក តែមិនព្រមឲ្យធ្លាក់ខ្លួនទៅជាក្រីក្រទេ! ដូចជាភ្លើងសូម្បីរលត់ហើយក៏មិនព្រមត្រជាក់ ។

១៣២- អ្នកមានប្រាជ្ញា នឹងផ្កាភ្ញូងមានសភាពដូចគ្នា ស្ថិតនៅក្នុងគតិតែ ២ យ៉ាងគឺៈ ១ទៅទំលើក្បាលនៃនរជនទាំងពួង និង២ ស្រពោនស្វិតក្រៀមក្រញង់ស្លាប់ក្នុងព្រៃ ។

ឱកិរិយារស់នៅដោយការដើរសូមទានគេចិញ្ចឹមជីវិតនេះ មុខគួរឲ្យអាម៉ាស់មុខណាស់ហ្ន៎! ព្រោះថាៈ

១៣៣- នរជនធ្លាក់ខ្លួនទៅជាក្រីក្រ លោតទម្លាក់ខ្លួនក្នុងគំនរភ្លើងឲ្យស្លាប់បាត់បង់ជីវិតស្រឡះទៅប្រសើរជាងការដើរទៅអើតឆើបសូមទានគេដែលគេឥតគួរសម កំណាញ់មិនចង់ឲ្យទាន មិនប្រសើរឡើយ ។

១៣៤- សេចក្តីក្រីក្រ នាំឲ្យកើតក្តីអៀនខ្មាស, ក្តីអៀនខ្មាស នាំឲ្យបាត់ក្តីក្លាហាន, ការបាត់ក្តីក្លាហាន នាំឲ្យបុគ្គលដទៃមើលងាយ, ការគេមើលងាយ នាំឲ្យកើតក្តីស្អប់ខ្ពើម, ក្តីស្អប់ខ្ពើម នាំឲ្យកើតសេចក្តីទុក្ខសោក, សេចក្តីទុក្ខសោក នាំឲ្យអាប់ប្រាជ្ញា, ការអាប់ប្រាជ្ញា នាំឲ្យដល់ក្តីក្ស័យអន្តរធានអ្វីទាំងអស់ ។ ឱ! អនិច្ចាក្តីក្រីក្រអើយ អ្នកជាប្រធាននៃសេចក្តីវិនាសគ្រប់ប្រការ ។

១៣៥- ការនៅស្ងៀមប្រសើរ, ការពោលពាក្យកុហកមិនប្រសើរឡើយ, ការតាំងខ្លួនជាបុរសខ្សោយអំណាចប្រសើរ, ការលួចភរិយាអ្នកដទៃមិនប្រសើរឡើយ, ការលះបង់ជីវិតប្រសើរ, ការពេញចិត្តស្តាប់ពាក្យញុះញង់ស៊កសៀតមិនប្រសើរឡើយ, ការតាំងខ្លួនជាយាចកប្រសើរ, សេចក្តីសុខ ដែលកើតពីការចិញ្ចឹមជីវិតដោយសារទ្រព្យជនដទៃមិនប្រសើរឡើយ ។

១៣៦- ការនៅក្នុងខ្ទមសោះសូន្យប្រសើរ, ការនៅក្នុងផ្ទះឥស្សរជនកាចកំរោលមិនប្រសើរឡើយ, ការយកស្ត្រីផ្កាមាសជាភរិយាប្រសើរ, ការយកស្ត្រីមានត្រកូល ដែលប្រព្រឹត្តកន្លងប្រពៃណី(១)

---

[១] អវិនីតៈ ប្រែថា ប្រព្រឹត្តខុសគន្លងធម៌ ។ សេចក្តីប្រែជាភាសាសៀម របស់លោកនាគប្រទីបថា “រៀបការពីរដង, ដាក់លេខយោងន័យលក្ខណៈថា តាមប្រពៃណីឥណ្ឌាស្រីមេម៉ាយ បើមានស្វាមីទៀតប្រកាន់ថាល្មើសចរិយាដ៏អាក្រក់ក្រៃលែង” ។ ឆ្ងល់ថាបានអ្វីជាគ្រឿងយល់ ឬលោកចេះទំនៀមឥណ្ឌាបរិបូណ៌ ។ បើស្ត្រីប្តីស្លាប់ ហើយយកស្វាមីទៀត ប្រកាន់ថាអាក្រក់

មិនប្រសើរឡើយ, ការនៅក្នុងព្រៃប្រសើរ, ការនៅក្នុងបុរីដែលមានសេចក្ដីអយុត្តិធម៌មិនប្រសើរឡើយ និងការបរិច្ចាកជីវិតប្រសើរ ការសេពគប់ទុជ៌នមិនប្រសើរឡើយ ។

១៣៧- ការនៅជាទាសៈគេ តែងទម្លាយបង់នូវមានៈទាំងអស់ ការចាស់ជរាតែងទម្លាយបង់នូវរូបសោភា, ការនិយាយរឿងព្រះនារាយន៍ និងព្រះឥសូរតែងទម្លាយបង់នូវបាបកម្ម([២]) ឯការធ្វើជាយាចកឈ្មោះថាទម្លាយបង់នូវគុណរាប់រយ ទាំងអស់នេះ លោកប្រៀបថាដូចជា ងងឹតទម្លាយបង់នូវពន្លឺ” ។

លុះត្រិះរិះមើលឃើញសព្វដូច្នេះហើយ ខ្ញុំគិតថា៖ “អាត្មាអញចិញ្ចឹមជីវិតដោយអាហារជនដទៃដូចម្ដេចកើត? ឱ! សេចក្ដីក្រីក្រតោកយ៉ាកនេះ ប្រាកដជាបើកទ្វារទីពីរឲ្យដល់ម្រឹត្យុរាជពិតៗតែម្ដងហើយហ្ន៎! ព្រោះថា៖

១៣៨- ការចេះដឹងផាត់រទាំង១ មេថុនដោយការទិញដូរ១ និងការចិញ្ចឹមជីវិតដោយសារជនដទៃ១ ទាំង៣ប្រការនេះ ជាគ្រឿងរំខាននាំឲ្យអាម៉ាស់មុខនៃបុរសទាំងឡាយ ។

១៣៩- បុគ្គលមានរោគបៀតបៀន បុគ្គលព្រាត់ប្រាសអស់កាលយូរ បុគ្គលអាស្រ័យបាយទឹកគេចិញ្ចឹមជីវិត និងបុគ្គលប្រព្រឹត្តដេកនៅក្រោមសំយ៉ាបផ្ទះជនដទៃ ជីវិតនៃបុគ្គលនោះៗឈ្មោះថា ជាជីវិតស្លាប់សូន្យឈឹង, សេចក្ដីស្លាប់នៃបុគ្គលនោះៗឈ្មោះថា ជាទីសម្រាកដ៏ស្ងប់ស្ងៀម ។

បើទុកជាខ្ញុំគិតឃើញដូច្នេះហើយ សេចក្ដីល្មោភក៏ចេះតែដឹកនាំខ្ញុំឲ្យស្វះស្វែងរកទ្រព្យសម្បត្តិទៀត ព្រោះថា៖

១៤០- នរជនមានប្រាជ្ញា តែងនៅញាប់ញ័រដោយសេចក្ដីលោភ សេចក្ដីលោភនាំបង្កើតតណ្ហា តណ្ហានាំបង្កើតបានក្ដីទុក្ខនៅនាលោកនេះ និងបរលោក ។

លំដាប់នោះ, បរិព្វាជក**វិណាកណ៌ៈ**ដើរបន្តិចៗសន្សឹមៗមកជិតខ្ញុំ យកបន្ទះឫស្សីបាក់មកវាយខ្ញុំ ខ្ញុំនឹកគិតថា៖

១៤១- បុគ្គលមានចិត្តជាប់ដោយទ្រព្យ មិនមានចិត្តរីករាយ មានចិត្តមិនលុះក្នុងអំណាចខ្លួន និងមានខ្លួនមិនបានទូន្មាន, សេចក្ដីអន្តរាយទាំងអស់ តែងគ្របសង្កត់ចិត្តនៃជនណាមួយដែលមិនសន្តោស ។

---

នេះប្លែកណាស់ហ្ន៎! ។ បើស្ត្រីមានប្ដី ហើយយកប្ដីមួយទៀត ថានេះគួរដែរ ចុះនាងទ្រោបទី ១ ភរិយាក្សត្រីយ៍បាណ្ឌព ៥ ព្រះអង្គក្នុងរឿងមហាភារតៈដូចម្ដេចទៅ?

[២] តាមជំនឿក្នុងសាសនាព្រាហ្មណ៍ថា ការនិយាយរឿងអាទិទេពទាំងឡាយនេះ បើមានបាបកម្ម នឹងបរិសុទ្ធបាន ដូចការទៅមុជទឹកលាងបាប ក្នុងទន្លេគង្គាដែរ ។

១៤២- នរជនណាមានចិត្តសន្តោសរីករាយ នរជននោះឈ្មោះថាជាម្ចាស់នៃសម្បត្តិទាំងអស់ ដូចបុគ្គលពាក់ទ្រនាប់ស្បែកជើង ដើរលើផែនដីក៏ហាក់ដូចជាដឹងថា ផែនដីទាំងមូលក្រាលពាសពេញដោយស្បែក, មិនមែនដូច្នោះឬ?

១៤៣- បុគ្គលដែលក្រេបផឹកទឹកអម្រឹតគឺសន្តោស មានចិត្តក្សេមក្សាន្តតែងបាននូវសេចក្តីសុខត្រជាក់ត្រជំ ឯបុគ្គលល្មោភដើរស្វះស្វែងរកទ្រព្យ ទៅខាងនេះទៅខាងនោះ ខ្វល់រចល់ញ័រទទ្រើកដូចរកខ្យល់ តើបានសេចក្តីសុខមកពីណា?

១៤៤- អ្នកណាលះបង់សេចក្តីប្រាថ្នាទ្រព្យទុកក្រោយខ្នង មិនមានអាល័យទ្រព្យនោះសោះ អ្នកនោះឈ្មោះថាបានរៀនសូត្រហើយ ឈ្មោះថាបានស្តាប់យល់ហើយ និងឈ្មោះថាបានប្រតិបត្តិធម៌ទាំងអស់ ។

១៤៥- ជីវិតនៃបុគ្គលណាមួយ ដែលមិនទៅអើតងើបសូមទានតាមទ្វារផ្ទះនៃឥស្សរជនមិនធ្លាប់គប់គេ មិនដែលភពប្រសព្វសេចក្តីព្រាត់ប្រាសទុក្ខព្រួយ និងមិនដែលពោលពាក្យឥតខ្លឹមសារ, បុគ្គលនោះឈ្មោះថាមានបុណ្យវាសនាធំណាស់ហ្ន៎!

១៤៦- ទីឋានឆ្ងាយចំនួនមួយរយយោជន៍ មិនមែនឆ្ងាយណាស់ណាទេ សម្រាប់បុគ្គលជាខ្ញុំតណ្ហា, ឯបុគ្គលមានចិត្តសន្តោស សូម្បីទ្រព្យមកដល់ដៃហើយ ក៏មិនរវល់អើពើប៉ុន្មានដែរ ។

បើដូច្នេះ, ក្នុងលោកនេះ ការកំណត់ដឹងប្រមាណខ្លួនក្នុងការងារឲ្យសមគួរតាមគុណានុរូប ជាការគាប់ប្រសើរណាស់, ព្រោះថា៖

១៤៧- សម្រាប់ជននាផ្ទៃក្រោមនេះ, អ្វីហ្ន៎ជាធម៌? សេចក្តីអាណិតអាសូរសត្វលោក, អ្វីហ្ន៎ជាសេចក្តីសុខ! កិរិយាប្រាសចាករោគាពាធ, អ្វីហ្ន៎សេចក្តីស្នេហា? ភាពនៃបុគ្គលជាអ្នកសប្បុរស, អ្វីហ្ន៎ជាភាពនៃបណ្ឌិត? ការដឹងកំណត់ប្រមាណខ្លួន ។

១៤៨- ពិតមែន, ភាពជាបណ្ឌិតគឺការដឹងកំណត់ប្រមាណ កាលមានហេតុវិបត្តិកើតឡើង នរជនដែលមិនដឹងការកំណត់ប្រមាណខ្លួន តែងភពប្រសព្វក្តីវិបត្តិអន្តរាយគ្រប់ៗជំហានជើង ។

១៤៩- ([១]) គប្បីលះបង់បុគ្គលម្នាក់ ដើម្បីស្រង់ត្រកូល, គប្បីលះបង់ត្រកូល ដើម្បីរក្សាភូមិ, គប្បីលះបង់ភូមិ ដើម្បីរក្សាប្រទេស, គប្បីលះបង់ប្រទេស ដើម្បីស្រោចស្រង់ខ្លួន ។

១៥០- មានទឹកផឹកមិនបាច់ព្យាយាម ដឹងក្តីមានអាហារប្រកបដោយរសឆ្ងាញ់កន្លងផុតភ័យក្តី ខ្ញុំ (**ហិរណ្យកៈ**) ពិចារណាមើលរួចហើយ ទើបខ្ញុំមកកាន់ទីឋាននិរជនស្ងាត់ដូច្នេះឯង, ព្រោះថា៖

---

[១] ហិតោបទេសសេចក្តីប្រែជាភាសាបារាំង របស់លោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះ កាលបើចូលទៅដល់ឥស្សរជនខ្ពង់ខ្ពស់ហើយ បុគ្គលត្រូវទទួលផលនៃឥស្សរជននោះ ដូចនាគវសុកំព័ទ្ធ (ព្រះឥសូរ) បានទៅជាព្រះតាបស ។

១៥១- ជីវិតអ្នកទីទ័លក្រីក្រ ដែលហីនហោចចាកទ្រព្យសម្បត្តិអាស្រ័យនៅក្នុងព្រៃទុរគមជ្រងំស្ងាត់ ប្រកបដោយម្រឹគពាឡសាហាវយង់ឃ្នងមានតែខ្លា និងដំរី, យកឈើព្រៃជាលំនៅ យកផ្លែឈើទុំ និងទឹកជាចំណីអាហារ យកស្មៅជាកម្រាលដេក និងយកសំបកឈើជាគ្រឿងស្លៀកពាក់ ប្រសើរជាងការនៅកណ្តាលហ្វូងញាតិផៅពង្ស ។

តមក ហេតុតែភ័ព្វវាសនា ដែលខ្ញុំបានកសាងសន្សំទុកមកពីក្នុងបុរេជាតិ បានជូនខ្ញុំឲ្យមកជួបប្រទះមិត្តនេះ ហើយបានចងមេត្រីរាប់អានគ្នាស្និទ្ធស្នាលស្នេហាជាទីបំផុត មួយទៀត, ខ្ញុំមានព្រេងសំណាងបានមកអាស្រ័យនៅជាមួយបងទៀត ក៏ហាក់ដូចជាខ្ញុំបានឡើងទៅកាន់ស្ថានសួគ៌ទាំងរស់តែម្តង, ព្រោះថា៖

១៥២- ([២]) ព្រឹក្សាជាតិ មានពិសពុល ពោលគឺសំសារវដ្តនេះ មានផលទុកដូចជារសផ្អែមតែពីរប្រការ គឺចម្ងាញ់នៃរសទឹកអម្រឹត ពោលគឺកាព្យឃ្លោង ១ និងសមាគមមួយអន្លើដោយសប្បុរសទាំងឡាយ ១ ។

អណ្តើកមន្ថរៈ ពោលបញ្ជាក់ថែមទៀតថា៖

១៥៣- ទ្រព្យសម្បត្តិប្រៀបដូចធូលីជាប់បាតជើង, យោព្វនវ័យប្រៀបដូចជាខ្សែទឹកក្នុងជ្រោះហូរខ្លាញ់ចុះពីកំពូលភ្នំ, ការមានអាយុរស់នៅយឺនយូរប្រៀបដូចការឃ្លេងឃ្លោងនៃដំណក់ទឹកកម្រើក, ជីវិតសត្វប្រៀបដូចក្រពេញទឹក, អ្នកណាមានចិត្តរីករាយមិនប្រព្រឹត្តធម៌ ដែលទុកដូចជាកូនសោចាក់បើកទ្វារទៅកាន់ស្ថានសួគ៌ទេ, អ្នកនោះលុះត្រូវជរាវួបរឹតស៊ីឲ្យទ្រុឌទ្រោមហើយ ក៏រមែងឆេះដោយភ្លើងគឺសេចក្តីសោកសង្រេងសង្រៃ និងសេចក្តីក្តៅក្រហាយស្តាយក្រោយមិនមានទីបំផុត ។ មកពីខំប្រឹងប្រែងកពូនទ្រព្យសម្បត្តិហួសពេកហ្ន៎! បានជាបងត្រូវទទួលទោសគ្រោះថ្នាក់លំបាកដូច្នេះ, ចូរស្តាប់ខ្ញុំ ខ្ញុំនឹងប្រាប់ថា៖

---

[២] ហិតោបទេស សេចក្តីប្រែជាភាសាបារាំងនៃលោក ឡង់ស៊ីរ៉ូ មានគាថាជ្រែកចូលដូច្នេះថា "ក្នុងសំសារវដ្តមិនមានខ្លឹមសារនេះគួរបំពេញកិច្ចជាខ្លឹមសារ ៣ ប្រការគឺ៖ សមាគមមួយអន្លើដោយសាធុជន ១ បង្អោនចិត្តជ្រះថ្លាចំពោះព្រះកេសវៈ (ព្រះនារាយណ៍) ១ និងជម្រះកាយក្នុងគង្គា១ ។ សេចក្តីប្រែជាភាសាសៀមរបស់លោកនាគប្រទីប មានគាថាដូច្នេះ៖ ក- ជីវិតអ្នកណាប្រព្រឹត្តកន្លងទៅដោយសេចក្តីកំណាញ់ មិនបរិភោគខ្លួនឯង មិនចែកចាយជាប្រយោជន៍សាធារណៈ ជីវិតអ្នកនោះឈ្មោះថាស្លាប់បាត់បង់ហើយ សូម្បីមានខ្យល់ចេញចូល ក៏មិនអស្ចារ្យអ្វីជាងស្នប់ ជាងដែកឡើយ ។ ខ- ប្រយោជន៍អ្វីដោយទ្រព្យដែលមិនប្រើប្រាស់ខ្លួនឯង និងមិនចែកចាយជាប្រយោជន៍សាធារណៈ? ប្រយោជន៍អ្វី ដោយរេហ៍ពល ដែលមិនគំរាមសត្រូវ ប្រយោជន៍អ្វីដោយការចេះដឹង ដែលមិនបានប្រតិបត្តិតាមព្រះធម៌? ប្រយោជន៍អ្វីដោយអត្តភាពខ្លួន ដែលមិនបានទូន្មានឥន្ទ្រិយ ។

១៥៤- ការបរិច្ចាកទ្រព្យសម្បត្តិ ដែលបុគ្គលសន្សំកពូនទុកនេះឯង ឈ្មោះថា “រកទ្រព្យសម្បត្តិ” ដូចធារី ទឹកជំនន់បរិច្ចាគទឹកដែលនៅក្នុងពោះបឹង ហើយពេញដោយទឹកដដែលវិញដូច្នោះ ។

១៥៥- មនុស្សកំណាញ់ ដែលជីកកប់ទ្រព្យទុកក្នុងខាងក្រោមដីដោយហេតុឯណា ដោយហេតុនោះ មនុស្សកំណាញ់នោះឈ្មោះថា៖ កសាងផ្លូវ ដើម្បីទៅឋានក្រោមគឺនរកទុកមុនស្រេចហើយ ។

១៥៦- នរជននោះ គិតតែចង់បានទ្រព្យសម្បត្តិ តែងបិទផ្លូវសេចក្តីសុខខ្លួនឯង, នរជននោះទុកដូចជារែកភារៈដ៏ធ្ងន់ឲ្យជនដទៃ យកខ្លួនធ្វើជាភាជន ទទួលរងទុក្ខលំបាកជំនួសគេទទេៗ ។

១៥៧- ថាបើធ្វើជាសេដ្ឋីមានទ្រព្យច្រើន ក៏កំណាញ់ស្វិតស្វាញមិនឲ្យទាន និងមិនបរិភោគប្រើប្រាស់ខ្លួនឯងឲ្យល្មមដល់ទ្រព្យ នុ៎ះយើងទាំងអស់គ្នា ក៏ឈ្មោះថាមានទ្រព្យដូចសេដ្ឋីនោះដែរ មិនមែនដូច្នោះឬអ្វី?

១៥៨- ទ្រព្យសម្បត្តិនៃមនុស្សកំណាញ់ ទុកដូចជាទ្រព្យនៃជនដទៃស្រេចទៅហើយ ព្រោះថាមិនបានរីករាយប្រើប្រាស់ខ្លួនឯង, គ្រាន់តែបានពាក្យគេសរសើរថា “នេះជាទ្រព្យនៃអ្នកនោះ” ប៉ុណ្ណោះ លុះទ្រព្យនោះដល់នូវសេចក្តីសាបសូន្យទៅហើយ បានសេចក្តីទុក្ខថែមទៀត ។

១៥៩- ([១]) ការឲ្យទាន ព្រមទាំងមានវាចាពីរោះ ១ ការចេះដឹង ព្រមទាំងការធ្ងន់ធ្ងរ ១ សេចក្តីក្លៀវក្លា ព្រមទាំងការអត់ធន់ ១ និងទ្រព្យសម្បត្តិ ប្រកបដោយការបរិច្ចាកទាន ១ មង្គល ៤ ប្រការនេះកម្ររកបានណាស់ក្នុងលោកនេះ ។

១៦០- បុគ្គលគប្បី កពូនទ្រព្យសម្បត្តិអស់កាលជានិច្ច តែមិនគប្បីលោភលន់ហួសប្រមាណពេកទេ៖ ចូរមើល! សត្វចចកល្មោភនេះមាននិស្ស័យជាអ្នកល្មោភ ស្លាប់ចោលបង់សៀត, ព្រោះត្រូវសរ ។

កណ្តុរ**ហិរណ្យកៈ** និងក្អែក**លឃុបតនកៈ** សួរឡើងថា៖ រឿងនោះតើដូចម្តេចទៅ?

អណ្តើក**មន្ថរៈ** ចាប់ផ្តើមនិយាយរឿងនោះដូចតទៅនេះ៖

# កថាទី៦

## រឿងព្រាន, ប្រើស, ជ្រូក, ពស់ និងចចក

---

[១] ហិតោបទេស សេចក្តីប្រែជាភាសាបារាំងរបស់លោកឡង់ សឹរ៉ូ និងភាសាសៀមនៃលោកនាគប្រទីប មានគាថាលើសដូច្នេះ “ទ្រព្យនៃមនុស្សកំណាញ់ ដែលមិនបានឲ្យទានដល់ទេវតា ដល់ព្រាហ្មណ៍ ដល់ញាតិសន្តាន និងប្រើប្រាស់ខ្លួនឯង តែងវិនាសទៅដោយអគ្គីភ័យ ដោយចោរភ័យ ជរាភ័យ” ។ ក្នុងសេចក្តីប្រែជាភាសាសៀម មានគាថាមួយទៀតថា៖ “ទ្រព្យសម្បត្តិមានគតិ ៣ យ៉ាងគឺ៖ ចែកទានឲ្យប្រយោជន៍ដល់ជនដទៃ ១, បរិភោគជាប្រយោជន៍ខ្លួន ១, និងវិនាសទៅ ១ ។ អ្នកណាមិនបានឲ្យទាន មិនបានបរិភោគខ្លួនឯង ទ្រព្យសម្បត្តិអ្នកនោះធ្លាក់ទៅគតិទី ៣” ។

មានព្រានព្រៃម្នាក់ឈ្មោះ **ភេររៈ** អាស្រ័យនៅក្នុងកល្យាណ**កដក**គ្រាម ។ ថ្ងៃមួយ, គាត់កាន់ធ្នូត្រាច់ចរចេញទៅស្វះស្វែងរកបរបាញ់ប្រើស ដើរទៅដល់ព្រៃ**វិន្ធ្យា** បាញ់បានប្រើស១ ហើយនាំយកប្រើសនោះវិលត្រឡប់មកផ្ទះវិញ ដល់កណ្ដាលផ្លូវជួបប្រទះឃើញជ្រូកព្រៃ១ រូបរាងធំសម្បើម ដ៏សាហាវយង់ឃ្នង ។ ព្រានព្រៃ**ភេររៈ** ត្រេកអរណាស់ ទម្លាក់ប្រើសទុកលើផែនដីសិន ហើយចាប់ធ្នូបាញ់តម្រង់ទៅជ្រូកព្រៃនោះភ្លាមៗ ឯជ្រូកព្រៃត្រូវសរ ក៏ផ្ទុះចេញជាសម្រែកយ៉ាងខ្លាំងមុខគួរខ្លាចមហិមា ក្នាញ់ណាស់បោលសំដៅទៅព្រានព្រៃ ខ្វេះត្រូវចំពងព្រានព្រៃ ដោយខ្នាយដួលតូងស្លាប់ទៅ ដូចជាគេកាត់ឈើដាច់គល់ ហើយរលំដូច្នោះ, ព្រោះថា៖

១៦១- សត្វលោកតែងដល់នូវសេចក្ដីក្ស័យប្រាណ ដោយទឹក, ដោយភ្លើង, ដោយពិសពុល, ដោយគ្រឿងសស្ត្រាវុធ, ដោយក្ដីអត់ឃ្លាន, ដោយព្យាធិ, និងដោយធ្លាក់ពីកំពូលភ្នំ ពុំនោះដោយហេតុឯណាមួយពុំខានឡើយ ។

កាលដែលព្រានដួលទៅនោះ, ជើងគាត់ដូចជាវាត់ធាក់ទៅត្រូវពស់ធំមួយស្លាប់ទៀត ។ លំដាប់នោះ, មានចចកមួយឈ្មោះ **ទីឃ៍រាវៈ** កំពុងដើរត្រាច់ស្វះស្វែងរកចំណីអាហារក្នុងទីនោះដែរ ដើរទៅឃើញប្រើស, ព្រានព្រៃ និងពស់នោះស្លាប់អាសាបង់ដូច្នោះ ក៏នឹករីករាយសប្បាយចិត្តគិតថា៖ “ឱថ្ងៃនេះអាត្មាអញហៅមានលាភសម្បើមអស្ចារ្យ អាត្មាអញបានប្រទះឃើញអាហារភោជនច្រើនអនេកអនន្ត, ព្រោះថា៖

១៦២- សេចក្ដីទុក្ខលំបាក ដែលគេមិនបានគិតទុកជាមុន អាចកើតឡើងដល់ប្រជាករយ៉ាងណា សេចក្ដីសុខកើតឡើងដល់ប្រជាករយ៉ាងនោះដែរ អាត្មាអញជឿថា ក្នុងលោកនេះស្រេចតែព្រេងសំណាង ។

ការណ៍នេះប្រពៃហើយ! អាត្មាអញនឹងញ៉ាំងជីវិតិន្ទ្រីយ៍ឲ្យប្រព្រឹត្តទៅដោយស្រួលចំនួនត្រៃមាសបាន ដោយអាស្រ័យសាច់ទាំងនេះជាអាហារ ។

១៦៣- មនុស្សនេះ បានជាអាហារបាន ១ ខែ ប្រើសនិងជ្រូកបាន ២ ខែ ឯពស់ទុកអាហារបាន ១ថ្ងៃដែរ, ថ្ងៃនេះ គួរអាត្មាអញស៊ីខ្សែធ្នូនេះមុនដំបូងបង្អស់ ។

ពេលនោះ, ចចក**ទីឃ៍រាវៈ** រំពឹងគិតថា៖ ដើម្បីនឹងធ្វើជាបឋមបរិភោគអាត្មាអញត្រូវស៊ីខ្សែដែលជាប់នឹងធ្នូ ឥតរសជាតិនេះមុនបណ្ដើរសិន “លុះគិតដូច្នេះហើយ ក៏ចាប់កកេរខ្សែធ្នូតាមដែលគិតទុក ។ កំពុងតែកកេរ រឺខ្សែធ្នូនោះដាច់ប៉ាត់វាត់ខ្ទាប់ មកត្រូវមុតធ្លុះដល់បេះដូងដួលតូងដេក ស្លាប់ដល់ក្ដី

បញ្ចភាព([១]) ក្នុងកាលនោះឯងហោង ។ ហេតុនេះហើយបានជាខ្ញុំ **(មន្ថរ:)** ពោលទុកថា បុគ្គលគប្បីកពូនទ្រព្យសម្បត្តិអស់កាលជានិច្ច, ដូច្នេះជាដើម (១៦០) ។ មួយទៀតលោកពោលថា៖

១៦៤- ទ្រព្យណាដែលគេឲ្យទាន ទ្រព្យណាដែលខ្លួនឯងបរិភោគ ទ្រព្យនោះៗឈ្មោះថាជាទ្រព្យនៃជនមានទ្រព្យពិតប្រាកដមែន, ព្រោះថា កាលបើខ្លួនអ្នកមានទ្រព្យនោះស្លាប់បាត់បង់ទៅហើយ សម្បត្តិទ្រព្យព្រមទាំងភរិយា នឹងធ្លាក់ទៅជាគ្រឿងល្បែងនៃជនដទៃៗ ។

១៦៥- ទ្រព្យណាដែលអ្នកឲ្យដល់បុគ្គលប្រសើរដ៏លើស ទ្រព្យណាដែលអ្នកបរិភោគរាល់ៗថ្ងៃ ខ្ញុំគិតឃើញថាទ្រព្យនោះៗ ជាសម្បត្តិទ្រព្យរបស់អ្នកពិតៗ តើអ្នកស្រវឹងរក្សាទ្រព្យសម្បត្តិដែលសេសសល់ទុកឲ្យនរណាទៀត?

គួរលើកទុករឿងនេះមួយអន្លើសិន, ក្នុងពេលនេះមិនគួរនឹងនាំយកមកពណ៌នាឲ្យហួសប្រមាណទេ មិនមែនឬអ្វី? ព្រោះថា៖

១៦៦- នរជនជាបណ្ឌិតមានប្រាជ្ញាល្អ តែងមិនរវល់ចង់បានទ្រព្យសម្បត្តិដែលមិនត្រូវបាន, មិនកើតទុក្ខសោកសៅក្ដៅក្រហាយស្ដាយទ្រព្យដែលវិនាសបាត់ទៅ ហើយនិងមិនវង្វេងជ្រប់ដល់ទៅបាត់ស្មារតីក្នុងពេលដែលសេចក្ដីក្រីក្រមកដល់ប៉ុន្មានឡើយ ។

ណ្ហើយសម្លាញ់! កុំតូចចិត្ត! បងឯងគប្បីឧស្សាហ៍ប្រឹងប្រែងតទៅទៀតទៅ, ព្រោះថា៖

១៦៧- បុរសសូម្បីបានសិក្សារៀនសូត្រសាស្ត្រវិជ្ជាទាំងឡាយហើយ ក៏នៅតែល្ងង់ លុះត្រាតែបុរសណាហាត់ធ្វើថ្នឹក បុរសនោះទើបឈ្មោះថាជាអ្នកប្រាជ្ញមែន, ដូចគ្រូពេទ្យធ្លាប់ត្រិះរិះគិតផ្សំថ្នាំបានល្អ ថ្នឹកមើលមនុស្សឈឺឲ្យជារោគ មិនមែនគ្រាន់តែប្រាប់ឈ្មោះថ្នាំ ហើយជារោគនោះទេ ។

១៦៨- សេចក្ដីពិត, វិធីនៃការចេះដឹង មិនអាចញ៉ាំងបុគ្គលខ្លាចនឿយហត់ (ខ្លាចសេចក្ដីព្យាយាមហាត់ធ្វើ) សូម្បីតែបន្តិចបន្តួចឲ្យបានជាបុគ្គលមានគុណគាប់ប្រសើរទេ ក្នុងលោកនេះ, បុគ្គលភ្នែកខ្វាក់សូម្បីកាន់ប្រទីបនៅដៃ នឹងថាមើលឃើញទ្រព្យសម្បត្តិដែលនៅជុំវិញខ្លួនឬអ្វី?

ដូច្នេះសម្លាញ់! រឿងនេះត្រូវអ្នកធ្វើចិត្តឲ្យស្ងប់សុខក្សេមក្សាន្តតាមដំណើរបរិយាកាសសិន([២]) អ្នកមិនត្រូវកើតទុក្ខឆ្អិតចិត្តគិតរវល់តែរឿងឧបទ្រពចង្រៃនេះពេក, ព្រោះថា៖

---

[១] ធាតុប្រាំប្រការ បឋវី, អបោ, តេជោ, វាយោ និងអាកាសោ ។ ធាតុនេះផ្សំឲ្យកើតជារូបមនុស្ស សត្វ កាលបើដល់ពេលដែលហៅថាស្លាប់ ធាតុទាំងប្រាំប្រការនេះ ក៏ត្រឡប់ទៅធាតុដើមវិញ ហៅថាបញ្ចភូមិ ឬបញ្ចភាព, លោកថា សេចក្ដីស្លាប់ ។

[២] អាកាសដែលព័ទ្ធជុំវិញលោកនេះជាអត្តនូប ។ បើអត្តប្បដិរូបវិញគឺដំណើរការណ៍ផ្សេងៗ ដែលប្រព្រឹត្តទៅ, គេនិយាយថា "បរិយាកាសល្អ បរិយាកាសមិនល្អ ។

១៦៩- ស្តេច, ស្ត្រីក្រមុំនៃត្រកូលព្រាហ្មណ៍, មន្ត្រី, ដោះ, ធ្មេង, សក់, ក្រចក និង នរជន ទាំងអស់នេះ ដែលគេដកចេញពីកន្លែង (ពីតំណែង) មិនល្អទេ ។

បើពិចារណាមើលឲ្យសព្វគ្រប់ដូច្នេះហើយ អ្នកប្រាជ្ញមិនត្រូវលះបង់ចោលទីកន្លែងឡើយ តែសម្តីនេះ ជាសម្តីមនុស្សចោលម្សៀតទេ ព្រោះថា៖

១៧០- សីហ សប្បុរស និង ដំរី តែងលះបង់ទីឋានមិនល្អ ទៅរកទីឋានល្អ, តែសត្វក្អែក, បុរសគម្រក់ និងម្រឹគនៅស្លាប់នឹងទីកន្លែងខ្លួន ។

១៧១- វីរបុរស ជាអ្នកមានប្រាជ្ញា មិនរវល់យកចិត្តទុកដាក់ថា៖ ដូចម្តេចហៅថាប្រទេសខ្លួន ឬដូចម្តេចហៅថាប្រទេស "ឡើយ" ចូលទៅក្នុងប្រទេសណា ក៏ខំប្រឹងប្រែងរកទ្រព្យដោយកម្លាំងនៃខ្លួនក្នុងប្រទេសនោះ, ដូចសត្វសីហៈ ចូលទៅនៅក្នុងព្រៃណាមិនមានអ្វីជាអាវុធ មានតែចង្កូម ក្រចក និងកន្ទុយជាគ្រឿងប្រហារ អាចចាប់សម្លាប់ស្តេចដំរីសារហែកជញ្ជ្រែងស៊ីហុតឈាម ដើម្បីសេចក្តីស្រេកឃ្លាន នៅក្នុងព្រៃនោះ ។

១៧២- បុគ្គលមិនប្រឹងប្រែងរកទ្រព្យសម្បត្តិ ឈ្មោះថាប្រគល់ការសម្បូណ៌ទ្រព្យសម្បត្តិទៅលើដៃនរជនដែលមានសេចក្តីព្យាយាម ដូចកង្កែបលោតចូលទៅក្នុងអណ្តូង ឬដូចត្រីហែលចូលទៅក្នុងស្រះដែលពេញប្រៀបដោយទឹកដូច្នោះ ។

១៧៣- បុគ្គលគប្បីទទួលរ៉ាប់រងសេចក្តីសុខ និងសេចក្តីទុក្ខដែលមកដល់ហើយ ព្រោះថាសេចក្តីទុក្ខ និងសេចក្តីសុខទាំងពីរប្រភេទនេះតែងវិលចុះវិលឡើងដូចកង់រទេះ ។

១៧៤- ជោគលាភ (ព្រេងសំណាង) តែងរត់ទៅរកតែនរជនដែលបរិបូណ៌ដោយសេចក្តីព្យាយាម មិនដេកទ្រមក់ហួសកាលវេលា, ស្គាល់វិធីដំណើរការ, មិនជាប់ជំពាក់ចិត្តក្នុងក្តីអន្តរាយ, ក្លៀវក្លាហាន, ដឹងឧបការគុណគេ និងមានចិត្តល្អមាំមួនក្នុងសន្តានដោយទំនើងខ្លួនឯងមិនមែនមកពីទីលំនៅជាហេតុទេ ។

១៧៥- វិស័យវីរជន សូម្បីខ្សត់ខ្សោយទ្រព្យសម្បត្តិ ក៏អាចចូលទៅកាន់ភាពខ្ពង់ខ្ពស់ដោយកិត្តិយសដ៏ក្រៃលែង, ឯបុគ្គលកំណាញ់សូម្បីប្រកបដោយទ្រព្យសម្បត្តិសម្បូណ៌ច្រើនប៉ុន្មានក៏ដោយ ក៏ធ្លាក់ចុះទៅកាន់សភាពថោកទាប ដ៏អាក្រក់ក្រៃលែង ដូចសុនខជាតិ គេចងកដោយខ្សែក ជាវិការនៃមាសម្តេចឡើយនឹងបានល្អ ដូចសត្វសីហៈ ដ៏រុងរឿងប្រកបដោយវិស័យ លេចល្អឡើងស្រាប់ពីកំណើតព្រមទាំងគុណលក្ខណៈគ្រប់ប្រការ ។

១៧៦- បើមានទ្រព្យសម្បត្តិច្រើន ខ្ញុំរីករាយសប្បាយចិត្ត បើធ្លាក់ខ្លួនជាអ្នកខ្សត់ទ្រព្យ ខ្ញុំសោកសៅក្តៅក្រហាយចិត្ត ធ្វើដូចេ្នះឬអ្វី? ដោយពិត, ការធ្លាក់ទៅទាប និងការឡើងទៅខ្ពស់ នៃមនុស្សទាំងឡាយ ប្រៀបដូចបាល់ដែលគេបោះដោយដៃដូច្នោះឯង ។

១៧៧- ម្លប់ពពក, មេត្រីដោយមនុស្សសាហាវ, សម្លូងថ្មី, ស្រីក្រមុំ និងទ្រព្យសម្បត្តិ, ទាំងអស់នេះធ្វើឲ្យកើតសេចក្តីរីករាយតែមួយខណៈទេ ។

១៧៨- បុគ្គលមិនគប្បីប្រឹងខ្វល់ខ្វាយហួសប្រមាណពេកទេ ដើម្បីរកទ្រព្យចិញ្ចឹមជីវិត ព្រោះព្រះជាម្ចាស់បាននិម្មិតទុកស្រេចហើយ ដូចដោះទាំងគូនៃមាតា តែងបង្ហូរទឹកក្សីរឲ្យទារកតាំងពីប្រសូត្រចេញពីគភ៌ម្ដេះ ។

មានភាសិតទៀត, សម្លាញ់ចូរស្តាប់!

១៧៩- លោកអង្គណាដែលសាងហង្សឲ្យមានពណ៌ស លោកអង្គណាដែលសាងសេកឲ្យមានពណ៌ខៀវ លោកអង្គណាឯណាដែលសាងក្ងោកឲ្យមានពណ៌វិចិត្រផ្សេងៗ លោកអង្គនោះៗនឹងសាងគ្រឿងចិញ្ចឹមជីវិតទុកសម្រាប់នរជនទាំងឡាយដូចគ្នាដែរ ។

ម្យ៉ាងទៀត, សម្លាញ់! សូមចាំស្តាប់រហស្សោបាយនៃសប្បុរសទាំងឡាយទៅទៀត, សេចក្តីដូច្នេះថា...

១៨០- ការស្វែងរកទ្រព្យ បានក្តីទុក្ខលំបាកម្តង កាលវិបត្តិទ្រព្យសម្បត្តិទៅ បានក្តីទុក្ខក្តៅក្រហាយម្តង កាលបានសម្បូណ៌ទ្រព្យសម្បត្តិ កើតមានស្រវឹងម្តងទៀត ដូច្នេះតើទ្រព្យសម្បត្តិទាំងឡាយនោះនាំឲ្យយើងបានសេចក្តីសុខដូចម្តេចហ្ន៎?

១៨១- បើអ្នកស្វែងរកទ្រព្យដើម្បីប្រព្រឹត្តធម៌ កុំស្វែងរកល្អជាង ព្រោះការលាងឲ្យស្អាតមុនល្អជាងការឲ្យប្រឡាក់រួចទើបលាងក្រោយ ។

១៨២- បក្សីស្វែងរកអាហារចំណីបរិភោគក្នុងអាកាស ម្រឹគស្វែងរកអាហារចំណីបរិភោគលើផែនដី ក្រពើស្វែងរកអាហារចំណីបរិភោគក្នុងទឹកយ៉ាងណា, នរជនប្រាថ្នាទ្រព្យ ក៏ស្វែងរកទ្រព្យបរិភោគបាន គ្រប់ទីកន្លែងយ៉ាងនោះដែរ ។

១៨៣- អ្នកមានទ្រព្យ តែងមានភ័យជានិច្ច កើតពីរាជភ័យ អំពីឧទកភ័យ អំពីអគ្គិភ័យ អំពីចោរភ័យ និងវិវាទភ័យ (ការទាស់ទែងដណ្តើមគ្នាឯង) ដូចសព្វសត្វទាំងឡាយខ្លាចពីមរណៈភ័យដូច្នោះដែរ ។

១៨៤- ក្នុងជីវិតដែលបរិបូណ៌ដោយសេចក្ដីលំបាកគ្រប់ប្រការនេះ នឹងមានអ្វីជាទុក្ខឲ្យក្រៃលែងជាងនេះទៅទៀតហ្ន៎? មានតែសេចក្ដីប្រាថ្នាមិនសម្រេចដូចចិត្តនេះឯង, សេចក្ដីប្រាថ្នានេះមិនមែនជាមិនមាន ហើយមិនចេះត្រឡប់ថយចេញពីជាយចិត្តសោះ ។

នែសម្លាញ់! ចូស្ដាប់ពាក្យនេះទៀត៖

១៨៥- ដោយពិត, ទ្រព្យនេះ គេរកបានមកដោយក្រណាស់ រកបានហើយលំបាករក្សាទុកដាក់ទៀត រកបានហើយវិនាសទៅវិញទៀត ដូចគេរក្សាម្រឹត្យូវ (សេចក្ដីស្លាប់), ព្រោះហេតុនោះ បុគ្គលមិនគប្បីគិតពីទ្រព្យពេកទេ ។

១៨៦- ក្នុងលោកនេះ បើបុគ្គលលះបង់តណ្ហាចោលចេញ បាននរណាធ្វើជាអ្នកក្រីក្រ បាននរណាធ្វើជាអ្នកធំមានទ្រព្យ? តែថាបើបុគ្គលប្រគល់ខ្លួនឲ្យខ្ញុំតណ្ហាវិញនុ៎ះ ឈ្មោះថាបណ្ដោយឲ្យទាសភាពមកទំលើអំបែងក្បាលប្រាកដតែម្ដង ។

១៨៧- ([1]) ការចងមេត្រីរាប់អានគ្នាជាប់រហូតដល់ថ្ងៃស្លាប់ជាទីបំផុត, សេចក្ដីក្រេវក្រោធបាត់បង់ក្នុងមួយខណៈ និងការបរិច្ចាកទានឥតអាលោះអាល័យនេះ ជាធម៌តែងមានក្នុងសន្ដានចិត្តនៃបុគ្គលមានមហាត្ម័ន ។

ក្អែក**លឃុបតនកៈ** បានស្ដាប់ពាក្យអភិប្រាយអណ្ដើកហើយ នឹកស្ងើចអស្ចារ្យក្នុងចិត្តហើយពោលពាក្យថា៖ ហៃសម្លាញ់**មន្ថរៈ!** បងមានបុណ្យខ្ពស់ណាស់! មានគុណសម្បត្តិគួរជនផងទាំងពួងពឹងពាក់ជ្រកអាស្រ័យនៅផងបាន គ្រប់កាលទាំងពួង, ព្រោះថា៖

១៨៨- ([2]) លោកសប្បុរសទាំងឡាយ អាចជួយស្រោចស្រង់មិត្តចិត្តសប្បុរស ឲ្យរួចពីក្ដីវិនាសអន្តរាយអស់កាលជានិច្ច ដូចដំរីជួយព្រយុងដំរីដែលលង់ផុងជាប់ភក់ឲ្យរួចឡើងបាន ។

១៨៩- នរជនណាមានមនុស្សត្រូវការមកសូមទាន ឬសូមពឹងពាក់ជ្រកកោនមិនខូចបំណង មិនអាម៉ាស់មុខ ត្រឡប់ទៅវិញមិនក្ដៅក្រហាយ នរជននោះជាបុគ្គលឯកគួរសរសើរ ក្នុងចំណោមមនុស្សជាតិទាំងឡាយ នរជននោះជាបុគ្គលខត្តុង្គឧត្តមមានលក្ខណៈ ជាមនុស្សមានបុណ្យពិត ។

---

[1] ហិតោបទេសសេចក្ដីប្រែជាភាសាបារាំងរបស់លោកឡង់សឺរ៉ូ មានគាថា- តបធម៌ និងសីលធម៌ដូច្នេះ ការធ្លាក់ទៅទាបនិងឡើងទៅខ្ពស់ ការជួបជុំ និង ការព្រាត់ប្រាស់ទាំងអស់នេះសត្វលោកលះបង់មិនបានដោយពិត ជីវិតនេះមានតែសេចក្ដីស្លាប់ជាទីបំផុត ។

[2] ហិតោបទេស សេចក្ដីប្រែនៃលោកឡង់សឺរ៉ូ លោកនាគប្រទីបមានគាថាលើសដូច្នេះ សាធុជនពេញចិត្តប្រព្រឹត្តល្អ តែទុជ៌នមិនគាប់ចិត្តប្រព្រឹត្តល្អទេ ឃ្មុំសុខចិត្តហើរចេញទៅស្វែងរកក្រេបផ្កាឈូក តែជាតិកង្កែប សូម្បីនៅជិតឈូកក៏មិនអើពើ ។

តាមដំណើរនិទានដែលពណ៌នាមកនេះ សត្វទាំង ៣ នោះក៏យកគ្នាធ្វើជាមិត្តសម្លាញ់ស្និទ្ធស្នាល ស្ម័គ្រស្មោះសរស្វែងគោចររកចំណីអាហារតាមទំនើងចិត្ត អាស្រ័យនៅនាព្រៃនោះ ជាសុខនិរទុក្ខនិរភ័យ សប្បាយក្សេមក្សាន្តទៅហោង ។

អំណើះតមក, ថ្ងៃមួយប្រើស**ចិត្រាង្គៈ** កំពុងត្រអាលស៊ីស្មៅខ្ចីដោយក្ដីក្សេមក្សាន្ត ស្រាប់តែមានហេតុអ្វីមួយធ្វើឲ្យភ្ញាក់ព្រើត ភ័យតក់ស្លុតស្ទុះបោលផ្លោះរត់ទៅរកមិត្តសម្លាញ់ឲ្យជួយ ។ មិត្តសម្លាញ់ទាំង ៣ មើលទៅឃើញប្រើសបោលដូចជាបោះពួយសស្លន់សស្លោមកពីចម្ងាយដូច្នោះ បារម្ភក្រែងមានអន្តរាយអ្វីមកយាយីក៏រត់រកកន្លែងជ្រកពួនរៀងខ្លួន ។

អណ្ដើក**មន្ថរៈ** បោលរខូសៗចូលក្នុងទឹក, កណ្ដុរ**ហិរញ្ញកៈ**រត់ចូលរន្ធ អែបងក្អែក**លឃុបតនកៈ** ក៏ហើរទៅទំលើដើមឈើខ្ពស់ ក្រឡេកមៀងមើលទៅឆ្ងាយជុំវិញខ្លួន មិនឃើញមានហេតុអ្វីជាអន្តរាយនាំឲ្យភិតភ័យ ក៏ស្រែកបង្គូកហៅមិត្តសម្លាញ់ទាំង ៣ នាក់ឲ្យទៅរួមរ័ក្សសុខសប្បាយជាមួយគ្នាតាមប្រក្រតីដើម ។

អណ្ដើកនិយាយទៅកាន់ប្រើសថា៖ "នែសម្លាញ់**ចិត្រាង្គៈ!** សូមឲ្យសម្លាញ់មានសិរីសួស្ដីជ័យមង្គល សូមសម្លាញ់កំសាន្តចិត្តផឹកទឹកថ្លា ស្វែងរកចំណីអាហារតាមបំណង អាស្រ័យនៅក្នុងព្រៃនេះជាទីកន្លែងរួមជាមួយគ្នាតទៅ" ឯប្រើស**ចិត្រាង្គៈ** និយាយប្រាប់ថា៖ "អម្បាញ់មិញនេះ ខ្ញុំភិតភ័យណាស់ស្មានថាជាព្រានព្រៃដើរបរបាញ់ បានជាខំបោលខ្មីតរត់មករកលោកជាមិត្តជ្រកកោន" ([១]) ។ កណ្ដុរ**ហិរញ្ញកៈ** ពោលថា យើងត្រូវយកគ្នាជាមិត្ត អាស្រ័យនៅទីនេះជាមួយគ្នាមិនបាច់និយាយអង្វរករច្រើនពេកទេ, ព្រោះថា៖

១៩១- កូនដែលកើតចេញពីទ្រូង, អ្នកដែលធ្លាប់ចងស្ពានមេត្រីជាមួយគ្នា ១, អ្នកដែលជាប់ខ្សែស្រឡាយជាវង្សត្រកូល ១, និងអ្នកដែលរក្សាការពារឲ្យផុតពីសេចក្ដីអន្តរាយ ១ ទាំង ៤ ប្រការនេះ បុគ្គលគប្បីដឹងថា ជាវិធីត្រូវចងមិត្ត ។

សម្លាញ់! ចូរអ្នកនៅក្នុងទីនេះ កុំរង្កៀសសង្ស័យអ្វី ឲ្យដូចជានៅផ្ទះខ្លួនឯងដូច្នោះ ([១]) ។ ឯប្រើស

---

[១] ហិតោបទេស សេចក្ដីប្រែជាភាសាបារាំងនៃលោកឡង់សឺរ៉ូ និងសៀម នៃលោកនាគប្រទីប មានគាថាលើសដូច្នេះ "ការបដិសេធចោលបុគ្គលដែលមកសូមពឹងពាក់ ដោយសេចក្ដីលោភ ឬដោយសេចក្ដីខ្លាច បណ្ឌិតចុះមតិយល់ឃើញថា ជាបាបស្មើដោយការសម្លាប់ព្រាហ្មណ៍" ។

[១] ហិតោបទេសសេចក្ដីប្រែជាភាសាបារាំងនៃលោកឡង់សឺរ៉ូ និងភាសាសៀមនៃលោកនាគប្រទីប មានគាថាលើសដូច្នេះ ទឹកអណ្ដូង ម្លប់ដើមជ្រៃ ស្ត្រីស្យាមា (ស្រីមានរូបល្អវិសេស) ផ្ទះធ្វើដោយឥដ្ឋ ទាំងអស់នេះ ក្នុងរដូវរងា កក់ក្ដៅ ត្រជាក់សប្បាយ ។

**ចិត្រាង្គៈ** បានស្ដាប់ពាក្យកណ្ដុរប្រាប់ព្រមយកជាមិត្តរួមសុខរួមទុក្ខដូច្នោះហើយ ក៏សប្បាយរីករាយណាស់ស្វែងរកស្មៅជាអាហារតាមទំនើងចិត្ត ផឹកទឹកថ្លាអាស្រ័យដំណេកនៅនាម្លប់ដើមឈើជិតមាត់ត្រពាំងនោះឯង ។ កាលនោះអណ្ដើក**មន្ថរៈ**សួរឡើងថា "នែប្រើសសម្លាញ់! នៅក្នុងព្រៃនិរជនបែបនេះ បងខ្លាចអ្វី? ដែលមានព្រានព្រៃត្រាច់ចរទៅមកម្ដងៗដែរ!" ។ ប្រើសឆ្លើយតបទៅវិញថា៖ "នៅក្នុងដែនកលិង្គៈ មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាម**រុក្មាង្គទ** ស្ដេចទ្រង់កេណ្ឌរេហ៍ពលសាកលយោធាទៅកម្រាបប្រទេសជិតខាង, ពេលនេះ ទ្រង់បោះទ័ពតាំងបន្ទាយនៅនាត្រើយស្ទឹងចន្ទ្រភាគា([២]) ខ្ញុំបានដឹងដំណឹងខ្សឹបខ្សាយតាមពាក្យព្រានព្រៃថា ស្ដេចនឹងត្រាច់ចរបរបាញ់ម្រឹគបក្សីមកដល់ជិតនាឋានស្រះកប៉ុរៈ ក្នុងវេលាព្រឹកព្រាងស្វាងឡើងស្អែកនេះ បើយើងទាំងអស់គ្នានៅក្នុងទីនេះ រហូតដល់ព្រឹកឡើង ខ្ញុំនឹកឃើញថា នឹងមានហេតុនាំឲ្យភ័យមិនខាន គួរយើងរៀបចំរកទីកន្លែងទីពឹងតាមការណ៍ដែលនឹងរកបាន ។ ឯអណ្ដើក**មន្ថរៈ**បានឮហេតុប្រកបដោយភ័យនោះហើយ តក់ស្លុតរន្ធត់ចិត្តពោលឡើងថា ខ្ញុំមុខជានឹងទៅរកត្រពាំងឯទៀតជ្រកពួនហើយ បើតែយ៉ាងនេះ ។ ក្អែក**លឃុបតនកៈ** និងប្រើស**ចិត្រាង្គៈ** ក៏ពោលដោយយល់ឃើញល្អថា ធ្វើយ៉ាងនេះត្រូវហើយសម្លាញ់!" ។ ក្នុងកាលនោះ កណ្ដុរ**ហិរណ្យកៈ** គិតសព្វគ្រប់ជុំវិញហើយក៏អស់សំណើចសើចយឹកៗ ទើបនិយាយថា៖ "បងអណ្ដើក**មន្ថរៈ** នេះវារគើមៗ ទៅដល់ត្រពាំងឯទៀត ហើយចូលក្នុងទឹកភ្លាមពួនបាត់ទៅ នុ៎ះជាកុសលហើយ ចុះយើងគ្រប់គ្នា ជាសត្រូវនៅតែលើគោកបានអ្វីការពារហ្ន៎! ព្រោះថា៖

១៩២- ទឹកជាកំពែងការពារវារីជាតិទាំងឡាយ, ប៉មជាកំពែងការពារអ្នកនៅក្នុងប៉ម, ទួលជាកំពែងការពារសត្វទាំងឡាយមានឆ្កែជាដើម, សែន្យានុភាពនៃព្រះរាជា ជាកំពែងការពារអរិន្ទរាជ ។

ហៃសម្លាញ់**លឃុបតនកៈ**! បងត្រូវធ្វើតាមក្បួនតម្រាឧបទេសនេះចុះ, ព្រោះថា៖

១៩៣- បុត្រពាណិជបានឃើញព្រះរាជា ចាប់ដោះក្បាំក្រពុំដូចផ្លែទន្លាប់ផ្ទាប់ឱបនៃភរិយាខ្លួនប្រត្យក្សដោយភ្នែកឯង ក៏ទោមនស្សតូចចិត្តឥតឧបមា, ឯខ្លួនបងទាំងឡាយក៏ត្រូវបានសេចក្ដីក្ដៅក្រហាយដូច្នោះដែរ ។

សត្វទាំងឡាយសួររឿងនោះថា "តើរឿងរ៉ាវនោះដូចម្ដេច?" កណ្ដុរ**ហិរណ្យកៈ** ចាប់ផ្ដើមរៀបរាប់រឿងរ៉ាវនោះដូចតទៅនេះ៖

---

[២] ឈ្មោះស្ទឹងមួយ ដែលមានប្រភពនៅភ្នំចន្ទ្រភាគ សព្វថ្ងៃហៅចេណាប ជាស្ទឹងមួយក្នុងស្ទឹងទាំង ៥ ដែលហូរប្រសព្វគ្នានៅប្រទេសបញ្ចាប (បញ្ច+ អាប= ស្ទឹងប្រាំ) រួមទៅជាទន្លេសីន្ធុ (តណ្ណុំស) ឥណ្ឌា ។

# កថាទី ៧

## រឿងព្រះរាជា បុត្រពាណិជ និងភរិយា

នៅក្នុងប្រទេសកាន្យកុព្ជ([១]) មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមវិសេនរាជ ព្រះរាជាអង្គនេះទ្រង់បានប្រគល់រាជសម្បត្តិថ្វាយព្រះរាជឱរសមួយព្រះអង្គ ទ្រង់ព្រះនាម**តុង្គពលរាជ** ឲ្យគ្រប់គ្រងវីរបុរីរាជធានី ថែរក្សាប្រទេសជាតិមាតុភូមិ ។ ព្រះរាជបុត្រអង្គនេះទ្រង់តាំងនៅក្នុងបឋមវ័យ ឧត្តមសម្បូណ៌ដោយស្រីស្រឹង្គារបរិវារ និងភោគសម្បត្តិទាំងឡាយ ។ ថ្ងៃមួយ កាលព្រះបាទ**តុង្គពលរាជ**ស្តេចទ្រង់ប្រពាតតាមវិថីក្នុងព្រះរាជធានី ទ្រង់ទតព្រះនេត្រទៅប្រទះឃើញភរិយានៃបុត្រពាណិជម្នាក់ ឈ្មោះនាង**លាវណ្យវតី** ជាស្រីនៅក្មេងកំពុងពេញរូបល្អឥតខ្ចោះទាស់ត្រង់ណា ។ លុះស្តេចទ្រង់ត្រឡប់ទៅកាន់ព្រះរាជវាំងវិញ ព្រះរាជហឫទ័យនៅចងចាំរូបសោភានៃនាង**លាវណ្យវតី**មិនភ្លេច ដូចជាត្រូវសរកាមទេពទ្រាំមិនបានទាល់តែទ្រង់ត្រាស់បង្គាប់ឲ្យហៅមេអណ្តើកទៅនាំនាងនោះមកថ្វាយ, ព្រោះថា៖

១៩៤- សរ គឺកិរិយាក្រឡេកមើល កើតក្តីស្នេហាស្ត្រីមានរូបល្អទាំងឡាយ បាញ់ចេញអំពីកិរិយាយឺតកោទ័ណ្ឌ គឺរោមចិញ្ចើមដ៏មានពណ៌ខ្មៅនិលស្រិល កោងទ្រទ្រូយវែងដល់គុម្ពត្រចៀក បើមិនទាន់មកប៉ះដល់ចិត្តបុរសដរាបណា បុរសអាចតម្កល់ចិត្តមាំក្នុងធម៌ លោកសប្បុរសអាចគ្របសង្កត់ឥន្ទ្រិយទាំងឡាយ អាចរក្សាសេចក្តីអៀនខ្មាស និងអាចតាំងនៅក្នុងវិន័យបានដរាបនោះ ។

ឯនាង**លាវណ្យវតី**, តាំងពីបានប៉ះភ្នែកដោយព្រះនេត្រព្រះបាទ**តុង្គពលរាជ** ក៏មានចិត្តប្រតិព័ទ្ធនឹកមមៃមិនភ្លេច ហាក់ដូចជាត្រូវរបួសដោយសរ ដែលព្រះកាមទេពបាញ់មក ត្រូវចំដួងចិត្តចាប់ពើតស្អិតគិតតែផ្លូវមួយ, ព្រោះថា៖

១៩៥- មិនមានសច្ចៈ, ចិត្តរហ័ស, មាយា, ឥច្ឆា, លោភក្រៃពេក, មិនមានគុណសម្បត្តិល្អ និងលាមក ទាំងអស់នេះ ជាទោសនៃស្ត្រីកើតពីសភាពឯង ។

គ្រាកាលនាង**លាវណ្យវតី** ស្រីចិត្តចើកបានស្តាប់ពាក្យនិយាយដឹកនាំបញ្ចុកបញ្ចើនៃនាងមេអណ្តើកហើយ ក៏ធ្វើមាយាឆ្លើយតបថា ខ្ញុំចិត្តស្មោះត្រង់នឹងស្វាមី ឲ្យខ្ញុំប្រព្រឹត្តដូចស្រីអាក្រក់ ល្មើសកន្លងចិត្តស្វាមី ខុសគន្លងធម៌ ដូចម្តេចកើត? ព្រោះថា៖

---

[១] សព្វថ្ងៃ កាណោជ ស្ថិតនៅត្រើយខាងជើងទន្លេគង្គា និងស្ទឹងជម្នា ក្នុងខេត្ត អគ្រៈ, ប្រែថា "ព្រះរាជបុត្រីគម" ជាបុត្រីព្រះបាទកុសនាក ព្រោះព្រះនាងមិនព្រមយកព្រះពាយជាស្វាមី ។

១៩៦- ([១]) ស្រីណាឆ្លៀវឆ្លាតប្រសប់វាងវៃក្នុងការផ្ទះ ស្ត្រីនោះជាភរិយាមែនទែន, ស្ត្រីណាសាយកូន ស្ត្រីនោះជាភរិយាមែនទែន, ស្ត្រីណាប្រគល់ចិត្តឲ្យស្វាមី ស្ត្រីនោះជាភរិយាមែនទែន, ស្ត្រីណាស្មោះត្រង់ចំពោះស្វាមី ស្ត្រីនោះជាភរិយាមែនទែន ។

១៩៧- ស្ត្រីណាមិនធ្វើឲ្យភស្តារីករាយសប្បាយ ស្ត្រីនោះបុគ្គលមិនគប្បីហៅថាភរិយាទេ បើភស្តាពេញចិត្ត ចំពោះនារីណាជាភរិយាហើយ សូម្បីពួកទេវតាក៏ជួយរីករាយដែរ ។

កាលបើដូច្នេះ ស្វាមីជាម្ចាស់ប្រាណរបស់ខ្ញុំ មានបំណងយ៉ាងណា ខ្ញុំប្រតិបត្តិតាមបំណងយ៉ាងនោះ ឥតពិចារណាវេរាចិត្តទេ ។ នាងមេអណ្តើកនោះបញ្ជាក់សួរថា៖ “ពាក្យនេះ ជាពាក្យសច្ចៈដូចនាងនិយាយមែនឬអ្វី?” ។ នាង**លាវណ្យវតី** ឆ្លើយតបវិញ៖ “ចាស! ពាក្យនេះជាពាក្យសច្ចៈពិតប្រាកដមែន” ។ កាលនោះ, នាងមេអណ្តើកក៏លាត្រឡប់ចូលទៅកាន់ព្រះរាជវាំងវិញ នាំយកសេចក្តីទាំងអស់នេះចូលទៅក្រាបបង្គំទូលព្រះបាទ**តុង្គពលរាជ** ឲ្យទ្រង់ជ្រាបសព្វគ្រប់ប្រការ ។

ព្រះបាទ**តុង្គពលរាជ** ទ្រង់បានព្រះសណ្តាប់អស់អាថ៌សេចក្តីហើយ ទើបទ្រង់មានព្រះបន្ទូលត្រាស់ប្រឹក្សាថា៖ “តើយើងគិតធ្វើដូចម្តេចឲ្យប្តីវានាំខ្លួនវាយកមកឲ្យយើងបានហ្ន៎?” ។ នាងមេអណ្តើកក្រាបទូលថា៖ បើដូច្នេះសូមទ្រង់ប្រើឧបាយកល, ព្រោះថា៖

១៩៨- មែនពិត, កិច្ចការណាដែលអាចសម្រេចបានដោយឧបាយកល កិច្ចការនោះ គេមិនបាច់ប្រើសេចក្តីព្យាយាមទេ ដំរីស្ត្រ ត្រូវចចកដើរឧបាយបោកឲ្យចុះក្នុងបឹងភក់ ក៏ដល់ក្តីស្លាប់អន្តរធានទៅហោង ។

ព្រះបាទ**តុង្គពលរាជ** ត្រាស់សួរថា៖ រឿងនោះតើដូចម្តេច? ។ នាងមេអណ្តើកនោះក៏ក្រាបបង្គំទូលដូចសេចក្តីតទៅនេះ៖

# កថាទី ៨

## រឿងចចក និង ដំរីស្ត្រ

នៅក្នុងព្រៃធំ មានដំរីមួយឈ្មោះ **កប៉ុរតិលកៈ** ។ សត្វចចកមួយហ្វូងធំឃើញដំរីស្ត្រមួយនោះក៏គិតគូរគ្នាថា “បើយើងប្រើឧបាយកលណាមួយសម្លាប់ដំរីនេះបាន នោះមុខជាយើងបានសាច់វាជាចំណី

---

[១] ហិតោបទេសប្រែជាភាសាបារាំង នៃលោកឡង់ ស៊ីរ៉ូ និងភាសាសៀមនៃលោកនាគប្រទីប មានគាថាលើសដូច្នេះ សំឡេងពីរោះ ជាលម្អនៃសត្វតាវៅ, ចិត្តស្មោះត្រង់ចំពោះស្វាមី ជាលម្អនៃស្ត្រី, ចំណេះវិជ្ជា ជាលម្អនៃបុរស និង ខន្តី ជាលម្អនៃអ្នកប្រព្រឹត្តព្រត ។

អាហារចម្អែតផ្ទៃអស់កំណត់៤ ខែ" ។ បណ្ដាចចកទាំងឡាយនោះ មានចចកចាស់មួយយកអាសានិយាយអួតអាងថា "ដោយអានុភាពប្រាជ្ញាខ្ញុំ ខ្ញុំមានកិច្ចកលវិសេសមួយ អាចសម្លាប់ដំរីស្ដនេះឲ្យសម្រេចបាន" ។ លំដាប់នោះ ចចកចាស់ឆបោកនោះដើរចូលទៅរកដំរីស្ដ **កប៉ុរតិលកៈ** ធ្វើកិរិយាឱនលំទោនហាក់កោតខ្លាចលុតក្រាបដោយអស្ដាង្គបាត ពោលពាក្យជាទីគោរពថា "បពិត្រលោកជាស្ដេចដំរី! សូមលោកមេត្តាប្រោសខ្ញុំបាទ សូមជួបនឹងលោក" ។ ដំរីស្ដសួរទៅថា "ឯងជាអ្វី ឯងទៅណាមកណារកអ្វីហ្នឹង?" ។ ចចកឆ្លើយប្រាប់ថា "ខ្ញុំបាទជាសត្វចចក ឥឡូវនេះពួកបសុសត្វទាំងឡាយ ដែលអាស្រ័យនៅនាព្រៃនេះប្រជុំព្រមព្រៀងគ្នាមូលមតិស្រេចហើយ ទើបចាត់ឲ្យខ្ញុំបាទចូលមកក្រាបបង្គំទូលព្រះអង្គថា៖ ការរស់នៅមិនមានស្ដេចគ្រប់គ្រងថែរក្សា មិនបានសេចក្ដីសុខទេ សូមអញ្ជើញព្រះអង្គធ្វើជាស្ដេច ហើយគិតអភិសេកសោយរាជ្យនៅព្រៃនេះ ព្រោះព្រះអង្គប្រកបដោយស្វាមីគុណ សព្វគ្រប់ប្រការសមគួរនឹងបានជាស្ដេចគ្រប់គ្រងពពួកសត្វចតុប្បាទទាំងឡាយ ដែលនៅក្នុងទីនេះ, ព្រោះថា៖

១៩៩- នរជនណាបរិសុទ្ធដោយត្រកូល ដោយផៅពង្ស ដោយអារ្យធម៌ មានតបៈតេជៈដ៏ខ្លាំងក្លាប្រកបដោយធម្មចរិយា និងនីតិកោសល្យ (ជំនាញក្នុងនយោបាយ) នរជននោះ សមគួរនឹងបានជាស្ដេចលើផែនដីនេះ ។

២០០- តាមធម្មតា, បុគ្គលត្រូវរកម្ចាស់ផែនដីឲ្យបានទុកជាបឋមរួចហើយសឹមរកភរិយា និងរកទ្រព្យ, ថាបើមិនមានស្ដេចគ្រប់គ្រងផែនដីទេ តើត្រូវរកភរិយា និងរកទ្រព្យនៅក្នុងលោកនេះធ្វើអ្វី?

២០១- ម្ចាស់ផែនដី ជាទីពឹងពាក់នៃពលរដ្ឋទាំងឡាយ ដូចជាភ្លៀងជាទីពឹងពាក់នៃសត្វទាំងឡាយ បើភ្លៀងរអាក់រអួល សត្វលោកអាចញ៉ាំងជីវិតន្ទ្រីយ៍ឲ្យប្រព្រឹត្តទៅបាន តែបើព្រះរាជាមិនប្រកបដោយធម៌ ពលរដ្ឋរស់នៅមិនបានទេ ។

២០២-ក្នុងលោកនេះ នរជនប្រព្រឹត្តទៅតាមច្បាប់ដោយច្រើន ព្រោះតែខ្លាចទណ្ឌកម្មទេ នរជននៅក្នុងអំណាចគេ ហើយប្រព្រឹត្តល្អពិតមែននោះ រកបានដោយកម្រណាស់, ដូចកុលនារីគោរពស្វាមីស្គមវិកលសព៌ាង្គកាយ ឈឺរីងរៃ និងក្រីក្រ ព្រោះតែខ្លាចទណ្ឌកម្មប៉ុណ្ណោះ ។

បើដូច្នោះ, សូមព្រះអង្គកុំបង្អង់អេរង់ឲ្យយឺតយូរ សូមអញ្ជើញទៅដោយរួសរាន់ ឲ្យទាន់ពេលវេលាជាមង្គលសិរីសួស្ដី និយាយដូច្នោះហើយក៏នាំដំរីស្ដនោះដើរទៅ ។ ឯ**កប៉ុរតិលកៈ** ដែលលុះក្នុងអំណាចលោភធម៌ ចង់បានរាជសម្បត្តិចាញ់កលចចក ស្រវឹងយសភ្លេចខ្លួន ខំដើរទៅតាមចចកយ៉ាងលឿនដែលអាចនឹងលឿនបាន ទៅផុងលង់ទ្រនេសក្នុងបឹងភក់ជាប់ទៅទៀតមិនរួច ទើបស្រែកដង្ហោយហៅចចកឲ្យជួយស្រង់ថា៖ "អឺសម្លាញ់អើយ, ត្រូវធ្វើដូចម្ដេចហ្ន៎? ឥឡូវនេះអញលង់ទ្រនេសក្នុងបឹងភក់

ជ្រៅរើខ្លួនមិនរួចទេ នឹងដល់ក្តីស្លាប់ហើយដឹង? សូមសម្លាញ់វិលមកក្រោយរកឧបាយជួយគ្នាសិន" ។ ចចកបានសមដូចបំណងហើយ ធ្វើជាអស់សំណើចសើចហាសហាយ និយាយចំអកឡកឡឺយថា៖ "ទេវៈ! សូមលោកមេត្តាយកប្រមោយតោងចុងកន្ទុយខ្ញុំឲ្យជាប់ ខ្ញុំនឹងខំព្រយុងឡើងឲ្យរួច ដោយអំពើដែលលោកជឿស្តាប់ពាក្យខ្ញុំនេះ សូមលោកសោយរាជ្យនូវសេចក្តីទុក្ខនេះចុះ, ព្រោះថា៖

២០៣- ដរាបណា លោកប្រាសចាកការសេពគប់សប្បុរសរឿយៗ ដរាបនោះ លោកនឹងធ្លាក់ទៅនៅក្នុងសមាគមអសប្បុរសរឿយៗដែរ ។

លំដាប់នោះ, ចចកទាំងឡាយហែកជញ្ចែងដំរីស្ល ដែលផុងក្នុងបឹងភក់ជ្រៅស៊ីជាអាហារ ស្លាប់ក្នុងគ្រានោះឯងហោង ។ ព្រោះហេតុនេះ បានជាខ្ញុំម្ចាស់ក្រាបទូលថា "មែនពិត, កិច្ចការណាដែលអាចសម្រេចបានដោយឧបាយកល" ដូច្នេះជាដើម (១៩៨) ។

កាលព្រះបាទ**តុង្គពលរាជ** ទ្រង់ព្រះសណ្តាប់ពាក្យឧបទេសនៃនាងមេអណ្តើកនោះចប់អស់អាថ៌សេចក្តីហើយ ទើបត្រាស់បង្គាប់ឲ្យហៅ**ចារុទ័ត្ត**កូនពាណិជ ជាស្វាមីនាង**លាវណ្យវតី**មកកាន់ផ្ទៃព្រះរាជដំណាក់តាំងជាសេវកាមាត្យនៅបម្រើផ្ទាល់ព្រះអង្គ ទ្រង់តែងមេត្តាប្រោសប្រាណរាប់អានដោយសេចក្តីស្និទ្ធស្នាលដ៏ក្រៃលែង ។

ថ្ងៃមួយ ព្រះបាទ**តុង្គពលរាជ** ទ្រង់ស្រង់ព្រះជលវារីស្រេច ស្តេចព្រោះព្រំព្រះសព៌ាង្គកាយដោយគ្រឿងក្រអូប ឈ្មុយឈ្ងប់ត្រឡប់គន្ធពិដោរ ទ្រង់ប្រដាប់គ្រឿងអលង្ការដ៏ហើយដោយមាស និងពេជ្រនិលចិន្តាទាំងឡាយរួចហើយ ទើបមានបន្ទូលត្រាស់ថា "ហៃ**ចារុទ័ត្ត**! ថ្ងៃនេះយើងនឹងធ្វើពិធីគៅរីព្រត ([១]) ថ្វាយទេវតា អស់កាលកំណត់មួយខែ, ក្នុងពិធីបុណ្យនេះ អ្នកត្រូវទៅស្វែងរកស្រីក្រមុំមានរូបល្អ ជាស្ត្រីអ្នកមានត្រកូលយកមកឲ្យយើង ឲ្យបានម្នាក់ៗរាល់រាត្រី ចាប់ពីថ្ងៃនេះតទៅយើងនឹងប្រទានទ្រព្យសម្បត្តិនិងកេរ្តិ៍ឈ្មោះឲ្យតាមពិធីបុណ្យ ។ ឯ**ចារុទ័ត្ត** បុត្រពាណិជក៏ចាត់ចែងរកស្រីក្រមុំថ្មីៗតាមព្រះរាជបំណងយកមកថ្វាយរាល់វេលារាត្រី ឥតមានក្តីបារម្ភអ្វីឡើយ ហើយបំបាំងខ្លួនពួនអាត្មាសំងំលបចាំមើលឲ្យដឹងថា ព្រះរាជាទ្រង់ធ្វើដូចម្តេចខ្លះ ។ ព្រះបាទ**តុង្គពលរាជ** ទ្រង់ស្ថិតនៅឆ្ងាយពីស្ត្រីក្រមុំនោះ ធ្វើអាការពាយងាយ ហាក់ដូចពុំជ្រាបព្រះទ័យ ឥតធ្វើអ្វីឲ្យប៉ះពាល់បន្តិចបន្តួចសោះ, ទីបំផុត ទ្រង់ព្រះរាជទានគ្រឿងស្លៀកពាក់ គ្រឿងអលង្ការ គ្រឿងក្រអូប និងលម្អិតខ្លឹមចន្ទន៍ សុទ្ធសឹងតែគ្រឿងប្រសើរឆើតហើយត្រាស់បង្គាប់ឲ្យរាជអាមាត្យថែរក្សា នាំយកទៅប្រគល់ដល់ផ្ទះរៀងខ្លួនវិញភ្លាម ។

---

[១] ពិធីបូជាដល់នាងគៅរី គឺនាងទុគោជាសក្តិព្រះឥសូរ

រីបុត្រពាណិជ កាលលបមើលឃើញសព្វគ្រប់ប្រការដូច្នោះ ជឿទុកចិត្តស្តាប់គំនិតឈឹង កើតសេចក្តីលោភលន់ចង់បានទ្រព្យថែមទៀត ទើបទៅនាំភរិយាខ្លួនយកមកថ្វាយ ។ កាលនោះព្រះបាទ**តុង្គពលរាជ** ទតព្រះនេត្រឃើញនាង**លាវណ្យវតី** ស្ត្រីកំពូលព្រះទ័យមកដល់ ទ្រង់ស្គាល់ច្បាស់ ត្រេកត្រអាលណាស់ ស្ទុះទៅបីត្រកងនាំយកទៅលើព្រះទែនសយនាភិរម្យ ភ្លើតភ្លើនព្រះចិន្តាដោយក្តីស្នេហា បើកព្រះនេត្រារលីមព្រឹមៗ ត្រជាក់ដួងកមលស្កល់ព្រះទ័យ ។ កាលបុត្រពាណិជជាស្វាមីបានឃើញដូច្នោះ ស្តាយក្រោយសល់សែនទ្វី អស់បើគិត ភ័ន្តភាំងស្មារតី គាំងរឹងស្ដូក នៅនឹងថ្កល់ដូចកល់រូបគំនូរ ឬតក្កតា លែងហាមាត់ចេញស្តីអ្វីកើត ដោយក្តីក្តៅក្រហាយខុសគំនិតខ្លួនឯង ។ ព្រោះហេតុនោះបានជាខ្ញុំ (កណ្ដុរ**ហិរណ្យកៈ**) និយាយថា៖ “បុត្រពាណិជបានឃើញព្រះរាជាចាប់ដោះក្បុំក្រពុំដូចផ្លែទន្លាប់ផ្អាប់ឱរា នៃភរិយាខ្លួនប្រត្យក្សដោយភ្នែកឯង” ដូច្នេះជាដើម (១៩៣) ។

កណ្ដុរ**ហិរណ្យកៈ** និយាយបញ្ជាក់ឲ្យក្អែក**លឃុបតនកៈ**ទៀតថា៖ “រឿងបងក្អែកនេះដូចជារឿងបុត្រពាណិជដូច្នេះដែរ” ។ ឯអណ្ដើក**មន្ថរៈ** មើលងាយរឿងដែលកណ្ដុរ**ហិរណ្យកៈ**និយាយប្រាប់ បដិសេធមិនព្រមស្តាប់ ភ័យតក់ស្លុតរន្ធត់ចិត្តណាស់ ក៏ឡើងពីត្រពាំងនោះវារចេញទៅដោយរួសរាន់ ។ សត្វឯទៀតមានកណ្ដុរជាដើម មានសេចក្តីស្នេហាអណ្ដើក**មន្ថរៈ**, កាលបើឃើញមិត្តមិនស្តាប់ពាក្យខ្លួន, បារម្ភក្រែងមិត្តជាទីស្រឡាញ់ពេញចិត្តមានក្តីអន្តរាយ ក៏បបួលគ្នាដើរទៅតាម ។ កាលអណ្ដើក**មន្ថរៈ** វាររខូសៗលើគោក លេចវាលចូលព្រៃ មិនយូរប៉ុន្មានទៅជួបប្រទះនឹងព្រានព្រៃម្នាក់ ។ រីព្រានព្រៃឃើញអណ្ដើកវារគើមៗត្រេកអរណាស់ រើសហើយចងភ្ជាប់ព្នួដ៏ដងធ្នូពុនយកទៅ ដើរទៅៗអស់កម្លាំងឃ្លានបាយស្រេកទឹកខ្លាំង ក៏ត្រឡប់ទៅផ្ទះវិញ ។ ឯប្រើស ក្អែក និងកណ្ដុរ ឃើញព្រានព្រៃចាប់អណ្ដើកកើតក្តីក្តៅក្រហាយរសាប់រសល់ តប់ប្រមល់ខ្វល់ចិត្ត មិនដឹងបើគិតធ្វើដូចម្តេច ចេះតែទៅតាមព្រាននោះចរទៅ ។ កាលនោះឯងកណ្ដុរ**ហិរណ្យកៈ** យំទង្គឹសខ្សឹកខ្សួលរអាក់រអួលថ្លាថ្លែងថា៖

២០៤- ដរាបណាអាត្មាអញមិនទាន់បានដល់ទីបំផុត ពោលគឺត្រើយសមុទ្រនៃសេចក្តីទុក្ខមួយទេ, ដរាបនោះ អាត្មាអញក៏តែងតែជួបប្រទះសេចក្តីទុក្ខទីពីរទៀត, រីសេចក្តីទុក្ខនេះ បើមានច្រកជាទំនងហើយ ក៏ចេះតែកើតមានឡើងថែមហើយថែមទៀតច្រើនឡើងៗ ។

២០៥- មិត្តភាពណា មានភាពប្រក្រតីជាមិត្ត កើតឡើងដោយបុណ្យវាសនា មិត្តភាពប្រកបដោយភាពប្រក្រតីនោះ មិនលះបង់ចោលគ្នាក្នុងគ្រាវិបត្តិអន្តរាយឡើយ ។

២០៦- វិស្សាសភាពនៃនរជនក្នុងមាតា ក្នុងភរិយា ក្នុងបងប្អូន និងក្នុងបុត្រធីតា មិនស្មើដោយវិស្សាសភាពនៃមិត្តដែលកើតឡើងដោយសភាពប្រក្រតីជាមិត្តឡើយ ។ កណ្ដុររំពឹងគិតសាចុះឡើងមួយ

ស្របក់ ដកដង្ហើមធំឃ្លៗ ទួញយំថា៖ ឱពុទ្ធោកម្មអើយ! បាបកម្មអាត្មាអញនេះអីក៏អាក្រក់ម្លេះហ្ន៎?, ព្រោះថា៖

២០៧- ផលកម្មអាត្មាអញល្អក្តី អាក្រក់ក្តី ដែលប្រព្រឹត្តទៅក្នុងកាល ប្រាកដជាកើតឡើងក្នុងសន្តានអញពីបុព្វជាតិ, អាត្មាអញបានឃើញផលកម្មទាំងអស់ក្នុងលោកនេះ ដូចជាអាត្មាអញបានកើតមកហើយ ១០ ជាតិ ។

២០៨- គួរសង្វេគណាស់! រាងកាយនេះកើតឡើងហើយ ក៏ដល់នូវការបែកធ្លាយទៅវិញ ភោគសម្បត្តិកើតបរិបូណ៌ឡើងហើយ ក៏ព្រាត់ប្រាសគ្នាទៅវិញ, សារពើវត្ថុទាំងឡាយ មានការកើតឡើង និងការបាក់បែកពុកផុយរលួយទៅវិញនេះជាធម្មតា ។

២០៩- នរណាហ្ន៎ ជាអ្នកបង្កើតរតនវត្ថុឲ្យមានពាក្យពីរព្យាង្គថា "សម្លាញ់" ដែលទុកដូចជាគ្រឿងការពារនូវសេចក្តីសោក សត្រូវភ័យ សេចក្តីតក់ស្លុត និងជាភាជន៍ សម្រាប់ទ្រនូវសេចក្តីស្រឡាញ់ព្រមទាំងសេចក្តីជឿទុកចិត្ត ។

២១០- មិត្តណាជាទីកើតរសនៃបីតិ ជាទីគាប់ភ្នែក ជាទីរីករាយចិត្ត ជាភាជនៈសម្រាប់ទ្រនូវសេចក្តីសុខទុក្ខជាមួយគ្នា មិត្តនោះ ក្ររកបានណាស់, មានមិត្តដទៃទៀត, ក្នុងសម័យមានទ្រព្យច្រើន មិត្តណាមករាប់អានព្រោះតែចង់បាននុយគឺទ្រព្យ មិត្តនោះ ឃើញមានមីរដេរដាសគ្រប់ទីឋាន, គ្រាវិបត្តិទុកជាថ្មសម្រាប់សាកល្បងមើលមាសសុទ្ធ គឺមិត្តពិតទាំងឡាយនោះៗ ។

កណ្តុរ**ហិរណ្យកៈ** យំពិលាបខ្សឹកខ្សួលរអាក់រអួលតូចចិត្តយូរមួយស្របក់ ទើបនិយាយទៅរកក្អែក**លឃុបតនកៈ** និងប្រើស**ចិត្រាង្គ**ថា៖ "នែបងក្អែក បងប្រើស! ដរាបណាព្រានព្រៃមិនទាន់ចេញផុតពីព្រៃនេះ ដរាបនោះ យើងត្រូវព្យាយាមរកឧបាយជួយដោះអណ្តើក**មន្ថរៈ**នេះឲ្យរួចពីក្តីអន្តរាយទាល់តែបាន" ។ ក្អែក និងប្រើស សួរថា៖ "ចូរបងកណ្តុរប្រាប់ឧបាយឲ្យឆាប់មក តើយើងត្រូវធ្វើដូចម្តេច?" កណ្តុរប្រាប់ឧបាយថា៖ "បងប្រើស**ចិត្រាង្គៈ**ធ្វើពុតក្លែងជាស្លាប់ ដេកកណ្តាលវាលនៅក្បែរមាត់ត្រពាំងបង្ហាញខ្លួនឲ្យគេឃើញងាយ, បងក្អែកហើរខាងលើស្រែកកញ្ច្រៀវក្ងកៗ ឲ្យឮខ្លាំង ធ្វើហាក់ដូចជាចុះទៅជញ្ជែងស៊ីប្រើស, ឯព្រានព្រៃជាអ្នកត្រូវការសាច់, កាលបើឃើញប្រើសស្លាប់ដូច្នេះ, មុខជាទុកអណ្តើកមួយអន្លើសិន ហើយរត់ប្រញាប់ប្រញាល់ទៅយកប្រើសពិតប្រាកដឥតសង្ស័យឡើយ ពេលនោះខ្ញុំនឹងរត់ទៅកកេរកាត់ចំណងចងអណ្តើកឲ្យរួចខ្លួន ហើយឲ្យវារចូលទៅក្នុងត្រពាំងភ្លាមទៅ, រីឯបងប្រើសកាលបើព្រានព្រៃរត់ចូលមកដល់ជិតកាលណា ត្រូវក្រោកឡើងយ៉ាងរហ័សបោលឲ្យលឿន ដែលនឹងអាចលឿនបាន ហើយចូលក្នុងព្រៃប្រោកកាលនោះទៅ" ។

គិតគូរគ្នាស្រេចហើយ, ប្រើសចិត្រាង្គៈ និងក្អែកលឃុបតនកៈ ធ្វើតាមឧបាយនោះមួយរំពេច ។ឯព្រាន ព្រៃត្រាច់ចរស្វះស្វែងរកបរបាញ់តាមដែនដងព្រៃ មិនបានអ្វីសោះ កើតក្តីនឿយហត់អស់កម្លាំង ល្វើយ ស្រេកទឹកក៏ចុះទៅផឹកទឹកក្នុងត្រពាំង រួចហើយឡើងមកជ្រកសម្រាកកាយយកកម្លាំងនៅក្រោមម្លប់ ឈើមួយ ចោលភ្នែកក្រឡេកទៅឃើញប្រើសស្លាប់ប៉ោងពោះដូច្នោះ ត្រេកអរណាស់ កន្ត្រាក់កាំបិត ស្នៀតសៀតចង្កេះ ចោលអណ្តើកនៅទីនោះ រត់ខ្មីតយ៉ាងលឿនសំដៅទៅឯប្រើសស្លាប់នោះ ។ ក្សិណ នោះ, កណ្តុរហិរណ្យកៈ ឃើញព្រានព្រៃរត់ទៅហើយក៏គេទៅខំកកេរចំណងអណ្តើកមន្ថរៈរួចភ្លាម, អណ្តើកបានរួចចំណងហើយ វារខ្វូសៗយ៉ាងរហ័សចូលទៅក្នុងត្រពាំងភ្លុងទៅ ។ អែបងប្រើសមៀង មើលទៅឃើញព្រានព្រៃរត់ជិតមកដល់ខ្លួនហើយ ក្រោកប្រញាប់ប្រញាល់ផ្លោះបោលដូចគេបោះពួយ ចូលព្រៃប្រោកបាត់ទៅ ។ ព្រានព្រៃអាំងឡាំងភាំងស្មារតីអៀនឡក់ ត្រឡប់មកវិញ, ដរាបណាដល់ គល់ឈើ, ដរាបនោះ រកអណ្តើកមិនឃើញ អស់ផ្លូវសង្ឃឹមលាន់មាត់ស្រែកថា៖ នេះបានសមមុខ អាផេះកណ្តាលជើងក្រាន! មិនជឿពាក្យចាស់ស្រឡះដៃធេង ធ្វើការមិនគិតគូរឲ្យល្អិតល្អន់ទុកជាមុន, ព្រោះថា៖

២១១- នរជនណាលះបង់របស់ទៀងទាត់ ទៅស្រវាយករបស់មិនទៀងទាត់វិញ របស់ដែល ទៀងទាត់ក៏វិនាសបាត់សូន្យទៅ ឯរបស់ដែលមិនទៀងទាត់ក៏ហីនហោចបាត់ទៅថែមទៀតដែរ ។

ឯព្រានព្រៃធ្វើការខុសទំនងដោយខ្លួនឯង ខាតលាភស្រឡះដៃធេង ក្តៅក្រហាយស្តាយក្រោយ ដើរចូលព្រៃជ្រៅជ្រលងដងអួរបាត់ទៅ ។ សត្វជាមិត្តសម្លាញ់ទាំងឡាយ មានអណ្តើកមន្ថរៈ ជាដើមបាន រួចទុក្ខទោសភយន្តរាយហើយ ក៏ត្រឡប់ទៅកាន់ស្ថានលំនៅខ្លួនវិញតាមប្រក្រតីដើម នៅជាសុខសប្បាយ មានសាមគ្គីព្រមព្រៀងគ្នាត្រាតែអស់ជីវិតរៀងខ្លួនទៅហោង ។

ក្នុងកាលទីបំផុត ព្រះរាជបុត្រទាំងឡាយដែលបានទ្រង់ព្រះសណ្តាប់កថាដ៏វិចិត្រនេះ មានព្រះ ទ័យត្រេកអររីករាយដ៏ក្រៃលែង មានព្រះបន្ទូលត្រាស់ទៅកាន់បណ្ឌិតអាយ៍វិស្ណុស័ម៉ន ថា៖ “យើង ខ្ញុំទាំងអស់គ្នាបានស្តាប់រឿងរ៉ាវដែលលោកបានថ្លែងអម្បាញ់មិញនេះសព្វគ្រប់ មានសេចក្តីត្រេកអរណាស់, សេចក្តីប្រាថ្នាយើងខ្ញុំទាំងអស់គ្នា បានសំប្ញទ្ធិសម្រេចប្រយោជន៍ហើយ” ។ មហាបណ្ឌិតវិស្ណុស័ម៉ន ក្រាបបង្គំទូលថា “បំណងរបស់ទ្រង់ព្រះករុណាបានសម្រេចបរិបូណ៌ហើយ សូមទ្រង់ព្រះករុណាស្តេចព្រះសណ្តាប់ស្លោកទីបំផុតដូច្នេះទៀតថា៖

២១២- សូមសាធុជនទាំងឡាយ សាមគ្គាមូលត្រកូលចងចាប់គ្នាជាសាមគ្គី ឲ្យមានមិត្តភាព, សូមប្រជាជនក្នុងជនបទសម្បូណ៌ដោយសិរីសម្បត្តិគ្រប់ប្រការ! សូមព្រះភូមិបាលទាំងឡាយរក្សា

ប្រជាជននៅលើផែនពសុធាដោយប្រពៃ ហើយស្ថិតនៅក្នុងទសពិធរាជធម៌ជានិច្ចនិរន្តរ៍តទៅ! សូមទ្រង់ព្រះកុរណាគ្រប់ព្រះអង្គតាំងព្រះទ័យជាសប្បុរសមានសេចក្ដីពេញចិត្ត និយមប្រើនីតិសាស្ត្រ ទុកនីតិសាស្ត្រនេះដូចជាព្រះជាយាថ្មីមួយអង្គទៀត សូមព្រះមហាទេពដ៏មានបុណ្យជាចមអមរនិករដ៏ទ្រង់នូវចន្ទ្រាធិច្ចឌាមណី ប្រសិទ្ធីពរបវរសួស្ដីដល់មហាជនឲ្យប្រកបដោយវិបុលសុខ សិរីសួស្ដីជ័យមង្គលគ្រប់ទិនទិវារាត្រីទៅហោង ។

កថាសង្គ្រោះទី១ ឈ្មោះការគប់មិត្ត ដែលមានមកក្នុងហិតោបទេសចប់តែប៉ុណ្ណោះ ។

# ស្រី

# ហិតោបទេស

ភាគទី ២

# ការបំបែកមិត្ត

ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ
អ្នកប្រែចេញពីភាសាសំស្ក្រឹត

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥០៣ គ.ស ១៩៦០

នារាយណបណ្ឌិត

# ស្រី

# ហិតោបទេស

ភាគទី ២

## ការបំបែកមិត្ត

ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

ជា

អ្នកបកប្រែចេញពីភាសាសំស្ក្រឹត

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥០៣ គ.ស ១៩៦០

ចារឹកឡើងវិញ៖ ណុល ដារ៉ា

**២០០៩**

## កថាមុខ

ហិតោបទេសភាគទី១ ឈ្មោះ “ការគប់មិត្ត” ដែលផ្សាយចេញទៅហើយ បានទទួលការនិយមអានគួរជាទីពេញចិត្ត ។ ការនិយមអាននេះ ជាវត្ថុបំណងដ៏ប្រសើររបស់ខ្ញុំ ទុកថាខ្ញុំបានបោះជំហានទីមួយទៅស្រេចបរិបូណ៌ហើយ ថែមទាំងនាំឲ្យខ្ញុំមានកម្លាំងព្យាយាមសរសេរតទៅទៀតមិនតិចឡើយ ។

អស់លោកអ្នកអានខ្លះ កាលអានរួចហើយពោលត្អូញត្អែរថា ហិតោបទេសនេះល្អណាស់ តែពិបាកអានហួសពេក ហើយមិនងាយស្ដាប់សេចក្ដីបានផង ព្រោះដេរដាសដោយពាក្យសំស្ក្រឹត និងពាក្យមានអាថ៌ជ្រាលជ្រៅ ។ ខ្ញុំឥតប្រកែកទេ យល់ព្រមតាមពាក្យអ្នកអានទាំងអស់ តែក្នុងរឿងនេះខ្ញុំនឹកពិភាល់ថា លោកអ្នកអានទាំងឡាយភ្លេចថាខ្ញុំជាអ្នកប្រែទៅហើយ មួយទៀតខ្ញុំជឿថា អ្នកអានទាំងឡាយគង់មិនភ្លេចថា ធម្មតាច្បាប់ ឬសុភាសិតដែលជាទ្រឹស្ដី សុទ្ធសឹងមានអាថ៌ជ្រាលជ្រៅ មិនមែនអានហើយភ្លាមយល់ចូលចិត្តស្រួលទេ ។ អ្នកដែលខ្លាចគេបន្ទោសថាខ្វះការសិក្សា តែងព្យាយាមអានមិនលះបង់ចោល អានហើយអានទៀត ខំប្រឹងអានដរាបទាល់តែយល់សេចក្ដី ដូចគេទ្រាំលេបគីនីនឲ្យជាគ្រុនដូច្នោះ ។ ដើម្បីដាស់តឿនស្មារតីអ្នកអានទាំងឡាយ ខ្ញុំសូមនាំនិទានខ្លីមួយទុកជាគតិប្រចាំជីវិតថា៖

“កាលពីព្រេងនាយ កន្លងបាំងបាត់ស្ងាត់យូរយារណាស់ហើយ កាលនោះ អសុរ និងទេពតា យកនាគវសុកិជាព្រ័ត្រ យកភ្នំមន្ទរជាស្នូល យកអណ្ដើកអវតារនៃព្រះនារាយណ៍ជាអ្នកទ្រភ្នំមន្ទរ ហើយបបួលគ្នាកូរសមុទ្រទឹកដោះយកទឹកអម្រឹត តាមពាក្យយើងសព្វថ្ងៃថា អសុរ និងទេវតាទាញព្រ័ត្រ ។ ការកូរសមុទ្រទឹកដោះនេះ ប្រើថិរវេលាអស់វារៈកំណត់១.០០០ ឆ្នាំ ទើបបានទឹកអម្រឹត ។

បុរាណខ្មែរយើង ឆ្លាក់រឿងនេះនៅជញ្ជាំងថែវនគរវត្តភាគខាងកើតពេញផ្ទៃថែវ ធ្វើមុខមាត់មាឌសុទ្ធតែប្រឹង ។ មានធ្វើអសុរ និងទេពតាមមុខមាត់សម្បើមរាងក្រអឺត១ ទាញព្រ័ត្រនាគនៅគ្រប់ទ្វារនគរធំទៀត មិនតែប៉ុណ្ណោះទេសូម្បីរូបសីហៈ ឬរូបឆ្មាំទ្វារគោបុរៈក៏មានអាការថាថាងប្រឹងប្រែងទាំងអស់ ។ មើលចុះ មិនមែនទន់ល្វៃតល្វតរេទៅតាមខ្យល់ទេ ។ ទាំងអស់នេះ ជារូបភាពសម្ដែងភស្តុតាងព្យាយាម និងថាមភាពនៃដូនតានៅសម័យនគរវត្ត ។ បើយើងពោលដោយផ្លូវហេតុផលគួរទុកជាគតិបានថា គួរប្រឹងឬទេ? ព្រោះដូនតាសុទ្ធតែប្រឹងទាំងអស់ ។

នេះជាហិតោបទេស ភាគទី២ ឈ្មោះ “ការបំបែកមិត្ត” ជាជំហានទីពីរ ដែលបោះផ្សាយពេលនេះ ។ ខ្ញុំមានសង្ឃឹមថា ភាគទីពីរនេះ នឹងបានទទួលការនិយមអានគួរជាទីពេញចិត្តដូចភាគទី១ ដែរ ។ នៅសល់ពីរភាគទៀត ដែលនឹងផ្សាយទៅក្នុងអនាគតឆាប់ៗនេះ ខ្ញុំភ័យផ្អុកៗក្នុងពោះ ក្រែងខ្ញុំមិនអាចបោះជំហានទី៣ និងទី៤ ទៅមុខទៀតរួច ថាបើខ្ញុំអាចនឹងទៅបាន ខ្ញុំនឹងរីករាយសប្បាយចិត្តណាស់

ព្រោះវត្ថុបំណងរបស់ខ្ញុំ នឹងសម្រេចអស់ហើយ ។

ភាគទី២ នេះ ខ្ញុំទុកជាទីរលឹកការនៅចាំវស្សាអស់ត្រៃមាសក្នុងឆ្នាំខាលទោស័ក ព.ស. ២៤៩៣ ។

សូមប្រជាជនខ្មែរទាំងមូល បានប្រកបដោយសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ប្រការ!

វត្តឧណ្ណាលោម នៅថ្ងៃ៥ ១ ᧵ ១១ ឆ្នាំខាលទោស័ក ព.ស ២៤៩៣

ត្រូវនឹងថ្ងៃទី ២៦ ខែតុលា គ.ស. ១៩៥០

ភិក្ខុ ប៉ាង - ខាត់ (វីរិយបណ្ឌិតោ)

# បញ្ជីរឿង


| | | |
|---|---|---|
| កថាមុខអ្នកប្រែ | | ក |
| ការបំបែកមិត្ត | | ៣ |
| កថាទី១ | រឿងគោឧសភ ចចកពីរ និងសត្វសីហៈ | ៣ |
| កថាទី ២ | រឿងពានរ និងសសរ | ៨ |
| កថាទី ៣ | រឿង លា និង ឆ្កែ | ៩ |
| កថាទី ៤ | រឿង សីហៈ និង ឆ្មា | ១៨ |
| កថាទី ៥ | រឿងស្ត្រីពេស្យា និង គង | ២១ |
| កថាទី ៦ | រឿងបរិព្វាជកកន្ទប៏កេតុ | ២៥ |
| កថាទី ៧ | រឿងភរិយាគោបាល និងសហាយពីរនាក់ | ៣១ |
| កថាទី ៨ | រឿងក្អែកញី ឈ្មោល និង ពស់ | ៣២ |
| កថាទី ៩ | រឿងសីហៈ និង ទន្សាយ | ៣៣ |
| កថាទី ១០ | រឿងត្រដេវវិចញីឈ្មោល និងសមុទ្រ | ៣៩ |

# ២- ការបំបែកមិត្ត

កាលនោះ, ព្រះរាជកុមារទាំងឡាយទ្រង់ត្រាស់សួរមហាបណ្ឌិត**វិស្ណុស័ម៌ន**ថា "បពិត្រលោកអាយ៉ះ! លោកបានបង្រៀនយើងខ្ញុំទាំងអស់គ្នាឲ្យបានចេះដឹងរឿងមិត្តលាភ គឺការគប់មិត្តចប់ស្រេចហើយ ឥឡូវនេះ យើងខ្ញុំចង់ស្តាប់រឿងសុហ្ឫទ្ភេទ គឺការបំបែកមិត្តជាលំដាប់តទៅ សូមលោករៀបរាប់រឿងនេះឲ្យទានយើងខ្ញុំស្តាប់ទៀត" ។ មហាបណ្ឌិត**វិស្ណុស័ម៌ន** បានស្តាប់ព្រះបន្ទូលព្រះរាជកុមារទាំងឡាយនោះហើយ ក្រាបទូលថា៖ "បើដូច្នោះ សូមទ្រង់ទាំងឡាយរង់ចាំស្តាប់ ទូលព្រះបង្គំនឹងពណ៌នារឿងសុហ្ឫទ្ភេទ គឺការបំបែកមិត្តថ្វាយ ដូចមានស្លោកខាងដើមបទថា៖

១- សេចក្តីស្នេហាស្និទ្ធស្នាលដ៏ប្រសើរ កំពុងចម្រើនឡើងរវាងសត្វសីហ: និងគោឧសភ នៅក្នុងព្រៃមួយ ត្រូវចចកល្មោភជាអ្នកញុះញង់បំបែកឲ្យដល់សេចក្តីវិនាសអន្តរាយ" ។

ព្រះរាជកុមារទាំងឡាយត្រាស់សួរថា៖ "រឿងនោះតើដូចម្តេច?" ។ មហាបណ្ឌិត**វិស្ណុស័ម៌ន** ក្រាបទូលដូចតទៅនេះ៖

## កថាទី១

### រឿងគោឧសភ ចចកពីរ និងសត្វសីហ:

នៅក្នុងប្រទេសទក្សិណាបថ មាននគរមួយឈ្មោះសវណ្ណវតី ជាទីអាស្រ័យនៅនៃពាណិជម្នាក់ឈ្មោះវធ៌មាន: ជាអ្នកមានទ្រព្យច្រើន ។ ពាណិជវធ៌មាន: សូម្បីមានទ្រព្យស្រីង្គារស្តុកស្តម្ភដូច្នេះក្តី កាលបើឃើញញាតិសន្តានដទៃទៀតបរិបូណ៌ដោយទ្រព្យអនេកអនន្ត ក៏មានគំនិតនឹងស្វះស្វែងរកទ្រព្យសម្បត្តិ កពូនឲ្យរឹងរឹតតែមានច្រើនថែមទៀត, ព្រោះថា៖

២- នរជនដូចម្តេច កាលក្រឡេកមើលទៅខាងក្រោមឃើញជនជាន់ទាបជាងខ្លួន មិនឡើងជោរអួតអាងថាខ្លួនធំមហិមា តែកាលក្រឡេកមើលទៅខាងលើឃើញជនជាន់ខ្ពស់ជាងខ្លួន ទើបដឹងថា ខ្លួនជាអ្នកកម្សត់ក្រៃលែង ។

៣- នរជនណាមានទ្រព្យច្រើន នរជននោះសូម្បីសម្លាប់ព្រះព្រហ្មមួយ ក៏នៅតែមានគេគោរពបូជា, ឯនរជនក្រីក្រ សូម្បីមានវង្សត្រកូលខ្ពង់ខ្ពស់ស្មើនឹងវង្សព្រះបាទចន្ទ: ([១]) ក៏នៅតែគេមើលងាយ ។

---

[១] រាជវង្សមួយក្នុងប្រទេសឥណ្ឌា រាជធានីឈ្មោះ ប្រតិស្ឋាន: ស្ថិតនៅចន្លោះទន្លេគង្គា និងយមុនា សព្វថ្ងៃនៅក្នុងខេត្តដូអាប តមកព្រះរាជវង្សនេះផ្សាយអាណាខេត្តទៅដល់កុរុក្សេត្រ ហើយតាំងរាជធានីជាលំដាប់នៅ ឥន្ទ្រប្រស្ថ ហស្តិនាបុរ: និងកោសម្ពី ។

៤- លក្ខី ([1]) មិនរត់ទៅរកនរជនដែលឥតសេចក្តីប្រឹងប្រែង, ខ្ជិលច្រអូស, វង្វេងជឿព្រេងវាសនា និងមិនមានព្យាយាមទេ ដូចប្រពន្ធក្មេងមិនអើពើប្តីចាស់ជរាដូច្នោះ ។

៥- ភាវៈជាបុគ្គលខ្ជិល ១, ការសេពគប់ស្ត្រីផ្កាមាស ១, ភាវៈជាបុគ្គលមានរោគច្រើន ១, ចិត្តជាប់នឹងស្រុកកំណើត ១, ចិត្តសន្តោស ១, ភាវៈជាបុគ្គលខ្លាចច្រើន ១, ទោស ៦ ប្រការនេះ ជាគ្រឿងទម្លាយបង់នូវភាវៈនៃខ្លួនជាធំ ។

៦- នរជនណា មានទ្រព្យសម្បត្តិតិចតួច សម្គាល់ថាខ្លួនមានទ្រព្យច្រើន មិនខំរកតទៅទៀត ព្រះព្រហ្មដែលជាអ្នកសាងទ្រព្យសម្បត្តិមិនព្រមចម្រើនទ្រព្យសម្បត្តិឲ្យនរជននោះទេ ។

៧- កូនមិនឧស្សាហ៍ មិនជាទីគាប់ចិត្ត មិនមានវីរិយៈ ជាទីឡកឡឺយនៃសត្រូវ សូមកុំឲ្យស្ត្រីណាមួយបង្កើតកូនបែបនេះឲ្យសោះ ។

៨- បុគ្គលគប្បីស្វែងរកទ្រព្យដែលមិនទាន់បាន, គប្បីរក្សាទ្រព្យដែលរកបានហើយ កុំឲ្យរផាត់រទាំងអស់ទៅវិញ, គប្បីកពូនទ្រព្យសម្បត្តិដែលរក្សាទុកនោះ ឲ្យចម្រើនឡើងដោយប្រពៃ គប្បីកប់ទុកទ្រព្យសម្បត្តិដែលចម្រើនឡើងហើយក្នុងបុញ្ញខេត្ត ។

បុគ្គលកាលប្រាថ្នាទ្រព្យសម្បត្តិដែលមិនទាន់បាន តែងបានទ្រព្យសម្បត្តិនោះមក ដោយការយកទ្រព្យសម្បត្តិទៅទាក់ ឯទ្រព្យសម្បត្តិដែលរកបានហើយ បើមិនរក្សាទុកដោយម៉ត់ចត់ទេ សូម្បីមានទ្រព្យកប់ទុកជាកំណប់ច្រើនប៉ុណ្ណាក៏ដោយ ក៏នឹងវិនាសទៅឯង ។ មួយទៀត ទ្រព្យសម្បត្តិដែលបុគ្គលមិនធ្វើឲ្យបានចម្រើនឡើងទេ ក៏តែងតែអស់ទៅវិញបន្តិចម្តងៗគ្រប់កាល ដូចជាការអស់ទៅនៃថ្នាំបន្តក់ភ្នែក ។ ទ្រព្យសម្បត្តិនេះឯង បើបុគ្គលមិនចែកចាយជាទានឲ្យបានជាសាធារណសុខដល់ជនដទៃទេ ក៏អសារបង់សោះសូន្យទទេ, ព្រោះថា៖

៩- ទ្រព្យដែលគេមិនឲ្យទាន ឬមិនបរិភោគខ្លួនឯង មានប្រយោជន៍អ្វី? វេហ៍ពលដែលមិនយកទៅច្បាំងតស៊ូសត្រូវ មានប្រយោជន៍អ្វី? ការចេះដឹងគម្ពីរដីកាធម៌អាថ៌ បើគេមិនប្រតិបត្តិតាម តើមានប្រយោជន៍អ្វី? ខ្លួនយើង បើមិនទូន្មានឥន្ទ្រិយឲ្យបានបទទេ តើមានប្រយោជន៍អ្វី? ។

១០- ទឹកសម្រក់មួយដំណក់ៗ ជាលំដាប់ អាចពេញក្អមបាន នេះជាគ្រឿងឧបមានៃការរៀនសព្វវិជ្ជា ការប្រតិបត្តិធម៌ និងការសន្សំទ្រព្យសម្បត្តិ ។

១១- ជីវិតនរជនណា ដែលបណ្តោយឲ្យថ្ងៃប្រព្រឹត្តកន្លងទៅទទេ ដោយមិនបានបរិច្ចាគទ្រព្យខ្លួន

---

[1] សំណាងទ្រព្យសម្បត្តិ ។

ជាទាន និងបរិភោគបំពេញផ្ទៃខ្លួនឯងទេ ជីវិតនរជននោះ ដូចស្នប់ជាងដែក សូម្បីរស់ដកដង្ហើមចេញចូលបាន ក៏ឈ្មោះថាស្លាប់ ។

ពាណិជ**វឌ្ឍមានៈ**គិតឃើញដូច្នេះហើយ ក៏ប្រមូលទំនិញផ្សេងៗផ្ទុកពេញរទេះ ហើយយកគោឧសភទាំងពីរ គឺ**នន្ទកៈ** និង **សញ្ជីវកៈ** ទៅទឹម ធ្វើដំណើរចេញទៅប្រទេសកស្មីរ ដើម្បីធ្វើជំនួញ, ព្រោះថា៖

១២- បុគ្គល កាលឃើញការអស់ទៅនៃថ្នាំបន្តក់ភ្នែក និងការកកូននៃកណ្ដៀរហើយ គប្បីប្រឹងប្រែងឲ្យកើតប្រយោជន៍រាល់ៗថ្ងៃ ដោយការឲ្យទាន ដោយការសិក្សាក្បួនខ្នាត និងដោយការធ្វើការងារ ។

១៣- ភារៈដូចម្ដេច ដែលហៅថាធ្ងន់ណាស់ សម្រាប់អ្នកមានសមត្ថភាព? ទីណា ដែលហៅថាឆ្ងាយណាស់សម្រាប់អ្នកមានព្យាយាមច្រើន? ប្រទេសណា ដែលហៅថាបរទេសសម្រាប់អ្នកមានចំណេះវិជ្ជា? ជនណា ដែលហៅថាកន្ទៀត សម្រាប់អ្នកមានប្រិយវាទ? ។

ខណៈដែលពាណិជ**វឌ្ឍមានៈ** ធ្វើដំណើរចរចេញទៅដល់ព្រៃធំទុរគមឋានស្ងាត់មួយ, ជាគ្រោះថ្នាក់, គោឧសភ**សញ្ជីវកៈ** ភ្លាត់ជើងដួលបាក់ភ្លៅម្ខាង ដើរទៅមិនរួច, ពាណិជ**វឌ្ឍមានៈ** ឃើញដូច្នោះហើយ រំពឹងគិតថា៖

១៤- ជនអ្នកចេះដឹងនីតិសាស្ត្រ ល្បងធ្វើព្យាយាមខាងនេះខាងនោះលងមើលទៅចុះ តែផលដែលត្រូវបាននោះ ព្រះព្រហ្មលោកលិខិតទុកឲ្យជិតជាប់ក្នុងចិត្តរួចស្រេចហើយ ។

១៥- សេចក្ដីសង្ស័យស្ទាក់ស្ទើរចិត្តជាការអន្តរាយដល់សារពើការងារ បុគ្គលគប្បីលះបង់ចោលឲ្យអស់ស្រឡះទៅ ព្រោះថា កាលបើលះបង់សេចក្ដីសង្ស័យស្ទាក់ស្ទើរចិត្តហើយ ការសម្រេចផលប្រយោជន៍នឹងកើតប្រាកដទៅតាមរបៀប ។

លុះពិចារណាឃើញច្បាស់ដូច្នេះហើយ ពាណិជ**វឌ្ឍមានៈ** ទុកគោឧសភ**សញ្ជីវកៈ** ចោលនៅនាព្រៃនោះ ដើរកាត់ទៅកាន់នគរធម៌បុរីរកទិញគោឧសភមានរូបធាត់ធំមាំមួនបានមួយ យកមកទឹមរទេះជំនួស ហើយធ្វើដំណើររហូតតទៅទៀត ។ ឯគោ**សញ្ជីវកៈ** កាលដែលគេបោះបង់ចោលហើយទៅបាត់ ខំដើរខ្ចាក់ខ្ចើចតែជើង ៣ ខ្វានៗ រកស៊ីស្មៅក្បែរទីនេះទីនោះ ចិញ្ចឹមជីវិត, ព្រោះថា៖

១៦- សូម្បីលិចលង់ក្នុងមហាសមុទ្រ ឬធ្លាក់ចុះពីលើកំពូលភ្នំ ឬក៏ត្រូវនាគតក្សកៈ([១])ចឹក បើមិនទាន់ដល់កាលស្លាប់ទេ អាយុនៅតែរក្សាជីវិតន្ទ្រីយឲ្យរស់តទៅបាន ។

១៧- ([២]) សត្វលោក សូម្បីត្រូវសរមួយរយផ្លែ បើមិនទាន់ដល់កាល ក៏មិនស្លាប់, បើដល់កាល

---

[១] ឈ្មោះស្ដេចនាគ មានឫទ្ធិខ្លាំងពូកែ ។ [២]ហិតោបទេសសេចក្ដីប្រែជាភាសាបារាំង នៃលោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះ នរជនមិនទាន់ដល់មរណៈ សូម្បីធ្លាក់ពីលើកំពូលភ្នំក្ដីលិចលង់ក្នុងមហាសមុទ្រក្ដី ធ្លាក់ក្នុងភ្លើងក្ដី ឬប្រឡែងជាមួយពស់ក្ដី ក៏មិនស្លាប់ ។

មរណៈហើយ សព្វបើមុតដោយស្បូវបន្តិចក៏មិនរស់ដែរ ។

១៨- អ្វីមួយ មិនមានគេរក្សា តែមានបុណ្យវាសនាជួយរក្សា ក៏អាចស្ថិតស្ថេរទៅបាន អ្វីមួយមានគេរក្សាល្អហើយ តែបុណ្យវាសនាមិនជួយរក្សាផងក៏វិនាសអន្តរាយទៅបាន ប្រៀបដូចនរជនអនាថាគេលះបង់ចោលកណ្តាលព្រៃជ្រៅ គង់មានជីវិតរស់បាន, ឯនរជនមានគេរក្សាប្រយ័ត្នប្រយែង នៅតែក្នុងផ្ទះ ក៏ស្លាប់ទៅបាន ។

ក្នុងថ្ងៃដែលកន្លងទៅដោយលំដាប់ គោឧសភ**សញ្ជីវកៈ** ដើរស៊ីស្មៅជាអាហារក្បែរមាត់ស្ទឹងតាមទំនើងចិត្ត ហើយអាស្រ័យនៅក្នុងទីនោះ ឡើងសាច់ឈាមធាត់ធំមាំមួន មានកម្លាំងក្លៀវក្លាហានបោលលោតលេងកញ្ឆាត់កញ្ឆេង រោទិ៍លាន់ឮគឹកកងរំពងព្រៃ ។ មានសត្វសីហៈមួយឈ្មោះ**បិង្គលកៈ** ជាស្តេចសត្វចតុប្បាទអាស្រ័យនៅក្នុងព្រៃនោះ សោយសេចក្តីសុខក្នុងរាជសម្បត្តិដែលខ្លួនតតាំងច្បាំងយកបានដោយកម្លាំងដៃខ្លួន, ព្រោះថា៖

១៩- ម្រឹគទាំងឡាយមិនធ្វើពិធីបុណ្យអភិសេកឲ្យសីហៈទេ សីហៈបានរាជ្យ បានជាធំលើពួកសត្វម្រឹគ ដោយកម្លាំងព្យាយាមនៃខ្លួនឯង ។

ថ្ងៃមួយ, **បិង្គលកៈ** ស្រេកទឹក ដើរចេញទៅរកផឹកទឹកនៅត្រើយស្ទឹងយមុនា កំពុងតែដើរទៅ បានឮសំឡេងរោទិ៍រំពងព្រៃ ហាក់ដូចជាមហាមេឃគ្រហឹមគ្រិលៗ គគ្រឹកគគ្រេងរកកល់នឹងស្រក់ធ្លាក់ចុះមក លុះឮសំលេងរោទិ៍នោះហើយ ភ័យតក់ស្លុតរន្ធត់ចិត្តមហិមា មិនប៉ានចុះទៅផឹកទឹក ក៏វិលត្រឡប់ថយទៅកាន់ទីលំនៅដើមខ្លួនវិញ គិតពិចារណាមើលមិនយល់ថាជាសំឡេងអ្វីសោះ ក៏អង្គុយនៅស្ងៀមស្ងាត់មិនមាត់កឡើយ ។ កាលនោះ, មានចចកពីរ ឈ្មោះ**ករដកៈ** មួយទៀតឈ្មោះ**ទមនកៈ** ជាកូនមន្ត្រីចាស់នៃសីហៈនោះ នៅក្នុងទីជិតនោះដែរ ឃើញ**បិង្គលកៈ** កំពុងអង្គុយវិតក្កទ្រមឹងទ្រមើយដូច្នោះ ចចក**ទមនកៈ** សួរទៅកាន់ចចក**ករដកៈ**ថា “នែសម្លាញ់**ករដកៈ**! ម្ចាស់យើងស្រេកទឹកមានរឿងអ្វីទៅហើយបានជាមិនផឹក ហើយវិលត្រឡប់មកវិញ ស្រាប់តែញាប់ញ័ររន្ធត់ សញ្ជប់សញ្ជឹងអង្គុយនៅស្ងៀមស្ងាត់បាត់មាត់បាត់កដូច្នេះហ្ន៎?” ។ ចចក**ករដកៈ**ឆ្លើយប្រាប់ថា៖ “ហៃមិត្ត**ទមនកៈ**! តាមចិត្តខ្ញុំ យើងមិនត្រូវសេពគប់ម្ចាស់នេះទេ បើទុកជាមានរឿងដូច្នេះកើតឡើង មានប្រយោជន៍អ្វី នឹងជួយយកអាសា ឥឡូវនេះកុំទៅឲ្យប្រើល្អជាជាង ម្ចាស់យើងមិនមានលក្ខណៈធ្វើជាមេបាគេទេ យើងមិនមានទោសខុសអ្វីសោះ ស្រាប់តែមើលងាយបណ្តេញបំបរបង់យើង មិនដែលនឹកនាយើងសោះ យើងរងសេចក្តីទុក្ខធំបែបនេះ មកអស់

កាលយូរយារណាស់ហើយ, ព្រោះថា៖

២០- ចូរមើល! គួរអនិច្ចាអ្នកបម្រើ ចូលចិត្តធ្វើខ្ញុំបម្រើគេ ព្រោះតែចង់បានទ្រព្យ, មនុស្សល្ងង់ចូលចិត្តបម្រើគេ រហូតដល់វិនាសឥស្សរភាពខ្លួនក៏មិនថា ។

២១- អ្នកធ្វើខ្ញុំបម្រើគេ តែងធន់ទ្រាំលំបាកដោយត្រជាក់ ដោយខ្យល់ និងដោយកំដៅថ្ងៃ ឥតបានប្រយោជន៍អ្វីសោះ, ឯអ្នកប្រាជ្ញខំបំពេញតបៈ, បើទុកជាលំបាក គង់បានសេចក្ដីសុខជាផល ។

២២- ([1]) ការតាំងខ្លួនមិនឲ្យជាខ្ញុំគេ តែងបានផលជាសុខដល់ជីវិត, បើជនណា ព្រមនៅក្នុងអំណាចគេ ជននោះឈ្មោះថាមានជីវិតរស់ ដូច្នោះតើជនបែបណាវិញហ្ន៎ដែលឈ្មោះថាស្លាប់? ។

២៣- "មកណេះ! ទៅ! ក្រោកឡើង! នៅឲ្យស្ងៀម!" នេះជាសម្ដីអ្នកធំមានទ្រព្យសម្បត្តិនិយាយលេងជាល្បែងចំពោះអ្នកក្រីក្រជាខ្ញុំបម្រើ ដែលសេចក្ដីប្រាថ្នាទ្រព្យចាប់ត្របាក់បានហើយ ។

២៤- ជនអប្បឥតប្រាជ្ញា សម្រាំងខ្លួនហើយសម្រាំងទៀត ទុកបម្រុងគ្រាន់តែបម្រើជនដទៃជានាយ ព្រោះប្រាថ្នាទ្រព្យ ដូចស្ត្រីផ្កាមាសតុបតែងខ្លួនឲ្យល្អ ទុកសម្រាប់តែបុរស ។

២៥- ចៅហ្វាយនាយ តែងក្រឡេកសម្លឹងមើលការខុសឆ្គងមិនបរិសុទ្ធជាប្រក្រតីនៃខ្ញុំបម្រើដោយភ្នែកណាអ្នកបម្រើតែងរំពៃមើលភ្នែកនោះនៃម្ចាស់ដោយច្រើន ។

បើនៅទ្រមឹងមិននិយាយច្រើន គេថាល្ងង់, បើនិយាយ គេថានិយាយច្រើនពេក ឬថាឆ្កួត បើចេះអត់ធ្មត់ គេថាខ្លាច, បើជេរមិនឈឺ គេថានាភិជាតិ([2]), បើនៅជិត គេថាហ៊ានពេក បើនៅឆ្ងាយ ដោយមានវិន័យ គេថាញញើតញញើមពេក, សូម្បីព្រះយោគី ([3]) ក៏ផ្គាប់ចិត្តម្ចាស់ឲ្យពេញបរិបូណ៌មិនបានដែរ, ឱហ្ន៎ នាទីជាខ្ញុំបម្រើគេនេះ មានអាថ៌កំបាំងជ្រាលជ្រៅគួរតក់ស្លុតណាស់តើ! ។

២៧- អ្នកបម្រើលើកដៃសំពះ ព្រោះតែម្ចាស់ក្រោក, លះបង់ប្រាណ ព្រោះតែការពារជីវិតម្ចាស់ទទួលរងសេចក្ដីទុក្ខខ្លួនឯង ព្រោះតែរក្សាសេចក្ដីសុខម្ចាស់, ឱអនិច្ចាខ្ញុំបម្រើគេ! មានអ្វីល្ងង់ខ្លៅថោកទាបជាងនេះទៅទៀតហ្ន៎!

ចចក**ទមនកៈ** និយាយកាត់ឡើងថា ៖ "នែសម្លាញ់! ពាក្យនេះគេមិនត្រូវយកមកទុកដាក់ក្នុងចិត្ត

---

[1] ហិតោបទេសេចក្ដីប្រែជាភាសាបារាំង នៃលោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះ នរជនខ្លះប្រលែងជាមួយនឹងពស់ នរជនខ្លះបរិភោគកាមដោយប្រពន្ធជនដទៃ និងនរជនខ្លះជាខ្ញុំបម្រើស្ដេច, ឱគួរអនិច្ចា! មនុស្សលោកយើងនេះជាសត្វកាចកំរោលណាស់តើ! ។

[2] ត្រកូលថោកទាប ។

[3] ព្រះឥសូរ

សោះទេ, ព្រោះថា៖

២៨- ហេតុដូចម្តេច ក៏គេមិនគប្បីសេពគប់ឥស្សរជនជាម្ចាស់ដ៏ប្រសើរ បើម្ចាស់គាប់ចិត្តហើយ មិនយូរប៉ុន្មាន ម្ចាស់នឹងបំពេញមនោរថមិនខាន ។

២៩- បើមិនធ្វើជាសេវកាមាត្យ តើនឹងបានចាមរសែនត្វ័នស្វេតច្ឆ័ត្រដោយមដុងលើចុងដងក្តស់ មានពាជី គជេន្ទ្រនិងកងទ័ពចោមរោមរុងរឿងមកពីណា?" ។

ចចក**ករដក:** និយាយថា៖ "បើទុកជាដូច្នោះ យើងមិនត្រូវជួញរស់ដែរ មានប្រយោជន៍អ្វីសម្រាប់យើង? ការជួញរស់ក្នុងការមិនត្រូវជួញរស់ មានតែសេចក្តីវិនាសសាបសូន្យ, ចូរមើល!

៣០- នរជនណាជួញចិត្តរស់ក្នុងការដែលមិនត្រូវរស់ នរជននោះ នឹងត្រូវដេកស្លាប់លើផែនដីដូចពានរថ្លស់ខ្លួនដល់ស្លាប់ព្រះចាប់ទាញឈើស្នៀត" ។

ចចក**ទមនក:** សួរឡើងថា៖ "ចុះរឿងនោះ តើដូចម្តេច?" ។ ចចក **ករដក:** និយាយរៀបរាប់ប្រាប់ថា៖

# កថាទី២

## **រឿងពានរ និងសសរ**

នៅក្នុងប្រទេសមគធៈ មានជនត្រកូលកាយស្ថ ([១]) ម្នាក់ឈ្មោះ**សុភទត្ត** បានចាត់ចែងជាងឲ្យកសាងវិហារជិតធម៌ារណ្យមួយ ។ នៅវិហារនោះ មេជាងបង្គាប់ឲ្យកូនជាងអារពុះចុងសសរចំកណ្តាល ហើយឲ្យយកស្នៀតទៅស៊កទុកត្រង់កណ្តាលសសរដែលអារនោះ ។ មានស្វាមួយហ្វូងធំ តែងវារលោតលេងតាមទំនើងចិត្តពីទីនេះទីនោះរហូតដល់ទីឋាននោះ ។ មានពានរមួយ កាលមរណៈមកដល់ ក៏ទៅអង្គុយលើសសរដែលគេអារពុះជាពីរនោះ យកដៃទាំងពីរចាប់ទាញស្នៀតលេងជាល្បែងឥតពិចារណា ។ ស្វាសវាទាំងពីរសំយុងស្តោកធ្លាក់ទៅចំចន្លោះសសរ ដែលគេអារពុះជាពីរនោះ ។ រីចុងទាំងពីរនៃសសរនោះ កាលពានរទាញស្នៀតចេញផុតហើយ ក៏ក្តោបមកវិញកៀបស្វាសទាំងពីរខ្ទេចល្អិតជាផង់ធូលីដល់ក្តីស្លាប់ទៅហោង ហេតុនោះបានជាខ្ញុំ (**ករដក:**) និយាយថា៖ "នរជនណាជួញចិត្តរស់ ក្នុងការដែលមិនត្រូវរស់" ដូច្នេះជាដើម (លេខ ៣០) ។

ចចក**ទមនក:** និយាយអួតអាងថា៖ "មែនពិតហើយ, តែសេវកាមាត្រត្រូវតែយកចិត្តទុកដាក់មើលការងារម្ចាស់នឹងខានពុំបាន" ។ ចចក**ករដក:** ឆ្លើយកាត់ថា៖ "មុខក្រសួងត្បូងការទាំងពួង អ្នកណា

---

[១] ត្រកូលនេះ តាមយាជ្ញវល្កយ្យ ថាជាវណ្ណសូទ្រ: តែមានឋានៈជាក្សត្រ ។

មាននាទីជាប្រធានមន្ត្រី អ្នកនោះត្រូវធ្វើការងារនោះចុះ, អ្នកតូចតាចដូចយើងមិនគួរគប្បីទៅជែង ជួយព្រួយយកការងារគេដទៃមកធ្វើជំនួសទេ, ចូរមើល!

៣១- នរជនណាព្រួយជួសគេ ទៅជែងយកការងារជនដទៃមកធ្វើជំនួស ព្រោះតែប្រាថ្នាប្រយោជន៍ឲ្យចៅហ្វាយ នរជននោះ ត្រូវគេសម្លាប់ចោលបង់លើផែនដី ដូចលាត្រូវគេវាយសម្លាប់ចោលបង់សៀត ព្រោះតែបញ្ចេញសំឡេង” ។

ចចក**ទមនកៈ** សួររឿងនោះថា៖ “តើរឿងនោះដូចម្តេច?” ។ ចចក**ករដកៈ**និយាយរឿងនោះប្រាប់ថា៖

# កថាទី៣

## រឿងលា និង ឆ្កែ

នៅក្រុងពារាណសី មានអ្នកជ្រលក់ម្នាក់ឈ្មោះ**កប៉ូរបដកៈ** ។ អ្នកជ្រលក់នោះអង្គុយនិយាយលេងជាមួយប្រពន្ធក្មេងស្រស់ប្រិមប្រិយកំពុងពេញពាល ដោយក្តីស្នេហ៍ស្នាលអស់កាលយូរ ហើយដេកប្រកៀកប្រឱបគ្នាលន់លក់ស៊ប់មិនដឹងខ្លួន ។ កាលនោះ, មានចោរម្នាក់ចូលមកលបលួចទ្រព្យក្នុងផ្ទះអ្នកជ្រលក់នោះ ។ នៅក្នុងទីលានផ្ទះនោះ គេមានចងលាមួយទុក មានឆ្កែមួយចូលទៅដេកជាមួយលានោះដែរ, លាក៏និយាយទៅកាន់ឆ្កែថា “ហៃសម្លាញ់! មុខការនេះជាកិច្ចធុរៈឯងហើយ ហេតុអ្វីក៏ឯងមិនព្រុសឲ្យឮខ្លាំងឡើងឲ្យម្ចាស់យើងភ្ញាក់?” ឆ្កែឆ្លើយថា៖ “នែសម្លាញ់ដ៏ចម្រើន! ឯងមិនត្រូវជួយព្រួយជែងរវល់ដល់កិច្ចការអញទេ ឯងមិនដឹងជាអញនៅរក្សាផ្ទះទាំងយប់ទាំងថ្ងៃទេឬអ្វី? សូម្បីអញយកចិត្តទុកដាក់ថែរក្សាផ្ទះដល់ម្ល៉ោះ ម្ចាស់យើងក៏មិនរវល់ធ្វើដឹងឮ ម្ចាស់យើងមិនភិតភ័យអ្វីសោះ បានក្តីសុខមកអស់កាលយូរណាស់ហើយ ដល់មកពេលនេះ គ្រាន់តែអើពើនឹកនាឲ្យទានអាហារបន្តិចបន្តួចក៏មិនឲ្យ តែការនេះជាធម្មតាម្ចាស់ បើមិនឃើញមានទុក្ខធុរៈអ្វីទេ មិនរវល់អើពើនឹកនាអ្នកបម្រើឡើយ” ។ លាបានស្តាប់ហើយស្តីបន្ទោសថា៖ “ស្តាប់មើលវាហ៎ះ អាពាលចង្រៃនេះ!

៣២- នរជនណាមួយ ចាំបាច់គេហៅរកក្នុងកាលប្រកបការងារ នរជននោះ គេហៅថា “អ្នកបម្រើ” ឬហៅថា “សម្លាញ់” ដូចម្តេចកើត? ។

ឆ្កែឆ្លើយថា៖ “បើនរជនណាហៅរកខ្ញុំបម្រើ តែក្នុងពេលដែលត្រូវប្រើធ្វើការងារ តើនរជននោះនឹងឈ្មោះថា “ម្ចាស់” ដូចម្តេចកើត? ។

៣៣- ការចិញ្ចឹមខ្ញុំបម្រើដែលជ្រកអាស្រ័យនៅជាមួយ ការសេពគប់ម្ចាស់ ការប្រតិបត្តិធម៌ និង

ការប្រសូតកូន ទាំងអស់នេះឥតមានអ្នកណាលូកដៃទៅធ្វើជំនួសបានទេ” ។

លំដាប់នោះ, លាក្រោធស្រែកជេរថា៖ “នែអាចង្រៃ! អាគំនិតខូច! អាឯងចិត្តអាក្រក់អីម្ល៉េះ ក្នុងកាលវិបត្តិ ឯងប៊ានធ្វើព្រងើយ មិនអើពើដល់ការងារម្ចាស់ មិនថ្វីទេ ចាំមើលដល់ម្ចាស់ក្រោកឡើង ឯងគង់ដឹងខ្លួន អញមុខជាប្រាប់ម្ចាស់ហើយ, ព្រោះថា៖

៣៤- បុគ្គលគួរបូជាព្រះអាទិត្យពីខាងក្រោយខ្នង បូជាភ្លើងពីខាងពោះ បូជាម្ចាស់ដោយកាយ និងចិត្ត និងប្រតិបត្តិដើម្បីបរលោកដោយមិនមានមាយា” ។

លុះលាពោលដូច្នេះហើយ ក៏តាំងស្រែកដោយសម្រែកដ៏ខ្លាំង ដើម្បីឲ្យម្ចាស់ភ្ញាក់ ។ ខណៈនោះ អ្នកជ្រលក់ភ្ញាក់ស្ទន់ស្ទោក្រញាងឡើង ដោយសម្រែកខ្លាំងនោះ គ្នាន់ក្នាញ់ណាស់ព្រោះដាច់ដំណេក ក្រោកឡើងក្រទីក្រទាចាប់ទាញដំបងសំពងលានោះយ៉ាងអស់ទំហឹង រីលានោះត្រូវដំបងដំណាំទ្រមខ្លួនដល់នូវក្ដីស្លាប់ទៅហោង ។ ព្រោះហេតុនោះបានជាខ្ញុំ (**ករដក:**) ពោលថា៖ “នរណាព្រួយជួសគេ” ដូច្នេះជាដើម (លេខ ៣១) ។

ឯងពិនិត្យមើល! យើងត្រូវហែហាមម្ចាស់តែក្នុងកិច្ចការរបស់យើងប៉ុណ្ណោះបានហើយ, ថ្ងៃនេះយើងក៏សេសសល់អាហារគ្រប់គ្រាន់ហើយ យើងទៅជួយរវល់តើបានប្រយោជន៍ដូចម្ដេច? ។

ចចក**ទមនក:** ទាស់ចិត្តឆ្លើយកាត់ឡើងថា៖ “ចុះយើងបម្រើម្ចាស់ផែនដី ព្រោះតែចង់បានអាហារស៊ីតែប៉ុណ្ណឹងទេ? សម្ដីឯងនិយាយនេះឆ្វេងណាស់ មិនសមរម្យតាមគន្លងទេ, ព្រោះថា៖

៣៥- ការពឹងពាក់ព្រះនរបតី អ្នកប្រាជ្ញត្រូវការចង់បាន ដើម្បីធ្វើឧបការជួយមិត្ត និងដើម្បីបំផ្លាញសឹកសត្រូវ នរណាហ្ន៎ ពឹងពាក់ព្រះនរបតីព្រោះហេតុតែបំពេញផ្ទៃខ្លួនប៉ុណ្ណោះ? ។

៣៦- ជីព្រាហ្មណ៍ មិត្ត និងញាតិសន្តាន មានជីវិតរស់នៅព្រោះអាស្រ័យជីវិតនៃនរជនណា ជីវិតនៃនរជននោះឈ្មោះថា ប្រកបដោយផល នរណាហ្ន៎ មិនចិញ្ចឹមជីវិត ព្រោះប្រយោជន៍ខ្លួន? ។

៣៧- បើអ្នកណាមានជីវិតរស់នៅ បានញុំាងជនដទៃច្រើននាក់ឲ្យមានជីវិតរស់នៅបានផង សូមឲ្យអ្នកនោះមានជន្មាយុរស់នៅយឺនយូរ រីសត្វក្អែកវាមិនអាចបំពេញផ្ទៃវាបានដោយចំពុះវាឬ? ។

៣៨- មនុស្សខ្លះសុខចិត្តនៅជាខ្ញុំគេ ត្រឹមតែ ៥ បុរាណ (រៀល) មនុស្សខ្លះទៀត សុខចិត្តនៅជាខ្ញុំគេលុះត្រាតែបាន ១០០.០០០ បុរាណ, រីមនុស្សមួយពួកទៀត ចិត្តប្រសើរមិនសុខចិត្តនៅជាខ្ញុំគេ សូម្បីបានច្រើនជាង ១០០.០០០ បុរាណ ។

៣៩- ធម្មតាមនុស្សជាតិដូចគ្នា ភាពជាខ្ញុំគេ អ្នកប្រាជ្ញតិះដៀលក្រៃលែង, បណ្ដាខ្ញុំគេ អ្នកណាមិនបានជាដើមគេទេ គួរនឹងរាប់អ្នកនោះថាមានជីវិតរបស់នៅនឹងគេដែរឬទេ?

៤០- រវាងពាជី ដំរី លោហធាតុ, រវាងឈើ ថ្ម សំពត់, រវាងនារី បុរស ទឹក ទាំងអស់នេះឃ្លាតផ្សេងពីគ្នាធំណាស់ ។

៤១- ធម្មជាតិឆ្កែ បានឆ្អឹង សូម្បីអស់សាច់រលីងហើយនៅសល់តែសរសៃខ្លាញ់វារបន្តិចបន្តួច ក៏ត្រេកអរកខិបកខុប, មែនពិត ឆ្អឹងនោះមិនអាចបន្សាត់បង់សេចក្តីស្រេកឃ្លានឡើយ, រីឯសីហៈ សូម្បីបានចចកមួយមកនៅក្នុងក្រញាំក្រចកខ្លួនហើយ ក៏នៅតែបោះបង់ចោល ហើយស្ទុះទៅចាប់សម្លាប់ដំរីសារមួយទៀត, នរជនទាំងពួង ទោះគោកយ៉ាកលំបាកក្តីណា តែងតែមានសេចក្តីប្រាថ្នាចង់បានផលទៅតាមទំនងភាពខ្លួនជាសត្វលោក ។

មួយទៀត, ចូរពិចារណាមើលសេចក្តីផ្សេងគ្នារវាងម្ចាស់ និងខ្ញុំបម្រើដូចតទៅនេះ៖

៤២- ឆ្កែ លុតក្រាបរាបទាបជិតជើងម្ចាស់ ហាមាត់បង្ហាញចង្កូម បក់កន្ទុយរវិចៗនៅនឹងដីចាំទទួលសំណល់អាហារដែលម្ចាស់បោះទៅឲ្យ ឯដំរី ជាសត្វប្រសើរ មៀងមើលម្ចាស់ដោយឫកមាំ លុះត្រាតែលួងលោមច្រើនរយដងទើបបរិភោគ ។

៤៣- ជីវិតនៃមនុស្សណា សូម្បីតាំងនៅតែមួយខណៈ តែមិនប្រាសចាកការចេះដឹង សេចក្តីព្យាយាមអង់អាច នឹងកេរ្តិ៍ឈ្មោះយសសក្តិ អ្នកប្រាជ្ញពោលថាជីវិតនៃមនុស្សនោះ ពេញជាជីវិតដ៏ប្រសើរនៅនាលោកនេះ ព្រោះថា ក្អែកអាចមានជីវិតរស់នៅបានយូរ ព្រោះការស៊ីសំណល់គ្រឿងពលី ។

៤៤- ជីវិតនរជនណាដែលមិនផ្សាយសេចក្តីអាណិតអាសូរចំពោះកូនខ្លួន ចំពោះគ្រូ ចំពោះពួកខ្ញុំបម្រើ ចំពោះជនក្រីក្រលំបាក និងចំពោះញាតិសន្តាន ជីវិតនៃនរជននោះ បានផលប្រយោជន៍អ្វីនៅនាមនុស្សលោកនេះ? ព្រោះថា ក្អែកអាចមានជីវិតរស់នៅបានយូរបាន ព្រោះការស៊ីសំណល់គ្រឿងពលី ។

៤៥- នរជនអប្បឥតប្រាជ្ញាពិចារណាប្រយោជន៍ និងមិនមែនប្រយោជន៍ ប្រព្រឹត្តកន្លងគន្លងច្បាប់ច្រើនប្រការ មានសេចក្តីប្រាថ្នាគ្រាន់តែបំពេញផ្ទៃខ្លួនប៉ុណ្ណោះ នរជននេះហៅថាមនុស្សតិរច្ឆាន, ឯមនុស្សតិរច្ឆាន និងបសុសត្វ មានសេចក្តីប្លែកគ្នាដូចម្តេចខ្លះ?” ។

ចចក**ករដកៈ** ពោលតទៅថា៖ “ណ្ហើយ! យើងទាំងពីរនាក់មិនមែនជាប្រធានទេ យើងបបួលគ្នាគិតពីរឿងនេះ តើមានប្រយោជន៍អ្វី?” ។ ចចក**ទមនកៈ** ឆ្លើយថា៖ “បើដូច្នេះ តើអាមាត្យ ដែលបានជាប្រធាន ឬមិនទាន់បានជាប្រធាន នឹងទ្រទ្រង់ភាពបែបនោះអស់កាលប៉ុន្មាន, ព្រោះថា៖

៤៦- នៅនាលោកនេះ នរណាៗក៏គេមិនអាចកំណត់បានថាខ្លួនជាជនខ្ពង់ខ្ពស់ ឬជាជនថោកទាបជាងអ្នកណាតាមសភាពខ្លួនឯងបានទេ ចេស្តា (សំណាង) ខ្លួន ទើបនាំនរជនទៅកាន់ភាវៈគួរគោរព ឬកាន់ភាវៈវិបរិតមិនគួរគោរព ។

៤៧- ថ្ម បុគ្គលលើកយកឡើងទៅដាក់លើកំពូលភ្នំបានដោយសេចក្តីព្យាយាមដ៏ធំ តែបើទម្លាក់ចុះពីលើកំពូលភ្នំវិញបានដោយងាយយ៉ាងណា ខ្លួនយើងឡើងទៅកាន់ឋានៈខ្ពង់ខ្ពស់ដោយគុណគឺក្តីព្យាយាមដ៏ធំ តែបើធ្លាក់ខ្លួនទៅកាន់ឋានៈថោកទាបវិញដោយទោសដ៏ងាយៗក៏យ៉ាងនោះឯង ។

៤៨- នរជនធ្លាក់ចុះទៅខាងក្រោម ឬឡើងខ្ពស់ទៅខាងលើ ដោយកម្មជារបស់ខ្លួន ដូចជាគេជីកអណ្តូង ឬកសាងកំពែង តែងទាបខ្លួនចុះទៅតាមជម្រៅអណ្តូង ឬអណ្តែតខ្ពស់ឡើងតាមកម្ពស់កំពែង ។

នែសម្លាញ់អើយ! ខ្លួនយើងនេះ មានតែសេចក្តីព្យាយាមដែលនាំឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង" ។ ចចក**ទមនកៈ** សួរថា៖ "**បិង្គលកៈ** ម្ចាស់យើងនេះ ខ្ញុំឆ្ងល់មិនដឹងជាមានហេតុការណ៍អ្វីបានជាភិតភ័យតក់ស្លុតរត់ត្រឡប់មកវិញ" ។ ចចក**ករដកៈ**ឆ្លើយថា៖ "ចុះឯងធ្វើដូចម្តេចនឹងដឹងរឿងពិត?" ។ ចចក**ទមនកៈ**និយាយបញ្ចេញប្រាជ្ញថា៖ "រឿងអ្វី ដែលអ្នកប្រាជ្ញមិនដឹង? ព្រោះថា៖

៤៩- ពាក្យពេចន៍ ដែលបុគ្គលពោលចេញហើយ សូម្បីបសុសត្វក៏ចាប់យកសេចក្តីបាន, សេះនិងដំរី ដែលគេហ្វឹកហ្វឺនហើយ កាលបើជនបង្គាប់អាចនាំជនទៅបាន, ជនជាបណ្ឌិត សូម្បីគេមិនទាន់ហាមាត់ចេញនិយាយ វាងវៃដឹងទាន់ ព្រោះថា ប្រាជ្ញាមានផលប្រសើរ គឺការដឹងនូវទឹកចិត្តនៃជនដទៃដែលមានអាការចេញមកខាងក្រៅ ។

៥០- បុគ្គលអាចកត់សម្គាល់ នូវចិត្តនៃបុគ្គលដទៃដែលស្ថិតនៅខាងក្នុងដោយអាការខាងក្រៅបាន គឺដោយចរិយា ដោយគតិ ដោយកិរិយា ដោយទឹកសម្តី និងដោយវិការៈនៃភ្នែក និងមុខមាត់ ។

ពេលនេះ, ជាឱកាសល្អ រូបខ្ញុំនឹងធ្វើម្ចាស់យើង ដែលកំពុងមានអាសន្នភ័យខ្លាចនេះ ឲ្យនៅក្នុងកណ្តាប់ដៃដោយកម្លាំងប្រាជ្ញារបស់ខ្ញុំ, ព្រោះថា៖

៥១- ពោលពាក្យឲ្យសមកតាមកាលៈទេសៈ ធ្វើខ្លួនឲ្យគេស្រឡាញ់ប្រាកដ ស្មើនឹងភាពជាអ្នកសម្បុរស ចេះក្រោធឲ្យសមតាមសក្តិខ្លួន អ្នកណាចេះធ្វើដូច្នេះ អ្នកនោះជាបណ្ឌិត" ។

ចចក**ករដកៈ** ពោលបង្អាក់ថា៖ "នែសម្លាញ់អើយ! ឯងមិនចេះប្រតិបត្តិនាទីជាសេវកាមាត្យទេ, ឯងមើលហ៎ះ! លោកពោលថា៖

៥២- នរជនណាម្ចាស់មិនបានហៅ ដើរតត្រុកចូលទៅរក ម្ចាស់មិនសួរ និយាយថែប៉ប្រែច្រើនដោយសម្គាល់ខ្លួនថាជាទីប្រោសប្រាណនៃព្រះភូបាល នរជននោះ ឈ្មោះថាជនអប្បឥតប្រាជ្ញា" ។

ចចក**ទមនកៈ** ឆ្លើយកាត់ឡើងថា៖ "នែសម្លាញ់ដ៏ចម្រើនអើយ! ម្តេចក៏សម្លាញ់យល់ថារូបខ្ញុំមិនចេះប្រតិបត្តិនាទីជាសេវកាមាត្យ? ចូរមើលហ៎ះ!

៥៣- មានរបស់អ្វីមួយដែលល្អ ឬមិនល្អ ទៅតាមសភាពរបស់វាឬទេ? របស់ណាគាប់ចិត្ត នរជនណា របស់នោះឈ្មោះថាល្អសម្រាប់នរជននោះ ។

៥៤- នរជនណាៗមានភាពលក្ខណៈយ៉ាងណាក៏ដោយ កាលអ្នកប្រាជ្ញចូលទៅនៅជិតហើយ អាចញ៉ាំងនរជននោះៗ ឲ្យនៅក្នុងអំណាចនៃខ្លួនបានដោយឆាប់រួសរាន់ ។

៥៥- កាលបើព្រះរាជាជាម្ចាស់សួរថា "អ្នកណានៅទីនេះ?" ដូច្នេះ សេវកាមាត្យឆ្លើយថា "ទូលព្រះបង្គំជាខ្ញុំ ព្រះករុណាថ្លៃវិសេស រង់ចាំទទួលព្រះរាជបញ្ជា" ដូច្នេះហើយ សេវកាមាត្យនោះត្រូវចាត់ចែងការនោះដោយប្រពៃ និងត្រូវធ្វើតាមព្រះរាជអាជ្ញាឲ្យពិតប្រាកដតាមសក្តិខ្លួន ទាល់តែសម្រេចតាមសេចក្តីប្រាថ្នាម្ចាស់ផែនដី ។

៥៦- សេវកាមាត្យណាមានសេចក្តីប្រាថ្នាតិច មាននិស្ស័យម៉ឺងម៉ាត់ មានប្រាជ្ញា ដើរតាមហែហមព្រះរាជាគ្រប់កាលទាំងពួងដូចស្រមោលអន្ទោលតាមប្រាណ ធ្វើតាមបញ្ជាមិនរួញរា សេវកាមាត្យនោះ សមនៅក្នុងព្រះរាជដំណាក់បាន" ។

ចចក**ករដកៈ** និយាយកាត់ទៀតថា៖ "ចួនកាលម្ចាស់មិនពេញព្រះទ័យនឹងឯង ក្នុងពេលដែលឯងចូលគាល់ក្នុងកាលមិនគួរ" ។ ចចក**ទមនកៈ**ឆ្លើយថា៖ "ពិតមែនហើយ, តែបើទុកជាដូច្នេះក៏ដោយ អ្នកបម្រើត្រូវតែនៅរង់ចាំទទួលមុខងារខ្លួនដោយប្រយ័ត្នប្រយែង, ព្រោះថា៖

៥៧- ការមិនប៊ានប្រារព្ធធ្វើអ្វី ព្រោះភ័យខ្លាចតែពីខុស នេះជាលក្ខណៈនៃបុរសគម្រក់, នែសម្លាញ់អើយ! នរណាលះបង់ចោលអាហារភោជនមិនប៊ានបរិភោគ ព្រោះខ្លាចអាហារមិនរលួយ? ។

៥៨- ព្រះនរបតីតែងរាប់រកតែមនុស្សណាដែលនៅជិតផ្ទាល់ព្រះអង្គ ទោះមនុស្សនោះល្ងង់ខ្លៅក្តី ត្រកូលថោកទាបក្តី ឬមិនបានទូន្មានខ្លួនដោយប្រពៃក្តី, តាមធម្មតា ព្រះរាជា ស្ត្រីភាព ឬលតាជាតិ តែងទាក់ទងព័ទ្ធព័ន្ធចំពោះតែអ្នកណា ឬដើមឈើណាដែលនៅជិត" ។

ចចក**ករដកៈ** សួរថា៖ "នែសម្លាញ់! ថាបើដូច្នោះ ឯងចូលទៅគាល់ព្រះរាជា តើគិតនិយាយថាដូចម្តេច?" ។ ចចក**ទមនកៈ** ឆ្លើយប្រាប់ថា៖ "ចូរឯងចាំស្តាប់ រូបខ្ញុំទៅនេះ ដើម្បីឲ្យបានដឹងថា ម្ចាស់យើងមានសេចក្តីប្រោសប្រាណ ឬមិនប្រោសប្រាណទេ?" ។ ចចក**ករដកៈ** សួរថា៖ "ធ្វើម្តេចឯងនឹងដឹងលក្ខណៈបានថា ទ្រង់ប្រោសប្រាណ ឬមិនប្រោសប្រាណ?" ។ ចចក**ទមនកៈ** ឆ្លើយប្រាប់ថា៖ "ចូរឯងពិចារណាមើល៖

៥៩- ទតព្រះនេត្រមើលមកពីចម្ងាយ ទ្រង់ញញឹមស្រស់ពព្រាយ ទ្រង់ចចាកអារាក សាកសួរដោយរួសរាយ សរសើរគុណលក្ខណៈ សូម្បីក្នុងទីកំបាំងមុខ ឬទ្រង់រំឭកការកម្សត់ដែលយើងពេញ

ចិត្ត ។

៦០- ទ្រង់ប្រោសប្រាណ សូម្បីជនមិនមែនជាសេវកាមាត្យ, ទ្រង់ប្រោសព្រះរាជទាន, ទ្រង់ពោលប្រាស្រ័យគួរឲ្យស្រឡាញ់ពេញចិត្ត, ទ្រង់រំឭករឿងសព្វព្រះទ័យនៃជនដែលទ្រង់ប្រោសប្រាណ ឬទ្រង់សង្គ្រោះនឹកដល់គុណយើង សូម្បីចំពោះរឿងដែលជាទោស ។

៦១- ទ្រង់ត្រាស់ប្រើមិនមានកាលកំណត់, ទ្រង់ពោលពាក្យសន្យារឿយៗ និងទ្រង់កំណត់ផលដែលត្រូវបាន ទាំងអស់នេះ នរជនដែលមានប្រាជ្ញាអាចកំណត់ដឹងបាននូវលក្ខណៈព្រះរាជា ដែលមានសេចក្តីប្រោសប្រាណ ឬមិនមានសេចក្តីប្រោសប្រាណ ។

កាលបើខ្ញុំដឹងកិច្ចការនេះសព្វគ្រប់ហើយ ខ្ញុំនឹងរករឿងនិយាយដូចម្តេចឲ្យទាល់តែព្រះរាជាសព្វព្រះទ័យពុំខាន ។

៦២- ([១]) អ្នកប្រាជ្ញទាំងឡាយតែងសម្តែងប្រាប់នូវការវិបត្តិ (អន្តរាយ) ដែលកើតពីការយល់ឃើញខុស និងសិទ្ធិ(ការសម្រេច) ដែលកើតពីការយល់ឃើញត្រូវ ឲ្យឃើញស្តែងតាមនីតិវិធី បង្ហាញឲ្យឃើញដូចជាអ្វីមួយដែលផុសប្រាកដឡើងក្នុងទីចំពោះមុខ" ។

ចចក**ករដក:** និយាយប្រាប់ថា "ប៉ុន្តែបើកាលមិនគួរទេ កុំនិយាយ, ព្រោះថា៖

៦៣- ([២]) សូម្បីព្រះពួហស្បតិ៍ កាលពោលនូវពាក្យខុសកាល ក៏បាននូវការមើលងាយប្រាជ្ញា និងការមើលងាយដទៃទៀតច្រើនប្រការ" ។

ចចក**ទមនក:** ឆ្លើយថា៖ "នែមិត្ត! ឯងកុំភិតភ័យអ្វី ទុកងារឲ្យរូបខ្ញុំចុះ ពាក្យណាដែលមិនគួរដល់ការ រូបខ្ញុំមិននិយាយពាក្យនោះទេ, ព្រោះថា៖

៦៤- ក្នុងគ្រាអន្តរាយកើតឡើង ក្នុងការដើរវង្វេងផ្លូវ និងក្នុងគ្រាប្រកបការក្នុងកាលគួរធ្វើ ខ្ញុំបម្រើ ដែលប្រាថ្នាប្រយោជន៍ សូម្បីម្ចាស់មិនសួរនាំ ក៏ត្រូវតែពោល ។

ថាបើរូបខ្ញុំមិននិយាយស្នើមតិ ក្នុងកាលគួរមកដល់ហើយ នុ៎ះ ក៏រូបខ្ញុំមិនសមធ្វើជាមន្ត្រីដែរ, ព្រោះថា៖

---

[១] ហិតោបទេស សេចក្តីប្រែជាភាសាសៀមរបស់លោកនាគប្រទីប មានគាថាលើសដូច្នេះគឺ ទោសត្រឡប់ទៅជាគុណ គុណត្រឡប់ទៅជាទោសវិញ និងទោសនៅជាទោស គុណ នៅជាគុណ ការមិនមានលក្ខណៈជាម្ចាស់មាន ៣ ប្រការដូច្នេះ ។

[២] ហិតោបទេស សេចក្តីប្រែជាភាសាបារាំង របស់លោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះគឺ បពិត្រព្រះទេវបាទ! ព្រះរាជាតែងជួបប្រទះតែមនុស្សបញ្ចោរឿយៗ ឯមនុស្សដែលមិនសូវជួបប្រទះណោះគឺមនុស្សដែលចង់និយាយឮ ចង់ស្តាប់សេចក្តីពិត សូម្បីរឿងមិនពេញចិត្ត ។

៦៥- ការប្រព្រឹត្តចិញ្ចឹមជីវិត ដែលលោកសប្បុរសទាំងឡាយសរសើរនៅក្នុងលោកនេះ ដោយគុណណា គុណនោះ បុគ្គលអ្នកមានគុណគួររក្សាទុកដោយប្រពៃផង គួរធ្វើឲ្យចម្រើនកើនឡើងផង ។

ហៃសម្លាញ់! បើដូច្នោះ ចូរសម្លាញ់បើកឲ្យរូបខ្ញុំទៅជួប**បិង្គលកៈ** ក្នុងកាលឥឡូវនេះចុះ” ។ ចចក**ករដកៈ**ឲ្យពរថា៖ “សុភមស្តុ! សូមឲ្យបានប្រកបដោយសេចក្តីសុខក្សេមក្សាន្តកុំបីឃ្លាត, សូមសេចក្តីប្រាថ្នាបានសម្រេចផលតាមដែលបានដៅកុំបីខាន” ។ លំដាប់នោះ ចចក**ទមនកៈ** ដើរចូលទៅកាន់សំណាក់ **បិង្គលកៈ** ។ គ្រានោះឯង **បិង្គលកៈ** មើលទៅឃើញចចក**ទមនកៈ** ដើរចូលមកពីចម្ងាយក៏បង្គាប់ឲ្យគេហៅចូលទៅ ។ ចចកដើរចូលទៅធ្វើហាក់ដូចជាខ្លាចណាស់ ធ្វើអាការៈញញើតញញើមបែបត្រុនៗ ដល់ហើយឱនក្រាបប្រណិប័តន៍ដោយអស្តាង្គបាត ប្រណិប័តន៍ហើយអង្គុយក្នុងទីដ៏គួរមួយ ។ **បិង្គលកៈ** ថៅវៅសួរទៅថា៖ “យីអើ! អញខានឃើញមុខឯងយូរយារណាស់ហើយណ៎ា!!” ។ ចចក **ទមនកៈ** ឆ្លើយភ្លាមថា៖ “ព្រោះព្រះទេវបាទដ៏មានសិរី មិនមានកិច្ចការអ្វីជាប្រយោជន៍ចំពោះខ្ញុំបាទជាសេវកាមាត្យ តែបើទុកជាដូច្នោះ, ដល់កាលគួរហើយ ខ្ញុំបម្រើត្រូវតែចូលមកគាល់, ហេតុនោះទើបខ្ញុំបាទចូលមកគាល់ឥឡូវនេះ ព្រោះថា៖

៦៦- បពិត្រព្រះរាជា! ការងារម្ចាស់មានច្រើនណាស់ លោកតែងត្រូវការ សូម្បីស្មៅមួយទងសម្រាប់ជម្រះព្រះទន្ត ឬធ្វើជាតំបារត្បារព្រះកាណ៌ ចាំបាច់និយាយថ្វីដល់ទៅនរជនដែលមានខ្លួនទាំងដុលចេះនិយាយមានដៃជើងប្រាកដដូច្នេះ ។

បើលោកម្ចាស់ល្មេងយល់ថា ខ្ញុំបាទនេះជាបុគ្គលអប្បឥតប្រាជ្ញា ដូច្នោះមែនបានជាលះបង់ចោលយូរយារណាស់ហើយ នុ៎ះគួរលោកម្ចាស់កុំល្មេងយល់ដូច្នេះទៀតឡើយ, ព្រោះថា៖

៦៧- ([១]) នរជនមានប្រាជ្ញា និងមានសេចក្តីប្រព្រឹត្តម៉ឹងម៉ាត់ សូម្បីជនដទៃមើលងាយថាមិនបានជាការអ្វី នុ៎ះក៏បុគ្គលមិនគប្បីសន្និះសង្ស័យថា “វិនាសសាបសូន្យ”ឡើយ ភ្លើងសូម្បីបុគ្គលយកទៅដាក់ខាងក្រោម, ក្នុងកាលណាក៏ដោយ អណ្តាតភ្លើង មិនដែលទៅក្រោមទេ តែងទៅតែខាងលើជាដរាប ។

---

[១] ហិតោបទេស សេចក្តីប្រែជាភាសាបារាំង របស់លោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះគឺ ក. ក្នុងសង្គ្រាម នរជនណាអាចបាញ់ព្រួញដេរដាស់ព្រះធរណីដ៏ធំនេះ ដោយសេចក្តីអង់អាចដោយទ្រង់ទ្រាយឆើត និងដោយការចេះជ្រាលជ្រៅ នរជននោះ កាលនៅជិតព្រះរាជាក៏ត្រូវនិយាយដោយញញើតញញើម ដោយសេចក្តីហេតុខ្លាចព្រះចេស្តា, នៅចំពោះព្រះភក្ត្រ, ត្រូវគារវៈបែបនេះដរាប ។ ខ. នៅចំពោះព្រះភក្ត្រព្រះរាជា នៅកណ្តាលប្រជុំពាល និងនៅក្នុងទីប្រជុំស្ត្រីផ្កាមាស សូម្បីនរជនមានថ្វីមាត់ ក៏មានចិត្តខ្លបខ្លាចក្លាយទៅជាត្រិនត្រុនទីមទាម ។ តាមលក្ខណៈសម្បត្តិ នៃបុគ្គលមិនចេញមកឲ្យឃើញប្រាកដឯងទេ, ដូចទឹកអប់កស្តូរិកា គេមិនអាចរកបានដោយផ្លូវងាយស្រួលទេ ។

ទេវៈ! សូមលោកម្ចាស់ឈ្វេងយល់ដោយវិសេសទៅទៀតថា៖

៦៨- កែវមណី គេយកទៅប្រដាប់ជើង កញ្ចក់គេយកទៅប្រដាប់លើសិរសា បើទុកជាដូច្នេះ របស់ណាដូចម្ដេច របស់នោះនៅតែដូច្នោះដដែល គឺកញ្ចក់នៅតែជាកញ្ចក់ កែវមណីនៅតែជាកែវមណី ។

៦៩- កាលណាព្រះរាជា ទ្រង់រាប់អាននរជនទាំងពួងស្មើភាគគ្នា មិនឲ្យមានវិសេសប្លែកគ្នា, ឧស្សាហៈនៃជនមានសមត្ថភាពប្រឹងប្រែងធ្វើការងារ នឹងសាបរលាបខិនថយចុះទៅ ។

៧០- បពិត្រព្រះរាជា! បុរសមាន ៣ ជាន់ គឺបុរសឧត្តម, បុរសទាបថោក និងមធ្យម, ទ្រង់គប្បីចាត់ចែងឲ្យធ្វើការងារទៅតាមជាន់ទាំង ៣ នេះឯង ។

៧១- សេវកាមាត្យដូចគ្នានឹងគ្រឿងអាភរណៈ ត្រូវទុកដាក់ឲ្យសមតាមឋានៈដូចកែវមណីសម្រាប់រំលេចមកុដ មិនត្រូវយកទៅដាំកងជើង ឬពុំនោះកងជើងមិនត្រូវយកទៅប្រដាប់សិរសាឡើយ ។

៧២- កែវមណី គួរយកទៅប្រដាប់គ្រឿងអាភរណៈ ជាវិការនៃមាស បើគេយកកែវមណីទៅប្រដាប់គ្រឿងអាភរណៈ ជាវិការនៃសំណរ កែវមណីនោះ មិនមានពន្លឺប្រុះផ្លុះច្រវាត់ផង មិនល្អរុងរឿងផង តែការនេះជាកំហុសជាងមាសដោយឡែកទេ ។

៧៣- លើកកញ្ចក់យកទៅបណ្ដុបលើកំពូលមកុដ សម្រុតកែវមណីយកទៅប្រដាប់កងជើងវិញ, នេះជាទោសនៃកែវមណីក៏ឥតអង្គីមាន ជាទោសនៃជាងមាសល្ងង់ មិនចេះប្រើ មិនស្គាល់តម្លៃទេតើ! ។

៧៤- ព្រះនរបតី ដែលទ្រង់ឈ្វេងយល់ស្គាល់សេវកាមាត្យថា "អ្នកនេះមានប្រាជ្ញា មានភក្ដី អ្នកនោះមានសេចក្ដីក្លៀវក្លាហាន ឬប្រកបព្រមដោយលក្ខណៈពីរប្រការនោះ តែងបរិបូណ៌ដោយសេវកាមាត្យទាំងឡាយ ។

៧៥- សេះ, សស្ត្រាវុធ, សាស្ត្រវិជ្ជា, ពិណ, សុន្ទរកថា, នរជន និងនារី វិសេស ឬមិនវិសេស ប្រើបានល្អ ឬមិនបានល្អ, ស្រេចហើយតែវិធីនៃម្ចាស់អ្នកប្រើ អ្នកបង្គាប់បញ្ជាទេ ។

៧៦- មានប្រយោជន៍អ្វីដោយជនភក្ដី តែមិនមានសមត្ថភាព, មានប្រយោជន៍អ្វីដោយជនអង់អាច តែមិនធ្វើអ្វីកើតប្រយោជន៍, បពិត្រព្រះរាជា! ទ្រង់មិនគួរមើលងាយទូលព្រះបង្គំជាខ្ញុំ ដែលមានភក្ដីផង មានសេចក្ដីអង់អាចផងដូច្នេះទេ ។

៧៧- បើទ្រង់មើលងាយអ្នកចេះដឹង ទ្រង់មានតែជនអប្បឥតប្រាជ្ញាជាបរិវារ, តទៅ ដោយអាស្រ័យហេតុនេះ ទ្រង់នឹងមិនមានជនជាអ្នកប្រាជ្ញនៅក្បែរព្រះអង្គឡើយ ព្រោះការមិនស្គាល់នីតិវិធីនេះឯង, កាលបើរាជ្យណាលះបង់សេវកាមាត្យជាអ្នកប្រាជ្ញហើយ រាជ្យនោះនឹងមិនមានផ្លូវនយោបាយ

ល្អទេ, បើវិបត្តិនយោបាយល្អហើយ ប្រទេសជាតិទាំងមូល នឹងកប់លិច ឬវិនាសបាត់ចេញពីក្នុងផែនទីលោកនេះឥតសង្ស័យឡើយ ។

៧៨- អ្នកនគរ គោរពអស់កាលជានិច្ច ចំពោះជនណាដែលព្រះនរបតីលើកតម្កើង ជនណាដែលព្រះនរបតីមើលងាយហើយ ជននោះក៏ត្រូវអ្នកនគរទាំងអស់មើលងាយតាមដែរ ។

៧៩- ពាក្យដែលត្រឹមត្រូវ គួរដល់ការងារ សូម្បីជាសម្តីកូនក្មេង អ្នកមានប្រាជ្ញា ក៏គួរកាន់យក, បើមិនមានពន្លឺព្រះអាទិត្យទេ ពន្លឺប្រទីប នឹងមិនមានគុណប្រយោជន៍ ឬអ្វី?" ។

**បិង្គលកៈ** និយាយតបថា "នែ**ទមនកៈ**ដ៏ចម្រើនអើយ! ឯងនិយាយអ្វីដូច្នោះ ឯងជាកូននៃប្រធានអាមាត្យរបស់យើង, ប្រហែលជាដោយពាក្យទ្រគោះបោកបោះបន្តិចបន្តួចឬអ្វី បានជាឯងមិនចូលមករកយើងអស់កាលយូរយារដល់ម្ល៉េះ? បើដូច្នោះ ចូរឯងនិយាយដោយសេរីមកចុះ មានរឿងអ្វីខ្លះ?" ។ ចចក**ទមនកៈ** និយាយតបទៅទៀតថា "បពិត្រលោកជាស្តេចម្រឹគ! ខ្ញុំបាទសូមទានឱកាសជម្រាបសួររឿងបន្តិច សូមលោកម្ចាស់មេត្តានិយាយប្រាប់ដំណើរសេចក្តីតាមខ្ញុំបាទដឹងថាលោកម្ចាស់ត្រូវការទឹក លោកម្ចាស់អញ្ជើញទៅហើយមិនទាន់បានក្រេបផឹកបំបាត់សេចក្តីស្រេកឃ្លានផង ក៏ស្រាប់តែវិលត្រឡប់មកនៅស្ងៀមវិញហាក់ដូចជាមានហេតុភេទអ្វីមួយ មុខគួរឲ្យតក់ស្លុតរន្ធត់ព្រះទ័យណាស់?" **បិង្គលកៈ** និយាយប្រាប់ថា៖ "អើ! ឯងមានវិចារណញ្ញាណល្អហើយ, តែយើងមិនមានអ្នកណាជាទំនុកទុកចិត្ត នឹងប្រាប់អាថ៌កំបាំងនេះបាន មានតែឯង ។ បើដូច្នោះ យើងនឹងបកអាថ៌កំបាំងនោះប្រាប់ឯងក្នុងកាលឥឡូវនេះ ឯងចាំស្តាប់ដូចសេចក្តីតទៅនេះចុះ ។ ឥឡូវនេះ, ព្រៃនេះមានសត្វអ្វីប្លែកមួយមកនៅត្រួតត្រា យើងគួរភៀសខ្លួនគេចចេញពីទីនេះទៅ នេះហើយជាហេតុការណ៍នាំឲ្យអញភ័យខ្លាច អញបានឮសំឡេងវាចម្លែកអស្ចារ្យ បើតាមប្រមាណមើលសម្រែកវាឮខ្លាំងដូច្នេះនេះ គង់រូបរាងធំមាំមួនមានកម្លាំងខ្លាំងមហិមា ទើបបានជាឮខ្លាំងដល់ម្ល៉ោះ" ។ ចចក**ទមនកៈ**និយាយឡើងថា៖ "ទេវៈ! នេះក៏ជាហេតុការណ៍នាំឲ្យមានភ័យធំពិត, សំឡេងនោះ ខ្ញុំបាទក៏បានឮដែរ តែខ្ញុំបាទឆ្ងល់ណាស់ អ្នកណាដែលមកជម្រាបលោកម្ចាស់ថា ឲ្យលះបង់ព្រះរាជអាណាចក្រ ហើយសឹមធ្វើសង្គ្រាមដណ្តើមយកព្រះរាជអាណាចក្រជាខាងក្រោយវិញ អ្នកនោះសមធ្វើជាមន្ត្រីជាទីប្រឹក្សាឬទេ? មួយទៀត, ក្នុងការដែលមានអាសន្នក្រនេះ លោកម្ចាស់គប្បីឈ្វេងយល់ការងារសេវកាមាត្យបាន, ព្រោះថា៖

៨០- គ្រាវិបត្តិ នរជនត្រូវស្គាល់ខ្លឹមសារប្រាជ្ញានៃពួកញាតិសន្តាន ភរិយា និងសេវកាមាត្យ ព្រមទាំងសត្តនិករ និងខ្លួនឯង ឲ្យដូចជាថ្មសម្រាប់ពិសោធន៍មើលមាសសុទ្ធ" ។

**បិង្គលកៈ** និយាយបញ្ជាក់ថា៖ “នែសម្លាញ់ដ៏ចម្រើន សេចក្តីភ័យនេះនាំឲ្យអញទុញទាល់គំនិត គិតអ្វីមិនឃើញទេ” ។ ចចក**តមនកៈ** នឹកតែក្នុងពោះថា “បើម្ល៉ឹងតើ ម្តេចឡើយនឹងមិនប៉ាននិយាយប្រាប់អាត្មាអញអំពីការលះបង់រាជ្យ ហើយគិតរត់ទៅនៅទីដទៃ”, ទើបប្រកាសឮខ្លាំងៗទៅសីហៈថា “ទេវៈ! សូមលោកម្ចាស់តាំងព្រះទ័យឲ្យក្សេមក្សាន្តចុះ, ដរាបណាខ្ញុំបាទមានជីវិតរស់នៅ ដរាបនោះ លោកម្ចាស់កុំភ័យខ្លាចឲ្យសោះ, តែសូមលោកម្ចាស់ប្រោសមេត្តារក្សាទឹកចិត្តចចក**ករដកៈ** និងសត្វឯទៀតជាបរិវារផង ក្នុងគ្រាក្រធ្វើម្តេចនឹងប្រមូលរកវេហ៍ពលជាបុគ្គលរកបានក្រឲ្យបានច្រើនសម្រាប់ជួយការពារ?” ។ លំដាប់នោះ ចចកទាំងពីរ**ទមនកៈ** និង**ករដកៈ** បានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់អំពី**បិង្គលកៈ** ហើយប្តេជ្ញានឹងការពារភ័យអន្តរាយទាំងពួងឲ្យ ហើយទើបបបួលគ្នាដើរចរចេញទៅ ។ ចចក**ករដកៈ** ដើរបណ្តើរនិយាយបណ្តើរទៅកាន់ចចក**ទមនកៈ**ថា៖ “នែសម្លាញ់! ហេតុនៃភ័យនេះយើងមិនអាចដឹងថាយើងអាចការពារបាន ឬមិនបាននៅឡើយទេ ហើយយើងបានប្តេជ្ញាជាដាច់ខាតរួចមុនទៅហើយថា នឹងរម្ងាប់ភ័យនោះឲ្យទាល់តែសម្រេច បានទាំងទទួលមហាប្រសាទស្រេចទៅហើយផង មិនមែនឬ? យើងមិនត្រូវទទួលយកអាសាចំពោះនរណាសោះ ដោយវិសេសចំពោះម្ចាស់យើង ថាបើយើងមិនអាចជួយបាន, ព្រោះថា៖

៨១- ទ្រព្យសម្បត្តិ មាននៅក្នុងសេចក្តីជ្រះថ្លានៃអ្នកណា, ជ័យជម្នះមាននៅក្នុងសេចក្តីព្យាយាមប្រឹងប្រែងនៃអ្នកណា ម្រឹត្យុស្ថិតនៅក្នុងសេចក្តីក្រោធនៃអ្នកណា, សេចក្តីពិត អ្នកនោះៗឈ្មោះថា ប្រកបហើយដោយតេជានុភាពទាំងពួង ។

៨២- ព្រះភូមិបាល សូម្បីតាំងនៅក្នុងយោព្វនវ័យ (ឬពាលល្ងង់ខ្លៅ?) បុគ្គលមិនគប្បីមើលងាយព្រះចេស្តាទុកដូចមនុស្សធម្មតាទេ ព្រោះថា៖ ព្រះរាជាជាទេពតាមានសក្តិធំ មកប្រាកដព្រះអង្គជាកាយមនុស្ស” ។

ឯចចក**ទមនកៈ** បានស្តាប់សម្តីចចក**ករដកៈ**និយាយហើយ អស់សំណើចសើចយឹកៗ ទើបនិយាយថា៖ “នែមិត្ត! ចូរឯងនៅឲ្យស្ងៀមទៅ កុំមាត់កថ្វី ហេតុដែលនាំឲ្យម្ចាស់យើងភ័យនោះ អញដឹងអស់ហើយ មិនគឺសំឡេងអ្វីដទៃផ្សេងទេ គឺជាសម្រែកគោឧសភរោទិ៍នោះឯង, ឯគោឧសភត្រូវជាចំណីអាហារយើងផង ចាំបាច់និយាយដល់ទៅសីហៈធ្វើអ្វី” ។ ចចក**ករដកៈ** និយាយទទួលថា “អ៎ា! អ្វីដូច្នោះទេហ៎ៈ? បើដូច្នោះ ហេតុអ្វីក៏ឯងមិនកម្ចាត់បង់សេចក្តីតក់ស្លុតម្ចាស់យើងឲ្យទាន់ភ្លាមទៅ?” ។ ចចក**ទមនកៈ** ឆ្លើយដោយអាការបន្ទោសប្រាប់ថា៖ “បើយើងដោះស្រាយសេចក្តីតក់ស្លុតម្ចាស់យើងភ្លាមទៅដូចម្តេចឡើយយើងនឹងត្រូវបានសេចក្តីគាប់ចិត្ត និងលាភសក្ការៈច្រើនថែមទៀត, ព្រោះថា៖

៨៣- ក្នុងកាលណាក៏ដោយ បុគ្គលមិនគប្បីធ្វើឲ្យម្ចាស់លែងពឹងពាក់សេវកាមាត្យទេ, បើសេវកាមាត្យធ្វើឲ្យម្ចាស់លែងពឹងពាក់ហើយ នឹងដល់សេចក្តីវិនាស ដូចឆ្មាឈ្មោះ**ទធិករណៈ**” ។

ចចក**ករដកៈ** សួរឡើងថា “តើរឿងនោះដូចម្តេច?” ។ ចចក**ទមនកៈ** និយាយរឿងរ៉ាវនោះប្រាប់ថា៖

# កថាទី៤

## រឿងសីហៈ និងឆ្មា

នៅក្នុងព្រៃឧត្តរាបថ មានសីហៈមួយឈ្មោះ**ទុទ៌ាន្តៈ** ជាសត្វមានសេចក្តីព្យាយាមធំ អាស្រ័យនៅក្នុងភ្នំមួយឈ្មោះអព៌ុទសិខរៈ ។ មានកណ្តុរមួយ វារចូលទៅកាត់ចុងកេសរនៃសីហៈនោះរៀងរាល់ៗថ្ងៃ ក្នុងពេលដែលសីហៈកំពុងដេកលក់ក្នុងញកភ្នំ ។ កាលភ្ញាក់ពីដេកឡើង សីហៈឃើញចុងកេសរខ្លួនរេចរឹលក្បិលដូច្នោះ ក្តៅក្រហាយនឹកគ្នាន់ក្នាញ់នឹងកណ្តុរនោះណាស់ ខំព្យាយាមលោតសង្គ្រុបចាប់រឿយៗតែកណ្តុរលោតរត់ចូលក្នុងព្រង់បាត់ចាប់មិនបានសោះ, សីហៈគិតថា៖

៨៤- បើសត្រូវតូច បុគ្គលមិនគប្បីចាប់បានដោយព្យាយាមក្លៀវក្លាទេ, ដើម្បីផ្ចាញ់សត្រូវនោះ បុគ្គលគប្បីរកសេនាទ្បនុភាព ដែលមានកម្លាំងប៉ុនគ្នាមកកម្រាប ទើបសម្រេចបាន ។

លុះគិតរកឧបាយឃើញដូច្នេះហើយ សីហៈក៏ចូលទៅក្នុងស្រុក ធ្វើសេចក្តីស្និទ្ធស្នាលជាមួយនឹងឆ្មាមួយឈ្មោះ **ទធិកណ៌ៈ** ល្បួងលួមលោមឆ្មានោះយកមកដោយថ្នាក់ថ្នម រកចំណីសុទ្ធតែសាច់មកឲ្យជាអាហារចិញ្ចឹមទុកនៅក្នុងញកភ្នំជាមួយនឹងខ្លួន ។ លំដាប់នោះ, រីកណ្តុរកាលឃើញឆ្មាមកនៅជាមួយសីហៈដូច្នោះហើយ មិនប៊ានចេញពីព្រង់ខ្លួនសោះ ។ តាំងពីកាលនោះមក, សីហៈមានកេសរល្អតលាស់ល្អដូចប្រក្រតីដើមឡើងវិញ ហើយដេកលក់ស្កប់ស្កល់ជាសុខសប្បាយរៀងមក ។ កាលណាបើសីហៈឮសំឡេងកណ្តុរច្រើនរឿយៗ កាលនោះទើបសីហៈខ្នះខ្នែងរកចំណីអាហារសុទ្ធតែសាច់ល្អយកមកបំប៉នឆ្មានោះយ៉ាងច្រើន ។ ដល់មកថ្ងៃមួយ, កណ្តុរមានក្តីស្រេកឃ្លានខ្លាំងពេកទ្រាំមិនបាន ចេញមកខាងក្រៅត្រូវឆ្មានោះខាំសម្លាប់ចោលបង់សៀតទៅ ។ តមក, ដរាបណា សីហៈមិនបានប្រទះឃើញកណ្តុរអស់កាលយូរ មិនដែលឮសំឡេងកណ្តុរនោះសោះ ដរាបនោះ សីហៈមិនសូវត្រូវការប្រើឆ្មា មិនរវល់អើពើនឹកនានឹងឲ្យចំណីអាហារឆ្មាឡើយ ។ ឯឆ្មា**ទធិកណ៌ៈ** កាលមិនមានអាហារគ្រប់គ្រាន់ក៏ស្គាំងស្គមថមថយកម្លាំងបន្តិចម្តងៗ ដរាបដល់បញ្ចត្វម ([១]) ទៅហោង ។ ហេតុនោះហើយបានជាខ្ញុំ (ចចក**ទមនកៈ**)

---

[១] សេចក្តីស្លាប់ ។

និយាយថា៖ “ក្នុងកាលណាក៏ដោយ” ដូច្នេះជាដើម (លេខ ៨៣) ។

លំដាប់នោះ, ចចក**ទមនកៈ** និង**ករដកៈ** ទាំងពីរដើរចូលទៅរកគោ**សញ្ជីវកៈ** ។ លុះទៅជិតហើយ ចចក**ករដកៈ** អង្គុយព្រងើយនៅទៀបគល់ឈើមួយ, ចចក**ទមនកៈ** ចូលទៅកាន់គោ**សញ្ជីវកៈ** ហើយស្រែកកំហែងខ្លាំងៗថា៖ “នែអាគោឧសភចង្រៃ! ឯងមកពីណា មិនដឹងទេឬអ្វី ព្រៃនេះស្ដេចម្ចាស់អញឈ្មោះ**បិង្គលកៈ** ឲ្យអញថែរក្សា? ឥឡូវនេះលោកសេនាបតី**ករដកៈ** បង្គាប់អញឲ្យមកប្រាប់ថាឲ្យឯងចូលទៅរកលោកឆាប់ៗ បើឯងមិនព្រមចូលទៅទេ ចូរចៀសចេញពីព្រៃនេះឲ្យឆ្ងាយទៅ បើឯងរឹងទទឹងមិនព្រមស្ដាប់ នឹងត្រូវទោសកំហុសដល់ក្ដីស្លាប់មិនខាន, ឯងមិនដែលឮទេឬអ្វី? ម្ចាស់យើងបើក្រោធហើយ នឹងប្រើវិធីក្ដៅក្រហាយណាស់” ។ គោ**សញ្ជីវកៈ** ស្ដាប់ពាក្យចចក**ទមនកៈ**ហើយ ក៏ចូលទៅរកសេនាបតី**ករដកៈ** នោះ ជាមួយចចក**ទមនកៈ** ។

៨៥- កិរិយាមិនធ្វើតាមអាជ្ញាព្រះនរេន្ទ្រ កិរិយាមិនអើពើចំពោះព្រាហ្មណ៍ និងកិរិយាដេកផ្សេងពីភរិយា ទាំងអស់នេះឈ្មោះថាស្លាប់មិនបាច់ប្រហារដោយសស្ត្រាវុធឡើយ ។

គោ**សញ្ជីវកៈ** មិនស្គាល់ទំនៀមប្រទេស ដើរញញ្ញាក់ញញ័រចូលទៅជិតដោយភ័យខ្លាច ក្រាបប្រណម្យសេនាបតី**ករដកៈ**ដោយអស្ដាង្គបាត, ព្រោះថា៖

៨៦- ប្រាជ្ញាប្រសើរខ្ពស់ជាងកម្លាំង, ការអប្បឥតប្រាជ្ញានាំឲ្យធ្លាក់ខ្លួនថោកទាបដូចដំរី, តែការពោលដូច្នេះ ដូចហ្នឹងដំរីវាយស្គរឃោសនាឲ្យលាន់ឮជិតត្រចៀកដំរីទេ ។

គ្រានោះ, គោ**សញ្ជីវកៈ** ជម្រាបសួរចចក**ករដកៈ** ដោយក្ដីខ្លបខ្លាចថា “បពិត្រលោកសេនាបតី! មេត្តាប្រោសប្រាប់ខ្ញុំបាទ តើខ្ញុំបាទមានទោសខុសអ្វី? ត្រូវធ្វើដូចម្ដេច?” ។ ចចក**ករដកៈ** ប្រាប់ថា៖ “នែគោឧសភ! បើឯងចង់អាស្រ័យនៅក្នុងព្រៃនេះតទៅទៀត ឯងត្រូវចូលទៅក្រាបប្រណម្យទេវបាទម្ចាស់យើងសុំនៅទីនេះទើបបាន” ។ គោ**សញ្ជីវកៈ** អង្វរករថា៖ “បើលោករ៉ាប់រងធានាការពារខ្ញុំមិនឲ្យមានភ័យទើបខ្ញុំបាទទៅ” ។ ចចក**ករដកៈ** ឆ្លើយប្រាប់ថា៖ “យីអាចង្រៃពលិព័ទ្ទ! ម្ដេចឯងមិនជឿអញ មិនអីទេកុំភិតភ័យខ្លាចអ្វី, ព្រោះថា៖

៨៧- ព្រះកេសវៈ មិនបានពោលពាក្យតប កាលព្រះរាជានៃប្រទេស[១] ចេទិ ទ្រង់ដាក់បណ្ដាសា, សីហកេសរី រមែងបញ្ចេញសីហនាទ តនឹងអសនីបាត តែមិនដែលឆ្លើយតបសំឡេងចចកឡើយ ។

៨៨- ព្រះពាយ មិនរំលើងឫសគល់ស្មៅទាំងឡាយ ដែលទាបៗ ហើយទន់ទោរឱនក្រាបស្រពាប

---

[១] ព្រះរាជាអង្គនេះព្រះនាមសិសុបាល ជាស្ដេចក្រុងចេទិ មានអគ្គមហេសីមួយអង្គនាមនាងរុក្មិនី ។ ក្រឹស្ណៈលបលួចយកនាងរុក្មិនីជាអគ្គមេហេសីព្រះអង្គ ក៏កើតជាចម្បាំងរវាងក្រឹស្ណៈ និងព្រះបាទសិសុបាលឡើង កាលនោះព្រះបាទសិសុបាលដាក់សម្បថព្រះកេសវៈ គឺព្រះឥស្វរ ។

ទៅតាមទិសសព្វកាល, តែរមែងរំលើងឫសគល់ដើមឈើធំខ្ពស់ៗ, រីអ្នកធំហៅហាន រមែងបំបាក់បំបបចំពោះអ្នកធំហៅហានដូចគ្នា” ។

កាលនោះ, ចចកទាំងពីរបណ្ដើរគោ**សញ្ជីវកៈ**ទៅ បង្គាប់គោឲ្យឈរនៅខាងក្រៅក្នុងទីមួយមិនឆ្ងាយប៉ុន្មាន ទើបចូលទៅកាន់សំណាក់**បិង្គលកៈ** ក្រាបថ្វាយបង្គំហើយអង្គុយក្នុងទីគួរមួយ ។ **បិង្គលកៈ** ក្រឡេកមើលឃើញចចកទាំងពីរនោះមកដល់ ត្រេកអររីករាយណាស់ ទទួលរាក់ទាក់ដោយអាការគួរសមក្រៃលែង ហើយសួរទៅភ្លាមថា៖ “ម៉េចទៅ! ឯងឃើញអាសត្វនោះឬទេ?” ។ ចចក**ទមនកៈ** ជម្រាបថា៖ “បពិត្រព្រះទេវបាទ! អាសត្វចម្រែងនោះ យើងខ្ញុំឃើញហើយ, សត្វនោះស្លូតបូតទេ តែធាត់ធំមាំមួនមានកម្លាំងខ្លាំងណាស់ ដូចលោកម្ចាស់ឈ្វេងយល់ប្រាកដ, ឥឡូវនេះវាចង់ចូលមកក្រាបបង្គំគាល់ផ្ទាល់ខ្លួន សូមលោកម្ចាស់រៀបចំរង់ចាំទទួល ។ សព្វបើឮសំឡេងខ្លាំងប៉ុណ្ណោះលោកម្ចាស់ពុំគួរគប្បីភ័យខ្លាចទេ, ព្រោះថា៖

៨៩- ([១]) សព្វបើឮសំឡេងខ្លាំង, បើមិនទាន់ដឹងហេតុការណ៍នៃសំឡេងនោះទេ បុគ្គលមិនគួរគប្បីភ័យខ្លាចឡើយ ស្ត្រីមេអណ្ដើកម្នាក់ គ្រាន់តែដឹងច្បាស់នូវហេតុនៃសំឡេងប៉ុណ្ណោះបានទៅជាស្ត្រីដែលគេគួរគោរព” ។

**បិង្គលកៈ** សួរថា៖ “រឿងនោះតើដូចម្ដេច?” ។ ចចក**ទមនកៈ** រៀបរាប់រឿងនោះថា៖

# កថាទី៥

## រឿងស្ត្រីពេស្យា និងគង

នៅកណ្ដាលភ្នំស្រីបព៌ត មាននគរមួយឈ្មោះព្រហ្មបុរៈ ។ អ្នកផងទាំងពួងតែងឮជនប្រវាទ ([២]) ថា នៅលើកំពូលភ្នំនោះ មានអារក្សមួយឈ្មោះ**ឃណ្ដាកណ៌ៈ**អាស្រ័យនៅ ។ ថ្ងៃមួយ, មានចោរម្នាក់ចូលមកលបលួចយកគងអ្នកស្រុកបានមួយ ហើយរត់គេចវេះវៀសខ្លួនចូលទៅពួនក្នុងព្រៃភ្នំ ប្រទះនឹងខ្លាមួយត្រូវខ្លានោះសង្គ្រប់ចាប់ហែកជញ្ជែងស៊ីដល់ក្ស័យមរណៈទៅ ។ ឯគងនោះបានទៅក្នុងកណ្ដាប់ដៃស្វាទាំងឡាយ ។ ពួកពានរបានគងហើយ វាយពាតលោតលេងលាន់ឮមោងម៉ាងៗ បរព្រៃរំពងទូទៅរឿយៗ ។ ឯចោរលួចគងនោះអ្នកស្រុកបានដឹងឮប្រាកដថា ខ្លាខាំហែកស៊ីស្លាប់ទៅហើយ ក៏នឹកឆ្ងល់គ្រប់គ្នាថា

---

[១] ហិតោបទេស សេចក្ដីប្រែជាភាសាបារាំង នៃលោកឡង់ស៊ីរ៉ូ និងជាភាសាសៀមនៃលោកនាគប្រទីប មានគាថាលើសដូច្នេះគឺ៖ ទឹកហូរទម្លាយស្ពានបាន, ការមិនចេះរក្សាការសម្ងាត់ ទម្លាយការកំបាំងបាន, ពាក្យញុះញង់ទម្លាយមិត្តភាពបាន, សម្រែកខ្លាំង ទម្លាយជនកម្លាចបាន ។

[២] ពាក្យពោលផ្ដេសផ្ដាស, ពាក្យចចាមអារ៉ាម ។

ហេតុដូចម្ដេចក៏នៅតែឮស្គរសំឡេងគងមោងម៉ាង១រឿយ១ដូច្នេះទៀត ។ ដោយការមិនដឹងហេតុនៃសំឡេងគងនោះ ប្រជាជនភិតភ័យខ្លាច នឹកស្មានតែផ្ដាសថា “ប្រហែលជាអារក្សកំណាចចង្រៃចាប់មនុស្សស៊ីជាអាហារ ហើយវាយពាតគងលេង” ។ ក៏បបួលគ្នីគ្នារត់ចេញពីក្រុងអស់រលីង ។ កាលនោះមានស្ដ្រីពេស្យាម្នាក់ឈ្មោះនាង **ករាលា** ខំត្រិះរិះពិចារណារាវរកហេតុនៃសំឡេងគងដ៏ចម្លែកនោះ រហូតទាល់តែដឹងហេតុប្រាកដថា ពួកពានរបានគងនោះពីចោរដែលខ្លាខាំស៊ី យកទៅវាយពាតលោតលេងជាល្បែង ។ នាង**ករាលា** ក៏ចូលទៅក្រាបបង្គំគាល់ព្រះនរបតី យកសេចក្ដីថ្វាយព្រះយោបល់ថា៖ “ទេវ! បើទ្រង់ព្រះករុណាប្រទានរង្វាន់ខាន់ខៅច្រើនដល់នាងខ្ញុំម្ចាស់ នាងខ្ញុំម្ចាស់ធានានឹងទៅសម្លាប់អារក្ស**ឃណ្ណាកណ៌:**ឲ្យបាន” ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនាងពិតទូលហើយ មានព្រះទ័យរីករាយសប្បាយណាស់ ប្រទានទ្រព្យសម្បត្តិតាមនាងត្រូវការ ។ នាងពេស្យាចាត់ចែងមណ្ឌលពិធីបួងសួងគោរពចំពោះព្រះគណេស និងទេព្ដាទាំងឡាយ ហើយទើបយកផ្លែឈើទាំងឡាយដែលស្វាតែងចូលចិត្តចូលទៅក្នុងព្រៃ ចោលផ្លែឈើនោះរាត់រាយរង្គូករណែលលើផែនដី ។ កាលនោះ វីបងពានរទាំងឡាយ, កាលក្រឡេកឃើញផ្លែឈើ ក៏ចោលគងពីដៃ ស្ទុះទៅរើសយក ។ នាងពេស្យា រើសយកគងបានហើយត្រឡប់ចូលមកក្រុងវិញ បានជាទីគោរពសក្ការបូជានៃប្រជាទាំងមូលតាំងពីកាលនោះមក ។ ហេតុនោះទើបបានជាខ្ញុំបាទ (ចចក**ទមនកៈ**) ជម្រាបថា៖ “សព្វបើឮសំឡេងខ្លាំង” ដូច្នេះជាដើម (លេខ ៨៩) ។

លំដាប់នោះ, ចចកទាំងពីរ នាំគោ**សញ្ជីវកៈ** មកប្រគល់**បិង្គលកៈ** ។ ក្នុងកាលតមក, មិនយូរប៉ុន្មានគោ**សញ្ជីវកៈ** និង**បិង្គលកៈ**រាប់អានគ្នាទៅវិញទៅមកជាមិត្តស្និទ្ធស្នេហាយ៉ាងជិតរហូតអស់កាលយូរ ។ ថ្ងៃមួយ, មានសីហៈមួយទៀតឈ្មោះ **ស្តព្ធកណ៌ៈ** ត្រូវជាបងបង្កើតនៃ**បិង្គលកៈ** មកជួបលេងសប្បាយ ។ **បិង្គលកៈ**មានភារត្រូវទទួលភ្ញៀវ រៀបដំណើរចរចេញទៅព្រៃ ដើម្បីស្វះស្វែងរកចាប់ម្រឹគមកធ្វើជាចំណីអាហារលៀងភ្ញៀវ ។ ក្នុងលំដាប់នោះឯង, គោ**សញ្ជីវកៈ** សួរទៅថា៖ “ទេវៈ! ថ្ងៃនេះយើងមានសាច់ម្រឹគស្លាប់មកពីណា?” ។ **បិង្គលកៈ** ឆ្លើយថា៖ “ចចក**ករដកៈ** និង**ទមនកៈ** ដឹងរឿងហើយ” ។ គោ**សញ្ជីវកៈ** និយាយថា៖ “ត្រូវតែមើលឲ្យដឹងថា សាច់នោះនៅមានសល់ ឬមួយក៏អស់រលីងហើយ” ។ **បិង្គលកៈ** ពិនិត្យរួចហើយ ឆ្លើយប្រាប់មកវិញថា៖ “សាច់នោះ គេស៊ីអស់រលីងហើយ” ។ គោ**សញ្ជីវកៈ** ពោលឡើងទៀតថា៖ “ក្រាបទូល, ចចកទាំងពីរនេះ ម្ដេចក៏ប៉ានស៊ីសាច់ទាំងដុលអស់រលីងហ្ន៎!” ។ **បិង្គលកៈ**និយាយបន្ទោសថា៖ “អើ! គេស៊ីខ្លួនគេខ្លះផង ចែកឲ្យទៅអ្នកដទៃខ្លះផង ខ្លះខ្ចាយចោលខ្លះផងទៅណ៎ា! គេធ្វើតែយ៉ាងហ្នឹងឯងរាល់តែថ្ងៃ” ។ គោ**សញ្ជីវកៈ**ពោលថា៖ “ដូចម្ដេចក៏ប៉ានធ្វើតាមទំនើងចិត្តខ្លួនឯង ដោយមិនបានទទួលសេចក្ដីអនុញ្ញាតិពីលោកទេវបាទសោះ?” ។ **បិង្គលកៈ** និយាយតទៅទៀត

ថា៖ “គេធ្វើយ៉ាងនេះឯង ឥតកោតក្រែងរអែងចិត្តយើងទេ” ។ កាលនោះគោ**សញ្ជីវកៈ** និយាយថា៖ “ធ្វើដូច្នេះ មិនគួរសមសោះ, ព្រោះថា៖

៩០- សេវកាមាត្យ បើមិនទាន់ប្រាប់ម្ចាស់ឲ្យដឹងមុន មិនត្រូវធ្វើអ្វីតាមទំនើងខ្លួនឡើយ លើកលែងតែកិច្ចការដែលត្រូវការពារម្ចាស់ ។

៩១- អាមាត្យគួរមានលក្ខណៈប្រៀបដូចក្អមតាបសឫសី វេលាចាក់ចេញតិច វេលាដងបានច្រើន បពិត្រព្រះនរបតី! អ្នកពោលថា ធ្វើអ្វីកើតមួយខណៈ ជាមនុស្សល្ងង់ខ្លៅ, ធ្វើអ្វីកើតមានប្រាក់បន្តិច ជាមនុស្សក្រីក្រ ។

៩២- នរជនណា កពូនទ្រព្យសម្បត្តិ សូម្បីមួយកាកណិកសម្រាប់ព្រះរាជាគ្រប់ៗកាល នរជននោះទើបជាអាមាត្យពិតមែន ព្រោះឃ្លាំង ជាជីវិតនៃស្តេច ជីវិតគឺការរស់នៅមិនមែនជាជីវិតនៃស្តេចទេ ។

៩៣- បុរសខ្សត់ទ្រព្យ បើទុកជាប្រព្រឹត្តតាមគន្លងធម៌នៃត្រកូល ក៏មិនជាទីសេពគប់នៃជនដទៃទេ សូម្បីប្រពន្ធខ្លួន ក៏លះបង់ខ្លួនចោលដែរ ចាំបាច់និយាយថ្វីដល់ជនដទៃ ។

អំពើតទៅនេះ ជាប្រធានសេចក្តីអន្តរាយនៃរាជសម្បត្តិ៖

៩៤- ការចាយវាយហួសប្រមាណ, ការពិនិត្យត្រួតត្រាមិនដិតដល់, ការបានទ្រព្យខុសគន្លងធម៌ និងការចាយខ្ជះខ្ជាយនៃអ្នកនៅឋានឆ្ងាយ ទាំងអស់នេះលោកពោលថា “ការវិនាសនៃឃ្លាំង” ។

៩៥- បុគ្គលមិនពិចារណាមើលទ្រព្យដែលត្រូវរកបាន ចាយវាយរផាត់រទាំងតាមអំពើចិត្តខ្លួន សូម្បីអ្នកមានទ្រព្យដូចព្រះសៃស្រវ័ណ (១) ក៏មិនយូរប៉ុន្មាន គង់នឹងដល់នូវការអន្តរធានរលីងមិនខាន ។

សីហៈ**ស្តព្ធកណ៌ៈ** ពោលឡើងថា៖ “នែប្អូន**បិង្គលកៈ**អើយ! ស្តាប់ខ្ញុំនិយាយសិន, ចចក**ទមនកៈ** និង**ករដកៈ** ទាំងពីរនេះអាស្រ័យនៅជាមួយប្អូនមកអស់កាលយូរហើយ ជាសេនាបតីកាន់កាប់កិច្ចការរក្សាសន្តិភាព និងធ្វើសង្គ្រាមច្បាំងតតាំងសត្រូវ ប្អូនមិនត្រូវយកទៅប្រើប្រាស់ឲ្យកាន់អធិការ (ការឃ្លាំង) ទេ ។ មួយទៀត, ខ្ញុំសូមរៀបរាប់ពីការចាត់ចែងអាមាត្យឲ្យធ្វើការ តាមដែលខ្ញុំបានដឹងឮមកដូចសេចក្តីតទៅនេះ៖

៩៦- ព្រាហ្មណ៍, អ្នកចម្បាំង និងផៅពង្ស មិនគួរលើកឲ្យធ្វើក្នុងការឃ្លាំងទេ ព្រោះព្រាហ្មណ៍ សូម្បីមានសិទ្ធិត្រូវឲ្យ ក៏មិនព្រមបើកទ្រព្យឲ្យ បើទុកជាឲ្យ ក៏ឲ្យដោយពិបាកណាស់ ។

---

(១) នាមព្រះកុវេរៈ ជាទេពតាម្ចាស់ទ្រព្យសម្បត្តិ ។

៩៧- អ្នកចម្បាំងកាន់ការឃ្លាំងទ្រព្យ ទៀងណាស់តែនឹងកាន់ក្របីសម្តែងឫទ្ធិ បើឲ្យផៅពង្សកាន់វិញ គេគិតតែពីកាញ់យកទ្រព្យសម្បត្តិអស់ ដោយអាងថាខ្លួនគេជាញាតិ ។

៩៨- ខ្ញុំបម្រើចាស់ សូម្បីធ្វើការភ្លាត់ខុស ក៏មិនក្រែងរអែងចិត្តម្ចាស់, គេតែងមើលងាយម្ចាស់ធ្វើការអ្វីៗតាមអំពើចិត្ត ។

៩៩- បុគ្គល កាលស្ថិតនៅក្នុងតំណែងតាំងចិត្តធ្វើការជាឧបការៈមិនសម្គាល់ថាខ្លួនធ្វើការខុសទេ តែងយកឧបការៈជាទង់ជ័យបាំងមុខ ហើយនឹងធ្វើការបំផ្លាញប្រទេសទាំងមូល ។

១០០- អាមាត្យជាអ្នកធ្លាប់លេងល្បែងជាមួយស្តេច ទៀងណាស់តែតាំងខ្លួនធ្វើឫកជាស្តេច មើលងាយស្តេចគ្រប់កាលទាំងពួង ព្រោះការធ្លាប់ស្និទ្ធ ។

១០១- អាមាត្យប្រទូសដោយផ្លូវកំបាំង ចេះធ្វើអត់ធន់ណាស់ ហើយមិនធ្វើការងារអ្វីសព្វជំពូកជាប្រយោជន៍សោះ, ក្នុងរឿងនេះ ព្រះភូបតីអាចយកអាមាត្យឈ្មោះ ([១]) សកុនី និងអាមាត្យឈ្មោះសកដា ([២]) ជាអ្នកប្រទូសមកជាឧទាហរណ៍បាន ។

១០២- ([៣]) គ្រប់កាលទាំងពួង អាមាត្យទាំងអស់ដែលនឹងត្រូវតែងតាំង មិនគួរឲ្យបរិបូណ៌ដោយទ្រព្យទេ, អ្នកប្រាជ្ញទាំងឡាយប្រាប់ឧបទេសថា "ឫទ្ធិគឺការមានទ្រព្យច្រើន អាចផ្លាស់ប្តូរចិត្តមនុស្សឲ្យទៅផ្សេងៗបាន" ។

១០៣- លួចយកទ្រព្យសម្បត្តិដែលបានមក, ([៤])ប្រវ័ញ្ចបំបាត់ទ្រព្យ, បណ្តោយតាមចិត្តម្ចាស់, ព្រងើយកន្តើយ, ភាពជាបុគ្គលឥតវិចារ, ភ្លើតភ្លើនសប្បាយ ទាំងអស់នេះជាគ្រឿងប្រទូសនៃអាមាត្រ ។

១០៤- ប្រើមធ្យោបាយដកយសសក្តិ, ត្រួតត្រាមើលជានិច្ច, ប្រទានឲ្យឡើងនាទី, ផ្លាស់ចេញពីនាទី នេះជាប្រសាសន៍វិធីនៃស្តេចដែលត្រូវធ្វើចំពោះអាមាត្យ ។

១០៥- ដោយច្រើន, អាមាត្យកាន់អំណាច បើគេសង្កត់រឹតត្បិតទើបធ្វើឲ្យចម្រើនព្រះរាជទ្រព្យនៃម្ចាស់ផែនដី ប្រៀបដូចបូសកាច បើគេច្របាច់ទើបខ្ទុះខ្ទុះចេញ ។

---

[១] មន្ត្រីទុរយោធត្រូវជាបិតុលាពួកកោរវៈ ។

[២] មន្ត្រីព្រះបាទនន្ទៈ ជាស្តេចដែនមគធៈ មើលរឿងនពាសរតិសាគរ ។

[៣] ហិតោបទេសសេចក្តីប្រែជាភាសាបារាំង របស់លោកឡង់ស៊ីរ៉ូ ប្រែថា៖ ទោះជាយ៉ាងណាក៏ដោយ មិនត្រូវបំប៉នឲ្យអាមាត្យមានទ្រព្យសម្បត្តិច្រើនទេ ឧបទេសនៃអ្នកប្រាជ្ញថា "ទ្រព្យ ច្រើននាំឲ្យផ្លាស់ទឹកចិត្តមនុស្ស" ។

[៤] ហិតោបទេសប្រែជាភាសាសៀមនៃលោកនាគប្រទីប ត្រង់ពាក្យថា គ្រហណៈ ថាមិនកាន់ទុកឲ្យបានទូវប្រយោជន៍ដែលដល់ហើយសេចក្តីប្រែនេះ គួរឲ្យមានសេចក្តីឆ្ងល់ ។

១០៦- អាមាត្យកាន់ឃ្លាំងប្រាក់ ព្រះរាជាគួរសង្កត់សង្កិនឲ្យរឿយៗ, សំពត់សម្រាប់ងូតទឹក បើគេពូតអស់វារៈតែម្តង នឹងសម្រក់ទឹកចេញភ្លាម មិនមែនឬ? ។

បុគ្គលកាលបានដឹងច្បាស់នូវហេតុការណ៍ដូច្នេះសព្វគ្រប់ហើយ គប្បីចាត់ចែងការងារឲ្យមានរបៀបរៀបរយតទៅ ទាន់មានឱកាសល្អ" ។ **បិង្គលកៈ** និយាយសម្របថា៖ "មានហេតុការណ៍ពិតដូច្នោះមែនហើយ, តែធ្វើម្តេចហ៎ះ! អាមាត្យ**ទមនកៈ** និង**ករដកៈ** ទាំងពីរនេះមិនធ្វើតាមពាក្យបង្គាប់យើងសោះ" ។ **ស្តព្ធកណ៌ៈ**និយាយទៀតថា៖ "បើដូច្នោះ ប្អូនមិនត្រូវបណ្តោយឲ្យខូចខាតការនេះតទៅទៀតទេ, ព្រោះថា៖

១០៧- ព្រះរាជា មិនត្រូវអត់ទោសសោះ សូម្បីព្រះរាជបុត្រដែលធ្វើឲ្យខូចព្រះរាជអាជ្ញា, បើមិនដូច្នោះទេ មានសេចក្តីប្លែកគ្នាដូចម្តេចខ្លះហ្ន៎ រវាងព្រះរាជា និងព្រះរាជារូបគំនូរ? ។

១០៨- មនុស្សរឹងរូសវិនាសយស, មនុស្សមានចិត្តមិនស្មើគ្នា បាត់មិត្តភាព, មនុស្សវិកលឥន្ទ្រិយមិនមានត្រកូល, មនុស្សល្មោភ មិនមានធម៌, មនុស្សធ្វើសេចក្តីអន្តរាយ ខាតផលវិជ្ជា, មនុស្សកំណាញ់វិនាសសេចក្តីសុខ, ឯព្រះនរាធិបតី មានតែអាមាត្យឡេបឡប្រស្រវឹងលាភយស វិនាសរាជ្យ ។

១០៩- មែនពិត, ព្រះរាជាដូចបិតា ត្រូវរក្សាការពារប្រជាករឲ្យផុតភយន្តរាយដែលកើតអំពីចោរ, ពីអាមាត្យមុខមន្ត្រី, ពីសត្រូវក្រៅប្រទេស, ពីបរិវារជំនិតព្រះអង្គ និងសេចក្តីលោភរបស់ព្រះអង្គឯង ។

នែប្អូនអើយ! ចូរប្អូនធ្វើតាមពាក្យដាស់តឿនបង, គួរយើងរៀបចាត់ចែងរបៀបឲ្យរៀបរយតាំងពីពេលនេះតទៅ ។ គោ**សញ្ជីវកៈ** នេះស៊ីស្មៅសន្ទូងជាចំណីអាហារ គួរប្រគល់ការឲ្យធ្វើជាមេឃ្លាំងព្រះរាជទ្រព្យ និងចាត់ចែងខាងស្បៀង" ។

កាល**បិង្គលកៈ**បានចាត់ចែងតាមពាក្យដាស់តឿន**ស្តព្ធកណ៌ៈ**ដូច្នេះហើយ សត្វទាំងពីរគឺ**បិង្គលកៈ** និងគោ**សញ្ជីវកៈ** លះបង់ផៅពង្សញាតិសន្តាន ព្រមទាំងសេវកាមាត្យចោល មិនសូវនឹកនាដូចកាលដើមទេ ហើយញ៉ាំងកាលឲ្យប្រព្រឹត្តកន្លងទៅដោយសេចក្តីស្នេហាដ៏ក្រៃលែងចំពោះគ្នាតែពីរនាក់ ។ លំដាប់តមក, ចចក**ទមនកៈ** និង**ករដកៈ** ព្រមមួយអន្លើដោយពួកសេវកាមាត្យ ឃើញម្ចាស់មិនរវល់នឹកនាឲ្យចំណីអាហារគ្រប់គ្រាន់នឹងបរិភោគដូច្នេះ ចេះតែខ្សឹបខ្សៀវគ្នីគ្នាទៅវិញទៅមក ។ កាលនោះ, ចចក**ទមនកៈ**និយាយនឹងចចក**ករដកៈ**ថា៖ "នែសម្លាញ់! យើងគិតធ្វើដូចម្តេចហ៎ៈ នេះជាកំហុសយើងធ្វើឲ្យខុសខ្លួនឯង ហើយមកយំសោកក្តៅក្រហាយស្តាយក្រោយ ធ្វើដូច្នេះមិនល្អមើល, ព្រោះថា៖

១១០- មនុស្ស ៣នាក់ ត្រូវទទួលទុក្ខលំបាក ព្រោះទោសកំហុសខ្លួនឯង គឺរូបខ្ញុំ ព្រោះទៅពាល់រូបគំនូរនាងសុវណ៌រេខា, នាងមេអណ្តើក ព្រោះព្រមឲ្យគេចងខ្លួនឯងជំនួស និងពាណិជ ព្រោះការលួច

យកកែវមណី" ។

ចចក**ករដកៈ**សួរថា៖ "ចុះរឿងនោះដូចម្ដេច?" ។ ចចក**ទមនកៈ**និយាយរឿងនោះប្រាប់តទៅថា៖

# កថាទី៦

## រឿងបរិព្វាជកកន្ទប៉កេត

(ប្រកបរឿងគោបាលប្ដីប្រពន្ធ អ្នកកាត់សក់ប្ដីប្រពន្ធ ព្រមទាំងរឿងពាណិជខាតទ្រព្យ)

មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាម**វីរវិក្រមៈ** សោយរាជ្យសម្បត្តិនៅក្នុងក្រុងឈ្មោះកាញ្ចនបុរៈ ។ ថ្ងៃមួយ ចៅក្រមកាត់ទោសអ្នកកាត់សក់ម្នាក់ដល់ប្រហារជីវិត បង្គាប់ឲ្យនាយពេជ្ឈឃាតនាំយកទៅសម្លាប់ ។ កាលពេជ្ឈឃាតបណ្ដើរអ្នកកាត់សក់ទៅកាន់ទីមនុស្សឃាត បានជួបបរិព្វាជកម្នាក់ឈ្មោះ**កន្ទប៉កេតុ** និងពាណិជម្នាក់ទៀត ។ **កន្ទប៉កេតុ** ឃាត់ពេជ្ឈឃាតថា៖ "នែពេជ្ឈឃាត! អ្នកកាត់សក់នេះមិនត្រូវគេសម្លាប់ទេ" ថាហើយចាប់ជាយសំពត់អ្នកកាត់សក់ជាប់ ទាញមិនព្រមឲ្យយកទៅសម្លាប់ ។ រាជបុរសជាពេជ្ឈឃាតសួរថា៖ "ហេតុអ្វី ក៏មិនត្រូវសម្លាប់មនុស្សទោសនេះ?" ។ **កន្ទប៉កេតុ** ឆ្លើយប្រាប់ថា៖ "សូមអ្នកទាំងអស់ចាំស្ដាប់, រូបខ្ញុំនេះ បានពាល់រូបនាងស្វណ៌រេខា បានជាធ្លាក់ខ្លួនមកកាន់សភាពដូច្នេះ" ។ រាជបុរសទាំងឡាយបានស្ដាប់ហើយ ងឿងឆ្ងល់ណាស់ ទើបសួរតទៅថា៖ "ចុះរឿងនោះតើដូចម្ដេចខ្លះ?" ។ បរិព្វាជក**កន្ទប៉កេតុ** ចាប់ផ្ដើមនិយាយរឿងខ្លួននោះឲ្យស្ដាប់ដូចសេចក្ដីតទៅនេះថា៖

ខ្លួនខ្ញុំនេះឈ្មោះ**កន្ទប៉កេតុ** ជាបុត្រព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាម**ជីមូតកេតុ** នៅសីហលទ្វីប ។ ថ្ងៃមួយ ខ្ញុំចូលទៅលេងកំសាន្តសប្បាយក្នុងសួនឧទ្យាន បានជួបពាណិជម្នាក់ជាអ្នកធ្លាប់ដើរសំពៅសមុទ្រ គាត់បាននិយាយប្រាប់ខ្ញុំថា៖ "នៅនាកណ្ដាលសមុទ្រ តែដល់ថ្ងៃ ១៤ កើតហើយ តែងមានផុសកល្បព្រឹក្សមួយដើម, នៅទៀបគល់កល្បព្រឹក្សនោះ ខ្ញុំឃើញនាងកញ្ញាម្នាក់ មានរូបឆោមលោមពណ៌ល្អអនេក ដូចនាងលក្ស្មី(១) ប្រដាប់តាក់តែងស្អិតស្អាងកាយដោយគ្រឿងអលង្ការគ្រប់ប្រការ អង្គុយលើទែនសយនាជាវិការៈនៃមាសភ្លឺប្រុះផ្លុះផ្ទៀលច្រវាត់ដោយរតនវត្ថុដ៏មានតម្លៃ ដៃដេញពិណលេងកំសាន្តសប្បាយឮសូរពីរោះក្រៃលែង ។ លំដាប់នោះ ខ្ញុំសូមឲ្យពាណិជធ្វើជាអ្នកនាំ ហើយបបួលគ្នាឡើងជិះសំពៅ លើកយុត្កាបើកយាត្រាចរចេញទៅកាន់ទីនោះ ។ កាលទៅដល់ ខ្ញុំបានឃើញនាងកញ្ញាអង្គុយលើទែនសយនាដ៏ល្អនោះមែន តែពេលនោះ ទែនសយនាលិចពាក់កណ្ដាលទៅក្នុងទឹកហើយ តទៅ នាងកញ្ញា

---

(១) សក្ដិព្រះនារាយណ ។

នោះក៏លិចបាត់ទៅក្នុងទឹកព្រមមួយអន្លើដោយស្រីជាបរិវារនៅចំពោះមុខខ្ញុំថែមទៀត ដូចសេចក្ដីដែលពាណិជបានប្រាប់ខ្ញុំសព្វគ្រប់មែន ។ កាលនោះឯង ខ្ញុំក៏ជាប់ចិត្តស្និទ្ធស្នេហាចំពោះរូបសោភានាងកញ្ញានោះខ្លាំងណាស់ ទាល់តែអត់ទ្រាំមិនបានក៏លោតភ្លុងចុះក្នុងទឹកមុជទៅតាមភ្លាម ខ្ញុំបានទៅដល់**កនកបុរី**ស្រីនគរមាស បានឃើញនាងកញ្ញានោះ អង្គុយលើទែនដដែលក្នុងសុវណ្ណប្រាសាទមាននាងវិជ្ជាធរីទាំងឡាយកំពុងចោមរោមគាល់ហ្មៅ ។ នាងកញ្ញានោះមើលមកឃើញខ្ញុំពីចម្ងាយ ក៏ប្រើនាងវិជ្ជាធរីម្នាក់ជាជំនិតឲ្យមកអញ្ជើញខ្ញុំ ។ នាងបម្រើនេះនិយាយប្រាប់ខ្ញុំដោយក្ដីរាក់ទាក់ដ៏ក្រៃលែង ។ ខ្ញុំសាកសួរនាងបម្រើនោះៗនិយាយប្រាប់មកខ្ញុំវិញថា នាងកញ្ញានេះព្រះនាមនាង**រត្នមញ្ជរី** ជាព្រះរាជបុត្រីនៃព្រះបាទចក្រពត្រាធិរាជ នៃពួកវិទ្យាធរទាំងឡាយ ទ្រង់ព្រះនាម**កន្ទប៍កេលី**, ព្រះនាងបានប្ដេជ្ញាទុកថា អ្នកណាបានមកដល់ឃើញក្រុង**កនកបុរី** នេះដោយភ្នែកខ្លួនឯង, សូម្បីព្រះវរបិតានាងមិនជ្រាប ព្រះនាងក៏ទទួលយកអ្នកនោះជារាជស្វាមី, បើដូច្នោះ ចូរអ្នករៀបចំមង្គលការនឹងនាងកញ្ញានេះ ដោយគាន្ធវ៌វិវាហៈក្នុងកាលឥឡូវនេះទៅ ។ កាលនោះឯង, ខ្ញុំក៏រៀបចំធ្វើមង្គលការគាន្ធវ៌វិវាហៈនឹងនាងកញ្ញានោះ ហើយនៅជាសុខក្សេមក្សាន្តមនោរម្យសមតាមសេចក្ដីប្រាថ្នាអស់កាលដ៏យូរ ។

ថ្ងៃមួយ នាង**រត្នមញ្ជរី**ជាភរិយាហាមប្រាមខ្ញុំដោយសេចក្ដីស្រឡាញ់ថា៖ “ស្វាមី! អ្នកបងចូរប្រើប្រាស់គ្រឿងឧបភោគបរិភោគដែលមាននៅក្នុងប្រាសាទទាំងអស់នេះតាមសេចក្ដីប្រាថ្នាចុះ កុំកោតញញើតឡើយ, តែរូបគំនូរនាងវិជ្ជាធរីឈ្មោះ**ស្វណ៌រេខា** មួយនេះ ក្នុងកាលណាក៏ដោយ អ្នកបងកុំពាល់ឲ្យសោះ ។ ក្នុងកាលជាខាងក្រោយមក, ដោយសេចក្ដីចំណង់ដ៏ខ្លាំងក្រៃលែង អត់ទ្រាំមិនបាន ខ្ញុំក៏យកដៃទៅពាល់សុដននាង**ស្វណ៌រេខា**រូបគំនូរនោះ ដកដៃស្ទើរតែមិនទាន់ទាំងផុតផង រូបគំនូរនាង**ស្វណ៌រេខា**នោះយកជើងមកធាក់ខ្ញុំមួយជើងប៉ុង ប៉ើងធ្លាក់មកដល់ស្រុកកំណើតខ្លួនវិញមួយរំពេច ។ ខ្ញុំកើតទុក្ខព្រួយក្ដៅក្រហាយស្ដាយក្រោយតប់ប្រមល់ទល់ពុទ្ធោមិនដឹងធ្វើដូចម្ដេច ក៏រត់មកបួសជាបរិព្វាជក ចេះតែដើរត្រាច់រង្គាត់លើផែនពសុធាវិលវល់ទៅវិញទៅមក ហើយដើររហូតមកដល់នគរនេះឯង ។ លុះព្រះទិនករដ៏បវរចរចូលកាន់សន្និយារាត្រី ខ្ញុំក៏ចូលទៅកាន់ផ្ទះគោបាលដែលនៅជិតទីឋាននេះ សុំជ្រកកោនអាស្រ័យនៅសម្រាកកម្លាំង ។ គោបាលបានទទួលឲ្យខ្ញុំពឹងពាក់អាស្រ័យក្នុងទីមួយកន្លែងនៅផ្ទះគាត់ៗ បាននិយាយប្រាប់ភរិយាគាត់ថា ឲ្យមើលថែរក្សាខ្ញុំដោយល្អផង ចាំទម្រាំដល់គាត់ត្រឡប់មកវិញ ។ គោបាលផ្ដាំទុកដាក់ខ្ញុំនឹងភរិយារួចហើយ គាត់ដើរចេញទៅក្រៅបាត់ ។ ក្នុងពេលដែលគោបាលជាប្ដីចេញផុតបាត់ទៅ, ភរិយាគាត់ប្រព្រឹត្តខុសគន្លងប្រវេណីស្ត្រីភាព ធ្វើការទាក់ទងជាមួយស្ត្រីពេស្យាជាមេអណ្ដើកម្នាក់ជាភរិយាអ្នកកាត់សក់ ។ លុះគោបាលត្រឡប់មកដល់ផ្ទះ គាត់ឃើញភរិយាគាត់កំពុង

និយាយចរចាជាមួយនឹងស្រីពេស្យានោះ ។ ឯភរិយាគោបាលកាលឃើញគោបាលជាប្ដីត្រឡប់មកដល់វិញ រត់ចូលទៅក្នុងផ្ទះភ្លាម ហើយធ្វើជារៀបចំតាក់តែងគ្រែពូកខ្នល់ក្នើយសម្រាប់ទទួលទានដំណេក ។ គោបាលជាប្ដី ចាប់ភរិយាកាឡកណ្ណីនោះមកវាយច្រើនខ្ទាប់ ហើយយកទៅចងភ្ជាប់នឹងសសរទ្រូងផ្ទះ រួចគាត់ក៏ចូលទៅសំងំដេកលក់ទៅ ។ ពេលរំលងអធ្រាត្រ ស្ត្រីពេស្យាមេអណ្ដើកនោះ វិលត្រឡប់មកជួបប្រពន្ធគោបាលវិញ ហើយនិយាយថា៖ “ម្រាក់អើយ! សហាយជាទីស្រឡាញ់ម្រាក់ កើតទុក្ខក្ដៅក្រហល់ក្រហាយរោលរាលខ្លាំងណាស់ ដូចភ្លើងឆេះ ដេកមិនលក់បក់មិនល្ហើយទេ ព្រោះមិនបានជួបឃើញមុខម្រាក់ថ្ងៃនេះ, ឥឡូវនេះត្រូវសរព្រះកាមទេពសន្ធប់សន្និនដូចរកកលស្លាប់ទៅហើយ, ព្រោះថា៖

១១១- កាលបើព្រះចន្ទ្ររះឡើងក្រឡង់ កម្ចាត់បង់អ័ព្ទងងឹតសូន្យសុង ចោលពន្លឺភ្លឺថ្លា ត្រជាក់ស្រអែតក្នុងរាត្រីកាលហើយ ព្រះកាមទេពតែងបាញ់សរទៅចំចិត្តកំលោះ ដែលខ្លួនបានឃើញ ។

ខ្ញុំបានឃើញសហាយនាង កើតទុក្ខព្រួយជ្រុបសញ្ជប់សញ្ជឹងមានប្រការដូច្នេះ ទើបបានជាខ្ញុំវិលត្រឡប់មកប្រាប់ម្រាក់វិញ ។ បើដូច្នេះ ដើម្បីឲ្យម្រាក់បានទៅជួបមុខ ខ្ញុំគិតថាយកខ្លួនខ្ញុំទៅចងជំនួសម្រាក់បណ្ដើរសិន ដើម្បីឲ្យម្រាក់ទៅជួបប្រុសសម្លាញ់ក្នុងទីនោះ លុះម្រាក់ធ្វើឲ្យគ្នាសប្បាយចិត្តរួចស្រេចហើយ សឹមម្រាក់ត្រឡប់វិលមកវិញ តែសូមម្រាក់កុំទៅយូរពេក ។ កាលនាងទាំងពីរនិយាយគ្នាហើយធ្វើតាមពាក្យមត់នោះ គោបាលក៏ភ្ញាក់ពីដេកឡើងវិញ ហើយនៅតែក្ដៅចិត្តជំនៅឡើយ ទើបនិយាយបញ្ឆោះបោះបោកទៅរកភរិយាថា៖ “ចុះហេតុអ្វី ពេលនេះមេសំផឹងឯងម៉េចក៏មិនទៅរកសហាយមីហាងឯងទៀតទៅហ៎ះ?” ។ ពេលនោះ, ដរាបណា ស្ត្រីពេស្យាមេអណ្ដើកដែលចងខ្លួនជំនួសភរិយាគោបាលមិនមាត់កថាដូចម្ដេចសោះ, ដរាបនោះ គោបាលច្រឡោតខឹងរឹតតែខ្លាំងឡើងស្រែកជេរសន្ធាប់ថា៖ “យើមីចោរចង្រៃ! មីហាងឯងព្រហើនណាស់ ម៉េចមិនចង់និយាយឆ្លើយឆ្លងនឹងអញផង ប្រយ័ត្នអញអត់មិនបាន តិចហ៊ឹះ!” ថាហើយ ក្រោធខឹងណាស់ ស្ទុះទៅកន្ត្រាក់យកកាំបិតមកកាត់ចុងច្រមុះស្ត្រីនោះដាច់ធ្លាក់ដល់ដីកំបុតថ្កុយកញ្ចុតច្រមុះទៅ, កាត់រួចហើយ គោបាលក៏ចូលទៅសំងំដេកលក់ដូចដើមវិញទៅ ។ តមក, មិនយូរប៉ុន្មានភរិយាគោបាលត្រឡប់មកដល់វិញ ហើយសួរទៅនាងមេអណ្ដើកនោះថា៖ “ម៉េចទៅម្រាក់! មានការអ្វីថ្មីទៀតទេ?” ។ “ចុះហាងម៉េចក៏មិនមើលមុខ, មេអណ្ដើកឆ្លើយ, ដាច់ច្រមុះគ្នាកញ្ចុតទៅហើយចាំ សួរគ្នាថាមានការអ្វីថ្មីទៀតទេ, មុខច្រមុះកញ្ចុតនេះវាប្រាប់ស្រាប់ហើយចាំសួរធ្វើអ្វី” ។ ភរិយាគោបាលផ្លាស់យកខ្លួនទៅចងវិញ ហើយឈរនៅព្រងើយដូចដើម ។ ឯស្ត្រីពេស្យាមេអណ្ដើកកាលគេស្រាយខ្លួនហើយ លូកដៃរើសចុងច្រមុះមួយកំណាត់កាន់ដើរចេញទៅផ្ទះខ្លួនវិញ ។ លុះដល់ព្រឹកព្រាងឡើង អ្នកកាត់សក់នៅក្រៅផ្ទះ ស្រែកហៅប្រពន្ធប្រើឲ្យយកស្រោមកាំបិត ព្រមទាំងកាំបិតមកឲ្យ

ផង, ឯនាងមេអណ្ដើកជាប្រពន្ធ មិនឲ្យទាំងស្រោមកាំបិត ត្រឡប់ជាឲ្យតែកាំបិតមកវិញ ។ អ្នកកាត់សក់ក្រោធខឹងឆេវកន្ត្រាក់កាំបិតពីដៃភរិយា យកទៅចោលឮស្នូរក្លុងក្លាំងពេញទាំងផ្ទះ ។ ភរិយាភិតភ័យស្លាំងកាំងរន្ធត់តក្កមាខ្លាំងណាស់ ទ្រហោយំហ៊ឺឡើង ហើយស្រែកឆោឡោអាក្រោសប្រាប់គេឯងថា៖ “ឱលោកអើយ! ខ្ញុំមិនខុសឆ្គាំឆ្គងអ្វីសោះ ស្រាប់តែយកកាំបិតមកកាត់ច្រមុះខ្ញុំដាច់ធ្លុយចេញឈាមសស្រាក់!” និយាយហើយកាន់ចុងច្រមុះចុះពីផ្ទះដើរចេញទៅប្ដឹងតុលាការឲ្យជំនុំជម្រះ ។ ក្នុងពេលនោះឯង គោបាលបែរទៅនិយាយនឹងភរិយាខ្លួនដោយសម្ដីឡូកឡឺយថា៖ “អើមីហាងឯង! គ្រាន់បើហើយ វាសមមុខហើយមីកញ្ឆតច្រមុះ” ។ “នែអាកំណាចចង្រៃ!, ភរិយាឆ្លើយ, អ្នកណាអាចធ្វើប្រពន្ធគ្រប់លក្ខណ៍ខ្លួនឯងឲ្យអាម៉ាស់មុខគេដូចអាចង្រៃឯងនេះ? អញមិនចង់និយាយប្ញូរបាច់ច្រើនពេកទេ, រឿងនេះលោកបាលជាទេវតារក្សាលោកទាំង ៨ ទិស ជ្រាបសេចក្ដីបរិសុទ្ធអញស្រាប់ហើយ ។

១១២- ព្រះអាទិត្យ និងព្រះចន្ទ្រ, ព្រះវាយុ និងព្រះអគ្គិ, មេឃដី និងទឹក, ហឫទ័យ និងព្រះយម, ថ្ងៃ និងយប់ ពេលសន្ធិ ([1])ទាំងពីរនឹងព្រះធម៌ តែងស្គាល់ច្បាស់នូវសេចក្ដីប្រព្រឹត្តនៃមនុស្សលោក ។

បើខ្លួនខ្ញុំជាស្រីគ្រប់លក្ខណ៍ មិនដែលលះបង់ចោលប្ដី មិនដែលស្គាល់ប្រុសដទៃ, សូម្បីយល់សប្តិក៏មិនដែលឃើញថាមានការប្រព្រឹត្តអនាចារនឹងប្រុសដទៃទេ ដោយអំណាចគុណធម៌ជាកុសលនេះ សូមកុំឲ្យមុខមាត់ច្រមុះវិកលវិការឡើយ ហើយសូមឲ្យខ្ញុំមានតេជះអាចរំលាយប្ដីចង្រៃនេះឲ្យខ្ទេចជាផង់ធូលីផែះកុំខាន, ប្ដីអ្វីកាចចង្រៃម្ល៉េះនេះ? ខ្ញុំមានចិត្តនឹកភ័យខ្លាចចំពោះតែលោកជាទេវតាធំទេ” ថាហើយស្រែកប្រាប់ទៅប្ដីថា៖ “មើលអាចង្រៃឯង! អាឯងមកមើលមុខអញមើល!” ។ កាលនោះ គោបាលជាប្ដីឮពាក្យសច្ចាប្រណិធានភរិយាម៉ឹងម៉ាត់ដូច្នោះឆេះដូចភ្លើង អត់ទ្រាំមិនបានក៏ដុតភ្លើងកាន់យកទៅទ្រោលបំភ្លឺមើលមុខភរិយា ដើម្បីនឹងផ្ចាញ់កុំឲ្យឆ្មាសពេក លុះមើលឃើញហើយ ឃើញច្រមុះពេញលេញដូចប្រក្រតីដើមភ័យណាស់ ក៏លុតជង្គង់ក្រាបទៀបជើងភរិយាពោលពាក្យលន់តួអង្វរទោស ហើយសរសើរសំណាងខ្លួនថា៖ “ឱអញអើយ! មានបុណ្យវាសនាណាស់តើ! បានភរិយាបរិសុទ្ធប្រាកដដូច្នេះ ជាស្រីគ្រប់លក្ខណ៍ប្រសើរណាស់ហ្ន៎! យីអញ! កុំអីវរសោះ([2])” ។

បរិព្វាជក**កន្ទប៍កេតុ**និយាយប្រាប់រាជបុរសតទៅទៀតថា រូបអ្នកនេះជាពាណិជដែលមានរឿងជាមួយគ្នា ខ្ញុំនឹងរៀបរាប់រឿងគាត់ជូនស្ដាប់ដូចសេចក្ដីតទៅ៖

---

[1] ពេលព្រះអាទិត្យជិតរះឡើង និងរះឡើងច្បាស់ហើយ១, ពេលព្រះអាទិត្យជិតអស្ដង្គត និងលិចបាត់ទៅ១ ។

[2] ហិតោបទេស សេចក្ដីប្រែជាភាសាបារាំងនៃលោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះ ក្នុងសម្ដីស្រី មានសុទ្ធតែទឹកឃ្មុំ តែក្នុងចិត្តស្រី មានសុទ្ធតែពិសពុល បើតពីរមាត់ទទឹកដោយពិសពុលហើយ ចិត្តពុះពោរដោយសេចក្ដីទុក្ខកក្ដៅក្រហាយ ។

នាយពាណិជនេះ ធ្វើដំណើរចេញពីផ្ទះខ្លួនទៅរកធ្វើជំនួញ ទៅនៅរកទទួលទាននៅប្រទេសជិតភ្នំមល័យអស់ ១២ឆ្នាំ រួចហើយទើបបានមកដល់ក្រុងនេះ ។ នៅក្នុងក្រុងនេះ គាត់បានសុំទីជ្រកអាស្រ័យដំណេកនៅផ្ទះស្រីពេស្យាម្នាក់ ។

នាងពេស្យានេះ បានឲ្យគេឆ្លាក់រូបវេតាលៈ([១]) ជាវិការៈនៃឈើយកទៅដាក់នៅមាត់ទ្វារផ្ទះ នៅលើក្បាលរូបវេតាលៈនោះ នាងពេស្យាបញ្ចុះពេជ្រដ៏មានតម្លៃទាំងគ្រាប់ ។ ដោយក្តីល្មោភជិះជាន់ខ្លាំង ពេលយប់នាយពាណិជដើរឡើងចូលទៅលបលួចយកពេជ្រ ដែលនៅលើក្បាលវេតាលៈនោះ កាលលូកដៃទៅចាប់យក ស្រាប់តែមានខ្សែយន្តទាញដៃវេតាលៈទាំងពីរឲ្យកម្រើកទៅរួបចាប់ដៃពាណិជជាប់រើមិនរួច ពាណិជភ័យខ្លាំងណាស់ទាល់តែស្រែកឲ្យគេជួយ ។ នាងពេស្យាភ្ញាក់ឡើង និយាយទៅកាន់ពាណិជថា៖ "នែកូនសម្លាញ់! ឯងមកពីប្រទេសជិតភ្នំមល័យ ឯងចូរប្រគល់រតនវត្ថុទាំងអស់នោះមកឲ្យយើង បើឯងរឹងមិនព្រមឲ្យទេ បិសាចនេះនឹងមិនព្រមលែងឯងទេ ព្រោះកិច្ចការនេះ ជាការងាររបស់វាជាបិសាច" ។ កាលនោះ, ពាណិជក៏ប្រគល់រតនវត្ថុខ្លួនទាំងអស់ឲ្យទៅនាងពេស្យា ឥតមានសេសសល់អ្វី, ឥឡូវនេះគាត់ខាតបង់ទ្រព្យសម្បត្តិអស់ ធ្លាក់ខ្លួនទៅជាអ្នកក្រីក្រត្រដេបត្រដាប ដូច្នេះទើបបានមកនៅជាមួយខ្ញុំសព្វថ្ងៃនេះ ។ លុះរាជបុរសជាពេជ្ឈឃាតទាំងឡាយបានស្តាប់ដំណើរដើមទងរឿងសព្វគ្រប់ហើយ ក៏យកសេចក្តីទាំងអស់នេះទៅប្រាប់ដល់ចៅក្រមវិញ ។ លំដាប់នោះចៅក្រមក៏ចាត់ការឲ្យបំបរបង់នាងពេស្យាមេអណ្តើក និងភរិយាគោបាលចេញពីភូមិមិនឲ្យនៅតទៅទៀត, បង្គាប់ឲ្យអ្នកកាត់សក់ត្រឡប់ទៅកាន់ផ្ទះទីលំនៅខ្លួនវិញ ។ ព្រោះហេតុនោះហើយបានជាខ្ញុំ (ចចក**ទមនកៈ**) ពោលបទដើមអាទិ៍ថា៖ "មនុស្ស ៣នាក់ ត្រូវទួលទុក្ខលំបាក" ដូច្នេះជាដើម (លេខ ១១០) ។

អើទោសនេះ ជាទោសគឺយើងធ្វើខ្លួនយើង, បើដូច្នេះ តើយើងទៅរវល់កើតទុក្ខយំសោយសោកថ្វី ។ ចចក**ទមនកៈ** ពិចារណាមើលមួយស្របក់ ក៏និយាយតទៅថា៖ "នែសម្លាញ់! អត់សង្កត់ចិត្តបន្តិចទៅសិនចុះ, ខ្ញុំជាដើមហេតុនាំឲ្យចងមេត្រីភាពយ៉ាងណា, ខ្ញុំក៏ជាដើមហេតុនាំបំបែកមិត្តឲ្យបានយ៉ាងនោះដែរ, ព្រោះថា៖

១១៣- នរជនឆ្លៀវឆ្លាត អាចប្រឌិតរបស់ដែលមិនពិត ឲ្យមើលឃើញជារបស់ពិតប្រាកដបាន ដូចចិត្រករប្រសប់ប៉ិនប៉ៅ អាចគូររូបភាពលើផ្ទៃដ៏រៀបស្មើឲ្យផ្តុះស្រមោល គេមើលទៅឃើញមានទាបខ្ពស់ទៅតាមចិត្តបាន ។

---

[១] រូបបិសាចស៊ីខ្មោចស្រស់ ។

១១៤- វីហេតុការណ៍ណាមួយដែលកើតឡើងភ្លាមៗ ដោយមិនដឹងខ្លួន នរជនណាមិនភ័ន្តភាំងបាត់គំនិតប្រាជ្ញាទេ នរជននោះអាចឆ្លងផុតពីក្រទុក្ខលំបាកគ្រប់ប្រការបាន ដូចភរិយាគោបាល និងសហាយ ២នាក់ ។ ចចក**ករដក:** សួររឿងនោះថា៖ “រឿងនោះតើដូចម្តេច?” ។ ចចក**ទមនក:** រៀបរាប់រឿងរ៉ាវនោះប្រាប់ដូចតទៅនេះថា៖

# កថាទី៧

## រឿងភរិយាគោបាល និងសហាយពីរនាក់

នៅក្នុងក្រុងបុរីទ្វារាវតី មានស្ត្រីម្នាក់ជាភរិយាគោបាល ជាស្ត្រីចិត្តចើកហើរហាយទៅចងចិត្តរីករាយដោយផ្លូវកាមលោកិយ នឹងមន្ត្រីកាន់ការជាទណ្ឌនាយក([១]) ព្រមទាំងបុត្រកំលោះគាត់ផងនៅក្នុងក្រុងនោះ, ព្រោះថា៖

១១៥- ភ្លើងតែងមិនឆ្អែតដោយអង្កត់ឧសទាំងឡាយ, មហាសមុទ្រតែងមិនឆ្អែតដោយទឹកស្ទឹងទាំងឡាយ, ម្រឹត្យុតែងមិនឆ្អែតដោយសព្វសត្វទាំងឡាយ, ឯស្ត្រីមានរូបល្អ តែងមិនឆ្អែតដោយប្រុសទាំងឡាយ ។

១១៦- ដោយការឲ្យរង្វាន់ក៏មិនបាន ដោយការយកចិត្តក៏មិនបាន ដោយការប្រើអាវុធបង្ខំក៏មិនបាន ឬដោយការប្រើច្បាប់ចរិយាបង្គាប់ក៏មិនបានទៀត ដោយពិត, ស្ត្រីភាពគឺគេទូន្មានមិនងាយបានដោយប្រការទាំងពួង ។

១១៧- ស្ត្រីភាព ចិត្តដាច់ណាស់ អាចលះបង់ប្តីដែលមានគុណដ៏ប្រសើរ មានកិត្តិយស មានរូបល្អជាទីពេញចិត្ត ឆ្លាតក្នុងកាមវិធី មានទ្រព្យសម្បត្តិច្រើន ឬនៅក្មេងស្រឡាងចោលភ្លាមមួយរំពេច ហើយរត់ទៅរើសរកប្រុសគម្រក់តាមថ្នល់ដែលឥតគុណ និងចរិយា ។

១១៨- ពិតប្រាកដណាស់! នារី សូម្បីដេកលើទែនសយនារចនាដ៏វិចិត្រប្រណីតគួរជាទីមនោរម្យក៏មិនគាប់ចិត្តស្និតស្នេះដោយក្តីភ្លើតភ្លើនរួមខ្នើយដោយប្រុសប្តីគេ ជាគូស្នេហាថ្មីប្លែកមុខ យកផែនដីជាគ្រែក្រាលដោយស្មៅក្រៀមក្រោះជាកន្ទេល ។

ថ្ងៃមួយ, ភរិយាគោបាលនោះ អង្គុយប្រឡែងលេងជាទីរីករាយជាមួយនឹងបុត្រទណ្ឌនាយកដោយកាមតណ្ហា ។ កំពុងតែរីករាយដោយក្តីស្នេហា, ទណ្ឌនាយកមកដល់, ភរិយាគោបាល ក៏លបយកបុត្រទណ្ឌនាយកនោះទៅលាក់ក្នុងជង្រុកភ្លាម ហើយចេញមកសំណេះសំណាលជាមួយទណ្ឌនាយកវិញ

---

[១] មេតម្រួត, មេនគរបាល ។

និយាយលើចលេងក្អាកក្អាយដោយក្ដីប្រតិព័ទ្ធ ។ កាលនោះឯង, គោបាលជាប្ដីនាងនោះត្រឡប់ពីឃ្វាលគោមកដល់ ។ ភរិយាគោបាលឃើញប្ដីមកដល់ និយាយខ្សឹបៗនឹងទណ្ឌនាយកថា៖ "នែលោកទណ្ឌនាយក! លោកកាន់ដំបងមួយ ហើយដើរចេញទៅរហ័សធ្វើអាការហាក់ដូចជាក្រោធខឹងណាស់" ។ និយាយរួចហើយ ទណ្ឌនាយកធ្វើតាមភ្លាម ។ ឯគោបាលចូលមកដល់ក្នុងផ្ទះសួរប្រពន្ធថា៖ "ទណ្ឌនាយកនេះក្រោធខឹងរឿងអ្វីខ្លាំងម្ល៉េះ?" ។ ភរិយាគោបាលឆ្លើយប្រាប់ថា៖ "លោកទណ្ឌនាយក លោកខឹងនឹងកូនលោក ខ្ញុំមិនដឹងជាមានហេតុអ្វីដែរ កូនលោកនោះរត់ចូលមកជ្រកក្នុងផ្ទះយើង ឥឡូវខ្ញុំជួយយកទៅលាក់ក្នុងជង្រុករក្សាទុកទៅហើយ, លោកទណ្ឌនាយកចូលមកក្នុងផ្ទះយើងរកកូនលោកនោះមិនឃើញ ខឹងណាស់មុខក្រញូវដើរចេញទៅវិញទៅ" ។ ពេលនោះ ភរិយាគោបាល ចូលទៅនាំយកបុត្រទណ្ឌនាយកនោះចេញពីជង្រុកមកបង្ហាញប្ដី, ព្រោះថា៖

១១៩- បុគ្គលគប្បីជ្រាបថា ស្ត្រីបរិភោគអាហារទ្វេគុណ, មានប្រាជ្ញាចតុគុណ, មានកលមាយាឆគុណ និងបរិភោគកាមអដ្ឋគុណ" ។

ហេតុនោះហើយ បានជាខ្ញុំ (ចចក**ទមនកៈ**) ពោលថា៖ "រីហេតុការណ៍ណាមួយ ដែលកើតឡើងភ្លាមៗដោយមិនដឹងខ្លួន" ដូច្នេះជាដើម (លេខ១១៤) ។

ចចក**ករដកៈ**ឆ្លើយឡើងថា៖ "ឯងនិយាយនេះ តែងមានសេចក្ដីពិតហើយ, តែធ្វើដូចម្ដេចហ្ន៎ៈ មេត្រីរាប់អានគ្នាទៅវិញទៅមកនៃសត្វទាំងពីរនោះ កើតជាប់ជានិស្ស័យស្និទ្ធជិតជាប់លាប់ណាស់ទៅហើយ យើងធ្វើដូចម្ដេចទើបអាចនឹងបំបែកគ្នាចេញបាន?" ។ ចចក**ទមនកៈ** ឆ្លើយប្រាប់ថា៖ "យើងរកឧបាយបំបែកឲ្យទាល់តែបាន, ព្រោះថា៖

១២០- កិច្ចការណាដែលគេអាចធ្វើឲ្យសម្រេចបានដោយឧបាយ, កិច្ចការនោះ គេមិនបាច់ប្រើកម្លាំងព្យាយាមទេ ព្រោះប្រើឧបាយដោយខ្សែ-កជាវិការនៃមាស ក្អែកសម្លាប់ពស់វែកបាន" ។

ចចក**ករដកៈ** សួរថា៖ "ចុះរឿងនោះដូចម្ដេច?" ។ ចចក**ទមនកៈ**និយាយរឿងនោះប្រាប់ថា៖

# កថាទី៨

## រឿងក្អែកញីឈ្មោល និងពស់

មានក្អែកញីឈ្មោលមួយគូ អាស្រ័យនៅលើដើមឈើមួយដើម ក្នុងព្រង់ដើមឈើនោះមានពស់វែកមួយ ។ ពស់នោះ វាតែងតែចាប់កូនក្អែកស៊ីជាចំណីអាហារ ។ តមក, ក្អែកញីរកកល់ពងទៀត និយាយទៅកាន់ប្ដីថា៖ "អ្នកបងជាទីពឹង! គួរយើងលះបង់ចោលដើមឈើនេះទៅ ហើយហើរទៅរកដើមឈើ

ឯទៀតអាស្រ័យនៅវិញ ព្រោះដើមឈើជាទីលំនៅយើងនេះប្រកបដោយភ័យ ពស់វែកចង្រៃនេះវាចេះតែចាប់កូនយើងស៊ីញយៗ, តទៅយើងអស់មានកូនចៅពូជពង្សទៀតហើយ, ព្រោះថា៖

១២១- ភរិយាចិត្តអាក្រក់សាមាន្យ, មិត្តជាសត្រូវ, អ្នកបម្រើព្រហើនពោលពាក្យតប, នៅក្នុងផ្ទះមានពស់ ទាំងអស់នេះលោកថាសុទ្ធតែម្រឹត្យុឥតសង្ស័យឡើយ ។

ក្អែកឈ្មោលនិយាយតបវិញថា៖ "នែប្អូនសម្លាញ់! ប្អូនកុំថប់ថ្វី ទុកងារឲ្យបង, រឿងនេះបងខំទ្រាំទល់ទុក្ខវេទនាចំពោះកំហុសធំនៃពស់វែកនេះមកជាច្រើនដងច្រើនគ្រាណាស់ហើយ, ឥឡូវនេះ បងអត់ទ្រាំទៅទៀតមិនបានទេ" ។ ក្អែកញីនិយាយនឹងក្អែកឈ្មោលថា៖ "ចុះអ្នកបងធ្វើដូចម្ដេចទៅហ៎ះ បើពស់វែកនេះវាមានកម្លាំងខ្លាំងច្រើនជាងយើងម្ល៉េះ? អ្នកបងអាចប៊ានទៅតនឹងវាបានឬទេ?" ។ ក្អែកឈ្មោលឆ្លើយថា៖ "រឿងនេះប្អូនកុំឆ្ងល់ធ្វើអ្វី, នៅឲ្យស្ងៀមទៅ, ព្រោះថា៖

១២២- នរជនណាមានប្រាជ្ញា នរជននោះឈ្មោះថាមានកម្លាំង ឯនរជនមិនមានប្រាជ្ញា នឹងមានកម្លាំងមកពីណា! ចូរមើល៖ សីហៈជោរឡើងចាងត្រូវទន្សាយសម្លាប់បាន" ។

ក្អែកញី សើចចំអកហើយសួរថា៖ "ចុះរឿងនោះ តើដូចម្ដេច?" ក្អែកឈ្មោលនិយាយរឿងរ៉ាវនោះប្រាប់ថា៖

## កថាទី៩

### រឿងសីហៈ និងទន្សាយ

នៅភ្នំមន្ទរៈ មានសីហៈមួយឈ្មោះ**ទុទ៌ាន្តៈ** ។ **ទុទ៌ាន្តៈ** តែងចាប់បសុសត្វទាំងឡាយច្រើនសម្លាប់ស៊ីជាចំណីអាហាររាល់ៗថ្ងៃ ។ សព្វសត្វទាំងឡាយភិតភ័យណាស់ បបួលគ្នាមកប្រជុំរិះគិតរកឧបាយហើយចូលទៅអង្វរករសីហៈថា៖ "បពិត្រលោកជាស្ដេចម្រឹគ ហេតុអ្វីក៏លោកចាប់សម្លាប់បំផ្លាញបសុសត្វបរិភោគជាអាហារម្ដងៗច្រើនដល់ម្ល៉េះ? បើលោកជ្រះថ្លាយល់ព្រមតាមគំនិតយើង, យើងខ្ញុំនឹងបញ្ជូនបសុសត្វមួយរាល់ថ្ងៃ ជាគ្រឿបណ្ណាការមកជូន ដើម្បីជាអាហារលោក" ។ ពេលនោះ **ទុទ៌ាន្តៈ** ឆ្លើយឡើងថា៖ "បើឯងទាំងឡាយមានប្រាថ្នាដូច្នោះ, អញត្រេកអរណាស់ហើយ, ឯងធ្វើតាមបំណងឯងចុះតាំងពីពេលនេះទៅ" ។ ចំណេរកាលមក, សីហៈលែងរវល់ចេញទៅបរបាញ់ចាប់សត្វដូចកាលសព្វដងទៀត នៅតែនឹងកន្លែងចាំទទួលបណ្ណាការ គឺបសុសត្វមួយៗដែលម្រឹគទាំងឡាយបញ្ជូនមកឲ្យរាល់ថ្ងៃ ។ ថ្ងៃតមក, ដល់វេនទន្សាយចាស់មួយ, ទន្សាយចាស់នោះគិតថា៖

១២៣- បុគ្គលធ្វើសេចក្ដីគោរពឱនលំទោន ព្រោះហេតុតែខ្លាចគេផង ព្រោះតែចង់ឲ្យមានជីវិត

រស់នៅផង ថាបើអាត្មាអញទៀងតែដល់បញ្ចភាពដដែល ប្រយោជន៍អ្វី អាត្មាអញនឹងត្រូវធ្វើសេចក្តីកោតក្រែងសីហៈនេះ ។

ទន្សាយគិតបណ្តើរដើរបណ្តើរ ទៅសន្សឹមៗបន្តិចៗចូលទៅរក**ទុទ៌ាន្តៈ** ។ ពេលនោះ **ទុទ៌ាន្តៈ** ដែលមានសេចក្តីស្រេកឃ្លានបៀតបៀនខ្លាំង ក្រោធច្រឡោតខឹង និយាយទ្រគោះបោកបោះទៅឲ្យទន្សាយថា៖ “យីអានេះ! អាឯងអាល័យដើរទៅលេងជាប់នៅឯណាឲ្យយឺតយូរក្របានមកដល់ហ៎ៈ!” ។ ទន្សាយលោមទោមអង្វរថា៖ “ទេវៈ! ខ្ញុំបាទមិនមានកំហុសទេ, កាលខ្ញុំបាទកំពុងដើរមកតាមផ្លូវមានសីហៈមួយធំណាស់ មកចាប់ឃាត់ខ្ញុំបាទទាំងអំណាច, ខ្ញុំបាទបាននិយាយអង្វរករស្បថស្បែចំពោះសីហៈកំណាចនោះថា នឹងត្រឡប់ទៅជួបវិញ សូមតែអនុញ្ញាតឲ្យខ្ញុំបាទចូលមកជម្រាបលោកម្ចាស់ក្នុងទីនេះ ឲ្យបានជ្រាបជាមុនសិន ព្រោះហេតុនេះបានជាយឺតយូរក្របានមកដល់ឆាប់” ។ **ទុទ៌ាន្តៈ** បានស្តាប់ហើយ ក្រេវក្រោធឆេវ សួរតបទៅវិញទាំងកំរោលថា៖ “បើដូច្នោះ អាឯងនាំអញទៅបង្ហាញឲ្យឆាប់ឥឡូវនេះ តើអាព្រហើនកោងកាចនោះវានៅឯណា?” ។ ពេលនោះ ទន្សាយក៏នាំសីហៈទ្រនង់នោះទៅបង្ហាញអណ្តូងជ្រៅស្រឡូងមួយ, លុះដើរទៅដល់មាត់អណ្តូងនោះហើយ, និយាយប្រាប់ថា៖ “សូមលោកម្ចាស់អញ្ជើញទៅមើលខ្លួនឯងចុះ វានៅក្នុងអណ្តូងនោះឯង” ។ ឯ**ទុទ៌ាន្តៈ** ដើរចូលទៅជិតក្រឡេកមើលក្នុងអណ្តូងឃើញស្រមោលខ្លួន សម្គាល់ថាជាសីហៈមួយធំសម្បើមអស្ចារ្យ ក្នាញ់ខ្លាំងណាស់ ដំឡើងប្រែងសម្តែងឫទ្ធិដ៏ឃោរឃៅលោតចុះទៅសង្គ្រុបក្នុងអណ្តូងដោយក្តីទ្រនង់យង់ឃ្នង ក៏ដល់នូវក្តីបញ្ចភាព ([១]) ស្លាប់ព្នដ៏កាលនោះទៅហោង ។ ហេតុនោះហើយបានជាបង (ក្អែកឈ្មោល) និយាយប្រាប់ថា៖ “នរជនណាមានប្រាជ្ញា នរជននោះឈ្មោះថាមានកម្លាំង” ដូច្នេះជាដើម (លេខ ១២២) ។ ក្អែកញីសួរថា៖ “អើខ្ញុំបានស្តាប់អស់អាថ៌សេចក្តីហើយ, តើអ្នកបងគិតធ្វើឧបាយនោះដូមម្តេច? ចូរប្រាប់ឧបាយនោះឲ្យខ្ញុំដឹងមើល!” ។ ក្អែកឈ្មោលនិយាយប្រាប់ថា៖ “នៅស្រះបោក្ខរណីទឹកថ្លាយល់ដី ជិតទីឋានយើងនេះមានព្រះរាជបុត្រទាំងឡាយតែងយាងចូលមកប្រពាតក្រសាលស្រង់ឧទកវារីលេងសប្បាយរាល់ៗថ្ងៃ, ក្នុងស្នានសម័យ([២]) ស្តេចតែងដោះខ្សែព្រះសូរងជាវិការៈនៃមាសសម្រាប់តែងព្រះអង្គ ទុកនៅលើផែនថ្មនាឆ្នេរស្រះ ហើយទើបចុះទៅស្រង់ ចូរប្អូនហើរចុះទៅឆក់លួចយកនូវខ្សែព្រះសូរងជាវិការៈនៃមាសនោះដោយចំពុះ ហើយនាំយកមកទម្លាក់ក្នុងព្រង់ដែលពស់ចង្រៃវាអាស្រ័យនៅ” ។ ថ្ងៃមួយ, ព្រះរាជបុត្រទាំងឡាយស្តេចយាងមកស្រង់ក្រសាលឧទកវារី មេក្អែកក៏ធ្វើដូចបានគិតគូរគ្នាទុកមុន ។ គ្រានោះឯង,

---

[១] សេចក្តីស្លាប់ ។

[២] ពេលមុជទឹក ។

ព្រះរាជបុត្រទាំងឡាយ បានទតឃើញមេក្អែកឆក់យកខ្សែព្រះសូរងដូច្នេះ ស្តេចដេញតាមមេក្អែក ដើម្បីដណ្តើមយកខ្សែព្រះសូរងនោះរហូតទៅដល់ព្រង់ ទៅប្រទះឃើញពស់វែកនោះ ហើយក៏បបួលគ្នាវាយសម្លាប់ចោលបង់សៀតទៅហោង ។ ព្រោះហេតុនោះបានជាខ្ញុំ (ចចក**ទមនកៈ**) ពោលថា៖ “កិច្ចការណាដែលគេអាចធ្វើឲ្យសម្រេចបានដោយឧបាយ” ដូច្នេះជាដើម (លេខ ១២០) ។

ចចក**ករដកៈ**និយាយចាក់បណ្តោយថា៖ “បើដូច្នោះ, ចូរឯងទៅចាត់ចែងធ្វើក្នុងកាលឥឡូវនេះទៅ, ហើយសូមឲ្យបានសម្រេចសមប្រកបតាមក្តីប្រាថ្នាកុំបីខានឡើយ” ។ លំដាប់នោះឯង, ចចក**ទមនកៈ**ដើរចូលទៅរក**បិង្គលកៈ** លុះចូលទៅដល់ហើយ លើកទសករប្រណម្យ ទើបពោលពាក្យថា៖ “ទេវៈ! ខ្ញុំបាទសង្កេតឃើញហេតុការណ៍ប្រកបដោយភ័យធំគួរឲ្យវិតក្កខ្លាំង ទើបចូលមកជួបលោកជាម្ចាស់ដោយប្រញាប់ប្រញាល់, ព្រោះថា៖

១២៤- ក្នុងគ្រាអន្តរាយ ឬក្នុងការដើរខុសគន្លងផ្លូវ ឬក៏ក្នុងការប្រព្រឹត្តកន្លងឱកាសជាកាលគួរនរជនជាអ្នកធ្វើប្រយោជន៍ទូទៅ, សូម្បីគេមិនសាកសួរ ក៏គប្បីស្នើណែនាំផ្លូវដោយពាក្យជាលក្ខណធម៌ ។

១២៥- ព្រះរាជា ជាភាជន៍សម្រាប់ត្រងរងនូវភោគសុខ(១) មិនមែនជាភាជន៍សម្រាប់ត្រងរងនូវរាជការទេ, កាលបើរាជការវិនាសខូចខាតហើយ មន្ត្រីត្រូវជាប់ទោស ។

ក្នុងករណីនេះ សូមលោកជាម្ចាស់ពិចារណាមើលចុះ, ក្រមនេះជាវិធីដំណើរការនៃអាមាត្យទាំងឡាយ, លោកថា៖

១២៦- ការស៊ូលះបង់ជីវិត ពុំនោះ ការកាត់សិរសាអាមាត្យឲ្យដាច់ចេញ ជាការគាប់ប្រសើរណាស់ តែអាមាត្យភក្តីធ្វើព្រងើយ កន្តើយចំពោះអាមាត្យក្បត់ដែលប្រុងសម្លាប់ម្ចាស់របស់ខ្លួន ដើម្បីធ្វើជាម្ចាស់ផែនដី មិនគាប់ប្រសើរសោះឡើយ” ។

**បិង្គលកៈ** ត្រេកអរសាទរណាស់ សួរទៅវិញថា៖ “បើដូច្នោះតើឯងត្រូវការនិយាយដូចម្តេចខ្លះ?” ។ ចចក**ទមនកៈ** និយាយឡើងថា៖ “ទេវៈ! គោ**សញ្ជីវកៈ**សម្តែងអាការកិរិយាចំពោះមុខខ្ញុំបាទមើលទៅហាក់មិនគួរគប្បីដល់លោកជាម្ចាស់សោះ, មានពោលពាក្យនិន្ទាទ្រគោះបោកបោះមើលងាយព្រះចេស្តាសក្តានុភាព ៣ ប្រការ(២) ប្រាថ្នាលោភលន់ប្រុងដណ្តើមយករាជសម្បត្តិ” ។ **បិង្គលកៈ** បាន

---

១ សេចក្តីសុខដែលកើតមានពីទ្រព្យសម្បត្តិ ។

២ រាជភណ្ឌ ៣ ប្រការគឺ៖ ប្រភាវៈ, មហាអំណាច (ពលានុភាព, អំណាចគ្រប់គ្រង, តេជានុភាព, គុណានុភាព) ១, មន្ត្រៈ មន្ត្រចំណេះវិជ្ជា ១, និងឧស្សាហៈកម្លាំងសក្តានុភាព១ ។

ស្តាប់ពាក្យញុះញង់នេះហើយ ភ័តតក់ស្លុតនឹកអស្ចារ្យក្នុងចិត្តស្ថិតនៅស្ងៀមមិនចេញស្តីសោះ ។ ចចក**ទមនកៈ**និយាយបន្ថែមទៀតថា៖ "ទេវៈ! លោកជាម្ចាស់ដកដាលបោះបង់ចោលអ្នករាជការចាស់មុនចោលអស់ ហើយតាំង**សញ្ជីវកៈ**នេះឲ្យកាន់តំណែងធំអភិបាលសម្រេចរាជការផែនដីទាំងអស់ អំពើនេះជាទោសធំសម្បើមណាស់, ព្រោះថា៖

១២៧- ស្រី[១] ទ្រទ្រង់នូវមន្ត្រី ដែលមានសក្តានុភាពខ្លាំង និងម្ចាស់ផែនដីឲ្យរឹងជំហរ ហើយយកជើងទាំងពីរទប់ជ្រែង, ឯស្រីនោះជាស្ត្រីភាព មានសមត្ថភាពមិនអាចទប់ទល់នូវភារៈដ៏ធ្ងន់ទាំងពីរឲ្យប្រព្រឹត្តទៅបានទេ ម្ល៉ោះហើយតោងទម្លាក់ភារៈណាមួយចោល ក្នុងភារៈទាំងពីរនោះ គឺខ្ញុំបាទ ឬលោកម្ចាស់ ។

១២៨- ក្នុងកាលណា ព្រះភូមិបតី ទ្រង់តែងតាំងមន្ត្រីណាមួយជាឯកអគ្គផ្តាច់ការក្នុងរាជ្យ, ក្នុងកាលនោះ ក្តីស្រវឹងយសតែងហូរចូលទៅគ្របសង្កត់ចិត្តមន្ត្រីនោះដោយអំណាចមោហាធម៌ មន្ត្រីនោះឯងរមែងទម្លាយបង់នូវការងារឲ្យវិនាស ដោយអំណាចស្រវឹងយស និងក្តីខ្ជិលច្រអូសមិនខាន, កាលបើការងារវិនាសហើយ សេចក្តីល្មោភអន្ទះអន្ទែងនឹងបង្កក្តីចង់បាន កាន់អំណាចដាច់ខាតខ្លួនឯងឲ្យកើតឡើងក្នុងចិត្ត, លំដាប់តទៅ, ដោយសេចក្តីល្មោភអន្ទះអន្ទែងចង់បានកាន់អំណាចដាច់ខាតខ្លួនឯងនេះជាមូលហេតុ, មន្ត្រីនោះនឹងទ្រុស្តធ្វើគុតម្ចាស់ខ្លួនឲ្យដល់ក្តីក្ស័យប្រាណមិនខាន ។

១២៩- អាហារទទឹកជ្រាបដោយពិសពុល ធ្មេញដែលរង្គើ និងអាមាត្យប្រទូស ទាំងអស់នេះត្រូវកកាយដកចោលឲ្យទាល់តែអស់ដល់បាត ដល់ឫសគល់ ទើបបានក្តីសុខ ។

១៣០- ព្រះរាជាអង្គណា ប្រគល់ព្រះរាជស្រី [២] ឲ្យជាអាយ័តដាច់ខាតដល់មន្ត្រីណាហើយ, ក្តីវិនាសអន្តរាយ នឹងកើតមានប្រាកដក្នុងទីនេះ ព្រះរាជាអង្គនោះ នឹងទ្រង់ផ្ទំកើតទុក្ខសោកសៅក្តៅក្រហាយ ដូចមនុស្សខ្វាក់ឥតអ្នកដឹកដៃ ។

**សញ្ជីវកៈ**នេះ ធ្វើកិច្ចការសារពើបរិហារផែនដី តាមតែទំនើងចិត្តវា លោកម្ចាស់ជាបន្ទាល់សាក្សីក្នុងរឿងនេះស្រាប់ហើយ បានទាំងជ្រាបច្បាស់នូវកិច្ចការទាំងអស់នេះសព្វគ្រប់ផង, ព្រោះថា៖

១៣១- បុរសណា មិនចង់បានទ្រព្យ បុរសនោះមិនមាននៅក្នុងលោកនេះទេ, ក្នុងលោកនេះ



[១] ពាក្យនេះ មានសេចក្តីច្រើន (បាលីថា សិរី) ប្រែថា សេចក្តីរុងរឿង សោភាលម្អ សេចក្តីចម្រើន សេចក្តីសុខ សម្បត្តិ ឃ្លាំងទ្រព្យ តេជានុភាព គុណានុភាព សក្តានុភាព និងលក្សី ដែលជាឈ្មោះទេពតា ទ្រព្យសម្បត្តិ ។

[២] បាលី រាជសិរី អធិបតេយ្យព្រះរាជា ។

នរណាមួយមិនក្រឡេកមើលដោយសាទរចំពោះប្រពន្ធក្មេងដែលមានរូបល្អគួរជាទីពេញចិត្តជនដទៃ?” ។

សីហៈពិចារណាមើលមួយស្របក់ ឆ្លើយតបទៅវិញថា៖ “នែសម្លាញ់! ពាក្យដែលឯងនិយាយនេះ ពិតមែនហើយ, ទោះបីដូច្នោះគួរនឹកដល់ការកម្សត់កម្រដែលយើងនឹង**សញ្ជីវកៈ**នេះបានធ្វើក្ដីស្និទ្ធស្នេហាយ៉ាងខ្លាំងមកយូរយារណាស់ហើយផង, ឯងចូរមើល! លោកថា៖

១៣២- មិត្តណាជាទីស្រឡាញ់ពេញចិត្ត បើទុកជាកុហកបោកប្រាសយើងខ្លះ មិត្តនោះ នៅតែជាទីស្រឡាញ់ពេញចិត្តដដែល ដូចរាងកាយយើង ទោះបីមានរោគាព្យាធិប្រទូសសព្វទាំងអស់ អ្នកណាមួយមិនស្រឡាញ់រាងកាយខ្លួន ។

១៣៣- មិត្តណាជាទីស្រឡាញ់ពេញចិត្ត សូម្បីធ្វើឲ្យយើងមិនពេញចិត្តច្រើនយ៉ាង មិត្តនោះ នៅតែជាមិត្តជាទីស្រឡាញ់ពេញចិត្តដដែល, ដូចភ្លើង សូម្បីឆេះមន្ទីរមហាសាល អ្នកណាមួយ លែងនិយមរាប់អានភ្លើងទៀត?” ។

ចចក**ទមនកៈ**និយាយថែមទៀតថា៖ “ទេវៈ! រឿងនេះ ជាទោសកំហុសធំខ្លាំងណាស់, ព្រោះថា៖

១៣៤- ព្រះរាជា ទតព្រះនេត្រដោយក្រៃលែង ចំពោះជនណាទោះជាព្រះរាជបុត្រក្ដី ទោះជាអាមាត្យក្ដី ឬក៏ជាជនបរទេសក្ដី លក្ស្មី(ទ្រព្យ) តែងរត់ចូលទៅជាសិរីនៃជននោះ ។

សូមលោកម្ចាស់ស្ដាប់ពាក្យនេះតទៅទៀតថា៖

១៣៥- ការរលត់បង់នូវពាក្យជដែក ដែលមិនជាទីពេញចិត្ត តែងនាំមកនូវសេចក្ដីសុខ, ទីណាមានអ្នកនិយាយ ហើយមានអ្នកស្ដាប់ ទីនោះ ក្ដីសម្រេចផលគួរជាទីពេញចិត្តតែងកើតឡើង ។

ពេលនេះ ព្រះបាទជាម្ចាស់ដកដាលខ្ញុំរាជការចាស់ជាឫសគល់ចោលអស់ហើយ ទៅតាំងបន្ទុបលើកកម្ដើងជនបរទេសអាគន្តុកជាត្រីមុខឲ្យជាធំជាងពួកខ្ញុំរាជការចាស់វិញ អំពើនេះមិនត្រឹមត្រូវតាមធម៌ទេ, ព្រោះថា៖

១៣៦- ព្រះភូមិបាល មិនគួរគប្បីរាប់អានលើកតម្កើងជនរបទេសអាគន្តុកដោយអាងហេតុថា “ខ្ញុំរាជការចាស់ប្រព្រឹត្តខុស”ទេ អំពើនេះជាទោសធំណាស់, ព្រោះថា ជនបរទេសយើងនឹងជឿទុកចិត្តបានថាមិនទម្លាយរាជ្យសម្បត្តិឲ្យវិនាសឬអ្វី?” ។

សីហៈនិយាយទទឹងទាស់ថា៖ “ពាក្យឯងនេះ ប្លែកអស្ចារ្យណាស់ មិនមែនឬអ្វី? **សញ្ជីវកៈ**នេះយើងបានឲ្យអភ័យ ហើយនាំយកមកទំនុកបម្រុងឲ្យធ្វើការឲ្យមានកិត្តិយស, ហេតុដូចម្ដេចក៏ឯងសម្គាល់យល់ថា វាគិតប្រទូសក្បត់រាជ្យយើងវិញ?” ។ ចចក**ទមនកៈ**និយាយបញ្ជាក់ថា៖ “ទេវៈ!

១៣៧- មនុស្សទុជ៌ន បើទុកជាលើកតម្កើងឲ្យមានយសសក្ដិជានិច្ចក៏ដោយ ក៏នៅតែមិនមានក្ដី

ស្មោះត្រង់ មិនលះបង់ប្រក្រតីដើម ដូចកន្ទុយឆ្កែ សូម្បីគេយកប្រេងលាបរឹតឲ្យត្រង់ ក៏មិនលះបង់ចុងស្មើតទៅលើដូចប្រក្រតីវាឡើយ ។

១៣៨- ធម្មតាកន្ទុយឆ្កែ ទោះជាគេកែយកប្រេងលាប យកខ្សែចង យកសំពត់រុំចងទុកអស់១២ ឆ្នាំ ក៏ឥតអំពើ កាលណាគេស្រាយចំណងចេញ ក៏ត្រឡប់កងកន្ទុយងក្ងក់ឡើងវិញដូចប្រក្រតីដើម ។

១៣៩- ការបណ្តុះបណ្តាលឲ្យចម្រើន ឬការរាប់អានលើកតម្កើងឲ្យប្រសើរ នឹងអាចញ៉ាំងមនុស្សខិលខូចចិត្តអាក្រក់ ឲ្យត្រេកអរពេញចិត្តដូចម្តេចកើត? ដូចដើមឈើមានពិសពុល សូម្បីយកទឹកអម្រឹតទៅស្រោចស្រព ក៏មិនអាចត្រឡប់ចេញផ្លែគួរជាទីប្រាថ្នាបានដូច្នោះដែរ ។

ព្រោះហេតុនោះ បានជាខ្ញុំបាទនិយាយថា៖

១៤០- នរជនមិនចង់ឲ្យកល្យាណមិត្តណាបានក្តីវិនាស សូម្បីកល្យាណមិត្តនោះមិនសាកសួរមុន ក៏គួរគប្បីប្រាប់ឧបាយឲ្យកើតប្រយោជន៍ដែរ នេះជាធម៌នៃលោកសប្បុរសទាំងឡាយ, បើពុំនោះទេ នរជននោះនឹងធ្លាក់ក្នុងគតិនៃជនមានមតិថោកទាប (សេចក្តីដូចលេខ ១២៤) ។

១៤១- នរជនណាឃាត់ហាមមិនឲ្យធ្វើអំពើអកុសល នរជននោះឈ្មោះថាជាមិត្តនាំឲ្យរឹតតែរុងរឿង, កម្មណាប្រាសចាកមន្ទិល គឺពាក្យតិះដៀល កម្មនោះឈ្មោះថាជាកម្មបរិសុទ្ធប្រពៃ, ស្រីណាប្រព្រឹត្តតាមឆន្ទៈស្វាមី ស្រីនោះឈ្មោះថាជាភរិយា, នរជនណាមានសប្បុរសទាំងឡាយគោរពបូជាសរសើរ នរជននោះ ឈ្មោះថាជាបណ្ឌិត, ធម្មជាតិណាមិនឲ្យស្រវឹងសៅហ្មង ធម្មជាតិនោះ ឈ្មោះថាជាសិរី, នរជនណារួចពីខ្ញុំតណ្ហា នរជននោះឈ្មោះថាជាបុគ្គលមានសេចក្តីសុខ, នរជនណា ស្មោះត្រង់តាមប្រក្រតី នរជននោះឈ្មោះថាជាមិត្ត, នរជនណាទូន្មានឥន្ទ្រិយបាន នរជននោះឈ្មោះថាជាបុរស ។

រឿងនេះ ថាបើលោកម្ចាស់មិនព្រមត្រឡប់ស្មារតី បណ្តោយឲ្យ**សញ្ជីវកៈ**ធ្វើគុតឲ្យរលត់ផុតជីវិតវិនាសទាំងដែលទ្រង់បានជ្រាបរួចហើយ កំហុសដូច្នេះមិនមែនជាទោសអាមាត្យមុខមន្ត្រីខ្ញុំបម្រើទេ, ព្រោះថា៖

១៤២- ព្រះនរបតី ជាប់ព្រះទ័យស្អិតក្នុងកាម មិនគយគន់មើលកិច្ចរាជការ និងផលប្រយោជន៍ប្រទេសជាតិ ប្រព្រឹត្តធ្វើតាមតែទំនើងព្រះទ័យ ស្រវឹងពន់ពេកក្រៃដូចដំរីចុះប្រេង កាលតមក ទ្រង់កើតមានៈ ក្សត្រគ្របសង្កត់ធ្លាក់ព្រះអង្គទៅក្នុងជ្រោះជ្រៅ គឺសេចក្តីសោកសល្យហើយ, ទ្រង់តែងដាក់ទោសទម្លាក់ខុសមកលើអាមាត្យមុខមន្ត្រី មិនបាននឹកនាដល់ទោសពៃរ៍កំហុសកន្លងវិន័យព្រះអង្គឡើយ" ។

**បិង្គលកៈ**នឹកតែក្នុងចិត្តថា៖

១៤៣- ព្រះរាជាមិនត្រូវដាក់ទណ្ឌកម្មដល់ជនដទៃៗ ដោយអាងយកតែពាក្យពោលបង្កុសនៃជន

ឯទៀតឡើយ, គួរគប្បីសាកសួរឲ្យឃើញទោសប្រត្យក្សដោយខ្លួនសិន សឹមត្រូវចាប់ចងដាក់ទោស ឬពុំនោះត្រូវបូជា ។

១៤៤- នរជន មិនបានពិចារណាគុណ និងទោសឲ្យឃើញម៉ត់ចត់តាមវិធីមុនសិនទេ មិនគួរអាណិតលើកលែង ឬដាក់ទោសទណ្ឌទេ ដូចការមើលងាយយកដៃលូកទៅក្នុងមាត់ពស់ ឈ្មោះថាយកក្ដីវិនាសមកឲ្យខ្លួនឯងពិតឥតសង្ស័យឡើយ ។

នឹកឃើញដូច្នេះហើយ ទើប**បិង្គលកៈ**ប្រកាសខ្លាំងៗថា៖ "បើដូច្នោះ ត្រូវហៅ**សញ្ជីវកៈ**ឲ្យចូលមកនឹងប្រាប់ឲ្យដឹងខ្លួនឬអ្វី?" ។ ចចក**ទមនកៈ** ឆ្លើយតបដោយប្រញាប់ថា៖ "ទេ! ទេ! មិនបានទេ! ធ្វើដូច្នេះនាំឲ្យគេឯងដឹងឮច្រើន បែកការសម្ងាត់អស់ហើយ ព្រោះលោកថា៖

១៤៥- ពូជគឺការសម្ងាត់នេះ សូម្បីតែបន្តិច បុគ្គលគប្បីលាក់ទុកដោយប្រពៃ គប្បីរក្សាទុកដោយម៉ឺងម៉ាត់តាមដែលនឹងអាចម៉ឺងម៉ាត់បាន បុគ្គលត្រូវប្រយ័ត្នកុំឲ្យបែកការឡើយ, ការសម្ងាត់នោះ បើបែកធ្លាយហើយ មិនដុះដាលបានផលសម្រេចទេ ។

១៤៦- ការងារ ដែលត្រូវចាប់ធ្វើ ឬដែលត្រូវបង្គាប់គេ ឬដែលត្រូវធ្វើខ្លួនឯង បើបុគ្គលមិនគប្បីប្រញាប់ប្រញាល់ធ្វើឲ្យបានរួសរាន់ទាន់ពេលទេ កាលវេលា នឹងជញ្ជក់ក្រេបផឹកស៊ីរសជាតិការងារនោះអស់រលីង ។

ព្រោះហេតុនោះ, ការងារអ្វីមួយ ដែលនរជនប្រារព្ធធ្វើហើយ ត្រូវតែចាត់ការភ្លាមៗ ដោយការប្រយ័ត្នម៉ឺងម៉ាត់ ដែលអាចនឹងប្រយ័ត្នបាន, ព្រោះថា៖

១៤៧- ការសម្ងាត់ ដូចទាហានមិនមានទឹកចិត្តមាំមួន សូម្បីមានគ្រឿងក្រោះការពារសព៌ាង្គកាយបរិបូណ៌ហើយ ក៏មិនអាចធន់ទ្រាំស្ថិតនៅក្នុងកន្លែងអស់កាលយូរបាន ព្រោះក្ដីរង្កៀសខ្លាចក្រែងអាចឲ្យសត្រូវតយុទ្ធទម្លាយបាន ។

បើទុកជា**សញ្ជីវកៈ**នេះមើលឃើញទោសកំហុសខ្លួន ហើយចូលមកលោកម្ចាស់សូមឲ្យលោះលាត្រាប្រណីទោស ក៏មិនគួរគប្បីសម្ដែងមេត្រីយកជាមិត្តតទៅមុខទៀតដែរ, ព្រោះថា៖

១៤៨- នរជនណាចង់ចងសម្ព័ន្ធមេត្រីម្ដងទៀត ចំពោះមិត្តដែលបានប្រទូស្តរួចម្ដងហើយ នរជននោះឯង ឈ្មោះថាទៅកាន់យកម្រឹត្យុតែម្ដង ដូចមេសេះ ពផ្ទៃសេះអស្សតរដូច្នោះឯង" ។

សីហៈនិយាយដោយក្លាហានថា៖ "យើងចង់ដឹងដែរ, តើ**សញ្ជីវកៈ**នេះវាអាចប៉ានធ្វើគុតដណ្ដើមរាជ្យយើងម្ដ៉ាទៅ" ។ ចចក**ទមនកៈ**ឆ្លើយតបទៅវិញថា៖

១៤៩- នរជន មិនដឹងភារៈនៃការទាក់ទងនឹងជនដទៃហើយ មិនត្រូវគ្នេរចុះមតិសម្គាល់សមត្ថ

ភាព គេថាដូចម្ដេចឡើយ, ចូរមើល! សមុទ្រក៏ចាលចាញ់តេជដៃ សព្វបើត្រដេវវិចដែរ ។

សីហៈសួរថា: "ចុះរឿងនោះតើដូចម្ដេច?" ។ ចចក**ទមនកៈ**និយាយរឿងដូចតទៅនេះថា៖

# កថាទី១០

## រឿងត្រដេវវិចញីឈ្មោល និងសមុទ្រ

លើត្រើយសមុទ្រទក្ខិណាមានត្រដេវវិចញីឈ្មោលអាស្រ័យនៅ ។ កាលដល់ពេលពង ត្រដេវវិចញីនិយាយទៅកាន់ត្រដេវវិចឈ្មោលថា៖ "អ្នកបងជាទីពឹង! ខ្ញុំជិតពងហើយ, សូមអ្នកបងរៀបចំកាច់សំបុកទុកពងក្នុងទីដទៃឲ្យបានសុខស្រួលជាងទីនេះ" ។ ត្រដេវវិចឈ្មោលសួរតបទៅវិញថា៖ "ហៃអូន! ទីនេះ មិនសមគួរនឹងពងឬអ្វី?" ។ ត្រដេវវិចញីឆ្លើយប្រាប់ថា៖ "ទីនេះប្រកបដោយភ័យធំ រលកសមុទ្រអាចបោកមកផាត់យកពងយើងទៅបាន" ។ ត្រដេវវិចឈ្មោលនិយាយដោយការមើលងាយថា៖ "យី! អីបងឥតកម្លាំងតស៊ូបណ្ដោយឲ្យរលកសមុទ្របោកយកពងទៅបាន?" ។ ត្រដេវវិចញីអស់សំណើច សើចហើយឆ្លើយតបថា៖ "នែអ្នកស្វាមី! ចុះអ្នកបងនឹងសមុទ្រ អ្នកណាធំជាងអ្នកណា?, ព្រោះថា៖

១៥០- នរជនណាដឹងច្បាស់ថា គួរ ឬមិនគួរប្រកប ដើម្បីកម្ចាត់បង់នូវសេចក្ដីវិនាស, នរជននោះកាលដឹងថា "ទីនេះមានអន្តរាយ" ដូច្នេះហើយ មិនលិចលង់ផុងគំនិតនាំឲ្យវិនាស ក្នុងគ្រាក្រទុក្ខលំបាកឡើយ ។

១៥១- ការប្រារព្ធធ្វើការងារដែលមិនគួរធ្វើ ១, ការទាស់ទែងខ្វែងគំនិតបងប្អូនឯង ១, ការប្រណាំងប្រជែងតស៊ូអ្នកមានកម្លាំងជាង ១, ការទុកចិត្តក្នុងស្ត្រីទាំងឡាយ ១, ទាំង៤ ប្រការនេះឈ្មោះថាបើកទ្វារឲ្យដល់ម្រឹត្យុទាំងរស់" ។

កាលនោះឯង, ត្រដេវវិចញី ប្រកែកមិនឈ្នះត្រដេវវិចឈ្មោលក៏ព្រមពងនៅលើឆ្នេរសមុទ្រនោះទាំងសេចក្ដីទុក្ខព្រួយ ។ កាលដែលបក្សីញីឈ្មោលនិយាយជជែកគ្នា សមុទ្របានស្ដាប់អស់អាថ៌សេចក្ដីពីដើមដល់ចុង ក៏ចង់ដឹងសក្ដានុពលភាពសត្វញីឈ្មោលនោះ ទើបផាត់រលកធំៗមកបោកយកពងអស់ទៅ ។ លំដាប់នោះ ត្រដេវវិចញីកើតទុក្ខសោកសៅ ទង្គឹះខ្សឹកខ្សួលក្ដួលក្ដៅចិត្ត យំបណ្ដើរនិយាយប្រាប់ស្វាមីបណ្ដើរថា៖ "នែអ្នកបងជាទីពឹង! ម៉េចមិនជឿពាក្យខ្ញុំ ឥឡូវនេះក្ដីទុក្ខធ្លាក់មកដល់យើងហើយ, ពងវិនាសអន្តរធានបាត់អស់រលីង" ។ ត្រដេវវិចឈ្មោលឆ្លើយតបដោយអួតអាងថា៖ "ប្អូនអើយ! ប្អូនកុំភ័យបារម្ភថ្វី ទុកងារឲ្យបងចុះ" និយាយដូច្នេះហើយស្រែកកញ្ជៀវខ្ញៀវខ្ញាហាហៅហ្វូងបក្សីទាំងឡាយឲ្យចូលមកប្រជុំផ្ដុំគ្នាបានស្រេចកាលណា ក៏ហិចហើរទៅកាន់សំណាក់គ្រុឌជាស្ដេចបក្សី ។ លុះទៅដល់

ទីឋានគ្រុឌហើយ, ត្រដេវវិចឈ្មោលនិយាយរៀបរាប់ព្រឹត្តិការណ៍ទាំងអស់ប្ដឹងគ្រុឌបក្សាដ៏មានបុណ្យ ដែលជាស្ដេចគ្រប់គ្រងរក្សាពពួកបក្សី ឲ្យបានដឹងសេចក្ដីសព្វគ្រប់ប្រការថា៖ "ទេវ! ខ្ញុំបាទបានតាំងទីឋានកាច់សំបុកទុកពងអាស្រ័យនៅនាឆ្នេរសមុទ្រ មិនបានប្រព្រឹត្តឆ្គាំឆ្គងឲ្យខុសគន្លងធម៌ទេ ឥឡូវសមុទ្រកំណាចចង្រៃនេះផាត់រលកមកបោកយកពងខ្ញុំបាទទៅអស់រលីង ខ្ញុំបាទកើតទុក្ខពុំសុខចិត្ត ទើបចូលមកក្រាបប្រណិប័តន៍ជម្រាបព្រះបាទម្ចាស់ឲ្យជ្រាប" ។ កាលនោះ, គ្រុឌស្ដេចបក្សី បានស្ដាប់សម្ដីត្រដេវវិចប្ដឹងដូច្នោះហើយ ចូលទៅក្រាបបង្គំព្រះនារាយណ៍បរមឥស្វរដ៏ជាកំពូល អ្នកដ៏មានបុណ្យចេស្ដាជាអ្នកកសាងលោក ជាអ្នកគ្រប់គ្រងលោក និងជាអ្នកប្រល័យលាញលោក ឲ្យទ្រង់ជ្រាបតាមដំណើរសេចក្ដី ។ ព្រះនារាយណ៍កាត់សេចក្ដីឲ្យសមុទ្រយកពងមកសងត្រដេវវិចញីឈ្មោលវិញ ។ គ្រុឌស្ដេចបក្សីទទួលទេវឱង្ការតម្កល់លើត្បូងទុកជាទីគោរពហើយត្រឡប់វិលមកវិញ មកបង្គាប់សមុទ្រឲ្យយកពងទៅប្រគល់ឲ្យបក្សីញីឈ្មោលក្នុងកាលនោះឯងហោង ។ ព្រោះហេតុនោះឯងបានជាខ្ញុំបាទ (ចចក **ទមនកៈ**) ជម្រាបថា៖ "នរជន មិនដឹងភារៈនៃការទាក់ទងជនដទៃហើយ" ដូច្នេះជាដើម (លេខ ១៤៩) ។

សីហ**បិង្គលកៈ** សួរបញ្ជាក់ថា៖ "ធ្វើម្ដេច យើងគប្បីដឹងបានថា**សញ្ជីវកៈ**មានគំនិតក្បត់យើង?" ចចក**ទមនកៈ**និយាយដំណើរទំនងប្រាប់ថា៖ "**សញ្ជីវកៈ**នេះជាសត្វព្រហើនណាស់ កាលណាវាចូលមកទេវបាទម្ចាស់ វាសម្ដែងអាការធ្វើហាក់ជាគោរពកោតក្រែង ហើយបង្ហាញស្នែងតម្រង់ទៅមុខ កាលនោះទេវបាទម្ចាស់គង់ជ្រាបមិនខាន" ។ ចចកនិយាយហើយដើររលះរលាំងចូលទៅរក**សញ្ជីវកៈ** បង្ហាញឲ្យ**សញ្ជីវកៈ**មើលឃើញខ្លួន ធ្វើទឹកមុខស្រងូតហាក់ជាមានភ័យធំខ្លាំងណាស់ ។ ឯគោ**សញ្ជីវកៈ**មើលឃើញចចក ត្រេកអរសាទរណាស់ សួរថៅរ៉ៅទៅថា៖ "ហៃបងចចកដ៏ចម្រើនអើយ! មានការអ្វីរលះរលាំងដូច្នេះ ឬមួយសុខសប្បាយជាទេហ៎ះ?" ។ **ទមនកៈ**ឆ្លើយដោយឧបាយថា៖ "ឱលោកអើយ! ធម្មតាធ្វើជាខ្ញុំបម្រើរាជការផែនទឹក ផែនដី រកក្ដីសុខសប្បាយមកពីណា, ព្រោះថា៖

១៥២- នរជនណាធ្វើជារាជសេវកាមាត្យ នរជននោះ ត្រូវតែពឹងសម្បត្តិដែលនៅក្នុងអំណាចនៃជនដទៃ មានចិត្តមិនដែលបានស្ងប់ក្សេមក្សាន្តល្ហែល្ហើយទេ ព្រមទាំងមិនទុកចិត្តក្នុងជីវិតខ្លួនថែមទៀតផង ។

១៥៣- នរណាបានទ្រព្យសម្បត្តិហើយ មិនឡើងចាង? នរណាលុះក្នុងអំណាចវិស័យខ្លួនហើយអាចរំលត់ក្ដីទុក្ខទោសអន្តរាយបាន? លើផែនដី នរណាមានចិត្តរឹងមិនធ្លោយខ្លួនដួលព្រោះស្ត្រី? មួយទៀត, នរណាជាទីស្រឡាញ់នៃព្រះរាជា? ក្នុងលោកនេះ នរណាមានអំណាចខ្លាំង មិនចូលទៅក្នុងកណ្ដាប់ដៃនៃព្រះកាល? នរណាជាអ្នកសូមទាន ហើយបានដល់ក្ដីគោរពដ៏ខ្ពង់ខ្ពស់? មួយវិញទៀត,

នរណា ដែលធ្លាក់ខ្លួនទៅក្នុងអន្ទាក់នៃទុជ៌ន ហើយបានត្រឡប់ជាបុរសបរិបូណ៌ដោយក្ដីក្សេមក្សាន្ដ?" ។

**សញ្ជីវកៈ**សួរដោយក្ដីងឿងឆ្ងល់ថា៖ "បងសម្លាញ់អើយ! បងនិយាយនេះ តើចង់ថាដូចម្ដេច?" ។ ចចក**ទមនកៈ**ឆ្លើយប្រាប់ថា៖ "ចុះឲ្យខ្ញុំជាបុគ្គលមានបុណ្យតិចសក្ដិតូចប្រាប់ដូចម្ដេចទៅទៀត, ចូរមើល! លោកថា៖

១៥៤- ខ្លួនខ្ញុំនេះដូចជាបុគ្គលលិចលង់ក្នុងមហាសមុទ្រ មានតែពស់កាចសម្រាប់តោង នឹងលែងក៏មិនកើត នឹងប្រតោងកាន់ពស់ទៅទៀតក៏មិនកើត, ពេលនេះ លំបាកចិត្តខ្វល់គំនិតខូចអស់ហើយដូចអ្នកតោងពស់ច្នោះឯង ។

១៥៥- មួយចំណែក ក្ដីស្និទ្ធស្នាលចំពោះព្រះរាជា វិនាសអស់ហើយ, មួយចំណែកទៀត ក្ដីស្និទ្ធស្នាលចំពោះពួកញាតិសន្ដាន ក៏វិនាសដែរ, ឲ្យរូបខ្ញុំធ្វើដូចម្ដេច? ឲ្យរូបខ្ញុំទៅឯណា? ខ្លួនខ្ញុំដូចជាធ្លាក់ក្នុងកណ្ដាលសមុទ្រសាគរគឺក្ដីទុក្ខស្រេចទៅហើយ ។

ចចកនិយាយបណ្ដើរដង្ហើមធំឃ្លូវវែងៗបណ្ដើរ ហើយអង្គុយធ្វើមុខក្រៀមផ្អែះ ។ **សញ្ជីវកៈ**អង្វរករសួរថា៖ "បងសម្លាញ់! ចូរបងប្រាប់ឲ្យជាក់លាក់មកមើល! ក្នុងចិត្តបងតើមានគិតធ្វើអ្វីខ្លះ?" ។ ចចកធ្វើអាការហាក់ដូចតូចចិត្តណាស់ ឱនទៅជិតត្រចៀកហើយនិយាយខ្សឹបបន្តិចៗប្រាប់គោថា៖ "មែនពិត, បើតាមក្ដីស្និទ្ធស្នាលចំពោះព្រះរាជា ខ្ញុំមិនគួរយករឿងអាថ៌កំបាំងព្រះអង្គមកនិយាយបរិហារឲ្យគេឯងដឹងឮទេ, តែដូចរូបបង ខ្ញុំនឹងលាក់លៀមមិនកើត ព្រោះបងបាននៅក្នុងទីនេះក៏ដោយសារខ្លួនខ្ញុំនាំមកដែរ, ឯខ្ញុំក៏ចង់បានអានិសង្សទៅកើតក្នុងឋានសួគ៌គួរតែស្រាយអាថ៌កំបាំងជាប្រយោជន៍ប្រាប់ឲ្យដឹងមុន, សូមបងស្ដាប់មើល! ម្ចាស់យើងប្រែចិត្តចេញពីបងហើយ បាននិយាយរហស្សការប្រាប់ខ្ញុំដោយសម្ងាត់ថា៖ "អញបម្រុងនឹងសម្លាប់**សញ្ជីវកៈ**យកសាច់ស៊ីនឹងចែកចាយលៀងបរិវារឲ្យស៊ីចម្អែតផ្ទៃហើយ" ។ **សញ្ជីវកៈ**បានស្ដាប់ពាក្យនេះហើយ ធ្លាក់ទឹកមុខជ្រុបតូចចិត្តក្រៀមក្រំដំឱរា ។ ចចកធ្វើជាល្បួងលោមនិយាយរំឮកថា៖ "ណ្ហើយបងសម្លាញ់! កុំកើតទុក្ខតូចចិត្តធ្វើអ្វី ធ្វើម្ដេចសំណាងយើង, ត្រូវតែត្រិះរិះពិចារណារកឧបាយកែខៃតាមការគួរ កាលបើមានគ្រោះកាចចង្រៃធ្លាក់មកដល់" ។ គោ**សញ្ជីវកៈ**ត្រិះរិះមើលមួយស្របក់ហើយ យល់សេចក្ដីផ្សេងតែម្នាក់ឯងថា៖ "កិច្ចការដូច្នេះក៏អាចកើតមានដែរ, តែពាក្យនេះទំនងជាអាកប្បកិរិយាចចកទុជ៌ន ឬមិនមែនទេដឹង? ដំណើរនេះ, នរណាក៏មិនគប្បីអាចនឹងយល់សេចក្ដីចំពោះអំពើដូច្នោះបានឡើយ, ព្រោះថា៖

១៥៦- ដោយច្រើន នារីទាំងឡាយតែងចូលចិត្តសេពគប់ទុជ៌ន, ព្រះរាជាតែងសព្វព្រះទ័យអាមាត្យមិនមានគុណសម្បត្តិ, ទ្រព្យសម្បត្តិតែងហូរទៅរកតែជនកំណាញ់ ឯភ្លៀងតែងបង្អុរចុះតែលើភ្នំ និងមហា

សមុទ្រ ។

១៥៧- ([១]) ជនអសប្បុរស តែងទទួលរស្មីសោភាដែលផ្សាយចេញពីគុណសម្បត្តិនៃអភិជនដែលខ្លួនអាស្រ័យនៅ ដូចអញ្ជនៈ ([២]) ខ្មៅក្រខ្វក់ពីកំណើត កាលបើទៅស្ថិតលើរោមចិញ្ចើមនៃស្ត្រីល្អហើយ ក៏ត្រឡប់ជារបស់រុងរឿង" ។

គោ**សញ្ជីវកៈ**ត្រិះរិះគិតមើលសាចុះសាឡើងមួយស្របក់ហើយពោលថា៖ "អនិច្ចាឱកម្មអាក្រក់ចង្រៃ! ចុះហេតុដែលនាំឲ្យវិបត្តិនេះកើតមកពីណាអេះ? ព្រោះថា៖

១៥៨- ព្រះនរបតី សូម្បីអាមាត្យប្រតិបត្តិការដោយប្រយ័ត្នប្រយែងដ៏ក្រៃលែង ក៏មិនសព្វព្រះទ័យត្រេកអរប៉ុន្មាន, តែរឿងនេះនឹងទុកថាប្លែកដូចម្ដេចកើត? ឯអាមាត្យណានីមួយដែលគោរពភក្ដីដោយល្អហើយក៏ត្រឡប់បានភាពជាសត្រូវវិញ នេះទើបហៅថាប្លែកអស្ចារ្យមែន ។

ដំណើរនេះ, នរជនណាមួយក៏មិនគប្បីអាចយល់សេចក្ដីបានងាយទេ ព្រោះថា៖

១៥៩- មែនពិត, នរជនណា កាន់យកហេតុណាមួយជានិមិត្តហើយទើបក្រេវក្រោធ នរជននោះកាលបើកម្ចាត់បង់ហេតុនោះបានហើយនឹងបាត់ក្រេវក្រោធហើយកើតក្ដីជ្រះថ្លាភ្លាម, បើចិត្តនរជនណាក្រេវក្រោធស្អប់ដោយមិនមានហេតុ ធ្វើដូចម្ដេចហ្ន៎ នឹងញ៉ាំងចិត្តនរជននោះឲ្យស្ងប់ហើយឲ្យត្រេកអរបាន? ។

អាត្មាអញធ្វើអំពើអ្វីខ្លះក្បត់ព្រះរាជា? ឬមួយ ព្រះរាជាទ្រង់ក្រេវក្រោធដោយព្រះទ័យអាក្រក់ប្រាសចាកហេតុផល?" ។ ចចក**ទមនកៈ**ឆ្លើយស្របតបវិញថា៖ "អើ! រឿងនេះ ក៏អាចកើតមានយ៉ាងនោះបានដែរ, ចូរបងស្ដាប់សុភាសិតនេះតទៅ៖

១៦០- អាមាត្យខ្លះ ជាអ្នកប្រាជ្ញា ជាអ្នកស្វាមីភក្ដិស្និទ្ធស្នេហាធ្វើឧត្តមប្រយោជន៍ចំពោះព្រះរាជាពិតៗ ត្រឡប់ជាបានក្ដីស្អប់ខ្ពើមវិញក៏មាន, អាមាត្យខ្លះទៀត ក្បត់ព្រះរាជាដោយប្រត្យក្សលាំងៗ ត្រឡប់ជាបានមេត្រីទៅវិញក៏មាន, ឱចរិតនៃព្រះរាជាជាទីជ្រកកោននៃជននេះប្លែកអស្ចារ្យ ប្លែកអស្ចារ្យច្រើនប្រការអ្វីម្ល៉េះហ្ន៎! សេវាធម៌ (នាទីនៃអាមាត្យ) នេះ មានប្រស្នារញ៉ិករញ៉ុកសាំញ៉ាំស្មុគស្មាញណាស់ សូម្បីព្រះយោគីមានឫទ្ធិ ក៏មិនអាចប្រតិបត្តិឲ្យល្អបរិបូណ៌បានឡើយ ។

---

[១] ហិតោបទេស សេចក្ដីប្រែជាភាសាបារាំងនៃលោកឡង់សឺរ៉ូ និងជាភាសាសៀមនៃលោកនាគប្រទីបមានគាថាលើសដូច្នេះគឺ ព្រះលក្ស្មីតែងប្រទានកិត្តិយសចំពោះតែជនថោកទាប ព្រះសូរស្វស្ដីតែងប្រោសប្រាណចំពោះតែជនសក្តិតូច, នារីតែងស្រឡាញ់ពេញចិត្តចំពោះតែទុជ៌ន ឯព្រះឥន្ទ (ម្ចាស់ភ្លៀង) តែងបង្អុរភ្លៀងតែលើកំពូលភ្នំ ។

[២] ជ័រពណ៌ខ្មៅ សម្រាប់លាបរោមចិញ្ចើមឲ្យខ្មៅរលោងស្រិល ។

១៦១- ធ្វើគុណដល់អសប្បុរស ១០០ ដង មិនបានផល, និយាយពាក្យសុភាសិតដល់មនុស្សល្ងង់ ១០០ ដង ឥតប្រយោជន៍ ប្រើឧបាយប្រាជ្ញា ១០០ ដង ចំពោះជនឥតការត្រិះរិះពិចារណា ក៏មិនបានការ ។

១៦២- នៅលើដើមចន្ទន៍ មានពស់, នៅក្នុងត្រពាំងដែលដេរដាសដោយផ្កាឈូក មានក្រពើ, នៅក្នុងភោគទ្រព្យ មានជនពាលជាអ្នករុកកួនឈ្នានីស, ក្នុងលោកនេះ សេចក្ដីសុខ ប្រាសចាកការថ្នាំងថ្នាក់ចិត្តមិនដែលមានសោះឡើយ ។

១៦៣- នៅគល់ដើមចន្ទន៍ មានអាសិរពិស, នៅផ្កាចន្ទន៍ មានមេឃ្មុំកាច, នៅមែកចន្ទន៍ មានពានរ, នៅចុងដើមចន្ទន៍ មានខ្លាឃ្មុំ ដូច្នេះនៅដើមចន្ទន៍ទាំងមូល ឥតមានផ្នែកត្រង់ណាដែលមិនមានសត្រូវចង្រៃអាក្រក់អាស្រ័យនៅទេ ។

ស្ដេចយើង ខ្ញុំស្គាល់លក្ខណៈគ្រប់, ព្រះបន្ទូលពីរោះផ្អែមដូចទឹកឃ្មុំ តែព្រះទ័យពេញពោរដោយពិសពុល, ព្រោះថា៖

១៦៤- ហុចដៃបក់ហៅពីចម្ងាយ, ភ្នែកក្រឡេកមើលដោយអាការស្រឡាញ់ពេញចិត្ត, ហៅឲ្យអង្គុយអាសនៈរួមជាមួយពាក់កណ្ដាលម្នាក់, លូកដៃទៅត្រកងឱបដោយក្ដីស្នេហា, សម្ដែងការអើពើថៅរៅសាកសួរដោយវាចាជាទីស្រឡាញ់ពេញចិត្ត, តែខាងក្នុងចិត្ត ពេញដោយពិសពុល, ខាងក្រៅ ទឹកសម្ដីផ្អែមដូចទឹកឃ្មុំ, ស្ទាត់ជំនាញក្នុងកលោបាយ, ឱនាដកវិធី ([១]) បែបថ្មីអ្វីនេះ ពួកទុជ៌នសិក្សាយកមកប្រើជាល្បែងបានហ្ន៎? ។

១៦៥- សំពៅ គេសាងសម្រាប់ឆ្លងសមុទ្រសាគរ ដែលគេឆ្លងបានដោយក្រ, ប្រទីប គេសាងសម្រាប់អុជទ្រោលបំភ្លឺ ក្នុងពេលងងឹតអន្ធការ, វីជនី គេធ្វើសម្រាប់បក់ក្នុងពេលមិនមានខ្យល់, កង្វេរ គេធ្វើសម្រាប់ហ្វឹកហ្វឺនដំរីកាចទ្រនង់ងងឹតមុខដោយចុះប្រេង, ដូច្នេះ នៅលើភពគោលនេះ មានរបស់អ្វីមួយដែលព្រះអ្នកកសាងលោកមិនបានកសាងទុកឲ្យជាឧបាយចិន្ដា ([២]) ខ្ញុំជឿជាក់ច្បាស់ថា សូម្បីព្រះព្រហ្មដែលបង្កើតលោក ក៏ទម្លាក់កម្លាំងព្យាយាមចោល ក្នុងការទូន្មានប្រៀនប្រដៅសន្ដានមនុស្សទុជ៌ន” ។

គោ**សញ្ជីវកៈ**ព្រួយបារម្ភតានតឹងក្នុងចិត្តស្ទើរប្រេះទ្រូង ដកដង្ហើមធំយូរៗវែងៗ គិតថា៖ “ឱកម្មអាត្មាអញអើយ អ្វីក៏អាក្រក់ម្ល៉េះហ្ន៎? អាត្មាអញស៊ីតែសន្ទូងជាភក្សាហារ ហេតុអ្វីក៏លោកមកចោទប្រកាន់ ហើយប្រាថ្នាសម្លាប់ចោលបង់សៀតដូច្នេះហ្ន៎? ព្រោះថា៖

---

[១] វិធីអ្នករាំ កិច្ចកលឧបាយអ្នករាំ ។

[២] ឧបាយខាងផ្លូវគំនិតត្រិះរិះពិចារណានាំឲ្យយល់សេចក្ដី ឬឲ្យយល់កិច្ចការផងទាំងពួងឥតចន្លោះ ។

១៦៦- ជនពីរផ្នែកណាមានទ្រព្យស្មើគ្នា មានកម្លាំងស្មើគ្នា ជនពីរផ្នែកនោះ ទើបវិវាទច្បាំងគ្នាបាន ចុះបើមួយផ្នែកមានអំណាចខ្ពង់ខ្ពស់ មួយផ្នែកទៀតថោកទាបឥតអំណាចសោះ តើគួរនឹងនាំឲ្យកើតវិវាទច្បាំងគ្នាបានខ្លះទេឬ? ។

**សញ្ជីវកៈ**សញ្ជឹងគិតហើយគិតទៀត៖ "នរណាហ្ន៎ ញុះញង់ស្ដេច**បិង្គលកៈ**ឲ្យក្រេវក្រោធ ហើយឲ្យគុំគួនរករឿងប៉ងសម្លាប់អាត្មាអញដូច្នេះ? អាត្មាអញគិតពុំយល់ហេតុនេះសោះ ។ បើលោកម្ចាស់ក្រេវក្រោធ ហើយប្រាថ្នានឹងបំផ្លិចបំផ្លាញអាត្មាអញមែន រឿងនេះគួរភិតភ័យជានិច្ចមែន, ព្រោះថា៖

១៦៧- កាលណាក៏ដោយ ព្រះទ័យព្រះភូមិបាល ដែលមន្ត្រីព្រះអង្គបំបែកឲ្យបែកហើយ តវិញមិនជាប់ទេ ដូចកងដៃជាវិការៈនៃកែវផលិតដែលជនឲ្យបែកហើយ ជនណាហ្ន៎ មានអំណាចអាចតឲ្យជាប់ដូចដើមវិញបាន? ។

១៦៨- ហេតុដែលគួរភ័យខ្លាចមាន២ប្រការគឺ៖ អសនីបាត និងតេជានុភាពព្រះរាជា តែអសនីបាត ធ្លាក់តែមួយកន្លែង ឯតេជានុភាពព្រះរាជាធ្លាក់នៅជុំវិញខ្លួនយើង ។

ក្នុងករណីបែបនេះ ថាបើត្រូវស្លាប់ ស្លាប់ក្នុងសង្គ្រាមប្រសើរជាជាង, ឥឡូវនេះ មកស្លាប់ដោយប្រើអាជ្ញាយ៉ាងនេះមិនល្អមើលសោះ, ព្រោះថា៖

១៦៩- ស្លាប់ហើយបានទៅកើតក្នុងឋានសួគ៌ ១, សម្លាប់សត្រូវហើយបានក្ដីសុខ ១, ធម៌២ប្រការនេះឯង ជាធម៌មានគុណប្រសើរបំផុត គេធ្វើបានដោយក្រក្រៃលែង មានតែបុរសមានចិត្តក្លៀវក្លាទាំងឡាយទេ ទើបអាចធ្វើបាន ។

ពេលនេះ ជាកាលតយុទ្ធគ្នាទៅហើយ នឹងដកថយវិញក៏មិនកើត ។

១៧០- ក្នុងកាលណា បើមិនច្បាំងក៏ទៀងតែស្លាប់, បើច្បាំងមានផ្លូវរួចជីវិតបាន ក្នុងកាលនោះ ពួកអ្នកប្រាជ្ញតែងសម្រេចសេចក្ដីថា "ត្រូវច្បាំងតយុទ្ធពិតប្រាកដ" ។

១៧១- ថាបើ, ក្នុងកាលណា អ្នកប្រាជ្ញមើលមិនឃើញផ្លូវអ្វីមួយដទៃក្រៅពីការច្បាំងតយុទ្ធទេ ក្នុងកាលនោះ លោកយល់ថាត្រូវតែធ្វើសង្គ្រាមស៊ូស្លាប់ក្នុងដៃសត្រូវ ។

១៧២- បើមានជ័យ ត្រូវបានទ្រព្យសម្បត្តិ, បើបែរជាស្លាប់វិញ ក៏ត្រូវបានជាភស្ដាស្រីទេពអប្សរបវរកញ្ញា, កាយយើងនេះជារបស់ត្រូវបែកធ្លាយទៅក្នុងមួយខណៈ ហេតុអ្វីក៏គិតញញើតញញើមមិនហ៊ានស្លាប់ក្នុងរណរង្គ?" ។

គោ**សញ្ជីវកៈ**គិតយ៉ាងនេះរួចហើយ បែរទៅនិយាយប្រាប់ចចកថា៖ "នែសម្លាញ់! ធ្វើដូចម្ដេចនឹងដឹងថា **បិង្គលកៈ**នេះចង់សម្លាប់ខ្ញុំ" ។ ចចក**ទមនកៈ**ឆ្លើយប្រាប់ថា៖ "កាលណា**បិង្គលកៈ**នេះចងចិញ្ចើមមាំ

សម្លឹងមើលបងឯងដោយភ្នែកដ៏មុត កងកន្ទុយផ្អែត លាក់ក្រញ៉ាំក្រចក ហាមាត់បញ្ចេញចង្កូមគួរស្ញើម កាលនោះបងត្រូវសម្តែងក្តីអង់អាចហៅប៉ានតស៊ូសីហៈវិញ ព្រោះថា៖

១៧៣- នរជន សូម្បីមានកម្លាំង តែឥតតេជៈ បើដូច្នេះ ម្តេចក៏មិនមានទំនងឲ្យគេមើលងាយ? ចូរមើល! អ្នកភ្លើង មនុស្សលោកប៉ានជាន់ក្រោមបាតជើងឥតកោតញញើតទេ ។

ទោះយ៉ាងណាក៏ដោយ, រឿងទាំងអស់នេះ ត្រូវលាក់បំបិទបំបាំងឲ្យជិតកុំឲ្យសាយភាយឡើយ បើមិនដូច្នោះទេ ខ្លួនបងឬក៏ខ្លួនខ្ញុំត្រូវវិនាសអន្តរធានមិនខានឡើយ" ។ **ទមនកៈ**និយាយបង្ការស្កាត់ផ្លូវយ៉ាងនេះរួចស្រេចហើយ ដើរចេញទៅរកជួបចចក**ករដកៈ** ។ ចចក**ករដកៈ**ឃើញ**ទមនកៈ**មកដល់ស្រែកសួរថា៖ "ម៉េចទៅបងអើយ! ការនោះសម្រេចហើយឬនៅ?" ចចក**ទមនកៈ**ឆ្លើយប្រាប់មកវិញថា៖ "សម្រេចហើយវើយ! ទាំងពីរនាក់នោះបែកបាក់គ្នាស្រឡះហើយ" ។ ចចក**ករដកៈ**សួរបញ្ជាក់ថាទៀតថា៖ "រឿងនេះ មានកិច្ចការអ្វីសង្ស័យគួរនាំឲ្យទាក់ទាមទៀតទេ?" ព្រោះថា៖

១៧៤- នរណាហ្ន៎ចង់ចងពន្ធជាមួយនឹងមនុស្សទុជ៌ន? នរណាហ្ន៎មិនក្តាញ់បើមានគេសូមញយៗ? នរណាហ្ន៎ ជាបណ្ឌិត មិនចាញ់កលក្នុងវិធីទុច្ចរិត? ។

១៧៥- ជនពាលប៉ិនកល អាចញ៉ាំងនរជនដែលមានសិរីឲ្យប្រព្រឹត្តអាក្រក់បាន ព្រោះមានបំណងចង់ចម្រើនបានប្រយោជន៍ខ្លួន, ការសេពគប់ជនពាលប៉ិនកលនេះ មិនទុកដូចជាការលេងជាមួយភ្លើងឬអ្វី?" ។

លំដាប់នោះ ចចក**ទមនកៈ**ដើរទៅរកជួប**បិង្គលកៈ** ហើយនិយាយប្រាប់ថា៖ "ទេវៈ! ឥឡូវនេះ អាគោចង្រៃទុយ៌សចិត្តអាក្រក់ វាមកហើយ សូមលោកម្ចាស់រៀបចំត្រៀមខ្លួនទុកមុនឲ្យស្រេច" និយាយដាស់តឿនដូច្នេះហើយ បង្គាប់ឲ្យសីហៈបញ្ចេញចង្កូមដូចបានពោលខាងដើម ។ មិនយូរប៉ុន្មាន, គោ**សញ្ជីវកៈ**ដើរចូលមកដល់ ឃើញសីហៈរៀបចំខ្លួនស្រេចដូចចចកប្រាប់ ក៏ចូលទៅប្រយុទ្ធជាញជ័យ ។ កាលនោះឯងកើតសង្គ្រាមធំរវាងសីហៈ និងគោយ៉ាងសម្បើមអស្ចារ្យ **បិង្គលកៈ**ប្រហារ**សញ្ជីវកៈ**

ដល់ក្តីស្លាប់ទៅហោង ។ កាលធ្វើសង្គ្រាមជាញជ័យសម្លាប់គោជាសេវកាមាត្យល្អរួចហើយ សីហៈទើបដឹងខ្លួនថាចាញ់កលចចក កើតសុបសៅសែនស្តុតចិត្ត បន្ទឺវាចាថា៖ "អនិច្ចាអាត្មាអញមិនគួរមកធ្វើអំពើទារុណកម្មដូច្នេះសោះ, ព្រោះថា៖

១៧៦- រាជ្យខ្លួនឯង នៅក្នុងកណ្តាប់ដៃស្តេចដទៃគ្រប់គ្រង ទុកដូចជាភាជនៈសម្រាប់ត្រងរងនូវ

បាបអប្បមង្គល ព្រះរាជាប្រព្រឹត្តល្មើសច្បាប់ ដូចសីហៈសម្លាប់ដំរី([១]) ។

១៧៧- ត្រូវឲ្យវិនាសភាគផែនដីខ្លះ ឬក៏ត្រូវឲ្យវិនាសអាមាត្យដែលមានគុណសម្បត្តិ និងប្រាជ្ញា? ការវិនាសអាមាត្យទុកដូចជាមរណៈនៃព្រះរាជាទាំងឡាយ ឯការវិនាសភាគផែនដី គេអាចដណ្តើមយកវិញបាន មិនមែនដូចខូចខាតអាមាត្យឡើយ ។

ចចក**ទមនកៈ**និយាយកាត់ឡើងថា៖ “លោកម្ចាស់! នេះជាវិធីពិចារណាបែបថ្មីដូចម្តេច? ហេតុអ្វីក៏លោកមកសោកស្តាយសត្រូវដែលលោកសម្លាប់ដូច្នេះ, ព្រោះថា៖

១៧៨- នរជនដែលធ្វើអន្តរាយដល់ជីវិត ទោះជាបិតា ឬជាបងក្តី ពុំនោះទោះជាបុត្រ ឬក៏ជាមិត្តសម្លាញ់ក្តី ព្រះរាជាប្រាថ្នាសេចក្តីចម្រើនត្រូវតែសម្លាប់ចោលបង់ ។

១៧៩- នរជនអ្នកស្គាល់សភាពពិតនៃព្រះធម៌ ប្រយោជន៍ និងកាម មិនគួរមានករុណាតែមួយចំណែកទេ ព្រោះថា នរជនដែលមានតែចិត្តអត់ឱន មិនអាចស៊ីបាយដែលស្ថិតនៅក្នុងកណ្តាប់ដៃខ្លួនឡើយ ។

១៨០- ការអត់ឱនចំពោះសត្រូវ ឬមិត្ត ជាគ្រឿងលម្អនៃអ្នកប្រាជ្ញដែលបំពេញព្រឹត្តិពិតមែនហើយ តែការអត់ឱនចំពោះសត្វដែលមានកំហុសនេះ ត្រឡប់ជាគ្រឿងប្រទូសនៃព្រះរាជាទាំងឡាយវិញទេ ។

១៨១- នរជនណា ចង់សម្លាប់ម្ចាស់ដោយល្មោភចង់បានរាជ្យ ឬដោយការមើលងាយគំនិតទោសនរជននោះ បើឲ្យសមតាមកំហុសមានតែបទមួយទេ គឺការប្រហារជីវិត មិនមែនប្រការដទៃទៀតឡើយ ។

១៨២- ព្រះរាជា មានសេចក្តីអាណិតហួសមាត្រា, ព្រាហ្មណ៍បរិភោគសាច់សត្វសព្វមិនចន្លោះ, ភរិយា មិននៅក្នុងឱវាទ, មិត្តមាននិស្ស័យប៉ងធ្វើសេចក្តីអន្តរាយ, អ្នកបម្រើរឹងទទឹង, ភ្នាក់ងារធ្វេសប្រហែស និងមនុស្សអកតញ្ញូ នរជនគួរលះបង់ជនអស់នេះចោលឲ្យស្រឡះចេញ ។

លោកពោលសេចក្តីវិនាសតទៅទៀតថា៖

១៨៣- រាជនីតិ មានការផ្លាស់ប្តូររូបអនេក ដូចកលមាយាស្រីមានរូបល្អ គឺថាត្រង់តាមសេចក្តីពិត ឬមិនត្រង់តាមសេចក្តីពិតខ្លះ ពោលពាក្យរឹងរូស ឬក៏ជាទីស្រឡាញ់ខ្លះ ធ្វើកាចឃោរឃៅ ពុំនោះធ្វើអាណិតអាសូរខ្លះ កំណាញ់ស្វិតស្វាញ ពុំនោះសោតទូលាយជួយទ្រព្យដើមទុនខ្លះ ចំណាយទ្រព្យជានិច្ច ពុំនោះសោតទៀត ប្រមូលកៀរគររតនវត្ថុ និងទ្រព្យសម្បត្តិឲ្យបានច្រើនខ្លះ ។

---

[១] សីហៈសម្លាប់ដំរី ទោសធ្លាក់មកលើសីហៈ ព្រោះសាច់ឆ្អឹងដំរី ត្រូវបានទៅជាអាហារសត្វដទៃ ។

លុះចចក**ទមនកៈ**មេប្រាជ្ញមេខិលពោលពាក្យចោលល្បួងដោយទឹកប្រយោគសម្តី ប្រាប់ក្តីហេតុផលឲ្យស្ងប់ក្សេមក្សាន្តហើយ **បិង្គលកៈ**ត្រឡប់តាំងខ្លួនដូចធម្មតាដើម ចូលទៅស្ថិតនៅលើរាជបល្ល័ង្កសីហាសនៈវិញ ។ **ទមនកៈ**បានប្រកបតាមក្តីប្រាថ្នាហើយ មានចិត្តរីករាយសប្បាយក្រៃលែង ស្រែកឲ្យសព្ទសាធុការពរដល់ស្តេចចតុប្បាទថា៖ “បពិត្រមហារាជ សូមព្រះអង្គមានជ័យសិរីមង្គលគ្រប់ប្រការ សូមសុភមង្គលផ្តល់ក្តីសុខចម្រើនដល់សព្វសត្វក្នុងសាកលពិភពផ្ទៃក្រោមតទៅ!” ចចកជូនពររួចហើយចូលទៅកាន់ទីឋានខ្លួន សុខសប្បាយដូចប្រក្រតីដើមហោង ។

កាលនោះ មហាបណ្ឌិត**វិស្ណុស័ម៉ន** ក្រាបបង្គំទូលព្រះរាជបុត្រទាំងឡាយមុនបញ្ចប់ថា៖ “ការបំបែកមិត្តនេះ ដែលទ្រង់ទាំងឡាយបានត្រងត្រាប់ស្តាប់តាំងពីដើមដល់ចុងសន្ទតថាចប់អស់អាថ៌សេចក្តីត្រឹមប៉ុណ្ណោះហើយ” ។ ព្រះរាជបុត្រទាំងឡាយត្រាស់តបវិញថា៖ “យើងខ្ញុំទាំងអស់គ្នា បានស្តាប់កថាវិចិត្រដោយសេចក្តីជ្រះថ្លាក្រៃលែង បានក្តីសុខកាយសប្បាយចិត្តឥតឧបមា” ។ មហាបណ្ឌិត**វិស្ណុស័ម៉ន** ក្រាបទូលបញ្ចប់ថា៖ “សូមទ្រង់គ្រប់ព្រះអង្គ បានប្រកបដោយពរនេះតទៅ៖

១៨៤- សូមឲ្យការបំបែកមិត្តនេះ មានចំពោះតែទីលំនៅសត្រូវរបស់ទ្រង់ទាំងឡាយចុះ, ទុជ៌នខិលខូចចិត្តអាក្រក់សាមាន្យ សូមព្រះកាលចាប់កាច់កបំផ្លិចបំផ្លាញ នាំយកទៅកាន់ទីវិនាសហិនហោចខ្ទាចផ្សាអស់រលីងរាល់ៗថ្ងៃទៅកុំបីខាន, សូមមហាជនតាំងនៅដោយការបរិបូណ៌ព្រមដោយសេចក្តីសុខចម្រើនគ្រប់ប្រការ ជាអនេកអនន្តអស់កាលជានិច្ចនិរន្តរ៍ និងសូមកុលបុត្រយុវជនទាំងឡាយ មានចិត្តរីករាយជ្រះថ្លាចំពោះមធុរកថាជាទីមនោរម្យក្នុងលោកនេះ គ្រន់ទិនទិវារាត្រីទៅហោង ។

កថាសង្គ្រោះទី ២ ឈ្មោះការបំបែកមិត្ត មានមកក្នុងហិតោបទេសចប់តែប៉ុណ្ណោះ ។

# ស្រី

# ហិតោបទេស

ភាគទី ៣

# ឈ្មោះ "សង្គ្រាម"

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស. ២៥០០

នារាយណបណ្ឌិត

# ស្រី

# ហិតោបទេស

ភាគទី ៣

## ឈ្មោះ “សង្គ្រាម”

ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

ជា

អ្នកបកប្រែចេញពីភាសាសំស្ក្រឹត

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥០០ គ.ស ១៩៥៧

ចារឹកឡើងវិញ៖ ណុល ដារ៉ា

២០០៩

# បញ្ជីរឿង


| | | |
|---|---|---|
| ១_ កថាមុខ... | ទំព័រ | ក |
| ២_ ៣ សង្គ្រាម... | | ២ |
| ៣_ កថាទី១ រឿងហង្ស និងក្អែក | | ២ |
| ៤_ កថាទី២ រឿងបក្សី និងស្វា | | ៣ |
| ៥_ កថាទី៣ រឿងលាពាក់ស្បែកខ្លា | | ៥ |
| ៦_ កថាទី៤ រឿងដំរី និងទន្សាយ | | ៦ |
| ៧_ កថាទី៥ រឿងហង្ស និងក្អែក | | ១០ |
| ៨_ កថាទី៦ រឿងក្អែក និងទទា | | ១១ |
| ៩_ កថាទី៧ រឿងជាងរថ ភរិយា និងសហាយ | | ១២ |
| ១០_ កថាទី៨ រឿងចចកនីលពណ៌ | | ១៨ |
| ១១_ កថាទី៩ រឿងស្តេចសមុទ្រ និងអាមាត្យវីរវរៈ | | ២៥ |
| ១២_ កថាទី១០ រឿងជាងកោរកាត់ល្មោភ | | ៣០ |

# កថាមុខ

ហិតោបទេសភាគទី៣ឈ្មោះ “សង្គ្រាម” បានធ្លាក់មកដល់ដៃអ្នកអានទាំងឡាយក្នុងថ្ងៃនេះហើយ ខ្ញុំមានសេចក្ដីត្រេកអរក្រៃលែង ព្រោះខ្ញុំតែងមានបារម្ភជានិច្ចក្រែងសៀវភៅនេះចេញមិនរួច ដោយមិនសូវមានអ្នកនិយមអាន ។ ហេតុនេះ ខ្ញុំសូមសម្ដែងសេចក្ដីត្រេកអរដ៏ក្រៃលែងចំពោះលោកអ្នកអានទាំងឡាយទុកក្នុងទីនេះផង ព្រោះអាស្រ័យដោយអស់លោកអ្នកអានទាំងឡាយនេះហើយ ទើបខ្ញុំមានព្យាយាមប្រែបានសម្រេច ។ ខ្ញុំនឹកឃើញកាលខ្ញុំបញ្ចប់មួយភាគៗខ្ញុំបានប្រគល់សំណៅទៅឲ្យអ្នកចាត់ការបោះពុម្ពផ្សាយ គេច្រើនតែមិនសូវចង់ទទួលបោះពុម្ពផ្សាយ ហើយគេឆ្លើយត្អូញត្អែរមកខ្ញុំវិញថា៖ “សៀវភៅនេះមានប្រយោជន៍ណាស់ តែមានអាថ៌ខ្ពស់ពេកហួសការចេះដឹងប្រជាជន លក់ចេញមិនសូវរស់នាំឲ្យកប់សោហ៊ុយ” ។ ដំណើរនេះ នាំឲ្យខ្ញុំញញើតមិនហ៊ានបង្ខំគេ ទើបបានជាសៀវភៅនេះយឺតមិនបានចេញមុខមកដល់អ្នកអានឲ្យទាន់កាលវេលា ។ តាមពិនិត្យមើលការផ្សាយ ខ្ញុំឃើញថាមិនមែនជាតឹងពេកទេ ព្រោះភាគទី១ គឺភាគ “ការគប់មិត្ត” កាលដែលបោះពុម្ពលើកទី១ នោះ មានចំនួន ៣.០០០ សៀវភៅក្នុងថិរវេលាត្រឹមតែ១៥ខែប៉ុណ្ណោះ ឃើញថាបាត់មុខពីបណ្ណាគារនៅក្រុងភ្នំពេញទៅហើយ ដូច្នេះឃើញថារស់គ្រាន់បើដែរ ។

ខ្ញុំបានខំប្រឹងប្រែហិតោបទេសបានដល់ភាគ៣នេះ ទុកដូចជាខ្ញុំខំឈានបាន៣ជំហាន នឹងជំហាននេះហើយ ខ្ញុំរីករាយសប្បាយចិត្តណាស់ នៅសល់តែមួយភាគទៀតទេគឺភាគទី៤ ។ ឯភាគទី៤ សំខាន់បំផុតក្នុងហិតោបទេសនេះ លោកឲ្យឈ្មោះថា “សន្តិភាព” ។ ខ្ញុំសូមលោកអ្នកអានទាំងឡាយកុំធុញទ្រាន់ ខំប្រឹងអានហើយចុតចាំសុភាសិត និងនិទានឲ្យបានច្រើន រៀនផ្លាស់និស្ស័យទន់រវើតរវែតរបស់យើងចោល យកនិស្ស័យរឹងប៉ឹងដែលមានក្នុងផ្ទៃសៀវភៅនេះមកជំនួស ហើយប្រើទៅជាប្រយោជន៍តទៅ ដើម្បីឲ្យបានខ្លួនយើងជាអរិយជន ។

ភាគទី៣ នេះ ខ្ញុំទុកជាទីរឭកមាឃបូជាក្នុងឆ្នាំខាលទោស័ក ព.ស. ២៤៩៣ ។

ក្នុងពេលអសន្តិសុខពេញប្រទេសនេះ ខ្ញុំសូមឲ្យប្រជាជនខ្មែរទាំងមូលបានប្រសព្វសេចក្ដីសុខសេចក្ដីចម្រើនកុំបីខានឡើយ ឧបទ្រពចង្រៃទាំងឡាយ ក៏សូមឲ្យបររៀះចៀសវាងចេញឆ្ងាយឆាប់ទៅ!!!

វត្តឧណ្ណាលោមនៅថ្ងៃ១ៗ[១២] ៣ឆ្នាំខាលទោស័ក ព.ស. ២៤៩៣

ត្រូវនឹងថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ១៩៥១

ភិក្ខុ ប៉ាង-ខាត់ (វីរិយបណ្ឌិតោ)

# ៣_ សង្គ្រាម

ក្នុងពេលដែលចាប់ផ្ដើមនិយាយរឿងតទៅ, ព្រះរាជបុត្រទាំងឡាយមានព្រះបន្ទូលត្រាស់ថា៖ "បពិត្រលោកអាយ៌ះ! យើងខ្ញុំទាំងអស់គ្នានេះជារាជបុត្រ យើងខ្ញុំត្រូវការស្ដាប់រឿងសង្គ្រាមទៀត" ។ បណ្ឌិត**វិស្ណុស័ម៌ន**ក្រាបបង្គំទូលតបថា៖ "បើដូច្នោះ ទូលព្រះបង្គំនឹងបរិយាយរឿងរ៉ាវដែលទ្រង់ព្រះករុណាទាំងឡាយសព្វព្រះទ័យ, សូមទ្រង់ទាំងឡាយតាំងព្រះទ័យព្រះសណ្ដាប់រឿងសង្គ្រាម ដូចមានស្លោកជាដើមបទដូច្នេះ៖

១- ក្នុងសង្គ្រាមរវាងហង្សនិងក្អែក ដែលមានកម្លាំងភៀវគ្នាស្មើគ្នា ហង្សត្រូវក្អែកនៅក្នុងសំណាក់ក្អែកជាសត្រូវមកលលួង ធ្វើឲ្យស្និទ្ធស្នាលបោកបញ្ឆោតបាន ។

ព្រះរាជបុត្រទាំងឡាយត្រាស់សួរឡើងថា៖ "ចុះរឿងនោះ តើដូចម្ដេច?" ។ មហាបណ្ឌិត**វិស្ណុស័ម៌ន**ពណ៌នារឿងនោះក្រាបទូលថ្វាយដូចសេចក្ដីតទៅនេះថា៖

## កថាទី១

### រឿងហង្ស និងក្អែក

នៅក្នុងកប្បូរទ្វីប មានស្រះមួយឈ្មោះបទ្មកេលិ ។ នៅក្នុងស្រះនោះមានរាជហង្សមួយឈ្មោះ**ហិរណ្យគត៌**អាស្រ័យនៅ ។ បក្សីជលចរទាំងអស់ព្រមព្រៀងគ្នាអភិសេក**ហិរណ្យគត៌** លើកឲ្យធ្វើជាស្ដេចបក្សី, ព្រោះថា៖

២- បើមិនមានព្រះនរបតីជាអ្នកគ្រប់គ្រងដឹកនាំដោយប្រពៃទេ ប្រជាជនទុកដូចជានាវាមិនមានអ្នកកាច់ចង្កូត នឹងវង្វេងលិចលង់ក្នុងជលធី ។

៣- ព្រះនរបតីគ្រប់គ្រងរក្សានូវប្រជាជន ប្រជាជនធ្វើឲ្យចម្រើនព្រះនរបតី, ការគ្រប់គ្រងរក្សាប្រសើរជាងសេចក្ដីចម្រើន បើមិនមានការគ្រប់គ្រងរក្សាសេចក្ដីចម្រើននោះទេ សេចក្ដីចម្រើននឹងត្រឡប់វិនាសអន្តរាយបាត់បង់ទៅវិញ ។

ក្នុងថ្ងៃមួយ, រាជហង្សកំពុងសម្រាកកាយលើបល្ល័ង្កឈូកដ៏ពិសាលមានបរិវារចោមរោមគាល់ហ្វៀត្រៀបត្រា ។ កាលនោះ កុកឈ្មោះ**ទីឃ៌មុខ**ត្រឡប់មកដល់ពីបរទេស ចូលទៅជិតហើយអង្គុយប្រណម្យ ។ រាជហង្សសួរថា៖ "ហៃ**ទីឃ៌មុខ**! អ្នកទើបមកដល់ពីបរទេស ចូរនិយាយរឿងអ្វីប្លែកឲ្យយើងស្ដាប់បន្តិចមើល!" ។ កុកឆ្លើយប្រាប់ថា៖ "ទេវៈ! មានរឿងប្លែកចម្លែកណាស់ ព្រោះហេតុនោះ ទើបខ្ញុំបាទវិលត្រឡប់មកដោយរហ័សដើម្បីជម្រាបដំណឹងនោះ, សូមលោកម្ចាស់ស្ដាប់ដូចសេចក្ដីតទៅនេះ៖

នៅក្នុងជម្ពូទ្វីប មានបព៌តមួយឈ្មោះវិន្ឡ: ជាទីអាស្រ័យនៅនៃក្អែក ជាស្តេចបក្សីថលចរឈ្មោះ **ចិត្រពណ៌** ។ កាលខ្ញុំបាទហើរត្រាច់ស្វះស្វែងរកចំណីអាហារនៅក្នុងព្រៃភ្លើងឆេះមួយកន្លែង ខ្ញុំបាទបានជួបនឹងបរិវារស្តេចក្អែកនោះ ។ បរិវារស្តេចក្អែកសួរខ្ញុំបាទថា៖ “អ្នកជាអ្វី? អ្នកមានការអ្វី? ទៅណាបានមកកាន់ទីនេះ?” ។ កាលនោះ ខ្ញុំបាទឆ្លើយប្រាប់ទៅវិញថា៖ “ខ្ញុំជាបរិវាររាជហង្ស ឈ្មោះ**ហិរណ្យគក៏** ជាស្តេចចក្រពត្រាធិរាជនៃកប៉ូរទ្វីប ខ្ញុំមកនេះដើម្បីដើរមើលក្រុងនៃនានាប្រទេសទាំងឡាយ” ។ បក្សីជាបរិវារស្តេចក្អែកបានស្តាប់ពាក្យខ្ញុំបាទហើយ សួរតទៅទៀតថា៖ “ចុះប្រទេសទាំងពីរនេះគឺប្រទេសអ្នក និងប្រទេសខ្ញុំ ប្រទេសណាគ្រាន់បើជាងប្រទេសណា? ស្តេចណាគ្រាន់បើជាងស្តេចណា?” ។ ខ្ញុំបាទឆ្លើយប្រាប់ថា៖ “អ៎ា! ដូចម្តេចក៏ប៉ានសួរដូច្នេះ? ផ្សេងខុសគ្នាធំណាស់! ប្រទេសស្តេចខ្ញុំ ល្អហើយធំណាស់ផង ព្រោះកប៉ូរទ្វីបទុកដូចជាស្ថានសួគ៌ រាជហង្សទុកដូចព្រះឥន្ទ្រាធិរាជជាស្តេចឋានសួគ៌ទីពីរ, អ្នកទាំងឡាយនៅក្នុងទីនេះ ដីក្រៀមក្រោះឥតជីវជាតិ មានតែដីភ្លើងឆេះរលីងធេងហេងហាងយ៉ាងនេះនៅម្តេចកើត? មក! ចូរទៅនៅក្នុងប្រទេសយើងជាមួយយើងទៅ” ។ បក្សីបរិវារស្តេចក្អែកបានឮពាក្យខ្ញុំបាទហើយ ទាំងអស់គ្នាក៏ក្រេវក្រោធច្រឡោតខឹងក្រៃលែង, ព្រោះថា៖

៤- ការឲ្យភុជង្គនាគផឹកទឹកដោះ បានតែនាំឲ្យចម្រើនពិសកាចបន្ថែមឡើងទៀតតែប៉ុណ្ណោះ, ឧបទេសដែលគេឲ្យដល់មនុស្សល្ងង់ក្រេវក្រោធច្រើន មិនបានសេចក្តីស្ងប់ទេ បានតែក្រោធថែមទៀត ។

៥- មានតែអ្នកប្រាជ្ញទេបុគ្គលគប្បីឲ្យឧបទេសបាន ឯមនុស្សល្ងង់ក្នុងកាលណាក៏ដោយ បុគ្គលមិនគប្បីឲ្យឧបទេសឡើយ សត្វបក្សីកាលឲ្យឧបទេសដល់ស្វាល្ងង់ ត្រូវស្វាបោចរោចសំបុកចោលហិនហោចអស់ ។

រាជហង្សសួរថា៖ “ចុះរឿងនោះ តើដូចម្តេច?” ។ កុក**ទីឃមុខ**និយាយរឿងរ៉ាវនោះប្រាប់ថា៖

# កថាទី២

## រឿងបក្សី និងស្វា

នៅជិតត្រើយទន្លេនម៌ទា មានដើមជ្រៃមួយដើមប្រកបដោយសាខាទ្រឈឹងទ្រឈៃ ។ នៅលើជ្រៃនោះបក្សីទាំងឡាយធ្វើសំបុកទុកពងជ្រកអាស្រ័យនៅដោយក្តីសុខក្សេមក្សាន្ត ។ សម័យថ្ងៃមួយក្នុងរដូវភ្លៀង, មណ្ឌលពពកមានផ្ទៃខ្មៅជាំងាសពាសពេញជាអាកាសវេហាស៍សុទ្ធសឹងជលធារា កាលនោះភ្លៀងធំក៏បង្អុរចុះមកយ៉ាងខ្លាំង ។ ខណៈនោះឯង បក្សីទាំងឡាយក្រឡេកមើលទៅឃើញពានរមួយហ្វូងដែលជ្រកអាស្រ័យនៅលើដើមជ្រៃនោះដែរ ត្រូវត្រជាក់រងាបៀតបៀនខ្លាំងកំពុងញាប់ញ័រចំប្រប់ឱបដៃតគ្រុន

វណ្ណាំធ្មេញក្រឹតៗ កើតមានចិត្តអាណិតអាសូរខ្លាំង ទាល់តែអត់ទ្រាំមិនបាន ក៏និយាយប្រាប់ទៅថា៖ “នែបងពានរ! ចូរស្ដាប់ខ្ញុំ ខ្ញុំនឹងនិយាយប្រាប់៖

៦- សំបុកដែលយើងជ្រកនេះយើងធ្វើខ្លួនឯងដោយស្មៅ ដែលយើងពាំយកមកគ្រាន់តែដោយចំពុះ ចុះបងពានរឯង មានដៃមានជើងដូចមនុស្សដែរ ម្ដេចក៏មកអង្គុយទ្រាំលំបាករងាញ័រទទ្រើកដូច្នេះ?” ។

ពានរទាំងឡាយបានស្ដាប់ពាក្យបក្សីទាំងឡាយហើយ កើតក្ដាញ់ក្នុងចិត្ត ឆ្លើយតបទៅវិញថា៖ “យីអើ! អាបក្សីនេះ វាអាងវាបាននៅក្នុងសំបុកឥតមានខ្យល់កក់ក្ដៅសុខក្សេមក្សាន្តស្រួល វាហ៊ាននិយាយឌឺដងឡកឡឺយឲ្យយើង មិនអីទេ ចាំមើលតែវាំងដឹងហើយ! (¹)” ។ លុះដល់វាំងភ្លៀងហើយ ពានរទាំងឡាយនោះវារឡើងទៅបោចរោចសំបុកបក្សីខ្ទេចខ្ទីហិនហោចទាំងអស់ ធ្លាក់ស៊ុតបក្សីរពុកមកដីបែកខ្ចាយអន្តរាយអស់ទៅហោង, ព្រោះហេតុនោះ បានជាខ្ញុំ (កុក**ទីឃមុខ**) និយាយថា៖ “មានតែអ្នកប្រាជ្ញទេ” ដូច្នេះជាដើម (លេខ ៥) ។ រាជហង្សសួរតទៅទៀតថា៖ “ចុះក្អែកទាំងនោះ វាធ្វើដូចម្ដេចតទៅទៀត?” ។ **ទីឃមុខ**និយាយតទៅថា៖ “កាលនោះ ក្អែកទាំងឡាយក្រេវក្រោធច្រឡោតខឹងសួរមកខ្ញុំបាទវិញថា៖ “ចុះរាជហង្សជាស្ដេចអ្នកឯងនោះ បាននរណាលើកតម្កើងឲ្យធ្វើជាស្ដេច?” ។ គ្រានោះ ខ្ញុំបាទអាក់អន់ចិត្តក្ដាញ់ខ្លាំងណាស់ ក៏សួរត្រឡប់ទៅក្អែកទាំងឡាយនោះវិញថា៖ “ចុះក្អែកជាស្ដេចអ្នកទាំងអស់គ្នានេះ បាននរណាលើកឲ្យសោយរាជ្យ?” ។ ក្អែកទាំងឡាយនោះ លុះបានស្ដាប់ពាក្យខ្ញុំបាទសួរដូច្នោះហើយ ក្ដៅក្រហាយខ្លាំង ចង់រករឿងសម្លាប់ខ្ញុំបាទ, ខ្ញុំបាទក៏សម្ដែងក្ដីអង់អាចមិនខ្លាចតបទៅវិញ, ព្រោះថា៖

៧- ក្នុងកាលខ្លះ សេចក្ដីអត់ធន់ជាគ្រឿងលម្អនៃបុរស ដូចសេចក្ដីអៀនខ្មាសជាគ្រឿងលម្អនៃស្ត្រីទាំងឡាយ, តែក្ដីក្លាហានជាគ្រឿងលម្អនៃបុរសក្នុងពេលដែលគេមើលងាយ ដូចការមិនអៀនខ្មាសជាគ្រឿងលម្អនៃស្ត្រីក្នុងការសពសន្ថវៈដូច្នោះដែរ ។

រាជហង្សអស់សំណើចឃឹក ហើយនិយាយថា៖

៨- នរជនណា កាលមើលឃើញការមានកម្លាំង និងការឥតកម្លាំងនៃខ្លួន និងសត្រូវហើយ មិនស្គាល់ប្រភេទផ្សេងគ្នាទៀត នរជននោះត្រូវសត្រូវមើលងាយ ។

៩- មែនពិតលាកម្លៅ ពាក់ស្បែកខ្លា ចូលទៅស៊ីស្រូវក្នុងស្រែអស់កាលយូរ ត្រូវគេសម្លាប់ចោលបង់សៀត ព្រោះទោសកើតមកពីសម្ដី ។

---

¹ ហិតោបទេស សេចក្ដីប្រែជាភាសាបារាំងរបស់លោកឡង់សឺរ្វ មានគាថាលើសដូច្នេះគឺ៖ បក្សីមនុស្សកាច មនុស្សល្ងង់ នឹងអ្នកដែលអួតខ្លួនថាជាអ្នកប្រាជ្ញ មិនមានសមត្ថភាពធ្វើគេហដ្ឋាននៅបានទេ បានគ្រាន់តែបំផ្លិចបំផ្លាញគេហដ្ឋានតែប៉ុណ្ណោះ ។

**ទីឃ៍មុខ**សួរថា៖ “ចុះរឿងនោះ តើដូចម្ដេច?” ។ រាជហង្សនិយាយរឿងរ៉ាវនោះប្រាប់ថា៖

# កថាទី៣

## រឿងលាពាក់ស្បែកខ្លា

នៅក្រុងហស្ដិនាបុរៈ, មានអ្នកបោកគក់ម្នាក់ឈ្មោះវិលាសៈ ។ គាត់មានលាមួយ ។ លានោះដឹកនាំភារៈធ្ងន់ក្រៃពេក ទៅជាស្គាំងស្គមថមថយខ្សោយកម្លាំងរកកល់នឹងស្លាប់ ។ កាលនោះ, អ្នកបោកគក់យកស្បែកខ្លាទៅគ្របពីលើលានោះ ហើយលែងឲ្យដើរទៅស៊ីស្រូវក្នុងស្រែមួយ ដែលមាននៅក្នុងទីជិតមាត់ព្រៃ ។ អ្នកស្រែមើលពីចម្ងាយទៅឃើញលានោះ តែសម្គាល់ថាជាសត្វខ្លា ក៏រត់ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ ។ តមកថ្ងៃមួយ, អ្នកស្រែស្លៀកពាក់ខោអាវប្រផេះ ដៃកាន់ដំបងមួយដើរឱនអង្គុលៗចូលទៅ ហើយអង្គុយក្នុងទីគួរមួយដើម្បីលបមើល ។ ឯលានោះបានស៊ីស្រូវតាមទំនើងចិត្តអស់កាលយូរថ្ងៃហើយ មានខ្លួនធាត់ផ្ទឹក ឡើងកម្លាំងក្លៀវក្លា កាលក្រឡេកមើលទៅឃើញអ្នកស្រែនោះពីចម្ងាយសម្គាល់ថាជាលាញី ក៏តាំងកញ្ជ្រៀវយ៉ាងខ្លាំង ហើយបោលសំដៅទៅរកអ្នកស្រែ ។ គ្រានោះឯង, អ្នកស្រែលុះដឹងច្បាស់ថាជាលាពិតប្រាកដហើយ ដោយសំឡេងកញ្ជ្រៀវហេហេនោះ យារដំបងលើកឡើងសំពងលានោះម៉ុង វាយអស់ទំហឹងសម្លាប់ចោលទៅហោង, ព្រោះហេតុនោះ បានជាខ្ញុំ (រាជហង្ស) និយាយថា៖ “មែនពិត លាកម្ដៅ” ដូច្នេះជាដើម (លេខ ៩) ។ **ទីឃ៍មុខ** រៀបរាប់តទៅទៀតថា៖ កាលនោះ ក្អែកទាំងឡាយជេរប្រទេចខ្ញុំបាទក្រោយបង្អស់ថា៖ “នែអាកុកគម្រក់ខិលខូចចង្រៃ! អាឯងចូលមកដល់ដីទឹកយើង អាឯងព្រហើនប៊ានមើលងាយព្រះចេស្ដាម្ចាស់យើង! ឥឡូវនេះ យើងអត់ទោសឲ្យអាឯងមិនបានទេ” ។ ក្អែកទាំងឡាយនោះ, ពោលដូច្នេះហើយ ហើរចូលមករោមចោមចឹកខ្ញុំបាទសម្លាប់ ហើយស្រែកជេរទាំងកំហឹងថា៖ “នែអាគម្រក់ល្ងង់ចង្រៃ! ហង្សជាស្ដេចអាឯងកំសាកញីទេ ឥតមានកម្លាំងអំណាចអ្វីគ្រប់គ្រងដែនទឹកដែនដីទេ ព្រោះស្ដេចដែលខ្សោយអំណាច មិនអាចគ្រប់គ្រងរាជ្យ ដែលនៅក្នុងកណ្ដាប់ដៃខ្លួនបានឡើយ បើដូច្នោះតើធ្វើដូចម្ដេចស្ដេចអាឯងនឹងអាចគ្រប់គ្រងលោកសន្និវាសនេះបាន? រាជ្យស្ដេចអាឯងនោះ វាធំម្ល៉ាទៅ? វីខ្លួនអាឯងនេះសោត ដូចកង្កែបមិនដែលចេញពីអណ្ដូងសោះ បើម្ល៉ឹង! តើអាឯងប៊ានមើលងាយយើង ឲ្យយើងចូលទៅស្វាមីភក្ដិស្ដេចអាឯង, យើ! អាឯងអីក៏កោងម្ល៉េះ! អាឯងស្ដាប់មើល!

១០- ([១]) ដើមឈើធំ បរិបូណ៌ដោយសន្លឹក មានម្លប់ត្រជាក់ និងរយោនរយានដោយផ្លែ ក៏បុគ្គលគប្បីពឹងពាក់អាស្រ័យ, តែបើជួនកាលខ្លះ ទេវតាបណ្ដាលមិនឲ្យមានផ្លែ មិនឲ្យមានម្លប់ បុគ្គលនឹងមិនត្រូវបំផ្លាញចោលឬអ្វី?

១១- បុគ្គលមិនគប្បីធ្វើការសេពគប់ពឹងពាក់ ចំពោះជនដែលតូចតាចថោកទាបឡើយ គប្បីធ្វើចំពោះតែឥស្សរជនដែលមានអំណាច ព្រោះថាទឹកដោះ បើនៅក្នុងកណ្ដាប់ដៃអ្នកស្រវឹង ក៏បានឡើងឈ្មោះទៅជាទឹកគ្រឿងស្រវឹងដែរ ។

១២- គុណធម៌គម្ពីរភាពជ្រាលជ្រៅហើយធំពិសាលផង បើស្ថិតនៅក្នុងបុគ្គលតូចឥតគុណ តែងដល់នូវការខិនថយតូចទៅៗពិត ព្រោះបុគ្គលជាគ្រឿងទ្រមិនសមល្មមដល់គុណធម៌ដែលត្រូវទ្រ ដូចរូបដំរី ដែលនៅក្នុងកញ្ចក់តូច ([២]) ។

១៣- ដោយការប្រើឧបាយកល បុគ្គលគប្បីយកឈ្នះព្រះនរាធិបតីដែលមានអំណាចធំក្រៃលែងទាល់តែសម្រេចបាន, ទន្សាយទាំងឡាយបានសេចក្ដីសុខស្រួលបួល ព្រោះប្រើឧបាយក្នុងនាមនៃព្រះចន្ទ្រ” ។

ខ្ញុំបាទ (**ទីឃ៍មុខ**) សួរថា៖ “ចុះរឿងនោះតើដូចម្ដេច?” ។ ក្អែកទាំងឡាយនិយាយរៀបរាប់រឿងរ៉ាវនោះប្រាប់ខ្ញុំបាទថា៖

# កថាទី៤

## រឿងដំរី និងទន្សាយ

ថ្ងៃមួយ, នៅក្នុងរដូវភ្លៀងរាំងរីងស្ងួតហួតហែងឥតមានទឹកភ្លៀងសោះ ដំរីមួយហ្វូងធំ ដែលមានក្ដីស្រេកឃ្លានបៀតបៀនហើយ ចូលទៅនិយាយនឹងដំរីជាមេខ្លោងថា៖ “លោកជាទីពឹង! ធ្វើឧបាយដូចម្ដេចយើងទាំងអស់គ្នានឹងមានជីវិតរស់នៅតទៅទៀត? ទីនេះត្រពាំងបឹងបួរីងអស់ហើយ សូម្បីតែសម្រាប់សត្វតូចតាចក៏មិនមានដែរ យើងទាំងអស់គ្នាបើមិនមានទឹកសម្រាប់ស្រប់សម្រាប់ផឹកសម្រាប់មុជទេ មុខ

---

[១] ហិតោបទេសសេចក្ដីប្រែជាភាសាបារាំងរបស់លោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះគឺ, បុគ្គលកុំគប្បីស្ថិតនៅ ឬដើរទៅជាមួយមនុស្សអាក្រក់ សូម្បីមួយរំពេចឲ្យសោះ ព្រោះថាការសេពគប់មនុស្សអាក្រក់ឈ្មោះថាសេចក្ដីស្លាប់ ការសេពគប់អ្នកសប្បុរសឈ្មោះថាសន្តិភាព ។

[២] ហិតោបទេសរោងពុម្ពភាគីវៈ បុស្តកាល័យ គាយឃាដិកាស៍ មានគាថាដូច្នេះគឺ, មេពតែ អាស្រ័យការប្រោសប្រាណនៃសីហៈ អាចដើរស្វែងរកអាហារក្នុងព្រៃឥតភិតភ័យ, ឯវិភីសណៈ (ពិភេក) អាស្រ័យបុណ្យព្រះរាម ទើបបានរាជ្យនៅក្រុងលង្កា ។

ជានឹងស្លាប់អសារបង់អស់ហើយ ដូចជាអណ្តើកខ្វាក់ទៅណាមិនរួច យើងទាំងអស់គ្នានឹងទៅឯណាហ្ន៎?" ។ កាលនោះ, ស្តេចដំរីបានស្តាប់ហើយ នាំបរិវារដើរចេញទៅមិនឆ្ងាយបានឃើញត្រពាំងមួយ ទឹកថ្លាយល់ដី ។ ក្នុងថ្ងៃដែលដំរីបបួលគ្នាដើរទៅនុ៎ះ ទន្សាយតូចធំទាំងឡាយដែលអាស្រ័យនៅនាត្រើយត្រពាំងទាំងប៉ុន្មាន ត្រូវដំរីដើរជាន់ស្លាប់ខ្ទេចខ្ទីស្ទើរតែអស់ ។ គ្រានោះ, មានទន្សាយមួយឈ្មោះ**សិលីមុខៈ** កាលបានឃើញព្រឹត្តិការណ៍អន្តរាយដូច្នោះ ទើបគិតថា៖ "ហ្វូងដំរីនេះ គឺកកងជ្រួលច្របល់ដោយក្តីស្រេកឃ្លាន នឹងគប្បីមកកាន់ត្រពាំងនេះរាល់ថ្ងៃ កាលបើដូច្នេះ ត្រកូលពូជទន្សាយទាំងឡាយមុខជានឹងវិនាសអន្តរធានអស់មិនខានឡើយ" ។ ពេលនោះ, មានទន្សាយចាស់មួយឈ្មោះ **វិជ័យ** ចូលមកនិយាយរ៉ាប់រងថា៖ "នែអ្នកទាំងឡាយ! កុំភិតភ័យជ្រួលច្របល់ថ្វី ទុកងារឲ្យខ្ញុំទៅធ្វើប្រតិបត្តិការក្នុងទីនោះជួយដោះទុក្ខបងប្អូនទាំងឡាយ" ។ ទន្សាយចាស់ឈ្មោះ**វិជ័យ**នោះធ្វើប្តេជ្ញាដូច្នេះហើយ ក៏ដើរចេញទៅ ។ កាលដែលកំពុងដើរចេញទៅ **វិជ័យ** ដើរបណ្តើរគិតបណ្តើរថា៖ "ដល់អាត្មាអញដើរទៅជិតស្តេចដំរីជាម្ចាស់ហ្វូង តើអាត្មាអញត្រូវធ្វើដូចម្តេច? ព្រោះថា៖

១៤- ដំរីគ្រាន់តែពាល់ ភុជង្គគ្រាន់តែព្រួសពិស ព្រះរាជាគ្រាន់តែរក្សា មនុស្សទុជ៌នសូម្បីញញឹមទាំងអស់នេះ សុទ្ធតែធ្វើឲ្យសេចក្តីស្លាប់បានទាំងអស់ ។

បើដូច្នោះ គួរតែអាត្មាអញឡើងទៅលើកំពូលភ្នំសិន ហើយសឹមនិយាយប្រាប់មេខ្លោងដំរី" ។ លុះទន្សាយធ្វើដូចគំនិតស្រេចហើយ មេខ្លោងដំរីស្រែកសួរតបទៅវិញថា៖ "ចុះអ្នកឯងជាអ្វី? អ្នកឯងមកពីណា?" ។ **វិជ័យ**ឆ្លើយប្រាប់ថា៖ "យើងជាទន្សាយព្រះចន្ទ្រដ៏មានបុណ្យ លោកប្រើយើងមកកាន់សំណាក់អ្នករាល់គ្នានេះឯង" ។ មេខ្លោងដំរីសួរតបវិញភ្លាមថា៖ "បើដូច្នោះ ចូរនិយាយប្រាប់មកមានការណ៍ដូចម្តេចខ្លះ?" ។ **វិជ័យ**ប្រាប់ថា-

១៥- ទូតសូម្បីនៅកណ្តាលសស្ត្រាវុធ ដែលគេលើកច្រូងច្រាងក៏មិននិយាយអ្វីដទៃក្រៅពីការខ្លួន, អាស្រ័យដោយខ្លួនជាទូត គេមិនសម្លាប់ ហេតុនោះទើបទូតចរចាត្រង់ទៅត្រង់មកតាមសេចក្តីពិត ។

ដូច្នោះ ខ្ញុំនឹងសូមពោលទៅតាមព្រះរាជាអាជ្ញាព្រះចន្ទ្រដ៏មានបុណ្យ ដែលខ្ញុំបាទទទួលមក, សូមប្រុងស្តាប់ដូចតទៅនេះ៖ "ទន្សាយទាំងឡាយនេះ ជាអ្នករក្សានូវត្រពាំងព្រះចន្ទ្រ ឥឡូវអ្នកទាំងឡាយមកបណ្តេញបំបរបង់ ហើយសម្លាប់ផង ការធ្វើដូច្នេះមិនត្រឹមត្រូវតាមគន្លងធម៌ទេ ព្រោះទន្សាយទាំងអស់ដែលរក្សានូវត្រពាំងនេះជាបរិវារយើង ហេតុនេះហើយបានជាមានពាក្យគេហៅយើងថា សសាង្ក, ([១])

---

[១] មានរូបទន្សាយជាគ្រឿងសម្គាល់, នាមធេយ្យ "ឈ្មោះ" ។

ជានាមធេយ្យរបស់យើង ។ កាលដែលទូតថ្លែងសេចក្តីដូច្នេះចប់ហើយ មេខ្លោងដំរីភ័យញ័ររន្ធត់ ហើយនិយាយទាំងញញាក់ញញ័រតបថា៖ "បពិត្រលោកជាអ្នកថ្លែងសេចក្តី! យើងខ្ញុំនេះមិនដឹង បើដូច្នោះចាប់តាំងពីពេលនេះតទៅ យើងខ្ញុំលែងទៅក្នុងត្រពាំងនោះទៀតហើយ" ។

**វិជ័យ**ជាទូតនិយាយបំភ័យថែមទៀតថា៖ "បើដូច្នោះ ចូរអ្នកទាំងឡាយទៅមាត់ត្រពាំងសិន ដើម្បីថ្វាយបង្គំព្រះអង្គលោក សូមឲ្យលោកត្រាប្រណីប្រោសប្រាណអត់ទោស រួចហើយសឹមត្រឡប់ទៅវិញចុះ ព្រះព្រះចន្ទ្រដ៏មានបុណ្យលោកខ្វាល់ខ្វាំងណាស់" ។ កាលនោះ **វិជ័យ**នាំដំរីមេខ្លោងនឹងបរិវារទៅក្នុងរាត្រី ហើយបង្ហាញរូបព្រះចន្ទ្រដែលកំពុងញ័រដោយរលកក្នុងត្រពាំងនោះ ដំរីមេខ្លោងមើលទៅឃើញព្រះចន្ទ្រញ័រមែន ។ **វិជ័យ**និយាយអង្វរថា: "ទេវៈ! កំហុសគឺដំរីធ្វើពិតមែនហើយ ព្រោះគ្នាមិនបានដឹង បើដូច្នោះ សូមលោកម្ចាស់អភ័យទោសឲ្យទានដោយករុណា, តទៅ, ហ្វូងដំរីទាំងឡាយនេះ ប្តេជ្ញាថានឹងមិនមកកាន់ទីនេះទៀតទេ" ។ **វិជ័យ**សូមអភ័យទោសឲ្យដំរីរួចហើយ ទើបបង្គាប់ឲ្យដំរីទាំងឡាយថយចេញពីទីនោះទៅហោង, ព្រោះហេតុនោះ បានជាយើង (ក្ងោកទាំងឡាយ) និយាយថា៖ "ដោយការប្រើឧបាយកល" ដូច្នេះជាដើម (លេខ ១៤) ។

លំដាប់នោះ, ខ្ញុំបាទ (**ទីឃ៏មុខ**) និយាយរួតប្រាប់ក្ងោកទាំងឡាយនោះថា៖ "រាជហង្សម្ចាស់យើងជាស្តេចមានតេជានុភាព មានសក្តានុភាព ព្រមទាំងមានសមត្ថភាពបរិបូណ៌ផង គួរនឹងបានសោយរាជ្យគ្រប់គ្រងត្រៃលោកនេះទៅទៀត នឹងនិយាយថ្វី សព្វបើរាជសម្បត្តិលើផែនដីនេះ" ។ កាលនោះក្ងោកជេរប្រទេចខ្ញុំបាទថា៖ "នែអាកុកព្រហើន! បើគ្រាន់បើណាស់ ម្តេចអាឯងមកកាន់ទឹកដីយើងនេះធ្វើអ្វី?" ជេរហើយចាប់ខ្ញុំបាទនាំយកទៅកាន់សំណាក់ស្តេចក្ងោកឈ្មោះ**ចិត្រពណ៌** ។ កាលទៅដល់ចំពោះមុខស្តេចក្ងោកហើយ ក្ងោកជាបរិវារលើកទសករប្រណម្យថ្វាយបង្គំ ទើបបង្ហាញខ្ញុំបាទប្រាប់ស្តេចក្ងោកថា៖ "ទេវៈ! សូមលោកម្ចាស់ជ្រាប អាកុកព្រហើននេះវាមកកាន់ប្រទេសយើង ហើយវាហ៊ានក្បត់ព្រះចេស្តានៃព្រះបាទ!" ។ ស្តេចក្ងោកសួរថា៖ "ចុះអាកុកនេះ វាជាអ្វី? វាមកពីណា?" ។ ក្ងោកជាបរិវារទាំងឡាយប្រាប់ថា៖ "អាកុកនេះជាចារបុរសនៃរាជហង្ស**ហិរណ្យគភ៌** វាមកពីកប៉ូរទ្វីប ។ គ្រានោះឯង, ត្មាតឈ្មោះ**ទុរទសី** ជាប្រធានរដ្ឋមន្ត្រីនៃស្តេច**ចិត្រពណ៌** សួរខ្ញុំបាទថា៖ "អ្នកណាជាប្រធានរដ្ឋមន្ត្រីក្នុងប្រទេសឯង?" ។ ខ្ញុំបាទឆ្លើយប្រាប់ថា៖ "**ចាក្រពាក**ឈ្មោះ**សវិជ្ញ:**ជាអ្នកដល់នូវត្រើយនៃវិទ្យាសាស្ត្រទាំងអស់" ។ ត្មាតនិយាយតទៅថា៖ "ថាបើ**ចាក្រពាក**ឈ្មោះ**សវិជ្ញ:**នេះកើតក្នុងប្រទេសនោះមែន សមគួរនឹងកាន់តំណែងជាប្រធានរដ្ឋមន្ត្រីហើយ, ព្រោះថា៖

១៦- កើតក្នុងប្រទេសខ្លួន ប្រព្រឹត្តល្អបរិសុទ្ធតាមវង្សត្រកូល មានចិត្តស្អាត ស្ទាត់ជំនាញក្នុង

សាស្ត្រ មានអាថ៌កំបាំង មិនតាំងខ្លួនជាអ្នកលេងល្បែងភ្នាល់ វៀរមិនប្រព្រឹត្តបរទារកម្ម ។

១៧- ព្រះរាជាគួរគប្បីស្វែងរកមន្ត្រី ជាអ្នកចេះចាំធម្មសាស្ត្រ និងអថ៌សាស្ត្រ ជាអ្នកមានពូជជានាម៉ឺនធំ មាននាមល្បីល្បាញ ជាបណ្ឌិត ជាអ្នកបង្កើតទ្រព្យសម្បត្តិ" ។

ក្នុងលំដាប់នោះ សេកជាមន្ត្រី និយាយប្រាប់ស្ដេចក្ងោក**ចិត្រពណ៌**ទៀតថា៖ "ទេវៈ! កប៉ូរទ្វីបនិងទ្វីបទាំងឡាយឯទៀត គ្រាន់តែជាកោះតូចតាចទេ ហើយនៅក្នុងបរិវេណអាណាចក្រជម្ពូទ្វីបទាំងអស់ដូច្នេះ ។ ទ្វីបទាំងឡាយនេះនៅក្នុងអធិបតេយ្យព្រះទេវៈបាទទាំងអស់" ។ ស្ដេចក្ងោកឈ្មោះ**ចិត្រពណ៌** និយាយចាក់បណ្ដោយដោយល្មោភថា "អើ! ពិតដូចឯងនិយាយមែន, ព្រោះថា៖

១៨- ព្រះរាជា ១, មនុស្សឆ្កួត ១, កូនក្មេង ១, អ្នកបរិភោគកាម ១, តែងចង់បានរបស់ដែលខ្លួនមិនទាន់បាន ចាំបាច់និយាយថ្វីដល់របស់ដែលខ្លួនបានហើយ" ។

កាលនោះ, ខ្ញុំបាទ (**ទីឃ៌មុខ**) ឆ្លើយតបថា៖ "ថាបើគ្រាន់តែថា ឬគ្រាន់តែនិយាយ ហើយបានសម្រេចអធិបតេយ្យដូចមាត់មែននោះ ខ្ញុំបាទក៏ចេះនិយាយដែរថា៖ "ជម្ពូទ្វីបទាំងមូលនៅក្នុងអំណាចស្ដេចម្ចាស់ខ្ញុំបាទឈ្មោះ**ហិរណ្យគភ៌**ទាំងអស់" ។ សេកសួរមកខ្ញុំបាទវិញភ្លាមថា៖ "ធ្វើមធ្យោបាយដូចម្ដេច នឹងឲ្យសម្រេចប្រស្នានេះបាន?" ។ ខ្ញុំបាទឆ្លើយតបពាក្យសេកវិញថា៖ "ធ្វើសង្គ្រាម" ។ កាលនោះស្ដេចក្ងោក**ចិត្រពណ៌**និយាយប្រាប់ខ្ញុំបាទថា៖ "ឯងត្រឡប់ទៅប្រាប់ម្ចាស់ឯងវិញទៅឲ្យរៀបចំសេនាខ្សោនុភាពត្រៀមចាំចុះ" ។ ខ្ញុំបាទនិយាយថា៖ "សូមលោកបញ្ជូនទូតទៅចរចាជាមួយលោកម្ចាស់ខ្ញុំសិន" ។ ពេលនោះ ស្ដេចក្ងោក**ចិត្រពណ៌** បែរទៅប្រឹក្សាចំពោះមន្ត្រីទាំងឡាយថា៖ "តើនឹងតែងតាំងអ្នកណាជាទូត? ព្រោះទូតគួរចេះការ និងឲ្យមានលក្ខណៈសម្បត្តិដូច្នេះ,

១៩- មានភក្ដី មានគុណ បរិសុទ្ធល្អ ប្រសប់វាងវៃ ឆ្លៀវឆ្លាត និងមានប្រតិភាន បុគ្គលបែបនេះគួរធ្វើជាទូត" ។

ត្មាតឆ្លើយថា៖ "បុគ្គលមានលក្ខណៈដូច្នេះមានច្រើនណាស់ ទោះម្ដេចម្ដា គួរយើងតែងតាំងព្រាហ្មណ៍ ឲ្យធ្វើជាទូតទៅចរចា, ព្រោះថា៖

២០- ធ្វើសេចក្ដីជ្រះថ្លា (ធ្វើឲ្យចម្រើន) ដល់ម្ចាស់ផែនដីមិនប្រាថ្នាចង់បានសម្បត្តិ ដូចថ្នាំពិសពុលឈ្មោះ កាលកូដៈ ([១]) មិនប្រាសចាកពណ៌ខ្មៅ ជាប់នៅក្រពះឥសូរជានិច្ច" ។

ក្ងោក**ចិត្រពណ៌**បង្គាប់សេកថា៖ "នែសេក! ឯងចូរទៅ, ឯងចូរទៅជាមួយ**ទីឃ៌មុខ**នេះ ហើយ

---

[១] ថ្នាំពិសពុលដែលកើតពីការកូរសមុទ្រទឹកដោះ នៅជាប់នឹងក ព្រះឥសូរមានពណ៌ខ្មៅ មិនប្រឡាក់កព្រះឥសូរ ហើយជាគ្រឿងលម្អព្រះឥសូរ ឯព្រាហ្មណ៍ ជាអ្នកទាល់ក្រនៅរួមជាមួយស្ដេចដែលមានទ្រព្យច្រើន ក៏មិនត្រូវការចង់បានទ្រព្យស្ដេច ។

និយាយប្រាប់ម្ចាស់គេថា យើងរៀបទ័ពត្រៀមព្រមហើយ" ។ សេកទទួលអាជ្ញាថា "ទេវៈ! ខ្ញុំបាទទទួលតាមអាជ្ញាហើយ តែកុក**ទីឃមុខ**នេះជាសត្វទុជ៌ន ខ្ញុំបាទទៅជាមួយផងមិនបានទេ, ព្រោះថា៖

២១- មនុស្សទុជ៌ន ប្រព្រឹត្តអំពើអាក្រក់ ផលអាក្រក់តែងធ្លាក់ទៅលើមនុស្សល្អវិញ ([១]) ដូចរាពណ៍ទៅលួចនាងសីតា (ផលអាក្រក់របស់រាពណ៍នេះធ្លាក់ទៅលើសមុទ្រ) គឺសមុទ្រត្រូវព្រះរាមចងថ្នល់ ។

២២- បុគ្គលមិនគប្បីស្ថិតនៅ ឬមិនគប្បីដើរទៅជាមួយមនុស្សទុជ៌នឡើយ ក្នុងកាលណាក៏ដោយ, ហង្សស្លាប់ព្រោះស្ថិតនៅជាមួយ ទទាស្លាប់ព្រោះដើរទៅជាមួយ ទាំងអស់នេះមកតែពីសមាគមមួយអន្លើដោយក្អែក ។

ក្ងោក**ចិត្រពណ៌**សួរឡើងថា៖ "ចុះរឿងនោះតើដូចម្តេច?" ។

សេកដំណាលរឿងនោះប្រាប់ដូចតនេះថា៖-

# កថាទី៥

## រឿងហង្ស និងក្អែក

នៅតាមផ្លូវធំទៅកាន់ក្រុងឧជ្ជយិនី មានដើមបិប្បលៈមួយដើមមានមែកទ្រលឹងទ្រឡៃ ។ សត្វហង្ស និងក្អែកអាស្រ័យនៅលើដើមឈើនោះ ។ នៅក្នុងរដូវក្តៅ មានអ្នកដំណើរម្នាក់ដើរមកដល់អស់កម្លាំងណាស់ ឃើញម្លប់ត្រជាក់ស្រួល ដាក់ធ្នូ និងសរក្បែរគល់ឈើប្រាស់ខ្លួនដេកលន់លក់ទៅ ។ ក្រោយបន្តិចមកម្លប់ដើមឈើនោះរេបែរឃ្លាតចេញពីមុខអ្នកដំណើរនោះ ។ កាលនោះហង្សទំនៅលើដើមឈើនោះក្រឡេកទៅឃើញមុខអ្នកដំណើរចាំងដោយកំដៅព្រះអាទិត្យ កើតមានចិត្តល្អ ជាចិត្តបុណ្យដ៏ក្រជាក់ត្រជុំទើបកាងស្លាបខ្លួនបាំងកំដៅព្រះអាទិត្យឲ្យម្លប់ទៅចំមុខអ្នកដំណើរនោះដោយចិត្តអាណិត ។ រីអ្នកដំណើរកំពុងអស់កម្លាំងខ្លាំង បានម្លប់ត្រជាក់ស្រួល ក៏ដេកលក់ស៊ុបច្រហមាត់ផ្ហុង ។ គ្រានោះឯង, ក្អែកដែលនៅជាមួយគ្នា ជាសត្វមានចិត្តអាក្រក់ជាសភាពទុជ៌នពីកំណើត តែងច្រណែនជនដទៃជានិច្ច មិនចង់ឲ្យគេបានសេចក្តីសុខសោះ ក៏បន្ទោបង់អាចម៍ខ្លួនឲ្យធ្លាក់ទៅចំប៉ាច់ក្នុងមាត់នៃអ្នកដំណើរនោះ ហើយហើរចេញបាត់ទៅភ្លាម ។ អ្នកដំណើរត្រូវអាចម៍ក្អែកស្អុយមួយដុំចំមាត់ ភ្ញាក់ណាស់ក្រោកគ្រទឹគ្រទាឡើងក្រឡេកមើលទៅលើ ឃើញតែហង្ស មិនឃើញក្អែក ក៏ចាប់ទាញធ្នូមកហើយបាញ់តម្រង់ទៅត្រូវស្លាប់ទៅហោង, ហេតុនោះហើយបានជាខ្ញុំ (សេក) ពោលថា៖ "បុគ្គលមិនគប្បីស្ថិតនៅ" ដូច្នេះជាដើម (លេខ

---

[១] កាលរាពណ៍លួចនាងសីតាយកទៅទុកនៅក្រុងលង្កា ព្រះរាមចងថ្នល់ឆ្លងសមុទ្រលើកសេហ៍ពលទៅវាយក្រុងលង្កាបែក ។

២២) ។ សេករៀបរាប់តទៅទៀត ([២]) ថា៖ “ទេវៈ! ខ្ញុំបាទនឹងនិយាយរឿងក្អែក និងទទាតទៅទៀត, សូមលោកម្ចាស់ប្រុងស្តាប់៖-

# កថាទី៦

## រឿងក្អែក និងទទា

ក្អែក និងទទាអាស្រ័យនៅលើដើមឈើជាសុខសប្បាយ ។ ថ្ងៃមួយ បក្សីទាំងឡាយបបួលគ្នាហិចហើរទៅកាន់ត្រើយសមុទ្រ ដើម្បីទៅគោរពគ្រុឌជាស្តេចបក្សីដ៏មានបុណ្យ ។ កាលនោះ ទទាធ្វើដំណើរជាមួយនឹងក្អែកដល់ពាក់កណ្តាលផ្លូវ ទៅជួបនឹងគោបាលម្នាក់ទូលភាជន៍ទឹកដោះលើក្បាល ក្អែកហើរទៅលបផក់ទឹកដោះនោះស៊ីរឿយៗ ។ គោបាលក្នាញ់ណាស់ ដាក់ភាជន៍ទឹកដោះលើនៅដី ក្រឡេកមើលទៅលើអាកាសឃើញក្អែក និងទទា ក៏រត់ដេញតាម ។ ក្អែកកាលដឹងខ្លួនថាគោបាលបានឃើញខ្លួនហើយ ក៏ហើរបាត់ទៅភ្លាម ។ ឯទទា ជាសត្វល្ងង់ខ្លៅ ដឹងខ្លួនថាមិនមានកំហុស មិនហើរទៅណាឆ្ងាយ ត្រូវគោបាលចាប់សម្លាប់ចោលបង់សៀតទៅហោង, ព្រោះហេតុនោះបានជាខ្ញុំ (សេក) ពោលថា “មិនគប្បីដើរទៅជាមួយ” ដូច្នេះជាដើម (លេខ២២) ។ កាលនោះ ខ្ញុំបាទ (**ទីឃ៌មុខ**) និយាយតបទៅកាន់សេកថា៖ “នែបងសេក! បងសេកម្តេចក៏និយាយយ៉ាងនេះ? រូបបងនឹងរូបខ្ញុំពីរនាក់នេះទុកដូចជារូបម្ចាស់ផែនដីដ៏មានបុណ្យមួយព្រះអង្គ ។ បងមិនគួរនិយាយបង្អាក់ដូច្នេះទេ” សេកឆ្លើយតបមកវិញថា៖ “ពិតដូចកុកនិយាយហើយ តែថា៖

២៣- ពាក្យដែលទុជ៌នពោល សូម្បីនិយាយញញឹមស្រស់ពីរោះផ្អែមដូចជាផ្ការីកពុំជួកាល ក៏អាចនឹងញុំាងភ័យឲ្យកើតឡើងបាន ។

សម្តីបងកុកនិយាយចេញមកនេះនាំឲ្យឃើញច្បាស់ហើយ ថាជាទុជ៌នស្រេចទៅហើយ ឯសម្តីដែលជាហេតុដើមនុ៎ះ គឺសម្តីដែលនិយាយនាំឲ្យព្រះរាជាទាំងពីរព្រះអង្គធ្វើសឹកសង្គ្រាមនឹងគ្នានេះឯង បងមើល!

២៤- វីទោសដែលបុគ្គលធ្វើឲ្យឃើញប្រត្យក្សហើយ មនុស្សល្ងង់នៅតែពេញចិត្តស្ងប់ស្ងៀមដោយគ្រាន់តែគេនិយាយពាក្យពីរោះផ្អែមប៉ុណ្ណោះ ដូចរឿងជាងរថទូលភរិយាលើក្បាល ព្រមទាំងសហាយភរិយាផង ។

---

[២] ហិតោបទេស សេចក្តីប្រែជាភាសាសៀមនៃលោកនាគប្រទីបមានគាថាដូច្នេះគឺ៖ ចូរវៀរការនៅច្រឡំបល់ជាមួយទុជ៌ន តែត្រូវសមាគមដោយសប្បុរស ចូរបំពេញបុណ្យទោះថ្ងៃទោះយប់ ចូររំឮកការមិនទៀងជានិច្ច ។

ក្អែកចិត្រពណ៌សួរថា៖ "ចុះរឿងនោះដូចម្ដេច?" ។ សេកនិយាយរៀបរាប់រឿងនោះ ដូចសេចក្ដីតទៅនេះថា៖

# កថាទី៧

## រឿងជាងរថ ភរិយា និងសហាយ

នៅយៅវនស្រីនគរ មានជាងរថម្នាក់ឈ្មោះមន្ទមតិ ។ មន្ទមតិដឹងច្បាស់ថាភរិយាខ្លួនផិតប្រាកដ តែមិនទាន់មានភស្ដុតាង គឺមិនទាន់ឃើញសហាយភរិយាស្ថិតនៅក្នុងទីជាមួយគ្នាជាក់ច្បាស់នៅឡើយ ។ ថ្ងៃមួយ ជាងរថឈ្មោះ មន្ទមតិ និយាយប្រាប់ភរិយាថា ខ្លួនមានដំណើរទៅកាន់ស្រុកដទៃ និយាយរួចហើយ ដើរចេញទៅ ។ មន្ទមតិ ធ្វើជាដើរទៅមិនបានប៉ុន្មាន ក៏ត្រឡប់វិលមកវិញ លបចូលទៅលាក់ខ្លួនពួនអាត្មានៅក្រោមគ្រែដោយស្ងាត់ៗ ។ សហាយភរិយាដឹងច្បាស់ថា ជាងរថចេញទៅកាន់ស្រុកក្រៅបាត់ហើយ ដល់ពេលសន្ធិយារាត្រី ក៏ចូលទៅដេកជាមួយភរិយាជាងរថ ។ ឯស្រីចិត្តចើក កាលប្រឡែងលេងជាមួយសហាយជាទីស្រឡាញ់ដោយសេចក្ដីស្នេហា យ៉ាងក្រៃលែងនៅលើគ្រែ ក្នុងទីកំបាំងនោះ បានទម្លាក់ដៃទៅខាងក្រោម ទៅប៉ះនឹងមនុស្សដែលដេកនៅក្រោមគ្រែនោះ ដឹងច្បាស់ថាជាប្ដីខ្លួនមកដេកបន្លំ ក៏ស្រងាកព្រួយចិត្ត ។ សហាយ កាលឃើញស្រីសហាយខ្លួនមិនសូវអើពើដូចសព្វដង សាកសួរទៅថា៖ "ថ្ងៃនេះ, ហេតុដូចម្ដេចក៏អូនមិនសូវអើពើលេងសប្បាយជាមួយបង? បងមើលទៅឃើញថា អូនបែបដូចជានឹកព្រួយចិត្តរឿងអ្វីមួយ" ។ ស្រីចិត្តចើកនោះឆ្លើយប្រាប់ថា៖ "បង! បងមិនដឹងថា ស្វាមីជាម្ចាស់ជីវិតខ្ញុំគាត់មិននៅថ្ងៃនេះឬអ្វី? គាត់ចេញទៅស្រុកក្រៅហើយ ក្នុងពេលដែលគាត់ចេញទៅនេះ នៅក្នុងផ្ទះសូម្បីមានមនុស្សពេញណែនណាន់តាន់តាប់ ខ្ញុំក៏ឃើញហាក់ដូចជាស្រឡះល្ហល្ហេវស្ងាត់សូន្យឈឹង, ស្វាមីខ្ញុំទៅកាន់ស្រុកគេ ប្លែកទឹកប្លែកដី មិនដឹងជាគាត់នឹកស្រងេះស្រងោចដូចម្ដេចទៅអេះ បានអ្វីបរិភោគអាស្រ័យដំណេកនៅឯណា ខ្ញុំឥតដឹងឥតយល់សោះ ខ្ញុំគិតទៅៗឃើញដូច្នេះហើយចិត្តខ្ញុំក៏រលឹកស្រណោះអាឡោះអាល័យ ហើយអណ្ដែតអណ្ដូងទៅបាត់ពីរូបរាងកាយខ្ញុំ" ។ សហាយនិយាយឡកឡឺយថា៖ "ចុះជាងរថប្ដីនាងចេះស្នៀតស្នេហាចំណានដូចម្ដេចទៅ?" ។ ស្រីចិត្តចើកធ្វើជាក្រោកឆ្លើយថា៖ "នែអាគម្រក់ចង្រៃ! អ្វីអាឯងប៉ាននិយាយដូច្នេះ? ឯងស្ដាប់មើល!៖

២៥- នារីណាប្ដីជេរប្រទេចក្ដី ឬប្ដីសម្លឹងសម្លក់ដោយក្ដីក្រោធក្ដី នៅតែធ្វើទឹកមុខស្រស់ស្រាយញញឹម នារីនោះទើបឈ្មោះថា ស្រីមានលក្ខណ៍ ។

២៦- ស្រីណា ស្រឡាញ់ប្ដី ទោះជាប្ដីនៅក្រុង ឬនៅស្រុកព្រៃ ឬពុំនោះទេ ជាប្ដីគ្មានបុណ្យ ឬមាន

បុណ្យក្តី ស្រីនោះទើបលោកទាំងមូលឲ្យសេចក្តីសុខ ។

២៧- សេចក្តីពិត, ភស្តាជាគ្រឿងអលង្ការនៃនារីទាំងឡាយ នារីឥតភស្តា ឈ្មោះថាមិនមានគ្រឿងអលង្ការ បើទុកជាមានរូបល្អ ក៏មិនឈ្មោះថាមានរូបល្អដែរ ។

ឯងគ្រាន់តែជាសហាយ មានចិត្តអាក្រក់ក្រឡិចក្រឡុចដូចជាផ្កាស្លា គេត្រូវការលេងតែមួយគ្រា ឯភស្តាវិញជាម្ចាស់ជីវិតអញ បើគាត់ចង់លក់ គាត់លក់អញទៅឲ្យទេពតា ឬក៏ឲ្យអញទៅដល់ព្រាហ្មណ៍ ក៏សឹងតែបាន តែចាំបាច់និយាយបូរបាច់ច្រើនធ្វើអ្វី, បើភស្តាអញមានជីវិតរស់នៅ អញក៏មានជីវិតរស់នៅដែរ ថាបើគាត់ធ្វើមរណកាល អញក៏សុខចិត្តស្លាប់ទៅតាម នេះជាសេចក្តីប្តេជ្ញារបស់អញ, ព្រោះថា៖

២៨- លោមជាតិ ដែលស្ថិតនៅនឹងរូបនរជនមានចំនួន ៣៥ កោដិ ឯនារីដែលស្លាប់ទៅតាមប្តី បានទៅកើតក្នុងសួគ៌ក៏មានចំនួនច្រើនដូចលោមជាតិដែរ ។

២៩- អាលម្ពាយ ចាប់ពស់ទាញចេញពីរូងបានយ៉ាងណា ភរិយាដែលស្លាប់ទៅតាមភស្តា អាចនាំភស្តាខ្លួន (ពីនរក) ទៅកាន់ឋានសួគ៌បានយ៉ាងនោះដែរ ។

៣០- ([១]) នារីណាស្រឡាញ់ប្តី ក្បៀកឱបប្តីស្លាប់ជាប់នឹងខ្លួន លះបង់ខ្លួនចូលក្នុងគំនរភ្លើងជើងថ្ករជាមួយប្តី នាងនារីនោះសូម្បីធ្វើបាបរាប់ទាំងសែនឆ្នាំ ក៏អាចនាំភស្តាខ្លួនទៅកាន់សុរលោក (ឋានសួគ៌) បាន" ។

កាលនោះ ជាងរថបានស្តាប់ភរិយានិយាយសព្វអស់អាថ៌សេចក្តី គិតក្នុងចិត្តថា៖ "អាត្មាអញហៅចំជាមានភ័ព្វមានសំណាងបានប្រពន្ធគ្រប់លក្ខណ៍ ចេះនិយាយពាក្យពីរោះ មានចិត្តស្មោះត្រង់នឹងប្តីប្រាកដដូច្នេះ" គិតដូច្នេះហើយ ក៏លើកទូលគ្រែដែលសហាយនិងភរិយាដេកនោះលើក្បាល លោតរាំកញ្ឆក់កញ្ឆេង ដោយក្តីត្រេកអរខ្លាំង, ព្រោះហេតុនោះហើយ បានជាខ្ញុំបាទ (សេក) និយាយថា៖ "រីទោសដែលបុគ្គលធ្វើឲ្យឃើញប្រត្យក្សហើយ" ដូច្នេះជាដើម (លេខ ២៥) ។

កាលនោះ ស្តេចក្ងោក**ចិត្រពណ៌** ទទួលស្គាល់ខ្ញុំបាទពេញកិត្តិយសថាជាទូត ហើយបណ្តោយឲ្យខ្ញុំបាទវិលត្រឡប់មកវិញ ព្រមទាំងឲ្យសេកជាទូតមកតាមខ្ញុំបាទផង" ។ ឥឡូវនេះ, បើលោកម្ចាស់បានជ្រាបសេចក្តីរហូតហើយ កិច្ចការណាដែលគួរចាត់ចែង ក៏សូមលោកម្ចាស់ត្រិះរិះមើលទៅចុះ ។ **ចាក្រពាក**ជាប្រធានរដ្ឋមន្ត្រីសើចសាសហាយ ហើយនិយាយ៖ "ទេវៈ! បងកុកធ្វើដំណើរចេញទៅបរទេស

---

[១] ហិតោបទេស សេចក្តីប្រែជាភាសាបារាំងនៃលោកឡង់ស៊ឺរ៉ូ និងសេចក្តីប្រែជាភាសាសៀមនៃលោកនាគប្រទីបមានគាថាលើសដូច្នេះ បិតា ឬបងប្រុសដែលបានទទួលបង្គាប់ពីបិតា ហើយបានឲ្យនាងនារីទៅជាភរិយានរជនណាហើយ នាងនារីត្រូវស្តាប់បង្គាប់ប្តីនោះមិនត្រូវក្បត់ចិត្ត ទោះរស់នៅក្តី ឬស្លាប់បាត់បង់ទៅហើយក្តី ។

ហើយត្រឡប់មកវិញ ចេះចាត់ចែងកិច្ចការរាជការស្រេចតាមសមត្ថភាព តែថាការចាត់ចែងរាជការដូច្នេះ ជាវិធីមនុស្សល្ងង់ទេ, ព្រោះថា៖

៣១- គួរគប្បីឲ្យមួយរយ តែមិនគួរធ្វើឲ្យកើតវិវាទជាមួយទេ នេះជាមតិអ្នកប្រាជ្ញ, សូម្បីមិនមានមូលហេតុអ្វីជាមាំមួន ហើយក៏ធ្វើវិវាទដែរ នេះជាលក្ខណៈមនុស្សល្ងង់ទេ” ។

រាជហង្ស**ហិរណ្យគភ៌**ឆ្លើយកាត់ឡើងថា៖ “បន្ទោសរឿងដែលកន្លងទៅហើយ តើមានប្រយោជន៍អ្វី? គួរជួយត្រិះរិះពិចារណាគ្នាមើលរឿងបច្ចុប្បន្ននេះវិញ ។ **ចាក្រពាក**និយាយថា ទេវៈ! ខ្ញុំបាទសូមជម្រាបរឿងនេះក្នុងទីសម្ងាត់, ព្រោះថា៖

៣២- អ្នកប្រាជ្ញអាចស្ទង់មើលចិត្តនៃជនដទៃដោយទឹកមុខ, អាការសំឡេង, វិការនៃភ្នែក និងវិការនៃមុខបាន ព្រោះដូច្នោះ គួរប្រឹក្សាគ្នាក្នុងទីស្ងាត់” ។

កាលនោះឯង, ហង្ស**ហិរណ្យគក៏** និង**ចាក្រពាក** ស្ថិតនៅក្នុងទីនោះតែពីរនាក់ សត្វទាំងឡាយជាបរិវារដទៃទៀតដឹងទំនងដូច្នេះ ក៏ថយគេចចេញទៅក្រៅអស់ ។ **ចាក្រពាក** និយាយប្រាប់ហង្ស**ហិរណ្យគក៏**ថា៖ “ទេវៈ! ខ្ញុំបាទមានសេចក្តីយល់ឃើញថា ប្រព្រឹត្តិហេតុដែល**ទីឃ៌មុខ**បានធ្វើឲ្យកើតឡើងនេះប្រហែលជាមានបរិវារយើងខ្លះជាអ្នកញុះញង់ឲ្យធ្វើទេដឹង, ព្រោះថា៖

៣៣- មនុស្សឈឺឲ្យសេចក្តីសុខចម្រើនដល់ពេទ្យ មនុស្សមានវិបត្តិគ្រោះថ្នាក់ ឲ្យសេចក្តីសុខចម្រើនដល់មន្ត្រី មនុស្សល្ងង់ជាការរស់នៅនៃអ្នកប្រាជ្ញ វណ្ណៈល្អទាំងឡាយ ជាការរស់នៅនៃសប្បុរសទាំងឡាយ [១] ។

រាជ្យហង្ស**ហិរណ្យគក៏**ឆ្លើយតបថា៖ “ដូច្នេះក៏ធ្លាប់មានដែរ តែរឿងនេះយើងទុកចាំស៊ើបអង្កេតរកមូលហេតុឲ្យឃើញក្នុងកាលជាខាងក្រោយចុះ, ពេលនេះ, យើងត្រូវធ្វើដូចម្តេច? បើត្រូវធ្វើយ៉ាងណាត្រូវចាត់ចែងដូច្នោះភ្លាមៗឲ្យទាន់ពេល ។ **ចាក្រពាក**ឆ្លើយថា៖ “ទេវៈ! យើងគួរបញ្ជូនចារបុរសឲ្យចូលទៅដល់ទីឋានសត្រូវ ត្រូវឲ្យដឹងថា សត្រូវមានកម្លាំង ឬឥតកម្លាំង ដូចម្តេចឲ្យដឹងមុនសិន, ព្រោះថា៖

៣៤- គួរប្រើចារបុរសក្នុងការស៊ើបអង្កេតឲ្យបានដឹងសេចក្តីថា ការគួរធ្វើ និងមិនគួរធ្វើក្នុងប្រទេសខ្លួន ឬក្នុងបរទេស, ព្រោះចារបុរសជាព្រះនេត្រានៃព្រះរាជា, ព្រះរាជាអង្គណាមិនមានសូម្បីតែម្នាក់ ព្រោះរាជាអង្គនោះទុកដូចជាមនុស្សខ្វាក់ពិតៗ ។ ត្រូវចាត់កុក**ទីឃ៌មុខ**នេះជាចារបុរសឲ្យនាំយកមនុស្សម្នាក់ដែលទំនុកទុកចិត្តទៅជាមួយជួយធ្វើការផង កាលបើស៊ើបសួរមើលដឹងការប្រឹក្សា ឬប្រព្រឹត្តិការណ៍

---

[១] ត្រង់បាតទី ៤ នេះក្នុងច្បាប់ខ្លះថា “បរិពារព្រះរាជា អាចនាំឲ្យកើតវិវាទបាន” ។

នៃសត្រូវនៅក្នុងប្រទេសគេនោះហើយ ខ្លួនឯងត្រូវនៅក្នុងប្រទេសគេនោះចុះ តែត្រូវប្រើឱ្យអ្នកទីពីរដែលនាំជាជំនួយនោះនាំយកការសម្ងាត់ ដែលស៊ើបបានមកប្រាប់យើងដោយសម្ងាត់ជាបំផុត, ព្រោះថា៖

៣៥- ព្រះរាជា ត្រូវបង្គប់ចារបុរសប្រើឱ្យយកភេទជាតបស ឱ្យចូលទៅដើម្បីសិក្សាសាស្ត្រវិជ្ជាក្នុងបុណ្យស្ថាន ក្នុងអាស្រម ឬក្នុងទេវស្ថានផ្សេងៗ ។

ចារបុរសនៃការសម្ងាត់នេះ ក៏ត្រូវរកមនុស្សសំខាន់ ដែលទៅផ្លូវទឹកក៏បានផ្លូវគោកក៏បាន ដូច្នេះបានជាត្រូវចាត់ឱ្យ**ទីឃ័មុខ**នេះទៅ ហើយត្រូវរកកុកមួយទៀតឱ្យបានជាគ្នាជូនទៅផង ព្រមទាំងយកកុកមួយក្នុងផ្ទះ**ទីឃ័មុខ**ឱ្យមកធ្វើជាទ្វាបាលរក្សាព្រះរាជវាំងជំនួសផង តែការនោះត្រូវធ្វើឱ្យស្ងាត់ដែលនឹងអាចស្ងាត់បាន, ព្រោះថា៖

៣៦- មន្ត្រី គឺការសម្ងាត់នេះ បើដឹងដល់ត្រចៀក ៦ ហើយ តែងបែកធ្លាយ ហើយខ្ចរខ្ចាយចេញទៅដោយការនិយាយតៗគ្នា ហេតុនេះព្រះរាជាគប្បីរក្សាការសម្ងាត់បាន ចំពោះតែរូបព្រះអង្គនឹងមនុស្សជាគម្រប់ពីរប៉ុណ្ណោះ ។

៣៧- កាលបើមន្ត្រី គឺការសម្ងាត់ធ្លាយហើយ ទោសតែងធ្លាក់ស្រោចមកលើព្រះរាជា ទោសនោះបុគ្គលមិនអាចកែសម្រួលបានងាយទេ នេះជាមតិអ្នកនយោបាយ" ។ ហង្ស**ហិរណ្យគក៏** ត្រិះរិះពិចារណាមួយស្របក់ហើយនិយាយថា៖ "អើ! ចារបុរសធ្វើការសម្ងាត់ប្រសើរដូច្នេះយើងរកបានហើយ" ។ ក្នុងលំដាប់នោះ បក្សីរក្សាព្រះអង្គចូលទៅលើកហត្ថប្រណម្យហើយជម្រាបថា៖ "ទេវៈ! សូមជ្រាប សេកដែលមកពីជម្ពូទ្វីបនោះ ឥឡូវនេះស្ថិតរង់ចាំនៅមាត់ទ្វារ" ។ ហង្ស**ហិរណ្យគក៏** ក្រឡេកមើលមុខ**ចាក្រពាក**ៗ ក៏វាងវៃទាន់ភ្លាមនិយាយថា៖ "ចូរបង្គាប់ឱ្យគេនាំសេកទៅរង់ចាំនៅសាលចាំមួយស្របក់សិន សឹមឱ្យគេនាំមកជួបនឹងលោកជាម្ចាស់" ។ អ្នករក្សាព្រះអង្គទទួលបង្គាប់ហើយ ក៏នាំសេកជារាជទូតចេញទៅរង់ចាំ ។ ហង្ស**ហិរណ្យគក៏**តក់ស្លុតនិយាយថា៖ "គួរឱ្យនឹកបារម្ភណាស់ ក្រែងសង្គ្រាមនឹងផ្ទុះឆេះឡើង" ។ **ចាក្រពាក**ឆ្លើយតបថា៖ "ទេវៈ! ការធ្វើសង្គ្រាមភ្លាមៗ មិនមែនជាវិធីល្អទេ ព្រោះថា៖

៣៨- ក្នុងការផ្តើមធ្វើសង្គ្រាម សេវកណាមិនមានការពិចារណាម៉ត់ចត់ ដឹកនាំឱ្យព្រះរាជាធ្វើសង្គ្រាម ឬឱ្យលះបង់ប្រទេសជាតិចោល សេវកនោះសមជាអាមាត្យឬទេ? សមជាមន្ត្រីឬទេ?

៣៩- ក្នុងកាលណាក៏ដោយ ព្រះរាជាគប្បីព្យាយាមយកជ័យជម្នះចំពោះសត្រូវដោយការមិនច្បាំងឱ្យបាន ព្រោះកាលបើអ្នកទាំងពីរខាងច្បាំងតយុទ្ធគ្នាហើយ គេមិនសូវឃើញជ័យជម្នះទៀងទាត់ទេ ។

៤០- ក្នុងកាលណាក៏ដោយ ព្រះរាជាគប្បីយកឈ្នះសត្រូវដោយការផ្សះផ្សាខ្លះ ដោយការបែង

ចែកឲ្យខ្លះ ដោយប្រើឧបាយបំបែកសាមគ្គីខ្លះ គប្បីប្រើឧបាយទាំងនេះ ឬប្រើឧបាយណាមួយៗ ធ្វើដូចម្ដេចកុំឲ្យកើតសង្គ្រាមបាន ។

៤១- ជនទាំងឡាយដែលមិនធ្លាប់ចូលសង្គ្រាម តែងអួតអាងថាខ្លួនក្លៀវក្លា នរណាមួយដែលមិនទាន់ឃើញសមត្ថភាពនៃសត្រូវទេ ម្ដេចឡើយនឹងមិនឡើងចិត្តទ្រនង់?

៤២- បុគ្គលមិនគប្បីអាចគាស់លើកដុំថ្មតាន់ ដោយកម្លាំងមនុស្សបានស្មើដោយការប្រើកំណាត់ឈើទេយ៉ាងណា ដោយការប្រើឧបាយតែបន្តិច គេបានសម្រេចប្រយោជន៍ធំយ៉ាងនោះ, នេះហើយការប្រឹក្សារកឧបាយមានផលធំណាស់ដូច្នេះ ។

៤៣- កសិកម្មដែលបានផលល្អ មកពីគេប្រកបព្យាយាម ធ្វើល្អម៉ត់ចត់ទៅតាមកាលវេលាយ៉ាងណា ទេវៈ នយោបាយនេះគេធ្វើដោយម៉ត់ចត់ ហើយអស់កាលយូរផងទើបបានផល មិនមែនធ្វើកញ្ឆក់កណ្ដៀតទេ យ៉ាងនោះដែរ ។

តែកាលណាគេឃើញថាសង្គ្រាមនឹងកើតពិតហើយ គេចមិនរួចទេ ទើបគេត្រូវច្បាំងត, ព្រោះថា៖

៤៤- ភ័យនៅឆ្ងាយមានក្ដីខ្លាច ភ័យមកដល់ជិតមានក្ដីក្លៀវក្លា នេះជាគុណលក្ខណៈមហាបុរស, ក្នុងកាលវិបត្តិនៅនាលោកនេះមហាបុរសតែងសម្ដែងខ្លួនជាអ្នកធីរជន ។

៤៥- មែនពិត ការប្រឹងប្រួសកម្លាំងជាឧបសគ្គធំខាងដើមនៃការសម្រេចសព្វកិច្ចការទាំងអស់ ទឹកស្ទួម្បីត្រជាក់ នឹងមិនទម្លាយភ្នំបានឬអ្វី?

ទេវៈ! មានដំណឹងផ្សេងមួយទៀតថា ស្ដេច**ចិត្រពណ៌**នេះ មានកម្លាំងសែនឡានុភាពធំណាស់, ព្រោះថា៖

៤៦- ការច្បាំងនឹងអ្នកមានកម្លាំងដូច្នេះមិនមានឧទាហរណ៍ទេ មនុស្សច្បាំងតនឹងដំរី ឈ្មោះថានាំម្រឹត្យុមកឲ្យឥតសង្ស័យឡើយ ។

៤៧- នរជនណា មិនទាន់ដល់កាលគួរ ហើយធ្វើសង្គ្រាម អ្នកនោះឈ្មោះថាជាមនុស្សល្ងង់ ព្រោះការច្បាំងតនឹងអ្នកមានកម្លាំងប្រាកដ ដូចជាប្រើស្លាបរុយហោះដូច្នោះ ។

៤៨- នរជនចេះដឹងនីតិសាស្ត្រ (នយោបាយ) ត្រូវនៅក្នុងគ្រឿងការពារដូចអណ្ដើកនៅក្នុងស្នូក ហើយត្រូវចេះអត់ធន់គ្រឿងប្រហារនៃសត្រូវផង កាលបើកាល [១] គួរមកដល់ហើយ គប្បីលោតឡើងតស៊ូដូចពស់មានអាសិរពិស ។

---

[១] ច្រក ផ្លូវ ទំនង ឱកាស ។

៤៩- នរជនចេះនយោបាយ អាចរំលើងឫសគល់សត្រូវទោះធំតូច ឬក៏ប៉ុនគ្នាបាន ដូចខ្សែទឹក អាចនាំយកឈើ ឬស្មៅទាំងឫសទាំងគល់បានដូច្នោះដែរ ។

បើដូច្នេះ, យើងគប្បីយកចិត្តទុកដាក់រក្សាសេកជាទូតនេះទុកក្នុងទីយើងសិន កុំអាលលែងឲ្យចេញទៅ ដរាបទាល់នឹងយើងកសាងបន្ទាយការពារយើងរួចស្រេចហើយសិន, ព្រោះថា៖

៥០- ទាហានធ្នូម្នាក់នៅក្នុងបន្ទាយ សម្លាប់ទាហានសត្រូវបានមួយរយនាក់ ទាហានធ្នូ១០០នាក់ សម្លាប់សត្រូវបាន ១.០០០នាក់ ព្រោះហេតុនោះ ការតាំងបន្ទាយការពារទុកមុន ជាកិច្ចសំខាន់មួយ ។

៥១- ប្រទេសជាតិដែលឥតបន្ទាយការពារ ម្តេចក៏សត្រូវនឹងមិនត្រូវមើលងាយ? ឯព្រះរាជាមិនមានបន្ទាយការពារ ក៏ឥតមានទីពឹងដូចមនុស្សធ្លាក់ពីសំពៅកណ្តាលសមុទ្រ ។

៥២- ([១])គួរកសាងបន្ទាយការពារ ហើយឲ្យមានគូធំៗ មានប្រាការខ្ពស់ៗ មានគ្រឿងយន្ត មានទឹក មានភ្នំ មានទន្លេ វាលខ្សាច់ និងព្រៃ ជាគ្រឿងការពារ ។

៥៣- សម្បត្តិបន្ទាយការពារមាន ៧ ប្រការដូចមានខាងលើនេះ ត្រូវកសាងឲ្យធំមាំ សត្រូវចូលប្រយុទ្ធលំបាកជាបំផុត ត្រូវមានឃ្លាំងដាក់ស្បៀងអាហារទឹកស្រូវអង្ករ ហើយឲ្យមានផ្លូវចេញចូល ។

ហង្សហិរណ្យគក៏ប្រឹក្សាថា៖ “គួរតាំងអ្នកណា ឲ្យចាត់ចែងបន្ទាយការពារត្រៀមទុកទើបបានល្អ?” ។ **ចាក្រពាក**តបថា៖

៥៤- នរជនណាឆ្លាតវាងវៃក្នុងកិច្ចការណា គួរតាំងនរជននោះឲ្យចាត់ចែងការនោះ នរជនដែលមិនធ្លាប់ប្រសប់កិច្ចការទេ សូម្បីចេះដឹងសាស្ត្រវិជ្ជា ក៏រមែងធ្វើការមិនជិតដល់ដែរ ។ បើដូច្នោះ, គួរហៅក្រសារជាសេនាបតីឲ្យចូលមក ។ កាលហៅក្រសារជាសេនាបតីឲ្យចូលមកដល់ហើយ ហង្ស**ហិរណ្យគក៏**បង្គាប់ក្រសារថា៖ “នែក្រសារ! ចូរឯងចាត់ចែងធ្វើបន្ទាយការពារត្រៀមទុកឲ្យសព្វគ្រប់យ៉ាងរហ័ស” ។ ក្រសារសេនាបតីប្រណម្យ ហើយពោលតបទៅវិញថា៖ “ទេវៈ! បន្ទាយការពារនោះខ្ញុំបាទបានចាត់ចែងត្រៀមទុកសព្វគ្រប់ហើយ មានទាំងគូទឹកធំផង តែសូមមានបង្គាប់ឲ្យធ្វើឃ្លាំងសន្សំស្បៀងទុកទៀត, ព្រោះថា៖

[១] ហិតោបទេសសេចក្តីប្រែជាភាសាបារាំងនៃលោកឡង់សឺរ៉ូ មានគាថាលើសដូច្នេះគឺ ក រដ្ឋមន្ត្រី១, ព្រះរាជទ្រព្យ១, ព្រះរាជណាអាចក្រ១, បន្ទាយព្រះអង្គ១, កងពលព្រះអង្គ១, និងព្រះរាជសម្ពន្ធមិត្ត១, ទាំង៧ ផ្នែកនេះ ជាសារវន្តនៃរដ្ឋាភិបាល ។ ខ មេបន្ទាយ១, មេទ័ព១, រដ្ឋមន្ត្រីឃ្លាំង, អគ្គរាជទូត, បុរោហិត១, ហោរាសាស្ត្រ១ និងពេទ្យ១, ទាំង៧នាក់ទុកជាទីប្រឹក្សាព្រះរាជា ។

៥៥- បពិត្រព្រះរាជា! ការប្រមូលគរទុកនូវស្រូវអង្ករជាស្បៀង ប្រសើរជាងប្រមូលទុកទ្រព្យឯទៀត, ព្រោះថា ពេជ្រទទឹមបុគ្គលយកមករក្សាទុកក្នុងមាត់ មិនអាចធ្វើឲ្យជីវិតទ្រទ្រង់នៅបានទេ ។

៥៦- បណ្ដាវត្ថុដែលមានរសជាងគេទាំងអស់ អំបិលគេទុកជាវត្ថុមានរសប្រសើរជាងគេ បុគ្គលគប្បីស្វែងរកអំបិលទុកកុំបីឃ្លាត ព្រោះថាបើឥតអំបិលហើយ សម្លគេទុកដូចគោម័យ ។

ហង្សហិរណ្យគត៌បង្គាប់ភ្លាមថា៖ "នែក្រសារសេនាបតី! ចូរឯងប្រញាប់ប្រញាល់ទៅស្វែងរកស្បៀងយកមកទុកដាក់ឲ្យមានគ្រប់ព្រមកុំបីឲ្យខ្វះខាត" ។ ក្នុងខណៈនោះ បក្សីរក្សាព្រះអង្គចូលមកម្ដងទៀតថ្លែងសេចក្ដីប្រាប់ថា៖ "ទេវៈ! ក្អែកឈ្មោះ**មេឃពណ៌** ទើបមកដល់ពីសីហលទ្វីបជាមួយនឹងបរិវារចង់ជួបលោកជាទេវបាទ ឥឡូវនេះនៅរង់ចាំឯមាត់ទ្វារ" ។ ហង្ស**ហិរណ្យគត៌**និយាយថា៖ "ក្អែក**មេឃពណ៌**ជាអ្នកប្រាជ្ញមានការធ្លាប់ពិសោធន៍ច្រើន បើដូច្នោះឯងឲ្យគេចូលមកចុះ!" ។ **ចាក្រពាក**និយាយរំឭកស្មារតីកាត់ឡើងថា៖ "ទេវៈ! លោកម្ចាស់ពោលនេះបានការម្យ៉ាង តែសុំកុំភ្លេចសូមជ្រាបថាក្អែកជាបក្សីគោក បើវាជាបក្សីថលចរ វាជាសត្រូវនឹងយើងដែរ តើយើងនឹងទទួលវាដូចម្ដេចបាន, ព្រោះថា៖

៥៧- នរជនណាលះបង់ចោលបក្សពួកខ្លួន ហើយត្រេកអរទៅចូលដៃនឹងបរបក្សវិញ នរជននោះជាមនុស្សល្ងង់ ត្រូវបរបក្សសម្លាប់បង់សៀត ដូចចចកឈ្មោះ**នីលពណ៌**" ។

ហង្ស**ហិរណ្យគត៌** សួរឡើងថា៖ "ចុះរឿងនោះ តើដូចម្ដេច?" ។ **ចាក្រពាក**និយាយរៀបរាប់រឿងនោះប្រាប់ថា៖

## កថាទី៨

## រឿងចចកនីលពណ៌

មានចចកមួយអាស្រ័យនៅក្នុងព្រៃ ហើយដើរស្វះស្វែងរកចំណីអាហារតាមទំនើងចិត្ត ដើរទៅៗដល់ជាយក្រុងមួយ មិនដឹងមានគ្រោះអ្វីក៏ធ្លាក់ទៅក្នុងរណ្ដៅផ្ទះមួយ ហើយមិនអាចឡើងពីរណ្ដៅនោះវិញបានសោះ ដល់ព្រឹកឡើងក៏ពុតធ្វើជាស្លាប់ស្ដូកស្ដឹង ។ ខណៈនោះ, ម្ចាស់រណ្ដៅឃើញចចកនោះមានជើងស្រទាំងឡើងលើ ភ្នែកបិទជិតហាមាត់បញ្ចេញធ្មេញស្ញេញ ក៏យល់ថាចចកនោះស្លាប់ហើយ ទើបស្រង់ចេញពីរណ្ដៅផ្ទះ ហើយអូសគ្រវែងចោលឆ្ងាយពីភូមិទៅ ។ កាលនោះ, ចចកនោះបានចូលព្រៃវិញ ដល់ក្រឡេកមើលខ្លួនឃើញខៀវស្រងាត់ដូច្នោះ គិតក្នុងចិត្តដោយក្ដីត្រេកអរថា៖ "យី! អាត្មាអញនេះមានពណ៌ខៀវល្អណាស់តើ! បើដូច្នេះ អាត្មាអញនេះខ្ពង់ខ្ពស់ប្រសើរជាងចចកឯទៀតទាំងអស់" ។ លុះគិតរួចហើយ ចចកនោះហាហៅចចកទាំងឡាយមកជួបជុំ ហើយនិយាយប្រាប់ដោយក្ដីរីករាយថា៖ "ទេពតា

ដ៏មានបុណ្យ អាស្រ័យនៅក្នុងព្រៃនេះ បានតាំងយើងឲ្យធ្វើជាស្តេចម្រឹគ ហើយលោកបានអភិសេកយើង នឹងព្រះហស្តលោកដោយទឹកទិព្វមន្តយកពីជាតិឈើគ្រប់មុខ, អ្នកទាំងអស់គ្នាក្រឡេកមើលរូបយើង មើល? ចាប់តាំងពីថ្ងៃនេះតទៅ អ្នកធ្វើកិច្ចការអ្វីៗត្រូវធ្វើតាមបង្គាប់យើងទាំងអស់" ។ បណ្តាចចកទាំងឡាយកាលមើលចចកនោះឃើញពណ៌ចម្លែកដូច្នោះ ក៏បបួលគ្នាប្រណិបតន៍ដោយអស្តាង្គបាត ប្រណម្យចំពោះចចកនោះ ហើយពោលតបដោយគោរពថា៖ "យើងខ្ញុំទាំងអស់គ្នាសូមទទួលបង្គាប់ពីលោកម្ចាស់គ្រប់គ្នា" ។ ដោយទំនងនេះ ចចកនោះឡើងជាស្តេចម្រឹគទាំងអស់ បណ្តាដែលអាស្រ័យនៅនាព្រៃនោះទាំងប៉ុន្មាន ។ មុនដំបូង, ចចក**នីលពណ៌**នោះរើសយកសុទ្ធតែចចកដូចគ្នាមកធ្វើបរិវារ មានអំណាចរាជសក្តិខ្ពង់ខ្ពស់ណាស់, ប៉ុន្តែតមក, ទៅរើសយកសត្វឯទៀតដូចសីហៈ ខ្លា និងសត្វឯទៀតដែលមានសភាពដូច្នេះជាដើម មកធ្វើជាបរិវារវិញ ហើយបោះបង់ចចកគ្នាឯងចោលអស់ ។ ខណៈនោះ, មានចចកចាស់មួយ កាលឃើញសហាយខ្លួនគ្រប់គ្នាព្រួយចិត្ត ទើបនិយាយលួងលោមថា៖ "នែសហាយទាំងឡាយអើយ អ្នកទាំងឡាយកុំព្រួយបារម្ភថ្វីសព្វបើប៉ុណ្ណោះ ព្រះទេវបាទយើងល្ងង់ខ្លៅមិនចេះនីតិសាស្ត្រ គឺនយោបាយប្រមាថមើលងាយយើងសូម្បីយើងចេះនយោបាយប្រាកដដូច្នេះ ការនេះមិនជាអ្វីទេ! ខ្ញុំមានមធ្យោបាយល្អ រករឿងនឹងសម្លាប់ចោលឲ្យទាល់តែបាន, រឿងនេះសត្វទាំងឡាយឯទៀតមានសីហៈ ខ្លាជាដើម ដែលភ័ន្តគំនិតព្រោះឃើញថាវាមានពណ៌ខៀវល្អ មើលមិនស្គាល់ថាជាចចក បានជាលើកទុកដាក់ឲ្យធ្វើជាស្តេចខ្លួន, បើដូច្នោះ យើងគិតដូចម្តេចឲ្យសត្វឯទៀតស្គាល់ថាជាចចក? ។ មធ្យោបាយដែលយើងត្រូវធ្វើដូច្នេះ "ពេលល្ងាចអ្នកទាំងឡាយត្រូវចូលទៅជិតចចកទាំងអស់គ្នា ហើយបបួលគ្នាស្រែកលូឲ្យពេញទំហឹង កាលចចកនេះឮសម្រែកយើងហើយ មុខជានឹងស្រែកលូ-តយើងវិញ ព្រោះជាសត្វដែលមានសភាពដូចគ្នា, ព្រោះថា៖

៥៨- សេចក្តីពិត, សភាពនៃនរជនណាដូចម្តេច នរជននោះមិនអាចប្រព្រឹត្តកន្លងសភាពខ្លួនបានឡើយ បើលើកសុនខជាតិឲ្យធ្វើជាស្តេច វានឹងមិនអង្កៀមទ្រនាប់ជើងស្បែកឬអ្វី?

កាលបើខ្លាឮសំឡេង និងស្គាល់ថាជាចចកពិត មុខជាខ្លានឹងគប្បីខាំស៊ីស្តេចខ្លួនមិនខាន, ព្រោះថា៖

៥៩- បើសត្រូវស្គាល់ចំណុចខ្សោយយើង និងសេចក្តីក្តៀវក្លាយើងហើយ គេនឹងចូលទៅរហូតដល់ចិត្តគំនិតយើងខាងក្នុងទៀត ហើយសម្លាប់យើងចោលបង់សៀត ដូចភ្លើងឆេះឈើស្ងួតតែងឆេះរូងរហូតដល់ខ្លឹមខាងក្នុង" ។ តមកចចកចាស់ព្រមទាំងចចកទាំងឡាយ ប្រើឧបាយកលដូចបានគិតទុក ហើយសម្លាប់ចចក**នីលពណ៌**បានដូចសេចក្តីប្រាថ្នា ព្រោះហេតុនោះបានជាខ្ញុំ (**ចាក្រពាក**) ពោលថា៖ "នរជនណាលះបង់ចោលបក្សពួកខ្លួនដូច្នេះជាដើម" (លេខ៥៧) ។

ហង្ស**ហិរណ្យគក៏** ឆ្លើយថា៖ "ពិតមែនហើយ ប៉ុន្តែក្អែកនេះមកពីប្រទេសឆ្ងាយណាស់ គួរតែឲ្យចូលមកជួប ហើយរក្សាទុកចាំពិនិត្យមើលទៅខាងមុខ" ។ **ចាក្រពាក**និយាយតទៅទៀតថា៖ "យើងបានបញ្ជូនចារបុរសទៅហើយ បន្ទាយការពារយើងបានធ្វើត្រៀមទុកព្រមហើយ បើដូច្នោះ យើងត្រូវឲ្យនាំសេកចូលមកសាកសួរហើយសឹមលែងឲ្យទៅវិញ ។ ពេលនោះយើងមានសែន្យានុភាពត្រៀមទុកព្រមហើយ យើងនឹងចាំមើលវាពីចម្ងាយ, ព្រោះថា៖

៦០- ព្រាហ្មណ៍ចាណក្យៈ ប្រើទូតដែលឆ្លៀវឆ្លាតមុះមុតឲ្យសម្លាប់ស្តេចចន្ទៈបាន ព្រោះហេតុនោះបើយើងមានយោធាក្លៀវក្លាហានចោមរោមការពារម៉ត់ចត់ហើយ ទើបគួរជួបទូតដែលមកពីប្រទេសឆ្ងាយ ។

លុះបានរៀបចំសភាសម្រាប់ទទួលភ្ញៀវសព្វគ្រប់ហើយ ហង្ស**ហិរណ្យគក៏** ក៏បើកសេកនិងក្អែកឲ្យចូលទៅជួប ។ កាលដើរចូលទៅសេកងើបក្បាលស្ញើនបន្តិច ទៅដល់ហើយអង្គុយលើអាសនៈដែលគេរៀបចំទុកសម្រាប់ ទើបថ្លែងសារយ៉ាងក្លៀវក្លាថា "បពិត្រលោក**ហិរណ្យគក៏** ស្តេចក្ងោកនាម**ចិត្រពណ៏**ជារាជាធិរាជ ជាម្ចាស់នៃមយុរជាតិ មានព្រះបាទទ្រដោយផ្កាឈូករីកភ្លឺច្រុះផ្លុះច្រវាត់ដោយកែវមណីដែលប្រដាប់ដោយមកុដនៃស្តេចសាមន្តរាជ ដែលឱនសិរសាក្រាបគោរពត្រាស់បង្គាប់មកលោកថា, "បើចង់មានជីវិតរស់នៅតទៅ ឬប្រាថ្នាឥស្សរិយយស ចូរប្រញាប់ចូលទៅអភិវាទ វន្ទាចំពោះបាទយើង បើមិនដូច្នោះទេ ចូរគេចរត់ចេញទៅកាន់ទីដ៏ទៃឲ្យឆាប់ៗ!ទៅ" ។ **ហិរណ្យគក៏** កាលបានស្តាប់សេចក្តីថ្លែងសារនោះចប់សព្វគ្រប់ហើយ ក៏ក្រេវក្រោធច្រឡោតតបទៅវិញថា៖ "អ៊ំា! ក្នុងសភានេះ ឥតមាននរណាម្នាក់ដែលមានចិត្តចាប់ច្របាច់កអាព្រហើននេះទេឬអ្វី?" ។ ក្អែក**មេឃពណ៏**ងើបឡើងស្ទុះចូលទៅនិយាយថា៖ "ទេវៈ! សូមត្រាស់បង្គាប់មកចុះ ខ្ញុំបាទនឹងប្រហារអាសេកព្រហើននេះចោលបង់ឥឡូវនេះ" ។ ខណៈនោះ**ចាក្រពាកសវ៏ជ្ញៈ** ជាប្រធានរដ្ឋមន្ត្រីឈ្មោះ និយាយសម្រុះសម្រួល**ហិរណ្យគក៏** និងក្អែក**មេឃពណ៏**ថា៖ "នែលោកម្ចាស់! ស្តាប់ខ្ញុំបាទជម្រាបសិន កុំអាលធ្វើក្រោធឆុរឆេវដូច្នេះ, ព្រោះថា៖

៦១- ទីណាមិនមានចាស់ព្រឹទ្ធាចារ្យ ទីនោះមិនមែនជាសភាទេ នរជនណាមិនពោលធម៌ នរជននោះមិនមែនជាព្រឹទ្ធាចារ្យទេ ពាក្យណាមិនមានសត្យ ពាក្យនោះមិនមែនជាធម៌ទេ ត្រង់ណាមានតែប្រវញ្ចន៍ ត្រង់នោះមិនមានពាក្យសត្យទេ ។

លក្ខណៈជនដែលប្រកបដោយធម៌ដូច្នេះ៖

៦២- ទូតសូម្បីជាអនារ្យជន និយាយពាក្យមិនគប្បីក៏មិនត្រូវសម្លាប់ដែរ ព្រោះគេជាមាត់នៃព្រះរាជា, កណ្តាលអាវុធច្រើងច្រាងភ្លឺស្វាច ទូតមិនចរចាអ្វីក្រៅពីពាក្យបង្គាប់ ។

៦៣- នរណាហ្ន៎ជាអ្នកប្រាជ្ញ អាចសម្គាល់ខ្លួនថាថោកទាប ឬសម្គាល់សត្រូវថាខ្ពង់ខ្ពស់ ព្រោះតែពាក្យទូតនិយាយជាប្រមាណ? អាស្រ័យដោយហេតុដែលគេមិនត្រូវសម្លាប់ទូត ទើបត្រូវតែនិយាយទាំងអស់សព្វកាលទាំងពួង" ។

រាជហង្សហិរណ្យគក៍ និងក្អែកមេឃពណ៌ បានតម្កល់ទឹកចិត្តជាប្រក្រតី ។ សេកក្រោកឡើងហើយសុំលាទៅវិញ ចាក្រពាកសវ៍ជ្ជៈជូនដំណើរ លុះនាំទៅដល់ក្រៅហើយ ក៏សម្ដែងអាការធ្វើជាសុំទោសឲ្យរង្វាន់ខាន់ខៅមានមាស និងវត្ថុឯទៀតជាដើមទើបបញ្ជូនសេកឲ្យត្រឡប់ទៅប្រទេសខ្លួនវិញ ។ សេកកាលត្រឡប់មកដល់ទៅភ្នំវិន្ធ្យាជាប្រទេសខ្លួនវិញហើយ ក៏ចូលទៅអភិវាទស្ដេចក្ងោកចិត្រពណ៌ជាម្ចាស់ខ្លួន ។ ស្ដេចក្ងោកចិត្រពណ៌ ឃើញសេកត្រឡប់មកដល់ហើយ ក៏និយាយប្រាស្រ័យនឹងសេកថា៖ "ម្នាលសេក! ឯងបានដំណឹងអ្វីខ្លះ? ប្រទេសនោះដូចម្ដេចទៅ?" ។ សេកឆ្លើយតបថា៖ "ទេវៈ! បើពោលឲ្យខ្លី ត្រូវតែរៀបទ័ពត្រៀមធ្វើសង្គ្រាមពីឥឡូវនេះ ឯកប៊ូរទ្វីបទុកជាឯកទេសមួយនៃស្ថានសួគ៌ ស្ដេចប្រទេសនោះទុកដូចជាម្ចាស់ស្ថានសួគ៌ទីពីរ គឺព្រះឥន្ទ្រជាគម្រប់ពីរ ធ្វើដូចម្ដេចនឹងពណ៌នាបាន?" ។ ស្ដេចក្ងោកចិត្រពណ៌ លុះបានហៅមន្ត្រីធំៗ ចូលមកកាន់ទីប្រជុំហើយ ទើបប្រឹក្សាថា៖ "យើងសូមសេចក្ដីយល់អស់លោកគ្រប់គ្នា យើងត្រូវចាត់ការអ្វីខ្លះ? បើទុកជាដូចម្ដេច យើងក៏ត្រូវធ្វើសង្គ្រាមពិតប្រាកដ, ព្រោះថា៖

៦៤- ក្ដីមិនសន្ដោសជាវិបត្តិនៃព្រាហ្មណ៍ ក្ដីសន្ដោសជាវិបត្តិនៃព្រះរាជា ក្ដីខ្មាសអៀនជាវិបត្តិនៃស្រីផ្កាមាស ក្ដីមិនខ្មាសអៀនជាវិបត្តិនៃកុលធីតាទាំងឡាយ" ។

កាលនោះ ត្មាតទុរទសីជាប្រធានរដ្ឋមន្ត្រីពោលឡើងថា៖ "ទេវៈ! ការធ្វើសង្គ្រាមសព្វបើដោយការឃ្នើសចិត្តជាប្រក្រតី មិនមែនជាវិធីទេ, ([១]) ព្រោះថា៖

៦៥- កាលណាមិត្តអាមាត្យជាពួកអ្នកមានចិត្តស្រឡាញ់ មានភក្ដីមាំហើយទំនាស់ចំពោះសត្រូវកាលនោះគប្បីធ្វើសង្គ្រាម ។

៦៦- ត្រូវបានផែនដី បានសម្ពន្ធមិត្ត បានមាស នេះជាផល ៣ ប្រការដែលគេត្រូវធ្វើសង្គ្រាម កាលណាបើគេប្រាកដជាបានផល ៣ ប្រការនេះហើយ កាលនោះគេត្រូវធ្វើសង្គ្រាម" ។

ស្ដេចក្ងោកចិត្រពណ៌ថ្លែងបង្គាប់ថា "ចូរឲ្យមន្ត្រីដើរត្រួតត្រាសែន្យានុភាពទ័ពមើល ត្រូវមើលគ្រឿងរុធយុទ្ធភណ្ឌ និងស្បៀងអាហារឲ្យដឹងសព្វគ្រប់ រួចហើយត្រូវហៅហោរាមកឲ្យគន់គូរមើល

---

[១] សេចក្ដីប្រែលោកឡង់ស៊ឺរូថា កាលណាគេមិនសប្បាយចិត្ត គេមិនត្រូវបង្ខំធ្វើសង្គ្រាមទេ ។ សេចក្ដីប្រែលោកនាគប្រទីបថា ការធ្វើសង្គ្រាមដោយអធម៌ មិនមែនជាវិធីត្រឹមត្រូវទេ ។ ច្បាប់ដើមថា វសនិតយា វគ្រហោ ន វិធី ។ សេចក្ដីពន្យល់ថា សព្វបើជម្លោះអាមាត្យ, បោរីជន, អ្នកជនបទ, មិត្ត, កុមារជាដើម ។

ឫក្សពារសុភមង្គល ដែលត្រូវយាត្រាទ័ព" ។ ត្អាត**ទុរទសី**និយាយរំឭកថា៖ "ទេវៈ! ការយាត្រាទ័ពចេញទៅដោយរួសរាន់ដូច្នេះ មិនគួរគប្បីទេ, ព្រោះថា៖

៦៧- មនុស្សល្ងង់ណា មិនបានពិចារណាសែន្យានុភាពពៃរី ហើយចូលទៅប្រយុទ្ធ ដោយរួសរាន់ មនុស្សល្ងង់នោះ, នឹងបានឱបមុខដាវ នេះជាសច្ចៈឥតសង្ស័យឡើយ" ។

ស្ដេចក្ងោក**ចិត្រពណ៌**ពោលទ្រគោះបោកបោះបន្ទោសត្អាតថា៖ "នែមន្ត្រី! ឯងកុំមកបង្អាក់ធ្វើឲ្យយើងថយក្ដីក្លាហានដូច្នេះ ចូរឯងនិយាយប្រាប់មក តើនរណាអាចចូលទៅកាន់ប្រទេសសត្រូវ ហើយយកជ័យជម្នះបាន?" ត្អាត**ទុរទសី**ឆ្លើយតបថា៖ "ទេវៈ! ខ្ញុំបាទនឹងជម្រាបឲ្យជ្រាបបាន តែនឹងឲ្យបានផលល្អ លុះត្រាតែទទួលប្រតិបត្តិតាម, លោកពោលទុកដូច្នេះថា៖

៦៨- មានប្រយោជន៍អ្វីដោយការណែនាំព្រះរាជា ឲ្យធ្វើតាមសាស្ត្របើទ្រង់មិនព្រមប្រតិបត្តិតាម! សេចក្ដីពិត, មិនមែនគ្រាន់តែចេះដឹងថ្នាំ ហើយបំបាត់ជំងឺបានទេ ។

ខ្ញុំបាទមិនហ៊ានប្រព្រឹត្តកន្លងព្រះរាជបង្គាប់ទេ តែខ្ញុំបាទសូមជម្រាបតាមកិច្ចការដែលខ្ញុំបាទបានចេះដឹងមក សូមលោកម្ចាស់ស្ដាប់ដូចតទៅនេះ៖

៦៩- បពិត្រព្រះរាជា បណ្ដាទីទាំងឡាយមានស្ទឹង ភ្នំ ព្រៃ បន្ទាយជាដើម ទីណាមានភ័យសេនីយ ត្រូវលើកព្យុហៈកងពលយាត្រាទ័ពទៅក្នុងទីនោះ ។

៧០- សេនាបតី ព្រមដោយមេកងពលដែលក្លៀវក្លាហាន ត្រូវដើរទៅមុខទ័ព, ត្រូវដាក់ស្រី ម្ចាស់ផែនដី ឃ្លាំង និងពលដែលមានកម្លាំងខ្សោយនៅកណ្ដាលទ័ព ។

៧១- ត្រូវដាក់កងទ័ពសេះនៅស្ដាបទ័ពទាំងសងខាង, នៅសងខាងទ័ពសេះត្រូវដាក់ពលរថ នៅសងខាងពលរថ ត្រូវដាក់ពលដំរី នៅសងខាងពលដំរី ត្រូវដាក់ពលថ្មើរជើង ។

៧២- សេនាបតី ត្រូវដើរខាងក្រោយកងទ័ព ដើម្បីកម្ដាកម្លាំងទឹកចិត្តកងពលដែលអន់ថយឲ្យក្លាហាន ព្រះរាជាចោមរោមដោយរដ្ឋមន្ត្រីជាទីប្រឹក្សា និងវីរយោធា ទ្រង់ជាអគ្គបញ្ជាការកងទ័ព ។

៧៣- ត្រូវយាត្រាទ័ពលុកចូលទៅ ក្នុងទីមិនរាបស្មើ និងភ្នំក្រំថ្ម ដោយកងទ័ពដំរី ក្នុងទីវាលដោយកងទ័ពសេះ ក្នុងទីទឹកដោយកងទ័ពជើងទឹក ក្នុងទីទាំងពួងដោយកងទ័ពថ្មើរជើង ។

៧៤- ក្នុងរដូវភ្លៀង លោកសម្ដែងទុកថា ត្រូវធ្វើដំណើរដោយកងទ័ពដំរី រដូវក្រៅពីនោះ ត្រូវប្រើកងទ័ពសេះ ឯកងពលថ្មើរជើង ប្រើបានគ្រប់ពេលទាំងពួង ។

៧៥- គប្បីប្រយ័ត្នរក្សាព្រះរាជាទុកក្នុងភ្នំ ឬតាមផ្លូវដែលគេទៅបានដោយលំបាក សូម្បីព្រះអង្គមានយោធាហៅហានចោមរោមរក្សាល្អហើយក្ដី ទ្រង់ក៏ត្រូវចូលកាន់យោគនិទ្រាបន្តិចៗងាយនឹងតើន ។

៧៦- ទ្រង់គប្បីបំផ្លិចបំផ្លាញសត្រូវ សម្លាប់សត្រូវញាំញីសត្រូវឲ្យខ្សោយ ដោយការបំផ្លាញកុំឲ្យមានបន្ទាយ មានភូមិ មានគ្រឿងចម្រូង កាលចូលទៅដល់ក្នុងបរទេសហើយ ត្រូវបញ្ជូនអ្នកថ្មើរព្រៃជាមុន ។

៧៧- ព្រះរាជាប្រថាប់នៅទីណា ត្រូវឃ្លាំងនៅទីនោះ, មិនមានឃ្លាំង ឥតមានរាជ្យ ព្រះរាជាទ្រង់ត្រូវប្រកបដោយព្រះទ័យទូលាយ ទ្រង់ត្រូវប្រទានរង្វាន់ដល់យោធាណាក្លៀវក្លាហាន តែសេចក្តីពិតយោធាណាមួយដែលមិនច្បាំង ដើម្បីព្រះរាជា? ។

៧៨- បពិត្រព្រះរាជា! មនុស្សមិនមែនជាទាសនៃមនុស្សទេ មនុស្សជាទាសនៃទ្រព្យ ការបានទៅជាបុគ្គលខ្ពង់ខ្ពស់ ឬការធ្លាក់ខ្លួនជាបុគ្គលថោកទាប ស្រេចហើយតែមានទ្រព្យ ឬក្រីក្រប៉ុណ្ណោះ ។

៧៩- ត្រូវចូលទៅប្រយុទ្ធកុំឲ្យបែកទ័ព ហើយប្រយ័ត្នមើលគ្នីគ្នាកងទ័ពណាទន់ខ្សោយកម្លាំងត្រូវប្រមូលមកទុកកណ្តាលក្បួនទ័ព ។

៨០- ព្រះមហីបាល ត្រូវកងពលថ្មើរជើងទៅនៅមុខកងទ័ព កាលបើបង្ក្រាបសត្រូវបានហើយព្រះអង្គត្រូវប្រថាប់នៅកម្រាបអរិរាជសត្រូវឲ្យរាបទាប ។

៨១- ទ្រង់គប្បីចូលទៅប្រយុទ្ធក្នុងទីវាល ដោយកងរថ និងកងសេះ ក្នុងទីទឹកដោយកងទូក និងដំរី ក្នុងទីព្រៃ និងព្រៃញាតស្បាត ដោយកងធ្នូ, ក្នុងទីគោកដោយដាវខែល និងអាវុធផ្សេងៗ ។

៨២- ទ្រង់ត្រូវបំផ្លិចបំផ្លាញរឿយៗនូវទីវាលស្មៅ ស្រូវ អង្ករ សត្រូវ ហើយបង្អត់កុំឲ្យមានទឹកមានឱស ត្រូវទម្លាយទំនប់ទឹក កំពែង និងគូ ។

៨៣- បណ្តាកងទ័ពទាំងអស់ កងទ័ពដំរីជាកងទ័ពជាន់ឯកសម្រាប់ព្រះមហីបតី មិនមានកងទ័ពអ្វីប្រសើរជាងឡើយ ព្រោះដំរីសូម្បីតែអវៈយវៈវាប៉ុណ្ណោះ ក៏ទុកថាជាអាវុធ ៨ ប្រការបានស្រេចហើយ ។

៨៤- សេះជាកម្លាំងនៃកងទ័ព គេទុកថាជាកំពែងដើរបានព្រោះហេតុនេះ បើព្រះរាជាអង្គណាប្រកបដោយកងទ័ពសេះច្រើនក្រៃលែងជាងសត្រូវហើយ ក៏ឈ្មោះថាមានជ័យក្នុងយុទ្ធសង្គ្រាមផ្លូវគោក ។

៨៥- ទាហានណា ឡើងសេះចូលប្រយុទ្ធ សូម្បីទេវតាក៏លំបាកនឹងយកឈ្នះទាហាននោះបានពួកពៃរី បើទុកជានៅឆ្ងាយ ក៏ទុកដូចជាធ្លាក់មកនៅក្នុងកណ្តាប់ដៃស្រេចហើយ ។

៨៦- ក្នុងប្រថមកិច្ចនៃយុទ្ធសង្គ្រាម ការអភិបាលរក្សាពលនិករទុកឲ្យគ្រប់សព្វ គេទុកជាគោលដ៏សំខាន់ ព្រោះការកម្រាបផ្លូវក្នុងទិសទាំងពួងជានាទីនៃកងពល ។

៨៧- លោកពោលថា៖ កងទ័ពដែលប្រសើរនោះគឺកងទ័ពដែលមាននិស្ស័យក្លៀវក្លាពីកំណើត

ប៉ិនប្រសប់ក្នុងការកាន់អាវុធ មានភក្តី ធន់ទ្រាំក្នុងការខ្សោយកម្លាំង ហើយមានវីរក្សត្រិយ៍ ( ទាហានវីរ) ជាប្រមុខដោយច្រើនផង ។

៨៨- បពិត្រព្រះរាជា! មនុស្សក្នុងលោក ចូលទៅច្បាំងដោយក្លាហាន ព្រោះចង់បានកិត្តិយសពីម្ចាស់ខ្លួន មិនមែនដោយចង់បានរង្វាន់គឺទ្រព្យទេ ។

៨៩- កងទ័ពមានចំនួនតិច តែសុទ្ធសឹងវិញ្ញូជនទើបប្រសើរ កងទ័ពមានចំនួនច្រើន តែសុទ្ធតែយោធាអស់ជម្រើសមិនល្អទេ ព្រោះយោធាអស់ជម្រើសបណ្តោយឲ្យចាញ់ងាយ ហើយនាំឲ្យទាហានវិញ្ញូជនយកជ័យថែមទៀតផង ។

៩០- ការមិនជ្រះថ្លា ១, ការបាក់មុខញយៗ ១, ការមិនឲ្យចំណែកដល់មនុស្សម្នាក់ៗដែលត្រូវបាន ១, ការពន្យឺតពេលវេលាចែក ១, ការមិនធ្វើតប ១, ទាំងអស់នេះជាហេតុនាំឲ្យព្រងើយកន្តើយពីគ្នា ។

៩១- ព្រះរាជាប្រាថ្នាជ័យ គប្បីវាយសត្រូវ ដោយមិនធ្វើឲ្យកងទ័ពព្រះអង្គឲ្យលំបាកក្តៅក្រហាយ កងទ័ពដែលរួយស្រពន់ដោយដើរផ្លូវឆ្ងាយ សត្រូវយកជ័យបានដោយងាយ ។

៩២- ត្រូវព្យាយាមបំបែកសត្រូវឲ្យបែកបាក់គ្នា វិធីបំបែកនេះមិនមានអ្វីដទៃក្រៅពីញុះញង់ព្រះរាជទាហាទក្នុងរាជ្យសត្រូវទេ ព្រោះហេតុនោះ ត្រូវព្យាយាមតាំងរាជទាយាទរបស់ប្រទេសសត្រូវឲ្យទាល់តែបាន ។

៩៣- ការចងស្ពានមេត្រី នឹងស្តេចយុវរាជ (១) ឬនាយករដ្ឋមន្ត្រីរបស់ប្រទេសសត្រូវបានហើយ គប្បីបំបែកសាមគ្គីខាងក្នុងពួកសត្រូវដែលមានចិត្តមឹងម៉ាត់ ។

៩៤- លុះដើរឧបាយបំបែកក្នុងសង្គ្រាមយ៉ាងនេះបានហើយ គប្បីសម្លាប់មិត្តដ៏ហៅហាននៃសត្រូវនោះចោលចេញ ពុំនោះចាប់ចងពួកមុខមន្ត្រី ឬកូនចៅបរិវារឃុំឃាំងទុក ធ្វើដូចជាការបំបែកកូនគោហើយចាប់មេគោ (២) ដូច្នោះ ។

៩៥- ព្រះរាជាគប្បីធ្វើឲ្យប្រទេសព្រះអង្គមានពលរដ្ឋច្រើនបរិបូណ៌ ដោយការការយកប្រជាជនពីបរទេស ឬពុំនោះទំនុកបម្រុងប្រជាជនដោយការឲ្យទាន និងរាប់អាន, មួយទៀត ប្រទេសដែលមានប្រជាជនច្រើនមកពីប្រទេសនោះអាចកពូនទ្រព្យសម្បត្តិជាមហាសេដ្ឋីបាន” ។

ស្តេចក្អែកចិត្រពណ៌ និយាយពាក្យទ្រគោះឲ្យត្បាតទុរទសីថា៖ “ឯងនិយាយបូរបាច់ច្រើនពេក

---

[១] មកុដរាជកុមារ។ ២ ត្រង់នេះអាចមានសេចក្តីមួយទៀតថា ពុំនោះចូលដៃនឹងមន្ត្រីរាជបរិពារ កូនចៅសត្រូវដោយឲ្យទ្រព្យដូចជាបង្ហាញស្មៅបញ្ឆោតគោ ។

ដូច្នេះតើមានប្រយោជន៍អ្វី?" ព្រោះថា៖

៩៦- សេចក្តីចម្រើនរបស់ខ្លួន និងសេចក្តីសាបសូន្យរបស់សត្រូវ ទាំងពីរប្រការនេះជារដ្ឋប្រសាសនោបាយ កាលបើប្រកាន់តាមមតិនេះបានហើយ ការពោលអួតសម្តីថ្វីមាត់របស់ខ្លួន ទើបបណ្ឌិតសរសើរ" ។

ត្មាត**ទុរទសី**ញញឹមបណ្តើរឆ្លើយតបបណ្តើរថា៖ "ពាក្យនេះវិសេសពិតមែនហើយ, តែលោកពោលថា៖

៩៧- ពួកមួយធ្វើតាមចិត្ត ពួកមួយទៀតធ្វើទៅតាមសាស្រ្តពន្លឺ និងងងឹត ទាំងពីរប្រការនេះ មានលក្ខណៈស្មើគ្នាបានឬទេ?" ។

កាលនោះ ស្តេចក្ងោក**ចិត្រពណ៌** លុះបានស្តាប់ហើយឃើញថាទាស់ចិត្តខ្លួន ក៏ក្រោកឡើងត្រាស់បង្គាប់ឲ្យបរទ័ពយាត្រាចេញទៅតាមហោរកំណត់នក្ខត្តឫក្សឲ្យ" ។

ឯចារបុរសរាជហង្ស**ហិរណ្យគភ៌** កាលបានដឹងកិច្ចការសត្រូវសព្វគ្រប់ហើយ ក៏ត្រឡប់យកដំណឹងទៅប្រាប់ម្ចាស់ខ្លួនវិញថា៖ "បពិត្រលោកម្ចាស់! ស្តេចក្ងោក**ចិត្រពណ៌** លើកក្បួនព្យុហៈ យាត្រាទ័ពចរចេញទៅបោះបន្ទាយនៅជើងមលយបព៌តហើយ សូមលោកម្ចាស់មានបញ្ជាឲ្យលើកទ័ពទៅបំផ្លាញបន្ទាយនោះឲ្យឆាប់ៗទៅ ។ ពេលនេះ, ត្មាត**ទុរទសី**ធ្វើជាប្រធានរដ្ឋមន្ត្រី តាមដែលខ្ញុំបាទបានដឹងមកថា សត្រូវបានបញ្ជូនចារបុរសគេឲ្យមកធ្វើការសម្ងាត់នៅខាងបន្ទាយយើងហើយ ។ ខណៈនោះ **ចាក្រពាកសវ៌ជ្ញះ** និយាយរំឭករាជហង្ស**ហិរណ្យគភ៌**ថា៖ "លោកម្ចាស់! ចារបុរសគេនោះ គឺក្អែក**មេឃពណ៌**នេះឯង" ។ ស្តេចហង្ស**ហិរណ្យគភ៌**គំហកថា៖ "មិនមែនទេ! មិនមែនទេ! បើវាជាចារបុរសមែន ហេតុអ្វីក៏វាប៊ានស្ទុះទៅបម្រុងក្រញិចសេកសម្លាប់ចោលបង់? មួយទៀត, ការប្រកាសសង្គ្រាមនេះ ទើបនឹងកើតឡើងពីកាលសេកវាមកទេតើ! ឯក្អែក**មេឃពណ៌**វាមកនៅទីនេះយូរយារណាស់ហើយ ។ **ចាក្រពាកសវ៌ជ្ញះ** ឆ្លើយកាត់ដោយម៉ឺងម៉ាត់ថា៖ "បពិត្រលោកម្ចាស់! ត្រូវតែយើងកុំទុកចិត្តអ្នកបរទេសអាគន្តុកៈ" ។ រាជហង្ស**ហិរណ្យគភ៌** និយាយទទឹងទាស់ថា៖ "ចួនកាល អាគន្តុកអ្នកបរទេស គេធ្វើប្រយោជន៍ឲ្យយើងដែរ, ឯងស្តាប់មើល លោកពោលថា៖

៩៨- ជនដទៃ តែជាអ្នកធ្វើប្រយោជន៍ឲ្យយើង ទុកជាផៅពង្ស ឯផៅពង្សពិត តែជាអ្នកមិនធ្វើប្រយោជន៍ឲ្យយើង ក៏ទុកជាអ្នកដទៃ រោគកើតក្នុងរាងកាយយើងពិតៗ រកប្រយោជន៍គ្មាន ថ្នាំកើតនៅក្នុងព្រៃធ្វើប្រយោជន៍ឲ្យយើង ។

៩៩- សេវកាមាត្យព្រះបាទ**ស្ទូទ្រកៈ**ម្នាក់ឈ្មោះ**វីរវរៈ** ទើបនឹងមកធ្វើខ្ញុំរាជការថ្មី ក៏អាចថ្វាយកូន

ខ្លួនឯងជារាជពលីបាន ។

**ចាក្រពាក**សួររឿងនោះថា៖ “តើរឿងនោះដូចម្ដេច?” ។ រាជហង្ស**ហិរណ្យគក៏**រៀបរាប់រឿងនោះថា៖

# កថាទី៩

## រឿងស្ដេចសូទ្រកៈ និងអាមាត្យវីរវរៈ

កាលពីមុននោះ យើងទៅអាស្រ័យនៅហែលលេងក្នុងស្រះមួយ នៃព្រះបាទ**សូទ្រកៈ** ដោយមានចិត្តប្រតិព័ទ្ធចំពោះនាងហង្សឈ្មោះ **កប៉ូរមញ្ជរី** ជាកូនហង្សឈ្មោះ **កប៉ូរកេលី** ។ ថ្ងៃមួយ, មានទាហានម្នាក់ឈ្មោះ ***វីរវរៈ*** ជាបុត្រស្ដេចនឹងគេដែរ គេទើបមកពីបរទេស ចង់ចូលទៅក្រាបបង្គំគាល់ព្រះបាទ**សូទ្រកៈ** ។ ***វីរវរៈ*** ទៅជួបនឹងទ្វារបាលសុំចូលទៅក្រាបបង្គំគាល់ព្រះរាជា និយាយប្រាប់ទ្វារបាលថា “ខ្ញុំបាទជាទាហានជាអ្នកចម្បាំង ខ្ញុំមានបំណងចង់ធ្វើជាខ្ញុំរាជការថ្វាយព្រះរាជា សូមលោកមេត្តានាំខ្ញុំចូលទៅក្រាបបង្គំគាល់ព្រះអង្គ ។ ទ្វារបាលនាំ ***វីរវរៈ*** ចូលទៅគាល់ ***វីរវរៈ*** ក្រាបបង្គំប្រណម្យហត្ថហើយក្រាបទូលថា៖ “ទេវៈ! សូមទ្រង់មេត្តាប្រោស បើព្រះករុណាយល់ឃើញមានប្រយោជន៍ សូមមេត្តាប្រោសទទួលទូលព្រះបង្គំជាខ្ញុំធ្វើជាសេវកាមាត្យ ហើយសូមទ្រង់ព្រះមេត្តាប្រទានរង្វាន់លាងជីវិត” ។ ព្រះបាទ**សូទ្រកៈ**ត្រាស់សួរថា៖ “ឯងចង់បានរង្វាន់ជាប្រាក់ប៉ុន្មាន?” ។ ***វីរវរៈ*** ទូលស្នងតបទៅវិញថា៖ “ក្នុងមួយថ្ងៃចំនួន ៥០០សុវណ៌ៈ” ។ ព្រះបាទ**សូទ្រកៈ** ត្រាស់សួរថា៖ “ឯងបានអ្វីជាគ្រឿងការពារ?” ។ ***វីរវរៈ*** ក្រាបទូលថា៖ “សូមព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំមានដៃពីរ និងដាវមួយជាគម្រប់បី” ។ ព្រះបាទ**សូទ្រកៈ**លុះទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ត្រាស់ដោយចម្អែកព្រះទ័យថា៖ “ទេ! ទេ! មិនកើតទេ” ។ ***វីរវរៈ*** ទទួលព្រះរាជឱង្ការហើយ អៀនអន់ចិត្តក្រាបបង្គំលាត្រឡប់ទៅវិញ ។ កាលនោះ, អាមាត្យជាទីប្រឹក្សាព្រះអង្គទូលស្នើថា៖ “ទេវៈ! សូមទ្រង់ព្រះមេត្តាប្រោសប្រទានល្បងមើលបាន ៤ ថ្ងៃសិន ដើម្បីពិនិត្យមើលលក្ខណៈ និស្ស័យវាឲ្យឃើញច្បាស់ថា វាមានគុណសម្បត្តិសមទទួលរង្វាន់ថ្លៃឈ្នួលប៉ុណ្ណោះ ឬមិនសមទទួលទេ ។ ខណៈនោះព្រះបាទ**សូទ្រកៈ**ទ្រង់ត្រាស់ហៅ***វីរវរៈ***មកវិញ តាមពាក្យស្នើណែនាំអាមាត្យទីប្រឹក្សាព្រះអង្គ ហើយទ្រង់ប្រោសប្រទានម្លូ ([១]) និងថ្លៃឈ្នួល ៥០០ សុវណ៌ៈតាមកំណត់ ។

---

[១] ហិតោបទេសសេចក្ដីជាភាសាបារាំងនៃលោកឡង់ស៊ីរ៉ូ និងជាភាសាសៀមនៃលោកនាគប្រទីបមានគាថាដូច្នេះ ម្លូ មានរសហើរ ល្វីង ក្ដៅ ផ្អែម កាត់មាត់ប្រហើរ រម្ងាត់ក្លិនខ្យល់អាក្រក់ ការស្លេស រម្ងាត់សត្វល្អិត កម្ចាត់ក្លិនស្អុយ ប្រដាប់មាត់ឲ្យល្អ ជម្រះមន្ទិលមាត់ និងធ្វើកាមរាគឲ្យកើត សំឡាញ់អើយ នេះសព្វគុណម្លូ ១៣ ប្រការ សូម្បីក្នុងស្ថានសួគ៌ក៏រកបានដោយក្រ ។

តាំងពីកាលនោះ ទ្រង់តែងសង្កេតមើលការចាយវាយនៃ***វិរវរៈ***នោះរឿយៗ ទ្រង់បានជ្រាបថា៖ ***វិរវរៈ*** បែងចែកផ្ទៃឈ្នួលខ្លះ សម្រាប់ធ្វើពលិការថ្វាយទេវតា និងបូជាព្រាហ្មណ៍ ខ្លះសម្រាប់ជួយដល់អ្នកដែលមានក្តីទុក្ខលំបាក នៅសល់ខ្លះសម្រាប់ការចិញ្ចឹមជីវិត និងការកម្សាន្តរបស់ខ្លួន ។ ***វិរវរៈ***ប្រតិបត្តិនាទីខ្លួនយ៉ាងនេះជានិច្ចនិរន្តរ៍ ចូលទៅរក្សាទ្វារព្រះរាជវាំង កាន់ដាវជាប់នៅដៃឥតធ្វេសប្រហែស កាលណាបើព្រះរាជាមានព្រះរាជឱង្ការអនុញ្ញាត កាលនោះទើបបានត្រឡប់ទៅកាន់ទីលំនៅខ្លួនវិញ ។

យប់មួយ, ពេលពាក់កណ្តាលអធ្រាត្រថ្ងៃ ១៤ រោចងងឹតសូន្យឈឹង ព្រះរាជាទ្រង់ព្រះសណ្តាប់សំឡេងយំលលួងក្រឡួចគួរឲ្យអាណិតទើបទ្រង់មានព្រះតម្រាស់ត្រាស់សួរថា៖ “អ្នកណានៅចាំទ្វារនេះ?” ។ ***វិរវរៈ*** បានឮព្រះតម្រាស់ត្រាស់សួរហើយ ក្រាបបង្គំទូលតបភ្លាមថា៖ “ទេវៈ! សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំ***វិរវរៈ***” ។ ព្រះបាទ***សូទ្រកៈ***ត្រាស់បង្គាប់ថា៖ “ឯងទៅមើល! អ្នកណាយំអ្វីហ្នឹង?” ។ ***វិរវរៈ***ទទួលព្រះរាជឱង្ការថា៖ “ទេវៈ! សូមតេជៈតម្កល់លើត្បូង!” ។ ហើយចេញទៅភ្លាម ។ ព្រះរាជាកាលត្រាស់បង្គាប់ឲ្យ***វិរវរៈ***ចេញទៅហើយ ទ្រង់មានព្រះបរិវិតក្កថា៖ “យីអាត្មាអញ ប្រើ***វិរវរៈ***នេះជារាជបុត្រផងឲ្យចេញទៅតែម្នាក់ឯងទាំងងងឹតសូន្យសុងស្ទើរតែចាក់ភ្នែកមិនយល់ បើដូច្នោះគួរតែអាត្មាអញចេញទៅដើម្បីឲ្យដឹងសេចក្តីនោះ ដោយខ្លួនឯងផង” ទ្រង់ព្រះចិន្តាហើយ ព្រះហស្តចាប់ព្រះខ័នស្តេចចេញពីរាជនិវេសន៍ទៅខាងក្រៅតម្រង់ទៅកន្លែងដែលឮសូរយំនោះ ។ ***វិរវរៈ*** ចេញទៅមុនទៅឃើញស្រីម្នាក់មានរូបឆោមល្អកំពុងពេញវ័យ ប្រដាប់តុបតែងខ្លួនដោយគ្រឿងអលង្ការដ៏វិចិត្រ កំពុងតែយំសោយសោកខ្សឹកខ្សួល ក៏សួរទៅថា៖ “ម្នាលនាង! នាងជាស្រីអ្វី? ហេតុដូចម្តេចក៏នាងយំសោយសោកដូច្នេះ?” ស្រីនោះ ឆ្លើយតបមកវិញថា៖ “ខ្ញុំនេះជារាជលក្ស្មី ជាទេវីប្រចាំសេចក្តីចម្រើនព្រះបាទ***សូទ្រកៈ***អង្គនេះ ខ្ញុំបានអាស្រ័យនៅក្រោមម្លប់ព្រះឆាយានៃព្រះពាហុព្រះអង្គ សុខសប្បាយមកយូរហើយ តែនៅបីថ្ងៃទៀត តពីថ្ងៃនេះទៅព្រះរាជាទ្រង់នឹងដល់នូវបញ្ចភាពក្ស័យព្រះជន្មហើយ ខ្ញុំជាមនុស្សឥតទីពឹងនៅតទៅទៀតមិនបាន ព្រោះហេតុនេះហើយបានជាខ្ញុំទួញយំ” ។ ***វិរវរៈ*** សួរតទៅទៀតថា៖ “បពិត្រព្រះនាងលក្ស្មី! ធ្វើដូចម្តេចទើបព្រះនាង***ភគវតី***អាចនៅតទៅទៀតបាន?” ។ នាងរាជលក្ស្មីតបថា៖ “ថាបើអ្នកអាចសម្លាប់ ***សក្តិធរ***ជាកូនអ្នកដ៏ប្រកដោយមហាបុរិសលក្ខណៈ ៣២ ប្រការនេះចេញ ដោយដៃខ្លួនឯងបូជាជាពលីកម្មដល់ព្រះសរីមង្គលា ([១]) ព្រះរាជាម្ចាស់ផែនដីស្តេចក៏នឹងមានព្រះជន្មនៅបានដល់រយវស្សាឯខ្លួនខ្ញុំនឹងបានអាស្រ័យនៅជាសុខតទៅផង” និយាយដូច្នេះហើយ ព្រះនាងរាជលក្ស្មី អន្តរធានបាត់ទៅ

---

[១] ព្រះនាងទុគ៌ា សក្តិព្រះឥសូរ ។

ក្នុងកាលនោះឯង ។ លំដាប់នោះ ***វីរវរៈ*** លុះបានស្តាប់ពាក្យព្រះនាងរាជលក្ស្មីសព្វគ្រប់ហើយ មានចិត្តត្រេកអរណាស់ ត្រឡប់ទៅផ្ទះខ្លួនវិញទៅដល់ដាស់កូនប្រពន្ធដែលកំពុងដេកលក់ស្និទ្ធ ឲ្យក្រោកឡើងអង្គុយ ហើយនិយាយរៀបរាប់រឿងរ៉ាវ ដែលព្រះនាងរាជលក្ស្មីប្រាប់ ឲ្យស្តាប់សព្វអាថ៌សេចក្តី ។ ***សត្តិធរ*** ជាកូនបានស្តាប់សេចក្តីរហូតដល់ចប់ ក៏មានចិត្តរីករាយ និយាយដោយទឹកមុខស្រស់ញញឹមថា៖ "លោកឪពុក! ហេតុអ្វីលោកឪពុកពន្យារពេលឲ្យយឺតយូរដល់ម្ល៉េះ! ព្រោះអំពើប្រសើរបែបនេះ មិនត្រូវគិតពេលណាៗទេ ការលះបង់អត្តភាពខ្លួនទៅក្នុងកិច្ចស្នងព្រះករុណាទិគុណ នេះជាអំពើដ៏ប្រសើរក្រៃលែង, ព្រោះថា៖

១០០- អ្នកប្រាជ្ញគប្បីលះបង់នូវទ្រព្យផង នូវជីវិតផង ដើម្បីជាប្រយោជន៍ដល់ជនដទៃ ថាបើសេចក្តីស្លាប់ជាធម៌ទៀង គួរលះបង់អត្តភាពខ្លួនទើបប្រសើរ" ។

មាតា***សត្តិធរ*** និយាយបណ្តោយដោយសប្បាយចិត្តថា៖ "ស្វាមី! បើមិនគិតធ្វើការនេះជាប្រយោជន៍ដល់ព្រះរាជាជាម្ចាស់យើងទេ តើត្រូវធ្វើអ្វីដទៃពីនេះវិញ ដើម្បីតបស្នងព្រះករុណាទិគុណឲ្យសមតាមដំណើរដែលទ្រង់បានប្រទាន ព្រះរាជទ្រព្យនិងវត្ថុខ្ពង់ខ្ពស់នោះ? ។ ជនទាំង ៣ នាក់ប្រឹក្សាព្រមព្រៀងគ្នាដោយក្តីរីករាយស្មោះចំពោះដូច្នេះហើយ ក៏បបួលគ្នាទាំង ៣ នាក់ដើរទៅកាន់ទេវស្ថាន ព្រះនាង***សវ៌មង្គលា*** ទៅដល់ហើយ ***វីរវរៈ***ដាក់ខ្លួនចុះ លើកទសករប្រណម្យដោយគោរពទើបពោលថា៖ "បពិត្រព្រះនាងទេវី! សូមព្រះនាងមេត្តាប្រោស សូមព្រះមហារាជ ព្រះបាទ***សូទ្រកៈ***ជាម្ចាស់យើងទ្រង់មានជ័យជម្នះឈ្នះអស់មារសត្រូវ សូមព្រះនាងទទួលទេវពលីនេះ" ពោលហើយក៏កាត់***សត្តិធរ***ជាកូនមួយរំពេចនោះជាគ្រឿងពលី ។ ក្រោយពីហេតុភេទនេះ ***វីរវរៈ***រំពឹងគិតថា "អាត្មាអញបានធ្វើអំពើដ៏ប្រសើរ តបស្នងព្រះករុណាទិគុណព្រះមហាក្សត្រិយ៍ធួនល្មមដល់រង្វាន់រាល់ខែ ដែលទ្រង់ប្រទានឲ្យអាត្មាអញរស់នៅក៏ជាភារៈធ្ងន់ឥតអំពើ" គិតហើយគិតទៀតឃើញថា នឹងរស់តទៅទៀតមិនសម ក៏កាត់កខ្លួនស្លាប់ទៀត ។ ឯភរិយា ក៏មានសេចក្តីសោកស្តាយ ក្នុងរឿងស្វាមី និងកូនមិនតិច ទើបសម្លាប់ខ្លួនទៅតាមស្វាមីនិងកូននោះថែមទៀត ។ ព្រះបាទ***សូទ្រកៈ*** ទ្រង់ប្រថាប់នៅក្បែរទីស្ថាននោះដែរ ទ្រង់បានព្រះសណ្តាប់ ទ្រង់បានទតព្រះនេត្រប្រព្រឹត្តិហេតុតាំងពីដើមដល់ចុងរហូតតក់ស្លុតរន្ធត់ព្រះទ័យ ទ្រង់រំពឹងគិតថា៖

១០១- មនុស្សអន់បែបដូចអាត្មាអញនេះ តែងកើតមានហើយស្លាប់បាត់ទៅវិញ, តែក្នុងលោកនេះ មនុស្សបែប***វីរវរៈ***នេះមិនសូវដែលមាន ហើយមិនសូវនឹងកើតមានទេ ។ បើដូច្នេះ អ្នកអស់នេះស្លាប់ចោលអាត្មាអញអស់ទៅហើយ សូម្បីមានរាជសម្បត្តិក៏មានប្រយោជន៍អ្វី? ទ្រង់រំពឹងហើយឃើញថានឹងរស់តទៅមិនកើត ទ្រង់ក៏ចាប់ព្រះសែងថ្លាមកបម្រុងនឹងកាត់ព្រះសិរសាព្រះអង្គ ។ លំដាប់នោះ, ព្រះនាង

***សរីមង្គលាភគវតី*** ក៏ផ្តែងខ្លួនឲ្យឃើញប្រាកដដោយករុណាដ៏ខ្លាំង ចាប់ព្រះករព្រះបាទ**សូទ្រកៈ**ជាប់ហើយត្រាស់ថា៖ "កូនអើយ! យើងមានសេចក្តីពេញចិត្តហើយ ណ្ហើយកុំសម្លាប់ខ្លួនឯង សព្វបើសេនាមាត្យខ្លួនប៉ុណ្ណោះ រាជសម្បត្តិអ្នកនឹងស្ថិតស្ថេររហូតមួយជីវិតអ្នក មិនវិនាសអន្តរាយទេ" ។ ព្រះបាទ**សូទ្រកៈ**ដាក់ព្រះអង្គចុះក្រាបប្រណម្យដោយអស្តាង្គបាត ហើយទូលថា៖ "បពិត្រព្រះនាងទេវី! ប្រយោជន៍អ្វីដោយរាជសម្បត្តិនេះ? កាលបើខ្ញុំព្រះអង្គមានជីវិតរស់នៅ តើមានប្រយោជន៍ដូចម្តេចខ្លះ? បើខ្ញុំព្រះអង្គសមគួរនឹងបានទទួលមេត្តា សូមឲ្យ***វីរវរៈ***រាជបុត្រជាសេវកាមាត្យខ្ញុំព្រះអង្គនេះ ព្រមទាំងបុត្រភរិយាមានជីវិតឡើងវិញ បើមិនដូច្នោះទេ ខ្ញុំព្រះអង្គនៅតែតាំងព្យាយាមសម្លាប់ខ្លួនទៅតាមគំនិតដែលបានតាំងទុករួចហើយ" ។ ព្រះនាង***ទូគ៌ាភគវតី***ត្រាស់តបថា៖ "កូនអើយ! យើងមានសេចក្តីពេញចិត្តណាស់ ព្រោះកូនមានចិត្តសប្បុរស មានចិត្តស្មោះត្រង់នឹងសេវកាមាត្យ ឯងចូរត្រឡប់ទៅចុះ ចូរឲ្យឯងមានជ័យជម្នះ ចូរឲ្យ***វីរវរៈ***ព្រមទាំងបុត្រភរិយាមានជីវិតរស់ឡើងឥឡូវនេះ" ។ ត្រាស់តែប៉ុណ្ណោះ នាងក៏អន្តរធានបាត់ទៅ ។ លំដាប់នោះ, ស្ទើរតែមិនទាន់ផុតផ្សែងផង ***វីរវរៈ***ព្រមទាំងបុត្រភរិយារស់ឡើងវិញភ្លាម ហើយបបួលគ្នាវិលត្រឡប់ត្រសងទៅកាន់ផ្ទះវិញ ។ ឯព្រះបាទ**សូទ្រកៈ** ជនទាំង ៣ នាក់នោះមិនបានឃើញទេ ទ្រង់ស្តេចត្រឡប់ទៅកាន់រាជនិវេសវិញ ។ លុះព្រឹកព្រាងឡើង ***វីរវរៈ***ទៅចាំទ្វារដូចប្រក្រតីដើម កាលព្រះរាជាត្រាស់សួរ គាត់ក៏ក្រាបទូលថា៖ "បពិត្រព្រះទេវវង្ស! មាននាងរូបល្អម្នាក់យំសោយសោក កាលឃើញទូលព្រះបង្គំជាខ្ញុំហើយ ក៏អន្តរធានបាត់ទៅ មិនឃើញមានហេតុភេទអ្វីផ្សេងដទៃទៀតទេ" ។ ព្រះបាទ**សូទ្រកៈ** កាលទ្រង់បានព្រះសណ្តាប់ហើយ ទ្រង់ព្រះតំរិះថា៖ "មហាបុរសបែបនេះ នឹងសរសើរដូចម្តេចឲ្យសមគួរ? ព្រោះថា៖

១០២- អ្នកមានចិត្តអាណិតតែងពោលពាក្យជាទីគាប់ចិត្ត អ្នកក្លៀវក្លាតែងមិនពោលអួតខ្លួន អ្នកឲ្យទានតែងឲ្យទានមិនរើសមុខ អ្នកមានប្រាជ្ញាប្រតិភាណតែងមិនកោងកាច ។

នេះជាលក្ខណៈមហាបុរស មាននៅក្នុងរូប***វីរវរៈ***ទាំងមូល" ។

ព្រឹកថ្ងៃមួយ, ព្រះបាទ**សូទ្រកៈ**ទ្រង់ត្រាស់បង្គាប់ឲ្យប្រជុំសភាជាន់ខ្ពស់ ហើយទ្រង់ប្រកាសប្រព្រឹត្តិការណ៍ដែលមានក្នុងយប់នោះទាំងអស់ ទើបទ្រង់ប្រទានប្រទេសកណ៌ាដកៈឲ្យ***វីរវរៈ***គ្រប់គ្រងដោយទ្រង់មានសេចក្តីពេញព្រះទ័យខ្លាំង ។ រាជហង្ស**ហិរណ្យគគ៌** និយាយបញ្ជាក់ថែមទៀតថា៖ "បើដូច្នេះ ថ្វីបើគ្រាន់តែជាអាគន្តុកសុទ្ធតែជាសត្រូវទាំងអស់ទៅឬ? ក្នុងពួកជនជាអាគន្តុកទាំងអស់ តែងមានខ្លះល្អ ខ្លះអាក្រក់ មានខ្លះទៀតតាំងនៅកណ្តាល ដូចគ្នានឹងអ្នកនៅក្នុងស្រុកដែរ" ។ **ចាក្រពាកសវិជ្ជៈ** ពោលសុភាសិតតទៅថា៖

១០៣- នរជនណាណែនាំព្រះរាជាក្នុងការមិនគួរធ្វើ ថាជាការគួរធ្វើ ដើម្បីបំពេញព្រះទ័យព្រះនរបតី នរជននោះសមធ្វើជាមន្ត្រីឬទេ? ការធ្វើឲ្យលំបាកព្រះទ័យម្ចាស់ ប្រសើរជាងការធ្វើឲ្យម្ចាស់វិនាស ព្រោះការនេះគ្រាន់តែជាកិច្ចមិនគួរប៉ុណ្ណោះទេ ។

១០៤- ព្រះរាជាអង្គណា មានទ្រព្យ រាជគ្រូ និងមន្ត្រីសុទ្ធតែជាអ្នកបញ្ឆោរ ព្រះរាជាអង្គនោះ នឹងស្គមព្រះសរីរៈ ថយគុណធម៌ នឹងអន្តរាយឃ្លាំងដោយឆាប់រហ័ស ។

សូមព្រះករុណាមេត្តាប្រោសទ្រង់ព្រះសណ្តាប់!

១០៥- ទ្រព្យណាដែលត្រូវបានដោយបុណ្យ ទ្រព្យនោះយើងគួរគប្បីចង់បាន ជាងកោរសក់ម្នាក់ជាអ្នកចង់បានទ្រព្យ សម្លាប់យាចកព្រោះល្មោភលោភលន់ពន់ប្រមាណ ក៏ត្រូវស្លាប់ខ្លួនឯងវិញ ។

រាជហង្ស**ហិរណ្យគក៌** សួររឿងនោះថា៖ "ចុះរឿងនោះតើដូចម្តេច?" ។ **ចាក្រពាកសវិជ្ជៈ** រៀបរាប់រឿងនោះដូចសេចក្តីតទៅថា៖

# កថាទី១០

## រឿងជាងកោរកាត់ល្មោភ

នៅក្រុងអយោធ្យា មានក្សត្រិយ៍មួយអង្គឈ្មោះ **ចូឌាមណី** ជាអ្នកល្មោភចង់បានទ្រព្យ ។ **ចូឌាមណី** នឿយខ្លួនយ៉ាងខ្លាំងដើម្បីបូជាព្រះឥសូរដ៏មានបុណ្យ ដែលទ្រទ្រង់នូវអធិចន្ទ្រជា**ចូឌាមណី** អស់កាលយូរលង់ណាស់ហើយ ។ ថ្ងៃមួយ ក្នុងកាលជាខាងក្រោយមក, **ចូឌាមណី** ជម្រះខ្លួនលាងបាបរួចហើយ ប្រាស់ខ្លួនដេកលក់ទៅ អាស្រ័យដោយសេចក្តីប្រោសប្រាណព្រះឥសូរដ៏មានបុណ្យ ក៏យល់សប្តិឃើញព្រះបាទ**កុវេរយក្ខ**មកបញ្ជាប្រាប់ថា៖ "នែក្សត្រិយ៍! ស្អែកនេះឯងចូរឲ្យជាងកោរកាត់មកកោរពីព្រឹកព្រលឹម កោរហើយ កាន់ដំបងមួយទៅឈរអែបប្រឡបទ្វារផ្ទះខ្លួន កាលឃើញយាចកណាចូលមកក្នុងអាណាខេត្តផ្ទះហើយ ចូរយកដំបងសំពងសម្លាប់ទៅកុំអាណិតឡើយ ធ្វើដូច្នេះ យាចកនោះនឹងក្លាយទៅជាក្អមពេញដោយមាសមួយរំពេច ខ្លួនឯងព្រមទាំងបរិវារនឹងបាននៅជាសុខសប្បាយរហូតមួយជីវិត ។ ក្សត្រិយ៍ **ចូឌាមណី**ធ្វើតាមពាក្យបង្គាប់បញ្ជារហូត ផលក៏សម្រេចដូចបំណង ។ ឯជាងកោរកាត់ដែលមកនោះបានឃើញប្រព្រឹត្តិការណ៍ជាក់លាក់នឹងភ្នែកខ្លួន គិតតែក្នុងចិត្តម្នាក់ឯងថា៖ "ឱហ្ន៎! នេះជាឧបាយឲ្យកើតទ្រព្យសម្បត្តិទេតើ! បើដូច្នេះអាត្មាអញចាំបាច់ធ្វើអ្វីផ្សេងទៅទៀត?" ។ ចាប់តាំងពីថ្ងៃនោះមក ជាងកោរកាត់កាន់ដំបងមួយធំទៅឈរនៅអែបមាត់ទ្វាររាល់ព្រឹក ចាំឆ្មក់ក្រែងលោមានយាចកណាមួយចូលមកក្នុងអាណាខេត្តផ្ទះខ្លួន ។

ថ្ងៃមួយ, មានយាចកម្នាក់ចូលមកក្នុងទីលានផ្ទះ ជាងកោរកាត់យកដំបងវាយម៉កស្លាប់ទៅ ក៏ត្រូវរាជបុរសមកចោមចាប់ដោយអំពើទុច្ចរិតរបស់ខ្លួន ហើយវាយត្រូវដំណំច្រើនដងទាល់តែស្លាប់ទៅហោង ព្រោះហេតុនោះ បានជាខ្ញុំ (**ចាក្រពាក**) ពោលថា៖ “ទ្រព្យណាដែលត្រូវបានដោយបុណ្យ ដូច្នេះជាដើម” (លេខ ១០៥) ។ រាជហង្ស**ហិរណ្យគក៏** រករឿងមកពោលជំទាស់ថា៖

១០៦- ការដែលយកប្រព្រឹត្តិហេតុពីបុរាណមកសម្តែងជាគ្រឿងនិទស្សន៍ថា មនុស្សអាគន្តុកមកពីបរទេសថាជាមិត្តឥតចេតនាអាក្រក់ ឬថាជាមនុស្សក្បត់ជាតិនោះបានឬទេ? ។

ទៅ! ទៅ! ត្រូវធ្វើតាមដំណើរការដែលមកដល់ហើយ, មិនត្រូវគិតច្រើនពេកទេ ឥឡូវនេះ ស្តេចក្ងោក**ចិត្រពណ៌** លើកទ័ពមកតាំងនៅលើ**មលយបព៌ត**ហើយ យើងនឹងគិតគូរធ្វើអ្វីផ្សេងទៀត ។ **ចាក្រពាកសរ័ជ្ញះ** និយាយទៀតថា៖ “ទេវៈ! ខ្ញុំបាទបានព្ញចារបុរសយើងនិយាយប្រាប់ថា ស្តេចក្ងោក**ចិត្រពណ៌** មិនជឿស្តាប់ពាក្យដាស់តឿនត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីទេ បើដូច្នោះមែន ស្តេចក្ងោក**ចិត្រពណ៌** នេះជាមនុស្សល្ងង់ យើងមានផ្លូវយកជ័យជម្នះបានហើយ, ព្រោះថា៖

១០៧- លោភ ទ្រនង់យង់ឃ្នង ខ្ជិល មិនមានពាក្យសត្យ ធ្វេសប្រហែស ខ្លាច មិនម៉ឺងម៉ាត់ ល្ងង់ខ្លៅ មើលងាយយោធា ទាំងអស់នេះជាលក្ខណៈសត្រូវ ដែលបរបក្សយកជ័យជម្នះបានដោយងាយ ។

ដរាបណា សត្រូវយើងនេះមិនទាន់ទម្លាយបន្ទាយយើងបានទេ ដរាបនោះ យើងនឹងបញ្ជូនសេនាបតីទាំងឡាយមានក្រសារជាដើម ដើម្បីទៅកម្ចាត់បង់នូវសែន្យានុភាពនៃសត្រូវដែលតាំងបន្ទាយនៅស្ទឹង, ទន្លេ, ភ្នំ, ព្រៃ និងផ្លូវទាំងឡាយនោះៗ មុនសិន, ព្រោះថា៖

១០៨- នឿយហត់ដោយដើរផ្លូវឆ្ងាយ ទីមទាមដោយស្ទឹង ភ្នំ និងព្រៃ តក់ស្លុតដោយអគ្គីភ័យសម្បើម រហេមរហាមដោយឃ្លានបាយក្រហាយទឹក ។

១០៩- ធ្វេសប្រហែស ខ្វះខាតស្បៀងអាហារ មានព្យាធិ និងទុរភិក្សបៀតបៀន គ្រប់គ្រងកងទាហានមិនល្អ មិនមានវេហ៍ពលច្រើន ជ្រួលច្របល់លំបាកដោយភ្លៀងនិងខ្យល់ ។

១១០- ប៉ះបាច់ដោយភក់ ធូលី និងទឹក រសាំរសាយខ្វាត់ខ្វាយ ឬបៀតបៀនដោយសត្រូវ សែន្យាករនៃពៃរីមានប្រការដូច្នេះ ព្រះមហីបាលគប្បីពិឃាតបានងាយ ។

១១១- ព្រះរាជាគប្បីបំផ្លាញកងទ័ពសត្រូវដែលហត់នឿយ ដោយការយាមល្បាតជាដរាប ក្នុងពេលដែលដេកសម្រាកក្នុងវេលាថ្ងៃ ឬងងុយងោកងក់ដោយនិទ្រា ។

អាស្រ័យដោយហេតុនេះ គួរឲ្យក្រសារព្រមទាំងសត្វឯទៀតលើកកងពលទៅបំផ្លាញកងទ័ពសត្រូវដែលប្រមាទ សម្លាប់ចោលបង់ទាំងយប់ទាំងថ្ងៃកុំឲ្យសេសសល់តាមឱកាសដែលគួរ” ។ រាជ

ហង្សហិរណ្យគក៏ ប្រតិបត្តិតាមពាក្យណែនាំ**ចាក្រពាកសរីជ្ជះ**សព្វប្រការ ។ កាលនោះស្ដេចក្ងោក**ចិត្រពណ៌** ខូចខាតកងទ័ពនិងសេនាបតីអស់ជាច្រើន ហើយកើតទុក្ខធ្លាក់ទឹកចិត្ត បែរទៅនិយាយនឹង**ត្មាតទុរទសី** ថា៖ "ម្នាលបា! ម្ដេចក៏ឯងធ្វើព្រងើយកន្ដើយចំពោះយើង? ឬក៏ថាយើងមិនមានវិន័យដូចម្ដេចខ្លះ? ព្រោះថា៖

១១២- បុគ្គលមិនគប្បីធ្វេសប្រហែសដោយគិតថា ឈ្នះបានប្រទេសហើយ ដូច្នេះមិនគួរទេ ព្រោះថា ការមិនមានវិន័យអាចបំផ្លាញព្រះរាជាណាចក្របាន ដូចជរាធ្វើឲ្យរូបសោភាវិនាស ។

១១៣- ជនក្លៀវក្លាតែងបានទ្រព្យ ជនបរិភោគអាហាររលួយងាយតែងមិនមានរោគ ជនមិនមានរោគតែងបានសេចក្ដីសុខ ជនមានព្យាយាមតែងបានដល់ត្រើយនៃវិជ្ជា ជនមានវិន័យតែងបានសេចក្ដីចម្រើនទ្រព្យសម្បត្តិនិងយសសក្ដិ ។

ត្មាត**ទុរទសី**ឆ្លើយតបថា៖ "ទេវៈ! សូមលោកម្ចាស់ស្ដាប់!

១១៤- ព្រះភូមិបាលសូម្បីមិនមានការចេះដឹង ក៏អាចទទួលសេចក្ដីចម្រើនយ៉ាងឯកបាន ដោយការសេពគប់អ្នកចេះដឹងវិជ្ជា ប្រៀបដូចព្រឹក្សាដុះក្បែរមេទឹកដូច្នោះ ។

១១៥- ប្រមឹកសុរា ស្រវឹងដោយនារី វក់ការបរបាញ់ លេងល្បែងភ្នាល់ រិបជាន់ទ្រព្យសម្បត្តិ វាចាអាក្រក់ ទណ្ឌកម្មដ៏អាក្រក់ ទាំងអស់នេះជាសេចក្ដីអន្តរាយនៃព្រះរាជា ។

១១៦- អ្នកនាំដែលប្រព្រឹត្តហៅហានតាមតែទំនើងចិត្តខ្លួន ឬដែលខូចចិត្តក្នុងការធ្វើនយោបាយ រមែងមិនអាចទទួលផលដ៏ពិសាលបានឡើយ សេចក្ដីចម្រើនរមែងធ្លាក់មកនៅលើដៃនៃបុគ្គលអ្នកមាននយោបាយល្អ និងសេចក្ដីក្លៀវក្លាហាន ។

លោកម្ចាស់ឃើញកងទ័ពមានកម្លាំង មានសេចក្ដីប្រឹងប្រែងហើយប្រញាប់ប្រញាល់ធ្វើ ហៅហានតែម្យ៉ាង ឥតពិចារណាមើលងាយពាក្យណែនាំមន្ត្រីទាំងឡាយដែលដាស់តឿនព្រះស្មារតីដោយពាក្យជូរចត់មិនជាទីពេញចិត្ត ហេតុនេះហើយបានជាលោកម្ចាស់ត្រូវទទួលផលនៃវិធីដើរផ្លូវខុសនេះឯង, ព្រោះថា៖

១១៧- មន្ត្រីអាក្រក់ណាដែលមិនធ្វើឲ្យភ្លាត់ខុសក្នុងផ្លូវនយោបាយ? ជំងឺណាដែលមិនចាក់ដោតអ្នកឈឺដែលបរិភោគអាហារមិនល្អ? ទ្រព្យសម្បត្តិណាដែលមិនធ្វើនរជនឲ្យឡើងចាង? នរជនណាដែលម្រឹត្យុមិនសម្លាប់? នរជនណាដែលស្ត្រីធ្វើឲ្យលុះវិស័យវាហើយមិនរសាប់រសល់ខ្វល់ខ្វាយ ។

១១៨- សេចក្ដីសុបសៅទម្លាយបង់នូវសេចក្ដីរីករាយ, សរទកាលទម្លាយបង់នូវសោភាក្នុងរដូវក្ដៅ, ព្រះអាទិត្យទម្លាយបង់នូវងងឹត, ការមិនតបគុណទម្លាយបង់នូវសេចក្ដីល្អ, ការបានអ្វីមួយជាទីស្រឡាញ់ទម្លាយបង់នូវការខូចចិត្ត, នយោបាយល្អទម្លាយបង់នូវការវិបត្តិ, នយោបាយមិនល្អទម្លាយបង់នូវសិរីសួស្ដីដែលខ្លួនបានហើយ ។

ព្រោះហេតុនេះ បានជាខ្ញុំបាទត្រិះរិះថា៖ “ឱ! ស្តេចអង្គនេះហីនប្រាជ្ញាទេតើ! បើមិនមែនដូច្នោះទេ ធ្វើម្តេចនឹងមិនបង្គាប់នូវនីតិសាស្ត្រគឺ កថារបស់អញដូចជាពន្លឺព្រះចន្ទ្រកំពុងភ្លឺឲ្យអាប់អន់ដោយពាក្យអាក្រក់របស់លោកដូចជាគប់ភ្លើង? ព្រោះថា៖

១១៩- នរជនណាមិនមានប្រាជ្ញាខ្លួនឯង សាស្ត្រវិជ្ជានឹងធ្វើអ្វីដល់នរជននោះកើត? នរជនខ្វាក់ភ្នែកទាំងសងខាង កញ្ចក់និងធ្វើប្រយោជន៍អ្វីដល់នរជននោះបាន? ។

ខ្ញុំបាទគិតឃើញដូច្នេះហើយ បានជាអង្គុយនៅស្ងៀម” ។ កាលនោះ, ស្តេចក្អែក**ចិត្រពណ៌** យកម្រាមជើងទាំងពីរមកផ្គុំគ្នាជាទីគោរព ហើយពោលថា៖ “សំឡាញ់អើយ! ខ្ញុំខុសពិតមែនហើយ តែឥឡូវនេះ ចូរសំឡាញ់ប្រាប់ឧបាយមក ធ្វើដូចម្តេចខ្ញុំអាចនឹងលើកទ័ពដែលសេសសល់ទាំងប៉ុន្មានឲ្យត្រឡប់ទៅកាន់ភ្នំវិន្ធ្យាវិញបាន? ។ ត្មាត**ទុរទសី** រំពឹងគិតថា៖ “ដំណើរនេះ ត្រូវតែរកផ្លូវកែខៃ, ព្រោះថា៖

១២០- បុគ្គលគប្បីអត់សង្កត់សេចក្តីក្រោធចំពោះទេវតា, គ្រូ, គោ, ព្រះរាជា, ព្រាហ្មណ៍, កូនក្មេង, ចាស់ព្រឹទ្ធា និងមនុស្សឈឺទាំងឡាយ” ។

លុះគិតឃើញឧបាយដូច្នេះហើយញញឹមៗទើបពោលថា៖ “ទេវៈ! សូមលោកកុំភ័យថ្វី សូមលោកធ្វើចិត្តឲ្យត្រជាក់ ហើយដកដង្ហើមឲ្យស្រួលទៅចុះ, ទេវៈ! សូមលោកស្តាប់ពាក្យនេះ៖

១២១- ប្រាជ្ញាមន្ត្រី គេឃើញច្បាស់ក្នុងពេលធ្វើការងារផ្លាស់ស្ពានមេត្រី, ប្រាជ្ញាគ្រូពេទ្យ គេឃើញច្បាស់ក្នុងពេលព្យាបាលរោគសាំនិបាតក៏ (រោគកាច?) ព្រោះថា កាលបើកិច្ចការប្រព្រឹត្តទៅដោយល្អហើយ នរណាមួយមិនអួតខ្លួនថាជាបណ្ឌិត? ។

១២២- ដោយពិត, នរជនអប្បឥតប្រាជ្ញា សូម្បីប្រារព្ធធ្វើការតូចតាច, តែងសម្តែងអាការឡោះឡោះ ឯអ្នកមានប្រាជ្ញា សូម្បីប្រារព្ធធ្វើការធំៗ នៅនឹងថ្កល់ដូចថ្ម មិនសម្តែងអាការឡោះឡោះឡើយ ។

ខ្ញុំបាទនឹងលើកកងទ័ពលោកម្ចាស់យាត្រាចេញទៅទម្លាយបន្ទាយសត្រូវក្នុងទីនោះៗ ឥឡូវនេះ, មិនយូរប៉ុន្មាននឹងនាំលោកម្ចាស់ទៅកាន់ភ្នំវិន្ធ្យាវិញដោយកិត្តិយស និងតេជានុភាពដ៏ខ្ពង់ខ្ពស់ក្រៃលែង” ។

ស្តេចក្អែក**ចិត្រពណ៌**សួរទៀតថា៖ “ពេលនេះ យើងនឹងទៅតស៊ូទៀតម្តេចកើត បើកងទ័ពយើងតិចម្ល៉េះ?” ។ ត្មាត**ទុរទសី**ឆ្លើយដោយអង់អាចថា៖ “ទេវៈ! គេអាចនឹងសម្រេចបានគ្រប់ប្រការ ព្រោះថាអ្នកជាញជ័យតែងយកការឆាប់រ៉ៃ គឺមិនឲ្យជ្រលៀកយឺតយូរកន្លងពេលវេលា នេះជាលក្ខណ៍ក្នុងការយកជ័យឲ្យសម្រេចបានឥតសង្ស័យឡើយ, ព្រោះហេតុនេះ ត្រូវចាប់ចូលលុកវាយទម្លាយបន្ទាយសត្រូវយ៉ាងឆាប់រហ័សតាំងពីពេលនេះទៅ” ។

កាលនោះឯង, ក្រសារចារបុរសដែលរាជហង្ស**ហិរណ្យគភ៌** បញ្ជូនឲ្យស៊ើបការត្រឡប់មករាយ

ការប្រាប់ថា៖ "ទេវ:! ស្តេចក្អែក**ចិត្រពណ៌**បង្គាប់ឲ្យលើកវេហ៍ពលបន្តិចបន្តួចរបស់ខ្លួន ដែលនៅសេសសល់ឲ្យចូលបន្ទាយយើង តាមពាក្យឧបទេសគ្នាត**ទុរទសី**ហើយ" ។

រាជហង្ស**ហិរណ្យគក៏**សួរថា៖ "**នែសវ័ជ្ជ:**! ឥឡូវនេះតើយើងគិតធ្វើដូចម្តេចហ៎ះ?" ។ **ចាក្រពាក** ឆ្លើយតបថា៖ "ទេវ:! សូមលោកម្ចាស់ពិចារណាមើលកងពល យោធាណាមានសារៈ យោធាណាឥតសារៈ ឲ្យស្គាល់ច្បាស់លាស់ លុះបានស្គាល់យោធាច្បាស់ហើយ សូមប្រទានរង្វាន់ខាន់ខៅមានមាសប្រាក់សំពត់អាវជាដើម តាមសមគួរដល់គុណានុរូប ដើម្បីរក្សាទឹកចិត្តយោធា, ព្រោះថា៖

១២៣- ព្រះរាជាអង្គណាប្រមូលគៀរគរទ្រព្យសម្បត្តិសូម្បីមួយកាកិនី ([១]) ដែលមិនគួរខ្ជះខ្ជាយក្នុងការមិនគួរចាយ ទុកស្មើដូចជាទ្រព្យមួយពាន់និស្កៈ (២) តែដល់កាលគួរហើយ ទ្រង់ត្រូវបរិច្ចាកទ្រព្យទាំងកោដិ លក្ស៊ី (៣) មិនលះបង់នូវសីហៈពោលគឺព្រះរាជានោះឡើយ ។

១២៤- ក្នុងកាលធ្វើពលីកម្ម ១, ក្នុងកាលធ្វើវិវាហៈ ១, ក្នុងកាលអន្តរាយ ១, ក្នុងការកម្ចាត់បង់នូវសត្រូវ ១, ក្នុងការតម្កើងយស ១, ក្នុងការសង្គ្រោះមិត្ត ១, ក្នុងភរិយាជាទីស្រឡាញ់ ១, ក្នុងផៅពង្សដែលក្រីក្រ ១, វត្ថុ៨ប្រការនេះ ឱព្រះនរាធិបៈ! លោកមិនហៅថា ខ្ជះខ្ជាយទ្រព្យទេ ។

១២៥- សេចក្តីពិត, មនុស្សល្ងង់ ឈ្មោះថាធ្វើទ្រព្យទាំងអស់ឲ្យវិនាស ព្រោះខ្លាចការបង់ខាតទ្រព្យបន្តិចបន្តួច, អ្នកមានប្រាជ្ញាណាដែលបោះបង់ទ្រព្យសម្បត្តិចោល ព្រោះតែខ្លាចបង់ពន្ធច្រើន? ។

រាជហង្ស**ហិរណ្យគក៏**សួរឡើងថា៖ "ការចាយវាយម្ល៉ាទៅទើបសមគួរ? ព្រោះលោកពោលថា៖ "បុគ្គលគប្បីរក្សាទ្រព្យទុក ដើម្បីការពារក្តីអន្តរាយ" ដូច្នេះ ។ **ចាក្រពាកសវ័ជ្ជ:** ឆ្លើយថា៖ "បុគ្គលមានសិរីសួស្តី តើនឹងកើតមានអន្តរាយមកពីណា?" ។ រាជហង្ស**ហិរណ្យគក៏**ពោលថា៖ "លក្ស៊ី ចួនកាលក៏កម្រើកញាប់ញ័រដែរ" ។ **ចាក្រពាកសវ័ជ្ជ:**ឆ្លើយកាត់ថា៖ "ឯទ្រព្យសម្បត្តិដែលសន្សំទុកហើយក៏វិនាសសាបសូន្យដែរ បើដូច្នោះសូមលោកម្ចាស់តាំងចិត្តលះសេចក្តីកំណាញ់ទ្រព្យចោលឲ្យស្រឡះទៅ ហើយចាយវាយទ្រព្យសម្បត្តិឲ្យជារង្វាន់ខាន់ខៅ និងឲ្យយសស័ក្តិដល់យោធាក្លៀវក្លា ដើម្បីនឹងឲ្យអ្នកបម្រើលោកម្ចាស់បានទទួលសេចក្តីពេញចិត្ត, ព្រោះថា៖

១២៦- ទាហាននិងម្ចាស់ស្គាល់ចិត្តគ្នាទៅវិញទៅមក, មានសេចក្តីរីករាយ, មានចិត្តដាច់លះបង់ជីវិតជាពលី, ជាអ្នកមានត្រកូល, ជាអ្នកគឺមេទ័ពសរសើរហើយ អាចកម្រាបពលពៃរីបានដោយប្រពៃ ។

១២៧- ទាហានអ្នកច្បាំង មានវិន័យល្អ ព្រមព្រៀងគ្នា មានទឹកចិត្តដាច់ខាត សុទ្ធតែជាវីរយោធា

[១] ឈ្មោះជាតិរូបសម្រាប់ចាយមានតម្លៃតិច ។ ២ ឈ្មោះជាតិរូបមាសមានតម្លៃច្រើន ។ ៣ ទ្រព្យ, សំណាង, សិរី ។ល ។

សូម្បីតែ៥០០នាក់ ក៏ជាសម្លាប់ទ័ពសត្រូវមួយវាហិនី ([១])បាន ។

១២៨- ម្ចាស់ណាគិតតែខ្លួនម្នាក់ឯង ឥតពិចារណា កាចទ្រនង់ មិនដឹងឧបការៈគេ ម្ចាស់នោះត្រូវអ្នកបម្រើដែលប្រសើរលះបង់ចោល ។

១២៩- គុណសម្បត្តិដ៏ប្រសើរនៃព្រះនរបតីមាន ៤ ប្រការគឺ៖ ពាក្យសត្យ ១, សេចក្តីអង់អាច ១, សេចក្តីអាណិត ១, និងបរិច្ចាគទាន ១, ព្រះមហីបាលខ្វះខាតគុណសម្បត្តិនេះហើយ ត្រូវបានពាក្យគរហានិន្ទាពិតប្រាកដ ។

ក្នុងហេតុការណ៍ប្រាកដដូច្នេះ លោកម្ចាស់គួរហៅអាមាត្យទាំងឡាយឲ្យចូលមកប្រឹក្សា, ព្រោះថា៖

១៣០- នរជនណាប្រតិព័ទ្ធនឹងជនណា គប្បីមានការខ្ពង់ខ្ពស់ ឬការថោកទាបមួយអន្លើដោយជននោះ នរជននោះ គួរប្រគល់ជីវិតផង ទ្រព្យសម្បត្តិផង ដល់ជននោះដើម្បីប្រកបកិច្ចការទាំងពួង ។

១៣១- ព្រះរាជាអង្គណា យកអ្នកឆរបោក ឬស្ត្រី ពុំនោះកូនក្មេងធ្វើជាមន្ត្រីប្រឹក្សា ព្រះរាជាអង្គនោះ នឹងត្រូវប៉ើងដោយខ្យល់គឺ នយោបាយមិនល្អ ហើយនឹងលិចលង់ក្នុងសមុទ្រគឺការងារ ។

មួយទៀត, សូមព្រះទេវបាទស្តាប់ពាក្យនេះតទៅ៖

១៣២- ព្រះរាជាអង្គណា មានសេចក្តីរីករាយ និងសេចក្តីក្រោធស្មើគ្នា មានសេចក្តីត្រេកអរក្នុងសាស្ត្រ និងអាចមានការទំនុកបម្រុងអាមាត្យអស់កាលជានិច្ច ផែនដីគប្បីចម្រើននូវទ្រព្យចំពោះព្រះរាជាអង្គនោះ ។

១៣៣- ក្នុងកាលណាក៏ដោយ ព្រះរាជាមិនគួរគប្បីមើលងាយអាមាត្យដែលធ្លាប់បានរុងរឿងនិងអាប់ឱនជាមួយព្រះអង្គ ដោយយល់ថាវាគ្រាន់តែជា “អាមាត្យ” ដូច្នេះឲ្យសោះ ។

១៣៤- ព្រះរាជាងងឹតងងល់ដោយការស្រវឹងរាជ្យ តែងធ្លាក់ផុងព្រះអង្គទៅក្នុងកណ្តាលការងារច្របូកច្របល់ ដូចជាដំរីផុងជាប់ភក់មានតែមន្ត្រីជាមិត្តពិតប្រាកដទេ ដែលលូកដៃចូលទៅជួយព្រយុងស្រង់ព្រះអង្គបាន” ។

ខណៈនោះ, ក្អែក**មេឃពណ៌**ចូលទៅដល់ លើកទសករប្រណម្យ ហើយជម្រាបថា៖ “ទេវៈ! សូមលោកមេត្តាប្រោសទស្សនាការឥឡូវ! ស្តេចក្ងោក**ចិត្រពណ៌**ជាបរបក្សបរពលសកលយោធាចូលមកឡោមព័ទ្ធប្រជិតបន្ទាយយើងហើយ បើទេវបាទមានបញ្ជាបង្គាប់នោះខ្ញុំបាទនឹងចេញទៅឥឡូវនេះ ដើម្បីតស៊ូសម្តែងឫទ្ធិថ្វីដៃដ៏ក្លាហានឲ្យឃើញប្រាកដជាកិច្ចតបសងគុណលោកម្ចាស់” ។ **ចាក្រពាកសរីជ្ជៈ**ស្រែក

---

[១] កងទ័ពដែលមានដំរី៨១, រថ៨១, ទាហានសេះ ២៤៣, ពលថ្មើរជើង ៤០៥នាក់ ។

កាត់ឡើងថា៖ “ទេ! ទេ! ចេញទៅមិនបានទេ បើយើងចេញតស៊ូ តើបន្ទាយជាប្រាការការពារយើងនេះមានប្រយោជន៍អ្វី! ព្រោះថា៖

១៣៥- ក្រពើ ដ៏កាចហៅហានពន្លឹក បើចេញផុតពីទឹកហើយ ក៏អន់អំណាច, សីហៈ សូម្បីសាហាវយង់ឃ្នង បើចេញផុតពីព្រៃហើយ ដូចគ្នានឹងសត្វចចក ។

ទេវៈ សូមលោកម្ចាស់ចេញទៅពិនិត្យមើល ឲ្យឃើញច្បាស់ ហើយតស៊ូដោយខ្លួនឯង, ព្រោះថា៖

១៣៦- ការបរពលចូលប្រយុទ្ធ ព្រះរាជាគប្បីទតព្រះនេត្រត្រួតត្រាមើល ហើយពោលពាក្យលើកទឹកចិត្តយោធាឲ្យក្លាហាន ឲ្យចូលតស៊ូផ្ចាញ់សត្រូវ សូម្បីសុនខ កាលបើម្ចាស់ឈរពន្យុះនៅជិតហើយនឹងសម្ដែងខ្លួនដូចជារាជសីហាពិតប្រាកដមិនមែនឬអ្វី? ។

គ្រានោះ, រាជហង្ស**ហិរណ្យគក៏**បរពលលើកចេញទៅតាំងទ័ពនៅទ្វារបន្ទាយធ្វើសង្គ្រាមជាញជ័យធំសែនសាហ័ស ។ លុះព្រឹកព្រាងឡើង ស្ដេចក្ងោក**ចិត្រពណ៌**សួរទៅត្មាត**ទុរទសី**ថា៖ “នែលោកមន្ត្រីជាទីស្រឡាញ់! ចូរលោកចាត់ការតាមដែលបានប្ដេជ្ញាទុកពីកាលមុនចុះ” ។ ត្មាត**ទុរទសី**ឆ្លើយតបថា៖ “ទេវៈ! សូមលោកម្ចាស់ស្ដាប់ពាក្យនេះ៖

១៣៧- អ្នកប្រាជ្ញពោលថា បន្ទាយដែលមានក្ដីអន្តរាយ គឺបន្ទាយមិនមាំទ្រាំតស៊ូយូរមិនបាន, តូចពេក, មេបញ្ជាការល្ងង់ ឬគម្រក់ ការពារមិនល្អ មានតែយោធាកម្លាច ។

១៣៨- ញុះញង់បំបែកឲ្យកើតក្បត់ ១, ឡោមព័ទ្ធទុកឲ្យបានយូរ ១, ចូលលុកចោមវាយ ១, ក្លាហានក្រៃលែង ១, ទាំង៤ ប្រការនេះ លោកពោលថាជាមធ្យោបាយសម្រាប់វាយបន្ទាយឲ្យបែក ។

ក្នុងពេលនេះ, ត្រូវបញ្ចេញសេចក្ដីប្រឹងប្រែងឲ្យអស់ទំហឹងតាមកម្លាំងដែលអាចធ្វើបាន” និយាយដូច្នេះហើយត្មាត**ទុរទសី**ឱនទៅខ្សឹបដាក់ជិតត្រចៀក**ចិត្រពណ៌**ប្រាប់ថាយើងនឹងធ្វើយ៉ាងនេះ ។ ព្រឹកព្រាង, ព្រះអាទិត្យមិនទាន់រះឡើង កាលសង្គ្រាមដ៏សាហ័សកំពុងតែប្រយុទ្ធតគ្នានៅទ្វារបន្ទាយទាំង៤ ឯពលក្អែកទាំងឡាយក៏យកភ្លើងទៅដុតបំផ្លាញគេហដ្ឋាននៅខាងក្នុងបន្ទាយ, ខណៈនោះ ឮសូរសម្រែកគឹកកងរំពងគ្រប់ទិសទីថា៖ “បន្ទាយបែកហើយ! បន្ទាយបែកហើយ!” ។ លុះឮសូរសម្រែកកោលាហលដូច្នេះ មើលទៅឃើញឆេះផុសសន្ធោសន្ធៅសព្វកន្លែង ស្ដេចហង្ស**ហិរណ្យគក៏** ព្រមទាំងវេហ៍ពលសកលយោធាបណ្ដាដែលនៅក្នុងបន្ទាយទាំងប៉ុន្មានជ្រួលច្របល់បបួលគ្នាប្រញាប់ប្រញាល់រត់ធ្លាក់ទឹកទាំងអស់, ព្រោះថា៖

១៣៩- កាន់យកពាក្យបញ្ជាម៉ត់ចត់ ១, សម្ដែងទឹកចិត្តក្លាហានមុះមុត ១, តយុទ្ធច្បាំងម៉ឺងម៉ាត់ ១, ថយទ័ពរត់រៀបរយល្អ ១, បើកាលយ៉ាងនេះមកដល់ហើយ បុគ្គលគប្បីធ្វើភ្លាមតាមការដែលអាចធ្វើបាន

កុំរេរង់ឡើយ ។

គ្រាកាលនោះ, រាជហង្ស**ហិរណ្យគក៏** តែងមានដំណើរយឺតៗតាមសភាពខ្លួន ព្រោះមាននិស្ស័យធ្លាប់សោយសុខ រត់ចេញទៅឥតមានអ្នកណាហែហមមានតែក្រសារជាសេនាបតីជាគ្នា ពេលនោះ មាន់ជាសេនាបតីនៃស្តេចក្ងោក**ចិត្រពណ៌** ចូលមកឡោមព័ទ្ធបិទផ្លូវបាន រាជហង្ស**ហិរណ្យគក៏** នឹកទាន់ពោលភ្លាមថា៖ "លោកសេនាបតី! លោកកុំនៅឲ្យគេសម្លាប់ ព្រោះតែលោកមានភក្តីចំពោះខ្ញុំធ្វើអ្វី ពេលនេះលោកនៅមានពេលអាចរត់គេចបានទេតើ រត់ទៅ! មុជចុះទៅក្នុងទឹកហើយរក្សាខ្លួនឲ្យបានសុខ កាលលោករួចខ្លួនហើយ ចូរលើកយកកូនខ្ញុំឈ្មោះ**ចូឌាមណី**ឲ្យឡើងសោយរាជ្យជំនួសខ្ញុំ ក្រោយដែលបានស្នើមតិ**ចាក្រពាកសព៌ជ្ញះ**ទៅឃើញថាព្រមព្រៀងផង ។ ក្រសារសេនាបតីឆ្លើយតបដោយរអាក់រអួលថា៖ "ទេវៈ! សូមលោកម្ចាស់កុំមានប្រសាសន៍យ៉ាងនេះ ពាក្យលោកម្ចាស់នេះធ្វើឲ្យខ្ញុំបាទតឹងទ្រូងណាស់ ដរាបណាព្រះចន្ទ្រ និងព្រះអាទិត្យនៅតែមានពន្លឺ ដរាបនោះ សូមឲ្យលោកម្ចាស់មានជ័យ, ទេវៈ! ខ្ញុំបាទជាសេនាបតីត្រួតត្រាការពារបន្ទាយ បើបច្ចាមិត្តចូលមកបាន លុះត្រាតែទ្វារបន្ទាយនេះប្រឡាក់ក្រហមច្រាលដោយឈាម និងសាច់ខ្ញុំបាទ, ព្រោះថា៖

១៤០- សេវកាមាត្យ រកម្ចាស់ប្រកបដោយគុណ គឺមានចិត្តសទ្ធាជាអ្នកអត់ធន់ ស្គាល់តម្លៃអាមាត្យបានដោយក្រ" ។

ស្តេចហង្ស**ហិរណ្យគក៏** ឆ្លើយតបថា៖ "ពិតមែនហើយ, តែថាតាមដែលខ្ញុំដឹង សេវកាមាត្យដែលទៀងត្រង់ វាងវៃ មានភក្តី ក៏ជាបុគ្គលរកបានដោយកម្រដែរ" ។

ក្រសារសេនាបតីពោលតទៅទៀតថា៖ "ទេវៈ! សូមលោកម្ចាស់ស្តាប់៖

១៤១- ថាបើបុគ្គលគេចរត់ចេញពីសង្គ្រាមក្នុងសមរភូមិ ហើយមិនមានភ័យពីក្តីស្លាប់ទេ ដូច្នេះក៏គួរគេចរត់ចេញទៅទីដទៃដែរ តែបើសេចក្តីស្លាប់ជាធម៌ទៀងសម្រាប់សត្វគ្រប់រូបគ្រប់នាមហើយ ហេតុអ្វីក៏ត្រូវឲ្យកិត្តិយសរបស់ខ្លួនប្រឡាក់សៅហ្មង ដោយទទេឥតប្រយោជន៍? ។

១៤២- ពិភពលោកនេះ មានតែការបែកធ្លាយ ដូចជាការឃ្លេងឃ្លោងនៃរលកទឹកដែលខ្យល់បោកបក់រំលាយហើយ ការលះបង់ជីវិត ដើម្បីប្រយោជន៍ជនដទៃ ឈ្មោះថាប្រកបកិច្ចការជាបុណ្យ ។

១៤៣- ម្ចាស់ផែនដី ១, អាមាត្យ ១, អាណាចក្រ ១, បន្ទាយ ១, ឃ្លាំង ១, សែន្យានុភាព ១, សម្ពន្ធមិត្ត ១, ពលរដ្ឋ ១, សង្គមប្រជាករ ១, ទាំងអស់នេះជាអង្គនៃរាជ្យគឺប្រទេសជាតិ ។

ទេវៈ! បើដូច្នេះ សូមលោកម្ចាស់រក្សាព្រះអង្គឲ្យស្ថិតស្ថេរតទៅដោយប្រការទាំងពួង, ព្រោះថា៖

១៤៤- ប្រក្រតី គឺពលរដ្ឋ សូម្បីចម្រើនធំប៉ុនណាក៏ដោយ បើព្រះរាជាជាម្ចាស់លះបង់ចោលហើយ មិនស្ថិតស្ថេរនៅបានទេ ដូចធន្វន្ត្រីជាពេទ្យទេពតា បើនរជនដល់កាលមរណៈហើយនឹងធ្វើអ្វីកើត? ។

១៤៥- កាលបើចមនរជន បិទព្រះនេត្រ (ទិវង្គត) ហើយ លោកទាំងមូលក៏បិទភ្នែក (ស្លាប់) ទៅតាមដែរ, កាលបើទ្រង់តើន (កើត) ឡើង លោកទាំងមូលក៏កើតឡើងដែរ ដូចផ្កាឈូកកាលព្រះអាទិត្យអស្តង្គតក៏រួយ, កាលព្រះអាទិត្យរះក៏រីកទទួល ។

តែបណ្តាអង្គទាំងឡាយនេះ អង្គធំជាប្រធានជាងគេនោះគឺព្រះរាជា ។ គ្រានោះឯង, មាន់មេទ័ពស្តេច**ចិត្រពណ៌**លុកចូលមកដល់ ហើយស្ទុះចូលទៅច្រាសរាជហង្ស**ហិរណ្យគក៏** ដោយខ្នាយរឹងដ៏ក្រៃលែងរបស់ខ្លួន ខណៈនោះក្រសាវសេនាបតីរាជហង្ស ឃើញដូច្នោះ ស្ទុះភ្លែតទៅរាំងយកខ្លួនការពារស្តេច បើទុកជាមាន់ចឹកដោយចំពុះស្រួច ចាក់ដោយខ្នាយរឹងមុត ដាច់សាច់សុះសព្វខ្លួនឈាមហូរណ្ហាច ក្រសារនៅតែយកខ្លួនជាបន្ទាយការពាររាជហង្សដរាបដល់ទីបំផុត នាំរាជហង្សចុះទឹកបាន ។ ឯមាន់សេនាបតីស្តេចក្ងោក ត្រូវក្រសារសេនាបតីរាជហង្ស ចឹកដោយចំពុះស្រួចសម្លាប់បាន ។ ខណៈនោះ, កងពលមាន់ឃើញមេទ័ពខ្លួនស្លាប់ដូច្នោះ ក៏បបួលគ្នាមកទាំងហ្វូងព្រួតគ្នាចោមចឹកចោមចាក់ក្រសារជាសេនាបតីនៃរាជហង្ស គ្រាំគ្រាដល់កាលមរណៈទៅហោង ។ ឯស្តេចក្ងោក**ចិត្រពណ៌** ចូលទៅក្នុងបន្ទាយបាន បង្គាប់យោធាឲ្យរឹបយកទ្រព្យសម្បត្តិដែលសេសសល់នៅក្នុងបន្ទាយទាំងប៉ុន្មាន ហើយលើករេហ៍ពលសកលយោធាត្រឡប់ទៅកាន់បន្ទាយខ្លួនវិញ ឮតែសូរស័ព្ទស្រែកហោសរសើរឲ្យពរជ័យថា៖ "ជយោ! ជយោ!" គឹកកងរំពងទូរទ័រផែនដី ។

ព្រះរាជកុមារទាំងឡាយត្រាស់ឡើងថា៖ "ក្នុងកងទ័ពស្តេចហង្ស**ហិរណ្យគក៏** ក្រសារជាបុគ្គលគួរបានពាក្យសរសើរថាជាអ្នកចិត្តបុណ្យ ព្រោះបានយកខ្លួនការពារស្តេចថ្វាយជារាជពលី, ព្រោះថា៖

១៤៦- មេគោសម្រាលកូនគោ សុទ្ធសឹងតែមានទ្រង់ទ្រាយដូចមេគោដោយច្រើន រីមេគោបង្កើតកូនបានជាម្ចាស់គោ (គោឧសភ) មានស្នែងងស្មើនដល់ដងខ្លួន កម្រមានណាស់!" ។

មហាបណ្ឌិត**វិស្ណុស័ម៌ន**ពោលថែមទៀតថា៖ "សូមឲ្យក្រសារជាសេនាបតី ជាមហាសត្វមានចិត្តប្រសើរ បានទៅកើតក្នុងសុគតិលោក ដោយគុណសម្បត្តិប្រសើររបស់លោក ហើយឲ្យបានចោមរោមហែហមដោយនាងវិទ្យាធរី សោយសេចក្តីសុខក្នុងឋានសួគ៌និរន្តរ៍ទៅហោង, ព្រោះថា៖

១៤៧- នរជនណាក្លៀវក្លាហាន លះបង់ជីវិត ដើម្បីម្ចាស់ក្នុងសង្គ្រាម មានភក្តីចំពោះអ្នកចិញ្ចឹមជាបុគ្គលកតញ្ញូ នរជននោះទៅកាន់ឋានសួគ៌ ។

១៤៨- វីរបុរសជាតិអ្នកច្បាំង ដែលសត្រូវឡោមព័ទ្ធជាប់ហើយ គេបំណងប្រហារជីវិតបង់ក្នុងទីណាក៏ដោយ មិនតក់ស្លុតលះបង់ឋានៈជាកូនប្រុស នឹងបានទៅដល់អមរលោក” ។

ឥឡូវនេះ ទ្រង់ទាំងឡាយបានស្ដេចព្រះសណ្ដាប់រឿងសង្គ្រាមចប់ហើយ ។ ព្រះរាជកុមារទាំងឡាយក៏ថ្លែងព្រះបន្ទូលគ្រប់ព្រះអង្គតបវិញថា៖ “យើងខ្ញុំគ្រប់គ្នាមានសេចក្ដីត្រេកអរក្រៃលែង ដោយបានស្ដាប់រឿងនេះ” ។ មហាបណ្ឌិត**វិស្ណុស័ម៌ន** ក្រាបបង្គំទូលតទៅថា៖ “សូមទ្រង់ទាំងឡាយ ព្រះសណ្ដាប់ស្លោកទីបំផុតនេះថែមទៀត៖

១៤៩- សូមព្រះរាជកុមារទាំងឡាយកុំបានជួបប្រទះសឹកសង្គ្រាម ដែលប្រកបដោយពលដំរី, សេះ និងយោធាទាំងឡាយ ដូច្នេះឡើយ សូមឲ្យអរិន្ទរាជពួកបច្ចាមិត្តបាក់បបខ្ចបខ្ចាចបារមី ដោយគ្រាន់តែខ្យល់ គឺព្រះរាជនយោបាយ ហើយរត់ខ្ចាត់ខ្ចាយទៅពួនលាក់ខ្លួននៅនាព្រៃភ្នំក្រំថ្មវិនាសគ្រប់កាលទៅហោង” ។

កថាសង្គ្រោះទី ៣ ឈ្មោះសង្គ្រាម ដែលមានមកក្នុងហិតោបទេសចប់តែប៉ុណ្ណោះ ។

ស្រីហិតោបទេសភាគ ៣

ចប់តែប៉ុណ្ណោះ

# ស្រី

# ហិតោបទេស

ភាគទី ៤

## ឈ្មោះ "សន្តិភាព"

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស. ២៥៣៨

នារាយណបណ្ឌិត

# ស្រី

# ហិតោបទេស

ភាគទី ៤

# ឈ្មោះ “សន្ធិភាព”


ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

ជា

អ្នកបកប្រែចេញពីភាសាសំស្ក្រឹត



ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥០៣ គ.ស ១៩៦០

ចារឹកឡើងវិញ៖ ណុល ដារ៉ា

២០០៩

# បញ្ជីរឿង


| | | |
|---|---|---|
| កថាមុខ | | ទំព័រ ក |
| ៤. សន្តិភាព | | ៣ |
| កថាទី ១ | រឿងអណ្តើក និងហង្ស | ៤ |
| កថាទី ២ | រឿងត្រី ៣ រូប | ៤ |
| កថាទី ៣ | រឿងពាណិជ, ភរិយា និងអ្នកបម្រើ | ៥ |
| កថាទី ៤ | រឿងកុក, ពស់ និងស្ការ | ៦ |
| កថាទី ៥ | រឿងកណ្តុរ និងតាបស | ៨ |
| កថាទី ៦ | រឿងកុក និងក្តាម | ៩ |
| កថាទី ៧ | រឿងព្រាហ្មណ៍វាយបំបែកក្រឡ | ១១ |
| កថាទី ៨ | រឿងសុន្ទៈ និងឧបសុន្ទៈ | ១២ |
| កថាទី ៩ | រឿងព្រាហ្មណ៍ និងអ្នកលេង | ១៨ |
| កថាទី ១០ | រឿងសីហៈ, ក្អែក, ខ្លា, ចចក និងឧដ្ឋ | ១៩ |
| កថាទី ១១ | រឿងពស់ និងកង្កែប | ២១ |
| កថាទី ១២ | រឿងព្រាហ្មណ៍ និងស្ការ | ២៧ |

_ក_

# កថាមុខ

នេះហិតោបទេសភាគទី ៤ ។ ការដែលបានធ្លាក់មកដល់ដៃអ្នកអានទាំងឡាយ ខ្ញុំរីករាយសប្បាយចិត្តណាស់ ព្រោះបំណងដែលខ្ញុំតាំងចិត្តមកយូរយារណាស់ហើយនោះ បានសម្រេចក្នុងថ្ងៃនេះហើយ បំណងនេះទុកជាយឺតយូរបន្តិចក៏មិនឈ្មោះថាស្កុនដំណើរទេដែរ ។ ខ្ញុំសូមអរគុណអ្នកអានដែលយកចិត្តទុកដាក់អានតក្នុងទីនេះផង ។

អស់លោកអ្នកអានទាំងឡាយ គង់បានជ្រាបហើយថា "ហិតោបទេសនេះ" លោកចែកជា ៤ ភាគ ។ ការបែងចែកជា ៤ ភាគនេះ ព្រោះលោកយល់ឃើញថា "ជីវិតមនុស្សម្នាក់ៗមានគ្រោះថ្នាក់ច្រើនបែបយ៉ាងណាស់ ច្រូងច្រាងដូចបន្លាដែលនៅព័ទ្ធជុំវិញខ្លួនយើង គ្រាន់តែភ្លាត់ងាកខ្លួនបន្តិចក៏ប៉ះមុតបន្លា" ។ ដើម្បីនឹងរក្សាខ្លួនឲ្យប្រព្រឹត្តិទៅដោយសុវត្ថិភាព ឬនឹងសម្ងបខ្លួនឲ្យរលុង កុំឲ្យប៉ះបន្លា គឺឧបសគ្គក្នុងជីវិតនោះៗ ត្រូវមានក្បួនខ្នាតគ្រប់ប្រភេទគ្រោះថ្នាក់ ទុកជាប្រទីបអុជទ្រោលបំភ្លឺឲ្យមើលឃើញផ្លូវឲ្យមើលឃើញច្រកល្ហក ល្មមនឹងគេចដើរទៅឲ្យបានសុខស្រួល ។ មុនដំបូង លោកពោលពីការគប់មិត្ត ព្រោះមិត្តនៅក្នុងលោកនេះ មានច្រើនបែបណាស់ មានកល្យាណមិត្ត និងបាបមិត្តជាដើម បើយើងស្គាល់ការគប់មិត្តហើយ លោកប្រដៅឲ្យស្គាល់ការបំបែកមិត្តទៀត ព្រោះថាបើយើងមិនស្គាល់ការបំបែកមិត្តទេ យើងនឹងត្រូវគេបំបែកសាមគ្គីអំពីកល្យាណមិត្តយើងបាន ខ្លួនយើងនឹងធ្លាក់ទៅក្នុងជ្រោះជ្រៅគឺសេចក្ដីទុក្ខ ដែលកើតពីការបែកសាមគ្គីនោះ នាំឲ្យអន្តរាយដល់ខ្លួន ដល់ត្រកូល និងដល់ប្រទេសជាតិ រួមសេចក្ដីឲ្យខ្លីមកគឺលោកប្រដៅឲ្យមានសាមគ្គី និងឲ្យស្គាល់ធម៌ជាសត្រូវដល់សាមគ្គី គឺការញុះញង់ ។ យើងច្រើនតែស្រែកប្រាប់គ្នាថា សាមគ្គីៗ!!! តែយើងច្រើនមិនស្គាល់ការញុះញង់បំបែកសាមគ្គី ហើយយើងត្រូវគេញុះពន្យុះឲ្យយើងបែកសាមគ្គីគ្នា ហេតុដូច្នេះហើយ បានជាលោកពោលពីការគប់មិត្ត ហើយលោកពោលពីការបំបែកមិត្តទៀត ព្រោះសាមគ្គីមានការញុះញង់ជាសត្រូវ ។ ការញុះញង់បំបែកសាមគ្គីនេះ តាមពាក្យបាលីលោកហៅថា៖ "សង្ឃភេទ ការបំបែកពួក, បំបែកក្រុម, បំបែកសង្គម, ឲ្យបែកចេញពីគ្នា"។ មានអំណាចខ្លាំងណាស់ មានឫទ្ធិខ្លាំងណាស់ អាចបំបែកសាមគ្គីដែលជាធម៌ចងបាច់គ្នា ជាធម៌រួបរួមគ្នាបង្កើតសេចក្ដីសុខ ឲ្យសាបសូន្យទៅបាន ទើបបានជាលោកចាត់ថា ការញុះញង់មានទោសធ្ងន់ណាស់ ធ្ងន់ក្រៃលែងធ្ងន់ ។ តទៅទៀត, លោកពោលពីវិវាទទាស់ទែងគ្នា ដោយលោកយល់ឃើញថា វិវាទនេះជាទោសធំមួយទៀត ហើយមិនអាចចៀសវាងបានដោយងាយផង ដោយប្រការទាំងពួង ថាបើកើតមានវិវាទគ្នាហើយ ត្រូវប្រញាប់ប្រញាល់ស្វែងរកមធ្យោបាយផ្សះផ្សាឲ្យបានរលត់ស្ងាប់ទៅវិញឆាប់ ដើម្បីរក្សាសន្តិភាពគឺសេចក្ដីសុខត្រជាក់ត្រជុំឲ្យមានជីវិតរស់នៅដោយប្រពៃ ព្រោះការសំខាន់បំផុតត្រង់

សេចក្ដីសុខនេះឯង ។ សន្តិភាព គឺសេចក្ដីសុខត្រជាក់ត្រជំនេះ នរណាៗក៏ពោលថាចង់បានគ្រប់គ្នាឥតប្រកែកបានឡើយ បានជាលោកពោលពីការវិវាទហើយ លោកពោលពីគណសន្និគីការចងបាច់គ្នាឲ្យកើតសុខទូលំទូលាយត្រឡុងត្រឡាយទៀត សមដូចជាពាក្យដែលលោកពោលទុកថា "ហិតោបទេសនេះ មានដល់ទៅ ៤ ភាគក៏ពិតមែន ប៉ុន្តែដែលថាបួនៗ នេះ គ្រាន់តែជាតួលេខរាប់ចំនួនឲ្យឃើញច្រើនៗប៉ុណ្ណោះទេ ឯសេចក្ដីពិតនោះ មានតែមួយគត់ គឺគណសន្និ ការចងបាច់គ្នានាំឲ្យមានសន្តិភាព សេចក្ដីសុខត្រជាក់ត្រជំនេះតែប៉ុណ្ណោះឯង ។

ខ្ញុំជឿជាក់ថា លោកអ្នកអានទាំងឡាយដែលបានមើលហិតោបទេសទាំង ៤ ភាគហើយ នឹងបានឃើញព្រឹត្តិការណ៍ក្នុងជីវិតមនុស្សម្នាក់ៗថាមានដូចម្ដេចខ្លះ ហើយមុខជាចាំនូវនិទាន និងសុភាសិតទាំងឡាយនោះៗ យកមកទុកជាគតិប្រចាំជីវិត ដើម្បីទុកប្រើជាប្រយោជន៍ដោះទាល់ ដោះឧបសគ្គ ដែលនឹងកើតមានដល់ខ្លួនគ្រប់គ្នាទៅអនាគត ។ ដោយខ្ញុំជឿជាក់ដូច្នេះហើយ បានជាខ្ញុំមានបំណងថា សៀវភៅនេះ គួរមានប្រចាំគេហដ្ឋានប្រជាជនខ្មែរគ្រប់ៗគ្នា តែកុំភ្លេចសុភាសិតមួយបទ ដែលបុរាណលោកពោលថា "ដាវមុតៗ មែនតែក្នុងស្រោម វិជ្ជាចេះព្រមនៅក្នុងក្បួន" ។

ទីបំផុតនេះ ខ្ញុំសូមអរគុណព្រះទេពសត្ថា សូរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក ព្រះគ្រូសេក្ខ-នាង, ជា-ទន់ ហៅឆាយ សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ព្រមទាំងភិក្ខុ សាមណេរអាស្រ័យនៅជាមួយ គឺភិក្ខុ ព្រាប-ផុន (នេក្ខមរតោ) ភិក្ខុ វ៉ាន់សាវ (ធម្មសារោ) សាមណេរ ប៊ុត-បូរ (ចក្ខុសំវរោ) សាមណេរ អឿ-ជួ (អង្កុរធម្មោ) ដែលបានជួយសរសេរចម្លងឲ្យបានត្រឹមត្រូវទុកក្នុងទីនេះផង ។

ភាគទី ៤ នេះ ខ្ញុំទុកជាទីរឭកការនៅចាំវស្សាអស់ត្រៃមាសក្នុងឆ្នាំថោះត្រីស័ក ព.ស. ២៤៩៤ ។

ក្នុងពេលដែលខ្ញុំប្រែសៀវភៅនេះ ប្រទេសកម្ពុជាកំពុងប្រសព្វសេចក្ដីទុក្ខគ្រប់ទីឋាន, ខ្ញុំមានចិត្តសៅហ្មងជាបំផុត, ខ្ញុំសូមឲ្យប្រជាជនខ្មែរទាំងមូលត្រឡប់បានសេចក្ដីសុខ សេចក្ដីចម្រើន ដូចប្រក្រតីដើមវិញ ក្នុងពេលឆាប់ៗនេះកុំបីឃ្លាតឡើយ!

វត្តឧណ្ណាលោម ថ្ងៃ ៧ ៗ ១១ ឆ្នាំថោះត្រីស័ក ព.ស. ២៤៩៤

ត្រូវនឹងថ្ងៃទី ៦ ខែតុលា ឆ្នាំ១៩៥១

វីរិយបណ្ឌិតោ ភិក្ខុ (ប៉ាង ខាត់)

# ៤ សន្តិភាព

ក្នុងពេលដែលចាប់ផ្តើមនិយាយរឿងតទៅទៀត, ព្រះរាជកុមារទាំងឡាយមានព្រះបន្ទូលត្រាស់ថា៖ “បពិត្រលោកអាយ៉ះ! យើងខ្ញុំបានស្តាប់រឿងសង្គ្រាមចប់ហើយ, ពេលនេះ សូមលោកមេត្តានិយាយរឿងសន្តិភាពតទៅទៀត” ។ បណ្ឌិត**វិស្ណុស័ម៉ន** ក្រាបបង្គំទូលតបថា៖ “បើដូច្នោះ សូមទ្រង់តាំងព្រះទ័យព្រះសណ្តាប់ ទូលព្រះបង្គំនឹងពណ៌នារឿងសន្តិភាពថ្វាយ ដូចមានស្លោកជាដើមបទថាដូច្នេះ៖

១- ក្នុងមហាសង្គ្រាមនៃស្តេចទាំងពីរនេះ សេនាវេហ៍ពលទាំងពីរស្លាប់អន្តរាយខ្ទេចខ្ទី, ក្នុងខណៈនោះ, ការចរចាដើម្បីសន្តិភាពក៏កើតមានឡើង ដោយប្រធានរដ្ឋមន្ត្រីពីរនាក់គឺ ត្មាត**ទុរទសី** និង**ចាក្រពាកសវ័ជ្ជះ** ។

ព្រះរាជបុត្រទាំងឡាយមានបន្ទូលត្រាស់សួរឡើងថា៖ “រឿងនោះតើដូចម្តេច?” ។ មហាបណ្ឌិត**វិស្ណុស័ម៉ន**ក៏រៀបរាប់ថ្វាយដូចសេចក្តីតទៅថា៖

ក្នុងលំដាប់នោះ, រាជហង្ស**ហិរណ្យគក៏**សួរឡើងដោយសេចក្តីឆ្ងល់ថា៖ “ចុះអ្នកណា ដុតបំផ្លាញបន្ទាយយើង សត្រូវ ឬប្រជាជនក្នុងបន្ទាយដែលចូលដៃជាមួយសត្រូវ?” ។ **ចាក្រពាកសវ័ជ្ជះ**ជាប្រធានរដ្ឋមន្ត្រីឆ្លើយប្រាប់ថា៖ “ទេវបាទ! ក្អែក**មេឃពណ៌**ព្រមទាំងបរិវារដែលលោកម្ចាស់ជាប់ចិត្តឥតហេតុផលនេះឯង បាត់មុខមិនឃើញនៅទីនេះទេ បើដូច្នោះប្រហែលជាក្អែកក្បត់នេះឯងវាដុតបន្ទាយយើង” ។ រាជហង្ស**ហិរណ្យគក៏**រំពឹងទ្រឹងមួយស្របក់និយាយតបទៅថា៖ “អើរឿងនេះបើពិតដូច្នោះមែន គឺជាវាសនាអាក្រក់នៃយើងនេះឯងតែម្តង, ព្រោះថា៖

២- កំហុសតែងកើតពីគ្រោះអាក្រក់ មិនមែនកើតមកពីមន្ត្រីទេ, ការងារដែលបានប្រុងប្រៀបរៀបរយល្អហើយ អាចហីនហោចទៅបានកាលណាទៅជួបគ្រោះថ្នាក់” ។

**ចាក្រពាក**ថ្លែងតបថា៖ “លោកពោលទុកដូច្នេះ៖

៣- នរជនដែលធ្លាក់ខ្លួនទៅក្នុងគ្រោះកាច តែងតែបន្ទោសព្រេងវាសនា, មនុស្សល្ងង់មិនព្រមទទួលកំហុសដែលខ្លួនធ្វើទេ ។

៤- នរជនណា មិនត្រេកអរចំពោះពាក្យដាស់តឿននៃមិត្តដែលប្រាថ្នាប្រយោជន៍ឲ្យ នរជននោះនឹងត្រូវវិនាសដូចអណ្តើកល្ងង់ កាលហាមាត់និយាយក៏របូតចេញពីឈើភ្ជាត់ខ្លួនធ្លាក់ស្លាប់ហីនហោចទៅ ។

៥- ពាក្យសម្តី បុគ្គលគប្បីរក្សាទុកគ្រប់កាលទាំងពួង ព្រោះសេចក្តីវិនាសមកពីពាក្យសម្តី ដូចជា

អណ្តើក កាលដែលហង្សហើរពាំនាំយកទៅភ្លាត់ហាមាត់និយាយក៏ធ្លាក់ស្លាប់ទៅហោង” ។

រាជហង្សហិរញ្ញគក៏ សួររឿងនោះថា៖ “រឿងនោះតើដូចម្តេច?” ។ **ចាក្រពាកសវ័ជ្ជៈ** ពោលរៀបរាប់ថា៖

# កថាទី ១

## រឿងអណ្តើក និងហង្ស

នៅក្នុងប្រទេសមគធៈ មានស្រះមួយឈ្មោះផុល្លោត្បលៈ ជាទីអាស្រ័យនៅនៃហង្សពីរ មួយឈ្មោះ**សំកដៈ** មួយទៀតឈ្មោះ**វិកដៈ**, មានអណ្តើកមួយឈ្មោះ**កម្ពុគ្រីព** ជាមិត្តនៃហង្សទាំងពីរនេះ ក៏អាស្រ័យក្នុងស្រះនោះដែរ ។ ថ្ងៃមួយ, ពួកព្រានប្រមង់ចរមករកចាប់ត្រីក្នុងស្រះនោះ មកដល់និយាយគ្នីគ្នារញ៉ថា៖ “យើងដេករង់ចាំនៅក្នុងទីនេះចុះ ដល់ព្រឹកឡើងពីព្រលឹម យើងនឹងចាប់ត្រី អណ្តើកទាំងឡាយ” ។ កាលនោះ, អណ្តើកបានឮពាក្យព្រានប្រមង់ទាំងឡាយនិយាយយ៉ាងនេះហើយ ភិតភ័យខ្លាំងណាស់ ខំវារទៅជួបនឹងហង្សទាំងពីរជាសំឡាញ់ ហើយនិយាយប្រាប់ថា៖ “នែមិត្តមានចិត្តល្អអើយ! ខ្ញុំបានឮពាក្យពួកព្រានប្រមង់វានិយាយគ្នាថា នឹងចាប់អណ្តើកក្នុងស្រះដល់ព្រឹកឡើង, ពេលនេះ តើយើងគិតធ្វើដូចម្តេច?” ។ ហង្សទាំងពីរឆ្លើយឡើងថា “មុនដំបូង, ត្រូវយើងដឹងរឿងនោះឲ្យជាក់លាក់ល្អសិនថាជាក្រ ឬងាយ សឹមយើងនឹងគិតអានថាត្រូវធ្វើម្តេចតទៅ” ។ អណ្តើកឆ្លើយកាត់ឡើងថា៖ “ទេ! ទេ! មិនបានទេ ព្រោះខ្ញុំធ្លាប់ឃើញភ័យក្នុងទីនេះមកច្រើនដងច្រើនគ្រាហើយ បានជាលោកពោលថា៖

៦- ត្រីឈ្មោះ**អនាគតវិធាតា** និងត្រីឈ្មោះ**ប្រត្យុត្បន្នមតិ** ទាំងពីរនេះ រត់រួចពីភ័យបានដោយសុវត្ថិភាព ឯត្រីឈ្មោះ**យ័ទភវិស្សតិ**ដល់នូវក្តីវិនាសអន្តរធានទៅ” ។

ហង្សទាំងពីរសួររឿងនោះថា៖ “រឿងរ៉ាវនោះតើដូចម្តេច?” ។ អណ្តើកឈ្មោះ**កម្ពុគ្រីព**និយាយរៀបរាប់ប្រាប់ថា៖

# កថាទី ២

## រឿងត្រី ៣ រូប

កាលពីមុន, នៅក្នុងស្រះនេះឯង មានព្រានប្រមង់ទំនងដូចគ្នានេះ ចូលមកដើម្បីចាប់ត្រី ។ ត្រី ៣ រូបប្រឹក្សាគ្នា ត្រីឈ្មោះ**អនាគតវិធាតា** និយាយថា “នៅទីនេះទៅទៀតមិនបានទេ ខ្ញុំនឹងរត់ចេញទៅរកជលាស័យដទៃទៀតក្នុងថ្ងៃនេះហើយ” ថាហើយក៏ហែលលលៃចរចេញទៅកាន់ស្រះដទៃ ។ ត្រីមួយទៀតឈ្មោះ**ប្រត្យុត្បន្នមតិ**និយាយថា៖ “អាត្មាអញទៅឯណាអេះ នឹងគ្មេរគ្មាន់ប្រមាណមើលអនាគតមិន

ឃើញការក្រងាយទេ កាលបើមានហេតុការណ៍កើតប្រាកដឡើង ទើបនឹងចាត់ការទៅតាមទំនងនោះកើត, ព្រោះថា៖

៧- នរជនណាកែខែក្ដីអន្តរាយដែលកើតឡើងភ្លាមបាន នរជននោះទើបឈ្មោះថាជាអ្នកមានប្រាជ្ញា ដូចជាភរិយានៃពាណិជលាក់សហាយទាន់ភ្លាមក្នុងទីចំពោះមុខស្វាមី" ។

ត្រីឈ្មោះ**យ័ទភវិស្សតិ**សួរថា៖ "ចុះរឿងនោះដូចម្ដេច?" ។ ត្រីឈ្មោះ**ប្រត្យុត្បន្នមតិ**ពណ៌នារឿងនោះប្រាប់ថា៖

# កថាទី ៣

## រឿងពាណិជ្ជ ភរិយា និងអ្នកបម្រើ

ក្នុងកាលពីដើម, នៅក្នុង**វិក្រមបុរី** មានពាណិជម្នាក់ឈ្មោះ**សមុទ្ទរទត្ត** ភរិយាឈ្មោះនាង **រត្នប្រភា** ជាស្រីចូលចិត្តរួមបេតីជាមួយនឹងខ្ញុំបម្រើរបស់ខ្លួនគ្រប់ៗកាល ([១]) ។ តមកថ្ងៃមួយ, ពាណិជ**សមុទ្រទត្ត** បានឃើញនាង**រត្នប្រភា**ជាភរិយាកំពុងឲ្យខ្ញុំបម្រើនោះជប់មាត់ ។ កាលនោះឯងនាង**រត្នប្រភា**ដឹងថាស្វាមីឃើញខ្លួនហើយគិតទាន់ភ្លាម ក៏ដើរតម្រង់ចូលទៅរកស្វាមីហើយក្លែងនិយាយថា៖ "នាថ! ខ្ញុំបម្រើនេះគំនិតមារយាទអាក្រក់ធំណាស់ វាប៉ានលួចកប៊ូរយកទៅស៊ី ខ្ញុំបានទៅហិតក្លិនមាត់វាបានដឹងច្បាស់ណាស់" ។ លោកបានពោលទុកថា៖ "ស្រី បរិភោគអាហារទ្វេគុណ មានប្រាជ្ញាឆ្លៀវឆ្លាតចតុគុណ មានកលមាយាឆគុណ និងមានកាមរាគអដ្ឋគុណ" ។ ខ្ញុំបម្រើ, លុះបានឮពាក្យនាងនោះនិយាយដូច្នោះ ក៏ធ្វើជាច្រឡោតខឹងតឹងឡើងហើយនិយាយថា៖ "នាថ! ខ្ញុំនឹងអាស្រ័យនៅក្នុងផ្ទះនាយចៅហ្វាយដែលមានភរិយាប្រើតដូច្នេះដូចម្ដេចកើត សព្វបើគ្រាន់តែការបន្តិចបន្តួចប៉ុណ្ណោះ ឲ្យភរិយាមកហិតមាត់ខ្ញុំបម្រើគ្រប់ខណៈយ៉ាងនេះ!" ។ លំដាប់នោះ, ខ្ញុំបម្រើនោះថាហើយក៏ក្រោកដើរចេញទៅភ្លាម ឯស្វាមីនាងទៅជាសូមទោសខ្ញុំបម្រើឃាត់ឲ្យវានៅបម្រើវិញ ។ ព្រោះហេតុនោះបានជាខ្ញុំ (ត្រីឈ្មោះ**ប្រត្យុត្បន្នមតិ**) ពោលថា៖

---

[១] ហិតោបទេស សេចក្ដីប្រែជាភាសាបារាំងនៃលោកឡង់ស៊ីរ៉ូ មានគាថាពីរលើសដូច្នេះគឺ ក. ស្ត្រីភាពមិនមើលបុរសជិតទេ ព្រមទាំងមិនសង្កេតមើលឲ្យដឹងថាបុរសនោះមានរូបល្អ ឬអាក្រក់, គ្រាន់តែឲ្យដឹងថាបុរសប៉ុណ្ណោះ ក៏រីករាយសប្បាយក្នុងចិត្តភ្លាម ។ ខ. ក្បួនតម្រា សូម្បីយើងចេះចាំហើយ ក៏ត្រូវតែរិះគិតសេចក្ដីមើលថែមទៀតដែរ ព្រះរាជាទោះបីសព្វព្រះទ័យនឹងយើងហើយ ត្រូវតែកោតខ្លាច, ឯស្ត្រីភាព, ទោះបីនៅក្នុងដៃយើងហើយ ក៏យើងមិនត្រូវទុកចិត្ត នរណាឡើយជាមេប្រាជ្ញចេះចាំអស់មួយសៀវភៅ កំណត់ដឹងព្រះទ័យព្រះរាជា និងចិត្តស្ត្រីភាពបាន? ។ សេចក្ដីប្រែជាភាសាសៀមនៃលោកនាគប្រទីប មានគាថាលើសមួយគឺ៖ បុរសណា នឹងថាមិនជាទីស្រឡាញ់នៃស្ត្រីក៏មិនមែន ឬថាជាទីស្រឡាញ់នៃស្ត្រីក៏មិនមែនទៀត, ដោយពិត, ស្ត្រីភាពដូចគោដើររកស៊ីស្មៅក្នុងព្រៃ តែងប្រាថ្នាស្មៅថ្មីៗជានិច្ច ។

“នរណាកែខែក្តីអន្តរាយដូច្នេះជាដើម (លេខ ៧) ។ លំដាប់នោះ, ត្រីឈ្មោះ**យ័ទភវិស្សតិ**ពោលតទៅទៀតថា៖

៨- របស់ណាមិនមានបច្ច័យ របស់នោះក៏តែងមិនមាន ថាបើរបស់ណាមានបច្ច័យ របស់នោះក៏មិនមែនជាដទៃ, ថ្នាំនេះរម្ងាប់នូវពិសពុលគឺសេចក្តីពិតបាន ហេតុដូចម្តេចហ្ន៎ ក៏គេមិនដឹងថ្នាំនោះ ។

កាលនោះឯង, ត្រី**ប្រត្យុត្បន្នមតិ**កំពុងតែគិតដូច្នេះ ត្រូវព្រានប្រមង់ពាក់មងជាប់ ទើបធ្វើពុតដូចជាខ្លួនស្លាប់ ស្ថិតនៅស្ងៀមឥតខ្មើកឡើយ ដល់ព្រានប្រមង់ដោះចេញពីមងរួចហើយ ក៏ខំបម្រះនឿលពេញទំហឹងលោតចូលទៅក្នុងទឹកជ្រៅភ្លាម ។ ឯត្រី**យ័ទភវិស្សតិ**ព្រានប្រមង់ចាប់បានហើយ បោកសម្លាប់ទៅ, ព្រោះហេតុនោះ បានជាខ្ញុំ (អណ្តើក**កម្ពុគ្រីព**) ពោលថា៖ “ត្រី**អនាគតវិធាតា**” ដូច្នេះជាដើម (លេខ ៦) ។ ហេតុការណ៍ដូចខ្ញុំ (អណ្តើក**កម្ពុគ្រីព**) បានពណ៌នាមកនេះ សូមមិត្តជួយចាត់ចែងឲ្យបានខ្ញុំចេញទៅកាន់ស្រះដទៃក្នុងពេលនេះទៅ” ។ ហង្សទាំងពីរតបថា៖ “បើបានទៅដល់ជលាស័យដទៃហើយ ជាកុសលសំឡាញ់ឯងហើយ តើសំឡាញ់នឹងទៅដោយវិថីតាមវិធីណា?” ។

អណ្តើកពន្យល់ឧបាយថា៖ “អើ! គិតរកវិធីណាដែលទៅតាមអាកាសជាមួយសំឡាញ់ទាំងពីរនាក់បានហើយ” ។ ហង្សទាំងពីរសួរទៅទៀតថា៖ “ឧបាយនេះ សំឡាញ់គិតថានឹងឲ្យសម្រេចបានបែបយ៉ាងណា?” ។ អណ្តើកឆ្លើយប្រាប់ទៅវិញថា៖ “នែសំឡាញ់! យកកំណាត់ឈើមួយមក ហើយសំឡាញ់ឯងទាំងពីរនាក់ពាំចុងកំណាត់ឈើម្ខាងម្នាក់ដោយចំពុះ ខ្ញុំខាំកណ្តាលគោងកំណាត់ឈើនោះ ដោយវិធីនេះ ហើយអាស្រ័យដោយកម្លាំងស្លាបសំឡាញ់ហើរទៅ ខ្ញុំនឹងទៅបានដោយស្រួល” ។ ហង្សទាំងពីរឆ្លើយតបមកដោយអរថា៖ “អើ! ឧបាយនេះស្រួលហើយ តែត្រូវគិតថា៖

៩- អ្នកប្រាជ្ញ កាលគិតដល់សេចក្តីចម្រើនហើយ ត្រូវគិតដល់សេចក្តីវិនាសផង កុកល្ងង់គិតឃើញសេចក្តីចម្រើនតែម្យ៉ាង ត្រូវស្ការស៊ីកូនខ្មុក” ។

អណ្តើកសួរដេញដោលថា៖ “រឿងនេះតើដូចម្តេច?” ។ ហង្សទាំងពីររៀបរាប់ប្រាប់ថា៖

# កថាទី ៤

## រឿងកុក, ពស់ និងស្ការ

ក្នុងឧត្តរាបថ, នៅលើភ្នំគិជ្ឈកូដ មានបិប្បលិព្រឹក្សមួយដើមធំ ជាទីអាស្រ័យនៅនៃកុកទាំងឡាយ ។ ពស់វែកមួយអាស្រ័យនៅក្នុងព្រង់ឰដ៏ខាងក្រោមដើមឈើនោះ វាតែងតែវារលូនចូលទៅចាប់យកកូនកុកស៊ីជាចំណីអាហារអស់កាលជានិច្ច ។ ចំណេរកាលមក, កុកល្ងង់មួយ លុះបានឮសំឡេងយំខ្សៀវខ្សានៃកុកទាំងឡាយដែលមានសេចក្តីសោកបៀតបៀនហើយ ក៏និយាយឡើងថា៖ “នែអ្នកទាំងឡាយ!

អ្នកកុំយំថ្វី ចូរធ្វើតាមឧបាយកលខ្ញុំវិញ យើងត្រូវទៅរកចាប់ត្រីយកមករាយតៗគ្នាតាំងពីព្រង់ស្ពារឲ្យរហូតមកដល់ព្រង់ពស់ ឯសត្វស្ពារជាសត្វជាប់ចិត្តដោយអាហារគឺត្រីនោះ នឹងចេះតែដើររៀងមកដល់ព្រង់ពស់ កាលឃើញពស់ជាសត្វសត្រូវពីកំណើតស្រាប់ មុខជានឹងខាំពស់សម្លាប់ដោយក្តីសម្អប់មិនខាន" ។ កុកទាំងឡាយក៏ព្រមព្រៀងគ្នាធ្វើតាមពាក្យកុកល្ងង់នោះ ។ ក្នុងកាលនោះឯង, សត្វស្ពារដែលនៅក្នុងព្រង់ឈើនោះ បានឮសំឡេងកុកយំអឺងកង ក៏វារឡើងដើមឈើនោះពីខាងម្ខាង ស្រង់តាមក្លិនត្រីនោះឃើញត្រីហើយស៊ីត្រីនោះៗបណ្តើរៗមក មិនស៊ីតែត្រី ស៊ីទាំងសាវកកុកអស់រលីងថែមទៀត, ព្រោះហេតុនោះហើយ បានជាខ្ញុំពោលថា៖ "អ្នកប្រាជ្ញ កាលគិតដល់សេចក្តីចម្រើនហើយ" ដូច្នេះជាដើម (លេខ ៩) ។ មិនថ្វីទេ យើង (ហង្សទាំងពីរ) នាំទៅបាន តែកាលដែលយើងនាំសំឡាញ់ទៅនោះ មុខជាមនុស្សលោកមើលឃើញ កាលបើឃើញហើយនឹងនិយាយឆោឡោអឺងកងឡើងមិនខាន, បើសំឡាញ់បានឮសំឡេងមនុស្សលោកហើយអត់ទ្រាំមិនបាន ចង់ឆ្លើយតបគេវិញ មុខជាសំឡាញ់នឹងធ្លាក់ក្អកដល់ដីស្លាប់អសារបង់មិនខានទេ ។ ចូរសំឡាញ់តាំងចិត្តដាច់ស្រេចនឹងនៅក្នុងទីនេះទៅល្អជាង" ។ អណ្តើកនិយាយរឹងទទឹងទៅទៀតថា៖ "បើមែនដូចថា, រូបខ្ញុំនឹងត្រូវគេសម្គាល់ថាជាអ្នកឥតចេះដឹងអ្វីទៅហើយឬ? មួយទៀត, បើរូបខ្ញុំឆ្លើយតបតនឹងគេវិញហើយតើ វាហើយគ្នាទៅហើយ អ្នកណាក៏មិនត្រូវនិយាយថាដូចម្តេចទៀតដែរ" ។ សត្វទាំង ៣ និយាយពិគ្រោះគ្នាហើយ ក៏ធ្វើតាមពាក្យដែលនិយាយនោះ ។ កាលនោះ, ក្មេងគង្វាលគោក្រឡេកមើលទៅឃើញហង្សទាំងពីរនាំអណ្តើកហោះហើរដើរលើអាកាសវេហាស៍ដូច្នោះ ក៏ស្រែកនិយាយជជែកគ្នាឆោឡោទ្រហឹងអឺងកងឡើង ហើយរត់ដេញតាមទៅ ក្មេងខ្លះនិយាយចំអកឡកឡឺយថា៖ "កាលណា អណ្តើកធ្លាក់មកដល់ដី កាលនោះយើងនឹងយកវាទៅស្លការីស៊ីឲ្យឆ្ងាញ់ម្តងវ៉ឺយ" ក្មេងខ្លះតទៅទៀតនិយាយឡកថា៖ "ទេ! យើងយកទៅស្ងួស៊ីឯផ្ទះវិញ" ។ ឯអណ្តើកនោះ លុះឮពាក្យក្មេងគង្វាលគោនិយាយឡកឡឺយឲ្យមុខគួរក្នាញ់ ក៏ភ័ន្តស្មារតីភ្លេចពាក្យដែលនិយាយមត់នោះ បែរទៅជាហាមាត់និយាយឆ្លើយតតបទៅវិញថា៖ "នែវ៉ឺយ! អាក្មេងអាឯងទាំងអស់គ្នាស៊ីតែផេះទៅចុះ" ។ កាលដែលអណ្តើកហាមាត់និយាយដូច្នេះ ក៏ធ្លាក់ក្អកមកដល់ដី បានដៃក្មេងដុតស៊ីជាចំណីអាហារទៅហោង ព្រោះហេតុនោះបានជាខ្ញុំ (**ចាក្រពាកសវ័ជ្ជ:**)ពោលថា៖ "នរជនណាមិនត្រេកអរនឹងពាក្យដាស់តឿននៃមិត្ត" ដូច្នេះជាដើម (លេខ ៣) ។ ក្នុងកាលនោះឯង, កុកជាចារបុរសដើរចូលមកក្នុងទីនោះហើយនិយាយឡើងថា៖ "ទេវ:! និយាយធ្វើអ្វី ខ្ញុំបាទបានប្រាប់ប្រុងតាំងពីកាលនោះម្ល៉េះថា ត្រូវចាត់ចែងបន្ទាយឲ្យឆាប់រួសរាន់ទៅ តែលោកម្ចាស់មិនធ្វើតាមពាក្យខ្ញុំបាទ ហេតុនោះហើយបានជាលោកម្ចាស់ត្រូវសោយផលនៃការព្រងើយកន្តើយក្នុងកាលនេះឯង, ឯការដុតបំផ្លាញបន្ទាយយើងនេះ គឺក្អែក**មេឃពណ៌**នេះឯង, ដែលត្បាត

**ទុរទសី**ប្រធានរដ្ឋមន្ត្រីសត្រូវប្រើមកឲ្យធ្វើការ" ។ រាជហង្ស**ហិរណ្យគក៏**ដកដង្ហើមវែងៗ ហើយពោលថា៖

១០- នរជនណាស្និទ្ធស្នាលចំពោះសត្រូវ ដោយការរាប់អានក្ដី ដោយយល់ឧបការៈក្ដី នរជននោះទុកដូចជាមនុស្សដេកលក់លើដើមឈើ ហើយភ្លាត់ធ្លាក់មកដល់ដីទើបភ្ញាក់ដឹងខ្លួន ។

កុកជាចារបុរសនិយាយតទៅទៀតថា៖ "កាលណាក្អែក**មេឃពណ៌**ចាត់ការដុតបំផ្លាញបន្ទាយសត្រូវហើយ ត្រឡប់ទៅដល់ទីកន្លែងដើមខ្លួនវិញ កាលនោះ ស្ដេចក្ងោក**ចិត្រពណ៌**ពោលអរគុណដោយក្ដីពេញចិត្តថា គួរអភិសេកក្អែក**មេឃពណ៌**ឲ្យគ្រប់គ្រងអាណាចក្រកប៉ុរទ្វីប ហើយឲ្យនៅក្នុងទីនេះ, ព្រោះថា៖

១១- បុគ្គលមិនគួរព្រងើយចំពោះកិច្ចការរបស់សេវកអ្នកដែលបានបំពេញនាទីបរិបូណ៌ហើយទេ គួរតែលើកតម្កើងសេវកនោះដោយរង្វាន់ ដោយទឹកចិត្តជ្រះថ្លា ដោយវាចាពោលសរសើរ និងដោយកិរិយាមើលដោយភ្នែក" ។

**ចាក្រពាកសវ័ជ្ជះ**សួរកុកតទៅទៀតថា៖ "រឿងនោះ, មានដូចម្ដេចតទៅទៀត?" ។ កុកចារបុរសនិយាយបន្តសេចក្ដីទៀតថា៖ "សេចក្ដីតទៅថាត្មាតប្រធានរដ្ឋមន្ត្រីនិយាយចំពោះក្ងោក**ចិត្រពណ៌**ថា៖ "ទេវ! ប៉ុណ្ណេះមិនទាន់សមគួរទេ សូមលោកម្ចាស់ប្រកាសសេចក្ដីពេញចិត្តដទៃផ្សេងទៀតផង, ព្រោះថា៖

១២- នរណា ប៉ានកម្ទេចជនដែលលោកទាំងមូលយល់ថាជាសត្រូវធំក្រៃលែងដោយឥតកោតញញើត? បពិត្រព្រះរាជា! ការតែងតាំងជនថោកទាបក្នុងតំណែងខ្ពស់នេះ ទុកដូចជាគំនូសដែលគេគូសលើដីខ្សាច់ ។

ក្នុងកាលណាក៏ដោយ គេមិនដែលតែងតាំងមនុស្សថោកទាបឲ្យកាន់តំណែងខ្ពង់ខ្ពស់ទេ, ព្រោះថា៖

១៣- មនុស្សថោកទាប កាលបើបានតំណែងខ្ពង់ខ្ពស់ តែងតែប្រាថ្នាកម្ចាត់បង់នាយខ្លួន ដូចកណ្ដុរដែលតាបសជបឲ្យបានទៅជាខ្លាក៏សង្គ្រាសម្លាប់តាបសបង់វិញ" ។ ក្ងោក**ចិត្រពណ៌**សួរថា៖ "រឿងនោះតើដូចម្ដេច?" ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីរៀបរាប់រឿងប្រាប់តទៅថា៖

# កថាទី ៥

## រឿងកណ្ដុរ និងតាបស

នៅក្នុងតបោវ័នមួយដែលជាទីអាស្រ័យនៅនៃមហាឫសីទាំងឡាយ មានតាបសម្នាក់មានតបៈច្រើន ។ នៅក្នុងតបោវ័ននោះ តាបសបានឃើញកូនកណ្ដុរមួយដែលក្អែកពាំហើយធ្លាក់ចុះមកដី លោក

មានចិត្តអាណិតអាសូររើសយកមកក្សាចិញ្ចឹមឲ្យស៊ីស្រូវអង្ករ គ្រាប់ស្ពៅទាល់តែធាត់ធំឡើង" ។ តមក, ឆ្មាវិឡារជាតិឃើញកណ្តុរនោះ ក៏ស្ទុះលោតទៅសង្រ្គុបចាប់ដើម្បីយកមកស៊ី ។ កណ្តុរឃើញឆ្មាលោតមកសង្រ្គុបចាប់ខ្លួន ភិតភ័យណាស់ ក៏លោតចូលទៅលើទ្រូងតាបស ។ ឯតាបសមានចិត្តអាណិតខ្លាំងជបកណ្តុរឲ្យទៅជាឆ្មាដោយគ្រាន់តែស្រែកថា៖ "នែកណ្តុរ! ចូរឯងទៅជាឆ្មាទៅ" ។ កណ្តុរនោះក្លាយទៅជាឆ្មាភ្លាមស្មើរតែមិនទាន់ផុតសម្តីផង ។ តមក, ឆ្មានោះឃើញឆ្កែបោលមក ខ្លាចឆ្កែរត់ទៅជ្រកនឹងតាបសទៀត ។ តាបសឃើញឆ្មាខ្លាច**ដូច្នេះ**និយាយថា៖ "យីអាឆ្មានេះខ្លាចឆ្កែទេតើ!" ហើយជបឆ្មានោះឲ្យទៅជាឆ្កែមួយជាន់ទៀត ។ តមក, ឆ្កែនោះខ្លាចខ្លាទៀត តាបសក៏ជបឆ្កែនោះឲ្យទៅជាខ្លាទៀត ។ កាលនោះឯង, បណ្តាជនទាំងឡាយដែលឃើញកណ្តុរនោះក្លាយទៅជាខ្លា ក៏និយាយអឹងកងថា៖ "អាកណ្តុរនេះតាបសនេះលោកជបវាឲ្យទៅជាខ្លា" ។ ខ្លានោះ លុះបានឮពាក្យជនទាំងផ្តាសនិយាយឡកឡឺយរឿយៗ ក៏កើតអៀនខ្មាស ទើបគិតថា៖ "ដរាបណាតាបសនេះមានជីវិតរស់នៅ ដរាបនោះរឿងអប្បកេរ្តិ៍ឈ្មោះនៃជាតិយើងនឹងមិនបាត់បង់ទៅទេ" ។ លុះខ្លាគិតឃើញដូច្នេះហើយ កើតចិត្តអាក្រក់ក៏ដើរចូលទៅដើម្បីសម្លាប់តាបស ។ កាលនោះ, តាបសដឹងចិត្តខ្លានោះហើយ និយាយភ្លាមថា៖ "នែអាសត្វអកតញ្ញូ! អាឯងក្លាយទៅជាកណ្តុរវិញឲ្យស្រឡះទៅ!" ។ មានពុទ្ធដីកាតែប៉ុណ្ណោះ ខ្លាអកតញ្ញូនេះ ក្លាយត្រឡប់ទៅជាកណ្តុរវិញស្មើរតែមិនទាន់ផុតមាត់ផង, ព្រោះហេតុនោះបានជាខ្ញុំ (ត្មាត**ទុរទសី**) ពោលថា៖ "មនុស្សថោកទាប" ដូច្នេះជាដើម (លេខ ១៣) ។ ទេវៈ! មួយទៀត, លោកម្ចាស់ក៏ពុំពាយងាយយល់ថា ការនេះជាការស្រួលងាយនោះឡើយ, ព្រោះលោកពោលទុកថា៖

១៤- កុកល្ងង់ ស៊ីត្រីទាំងតូចទាំងធំទាំងមធ្យមអស់រលីងដោយក្តីល្មោភ តមកខាងក្រោយ ត្រូវក្តាមកៀបស្លាប់ទៅហោង ។

ក្ងោក**ចិត្រពណ៌**សួរថា៖ "រឿងនោះតើដូចម្តេច?" ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីនិយាយរឿងនោះប្រាប់ថា៖

# កថាទី ៦

## រឿងកុក និងក្តាម

នៅក្នុងមាលវប្រទេស មានត្រពាំងមួយឈ្មោះបទ្មគភ៌ៈ ជាទីអាស្រ័យគោចរនៃកុកចាស់មួយ ។ កុកនោះខ្សោយកម្លាំងនឹងស្វែងរកចំណីអាហារបរិភោគមិនបានដោយស្រួល ក៏ពុតធ្វើជាព្រួយទុក្ខលំបាកឲ្យគេឃើញ ។ ក្តាមមួយនៅទីក្បែរនោះ ឃើញកុកសំកុកជ្រប់ដូច្នោះក៏សួរទៅថា៖ "ហេតុអ្វីក៏លោកឈរ

សញ្ជប់សញ្ជើងនៅព្រៃវើយ លះបង់មិននាំពាក្នុងការស្វែងរកចំណីអាហារដូច្នេះហ្ន៎?" ។ កុកពោលតបថា៖ "នែបងប្អូនទាំងឡាយអើយ ត្រីទាំងឡាយជាចំណីអាហារតម្រង់ជីវិតខ្ញុំមែនពិតហើយ តែខ្ញុំបានឮពាក្យព្រានប្រមង់ពិគ្រោះគ្នានៅទីជិតក្រុងដូច្នេះថា ត្រីនៅក្នុងត្រពាំងនេះមុខជាព្រានប្រមង់នឹងមកចាប់យកអស់មិនខាន, ថាបើខ្ញុំអស់ផ្លូវរកស៊ីចិញ្ចឹមជីវិតក្នុងទីនេះហើយ សេចក្ដីស្លាប់មុខជាចូលមកជិតខ្ញុំទៀងទាត់ណាស់ ព្រោះហេតុនោះបានជាខ្ញុំព្រួយចិត្តសូម្បីតែអាហារក៏ព្រងើយកន្តើយមិននឹកនាឃ្លានសោះ" ។ កាលនោះឯង, ហ្វូងត្រីទាំងឡាយរំពឹងគិតគ្នាថា៖ "នែអ្នកដ៏ចម្រើនទាំងឡាយ! ទោះជាយ៉ាងណាក៏ដោយ ពេលនេះគួរទុកកុកចាស់នេះជាអ្នកធ្វើឧបការៈដល់យើងគ្រប់គ្នាទៅចុះ ហើយគួរយើងចូលទៅសួរមើល តើនឹងត្រូវធ្វើដូចម្ដេចឲ្យបានសុខស្រួលតទៅ, ព្រោះថា៖

១៥- បុគ្គលគួរចងស្ពានមេត្រីមួយអន្លើដោយសត្រូវដែលធ្វើឧបការៈ តែកុំធ្វើមួយអន្លើដោយមិត្តដែលធ្វើអបការៈ (ទោស) ឡើយ ។ ឧបការៈ និងអបការៈទាំងពីរប្រការនេះជាលក្ខណៈដែលបុគ្គលគប្បីកំណត់ដឹងចំពោះសត្រូវ និងមិត្តទាំងឡាយ" ។

ត្រីទាំងឡាយសួរកុកតទៅថា៖ "លោកកុកដ៏ចម្រើនអើយ! ក្នុងកាលឥឡូវនេះ លោកមានឧបាយជួយរក្សាយើងដូចម្ដេចខ្លះ?" ។ កុកប្រាប់ថា៖ "ឧបាយដែលជួយរក្សាអ្នកទាំងឡាយឲ្យរួចជីវិតមាន គឺត្រូវឲ្យអ្នកទាំងឡាយចេញទៅរកទីអាស្រ័យនៅក្នុងជលាស័យនោះ" ។ ត្រីទាំងឡាយត្រេកអរពោលឡើងថា៖ "បើដូច្នោះ សូមលោកជួយតាមឧបាយនោះចុះ" ។ កាលនោះឯង, កុកចាស់នោះពាំនាំយកត្រីមួយម្ដងៗ ហើយស៊ីអស់ទៅ ។ លុះដាប់តមក, ក្ដាមនិយាយនឹងកុកថា៖ "លោកកុកដ៏ចម្រើន សូមលោកយកខ្ញុំទៅក្នុងជលាស័យនោះផង" ។ កាលនោះឯង, កុកចាស់ត្រេកអរចង់ស៊ីសាច់ក្ដាមម្ដង ព្រោះខ្លួនមិនដែលបានស៊ីសោះ ក៏នាំក្ដាមយកទៅដាក់លើទីគោកមួយកន្លែង ។ ក្ដាមជាសត្វវាងវៃដឹងទាន់ ក្រឡេកមើលទៅក្រោមឃើញឆ្អឹងត្រីសព្រាតដេរដាសពាសពេញដី ទើបរំពឹងគិតថា៖ "ហ៊ា! អាត្មាអញដល់គ្រោះស្លាប់ខ្លួនហើយតើ? ស្ដេះទុករឿងនេះមួយអន្លើសិន ឥឡូវនេះអាត្មាអញត្រូវរកឧបាយកែខៃឲ្យរួចពីទុក្ខឲ្យសមតាមបរិយាកាស([១])សិន" គិតរកឧបាយល្អឃើញហើយ តាំងយកដង្កៀបកៀបកកុកភ្លាម កៀបទាល់តែដាច់ម៉ាត់ស្លាប់ទៅហោង ។

---

[១] ហិតោបទេសសេចក្ដីប្រែជាភាសាសៀមនៃលោកនាគប្រទីបមានគាថាលើសដូច្នេះ ក. ដរាបណាភ័យនៅឆ្ងាយ ដរាបនោះគួរខ្លាចភ័យមកដល់ កាលណាភ័យមកដល់ហើយ បុគ្គលគួរតស៊ូភ័យកាលនោះតាមដែលគិតទុកមុន ។ ខ. កាលណាអ្នកប្រាជ្ញត្រូវគេធ្វើអន្តរាយខ្លួនហើយ តែមើលមិនឃើញការព្រមព្រៀងចុះសម្រុងគ្នា កាលនោះ ត្រូវចូលប្រយុទ្ធព្រមស្លាប់ជាមួយសត្រូវ ។

ព្រោះហេតុនោះបានជាខ្ញុំ (ត្មាត**ទុរទសី**) ពោលថា៖ “កុកល្ងង់” ដូច្នេះជាដើម ។ ក្នុងកាលនោះឯង, ក្អែក**ចិត្រពណ៌**ពោលឡើងទៀតថា៖ “នែប្រធានរដ្ឋមន្ត្រី! ចូរស្តាប់ពាក្យខ្ញុំសិន ខ្ញុំបានគិតទុកដូច្នេះថា កាលបើតាំងឲ្យក្អែក**មេឃពណ៌**ជាស្តេចនៅកប៉ូរទ្វីប វត្ថុប្រសើរទាំងឡាយឯណាដែលមាននៅក្នុងកប៉ូរទ្វីប ក្អែក**មេឃពណ៌**នឹងបញ្ជូនមកថ្វាយយើងជាសួយសារអាករ អាស្រ័យដោយហេតុនេះ យើងនឹងនៅលើភ្នំវិន្ធ្យាដោយសេចក្តីសុខដ៏ក្រៃលែង” ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីបានស្តាប់ហើយ សើចក្អាកក្អាយ ហើយពោលថា៖

១៦- ជនណាមួយត្រេកអរមុនចំពោះប្រយោជន៍ ដែលមិនទាន់មកដល់តាមគំនិតដែលខ្លួនគិតទុកទេ ជននោះនឹងត្រូវប្រសព្វសេចក្តីក្តៅក្រហាយស្តាយក្រោយ ដូចព្រាហ្មណ៍ដែលវាយបំបែកក្រឡ ។

ក្អែក**ចិត្រពណ៌**សួរថា៖ “រឿងនោះតើដូចម្តេច?” ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីនិយាយរឿងនោះប្រាប់ថា៖

# កថាទី ៧

## រឿងព្រាហ្មណ៍វាយបំបែកក្រឡ

នៅទេវីកោដ្ឋនគរ, មានព្រាហ្មណ៍ម្នាក់ឈ្មោះ**ទេវសម៌:** បានសត្តូវមួយក្រឡពេញក្នុងថ្ងៃសង្ក្រាន្ត ហើយរីករាយសប្បាយចិត្តដូចជាមហាសម្បត្តិ ។ ព្រាហ្មណ៍កាន់យកសត្តូវមួយក្រឡនោះ ហើយដើរទៅទទួលមានកំដៅព្រះអាទិត្យក្តៅខ្លាំងពេក គាត់ក៏ចូលទៅដេកសម្រាកកាយក្នុងល្វែងមួយ នៃរោងដាក់ឆ្នាំងដែលពេញដោយឆ្នាំង ដៃកាន់ដំបងមួយផង ដើម្បីរក្សាសត្តូវនោះ គាត់គិតថា៖ “កាលណា អាត្មាអញលក់សត្តូវមួយក្រឡនេះទៅនឹងបានប្រាក់ ១០រៀល កាលនោះអាត្មាអញនឹងបានប្រាក់ ១០ រៀល នោះទៅទិញវត្ថុមានចានឆ្នាំងជាដើមយកទៅលក់តទៅទៀតកពូនប្រាក់ឲ្យកាន់តែច្រើនថែមឡើងៗ ហើយទៅវិញវត្ថុដទៃទៀតមានម្លូ និងសំពត់ជាដើមយកទៅលក់ទៀត សន្សំប្រាក់ដរាបទាល់តែបានមួយសែនរៀល ហើយថាំទៅដណ្តឹងប្រពន្ធឲ្យបាន ៤ នាក់តែម្តង ។ ប្រពន្ធណានៅក្មេង មានរូបឆោមលោមពណ៌ល្អជាងគេ អាត្មាអញនឹងស្រឡាញ់ផ្តេកផ្តិតកាយចំពោះនាងនោះច្រើនជាងគេ, ដរាបណា បើប្រពន្ធទាំង៤ នាក់នោះវាច្រណែនបែនទាគ្នា ដរាបនោះអាត្មាអញកើតទោសោ ហើយយកដំបងវាយប្រពន្ធទាំងនោះ” អាល័យតែស្មុងគំនិតគិតអណ្តែតអណ្តូងបណ្តោយទៅតាមចិត្តវិតក្កនោះ ក៏លើកដំបងវាយក្រឡសត្តូវនោះម៉ោកបែកខ្ទាយ មិនតែប៉ុណ្ណោះ ជ្រុលដំបងទៅត្រូវឆ្នាំងនៃស្ទួនឆ្នាំងបែកប្រេវប្រាវអស់ក្រៃលទៅទៀត ។ កាលនោះឯង, ស្ទួនឆ្នាំងឮសូរឆ្នាំងបែកប្រេវប្រាវដូច្នោះ ក៏រត់ទៅមើលឃើញឆ្នាំងបែកខ្ទាត់ខ្ទាយ កើត

មួម៉ៅជេរប្រទេច វាយបណ្ដេញតាបសចេញពីរោងឆ្នាំងនោះទៅ, ព្រោះហេតុនោះបានជាខ្ញុំ (ត្មាត**ទុរទសី**) ពោលថា៖ "ជនណាមួយត្រេកអរ" ដូច្នេះជាដើម (លេខ ១៦) ។ កាលនោះ, ក្អែក**ចិត្រពណ៌**និយាយប្រឹក្សាគ្នា ជាមួយនឹងត្មាតជាប្រធានរដ្ឋមន្ត្រីក្នុងទីស្ងាត់ថា៖ "ម្នាលសំឡាញ់! លោកគិតណែនាំខ្ញុំដូចម្ដេច ខ្ញុំនឹងធ្វើតាមពាក្យលោកដូច្នោះ" ។ ត្មាត**ទុរទសី**ពោលថា៖

១៧- ជនអ្នកណែនាំព្រះនរបតីដែលដើរខុសផ្លូវ ដូចដំរីចុះប្រេងដ៏ទ្រនង់នឹងត្រូវទទួលពាក្យគេបន្ទោស ។

ទេវៈ! សូមមេត្តាប្រោសស្ដាប់, បន្ទាយដែលយើងទម្លាយនេះ ទម្លាយបានដោយអំណាចកម្លាំងខ្ញុំបាទ ឬមួយទម្លាយបានដោយឧបាយប្រតិស្ឋកើតឡើងដោយប្រាជ្ញាលោកម្ចាស់?" ។ ក្អែក**ចិត្រពណ៌**ឆ្លើយតបថា៖ "ដោយឧបាយលោកប្រធានរដ្ឋមន្ត្រីទេតើ មិនមែនខ្ញុំទេ" ។ ត្មាត**ទុរទសី**ពោលថា៖ "បើប្រតិបត្តិទៅតាមពាក្យណែនាំខ្ញុំបាទ គួរនឹងលើកព្យុហរេហ៍ពលសកលយោធាយាត្រាត្រឡប់ទៅប្រទេសយើងវិញព្រោះថា រដូវនេះជិតរដូវភ្លៀងមកដល់ហើយ បើនឹងរៀបចំធ្វើសង្គ្រាមតទៅទៀត ទាំងពីរខាងមានកម្លាំងរេហ៍ពលប៉ុនគ្នា ឯការដកថយកម្លាំងរេហ៍ពលដោះទៅកាន់ប្រទេសវិញក្នុងចម្បាំងក៏លំបាក, ហើយយើងនៅក្នុងប្រទេសសត្រូវផង, ដើម្បីជាប្រយោជន៍ឲ្យកើតសេចក្ដីសុខធំទូលាយ និងកេរ្ដិ៍ឈ្មោះនោះគួរតែយើងធ្វើសន្ដិភាព ហើយសឹមដកទ័ពថយចេញទៅ, យើងកុំនឹកសប្បាយថាបន្ទាយសត្រូវយើងក៏បានវាយបាក់បែកខ្ទេចខ្ទីអស់ហើយ កេរ្ដិ៍ឈ្មោះយើងក៏បានហើយនុ៎ះ, នេះជាទស្សនៈរបស់ខ្ញុំបាទ, ព្រោះថា៖

១៨- នរជនណា យកធម៌ដាក់ពីមុខ មិនរវល់គិតថាម្ចាស់ស្រឡាញ់ ឬមិនស្រឡាញ់ ហើយអាចប៉ានពុះពារពោលពាក្យមិនជាទីគាប់ចិត្តចំពោះម្ចាស់ផង នរជននោះទុកជាមិត្តព្រះរាជាពិត ។

១៩- ([១]) នរណាហ្ន៎មិនឈ្មោះថាល្ងង់ បើយកខ្លួន, មិត្តសំឡាញ់, រេហ៍ពល, រាជ្យរបស់ខ្លួន, និងកេរ្ដិ៍ឈ្មោះខ្លួនទៅបោះចោលនៅក្នុងជញ្ជីងបះបើក គឺសេចក្ដីសង្ស័យមិនច្បាស់ក្នុងចិត្ត ក្នុងសង្គ្រាម? ។

២០- ក្នុងយុទ្ធសង្គ្រាម, ចួនកាលក៏មានខូចខាតទាំងពីរខាង ដូចសុន្ទៈ និងឧបសុន្ទៈ មានកម្លាំងស្មើគ្នាតយុទ្ធគ្នាទៅវិញទៅមក ស្លាប់ទាំងពីរនាក់មិនមែនឬអ្វី?" ។

---

[១] ហិតោបទេស សេចក្ដីប្រែជាភាសាបារាំងនៃលោកឡង់ស៊ឺរ៉ូ និងសេចក្ដីប្រែជាភាសាសៀមនៃលោកនាគប្រទីបមានគាថាលើសដូច្នេះ ព្រះព្រហស្បតិពោលដូច្នេះ បុគ្គលគប្បីប្រាថ្នាសន្ដិភាពចំពោះសត្រូវដែលមានកម្លាំងស្មើគ្នា ការយកជ័យជម្នះក្នុងសង្គ្រាមតែងមិនទៀងទាត់ទេ មិនគួរធ្វើខ្លួនឲ្យនៅក្នុងសន្ទិះសង្ស័យដូច្នេះឡើយ ។

ក្អែកចិត្រពណ៌សួរថា៖ "រឿងនោះតើដូចម្ដេច?" ។ ត្អាតជាប្រធានរដ្ឋមន្ត្រីនិយាយរឿងនោះប្រាប់ថា៖

# កថាទី ៨

## រឿងសុន្ទៈ និងឧបសុន្ទៈ

ក្នុងបុរាណសម័យ, មានទៃត្យៈពីរនាក់, មួយឈ្មោះសុន្ទៈ មួយទៀតឈ្មោះឧបសុន្ទៈ ជាអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញទាំងពីរនាក់ បានប្រារព្ធបំពេញតបៈខ្លាំងក្លាបូជាព្រះចន្ទ្រសេខរៈ ([១]) មកអស់កាលដ៏យូរហើយ ដើម្បីប្រាថ្នារាជ្យក្នុងត្រៃលោក ។ តមក, ព្រះចន្ទ្រសេខរៈដ៏មានជោគ ពេញព្រះទ័យទើបទ្រង់ប្រោសប្រាណទៃត្យៈទាំងពីរនាក់នោះត្រាស់ថា៖ "ចូរឯងទាំងពីរនាក់ប្រាថ្នាពរចុះ" ។ កាលនោះ, ទៃត្យៈទាំងពីរនាក់ ដោយកម្លាំងព្រះនាងសរស្វតីជាទេវីវាចា ជ្រែកចូលក្នុងកាយខ្លួនទាំងពីរ ក៏នាំបណ្ដាលឲ្យទូលសូមពរចំពោះព្រះចន្ទ្រសេខរៈ ផ្សេងពីរសេចក្ដីប្រាថ្នាដែលតាំងចិត្តទុកពីមុនមកទៅវិញ បែរជានិយាយសូមពរថា៖ "បើព្រះភគវន្តទ្រង់ប្រោសប្រាណប្រទានពរ ក៏សូមប្រទាននាងបវ៌តីជាទីប្រិមប្រិយរបស់ព្រះអង្គ" ។ កាលនោះ, ព្រះចន្ទ្រសេខរៈដ៏មានជោគទ្រង់ព្រះក្រេវក្រោធ តែក៏ទ្រង់មិនលះបង់សច្ចៈនៅតែប្រសិទ្ធិពរប្រទាននាងបវ៌តីដល់ទៃត្យៈល្ងង់ខ្លៅឥតការពិចារណានោះ ។ ចំណេរកាលមក ទៃត្យៈទាំងពីរជាអ្នកទ្រទ្រង់លោក ជាប់ចិត្តក្នុងលម្អព្រះសរីរាវយវៈព្រះនាងបវ៌តី ដោយកាមរាគដុតដាលក្នុងចិត្តងងឹតងងល់អាក្រក់ក្រៃលែង កើតឈ្លោះទាស់ទែងដណ្ដើមគ្នាទៅវិញទៅមកដោយអាងថាត្រូវបានខ្លួនតែសព្វខ្លួន ទីបំផុតចុះមតិព្រមគ្នានឹងយកប្រមាណបុរស គឺអ្នកអាជ្ញាកណ្ដាលជាចៅក្រមមកកាត់ក្ដីឲ្យ, កាលនោះ ព្រះចន្ទ្រសេខរៈជាម្ចាស់លោកជ្រាបសេចក្ដី ក៏ប្លែងព្រះអង្គជាព្រាហ្មណ៍ព្រឹទ្ធចុះមកប្រាកដក្នុងលោកនេះ ។ ទៃត្យៈទាំងពីរ និយាយនឹងតាព្រាហ្មណ៍នោះថា៖ "នាងនេះ, យើងទាំងពីរនាក់បានមកដោយកម្លាំងយើងទាំងពីរ សមគួរនឹងឲ្យអ្នកណាក្នុងយើងទាំងពីរនាក់នេះ?" ។ តាព្រាហ្មណ៍ឆ្លើយថា៖

២១- គួរបូជាព្រាហ្មណ៍ ព្រោះជាអ្នកមានវណ្ណៈប្រសើរ, ក្សត្រ ព្រោះជាអ្នកមានអំណាចច្រើន, វៃស្យ ព្រោះជាអ្នកមានទ្រព្យ និងស្រូវច្រើន, សូទ្រ ព្រោះជាអ្នកបម្រើព្រាហ្មណ៍ ។

បើលោកទាំងពីរនាក់ជាក្សត្រត្រូវកាន់ធម៌ជាក្សត្រ ការច្បាំងជានាទីនៃលោកដែលលោកនិយមស្រាប់ហើយ ។ លុះតាព្រាហ្មណ៍ជាប្រមាណបុរស (អ្នកអាជ្ញាកណ្ដាល) ពោលពាក្យដូច្នេះហើយ ទៃត្យៈទាំងពីរនាក់យល់ឃើញតាមដោយគិតឃើញថា ពាក្យដែលតាព្រាហ្មណ៍ជាអាជ្ញាកណ្ដាលពោល

---

[១] ព្រះនាមព្រះឥសូរ ប្រែថា មានរូបព្រះចន្ទ្រខាងខ្នើតជាមកុដ ។

នេះត្រឹមត្រូវហើយ ក៏ចូលទៅប្រយុទ្ធគ្នាក្នុងខណៈនោះយ៉ាងសហ័សដ៏សាហាវយង់ឃ្នង តែដោយគូទាំងពីរមានកម្លាំងស្មើគ្នា ក៏ប្រហារគ្នាទៅវិញទៅមកស្លាប់ទាំងពីរនាក់ទៅហោង, ព្រោះហេតុនោះបានជាខ្ញុំ (ត្បាត**ទុរទសី**) ពោលថា៖ "ក្នុងយុទ្ធសង្គ្រាម" ដូច្នេះជាដើម (លេខ ២០) ។ ក្រោក**ចិត្រពណ៌**និយាយឡើងថា៖ "កាលបើដូច្នេះ ដូចម្ដេចក៏មន្ត្រីឯងមិននិយាយពីកាលមុន?" ។ ត្បាត**ទុរទសី**ឆ្លើយតបទៅវិញថា៖ "កាលនោះ, លោកម្ចាស់បានស្ដាប់ពាក្យខ្ញុំបាទយល់សេចក្ដីដល់ទីបំផុតហើយឬ? សង្គ្រាមនេះកើតឡើងដោយមិនបានទទួលមតិយល់ព្រមពីខ្ញុំបាទទេ ព្រោះមិនគួរនឹងទៅរុកកួនឲ្យកើតវិវាទសោះ, ឯរាជហង្ស**ហិរណ្យគក៏**ប្រាថ្នាតែចងស្ពានមេត្រីជាសាធុគុណតែប៉ុណ្ណោះទេ មិនចង់ធ្វើសង្គ្រាមទេ, ព្រោះថា៖

២២- បុគ្គលមានសច្ចៈ ១, បុគ្គលជាអាយ៌ជាតិ ១, បុគ្គលទ្រទ្រង់ធម៌ ១, បុគ្គលជាអនារិយជាតិ ១, បុគ្គលមានបងប្អូនច្រើន ១, បុគ្គលមានកម្លាំង ១, បុគ្គលធ្លាប់មានជ័យក្នុងយុទ្ធសង្គ្រាមច្រើនដង ១, ទាំង ៧ ប្រភេទនេះ លោកពោលថាត្រូវធ្វើសន្ធិភាព ។

២៣- បុគ្គលមានសច្ចៈ តែងរក្សាសច្ចៈទៀងទាត់, នរណាធ្វើសន្តិភាពមួយអន្លើដោយបុគ្គលមានសច្ចៈ សន្តិភាពរមែងមិនប្រែប្រួលទេ, បុគ្គលជាអាយ៌ជាតិ សូម្បីខូចខាតដល់ជីវិត ក៏មិនព្រមលះបង់កិត្តិយស មិនព្រមដើរទៅតាមទំនងដែលជាអនារិយជាតិឡើយ ។

២៤- មែនពិត, ជនដែលបានឡើងឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ហើយ កាលបើត្រូវគ្រោះអន្តរាយនរណាៗក៏ទៅជួយតស៊ូរក្សាដែរ, អាស្រ័យដោយការរាប់អាននៃប្រជាជនទូទៅ និងគុណធម៌នៃខ្លួន អ្នកទ្រទ្រង់ធម៌ដែលជាទីរាប់អាននៃជន បុគ្គលណានីមួយទៅធ្វើអន្តរាយមិនបានដោយងាយឡើយ ។

២៥- កាលបើសេចក្ដីវិនាសចូលមកជិតដល់ហើយ សូម្បីអនារិយជន យើងក៏គួរធ្វើសន្តិភាពដែរ ព្រោះថាបើវៀរមិនអាស្រ័យអនារិយជននោះហើយ យើងមិនអាចធ្វើឲ្យយើងរស់តទៅទៀតបានឡើយ ។

២៦- ឫស្សីដុះជាគុម្ពក្រាស់ ជិតប្រកិតគ្នាចោមរោមព័ទ្ធដោយដៃឫស្សីមានបន្លាស្អេកស្កះ បុគ្គលមិនអាចចូលទៅកាប់កាត់ឫស្សីនោះបានដោយងាយទេ យ៉ាងណា បុគ្គលមានបងប្អូនច្រើន ក៏យ៉ាងនោះដែរ។

២៧- ពាក្យដែលនិយាយថា "ត្រូវច្បាំងតស៊ូនឹងបុគ្គលមានកម្លាំង" ដូច្នេះ មិនមានឧទាហរណ៍ណាជានិទស្សន៍ទេ ក្នុងកាលណាក៏ដោយ ដុំពពកមិនដែលរសាត់ច្រាសខ្យល់ឡើយ ។

២៨- ជនគ្រប់គ្នា ទីឋានគ្រប់កន្លែង គ្រប់កាលវេលា បុគ្គលរមែងចុះញ៉មព្រមចាញ់អានុភាពនៃវីរបុរសដែលធ្លាប់មានជ័យច្រើនដងណាស់មកហើយ ដូចជាបុរសជារាជបុត្រព្រះបាទជមទគ្និ" ([១]) ។

---

[១] បរសុរាមជាបុត្រព្រះបាទជមទគ្និ ជាសត្រូវនឹងព្រះរាម ច្រណែននឹងព្រះរាមព្រោះខ្លួនឈ្មោះរាមដែរ ។

២៩- អ្នកធ្លាប់មានជ័យក្នុងយុទ្ធសង្គ្រាមច្រើនដងហើយ ទៅធ្វើសន្តិភាពមួយអន្លើដោយព្រះរាជាអង្គណា សត្រូវនៃព្រះរាជាអង្គនោះនឹងលុះក្នុងអំណាចនៃព្រះអង្គភ្លាម ដោយអានុភាពនៃការចងស្ពានមេត្រីសន្តិភាពនោះ ។

ក្នុងរឿងនេះ, រាជហង្ស**ហិរណ្យគក៏**នេះប្រកបដោយគុណលក្ខណៈច្រើនប្រការណាស់គួរនឹងធ្វើសន្តិភាពបាន" ។ **ចាក្រពាកសវ័ជ្ជះ**ជាប្រធានរដ្ឋមន្ត្រីនៃរាជហង្ស**ហិរណ្យគក៏**បានស្តាប់ពាក្យនៃកុក**ទីឃ័មុខ** ជាចារបុរស ដែលបានមកថ្លែងប្រាប់សព្វគ្រប់តាំងពីដើមដល់ចុង ដូចសេចក្តីរៀបរាប់នេះហើយ ទើបនិយាយតទៅទៀតថា៖ "នៃកុកចារបុរស! យើងបានស្តាប់ពាក្យអ្នកអស់អាថ៌សេចក្តីស្រេចហើយ តែអ្នកចូរទៅម្តងទៀត ទៅស្តាប់ឲ្យបានការអស់ ហើយចូរត្រឡប់មកប្រាប់យើងវិញយ៉ាងឆាប់ៗ" ។ តែក្នុងពេលដែល**ចាក្រពាក**បង្គាប់កុក**ទីឃ័មុខ**ដូច្នេះ រាជហង្ស**ហិរណ្យគក៏**សួរ**ចាក្រពាកសវ័ជ្ជះ**ថា៖ "លោកប្រធានរដ្ឋមន្ត្រី! ខ្ញុំចង់ដឹងថា បុគ្គលដែលយើងមិនគួរនឹងធ្វើសន្តិភាពចងស្ពានមេត្រីនោះបែបណាខ្លះ?" ។ **ចាក្រពាកសវ័ជ្ជះ**ឆ្លើយប្រាប់រាជហង្ស**ហិរណ្យគក៏**ថា៖ "ទេវៈ! ខ្ញុំបាទនឹងបរិយាយជូន, សូមលោកម្ចាស់ចាំស្តាប់ដូចសេចក្តីតទៅនេះ៖

៣០- ១ ក្មេង, ២ មនុស្សចាស់, ៣ មនុស្សឈឺរីងរៃ, ៤ មនុស្សដែលញាតិបណ្តេញចោលបង់, ៥ នាយខ្លាច, ៦ បរិវារខ្លាច, ៧ នាយល្មោភ, ៨ បរិវារល្មោភ,

៣១- ៩ មនុស្សដែលមានប្រក្រតីព្រងើយកន្តើយ, ១០ មនុស្សមានចិត្តជាប់ក្នុងកាមគុណ, ១១ មនុស្សមានចិត្តផ្លាស់ប្តូរច្រើន (ចិត្តមិនទៀងទាត់), ១២ មនុស្សនិន្ទាទេពតា និងព្រាហ្មណ៍,

៣២- ១៣ មនុស្សមានព្រេងសំណាងអាក្រក់, ១៤ មនុស្សជឿព្រេងសំណាង, ១៥ មនុស្សត្រូវអន្តរាយដោយទុរភិក្ស, ១៦ មនុស្សមានចិត្តរសាំរសាយក្នុងក្តីអន្តរាយវេហ៍ពល,

៣៣- ១៧ មនុស្សមិននៅក្នុងប្រទេសខ្លួន, ១៨ មនុស្សមានសត្រូវច្រើន, ១៩ មនុស្សមិនប្រកបដោយវេលា, ២០ មនុស្សមិនកាន់សច្ចៈ និងធម៌, មនុស្សដែលមិនត្រូវធ្វើសន្តិភាពមាន ២០ ពួក ដូចពោលមកនេះ ។

៣៤- បុគ្គលទាំង ២០ ពួកនេះ មិនត្រូវធ្វើសន្តិភាពជាមួយឡើយ មានតែត្រូវធ្វើសង្គ្រាមតបវិញតែប៉ុណ្ណោះ ព្រោះថាបុគ្គល ២០ ពួកនេះ កាលបើចាត់ធ្វើសង្គ្រាមហើយ មុខជាធ្លាក់ទៅក្នុងអំណាចសត្រូវពិតប្រាកដហើយឆាប់រហ័សផង ។

៣៥- ធម្មតាលោក តែងមិនពេញចិត្តធ្វើសង្គ្រាមដើម្បីកូនក្មេង ព្រោះកូនក្មេងមិនមានអំណាច, មួយទៀត កូនក្មេងមិនយល់ផលនៃការច្បាំង និងការមិនច្បាំងទេ ។

៣៦- មនុស្សចាស់ និងមនុស្សឈឺរឹងរៃ មិនមានឧស្សាហ: និងអង់អាចទេ ជនទាំង ២ ពួកនេះ សូម្បីតែបងប្អូនឯងក៏មើលងាយឥតសង្ស័យឡើយ ។

៣៧- មនុស្សដែលញាតិទាំងពួងបណ្តេញបង់ គេអាចទម្លាយបានដោយងាយ ព្រោះញាតិទាំងឡាយដែលមានគ្រោះដល់ខ្លួននឹងសម្លាប់ជនពួកនេះចោលបង់មិនខាន ។

៣៨- នាយខ្លាច រត់ចោលសង្គ្រាម នឹងដល់សេចក្តីវិនាសដោយខ្លួនឯង បរិវារខ្លាចក៏នឹងរត់ចោលម្ចាស់ខ្លាចសង្គ្រាមដូចគ្នាដែរ ។

៣៩- នាយល្មោភ តែងមានបរិវារមិនសូវចង់ច្បាំង ព្រោះបរិវារមិនសូវបានចំណែក ឯបរិវារល្មោភដែលមិនបានរង្វាន់នឹងសម្លាប់នាយល្មោភបង់ ។

៤០- មនុស្សដែលមានប្រក្រតីព្រងើយកន្តើយ ត្រូវមនុស្សដែលមានប្រក្រតីមិនព្រងើយកន្តើយលះបង់ចោលក្នុងសង្គ្រាម, ឯមនុស្សដែលមានចិត្តជាប់ក្នុងកាមគុណ គេតែងយកឈ្នះបានដោយងាយ ។

៤១- មនុស្សមានចិត្តផ្លាស់ប្តូរច្រើន តែងជាទីបែកចិត្តនៃជនអ្នកជួយប្រឹក្សា (មន្ត្រី) ដល់មានកិច្ចការកើងឡើង មនុស្សមានចិត្តផ្លាស់ប្តូរច្រើននោះតែងព្រងើយកន្តើយ ព្រោះមានចិត្តមិនទៀងទាត់ ។

៤២- មនុស្សនិន្ទាទេពតា និងព្រាហ្មណ៍ នឹងសាបសូន្យទៅឯង១ ព្រោះអំណាចព្រះធម៌ធំទូលាយណាស់ ឯមនុស្សមានព្រេងសំណាងអាក្រក់ វិនាសដូចគ្នាដែរ ។

៤៣- មែនពិត, ការជឿព្រេងសំណាងជាហេតុនៃសម្បត្តិ (សេចក្តីចម្រើន) ផង នៃវិបត្តិ (សេចក្តីវិនាស) ផង កាលបើដូច្នេះ មនុស្សជឿព្រេងសំណាង នឹងមិនតាំងចិត្តព្យាយាមធ្វើអ្វីដោយខ្លួនឯង ។

៤៤- មនុស្សដែលត្រូវអន្តរាយដោយទុរភិក្ស នឹងលិចស្រឹមទៅដោយខ្លួនឯង, រីនាយមានចិត្តរសាំរសាយក្នុងក្តីអន្តរាយរេហ៍ពលក៏មិនអាចនឹងកទ័ព ដើម្បីធ្វើចម្បាំងទៀតបានទេ ។

៤៥- មនុស្សដែលមិននៅក្នុងប្រទេសខ្លួន សូម្បីកូនសត្រូវតូចមួយក៏អាចសម្លាប់បាន ដូចក្រពើសូម្បីតូចតាច បើនៅក្នុងទឹកហើយ អាចចាប់ដល់ដំរីសារធំក៏បាន ។

៤៦- មនុស្សមានសត្រូវច្រើន តែងរន្ធត់តក់ស្លុត ដូចព្រាបនៅក្នុងកណ្តាលហ្វូងខ្លែង បើទុកជាដើរផ្លូវណាក៏ដោយ មិនយូរប៉ុន្មាននឹងដល់ក្តីស្លាប់មិនខាន ។

៤៧- មនុស្សដែលមានសេនាទុភាពមិនប្រកបដោយវេលា នឹងត្រូវយោធាដែលប្រកបដោយកាលវេលាវាយខ្ចាត់ខ្ចាយបាន ដូចក្អែកនៅក្នុងពេលរាត្រីឥតមានពន្លឺត្រូវទីទុយសម្លាប់បាន ។

៤៨- ក្នុងកាលណាក៏ដោយ បុគ្គលមិនគួរធ្វើសន្តិភាព (មេត្រី) មួយអន្លើដោយមនុស្សមិនកាន់

សច្ចៈ និងធម៌ឡើយ ព្រោះថា កាលបើធ្វើសន្តិភាពជាមួយជនបែបនេះហើយ មិនយូរប៉ុន្មាន នឹងដល់នូវការប្រែប្រួលដោយហេតុតែមិនមែនជាសប្បុរសនោះឯង ។

ខ្ញុំបាទនឹងជម្រាបតទៅទៀតថា ការធ្វើសន្តិភាព ១, ការធ្វើសង្គ្រាម១, ការយាត្រាទ័ព ១, ការសំចតទ័ព ១, ការពឹងពាក់អាស្រ័យនៃទ័ព ១, ការចាត់ចែងទ័ព ១ ទាំង៦ ប្រការនេះជាអង្គការនៃកងទ័ព ។ ឧបាយដើម្បីចាប់ផ្ដើមធ្វើការ ១, រេហ៍ពលនិងទ្រព្យសម្បត្តិ ១, ការលៃលកទៅតាមកាលៈទេសៈ ១, ឧបាយការពារមិនឲ្យចាញ់ ១, សេចក្ដីសម្រេចផលនៃការងារ ១ ទាំង ៥ ប្រការនេះជាអង្គនៃការប្រឹក្សា ។ ការផ្សះផ្សា ១, ការចែករំលែក ១, ការញុះញង់បំបែក ១, ការផ្ដន្ទាទោស ១ ទាំង៤ ប្រការនេះជាឧបាយយកឈ្នះ ។ អានុភាពនៃឧស្សាហៈ ១, អានុភាពនៃការប្រឹក្សា១ , អានុភាពនៃព្រះរាជា ១ ទាំង ៣ ប្រការនេះជាអានុភាព ([1]) ។ កាលបើបានពិចារណាតាមពាក្យដែលបានពោលមកនេះជានិច្ចហើយ អ្នកប្រាថ្នាជ័យជម្នះ នឹងបានសម្រេចផលបានទៅជាបុគ្គលធំមិនខាន ។

៤៩- សេចក្ដីពិត, ស្រីណា ([2]) ដែលបុគ្គលមិនគប្បីបានដោយតម្លៃគឺការបរិច្ចាកជីវិត ស្រីនោះសូម្បីទ្រេតទ្រោតឃ្លេងឃ្លោង រមែងរត់ទៅរកបុគ្គលដែលចេះនីតិសាស្ត្រ (ចេះនយោបាយ) ។

៥០- ក្នុងកាលណា ជនណាចេះចែកចាយទ្រព្យសម្បត្តិឲ្យជនដទៃស្មើភាគគ្នា មានចារបុរសចេះលាក់លៀមការសម្ងាត់ទុកដោយល្អ មានការប្រឹក្សាយ៉ាងស្ងាត់ មិនពោលពាក្យអសុរសចំពោះសព្វមនុស្សទាំងឡាយ ក្នុងកាលនោះ ជននោះ អាចគ្រប់គ្រងប្រឹថពីមណ្ឌលដែលមានសាគរជាខបខេត្តបាន ។

ទេវៈ! បើទុកជាត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីបានណែនាំឲ្យធ្វើសន្តិភាពក្ដី ក្នុងពេលនេះ ក្អែក**ចិត្រពណ៌**នៅកំពុងឡើងជោរដោយការមានជ័យ គង់មិនទាន់យល់ព្រមនៅឡើយទេ ។ ក្នុងរឿងនេះ, គួរលោកម្ចាស់ចាត់ការដូច្នេះវិញ ពេលនេះគួរឲ្យកុកឈ្មោះ**មហាពល**នៃសីហលទ្វីបជាសហាយរបស់យើងធ្វើជារាជា ហើយញុះឲ្យទៅកការចលាចលឡើងក្នុងជម្ពូទ្វីប, ព្រោះថា៖

៥១- វីរយោធា ដែលមានគ្រឿងការពារល្អ រក្សាការសម្ងាត់ទុកដោយប្រពៃ យាត្រាទ័ពដ៏ណាស់ណាន់តាន់តាប់ហើយមានរបៀប ចូលទៅដុតកំដៅសត្រូវណាដែលមានកម្លាំងស្មើភាគគ្នាឲ្យរំខាន សត្រូវដែលក្ដៅក្រហាយរំខានហើយនោះ នឹងចូលមកធ្វើសន្តិភាព ព្រោះហេតុតែសេចក្ដីរំខាននោះឯង” ។

រាជហង្ស**ហិរណ្យគក៏**យល់ព្រមហើយពោលថា៖ “ធ្វើយ៉ាងនេះត្រឹមត្រូវហើយ” ទើបប្រគល់

---

[1] អានុភាពគឺឥទ្ធិក្នុងចម្បាំងមាន ៣ ប្រការគឺ ១ ឧស្សាហឥទ្ធិ ២ មន្ត្រឥទ្ធិ និង ៣ ប្រភូឥទ្ធិ ។

[2] សិរីសួស្ដី, ទ្រព្យសម្បត្តិ, ជ័យជម្នះ ។

សាសន៍សម្ងាត់បញ្ជូនកុកឈ្មោះ**វិចិត្រ**ឲ្យទៅសីហលទ្វីប ។ ក្នុងពេលដែលរាជហង្ស**ហិរណ្យគក៏** និង **ចាក្រពាកសវ័ជ្ជៈ**កំពុងតែប្រឹក្សាគ្នាដូច្នេះ កុក**ទីឃ័មុខ**ជាចារបុរសមកដល់ ហើយនិយាយប្រាប់ថា៖ "ទេវៈ! ខ្ញុំបាទបានឮសត្រូវគឺត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីនិយាយប្រាប់ក្ងោក**ចិត្រពណ៌**ក្នុងទីនោះថា៖ " ទេវៈ! ក្អែក**មេឃពណ៌**បាននៅក្នុងសំណាក់រាជហង្ស**ហិរណ្យគក៏** អស់កាលយូរហើយ វាគង់នឹងបានដឹងថារាជហង្ស**ហិរណ្យគក៏**ជាបុគ្គលគឺយើង (ក្ងោក**ចិត្រពណ៌**) គួរគប្បីធ្វើសន្និសញ្ញាស្ងប់សឹកបាន ឬមិនបាន" ។ កាលដែលក្អែក**មេឃពណ៌**ចូលទៅដល់ខ្ញុំ (កុក**ទីឃ័មុខ**) បានឮថាក្ងោក**ចិត្រពណ៌**សួរថា៖ "នែ**មេឃពណ៌**! រាជហង្ស**ហិរណ្យគក៏**ជាស្ដេចបែបណា? **ចាក្រពាកសវ័ជ្ជៈ**ប្រធានរដ្ឋមន្ត្រីមានលក្ខណៈដូចម្ដេចខ្លះ?" ។ ក្អែក**មេឃពណ៌**ឆ្លើយប្រាប់ថា៖ "ទេវៈ! រាជហង្ស**ហិរណ្យគក៏** ជាស្ដេចមានអធ្យាស្រ័យទ្រង់សច្ចៈ ទៀងត្រង់ណាស់ប្រដូចជាអង្គព្រះបាទយុទ្ធិស្ធិរ ([1]) ឯប្រធានរដ្ឋមន្ត្រីដូច**ចាក្រពាកសវ័ជ្ជៈ**នេះក៏គេរកបានដោយក្រណាស់" ។ កាលនោះ, ក្ងោក**ចិត្រពណ៌**សួរកាត់ទៀតថា៖ "ថាបើកាន់សច្ចៈល្អដូច្នេះ ហេតុអ្វីក៏ឯងចូលទៅលល្បួងឲ្យចាញ់កលបាន?" ។ ក្អែក**មេឃពណ៌**សើចហើយឆ្លើយតបភ្លាមវិញថា៖ "ទេវៈ?

៥២- ការលួងបោកជនឲ្យជឿទុកចិត្តស្រេចហើយ ចាំបាច់ប្រើសេចក្ដីឆ្លៀវឆ្លាតអ្វីប៉ុន្មាន ដូចជាការប្រហារជនដែលចូលមកដេកលើស្មាយើងហើយ ចាំបាច់ប្រើសេចក្ដីអង់អាចជាជាតិបុរសអ្វីប៉ុន្មាន" ។

ទេវៈ! សូមលោកម្ចាស់ស្ដាប់, **ចាក្រពាកសវ័ជ្ជៈ**ជាប្រធានរដ្ឋមន្ត្រី ដឹងថាខ្ញុំបាទជាចារបុរសតាំងពីប្រថមទស្សន៍ម្ល៉េះ តែរាជហង្ស**ហិរណ្យគក៏**មានអធ្យាស្រ័យធំណាស់ ហើយជឿទុកចិត្តខ្ញុំបាទស៊ប់ បានជាខ្ញុំបាទលល្បួងបោកបាន, ព្រោះថា៖

៥៣- ជនណា ដឹងថាទុរជនពោលពាក្យសច្ចៈដូចខ្លួនដឹងដែរ ជននោះត្រូវទុរជនលល្បួងបោកបាន ដូចព្រាហ្មណ៍ត្រូវពួកអ្នកលេងបោកយកពពែបាន ។

ក្ងោក**ចិត្រពណ៌**សួរថា៖ "ចុះរឿងនោះតើដូចម្ដេច?" ។ ក្អែក**មេឃពណ៌**និយាយរៀបរាប់ប្រាប់ថា៖

## កថាទី ៩

### រឿងព្រាហ្មណ៍ នឹងអ្នកលេង

នៅអរញ្ញនៃព្រះគោតម មានព្រាហ្មណ៍ម្នាក់ល្ងង់ឆោត ដោយពាក្យសរសើរ ព្រាហ្មណ៍នោះមាន

---

[1] ព្រះរាជាបណ្ឌុក ក្នុងរឿងមហាភារតៈ ជាស្ដេចប្រកបដោយធម៌។

ប្រាថ្នាធ្វើយញ្ញពិធី ហើយចូលទៅគ្រាមមួយរកទិញពពែ ទិញបានហើយ លើកលីលើស្មាដើរត្រឡប់មកវិញ មកដល់ពាក់កណ្ដាលផ្លូវជួបនឹងអ្នកលេង ៣ នាក់ ។ អ្នកលេងទាំងឡាយនោះ លុះឃើញព្រាហ្មណ៍លីពពែមកដល់ ក៏គិតគ្នាថា៖ “បើយើងដើរកលឧបាយយកពពែនេះបាន ទុកជាយើងចេះកលឧបាយឆ្លាតមែន” គិតគ្នាដូច្នេះហើយ ទើបប្បួលគ្នាទៅអង្គុយក្រោមឈើមួយម្នាក់ៗគ្រប់ទាំង ៣ នាក់ នៅបណ្ដោយផ្លូវដែលព្រាហ្មណ៍នោះដើរទៅឃ្លាតឆ្ងាយពីគ្នាចម្ងាយប្រហែលមួយក្រោសៈ ([១]) ប៉ុណ្ណោះ ។ កាលដែលព្រាហ្មណ៍នោះដើរមកដល់ អ្នកលេងទី១ សួរទៅថា៖ “នែព្រាហ្មណ៍ដ៏ចម្រើន! អ្នកលីអ្វីលើស្មា មើលទៅដូចជាឆ្កែ យកឆ្កែទៅធ្វើអ្វីហ្នឹង? ។ ព្រាហ្មណ៍ឆ្លើយតបថា៖ “ទេ! មិនមែនឆ្កែទេ ពពែទេតើ, ខ្ញុំយកទៅធ្វើយញ្ញពិធី” ។ ព្រាហ្មណ៍ដើរតទៅទៀត ទៅជួបអ្នកលេងទីពីរៗនិយាយសួរដដែលដូចអ្នកលេងទី១ទៀត ។ ព្រាហ្មណ៍បានស្ដាប់ពាក្យសួរដដែលៗដូច្នោះ នឹកអៀនហើយរង្កៀសខ្លួនក៏ទម្លាក់ពពែចោលទៅដីសម្លឹងពិនិត្យមើលផ្អៀងផ្អងមួយស្របក់ មើលហើយមើលទៀតមិនអស់ចិត្ត នឹកស្ដាយក៏លើកពពែនោះលីលើស្មាដើរតទៅទៀត ហើយចេះតែមានសេចក្ដីសង្ស័យស្ទាក់ស្ទើរក្នុងចិត្តមិនអស់មិនហើយ, ព្រោះថា៖

៥៤- ទៀងណាស់, មតិនៃសប្បុរសទាំងឡាយ ក៏អាចទន់រេទៅតាមសម្ដីទុរជនទាំងឡាយដែរ ជនដែលជឿទុកចិត្តទុរជនទាំងឡាយនេះ នឹងដល់នូវសេចក្ដីស្លាប់ដូចឱដ្ឋឈ្មោះ**ចិត្រកណ៌ៈ** ។

ក្អែក**ចិត្រពណ៌**សួរថា៖ “រឿងនោះតើដូចម្ដេច?” ។ ក្អែក**មេឃពណ៌**និយាយរឿងនោះប្រាប់ថា៖

# កថាទី ១០

## រឿងសីហៈ, ក្អែក, ខ្លា, ចចក និងឧដ្ឋ

នៅអរញ្ញប្រទេសមួយ, មានសីហៈឈ្មោះមនោត្កដៈ ។ សីហៈនេះមានបរិវារ ៣នាក់ គឺក្អែក ១, ខ្លា ១, និងចចក ១ ។ ថ្ងៃមួយតមក, ក្នុងពេលដែលកំពុងត្រាច់ចររកអាហារ សត្វទាំង៣ នេះបានឃើញឱដ្ឋមួយហើយសួរថា៖ “នែឧដ្ឋ! ឯងបែកខ្ចាត់ខ្ចាយចេញមកពីក្បួនរទេះឯណា? រួចទៅណាហ្នឹង?” ។ ឧដ្ឋក៏រៀបរាប់ព្រឹត្តិហេតុខ្លួនប្រាប់តាំងពីដើមមកដល់ចប់ ។ កាលនោះ, សត្វទាំងនោះនាំឧដ្ឋទៅប្រគល់ឲ្យសីហៈជានាយ សីហៈក៏ឲ្យអភ័យវាចាហើយដាក់ឈ្មោះឧដ្ឋថា **ចិត្រកណ៌ៈ** អនុញ្ញាតឲ្យនៅក្នុងសំណាក់ខ្លួនតទៅ ។ ចំណេរតមក, សីហៈឈឺ រាងកាយស្គាំងស្គម ណាមួយភ្លៀងធ្លាក់មកជោគជាំខ្លាំងពេក មិនអាចដើរស្វះស្វែងរកចំណីអាហារបាន សត្វទាំងឡាយមានខ្លាជាដើមក៏និយាយប្រឹក្សាគ្នាថា៖

---

[១] ប្រហែល ១/៤ យោជន៍។

"ម្ចាស់យើងនឹងសម្លាប់ឧដ្ឋធ្វើជាចំណីអាហារបានយ៉ាងណា យើងត្រូវគិតអានឲ្យម្ចាស់យើងសម្លាប់យ៉ាងនោះ ប្រយោជន៍អ្វីនឹងសត្វស៊ីបន្លាជាចំណីអាហារនេះ?" ។ ខ្លាពោលថា៖ "ឧដ្ឋនេះម្ចាស់យើងបានឲ្យអភ័យវាចាហើយអនុគ្រោះរក្សាទុក បើដូច្នោះតើយើងនឹងសម្លាប់ដូចម្ដេចកើត?" ។ ក្អែកពោលថា៖ "សម័យនេះ ម្ចាស់យើងទន់ខ្សោយកម្លាំងណាស់ទៅហើយ បើទុកជាបាបក៏លោកប៉ានធ្វើដែរ, ព្រោះថា៖

៥៥- ស្រីភាព ដែលអត់ឃ្លានហើយ សូម្បីកូនឯងក៏លះបង់ចោល, ពស់ដែលអត់ឃ្លានហើយសូម្បីពងឯងក៏ស៊ី, នរណាហ្ន៎ដែលត្រូវទុក្ខវេទនាដោយអត់ឃ្លាន នឹងមិនប៉ានធ្វើបាប? នរជនទាំងឡាយដែលអត់ឃ្លានហេវកម្លាំងហើយ នឹងត្រឡប់ទៅជាមនុស្សឥតករុណា ។

៥៦- មនុស្សស្រវឹងស្រា មនុស្សឆ្កួត មនុស្សកាចកំរោល មនុស្សអស់កម្លាំង មនុស្សក្រោធ មនុស្សអត់ឃ្លាន មនុស្សល្មោភ មនុស្សខ្លាច មនុស្សរហ័សក្ដែត និងមនុស្សបរិភោគកាម មនុស្សទាំងអស់នេះមិនចេះធម៌ទេ" ។

សត្វទាំងឡាយគិតគូរគ្នាឃើញដូច្នេះហើយ ក៏បបួលគ្នាទៅកាន់សំណាក់សីហៈ ។ សីហៈសួរថា៖ "បានអ្វីជាអាហារបរិភោគឬទេ ថ្ងៃនេះ?" ។ សត្វទាំងឡាយឆ្លើយប្រាប់ថា៖ "យើងខ្ញុំទាំងអស់គ្នាខំប្រឹងស្វះស្វែងរកណាស់ តែរកមិនបានសោះ" ។ សីហៈសួរតទៅទៀតថា៖ "ចុះធ្វើម្ដេចទៅឥឡូវនេះ យើងនឹងរកឧបាយចិញ្ចឹមជីវិតបានហ៎ះ?" ។ ក្អែកនិយាយប្រាប់ថា៖ "ទេវៈ! មកពីលោកម្ចាស់លះបង់អាហារដែលមានក្នុងអំណាចលោកម្ចាស់ បានជាសេចក្ដីវិនាសចូលមកជិតដល់យើងគ្រប់គ្នា" ។ សីហៈសួរថា៖ "អាហារអ្វីហ្ន៎ដែលនៅក្នុងអំណាចយើង?" ។ ក្អែកចូលទៅជិតនិយាយខ្សឹបដាក់ត្រចៀកសីហៈថា៖ "**ចិត្រកណ៌ៈ**នេះឯង" ។ សីហៈយកជើងជាន់ដីហើយស្ទាបត្រចៀក (១) ទាំងពីរទើបពោលថា៖ "យើងបានឲ្យអភយវាចាហើយ នឹងទៅធ្វើទារុណកម្មដូចម្ដេចកើត?" ព្រោះថា៖

៥៧- ការឲ្យផែនដី ការឲ្យប្រាក់មាស ការឲ្យគោ ការឲ្យបាយទឹក លោកមិនទាន់ហៅថាមហាទានទេ បណ្ដាទានទាំងឡាយនេះ អភយទានទើបលោកចាត់ថាជាមហាទាន ។

៥៨- ផលនៃអស្វមេធៈណា (២) ដែលអាចញ៉ាំងសេចក្ដីទាំងពួងឲ្យសម្រេចបាន ផលនោះ គឺបុគ្គលគប្បីបានក្នុងការរក្សាជនណាដែលមកសូមទីពឹង ។

ក្អែកពោលថា៖ "ឧដ្ឋលោកម្ចាស់មិនត្រូវសម្លាប់ដោយខ្លួនឯងទេ គឺវាសុខចិត្តប្រគល់ខ្លួនវាឲ្យជា

---

១ កិរិយាសម្ដែងសេចក្ដីគោរព ។

២ អគ្គមេធៈ ពិធីសម្លាប់សេះបូជាយញ្ញ ដែលប្រកាន់ជឿថាបានបុញ្ញាភិនិហារដ៏ក្រៃលែងរហូតបានជាស្ដេចទេវតានៅឋានត្រៃត្រឹង្ស ។

ទានយ៉ាងណា យើងខ្ញុំទាំងឡាយនឹងធ្វើយ៉ាងនោះ” ។ សីហៈលុះបានស្តាប់ពាក្យក្អែកពន្យល់ឧបាយយ៉ាងនេះហើយ ក៏ទាល់គំនិតនៅស្ងៀម ។ កាលនោះ, ក្អែកបានឱកាសនឹងប្រើឧបាយកោង ក៏ទៅនាំយកសត្វទាំងឡាយឯទៀតឲ្យចូលទៅកាន់សំណាក់សីហៈ ហើយនិយាយថា៖ “ទេវៈ! យើងគ្រប់គ្នាប្រឹងស្វះស្វែងរកចាប់សត្វជាចំណីអាហារអស់ប៉ុណ្ណឹងហើយ នៅតែមិនបានសោះ ឯលោកម្ចាស់អត់ឃ្លានអាហារមកយូរថ្ងៃដែរហើយ បើដូច្នោះសូមលោកម្ចាស់ស៊ីសាច់យើងជាអាហារចុះ, ព្រោះថា៖

៥៩- មែនពិត, កិច្ចការរដ្ឋបាលទាំងអស់មានលោកម្ចាស់ជាមូល ជាទង់ជ័យ ដូចជានរជនដែលប្រយ័ត្នរក្សាដើមឈើព្រមទាំងគល់ តែងបានផល ។

សីហៈពោលថា៖ “ការសុខចិត្តព្រមលះបង់ជីវិតប្រសើរ តែការប្រព្រឹត្តិធ្វើអំពើអាក្រក់ប្រាកដដូច្នេះមិនប្រសើរសោះឡើយ” ។ ចចកពោលដូចក្អែកទៀត ។ សីហៈនិយាយតទៅទៀតថា៖ “ទេ! ទេ! កុំឡើយបាអើយ!” ។ កាលនោះ, ខ្លានិយាយទៀតថា៖ “បើដូច្នោះសូមលោកម្ចាស់បរិភោគខ្ញុំចុះ ដើម្បីឲ្យលោកមានជីវិត” ។ សីហៈឆ្លើយដោយអស្ចារ្យក្នុងចិត្តថា៖ “ក្នុងកាលណាក៏ដោយ មិនមានអ្នកណានិយាយដូចឯងទេ ពាក្យឯងនិយាយនេះមិនគួរសោះឡើយ” ។ ពេលនោះ, ឱដ្ឋ**ចិត្រកណ៌ៈ**ដែលជាសត្វមានការជឿទុកចិត្តពីកំណើត ក៏និយាយប្រគល់ខ្លួនដូចសត្វទាំងពួង ។ កាលដែលឱដ្ឋនិយាយបរិច្ចាកប្រាណស្ទើរតែមិនទាន់ផុតសម្តីផង ខ្លាស្ទុះភ្លែតទៅចាប់ហែកជញ្ជែងផ្ទៃឱដ្ឋសម្លាប់មួយរំពេច ហើយចែកគ្នាស៊ីបំពេញផ្ទៃទៅហោង ។ ព្រោះហេតុនោះបានជាខ្ញុំបាទ (ក្អែក**មេឃពណ៌**) ពោលថា៖ “ទៀងណាស់” ដូច្នេះជាដើម (លេខ ៥៤) ។ តមក, ព្រាហ្មណ៍បានស្តាប់ពាក្យអ្នកលេងទី៣ ទៀត ទើបកំណត់ទុកដាច់ខាតថាមតិរបស់ខ្លួនខុសពិត ហើយបោះទម្លាក់ពពែនៅលើស្មាចោលបង់ ដើរទៅងូតទឹកជម្រះអាត្មារួចដើរទៅផ្ទះដៃទទេទៅ ។ ឯពពែនោះ ត្រូវអ្នកលេងទាំង ៣ នាក់ សែងយកទៅសំឡេះបរិភោគជាអាហារទៅហោង ហេតុនេះបានជាខ្ញុំបាទ (ក្អែក**មេឃពណ៌**) និយាយថា៖ “ជនណាដឹងថាទុរជនដូច្នេះជាដើម” (លេខ ៥៣) ។ កាលនោះក្ងោក**ចិត្រពណ៌**សួរតទៅទៀតថា៖ “នែ**មេឃពណ៌**! ឯងធ្វើដូចម្តេច បានជាឯងនៅក្នុងកណ្តាលសត្រូវបានយូរម្ល៉េះ? ធ្វើដូចម្តេចបានជាស្និទ្ធស្នាលជិតដិតគ្នាម្ល៉េះហ្ន៎?” ។ ក្អែក**មេឃពណ៌**និយាយតបថា៖ “ទេវៈ! កិច្ចការជាប្រយោជន៍នាយចៅហ្វាយ និងកិច្ចការធ្វើឲ្យសម្រេចប្រយោជន៍ដល់ខ្លួនគេនឹងមិនត្រូវធ្វើអ្វីឬអ្វី?” ព្រោះថា៖

៦០- បពិត្រព្រះរាជា! មនុស្សលោកទូលឧសដែលឆេះនៅលើក្បាលមិនបានឬអ្វី? ខ្សែទឹកស្ទឹងហូរទៅស្រោចឈើ នឹងរំលើងឫសឈើមិនបានឬអ្វី? ។

៦១- អ្នកប្រាជ្ញ បើមានកិច្ចការណាមួយដែលត្រូវធ្វើខានមិនបាន សូម្បីសត្រូវក៏ត្រូវតែទូលលើ

ក្បាល ដូចកង្កែបត្រូវពស់ចាស់សម្លាប់បាន ។

ក្ងោក**ចិត្រពណ៌**សួរថា៖ "ចុះរឿងនោះតើដូចម្ដេច?" ។ ក្អែក**មេឃពណ៌**និយាយរឿងនោះប្រាប់ថា៖

# កថាទី ១១

## រឿងពស់ និងកង្កែប

នៅក្នុងឧទ្យានចាស់មួយ, មានពស់មួយឈ្មោះមន្ទវិស ។ ពស់នោះចាស់គ្រាំគ្រាណាស់វារលូនទៅរកចំណីបានដោយលំបាក ហើយលបលាក់ខ្លួនទៅនៅមាត់ត្រពាំងមួយ ។ កាលនោះ, មានកង្កែបមួយក្រឡេកទៅឃើញពីចម្ងាយ ក៏ស្រែកសួរទៅថា៖ "នែបងពស់! ម្ដេចក៏បងមកនៅទីនេះមិនដើរទៅស្វែងរកចំណីអាហារ?" ។ ពស់ចាស់នោះឆ្លើយប្រាប់វិញថា៖ "ហៃអ្នកដ៏ចម្រើន! ចូរអ្នកលោតទៅរកខ្លួនឯងចុះ, សួរខ្ញុំជាអ្នកមានបុណ្យតិចតួចស្តួចស្តើងនេះតើមានប្រយោជន៍អ្វី?" ។ កង្កែបស្ដាប់ហើយ ចង់ដឹងរឿងរ៉ាវដើមទង អត់ទ្រាំមិនបានក៏សួរដេញដោលទៅទៀតថា៖ "សូមរៀបរាប់រឿងរ៉ាវដើមទងឲ្យអស់មកមើល" ។ ពស់ចាស់ក៏រៀបរាប់ប្រាប់ថា៖ "នែអ្នកដ៏ចម្រើនអើយ! នៅព្រហ្មបុរីមានព្រាហ្មណ៍ម្នាក់ឈ្មោះកៅណ្ឌិន្យចេះចប់ត្រៃវេទ គាត់មានកូនប្រុសមួយឈ្មោះសុសីលអាយុ២០ឆ្នាំ មានគុណសម្បត្តិល្អគ្រប់យ៉ាង តែសំណាងអាក្រក់ ត្រូវខ្ញុំជាសត្វចិត្តកាចសាហាវចឹកសម្លាប់បង់ទៅ លុះគាត់ឃើញកូនគាត់ដេកស្លាប់ដូច្នេះ ក៏សំសោយសោកដេកបម្រះននៀលរហូតដល់បាត់ស្មារតីនៅលើផែនដី ។ កាលនោះឯង, ញាតិសន្តានព្រៀងលាន ដែលនៅក្នុងក្រុងព្រហ្មបុរីទាំងប៉ុន្មានក៏បបួលគ្នាមកឈូឆរអឹងកងចូលមកអង្គុយជុំជិតក្នុងទីនោះ, ព្រោះថា៖

៦២- ជនណាមិនលះបង់គ្នាចោលចូលមកអង្គុយជិតក្នុងកាលក្តីអន្តរាយ ក្នុងក្តីវិនាស ក្នុងកាលទុរភិក្ស ក្នុងកាលរាស្ត្របះបោរ ក្នុងទ្វារនៃព្រះរាជា និងក្នុងព្រៃស្មសាន ជននោះ ជាផៅពង្ស ។

កាលនោះឯង, មានព្រាហ្មណ៍អ្នកលាងបាបម្នាក់ឈ្មោះកបិលៈ ឃើញកៅណ្ឌិន្យយំសោយសោកបម្រះននៀលខ្លាំងពេក ក៏និយាយបន្ទោសថា៖ "នែកៅណ្ឌិន្យចង្រៃ! ឯងម៉េចក៏ល្ងង់ម្ល៉េះ អ្នកណាគេដែលយំសម្លាប់ខ្លួនដូច្នេះ ឯងស្ដាប់មើលហ៎ៈ៖

៦៣- អនិច្ចធម៌ ទុកដូចជាមាតា ឱបក្រសោបចិញ្ចឹមអ្នកបដិសន្ធិទុកក្នុងទ្រូង តាំងតែពីប្រថមម្ល៉េះឯមាតាជាអ្នកបង្កើតនេះ មានក្នុងកាលជាខាងក្រោយទេ បើដូច្នេះតើអ្នកឯងខំយំសោយសោកធ្វើអ្វី? ។

៦៤- ព្រះរាជាភូមិបាលទាំងឡាយ ប្រកបដោយរេហ៍ពលសេនាន្យានុភាពយានពាហនៈទាំងឡាយ

ច្រើនដល់ម្ល៉េះ ឥឡូវនេះ ស្ដេចទៅណាអស់ទៅហ្ន៎? ផែនប្រថពីស្ថិតស្ថេរគង់នៅរហូតមកដល់ថ្ងៃនេះជាសាក្សីនៃការព្រាត់ប្រាសព្រះរាជាទាំងឡាយនោះស្រាប់ ។

៦៥- គួរសង្វេគណាស់! រាងកាយនេះកើតឡើងហើយក៏ដល់នូវវិការបែកធ្លាយទៅវិញ ភោគសម្បត្តិកើតបរិបូណ៌ឡើងហើយ ក៏ដល់នូវក្ដីភោគវិបត្តិទៅវិញ, ការជួបជុំគ្នាកើតមានហើយក៏ដល់នូវការព្រាត់ប្រាសគ្នាទៅវិញ សារពើវត្ថុទាំងឡាយ មានការកើតឡើង និងការបាក់បែកពុកផុតរលួយទៅវិញយ៉ាងនេះជាធម្មតា ។

៦៦- កាយនេះរលត់រលាយទៅគ្រប់ខណៈ កាលកំពុងរលាយទៅ បុគ្គលកំណត់មើលមិនឃើញទេ ដូចឆ្នាំងជាវិការនៃដីដែលគេដុតមិនល្អ ស្ថិតនៅលើទឹករលាយបន្តិចម្ដងៗ ដល់បែកបាក់ហើយ ទើបគេមើលឃើញច្បាស់ ។

៦៧- ម្រឹត្យុតែងដើរចូលទៅជិតសត្វរាល់ថ្ងៃៗ ឯសត្វក៏ដើរចូលទៅរកសេចក្ដីស្លាប់គ្រប់ជំហានជើងដែរ ដូចជាសត្វដែលគេនាំចូលទៅរកទីសម្លាប់កាន់តែជិតសេចក្ដីស្លាប់រាល់ជំហានជើង ។

៦៨- អនិច្ចធម៌ យោវនវ័យ រូប ជីវិត ការសន្សំកពូនទ្រព្យឥស្សរិយយស ការនៅរួមមួយអន្លើដោយជនជាទីស្រឡាញ់ ទាំងអស់នេះបណ្ឌិតមិនវង្វេងភ័ន្តរហូតដល់កើតឧបាទានប្រកាន់ស្អិតយ៉ាងនេះទេ ។

៦៩- សំណាត់មួយ និងសំណាត់មួយទៀត រមែងរសាត់ទៅជួបគ្នាក្នុងមហាសមុទ្រ លុះបានភប់ប្រសព្វជួបគ្នាហើយ ក៏ឃ្លាតឃ្លាព្រាត់ប្រាសគ្នាទៅវិញយ៉ាងណា ការជួបជុំនៅរួមគ្នានៃជនដែលកើតមកក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។

៧០- មែនពិត, អ្នកដំណើរទាំងឡាយចូលទៅឈប់សម្រាកកម្លាំងក្រោមម្លប់ដើមឈើ ហើយស្ថិតនៅជួបជុំគ្នារហង់ លុះឈប់សម្រាកកម្លាំងរួចហើយ ធ្វើដំណើរតទៅទៀត មានឧបមាយ៉ាងណា ការជួបជុំនៅរួមគ្នានៃជនដែលកើតមកក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។

៧១- រាងកាយយើងនេះ ធម្មជាតិនិមិត្តដោយធាតុទាំង៥ យ៉ាង ហើយបែកធ្លាយត្រឡប់ទៅកាន់ធាតុទាំង ៥ យ៉ាងវិញ ធាតុទាំង៥ នេះតែងចូលទៅកាន់កំណើតដើមវិញជាធម្មតា, បើដូច្នេះ តើយើងមកយំសោយសោកក្នុងរឿងរាងកាយនេះធ្វើអ្វី?

៧២- ដរាបណា សត្វលោកណាធ្វើសម្ព័ន្ធជាមួយញាតិសន្តានជាទីស្រឡាញ់ទុកក្នុងចិត្ត ដរាបនោះ សត្វលោកនោះ ឈ្មោះថាកប់ទុកនូវបន្លាគឺសេចក្ដីសោកក្នុងចិត្តស្រេចទៅហើយ ។

៧៣- ([១]) ការនៅជួបជុំគ្នារហូតដល់ទីបំផុតនេះ មិនមានអ្នកណាមួយបានសោះ កុំថាឡើយដល់ញាតិសន្តានសូម្បីតែរូបរាងកាយខ្លួនឯងភាគណាមួយ ក៏ឥតមាននរណាមួយបានដែរ ចាំបាច់និយាយថ្វីដល់ញាតិសន្តានដែលនៅក្រៅពីកាយ ។

៧៤- មែនពិត, ការនៅជួបជុំគ្នា ឈ្មោះថាឲ្យកំណើតដល់ការព្រាត់ប្រាសគ្នាវិញ ឯកំណើតក៏ឈ្មោះថានាំមកនូវមច្ចុ ធម៌នេះមិនមានបុគ្គលណាមួយកន្លងបានឡើយ ។

៧៥- ការសាបសូន្យទៅនៃការជួបជុំជាទីរីករាយនេះ លឿនភ្លែតទៅមួយអន្លើដោយជនជាទីស្រឡាញ់ទាំងឡាយ ជាធម៌ទារុណក្រៃលែងណាស់ ដូចជាការបញ្ចុះអាហារស្ល៉ែងដ៏អាក្រក់ក្រៃលែងដូច្នោះដែរ ។

៧៦- ខ្សែទឹកក្នុងស្ទឹងទាំងឡាយតែងហូរទៅៗ ហើយកាន់យកសំណាត់ទៅជាមួយផង មិនដែលត្រឡប់ថយក្រោយវិញទេគ្រប់ៗកាល មានឧបមាយ៉ាងណា យប់នឹងថ្ងៃក៏ចាប់ឆក់យកនូវអាយុនៃសត្វទាំងឡាយ ហើយទៅមិនត្រឡប់ថយក្រោយវិញគ្រប់ៗកាល មានឧបមេយ្យយ៉ាងនោះដែរ ។

៧៧- ក្នុងសំសារវដ្តនេះ ការនៅជួបជុំមួយអន្លើដោយជនជាទីស្រឡាញ់ណា ដែលមានរសគឺសេចក្តីសុខនៅជាខាងដើម ការនៅជួបជុំមួយអន្លើដោយជនជាទីស្រឡាញ់នោះ ក៏ចងជាប់ជាមួយនឹងនឹមនៃសេចក្តីទុក្ខ ព្រោះការជួបជុំនោះមានការព្រាត់ប្រាសនៅក្នុងទីបំផុត ។

៧៨- ហេតុនេះឯងបានជាសប្បុរសទាំងឡាយ មិនប្រាថ្នានូវការជួបជុំមួយអន្លើ ដោយជនជាទីស្រឡាញ់ទាំងឡាយ ព្រោះមិនមានថ្នាំរក្សាចិត្តដែលមុតដោយដាវគឺសេចក្តីព្រាត់ប្រាសឲ្យជាសះស្បើយបានឡើយ ។

៧៩- អំពើជាកុសលទាំងឡាយ (ដូចអស្វមេធ:) ដែលព្រះបាទសគរ: ([២]) និងព្រះរាជាទាំងឡាយដទៃបានធ្វើហើយដោយប្រពៃ អំពើជាកុសលទាំងឡាយនោះឯង ក៏ដល់នូវការប្រល័យអស់រលីង ។

៨០- ([៣]) កាលបើគិតហើយគិតទៀត នូវអំណាចមច្ចុដែលមានអាជ្ញាដ៏អាក្រក់ក្រៃលែងនេះ សេចក្តីព្យាយាមប្រឹងប្រែងទាំងអស់នៃមនុស្សសូម្បីជាអ្នកប្រាជ្ញក៏ថមថយចាញ់ដៃ ប្រៀបដូចខ្សែពានជាវិការៈនៃស្បែកដែលទទឹកដោយទឹកភ្លៀង ។

---

[១] ហិតោបទេស សេចក្តីប្រែជាភាសាបារាំងនៃលោកឡង់សឺរ៉ូ មានគាថាលើដូច្នេះ គឺការស្វែងរកការជាប់លាប់នៅក្នុងជីវិតមនុស្ស និងការស្វែងរកការជាប់លាប់ដើមចេកក៏ឥតប្រយោជន៍ដូចគ្នា ដូចគេចង់ឲ្យក្រពេញទឹកស្ថិតស្ថេរយូរដូច្នោះដែរ ។

[២] ព្រះរាជាក្នុងសម័យបុរាណដែលសូមព្រះគង្គាឲ្យហូរចេញមកពីឋានសួគ៌ ។

៨១- នរជនសូម្បីជាវីរបុរសដែលចូលទៅចាប់បដិសន្ធិ ទៅកាន់គភ៌ក្នុងបឋមរាត្រីណា ចាប់តាំងពីបឋមរាត្រីនោះមក វីរបុរសនោះដើរត្រង់រឿយចូលទៅកាន់ម្រឹត្យុរាល់ៗថ្ងៃ ។

បើដូច្នោះ ចូរអ្នកពិចារណាមើលសំសារវដ្តនេះចុះ សេចក្តីសោកនេះជាគ្រឿងចម្រើននៃមោហៈទេតើ ចូរមើលហ៎ះ!

៨២- ថាបើសេចក្តីព្រាត់ប្រាសជាហេតុនៃសេចក្តីសោក មិនមែនមោហៈជាហេតុទេ ហេតុអ្វីថ្ងៃដែលកន្លងទៅៗ សេចក្តីសោកក៏មិនចេះតែចម្រើនច្រើនឡើងៗរាល់ថ្ងៃទៅហ៎ះ? ។

នែអ្នកដ៏ចម្រើនអើយ! ចូរធ្វើចិត្តឲ្យស្ងប់ លះលែងនិយាយពីសេចក្តីសោកនេះឲ្យស្រឡះទៅ, ព្រោះថា៖

៨៣- សេចក្តីសោកធ្ងន់ខ្លាំងណាស់ ទុកដូចជាសរដែលបាញ់មកមុតចំសាច់ឈឺជាងគេ ហើយជាធម្មជាតិត្រូវតែធ្លាក់ចុះមក មិនចាំបាច់សព្វសត្វគ្រប់គ្នាដឹងខ្លួនមុនទេ ការប្រហារបំបាត់សេចក្តីសោកនេះ មានតែការមិនគិតមួយទេ ដែលទុកជាមហាឱសថទិព្វជួយរក្សាបាន ។

កាលស្តាប់ពាក្យព្រាហ្មណ៍កបិលៈដូច្នេះហើយ ព្រាហ្មណ៍កៅណ្ឌិន្យក៏ដូចជាភ្ញាក់ខ្លួនព្រើត ក្រោកឡើងហើយនិយាយថា៖ “ឥឡូវនេះ, ការនៅក្នុងផ្ទះនរកល្មមប៉ុណ្ណឹងហើយ ខ្ញុំទៅនៅព្រៃប្រសើរជាង” ។ ព្រាហ្មណ៍កបិលៈនិយាយតទៅទៀតថា៖

៨៤- ការនៅក្នុងព្រៃ មានទោសកើតឡើងច្រើនប្រការដល់ជនដែលប្រកបដោយរាគៈ, នៅក្នុងផ្ទះ ការផ្ចាញ់ផ្ចាល់ឥន្ទ្រិយទាំង៥ ប្រការ ក៏ឈ្មោះថាព្រៃបំពេញតបៈបានដែរ ជនណាមិនប្រព្រឹត្តកម្មលាមក ផ្ទៃនៃជននោះដែលមានរាគៈរំលត់ហើយ ក៏ឈ្មោះថាជាតបោវ័នព្រៃបំពេញតបៈបាន ។

៨៥- បុគ្គលមានសេចក្តីទុក្ខ ចង់ប្រព្រឹត្តធម៌ ត្រេកអរពេញចិត្តនៅក្នុងអាស្រមណាមួយ ហើយធ្វើចិត្តឲ្យមានមេត្តាផ្សាយស្មើភាគទូទៅដល់សព្វសត្វទាំងឡាយ ក៏ឈ្មោះថាប្រព្រឹត្តធម៌បាន ព្រោះថាភេទខាងក្រៅមិនមែនជាហេតុនៃធម៌ទេ ។

៨៦- ជនណា មានភោជនគ្រាន់តែញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ មានមេថុនគ្រាន់តែបណ្តុះពូជ មានវាចាសម្រាប់តែពោលពាក្យសច្ចៈ ជននោះឈ្មោះថាកន្លងផុតនូវឧបសគ្គដ៏លំបាកបានហើយ ។

៨៧- ម្នាលបាណ្ឌុបុត្រ! អាត្មាយើងនេះទុកជាស្ទឹង ដ៏មានការសង្រួមជាកំពង់បុណ្យ (បុណ្យតិថិ)

---

[៣] ហិតោបទេសសេចក្តីប្រែជាភសាបារាំងនៃលោកឡង់ស៊ីរ៉ូ មានគាថាលើសដូច្នេះគឺ ការយំសោយសោកចំពោះព្រះរាម ព្រះវាយុ នៃព្រះវរមាតាបិតានិងប្រយូរវង់ដែលស្រឡាញ់ព្រះ នាំធ្វើឲ្យព្រះរាមខានបានឋានសួគ៌ ដោយការសម្រក់ទឹកព្រះនេត្រយំសោយសោកដល់ព្រះអង្គនេះឯង ។

មានពាក្យសច្ចៈជាទឹក មានសីលជាត្រើយ មានករុណាជារលក, អ្នកចូលអភិសេក គឺចូលមុជក្នុងស្ទឹងគឺអត្តភាពនេះចុះ អត្តរាត្មាគឺចិត្តខាងក្នុង មិនមែនបរិសុទ្ធបានដោយទឹកទន្លេទេ ។

៨៨- សំសារវដ្តនេះ ឥតខ្លឹមសារទេ កើតឡើងពេញដោយឧបទ្រពចង្រៃ គឺទុក្ខវេទនាដែលកើតពីកំណើត ម្រឹត្យុ ជរា និងព្យាធិ ជនណាមួយលះបង់សំសារវដ្តបាន ទើបបានសេចក្តីសុខ ។

៨៩- ក្នុងលោកនេះ, មានតែសេចក្តីទុក្ខមួយចំណែកពិត មិនមានសេចក្តីសុខទេ ដំណើរនេះបុគ្គលកំណត់ឃើញជាក់ច្បាស់ណាស់ព្រោះថា កាលបានជួយការពារបុគ្គលដែលមានសេចក្តីទុក្ខឱ្យរួចស្រឡះហើយ ទើបគេសម្គាល់ថាមានសេចក្តីសុខបាន ។

កៅណ្ឌិន្យនិយាយសរសើរកបិលៈថា៖ “អ្នកនិយាយនេះពិតជាត្រឹមត្រូវណាស់” ។ តាំងពីកាលនោះមក, ខ្លួនខ្ញុំ (ពស់) ត្រូវកៅណ្ឌិន្យដែលសោយសោកនេះដាក់បណ្តាសាថា តាំងពីថ្ងៃនេះតទៅ, ឯងត្រូវទៅជាពាហនៈកង្កែបកុំខានឡើយ” ។ លំដាប់តមក, ព្រាហ្មណ៍កបិលៈនិយាយលួងលោមបន្ថែមទៀតថា៖ “ឥឡូវនេះ អ្នកមិនចង់ស្តាប់ឧបទេសខ្ញុំទេ ព្រោះចិត្តអ្នកកំពុងពេញដោយពិសគឺសេចក្តីសោក ដូច្នេះត្រូវអ្នកចាំស្តាប់អំពើដែលត្រូវធ្វើតទៅទៀត៖

៩០- គួរលះបង់កិច្ចដែលជាប់ជំពាក់នេះចេញឱ្យស្រឡះពីខ្លួន ថាបើមិនអាចលះបង់បានទេ គួរសមាគមមួយអន្លើដោយសប្បុរសទាំងឡាយជាភេសជ្ជៈកែរោគគឺសេចក្តីទុក្ខបាន ។

៩១- គួរលះបង់កាមឱ្យស្រឡះ ថាបើអត់ទ្រាំទប់ទល់កាមមិនបានទេ គួរសេពគប់ចំពោះតែភរិយាខ្លួនមួយប៉ុណ្ណោះហើយ ព្រោះថា ភរិយាជាភេសជ្ជៈកែរោគគឺកាមរាគបាន” ។

កៅណ្ឌិន្យ លុះបានស្តាប់ហើយ ភ្លើងគឺសេចក្តីសោកក៏រលត់ដោយទឹកអម្រឹតគឺពាក្យឧបទេសនៃកបិលព្រាហ្មណ៍នោះ កាន់យកឈើច្រត់ហើយដើរចេញទៅបួសតាមលទ្ធិពិធីទៅ ។ តាំងពីកាលនោះមក, រូបខ្ញុំ (ពស់) តាំងទីឋាននៅទីនេះ ដើម្បីទទួលផលបណ្តាសានៃកៅណ្ឌិន្យព្រាហ្មណ៍ធ្វើជាពាហៈនៃកង្កែបទាំងឡាយ ។ លំដាប់នោះ, កង្កែបនោះបានដឹងប្រព្រឹត្តការណ៍នេះហើយ ចូលទៅប្រាប់កង្កែបឈ្មោះជលបាទជាមេលើកង្កែបទាំងឡាយ ។ កាលនោះ, មេកង្កែបនោះមកដល់ហើយលោតទៅជិះលើខ្នងពស់ដោយក្តីរីករាយ ។ ឯពស់ក៏បញ្ជិះមេកង្កែប ហើយលូនលោតលេងកញ្ឆក់កញ្ឆេងដោយក្តីរីករាយសប្បាយតាមអំពើចិត្ត ។ ចំណេរតមក, ដោយហេតុតែខ្លួនចាស់ជរា ហើយអស់កម្លាំង ពស់មិនអាចវារលូនលេងសប្បាយដូចសព្វមួយដង ទើបកង្កែបសួរថា៖ “នែអ្នកដ៏ចម្រើនអើយ! ហេតុអ្វីថ្ងៃនេះក៏អ្នកលូនយឺតៗម្ល៉េះ?” ។ ពស់ឆ្លើយប្រាប់ថា៖ “ទេវៈ! ខ្ញុំបាទអស់កម្លាំងណាស់ ព្រោះអត់អាហារមកយូរថ្ងៃហើយ បានជាលូនលឿនកញ្ឆក់កញ្ឆេងឱ្យសប្បាយមិនបាន” ។ មេកង្កែបនិយាយថា៖ “បើដូច្នោះ, ឯងចូរស៊ីកង្កែប

ចុះតាមអាជ្ញាយើង" ។ កាលនោះ, ពស់រីករាយសប្បាយណាស់និយាយថា៖ "ខ្ញុំបាទសូមសម្តែងសេចក្តីរីករាយដ៏ក្រៃលែងចំពោះលោកម្ចាស់" និយាយហើយក៏លោតទៅចាប់កង្កែបមកស៊ីជាចំណីអាហាររឿយៗទៅ ស៊ីទាល់តែអស់កង្កែបជាបរិវារហើយ ក៏ចាប់មេកង្កែបស៊ីក្អែមចុងបំផុតថែមទៀត, ព្រោះហេតុនោះបានជាខ្ញុំ (ក្អែក**មេឃពណ៌**)ពោលថា៖ "អ្នកប្រាជ្ញ" ដូច្នេះជាដើម (លេខ ៦១) ។ ក្អែក**មេឃពណ៌**និយាយតទៅទៀតថា៖ "ទេវៈ! ពេលនេះ, គួរលើកលែងនិយាយរឿងបុរាណចោលចេញទៅ រាជហង្ស**ហិរណ្យគក៏**នេះគួរយើងធ្វើសន្តិភាពស្ងប់សឹកហើយ ដោយប្រការទាំងពួង នេះជាមតិនៃខ្ញុំបាទ" ។ ក្ងោក**ចិត្រពណ៌**ឆ្លើយតបវិញដោយយល់ទាស់ថា៖ "ការពិចារណាយល់ឃើញរបស់អ្នក ម្តេចក៏យ៉ាងនេះហ្ន៎? បើយើងមានជ័យប្រាកដដូច្នេះហើយ ត្រូវបង្គាប់ឲ្យវាចូលមកជាឈ្លើយសឹករបស់យើងទើបសម បើមិនដូច្នោះទេយើងគួរលើកទ័ពទៅវាយកម្ទេចវាម្តងទៀត" ។ ក្នុងខណៈដែលកំពុងតែនិយាយ សេកមកដល់ពីជម្ពូទ្វីបហើយចូលទៅនិយាយប្រាប់ក្ងោក**ចិត្រពណ៌**ថា៖ "ទេវៈ! ឥឡូវនេះ កុកឈ្មោះ**មហាពល**នៃសីហលទ្វីបលើកទ័ពចូលទៅលុកវាយយកជម្ពូទ្វីបសោយរាជ្យហើយ" ។ សេកនិយាយប្រាប់ប្រព្រឹត្តិការណ៍តាំងពីដើមដល់ចុងប្រាប់គ្រប់ប្រការ ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីគិតក្នុងពោះខ្លួនឯងថា៖ "សាធុ! **ចាក្រពាកសវ័ជ្ជៈ**ប្រធានរដ្ឋមន្ត្រី សាធុ! សាធុ!" ។ ក្ងោក**ចិត្រពណ៌**ក្រេវក្រោធច្រឡោតខឹងនិយាយថា៖ "ណ្ហើយ! បណ្តោយឲ្យវានៅក្នុងទីនោះចុះ អញនឹងទៅគាស់រំលើងទាំងឫសទាំងគល់វាឲ្យអស់រលីងឥឡូវនេះ" ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីឮពាក្យនេះហើយ សើចឃឹក និយាយថា៖

៩២- បុគ្គលមិនត្រូវធ្វើការអ្វីក្នុងក្តាំង ដូចផ្គរគំរាមគ្រេងគ្រាំ ដូចមេឃក្នុងសរទកាលទេ អ្នកមានបុណ្យធំមិនត្រូវប្រកាសជ័យ ឬបរាជ័យនៃសត្រូវទេ,

៩៣- ព្រះរាជាជាធំ មិនត្រូវធ្វើសង្គ្រាមក្នុងកាលតែមួយចំពោះសត្រូវច្រើននាក់ទេ ដូចពស់សូម្បីមានពិសក្តៀវក្លា ត្រូវហ្វូងកណ្តូបបំផ្លាញសម្លាប់បានដោយពិត,

ទេវៈ! លោកម្ចាស់នឹងលើកទ័ពយាត្រាត្រឡប់ទៅវិញដោយមិនបានធ្វើសន្តិភាពឬអ្វី? ថាបើធ្វើដូច្នេះ មុខជារាជហង្ស**ហិរណ្យគក៏**នឹងលើកមកវាយរំខានយើងពីខាងក្រោយខ្នងមិនខានឡើយ, ព្រោះថា៖

៩៤- ជនពាលល្ងង់ មិនដឹងច្បាស់នូវសេចក្តីពិតនៃប្រយោជន៍ យកតែតាមអំណាចនៃសេចក្តីក្រោធ ជននោះនឹងត្រូវក្តៅក្រហាយស្តាយក្រោយដូចព្រាហ្មណ៍សម្លាប់ស្ការ ។

ក្ងោក**ចិត្រពណ៌**សួរថា៖ "រឿងនោះតើដូចម្តេច?" ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីនិយាយរៀបរាប់ប្រាប់ថា៖

# កថាទី ១២

## រឿងព្រាហ្មណ៍ និងស្ការ

នៅក្នុងក្រុងឧជ្ជយិនី, មានព្រាហ្មណ៍ម្នាក់ឈ្មោះមាឃវៈ ។ ភរិយាព្រាហ្មណ៍នោះប្រសូតកូនខ្ចីមួយ ហើយប្រគល់ទៅឲ្យព្រាហ្មណ៍រក្សា ខ្លួនឯងទៅមុជទឹកជម្រះកាយ ។ ក្នុងខណៈនោះឯង, ព្រះរាជាត្រាស់ប្រើរាជបុរសម្នាក់ឲ្យទៅហៅព្រាហ្មណ៍នោះទៅធ្វើពិធីបាវ៌ណស្រព្វ ([១]) ។ ព្រាហ្មណ៍បានដឹងហើយគិតឃើញថាខ្លួនក្រីក្រលំបាកតោកយ៉ាកណាស់ ថាបើអាត្មាអញមិនប្រញាប់ប្រញាល់ទៅ សមព្រាហ្មណ៍ដទៃគេដឹង គេនឹងយកបាវ៌ណស្រព្វនោះអស់, ព្រោះថា៖

៩៥- អំពើដែលគេត្រូវទទួល និងគេត្រូវឲ្យ បុគ្គលគប្បីធ្វើឲ្យឆាប់ៗ ព្រោះថា បើបុគ្គលមិនប្រញាប់ប្រញាល់ធ្វើឲ្យរហ័សទេ កាលវេលានឹងជញ្ជក់ស៊ីរសជាតិនៃអំពើនោះអស់ ។

ឯអាត្មាអញមិនមានអ្នករក្សាកូនខ្ចីនេះផង គិតធ្វើដូចម្ដេចអេះ?, ណ្ហើយចុះ, អាត្មាអញនឹងឲ្យកូនស្ការនេះរក្សាកូនបណ្ដើរសិន ព្រោះអាត្មាបានចិញ្ចឹមវាមកអស់កាលយូរណាស់ហើយៗស្រឡាញ់វាទុកដូចជាកូនបង្កើតដែរ បើដូច្នោះគួរប្រគល់កូននោះឲ្យវារក្សាហើយសឹមចេញទៅ ។ ព្រាហ្មណ៍ធ្វើតាមគិតដូច្នេះហើយ ដើរចេញទៅ ។ កាលដែលព្រាហ្មណ៍ចេញផុតទៅនោះ មានពស់វែកមួយវារចូលមកជិតកូននោះ ស្ការឃើញពស់ជាសត្វសត្រូវពីកំណើតមកដល់, ដំឡើងប្រែងប្រាងដោយក្ដៅក្រហាយខ្លាំងក៏ស្ទុះទៅខាំពស់នោះដាច់ជាពីរបីកំណាត់ភ្លាម ។ លំដាប់តមក, ស្ការក្រឡេកមើលទៅឃើញព្រាហ្មណ៍កំពុងដើរចូលមក ត្រេកអរណាស់ ទាំងមុខមាត់ដៃជើងប្រឡាក់ឈាមក្រហមច្រាលនៅឡើយ ក៏រត់យ៉ាងរហ័សទៅនៀលនៅក្បែរជើងព្រាហ្មណ៍នោះឯង ដើម្បីសម្ដែងអាការត្រេកអរដែលបានបម្រើម្ចាស់ដោយប្រពៃ ។ ឯព្រាហ្មណ៍ឃើញឈាមនៅមុខមាត់ជើងស្ការក្រហមដូច្នោះ ក៏កំណត់ក្នុងចិត្តឥតពិចារណាថា៖ "ស្ការនេះស៊ីកូនអាត្មាអញហើយ" ក៏លើកដំបងសំពងស្ការនោះម៉ក់ស្លាប់បង់ទៅហោង ។ តមក, ដរាបណាព្រាហ្មណ៍ចូលទៅមើលកូន ដរាបនោះ ព្រាហ្មណ៍ឃើញកូនសុខសប្បាយ ឃើញពស់ដាច់ជាពីរបីកំណាត់នៅរាត់រាយក្បែរកូននោះ ទើបដឹងឧបការគុណស្ការជាបំផុត ក៏កើតក្ដៅក្រហាយស្ដាយក្រោយដ៏ក្រៃលែង, ព្រោះហេតុនោះបានជាខ្ញុំ (ត្បាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រី) ពោលថា៖ "ជនល្ងង់" ដូច្នេះជាដើម (លេខ ៩៤) ព្រោះថា៖

---

[១] ទេយ្យទានដែលគេត្រូវបូជាក្នុងពិធីបុណ្យធំ សម្រាប់បូជាព្រាហ្មណ៍ ។

៩៦- កាម ១, ក្រោធ ១, លោភ ១, ឫស្យា ១, មានះ ១, ស្រវឹង ១, ធម៌៦ ប្រការនេះ បើលះបង់បានទើបបានសេចក្តីសុខ ។

ក្អែក**ចិត្រពណ៌**សួរថា៖ “នែលោកប្រធានរដ្ឋមន្ត្រី! នេះជាការសម្រេចដាច់ខាតនៃលោកហើយឬអ្វី?” ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីឆ្លើយថា៖ “យ៉ាងនេះពិតហើយ, ព្រោះថា៖

៩៧- សតិគឺការចាំបាន ១, ការប៉ិនត្រិះរិះសមហេតុផលក្នុងប្រយោជន៍ដ៏សំខាន់ ១, ការដឹងប្រាកដ ១, ការម៉ឺងម៉ាត់ ១, ការចេះរក្សាការប្រឹក្សាសម្ងាត់ ១, ទាំង៥ ប្រការនេះជាគុណសម្បត្តិនៃមន្ត្រី ។

៩៨- បុគ្គលឥតការសិក្សា មិនត្រូវធ្វើការប្រញាប់ប្រញាល់ទេ ព្រោះការខ្វះខាតការពិចារណាត្រឹមត្រូវជាប្រភពនៃសេចក្តីវិនាស, សេចក្តីពិត, ការពិចារណាត្រឹមត្រូវហើយសឹមធ្វើ គឺបុគ្គលត្រូវការចង់បាន ព្រោះសម្បត្តិគឺសេចក្តីចម្រើន បុគ្គលដែលមានគុណសម្បត្តិល្អត្រូវបានដោយខ្លួនឯង ។

ទេវៈ! បើលោកម្ចាស់ប្រាថ្នាធ្វើតាមពាក្យខ្ញុំបាទឥឡូវនេះ សូមធ្វើសន្តិភាពទៅ ព្រោះថា៖

៩៩- សូម្បី ហិតោបទេសគឺឧបាយក្នុងការញ៉ាំងផលឱ្យសម្រេចតាមសេចក្តីប្រាថ្នានេះមានដល់ទៅ ៤ ប្រការក៏ពិតមែន តែក៏គ្រាន់តែជាផលសំខ្យា គឺការរាប់ចំនួនឱ្យបានចំនួនដល់ទៅ ៤ ប៉ុណ្ណោះទេ, បណ្តាឧបាយទាំង ៤ប្រការនេះ សេចក្តីសម្រេចពិតៗ ស្ថិតនៅតែក្នុងការផ្សះផ្សាតែមួយប៉ុណ្ណោះទេ” ។

ក្អែក**ចិត្រពណ៌**សួរតទៅថា៖ “ធ្វើដូចម្តេច ទើបបានសម្រេចយ៉ាងនេះ?” ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីឆ្លើយប្រាប់ថា៖ “ទេវៈ! ការនេះមិនមែនជាមិនបានសម្រេចឆាប់នោះទេ” ព្រោះថា៖

១០០- ([១]) មនុស្សល្ងង់គេធ្វើឱ្យពេញចិត្តបានដោយងាយ មនុស្សអ្នកចេះដឹងវិសេស គេធ្វើឱ្យពេញចិត្តរឹតតែងាយទៅទៀត តែបុគ្គលមានការចេះដឹងបន្តិចបន្តួច កុំថាឡើយត្រឹមមនុស្ស សូម្បីព្រះព្រហ្មក៏ធ្វើឱ្យពេញចិត្តមិនបានដែរ ។

សេចក្តីវិសេសតទៅទៀត, រាជហង្ស**ហិរណ្យគភ៌**នេះជាស្តេចចេះដឹងរាជករណីយកិច្ចពិត, ឯ**ចាក្រពាកសវ័ជ្ញះ**នេះជាប្រធានរដ្ឋមន្ត្រីចេះដឹងកិច្ចការទូទៅ, រឿងនេះ ខ្ញុំបាទបានដឹងតាំងពីកាលខាងដើមម្ល៉េះ តាមពាក្យ**មេឃពណ៌** និងកិច្ចការដែលធ្វើរឿយៗមកហើយ, ព្រោះថា៖

១០១- គុណសម្បត្តិ និងសេចក្តីប្រព្រឹត្តនៃជនដែលគេមើលមិនឃើញ បុគ្គលគប្បីទាយទៅតាម

---

[១] ហិតោបទេសសេចក្តីប្រែជាភាសាបារាំងនៃលោកឡង់សឺរ៉ូមានគាថាលើដូច្នេះគឺៈ មនុស្សទុរជនចិត្តអាក្រក់សាមាន្យ ប្រៀបដូចឆ្នាំងដីបែកបាក់ប្រេះឆាក៏ឆាប់រហ័សណាស់ ដល់តវិញមិជាប់ទេ, ឯលោកសាធុជនចិត្តសប្បុរសប្រៀបដូចឆ្នាំងមាសមិនងាយបាក់បែកប្រេះឆាទេ ដល់ផ្សារជាប់វិញក៏ងាយជាប់ ។

អំពើនៃជននោះដែលបានធ្វើសព្វកាលទាំងពួង, មែនពិតហើយ សេចក្តីប្រព្រឹត្តនៃជនដែលគេមើលឃើញនោះ គេអាចស្ទង់មើលឃើញនូវផលនៃអំពើរបស់ជននោះបាន" ។

ក្អែក**ចិត្រពណ៌**ពោលសម្រេចថា៖ "និយាយជជែកគ្នាយូរទៅទៀតឥតប្រយោជន៍ទេ ចូរចាត់ការតាមដែលលោកប្រធានរដ្ឋមន្ត្រីគិតទុកស្រេចមកហើយនោះទៅចុះ" ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីប្រឹក្សាជាមួយនិងក្អែក**ចិត្រពណ៌**រួចហើយសម្រេចថា៖ "យើងគប្បីធ្វើការនេះតាមគួរដល់ការឲ្យសម្រេចក្នុងទីនេះតែម្តង" ។ គិតហើយក៏ធ្វើដំណើរទៅកាន់បន្ទាយនៃរាជហង្ស**ហិរណ្យគក៌**នោះ ។ ក្នុងខណៈនោះកុក**ទីឃ៍មុខ**ជាចារបុរសត្រឡប់ចូលទៅប្រាប់រាជហង្ស**ហិរណ្យគក៌**ថា៖ "ទេវៈ! ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីនឹងមកកាន់សំណាក់យើង ដើម្បីនិយាយប្រឹក្សាធ្វើសញ្ញាសន្តិភាពស្ងប់សឹកហើយ ។ រាជហង្ស**ហិរណ្យគក៌**ងាកបែរទៅមើល**ចាក្រពាក**ជាប្រធានរដ្ឋមន្ត្រីហើយនិយាយថា៖ "នែលោកមន្ត្រី! មានចារបុរសមកទៀតហើយហ៎ះ?" ។ **ចាក្រពាកសវ៍ជ្ញៈ**សើចភ្លាង ហើយឆ្លើយតបទៅវិញថា៖ "ទេវៈ! រឿងនេះមិនមែនជាហេតុនាំឲ្យបារម្ភខ្លាចទេ ព្រោះត្មាត**ទុរទសី**នេះជាបុគ្គលមានមហាអធ្យាស្រ័យប្រសើរណាស់, មួយទៀតការបារម្ភខ្លាចនេះជាស្ថិតិនៃមតិថោកទាបរបស់ជនល្ងង់ខ្លៅទេ រឿងនេះ ជួនកាលគេមិនទាំងត្រូវខ្លាចផងជួនកាលគេក៏ត្រូវខ្លាចគ្រប់កាលទាំងពួង, ព្រោះថា៖

១០២- ហង្សមិនឆ្លៀវឆ្លាត កាលស្វែងរកកមុទជាអាហារក្នុងវេលារាត្រីនៅក្នុងស្រះបោក្ខរណីដែលមានឆាយានៃកងតារាចោលស្រមោលមកច្រើន ក៏ពិលភ្នែកច្រឡំសម្គាល់ពន្លកកមុទថាជាដួងតារាក្នុងមួយខណៈៗដែរ សូម្បីក្នុងវេលាទិវាកាល ដែលមើលឃើញច្បាស់ហើយក៏ញញើតញញើមមិនហ៊ានចឹកពន្លកកមុទ ខ្លាចក្រែងថាជាដួងតារាទៅវិញយ៉ាងណា ឯមនុស្សលោកនេះ ដែលត្រូវមនុស្សកុហកឆកោងមកបៀតបៀនច្រើនដងហើយ មើលទៅសេចក្តីពិតប្រាកដមែន ក៏ភ័ន្តពិលភ្នែក ថាជាក្តីអន្តរាយទៅវិញយ៉ាងនោះ ។

១០៣- បុគ្គលដែលមានចិត្តធ្លាប់ទុរជនប្រទូសមកហើយ មិនហ៊ានធ្វើសេចក្តីស្និទ្ធស្នាលទុកចិត្តសូម្បីចំពោះសាធុជន ដូចកូនក្មេងដែលធ្លាប់រលាកដៃដោយបាយាសក្តៅ សូម្បីបាយាសត្រជាក់ក៏ញញើតមិនហ៊ានលូកដៃចាប់យកមកស៊ីដែរ ។

ទេវៈ! តាមដំណើរនេះ គួរលោកម្ចាស់ចាត់ចែងរកគ្រឿងបណ្ណាការដ៏មានតម្លៃមានរតនវត្ថុជាដើម តាមដែលនឹងអាចរកបានឲ្យមានព្រម ដើម្បីបូជាជាកិត្តិយសដល់ប្រធានរដ្ឋមន្ត្រី**ទុរទសី** ។ កាលកំពុងចាត់ចែងគ្រឿងបណ្ណាការនេះ ត្មាត**ទុរទសី**ប្រធានរដ្ឋមន្ត្រីមកដល់ **ចាក្រពាកសវ៍ជ្ញៈ**ទៅទទួលនៅមាត់បន្ទាយដោយការគួរសមដ៏ក្រៃលែង ហើយនាំចូលទៅកាន់សំណាក់រាជហង្ស**ហិរណ្យគក៌** ឲ្យអង្គុយ

ក្នុងទីដ៏សមគួរមួយកន្លែងដែលបានរៀបចំទុកមុនស្រេច ។ កាលនោះ, **ចាក្រពាក**ធ្វើដូចជាមិនដឹងខ្លួននិយាយថា៖ “លោកប្រធានរដ្ឋមន្ត្រី! វត្ថុទាំងពួងបណ្ដាដែលមានក្នុងទីនេះ ជាអាយ័តនៃលោកហើយលោកចូរគ្រប់គ្រងរាជ្យនេះតាមសេចក្ដីប្រាថ្នាលោកចុះ” ។ រាជហង្ស**ហិរណ្យគភ៌**ក៏និយាយស្របតាមថា៖ “អើកិច្ចការនេះដូចលោកប្រធានរដ្ឋមន្ត្រីមានប្រសាសន៍យ៉ាងនេះហើយ” ។ ត្មាត**ទូរទសី**ឆ្លើយតបភ្លាមថា៖ “ត្រូវយ៉ាងនេះហើយ, តែឥឡូវនេះ ការនិយាយពន្យារឲ្យយឺតយូរវែងពេកឥតប្រយោជន៍ទេ, ព្រោះថា៖

១០៤- ជនគប្បីយកចិត្តមនុស្សល្មោភដោយឲ្យទ្រព្យ មនុស្សស្កុកស្កម្កដោយអញ្ជលិកម្ម មនុស្សល្ងង់ដោយបណ្ដោយតាមចិត្ត បណ្ឌិតដោយការនិយាយពាក្យសច្ចៈ ។

១០៥- ជនគប្បីប្រតិបត្តិចំពោះមិត្តដោយសប្បុរសធម៌ ចំពោះផៅពង្សដោយការអើពើចរចាកអារាក ចំពោះស្ត្រីនិងជនបម្រើដោយឲ្យរង្វាន់ និងកិត្តិយស ចំពោះជនក្រៅពីនេះដោយការគោរព ។

រឿងនេះ, គួរយើងធ្វើសន្តិភាពស្ងប់សឹកឥឡូវនេះ ព្រោះស្ដេចក្ងោក**ចិត្រពណ៌**មានតេជានុភាពធំមហិមាណាស់” ។ **ចាក្រពាក**សួរថា៖ “ធ្វើសន្តិភាពស្ងប់សឹកនោះតើធ្វើដូចម្ដេច សូមប្រាប់មកខ្ញុំបាទមើល?” ។ រាជហង្ស**ហិរណ្យគភ៌**សួរបន្ថែមទៀតថា៖ “សន្ធិសញ្ញាការស្ងប់សឹកនោះតើមានប៉ុន្មានប្រការ?” ។ ត្មាត**ទូរទសី**ឆ្លើយប្រាប់ថា៖ “ខ្ញុំបាទនឹងនិយាយប្រាប់ សូមលោកម្ចាស់ចាំស្ដាប់៖

១០៦- ព្រះនរបតី ដែលត្រូវសត្រូវមានកម្លាំងជាងចូលមកប្រយុទ្ធខ្លាំងធ្លាក់ទៅក្នុងឋានៈដ៏លំបាក ហើយមិនអាចនឹងប្រយុទ្ធសងសឹកទៀតវិញបាននោះ គួរគប្បីធ្វើសន្តិភាពស្ងប់សឹកដើម្បីជាការពន្យារពេល ។

១០៧- សន្តិភាពស្ងប់សឹក មានឈ្មោះ ១៦ ប្រការគឺ៖ កបាលៈ ១, ឧបហារៈ ១, សន្តានៈ ១, សំគតៈ ១, ឧបន្យាសៈ ១, ប្រតីការ ១, សំយោគ ១, បុរុសាន្តរៈ ១ ។

១០៨- អទ្ធស្តនៈ ១, អាទិស្តៈ ១, អាត្មាទិស្ត ១, ឧបគ្រហៈ ១, បរិក្រយៈ ១, ឧច្ឆិន្នៈ ១, បរភូសណៈ ១ ។

១០៩- ស្កន្ធោបនេយៈ ១, សន្តិភាពទាំង ១៦ ប្រការនេះបណ្ឌិតជាអ្នកជំនាញក្នុងការធ្វើសន្ធិសញ្ញាស្ងប់សឹកបានពោលហើយ ។

១១០- ១ ដែលហៅថា **កបាលសន្ធិសញ្ញា** បុគ្គលគប្បីដឹងថាស្ងប់សឹកមានលក្ខន្តិកៈស្មើគ្នាទាំងសងខាង, ២ សន្ធិសញ្ញាណាដែលកើតឡើងដោយការឲ្យ សន្ធិសញ្ញានោះឈ្មោះថា **ឧបហារៈ** ។

១១១- ៣ ដែលហៅថា **សន្តានសញ្ញា** បុគ្គលគប្បីដឹងថាជាសញ្ញាមានការឲ្យធីតាជាភរិយាទុកជាខាងដើម, ៤ ការចងស្ពានមេត្រីមួយអន្លើដោយសប្បុរសទុកជាខាងដើម លោកឲ្យឈ្មោះថា **សំគត**សន្ធិសញ្ញា ។

១១២- **សំគត**សន្ធិសញ្ញានេះ មានចិរវេលាដរាបអស់អាយុ មានអត្ថប្រយោជន៍ស្មើៗគ្នា ក្នុងគ្រាចម្រើនក្តី ក្នុងគ្រាវិបត្តិក្តី ឬក្នុងហេតុការណ៍ណាមួយក្តី មិនដាច់ស្ពានមេត្រីនឹងគ្នាទេ ។

១១៣- **សំគត**សន្ធិសញ្ញានេះ មានគុណលក្ខណៈដូចសុវណ្ណ ព្រោះជាវិធីខ្ពង់ខ្ពស់បំផុត ចួនកាលលោកដែលឆ្លៀវឆ្លាតក្នុងសន្ធិសញ្ញាឲ្យឈ្មោះថា **កាញ្ចន**សន្ធិសញ្ញា ។

១១៤- ៥ សន្ធិសញ្ញាណា ដែលបុគ្គលឧទ្ទិសខ្លួន ឬព្រមឲ្យខ្លួនគិតតែបានសម្រេចសន្ធិសញ្ញានោះលោកអ្នកឆ្លៀវឆ្លាតក្នុងសន្ធិសញ្ញាឲ្យឈ្មោះថា **ឧបន្យាសៈ** ។

១១៥- ៦ សន្ធិសញ្ញាណាដែលធ្វើដូច្នេះគឺ៖ កាលដើមយើងបានធ្វើឧបការគុណឲ្យគេ គេត្រូវធ្វើឧបការគុណតបវិញ សន្ធិសញ្ញានោះលោកឲ្យឈ្មោះថា **ប្រតីការៈ** គឺការតបស្នង ។

១១៦- ពុំនោះ "យើងជួយគេ គេក៏ត្រូវជួយយើងវិញ" ដូច្នេះក៏ឈ្មោះថា**ប្រតីការៈ**ដែរ ដូចជាកាលព្រះរាមនិងសុគ្រីពធ្វើសន្ធិសញ្ញានឹងគ្នាដូច្នោះ ។

១១៧- ៧ សន្ធិសញ្ញា ដែលអ្នកទាំងសងខាងមានបំណងដោយប្រពៃ ដើម្បីប្រយោជន៍តែមួយដូចគ្នា ហើយធ្វើសន្ធិសញ្ញានោះ លោកឲ្យឈ្មោះថា **សំយោគ**សន្ធិសញ្ញា (ការរួបរួម) ព្រោះយកការរួបរួមគ្នាជាប្រមាណ ។

១១៨- ៨ ត្រូវទុកឲ្យសេនាជាប្រមុខនៃយោធាទាំងឡាយទាំងសងខាងធ្វើការស្ងប់សឹក សម្រេចដើម្បីប្រយោជន៍ដល់យើងទាំងឡាយ សេចក្តីព្រមព្រៀងយ៉ាងនេះ ហើយធ្វើក្នុងសន្ធិសញ្ញាណា លោកហៅសន្ធិសញ្ញានោះថា **បុរុសាន្តរៈ** ។

១១៩- ៩ "មានតែអ្នកមួយទេ ដែលអាចធ្វើសេចក្តីប្រាថ្នារបស់ខ្ញុំឲ្យសម្រេចបាន" សត្រូវចូលមកសូមធ្វើការស្ងប់សឹកដូច្នេះក្នុងសន្ធិសញ្ញាណា សន្ធិសញ្ញានោះលោកហៅថា **អទ្ទិស្តបុរុស** ។

១២០- ១០ សត្រូវព្រមស្ងប់ធ្វើសឹកដោយការបែងចែកដីមួយចំណែកឲ្យ សន្ធិសញ្ញាបែបនេះលោកជាអ្នកឆ្លៀវឆ្លាតក្នុងសន្ធិសញ្ញាឲ្យឈ្មោះថា **អាទិស្ត** (ការបែងចែកឲ្យ) ។

១២១- ១១ សន្ធិសញ្ញាណា ដែលសម្រេចដោយសេនានុភាពរបស់ខ្លួន លោកហៅថា **អាត្មាទិស្ត** (ការឲ្យខ្លួនឯង), ១២ សន្ធិសញ្ញាណាដែលធ្វើដើម្បីរក្សាជីវិតខ្លួន ហើយព្រមប្រគល់សព្វវត្ថុឲ្យដល់សត្រូវលោកហៅថា **ឧបគ្រហៈ** (ការសូមលា) ។

១២២- ១៣ សន្ធិសញ្ញាណា ដែលព្រមបែងចែកសម្បត្តិក្នុងឃ្លាំងមួយចំណែក ឬពាក់កណ្ដាល ពុំនោះឲ្យទាំងអស់ដល់សត្រូវ ដើម្បីរក្សាទ្រព្យដែលនៅសល់ខ្លះ សន្ធិសញ្ញានោះលោកឲ្យឈ្មោះថា **បរិក្រយៈ** ។

១២៣- ១៤ សន្ធិសញ្ញាណា ដែលព្រមលើកភូមិប្រទេស ដែលឧត្តមទីបំផុតឲ្យសត្រូវ លោកឲ្យឈ្មោះថា **ឧច្ឆិន្នៈ** (ការគាស់រំលើង), ១៥ សន្ធិសញ្ញាដែលព្រមលះបង់ផលព្រះធរណីដែលកើតក្នុងប្រទេសខ្លួនឲ្យសត្រូវ លោកហៅថា **ប្រភូសណៈ** (ប្រដាប់ជនដទៃ) ។

១២៤- ១៦ អ្នកប្រាជ្ញផ្សៀវផ្សាតក្នុងសន្ធិសញ្ញាពោលថា៖ "ការព្រមបែងចែកផលខ្លះក្នុងចំណែកដែលខ្លួនបេះបានហើយលើយកមក" សន្ធិសញ្ញានេះឲ្យឈ្មោះថា **ស្កន្ធោបនេយៈ** ។

១២៥- សន្ធិសញ្ញា ៤ ប្រការទៀតដែលបុគ្គលគួរដឹងគឺ **បរស្បរោបការៈ** (ការធ្វើឧបការៈទៅវិញទៅមក) ១, **មេត្រី** (ការចងស្ពានមេត្រី) ១, **សម្ពន្ធៈ** (ការទាក់ទងគ្នា) ១, **ឧបហារៈ** (ដង្វាយ) ១ ។

១២៦- មានតែ **ឧបហារសញ្ញា**មួយប៉ុណ្ណោះ ដែលខ្ញុំបាទយល់ថាគួរ កាលបើលើក**ឧបហារៈ**ចេញហើយ មេត្រីភាពក៏មិនមាន ។

១២៧- ធម្មតាសត្រូវដែលមានកម្លាំងសែនឡានុភាពច្រើន កាលបើមិនបានធ្វើសោះ ក៏មិនព្រមលើកទ័ពថយទៅវិញ ព្រោះហេតុនោះកាលបើវៀរលែង**ឧបហារៈ**ហើយ សន្ធិសញ្ញាដទៃទៀតមិនមានផ្លូវទេ ។

រាជហង្ស**ហិរណ្យគក៏**និយាយសរសើរថា៖ "លោកប្រធានរដ្ឋមន្ត្រី លោកជាមហាបណ្ឌិត ព្រោះហេតុនោះ ក្នុងវារៈនេះគួរលោកប្រាប់យើងនឹងចាត់ការយ៉ាងណាខ្លះ សូមលោកពន្យល់ឲ្យយើងស្ដាប់តទៅ" ។ ត្មាត**ទុរទសី**ឆ្លើយថា៖ "អ៊ំា! ហេតុអ្វីក៏លោកម្ចាស់ពោលដូច្នេះ?" ។

១២៨- បើក្នុងថ្ងៃនេះ ឬក៏ក្នុងថ្ងៃស្អែក សត្វនឹងត្រូវវិនាស ដោយក្ដីទុក្ខ និងជំងឺបៀតបៀន នរណាហ៊ានប្រព្រឹត្តធ្វើអំពើខុសចាកគន្លងធម៌ព្រោះតែរក្សារាងកាយ? ។

១២៩- មែនពិត, ជីវិតសត្វទាំងឡាយឃ្លេងឃ្លោងណាស់ ដូចជាការញាប់ញ័រនៃស្រមោលព្រះចន្ទក្នុងទឹក កាលបើដឹងថាជីវិតមានលក្ខណៈយ៉ាងនេះហើយ បុគ្គលគប្បីប្រព្រឹត្តកល្យាណធម៌ជានិច្ច ។

១៣០- ([១]) កាលបើបុគ្គលពិចារណាឃើញច្បាស់នូវសំសារវដ្តនេះថា បាក់បែកប្រេះឆាឆាប់ក្នុង

---

[១] ហិតោបទេសភាគីវៈ បុស្តកាលយៈ មានគាថាលើសដូច្នេះគឺភាពជាធំលើផែនដី (ស្ដេច) នេះរលត់រលាយទៅក្នុងមួយខណៈ ប្រៀបដូចពពកដែលខ្យល់ផាត់, ការបរិភោគកាមមានមធុរសតែមួយភ្លែត ប្រាណគឺជីវិតសត្វទាំងឡាយញាប់ញ័រឃ្លេងឃ្លោង ដូចដំណក់ទឹកនៅលើចុងស្មៅ ឯព្រះធម៌ទើបជាសំឡាញ់ដ៏ក្រៃលែង ព្រោះដឹកនាំសត្វទៅកាន់បរលោកនាយ ។

មួយខណៈ ប្រៀបដូចស្រមោលក្នុងទឹក គប្បីរកសេពគប់មួយអន្លើដោយសប្បុរសទាំងឡាយ ដើម្បីរកធម៌ផង ដើម្បីរកសេចក្ដីសុខផង ។

ព្រោះហេតុនោះឯង តាមសេចក្ដីយល់ឃើញខ្ញុំបាទថា គួរតែធ្វើយ៉ាងនេះឯង, ព្រោះថា៖

១៣១- ថាបើយកអស្វមេធៈមួយពាន់ដង និងសច្ចៈតែមួយមកឡើងកាន់ត្រាជូហើយថ្លឹងមើល សច្ចៈតែមួយនេះឯងមានទឹកទម្ងន់ធ្ងន់អនេកជាងអស្វមេធៈទាំងពាន់ដោយពិត ។

ព្រោះហេតុនោះ សូមឲ្យភូមិបាលទាំងពីរធ្វើសច្ចាបណិធានស្បថទុកខាងដើមនៅក្នុងនាមនៃសច្ចធម៌ ហើយធ្វើសន្ធិសញ្ញាសន្តិភាពឈ្មោះ **កាញ្ចនសច្ចៈ**នេះចុះ ។ **ចាក្រពាកសវិជ្ជៈ**ជាប្រធានរដ្ឋមន្ត្រីពោលថា៖ “ធ្វើយ៉ាងនេះត្រឹមត្រូវហើយ” ។ ក្នុងកាលនោះឯង, រាជហង្ស**ហិរណ្យគក៏**បូជាត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីដោយគ្រឿងប្រដាប់ទាំងឡាយមានសំពត់គ្រឿងអលង្ការដ៏ច្រើន ។ ឯត្មាត**ទុរទសី**បានគ្រឿងបណ្ណាការច្រើនហើយត្រេកអរសាទរក្រៃលែង ហើយអញ្ជើញ**ចាក្រពាកសវិជ្ជៈ**ជាប្រធានរដ្ឋមន្ត្រីទៅទីលំនៅនៃក្ងោក**ចិត្រពណ៌** ។ ស្ដេចក្ងោក**ចិត្រពណ៌**រៀបចំទទួល**ចាក្រពាកសវិជ្ជៈ**ជាប្រធានរដ្ឋមន្ត្រីដោយកិត្តិយសដ៏ក្រៃលែងតាមពាក្យត្មាត**ទុរទសី** ធ្វើសន្ធិសញ្ញាសន្តិភាព ហើយបូជា**ចាក្រពាក**ប្រធានរដ្ឋមន្ត្រីដោយវត្ថុមានតម្លៃផ្សេងៗ រួចស្រេចហើយទើបបញ្ជូនត្រឡប់ទៅកាន់សំណាក់រាជហង្ស**ហិរណ្យគក៏**វិញ ។ ត្មាត**ទុរទសី**ជាប្រធានរដ្ឋមន្ត្រីពោលដាស់តឿនតទៅទៀតថា៖ “ទេវៈ! សេចក្ដីប្រាថ្នាដែលយើងតាំងទុកហើយនោះ បានសមប្រកបសិទ្ធផលស្រេចបរិបូណ៌ហើយ គួរយើងយាត្រាទ័ពត្រឡប់ទៅកាន់វិន្ធ្យបព៌តទីឋានយើងវិញក្នុងកាលឥឡូវនេះឯង” ។ សព្វសត្វជាបរិវារទាំងឡាយ ក៏បានត្រឡប់កាន់ទីឋានផ្ទះសំបែងជួបមុខកូនប្រពន្ធញាតិមិត្តខ្លួនវិញ បានទទួលកិត្តិយសជាផលសមតាមចិត្តប្រាថ្នា សុខក្សេមក្សាន្តរៀងខ្លួនសព្វគ្នាទៅហោង ។

មហាបណ្ឌិត**វិស្ណុស៍ម៉ន**ក្រាបបង្គំទូលព្រះរាជាកុមារទាំងឡាយថា៖ “ទ្រង់! នៅសល់អ្វីដែលទូលបង្គំត្រូវថ្វាយទៀត, សូមទ្រង់ទាំងឡាយមានព្រះបន្ទូលមកចុះ?” ។ ព្រះរាជកុមារទាំងឡាយមានព្រះបន្ទូលត្រាស់តបថា៖ “បពិត្រលោកអាយ៌ៈ! ដោយករុណាធម៌ដ៏ខ្ពង់ខ្ពស់របស់លោក ទើបយើងខ្ញុំទាំងឡាយបានចេះដឹងអង្គការគ្រប់គ្រងរាជ្យគ្រប់ប្រការ អាស្រ័យគុណធម៌នេះ យើងខ្ញុំនឹងមានសេចក្ដីសុខសេចក្ដីចម្រើនច្រើនប្រការណាស់” ។ មហាបណ្ឌិត**វិស្ណុស៍ម៉ន**ថ្វាយសេចក្ដីបន្ថែមជាគ្រឿងបំពេញព្រះទ័យថា៖ “សេចក្ដីនេះពិតយ៉ាងនេះហើយ តែគួរបំពេញសេចក្ដីខាងចុងទីបំផុតថ្វាយទៀតថា៖

១៣២- សូមសន្តិភាពចូរមានដល់ព្រះរាជាទាំងពួងទាំងឡាយផង ដល់ព្រះរាជាទាំងឡាយដែលមានជ័យផង ហើយសូមឲ្យមានបីតិបាមោជ្ជរីករាយសប្បាយគ្រប់កាលទាំងពួង! សូមកិត្តិយសខ្ពង់ខ្ពស់

ចូរវឌ្ឍនាការចម្រើនដល់លោក ដែលប្រព្រឹត្តកុសលកម្មឲ្យបានស្ថិតស្ថេរចេរកាលវែងទៅ! សូមនីតិសាស្ត្រដែលទុកដូចជានាងវារវិលាសិនី ចូរស្ថិតជិតស្និទ្ធនៃបនិត្យឮដ៏ខរានៃមន្ត្រីទាំងឡាយ ហើយជុម្ពជប់នូវមាត់អស់កាលជានិច្ចនិរន្តតទៅ! សូមសេចក្តីសុខក្សេមក្សាន្តដ៏ធំក្រៃលែង ចូរមានដល់ប្រជាជនទាំងឡាយរាល់ទិនទិវារាត្រីគ្រប់កាលទៅហោង! ។

១៣៣- ([1]) ព្រះលក្ស្មី ជាបុត្រីនៃបព៌តហិមពាន្ត ជាសក្តិនៃព្រះនរាយណ៍ ជាមកុដនៃព្រះអាទិត្យ និងព្រះចន្ទ្រដែលជាអ្នកនាំលោក ជាអ្នកប្រទានផលធារាហូរចេញពីដួងចិត្ត គឺស្រះមានសៈដូចផ្ទេកបន្ទោរផ្សាយពន្លឺរស្មីភ្លឺផ្សៀលច្រវាត់ស្ថិតស្ថេរនៅដរាបណា សូមកថាសង្គ្រោះពោលគឺស្រីហិតោបទេសរបស់មហាបណ្ឌិត**នារាយណៈ** ដែលលោករចនាចងក្រងមកទុកដូចជាភ្នំមាស គឺភ្នំហិមាលយា ឬព្រះអាទិត្យ ដែលមានពន្លឺភ្លឺរុងរឿងសន្ធោសន្ធៅប្រាកដដូចជាពន្លឺភ្លើងប្រល័យលោកនេះ ផ្សាយចេញទូទៅពាសពេញសកលលោក ហើយស្ថិតស្ថេរចេរកាលនៅដរាបនោះ ។

១៣៤- កថាសង្គ្រោះនេះ គឺព្រះរាជាអង្គណាបានសូមឲ្យមហាបណ្ឌិតសរសេរចងក្រងទុកផ្សាយទូទៅដោយព្យាយាមដ៏ប្រពៃ សូមព្រះរាជាអង្គនោះដែលទុកដូចជាព្រះចន្ទ្រពេញវង់មានពន្លឺភ្លឺត្រចះ ដ៏មានសេរីកណ្តាលនភាល័យប្រទេស ឈ្នះអស់មារសត្រូវគ្រប់ប្រការទៅហោង! ។

កថាសង្គ្រោះទី ៤ ឈ្មោះសន្តិភាព ដែលមានក្នុងហិតោបទេសចប់តែប៉ុណ្ណេះ ។

ហិតោបទេស ចប់តែប៉ុណ្ណេះ ។

សូមសុភមង្គល ដ៏ច្រើនក្រៃលែងកើតមានដល់សព្វសត្វទាំងឡាយ! ។

---

វត្តឧណ្ណាលោមនៅថ្ងៃ ៧ ១១ ឆ្នាំថោះត្រីស័ក ព.ស. ២៤៩៤

ត្រូវនឹងថ្ងៃទី ៦ ខែតុលា គ.ស. ១៩៥១

សរសេរចប់នៅម៉ោង ១២ ខ្ទះ ១៥ នាទីពេលព្រឹក ។

---

[1] ហិតោបទេសភាគីវ: បុស្តកាលយ មានគាថាលើសដូច្នេះគឺ សូមព្រះឥន្ទ្រាធិរាជវាសវៈបង្អុរនូវភ្លៀងដែលសព្វសត្វប្រាថ្នាឲ្យត្រូវតាមកាល ដើម្បីឲ្យធញ្ញជាតិដុះលូតលាស់ បូរិបូណ៌ដេរដាសពាសពេញភូមិឋានឡើង សូមប្រមុខនៃព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតកវីប្រព្រឹត្តបំពេញព្រះទ័យទេពតាទាំងឡាយដោយគ្រឿងពលីទាំងឡាយ ទៅតាមយញ្ញពិធីសព្វៗកាល សូមសង្គមនៃសាធុជនទាំងឡាយ មូលមិត្តព្រមព្រៀងគ្នាកៀរគរប្រមែប្រមូលសេចក្តីសុខឲ្យកើតទូលំទូលាយត្រឡុងត្រឡាយឡើងរហូតដល់កល្បវសាន្ត សូមឲ្យភ្នំធំគឺទុរជនអាក្រក់សាមាន្យរឹងក្រៃលែង រងនូវស៊ីម៉ងត៍រឹង ហើយ គេផ្ចាញ់បានដោយកម្រនោះ ដល់នូវសេចក្តីហិនហោចខ្ទេចផ្សាសាបលាញសូន្យ អន្តរធានបាត់បង់ទៅ កុំឲ្យសល់ដល់ម្នាក់ឡើយ ។

## ជាទីរឭកការនៅចាំវស្សា ព.ស. ២៤៩៤
## សុភាសិតមិនចេះស្លាប់

| | | |
|---|---|---|
| កើតជាអង្គ | ពង្សជាមនុស្ស | ប្រុសឬស្រី |
| មានសម្តី | ថ្វីគំនិត | គិតគ្រប់ប្រាណ |
| ត្រូវប្រឹងរៀន | រៀនឲ្យចេះ | ចេះចំណាន |
| ទើបជាតិបាន | ឋានខ្ពង់ខ្ពស់ | យសថ្កុំថ្កើង ។ |